ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



# មូលដ្ឋានគ្រឹះភាសាវិទ្យា


រៀបរៀងដោយ
ឆាន់ គឹមសឿន


២០២១


CAMBODIA RESEARCH CREATIVITY INNOVATION

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# មូលដ្ឋានគ្រឹះភាសាវិទ្យា

រៀបរៀងដោយ
ឆាន់ គឹមសឿន

២០២១

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ**

**ដេប៉ាតឺម៉ង់ភាសាវិទ្យា**

**គណៈកម្មការនិពន្ធ**

លោក ឆាន់ គឹមសឿន

**គណៈកម្មការត្រួតពិនិត្យ**

លោក សំ អេងលាង

លោក វ៉ាន់ វី

លោក ហ៊ុន ឈុនតេង

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ជណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថល ដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផល ដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេស នៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០% នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេ នៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជាត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបន្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុង

ការផលិត ជ្រើសរើស បន្សាំ បង្កើត មុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំសង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែកទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្តគឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំគឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹង ក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់ នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាម៉េរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោកផងដែរ។ លក្ខណសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅ នៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាម៉េរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអាន

ដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ននេះ សិស្ស-និស្សិត និងសាធារណជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថល ដែលមានភាពសម្បូរបែប ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា។
2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវ តាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ។
3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន។
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន។
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាននិងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ។
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តន៍ឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាវូបនីយកម្ម ទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិ សម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់**ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបបន្ទាន់ចំពោះកង្វះខាតធនធានសិក្សាដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធសម្រាប់ឋានៈសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សា

រដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និង ថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# របស់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ គឺជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរ និងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

# អារម្ភកថា

សៀវភៅនេះ ត្រូវបានរៀបរៀងឡើង ក្រោមការឧបត្ថម្ភគាំទ្ររបស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍សម្រាប់ទុកជាសៀវភៅសិក្សាគោល ដើម្បីបម្រើឱ្យការរៀន និងបង្រៀនលើមុខវិជ្ជាភាសាវិទ្យាក្នុងដេប៉ាតឺម៉ង់ភាសាវិទ្យានៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សៀវភៅនេះផ្តល់ជូនអ្នកសិក្សាទាំងផ្នែកទ្រឹស្តីនិងអនុវត្តន៍ ដែលខ្លឹមសារគោលក្នុងសៀវភៅនេះ មានតាំងពីផ្នែកមីក្រូភាសាវិទ្យាដូចជា សញ្ញាណទូទៅនៃភាសានិងភាសាវិទ្យា សូរនិងប្រព័ន្ធសូរនៃភាសា (សូរវិទ្យានិងសទ្ទតាវិទ្យា) ការបង្កើតពាក្យនិងរូបសព្ទវិទ្យា សម្ព័ន្ធវិទ្យា ន័យវិទ្យា ការណ៍វិទ្យា រហូតដល់ផ្នែកម៉ាក្រូភាសាវិទ្យាខ្លះៗ ដូចជាសង្គមភាសាវិទ្យា ការប្រែប្រួលនៃភាសា (ភាសាវិទ្យាប្រវត្តិ) និងការចាប់យកភាសាទី១និងទី២ ដែលអាចសមល្មមឱ្យអ្នកសិក្សាភាសាវិទ្យាទាំងឡាយមានមូលដ្ឋានគ្រឹះរឹងមាំក្នុងការសិក្សាបន្ត ឬស្រាវជ្រាវបន្ថែម ឬក្នុងការប្រកបការងារផ្សេងៗក្នុងវិជ្ជាជីវៈរបស់ខ្លួន។ មិនតែប៉ុណ្ណោះ សៀវភៅនេះ ក៏អាចចាត់ទុកជាឯកសារពិគ្រោះសម្រាប់អ្នកស្នេហាវិស័យភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរផងដែរ។

បើយើងនិយាយអំពីវិស័យភាសាវិទ្យាវិញ យើងឃើញថា មុខវិជ្ជានេះទើបតែចាប់កំណើតនាអំឡុងសតវត្សទី១៩ ប៉ុណ្ណោះ។ អ្នកសិក្សាភាសាវិទ្យាបានដឹង ឬបានឮនូវវត្តមាននៃមុខវិជ្ជានេះតាមរយៈស្នាដៃដែលលេចឡើងដំបូងគេបង្អស់របស់លោក ហ្វេរឌីណង់ ដឺ សូស៊ៀរ ដែលកាលនោះ លោកបានប្រើទស្សនៈរូបវិទ្យាទម្រង់និយម ក្នុងការបកស្រាយនូវទ្រឹស្តីនិងការអនុវត្តជាក់ស្តែងនៅក្នុងភាសា។ អនុលោមតាមការវិវឌ្ឍនៃពិភពលោក ភាសាវិទ្យាក៏បានវិវឌ្ឍឥតឈប់ឈរ មានន័យថា ឆ្លងតាមរយៈទ្រឹស្តីភាសាវិទ្យារបស់ លោក សូស៊ៀរ គេសង្កេតឃើញថា មានភាសាវិទូក្រោយៗជាច្រើនរូបទៀតដែលលេចមុខជាមួយនឹងទ្រឹស្តីថ្មីៗរបស់ពួកគេ រួមចំណែកក្នុងការបកស្រាយនូវបាតុភូតភាសានៅលើលោក ទៅតាមទស្សនៈយោបល់និងទំនោររបស់ខ្លួនផងដែរ។

សម្រាប់បរិបទសង្គមខ្មែរយើងវិញ ចរន្តភាសាវិទ្យាគឺជាចរន្តថ្មីមួយ ដែលមជ្ឈដ្ឋានអ្នកសិក្សាភាគច្រើនមិនទាន់បានស្គាល់ជ្រៅជ្រះនៅឡើយ។ គេធ្លាប់ដឹងឮថា កាលណានិយាយពីបញ្ហាភាសា គេតែងតែនឹកដល់ការសិក្សាអំពីអក្សរសាស្ត្រ ឬវេយ្យាករណ៍ដែលមានលក្ខណៈជាប្រពៃណី ឬតូចចង្អៀត។ ប៉ុន្តែភាសាវិទ្យាពិតជាមានលក្ខណៈប្លែកទូលំទូលាយនិងមានមូលដ្ឋានទ្រឹស្តីវិទ្យាសាស្ត្រជាក់លាក់ណាស់។ ដោយសារមុខវិជ្ជានេះថ្មី និងមានប្រភពចេញពីប្រទេសលោកខាងលិច ទើបនៅក្នុងភាសាខ្មែរពុំទាន់សម្បូរបែបនូវស្នាដៃភាសាវិទ្យាជាភាសាខ្មែរ។ ដោយសម្លឹងឃើញភាពខ្វះចន្លោះនេះ ទើបយើងខ្ញុំខិតខំប្រមែប្រមូលឯកសារដែលជាភាសាខ្មែរនិងភាសាបរទេស មករៀបរៀងចងក្រងជាសៀវភៅស្តីពី «**មូលដ្ឋានគ្រឹះភាសាវិទ្យា**» នេះឡើង ក្នុងគោលបំណងជួយផ្សព្វផ្សាយនូវសារៈសំខាន់នៃមុខវិជ្ជានេះ។ តាមរយៈស្នាដៃនេះ យើងខ្ញុំមានក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោកអ្នកនឹងអាចដកស្រង់បាននូវចំណេះដឹងដែលមានសារៈសំខាន់សម្រាប់ខ្លួនអ្នក មិនថាតិច ឬច្រើន។

ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់ថា ស្នាដៃមួយនេះប្រាកដជា នឹងមានចំណុចខ្វះខាតនិងខុសឆ្គងដោយប្រការណាមួយជាក់ជាមិនខានឡើយ។ អាស្រ័យហេតុនេះ យើងខ្ញុំនឹងរង់ចាំនូវការទិតៀនស្ថាបនាពីសំណាក់អស់លោក លោកស្រីដោយសេចក្តីត្រេកអរជាអនេកប្បការ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ ឆាន់ គឹមសឿន ជាសាស្ត្រាចារ្យដេប៉ាតឺម៉ង់ភាសាវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាអ្នករៀបរៀងសៀវភៅសិក្សាដែលមានចំណងជើងថា «មូលដ្ឋានគ្រឹះភាសាវិទ្យា»។ ខ្ញុំបាទសូមសម្តែងនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តល់ថវិកាមកក្រសួងអប់រំ ដើម្បីបង្កើតជាមូលនិធិសម្រាប់គាំទ្រដល់ការសរសេរសៀវភៅសិក្សាសម្រាប់កម្រិតឧត្តមសិក្សារបស់ខ្ញុំបាទនេះ។

- ក្រសួងអប់រំ យុវជន និងកីឡា ដែលមាន ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ជាប្រមុខ ដែលលោកបានដឹកនាំបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ឡើង ដើម្បីគាំទ្រទាំងស្រុងដល់ដំណើរការសរសេរសៀវភៅនេះ ដែលជាចំណែកមួយក្នុងបេសកកម្មកំណែទម្រង់វិស័យអប់រំឧត្តមសិក្សារបស់លោក។

- ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលក្នុងនាមលោកជាតំណាងមូលនិធិ លោកបានយកអស់កម្លាំងកាយចិត្ត ជួយចាត់ចែងនិងជ្រោមជ្រែងយ៉ាងពេញទំហឹង ព្រមទាំងផ្តល់ជាអនុសាសន៍និងដំណោះស្រាយនានា ដើម្បីជម្នះនូវរាល់ឧបសគ្គដែលកើតមានក្នុងដំណើរការសរសេរសៀវភៅនេះ។

- ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានយកអស់កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មមាញឹកនិងមានតម្លៃរបស់លោក ក្នុងការជួយលើកទឹកចិត្ត ជួយខ្នះខ្នែងដោះស្រាយ និងផ្តល់អនុសាសន៍ដ៏ត្រឹមត្រូវ ក៏ដូចជាបង្កលក្ខណៈងាយស្រួលនានា ទាំងផ្នែករដ្ឋបាល និងទាំងផ្នែកបច្ចេកទេស ដើម្បីឱ្យដំណើរការរៀបរៀងសៀវភៅនេះ បានប្រព្រឹត្តទៅដោយរលូនរហូតចប់ចុងចប់ដើម។

- លោក លួន ពេជ្របូរី និង អស់លោក-លោកស្រី ជាក្រុមការងារសម្របសម្រួលទាំងអស់របស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានយកអស់កម្លាំងកាយចិត្ត ជួយឈឺឆ្អាលក្នុងការដោះស្រាយបញ្ហាប្រឈមនានាយ៉ាងសស្រាក់សស្រាំជាទីបំផុត ដោយមិនត្អូញត្អែរ និងមិនខ្លាចនឿយហត់ ដើម្បីឱ្យការសរសេរសៀវភៅនេះប្រព្រឹត្តទៅដោយរលូន។

- ឯកឧត្តមបណ្ឌិត ស្រ៊ីវ ថារិទ្ធ អ្នកសម្របសម្រួលសាលាក្រោយឧត្តម និង លោកបណ្ឌិត សុខ សិរី អនុប្រធានការិយាល័យស្រាវជ្រាវ ដែលតែងជួយឈឺឆ្អាល ជួយសម្របសម្រួល និងផ្តល់សេវាសម្រាប់ការប្រជុំបច្ចេកទេសនានាតាមអនឡាញតាំងពីដើមរៀងមក។

- អស់លោក-លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មការអភិវឌ្ឍសៀវភៅសិក្សា ក៏ដូចជាគណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្តល់ជាតុចូលដល់សៀវភៅនេះឱ្យកាន់តែមានគុណភាពប្រសើរថែមទៀត។

- ជាចុងក្រោយ និងជាពិសេស លោក ធូ រេណូ ប្រធានការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលតែងជួយផ្តល់ជាតុចូលចំពោះរាល់ឯកសារការងារ ទាំងផ្នែករដ្ឋបាលនិងទាំងផ្នែកបច្ចេកទេស លោកថែមទាំង ជួយសម្រួលរាល់បញ្ហាប្រឈមនានាយ៉ាងជិតដល់បំផុត ដោយមិនប្រកាន់ពេលវេលា និងដោយចិត្តជ្រះថ្លា ហេតុការសរសេរសៀវភៅនេះទទួលបានជោគជ័យជាស្ថាពរ។

# មាតិកា


**បុព្វកថា** i

**សេចក្តីបញ្ជាក់** vi

**អារម្ភកថា** vii

**សេចក្តីថ្លែងអំណរគុណ** viii

**មេរៀនទី១ សញ្ញាណទូទៅនៃភាសានិងភាសាវិទ្យា**

១. ភាសា ១

១.១. និយមន័យ ១

១.២. ប្រភពកំណើតនៃភាសា ៤

១.៣. ភាសាមនុស្សនិងទំនាក់ទំនងរបស់សត្វ ៧

១.៤. ប្រវត្តិនិងបណ្តូរទំនាក់ទំនងនៃភាសា ៨

១.៥. បែបនៃភាសាតាមការប្រើប្រាស់ ១១

១.៦. ប្រភេទនៃភាសាតាមភាសាវិទ្យា ១៣

១.៧. មុខងារនៃភាសា ១៥

២. ភាសាវិទ្យា ១៦

២.១. និយមន័យ ១៦

២.២. ប្រវត្តិភាសាវិទ្យា ១៧

២.៣. ភាសាវិទូ ២៩

២.៤. មែកធាងភាសាវិទ្យា ៣២

២.៥. ការងារក្នុងវិស័យភាសាវិទ្យា ៣៣

**មេរៀនទី២ ប្រព័ន្ធសំណេរ**

១. សំណេរនិងការនិយាយ ៣៦

២. ប្រភេទនៃប្រព័ន្ធសំណេរ ៣៦

២.១. អក្សររូបភាពឬអក្សរគំនូរ ៣៦

២.២. អក្សរគំនិត ៣៧

២.៣. អក្សរព្យាង្គ ៣៧

២.៤. អក្សរសូរសំឡេងឬសំណេរអក្ខរក្រម ៣៨

៣. អក្សរខ្មែរនិងអក្ខរាវិរុទ្ធនៃភាសាខ្មែរ ៤០

៣.១. អក្សរខ្មែរ ៤០

៣.២. អក្ខរាវិរុទ្ធនៃភាសាខ្មែរ ៤៣

**មេរៀនទី៣ សូរនិងប្រព័ន្ធសូរនៃភាសា**

១. សូរនៃភាសា ៤៦

១.១. និយមន័យសូរវិទ្យា ៤៧

១.២. សូរវិទ្យាអាគូស្ទិក ៤៨

១.៣. សូរវិទ្យាបន្លឺ ៥០

២. ប្រព័ន្ធសូរនៃភាសា ៦៥

២.១. និយមន័យសទ្ទតាវិទ្យា ៦៦
២.២. សទ្ទតា ៦៦
២.៣. សូរនិងកាឡាសូរ ៦៧
២.៤. គូអប្បបរិមាណ ៦៨
២.៥. សទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈក្នុងភាសាខ្មែរ ៦៨
២.៦. សទ្ទតាវិទ្យាស៊ុបប្រាសិចម៉ង់និងវិធានសទ្ទតាវិទ្យា ៧៣
២.៧. ព្យាង្គ ៧៦
**មេរៀនទី៤ ការបង្កើតពាក្យនិងរូបសព្ទវិទ្យា**
១. ការបង្កើតពាក្យ ៨២
១.១. និយមន័យ ៨២
១.២. វិធីបង្កើតពាក្យ ៨២
២. រូបសព្ទវិទ្យា ៨៨
២.១. និយមន័យ ៨៨
២.២. រូបសព្ទ ៨៨
២.៣. កាឡារូប ៩៨
២.៤. ក្បួនរូបសព្ទវិទ្យា ៩៩
២.៥. រចនាសម្ព័ន្ធពាក្យ ១០៣
**មេរៀនទី៥ សម្ព័ន្ធវិទ្យា**
១. និយមន័យ ១០៨
២. ប្រវត្តិនៃការសិក្សាសម្ព័ន្ធវិទ្យា ១០៨
៣. និមិត្តសញ្ញាក្នុងសម្ព័ន្ធវិទ្យា ១០៩
៤. ទិដ្ឋភាពនៃសម្ព័ន្ធវិទ្យា ១០៩
៥. ក្បួនរចនាសម្ព័ន្ធនៃកន្សោមពាក្យ ១១១
៥.១. ប្រវត្តិនៃក្បួនរចនាសម្ព័ន្ធនៃកន្សោមពាក្យ ១១១
៥.២. ប្រភេទកន្សោមពាក្យ ១១២
៦. ឈ្នះ ១១៣
៦.១. និយមន័យឈ្នះ ១១៣
៦.២. រចនាសម្ព័ន្ធឈ្នះ ១១៤
៦.៣. ប្រភេទឈ្នះ ១១៩
**មេរៀនទី៦ ន័យវិទ្យានិងការណ៍វិទ្យា**
១. ន័យវិទ្យា ១២១
១.១. និយមន័យ ១២២
១.២. លក្ខណៈវិនិច្ឆយន័យវិទ្យា ១២៣
១.៣. ទិដ្ឋភាពនៃការសិក្សាន័យវិទ្យា ១២៥
១.៤. ទំនាក់ទំនងន័យវចនៈ ១២៧
២. ការណ៍វិទ្យា ១៣៥

២.១. និយមន័យ ១៣៦
២.២. បរិបទ ១៣៦
២.៣. យោបោង ១៣៨
២.៤. ទង្វើសម្តី ១៤១
២.៥. ភាពគួរសម ១៤២
៣. ភាពខុសគ្នារវាងន័យវិទ្យានិងការណ៍វិទ្យា ១៤៣
**មេរៀនទី៧ ការប្រែប្រួលនៃភាសា**
១. អម្បូរភាសា ១៤៥
១.១. អម្បូរភាសាឥណ្ឌូ-អឺរ៉ុប ១៤៦
១.២. អម្បូរភាសាអូស្ត្រូអាស៊ី ១៥០
២. លក្ខណៈនៃបម្រែបម្រួលភាសា ១៥៥
២.១. ភាពជាប្រព័ន្ធនៃបម្រែបម្រួលភាសា ១៥៥
២.២. មូលហេតុនៃបន្លាស់ប្តូរភាសា ១៥៦
២.៣. ភាពទៀងទាត់នៃបម្រែបម្រួលសូរសំឡេង ១៥៦
២.៤. ការឆ្លើយតបនៃសូរសំឡេង ១៥៦
៣. បម្រែបម្រួលខាងសូរសំឡេង ១៥៦
៣.១. បម្រែបម្រួលសូរស្រៈ ១៥៧
៣.២. បម្រែបម្រួលព្យញ្ជនៈ ១៥៧
៣.៣. វិធីសង្កត់សំឡេង ១៦០
៤. បម្រែបម្រួលខាងរូបសព្ទនិងវចនសព្ទ ១៦២
៤.១. បម្រែបម្រួលខាងរូបសព្ទ ១៦២
៤.២. បម្រែបម្រួលខាងវចនសព្ទ ១៦២
៥. បម្រែបម្រួលខាងសម្ព័ន្ធ ១៦២
៦. បម្រែបម្រួលខាងន័យ ១៦៤
**មេរៀនទី៨ សង្គមភាសាវិទ្យា**
១. កំណកំណើតនៃសង្គមភាសាវិទ្យា ១៦៧
១.១. ប្រវត្តិនៃសង្គមភាសាវិទ្យា ១៦៩
១.២. និយមន័យសង្គមភាសាវិទ្យា ១៧៣
២. គ្រឹះទ្រឹស្តីនៃសង្គមភាសាវិទ្យា ១៧៣
២.១. និន្នាការនិងកិច្ចការស្រាវជ្រាវនៃសង្គមភាសាវិទ្យា ១៧៣
២.២. ទ្រឹស្តីលោក វិលីយាម ឡាបូវ ១៧៣
២.៣. ទ្រឹស្តីរយៈគ្រឹះរបស់លោក ហ្សង់ ហ្គាញើបាំង ១៧៤
៣. ការស្វែងយល់ពីបញ្ញត្តិមួយចំនួនតាមរយៈគ្រឹះទ្រឹស្តី ១៧៥
៣.១. សំនួនវត្តមានវិស័យនិងសំនួនអវត្តមានវិស័យ ១៧៥
៣.២. សណ្ឋានភាសានិងកម្រិតភាសា ១៧៦
៤. យោបាយល្បាយ ១៧៦

៤.១. សាប៉ៀរ ១៧៦
៤.២. ពិតឈីន ១៧៦
៤.៣. ក្រេអូល ១៧៩
៥. ការអនុវត្តទ្រឹស្តីតាមទិសទាំងបីនៃរយៈគ្រឹះ ១៨០
៥.១. កាលយោបាយ ១៨០
៥.២. វណ្ណយោបាយ ១៨១
៥.៣. ទេសយោបាយ ១៨២
**មេរៀនទី៩ ការចាប់យកភាសា**
១. ការចាប់យកភាសាទី១ ១៨៤
១.១. ការចាប់យកនិងជាតុចូល ១៨៤
១.២. ដំណាក់កាលនៃការចាប់យកភាសា ១៩១
១.៣. ដំណើរការនៃការចាប់យកភាសា ១៩៣
១.៤. ការអភិវឌ្ឍផ្នែករូបសព្ទវិទ្យា ១៩៤
១.៥. ការអភិវឌ្ឍផ្នែកសម្ព័ន្ធវិទ្យា ១៩៥
១.៦. ការអភិវឌ្ឍផ្នែកន័យវិទ្យា ១៩៨
២. ការចាប់យកភាសាទី២ ១៩៩
២.១. ការចាប់យកភាសាទី២តាមធម្មជាតិ ១៩៩
២.២. ការចាប់យកភាសាទី២តាមការរៀន ១៩៩
២.៣. ការផ្ដោតលើវិធីសាស្រ្ត ២០២
២.៤. ការផ្ដោតលើអ្នករៀន ២០៣
២.៥. សមត្ថភាពបណ្ដូរទំនាក់ទំនងនៃភាសា ២០៦
៣. ភាពផ្សេងគ្នារវាងការអានរបស់អ្នកសិក្សាភាសាទី១និងភាសាទី២ ២០៧
៣.១. ភាសានិងដំណើរការផ្សេងៗគ្នា ២០៧
៣.២. ភាពខុសគ្នារវាងកត្តាបុគ្គលនិងបទពិសោធនៃអ្នកអានភាសាទី១និងអ្នកអានភាសាទី២ ២០៩
៣.៣. ភាពខុសគ្នារវាងកត្តាសង្គមវប្បធម៌និងស្ថាប័នផ្សេងៗដែលជះឥទ្ធិពលលើការអភិវឌ្ឍ
ការអានរបស់ភាសាទី១និងភាសាទី២ ២០៩
**សេចក្តីសន្និដ្ឋានសៀវភៅ** ២១២
**ឯកសារពិគ្រោះ** ២១៣

# មេរៀនទី១
# សញ្ញាណទូទៅនៃភាសានិងភាសាវិទ្យា

## ១. ភាសា

### ១.១. និយមន័យ

តាមធម្មជាតិនៃភាសា រហូតមកដល់សព្វថ្ងៃនេះ គេមិនទាន់ឱ្យនិយមន័យច្បាស់លះទៅលើភាសាឡើយ។ និយមន័យទាំងឡាយទៅលើភាសាដែលយើងធ្លាប់ដឹងឮពីពេលមុនមក ហើយគ្រាន់តែជាផ្នែកមួយនៃធម្មជាតិភាសាប៉ុណ្ណោះ។ ឧទាហរណ៍អ្វីដែលគេចូលចិត្តនិយាយថា «ភាសាជាមធ្យោបាយសំខាន់សម្រាប់បម្រើក្នុងទំនាក់ទំនងរបស់មនុស្សក្នុងសហគមន៍មួយ» នេះគ្រាន់តែជាការឱ្យន័យមួយទៅលើភាសាដែលទាក់ទងនឹងមុខងារ ឬតួនាទីរបស់ភាសាប៉ុណ្ណោះ ព្រោះភាសាបម្រើដល់ការទាក់ទងគ្នារវាងមនុស្សក្នុងសហគមន៍។ ន័យមួយទៀតថា «ភាសាជាប្រព័ន្ធនៃសញ្ញា (ក្នុងនោះមានសូរនិងសំណេរ) » នេះគ្រាន់តែជាន័យមួយដែលទាក់ទងនឹងសញ្ញាវិទ្យាប៉ុណ្ណោះ។ ការលើកឡើងមួយទៀតដែលថា «ភាសាជាសមិទ្ធិផលនៃសង្គម» នេះគ្រាន់តែជាការបង្ហាញថា ភាសាកើតមានទៅបានតែនៅក្នុងសង្គមមនុស្ស ភាសាមិនអាចស្ថិតនៅក្រៅសង្គមបានឡើយ។ ការលើកឡើងមួយទៀតថា «ភាសាគឺជាកូដ» បានន័យថា ក្នុងការប្រាស្រ័យទាក់ទងគ្នា មនុស្សអាចយល់គ្នាបាន លុះត្រាតែមនុស្សទាំងនោះស្គាល់កូដនៃភាសានោះដូចគ្នា។ ការឱ្យន័យទៅលើភាសាបែបនេះ ទាក់ទងទៅនឹងព័ត៌មានវិទ្យាប៉ុណ្ណោះ។ ន័យមួយទៀតដែលគេឱ្យទៅលើភាសាគឺ «ភាសាជាប្រព័ន្ធទំនាក់ទំនងតាមលំដាប់ឋានានុក្រមរវាងឯកតាទាំងឡាយរបស់ភាសា» (ចាប់ពីសទ្ទតារហូតដល់អត្ថបទ)។ ន័យនេះទាក់ទងតែទៅនឹងអ្វីដែលចាត់ទុកភាសាថា «ភាសាជាការកកើតឡើងដោយសារទំនាក់ទំនងនៃប្រព័ន្ធនិងរចនាសម្ព័ន្ធ» (នៅ ស៊ុន, ២០១០: ១)។



ប្រភព៖ https://www.salesforce.com

ភាសា (ន.) សម្ដី, ពាក្យ: ភាសាសំស្ក្រឹត, ភាសាបាលី, ភាសាជាតិ, ភាសាបរទេស។ល។ (វចនានុក្រមខ្មែរ, ១៩៦៧: ៨២០)។

ភាសា ជាការសម្ដែងចិត្តគំនិតគ្រប់យ៉ាង។ មាន់ឈ្មោលកាលបើរីករាយសប្បាយចិត្ត វារងាវ មាន់ញីកាលវាឈឺពង វាអត កាលវាពងរួច វាខ្កត ឆ្កែបក់កន្ទុយដើម្បីសម្ដែងសេចក្ដីគោរព។ សរុបរួមតូចមក ភាសាត្រឹមតែជាការសម្ដែងចិត្តគំនិតដោយពាក្យសម្ដី (អៀវ កើស, ១៩៩៥:៧)។

ភាសា តាមមតិសាធារណទូទៅ ភាសាជាពាក្យសម្ដី ដែលមនុស្សនិយាយស្ដី ដើម្បីទាក់ទងគ្នា។ ដោយគេច្រើនតែច្រឡំភាសានិងអក្ខរាវិរុទ្ធរបស់ភាសា ភាសាវិទូឈ្មោះ ហ្វេរឌី ណង់ ដឺ សូសៀរ (Ferdinand de Saussure) បានរំលឹកថា «ភាសាជាសូរ គឺមិនមែនជាសំណេរទេ»។ លោក អង់ដ្រេ ម៉ាទីណេ (André Martinet) បានបន្ថែមថា ភាសា (របស់មនុស្ស) មានសន្ធិយោគពីរជាន់៖ ជាន់ទី១ មានមូលស័ព្ទ ជាន់ទី២ មានសទ្ទតា ក្នុងន័យថា ខ្សែសម្ដីអាចវិភាគចេញដំបូងជាមូលស័ព្ទឬធាតុតូចបំផុតដែលមានន័យសម្គាល់អ្វីៗបាន រួចតទៅទៀតចេញជាសទ្ទតា [1] ដែលជាឯកតាសូរសុទ្ធសាធឈប់មានន័យអ្វីទាំងអស់ (ព្រុំ ម៉ល់, ២០០៦: ១)។

---

[1] សទ្ទតាជាសូរដែលធ្វើឱ្យមានពាក្យពីរ (យ៉ាងតិច) ប្លែកគ្នាក្នុងបរិបទតែមួយ។

តាមសង្គមភាសាវិទ្យា ភាសាជាប្រព័ន្ធ២ប្រការ ដែលចិញ្ចឹមគ្នាទៅវិញទៅមក មានប្រព័ន្ធវេយ្យាករណ៍ (ឬ ប្រព័ន្ធយន្តការ) នៅក្នុងប្រព័ន្ធវេយ្យាករណ៍នេះមានដូចជា សទ្ទតាវិទ្យា វចនវិទ្យា និងសម្ព័ន្ធវិទ្យា និងប្រព័ន្ធទម្លាប់វាចា (ឬ ប្រព័ន្ធនៃផលប្រើប្រាស់ភាសា) ដែលចែកជាប្រព័ន្ធតូចៗតទៅទៀតដូចជា សូរវិទ្យា វាក្យវិទ្យា និងល្បះវិទ្យា (ព្រុំ ម៉ល់, ២០០៣: ១៣)។

- ភាសា
  - វេយ្យាករណ៍
    - សទ្ទតាវិទ្យា
    - វចនវិទ្យា
    - សម្ព័ន្ធវិទ្យា
    - → ន័យកម្មវិទ្យា
  - ទម្លាប់វាចា
    - សូរវិទ្យា
    - វាក្យ(ស័ព្ទ)វិទ្យា
    - ល្បះវិទ្យា
    - → ន័យវិទ្យា

ភាសា ជាបាតុភូតសង្គមពិសេស។ ភាសាកើតឡើងហើយប្រែប្រួលដោយសារតម្រូវការ និងការចាំបាច់របស់សង្គម។ វាប្រែប្រួលផ្លាស់ប្តូរទៅតាមច្បាប់ពិតរបស់ខ្លួន ពុំមែនទៅតាមស្ថាប័នណាមួយឡើយ។ ភាសាជាមធ្យោបាយនៃបណ្តូរទំនាក់ទំនងសំខាន់ជាងគេបំផុតរបស់មនុស្ស។ ក្រៅពីភាសា មនុស្សមានមធ្យោបាយបណ្តូរទំនាក់ទំនងផ្សេងៗទៀត ដូចជា កាយវិការ លំញាក់ សិល្បៈជាដើម។ កាយវិការនិងលំញាក់ គឺជាមធ្យោបាយខ្សត់ខ្សោយ មិនជាក់លាក់ ហើយមិនអាចសម្តែងសញ្ញាណអរូបីបានទេ។ ចំណែកឯ សិល្បៈ (គ្មានសម្តី) ដូចជា ភ្លេង គំនូរ របាំជាដើម គឺជាមធ្យោបាយដែលសម្តែងមនោសញ្ចេតនារំភើប ហើយក៏ពុំអាចបញ្ជាក់ឱ្យបានច្បាស់លាស់ដែរ (ក្រសួងអប់រំ, ១៩៨៦: ៩)។

ភាសា គឺជាពាក្យសម្តីដែលមនុស្សនិយាយចេញជាសំឡេងចេញមកក្រៅ ឬថា ភាសា គឺជាឧបករណ៍មួយយ៉ាងដែលមនុស្សប្រើជាមធ្យោបាយដើម្បីលាតត្រដាងនូវមនោសញ្ចេតនា គំនិត សតិអារម្មណ៍...ក្នុងការទាក់ទងរាប់អានគ្នាឱ្យយល់គ្នាបានទៅវិញទៅមកដោយសម្តី។ បើយើងនិយាយមួយបែបទៀតថាភាសា គឺជាបាតុភូតនៃសង្គមមនុស្ស។ ភាសា កើតឡើងអំពីសេចក្តីត្រូវការរបស់មនុស្ស ដែលរស់នៅក្នុងសង្គមខាងការបង្ហាញសតិអារម្មណ៍ គំនិតស្មារតី...ឱ្យគ្នាទៅវិញទៅមកក្នុងដំណើរចលនាធ្វើពលកម្មដើម្បីបម្រើជីវិត (ហ៊ុន គឹមសៀ, ១៩៦៣: ១)។

ភាសា គឺជាប្រព័ន្ធសំឡេងរបស់មនុស្សដែលមានចម្បាស់ភាព ហើយនិងចារឹកនៅក្នុងក្បួនមួយកំណត់ច្បាស់លាស់ដែលគេហៅថាវេយ្យាករណ៍។ ផ្អែកលើមុខងាររបស់វា គេអាចឱ្យនិយមន័យថា ភាសាជាប្រព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នាដែលមានលក្ខណៈជាសង្គម។ ភាសាជាធាតុចាំបាច់សម្រាប់សង្គមមនុស្ស។ គ្មានសង្គមណាមួយដែលគ្មានភាសានោះទេ។ ភាសានាំឱ្យមនុស្សរួបរួមគ្នាជាក្រុម ជាសហគមន៍ ជាសង្គម ជាជាតិមួយ។ ប៉ុន្តែព្រមពេលជាមួយគ្នានោះ ភាសាដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងដើមកំណើតនិងជាតិពន្ធុរបស់មនុស្ស បានបណ្តាលឱ្យមានការបែងចែកជាជាតិសាសន៍ផ្សេងៗគ្នា។ អន្តរកម្មនេះអាចឱ្យយើងសន្និដ្ឋានបានថា ភាសាជាកត្តាបង្រួបបង្រួមផងនិងជាកត្តាបំបែកបំបាក់ផង។ តែទោះជាយ៉ាងណាក៏ដោយ ក៏យើងអាចចាត់ទុកថា ភាសាជាអាវុធសន្តិភាពដែលអាចផ្តល់ផលវិជ្ជមានឬអវិជ្ជមាន ពោលគឺអាស្រ័យដោយការប្រើប្រាស់របស់មនុស្ស។ ដោយសារមនុស្សមានជីវិត ភាសាក៏មានជីវិតដែរ។ វាមានអត្ថិភាពទៅបានក៏ដោយសារតែមនុស្សដែលមិនត្រឹមតែប្រើវាដើម្បីទាក់ទងគ្នាប៉ុណ្ណោះទេ តែថែមទាំងបានកត់ត្រាវាតាមរយៈអក្សរទៀតផង។ ប្រការនេះបានផ្តល់នូវទម្រង់ដល់ភាសាដែលគេអាចបំបែកជាឯកតា ហើយដែលគេហៅថាពាក្យ (ច័ន្ទ សំណព្វ, ២០១០: ១)។

ពាក្យថា ភាសា ជាពាក្យបាលីនិងសំស្ក្រឹត មកពីពាក្យដើមថា ភាស-ធាតុ ប្រែថា ពោល និយាយឬប្រាប់។ កាលយកមកប្រើជានាមសព្ទ មានរូបជា ភាសា ប្រែតាមរូបសព្ទថា សម្ដីឬពាក្យ ប្រែយកន័យថា ឧបករណ៍សម្រាប់បំភ្លឺអត្ថន័យ ក្នុងកិច្ចការទាក់ទងនៃសង្គមមនុស្ស ដើម្បីអាចកំណត់ដឹងអំពីកម្មវត្ថុរវាងគ្នានិងគ្នាបាន ដោយក្នុងនោះរួមមាន សទ្ទតា ពាក្យ ប្រយោគ ជាដើម (សួន ឱសថ,២០១៣:៣៧)។

សរុបមក យើងឃើញថា និយមន័យនៃភាសាមានច្រើនយ៉ាងដោយយោងទៅតាមការឱ្យន័យប្លែកៗគ្នាទៅតាមភាសាវិទូនិងអ្នកសិក្សាស្រាវជ្រាវផ្សេងៗ។

**អ្វីជាសម្ដី?**

តាមបែបភាសាវិទ្យា សម្ដីមានន័យថាជាបាតុភូតរូបសាស្ត្រដែលមានលក្ខណៈរូបី ហើយមានការប្រែប្រួលទៅតាមឆន្ទៈមនុស្សឬតាមលក្ខណៈរូបសាស្ត្ររបស់មនុស្ស។ សម្ដីត្រូវការអ្នកនិយាយប្រាប់ (អ្នកបកស្រាយ) អ្នកស្ដាប់ (អ្នកទទួល) និងកម្មវត្ថុសម្រាប់និយាយ។ ការនិយាយក្នុងចិត្ត (និយាយក្នុងពោះ) និងការចារឹកជាអក្សរ (ឯកសារសរសេរ) ក៏ត្រូវបានគេចាត់ទុកថាជា «សម្ដី» ដែរ។ សម្ដីគឺជាដំណើរការនៃការនិយាយ (សកម្មភាពសម្ដី) និងជាលទ្ធផលនៃការនិយាយ (សមិទ្ធិផលសម្ដីដែលក្នុងនោះមានការកត់ត្រាក្នុងលំនឹក) និងក្នុងសំណេរ។

ជាធម្មតា គេតែងតែកំណត់ចរិតលក្ខណៈរបស់សម្ដីឱ្យមានភាពខុសប្លែកពីចរិតលក្ខណៈរបស់ភាសាដែលជាកូដ ហើយមានលក្ខណៈជាសង្គម ជាក្រឹត្យក្រមមួយជាកំណត់ ជាប្រព័ន្ធនៃវិធានទាំងឡាយសម្រាប់ការប្រើប្រាស់ និងការផ្ដុំសូរភាសា។ សម្ដីនិងភាសាបង្កើតបានជាបាតុភូតរួមរបស់ភាសាមនុស្សនិងភាសាណាមួយជាកំណត់ និងនៅក្នុងបរិបទនៃភាសានោះ។

**ភាពប្លែកគ្នានិងភាពបំពេញគ្នារវាងសម្ដីនិងភាសា**

សម្ដី គឺជាបុគ្គលកម្មនិងជាសមិទ្ធិផលរបស់ភាសាដែលមានវត្តមានក្នុងសម្ដី ហើយតាមរយៈសម្ដីតែប៉ុណ្ណោះដែលភាសាអាចបំពេញមុខងារជាមធ្យោបាយសំខាន់សម្រាប់បម្រើការទាក់ទង។ ប្រសិនបើភាសាជាមធ្យោបាយ ឬជាឧបករណ៍សម្រាប់បម្រើការទាក់ទង នោះសម្ដីគ្រាន់តែជាទិដ្ឋភាពនៃទំនាក់ទំនងនោះ ហើយកើតចេញមកពីមធ្យោបាយសម្រាប់ទំនាក់ទំនងនោះ។ សម្ដីនាំភាសាចូលទៅក្នុងបរិបទនៃការប្រើប្រាស់ បានន័យថា សម្ដីយកធាតុទាំងឡាយរបស់ភាសាទៅប្រើប្រាស់ក្នុងសកម្មភាពសម្ដី។ សម្ដីមានលក្ខណៈរូបីនិងគ្មានភាពច្រំដែល ដែលផ្ទុយពីភាសាដែលមានលក្ខណៈអរូបីនិងអាចបង្កើតអ្វីថ្មីបាន។ សម្ដីមានមានលក្ខណៈជាក់ស្ដែង ចំណែកឯភាសាមានលក្ខណៈជាសក្ដានុភូត (មិនឃើញជាក់ស្ដែង)។ សម្ដីមានលក្ខណៈជាសម្ភារៈ ដោយសារតែសម្ដីកើតចេញពីសញ្ញានៃការបន្លឺដែលគេអាចទទួលបានដោយវិញ្ញាណ (គេអាចទទួលបានដោយត្រចៀក ភ្នែក និងកាយ ជាដើម)។ ចំណែកប្រព័ន្ធភាសាបញ្ចូលខ្លួនវានូវឯកតាទាំងឡាយ ដូចគ្នានឹងឯកតាសម្ដី តែក្នុងលក្ខណៈអរូបី។ សម្ដីស្ដែងឱ្យឃើញនូវបទពិសោធរបស់ឯកត្តបុគ្គល ចំណែកភាសាវិញ ក្នុងប្រព័ន្ធនៃការបង្ហាញន័យកំណត់បទពិសោធរបស់សមូហភាព និងបង្ហាញពីរូបភាពរបស់ជនជាតិដែលនិយាយភាសានោះ (នៅ ស៊ុន, ២០១០:២)។



### ១.២. ប្រភពកំណើតនៃភាសា

តាមទស្សនៈរបស់លោក ឆាល ដារីន (Charles Darwin) អំពីដើមកំណើតភាសា លោកបានលើកឡើងថា ដំបូងមនុស្សបានអភិវឌ្ឍសមត្ថភាពនៃតន្ត្រីរួចទៅហើយមុនពេលប្រើភាសា ហើយបានប្រើវាដើម្បីបង្ហាញពីសេចក្ដីស្រលាញ់ជាមួយគ្នាទៅវិញទៅមក។

ភាសាជាមធ្យោបាយមួយក្នុងចំណោមមធ្យោយទាំងឡាយរបស់មនុស្សសម្រាប់ធ្វើការទំនាក់ទំនងគ្នាក្នុងន័យស្តែងចេញពីអារម្មណ៍ មនោសញ្ចេតនា ការឈឺចាប់ សប្បាយរីករាយ កំហឹង សេចក្តីស្រឡាញ់។ ភាសាចែកចេញជាបីប្រភេទ គឺភាសានិយាយ ភាសាសរសេរ និងភាសាសញ្ញា។ យើងអាចសន្និដ្ឋានបានថា ភាសានិយាយបានវិវត្តប្រមាណជា ១០០០០០ ឬ៥០០០០ ឆ្នាំមុនមកម្ល៉េះ រីឯភាសាសរសេរវិញ វិវត្តប្រមាណជា៥០០០ឆ្នាំមកហើយ។ ចំពោះប្រភពកំណើតភាសាអាចមានប្រភពច្រើនផ្សេងៗគ្នាតាមទ្រឹស្តីភាសាវិទូនីមួយៗ។

#### ១.២.១. កត្តាសាសនា

នៅក្នុងគម្ពីរសាសនាគ្រិស្តដែលបានកត់ត្រាទុកក្នុងសៀវភៅកំណត់ត្រាពិភពលោកបានចែងថា ព្រះយ៉េស៊ូគ្រិស្តបានបង្កើតអាដាម (adam) បន្ទាប់មក អាដាម (adam) ក៏បានបង្កើតរាល់ជីវិតនិងអ្វីៗនៅលើផែនដី។ ចំណែកសាសនាព្រាហ្មណ៍វិញ ភាសាមានដើមកំណើតពីនាងសរស្វាតី (sarasvati) ដែលត្រូវជាព្រះមហេសីរបស់ព្រះព្រហ្ម (ព្រះព្រហ្មគឺជាអាទិទេពដែលបានបង្កើតរាល់ជីវិតនិងអ្វីៗលើផែនដី)។ ជំនឿបែបនេះ បានបង្កឱ្យមានបញ្ហាច្រើនក្នុងការសិក្សាតាមបែបវិទ្យាសាស្ត្រ។ ចំពោះសម្មតិកម្មវិទ្យាសាស្ត្រវិញ បើក្នុងករណីទារកធំពេញវ័យឡើង ដោយមិនបានឮភាសាពីបរិស្ថានជុំវិញខ្លួន ពួកគេមិនអាចប្រើប្រាស់ភាសាបានឡើយ ហើយក៏មិនអាចប្រើប្រាស់ភាសាដែលបានមកពីអាទិទេពផងដែរ។

អ្នកនិពន្ធជាជនជាតិក្រិកឈ្មោះ ហេរ៉ូដូទុស (Herodotus) ជាអ្នកចងក្រងប្រវត្តិស្តេច ព្សាមម៉េទីកុស (Psammetichus) (ឬ យើងអាចហៅថា Psamtik) ព្រះអង្គជាអ្នកព្យាយាមធ្វើពិសោធន៍ទៅលើទារកពីនាក់តាំងតែពី២៥០០ឆ្នាំមុនម្ល៉េះ។ បន្ទាប់ពីដាក់កុមារៗដោយឡែកអស់រយៈពេលពីរឆ្នាំជាមួយនឹងហ្វូងពពែនិងកសិករ (កសិករនេះជាមនុស្សគ) ក្រោយមក គេបានថ្វាយសារទូលព្រះអង្គថា កុមារទាំងនេះមានលទ្ធភាពបន្លឺសំឡេងបាន ប៉ុន្តែមិនមែនជាពាក្យអេហ្ស៊ីបទេ ប៉ុន្តែគេអាចបញ្ជាក់បានថា ជាភាសាហ្វ៊ីហ្គាន(phygian) គឺ បេកូស (*bekos)* ដែលមានន័យថា នំប៉័ង។ អ្នកពិសោធអាចសន្និដ្ឋានថា ហ្វ៊ីហ្គាន ជាភាសាបុរាណចំណាស់មួយ ដែលសព្វថ្ងៃនិយាយក្នុងប្រទេសតួកគី (ភាសាដែលប្រើក្នុងតំបន់ខ្លះនៃប្រទេសតួកគី) អាចជាដើមកំណើតនៃភាសា។ វាគួរឱ្យឆ្ងល់ណាស់ ព្រោះកុមារទាំងនេះមិនបានស្តាប់ឮពាក្យនេះពីមនុស្សជុំវិញខ្លួនទេ ចុះហេតុអ្វីបានជាពួកគេអាចបន្លឺពាក្យទាំងនេះបាន? គេអាចសន្និដ្ឋានបានថា ប្រហែលពួកគេស្តាប់ឮពពែយំ។

ព្រះមហាក្សត្រទី៤នៃប្រទេសស្កត់លែន (Scotland) ក៏បានធ្វើពិសោធន៍មួយស្រដៀងនឹងការពិសោធខាងលើដែរ ប្រហែលជា១៥០០ឆ្នាំមុន ហើយជាលទ្ធផលគឺថាកុមារទាំងនេះអាចនិយាយភាសាហេប្រូវ (Hebrew) បាន។ ដូចនេះ ព្រះអង្គជឿថា ដើមកំណើតនៃភាសាអាចមកពីភាសាហេប្រូវ (Hebrew)។ យើងក៏អាចមានលទ្ធភាពរកឃើញកុមារដទៃទៀត ដែលបានរស់នៅដាច់ដោយឡែកពីសង្គមមនុស្ស។

#### ១.២.២. កត្តាធម្មជាតិ

វាពិតជាប្លែកមែនទែន ដែលថាដើមកំណើតភាសាកើតមកពីសំឡេងនៃធម្មជាតិ។ ចំពោះគំនិតនេះ ចង់សំដៅដល់ការគ្រាប់សូរដំបូងតាមរយៈសំឡេងធម្មជាតិដែលបុរសនិងស្ត្រីបានស្តាប់ឮនៅជុំវិញពួកគេ។ របស់មួយហោះហើយមានសំឡេងខាវៗ ពេលនោះ មនុស្សក៏ស្តាប់ឮនិងព្យាយាមធ្វើត្រាប់តាម ដោយដាក់ឈ្មោះវត្ថុនោះតាមសំឡេងនោះ។ តាមពិត ភាសាទំនើបក៏មានពាក្យជាច្រើនបង្កើតឡើងដោយការត្រាប់តាមសំឡេងធម្មជាតិដែរ។ ដូច្នេះ កត្តាទាំងនេះហើយដែលយើងអាចយកវាមកគាំទ្រចំពោះគំនិតលើកឡើងខាងលើ។ ឧទាហរណ៍ តុកកែ

តាវ៉ៅ វូៗ ក្ដាំង គ្រាំងៗ ...និងទម្រង់បូវ-វ៉ូវ (bow-wow) ជាដើម។ សរុបមក ចំពោះទស្សនៈបែបនេះ យើងអាចសន្និដ្ឋានបានថា វាជាទ្រឹស្ដីបូវ-វ៉ូវ (bow-wow) នៃដើមកំណើតភាសា។ ពាក្យដែលបង្កើតឡើងដោយត្រាប់តាមសំឡេងធម្មជាតិ ឬការយកពាក្យដាក់ឈ្មោះឱ្យធម្មជាតិ គេហៅថា ទ្រឹស្ដីតម្រាប់សូរ។ វាជាការពិតណាស់ ពាក្យខ្លះបានបង្កើតឡើងដោយត្រាប់សូរ ដើម្បីបំពេញតម្រូវការប្រើប្រាស់នៅក្នុងសង្គម។ ដូចនេះ ភាសាមួយត្រូវតែបង្កើតពាក្យសម្រាប់សម្គាល់ឈ្មោះវត្ថុឬធម្មជាតិនានា។ ដូចដែលយើងបាននិយាយខាងលើមកហើយ ដើមកំណើតសូរភាសាអាចមកពីស្នូរបាតុភូតធម្មជាតិនានា។ ការសន្និដ្ឋានបែបនេះ ដោយហេតុថាអ្នកសិក្សាបានសង្កេតទៅលើពាក្យមួយចំនួន ដូចជា អូ! យ៉ើ! វឹបៗ!...ជាដើម។

**១.២.៣. កត្តាសង្គម**

ទ្រឹស្ដីផ្សេងទៀតដែលទាក់ទងនឹងការបង្កើតពាក្យដោយការត្រាប់សូរសំឡេងធម្មជាតិ គឺជាទ្រឹស្ដីយូហេ-ហូ (Yohe-ho)។ សំឡេងដែលកើតឡើងពីការប្រឹងធ្វើអ្វីមួយរបស់មនុស្ស ក៏អាចជាដើមកំណើតភាសាដែរ ជាពិសេសនៅពេលដែលប្រឹងលើករបស់អ្វីដែលធ្ងន់ជាមួយដៃគូ។ ឧទាហរណ៍ សំឡេងមនុស្សរអ៊ូរ ដេរប្រទេច ខ្សឹកខ្សួល និងសំឡេងប្រឹងលើករបស់អ្វីមួយដែលមានទម្ងន់ធ្ងន់ជាដើម។

ទ្រឹស្ដីដែលនឹងបង្ហាញជូនបន្តទៀតនេះ ដែលនិយាយអំពីប្រភពកំណើតនៃភាសាមនុស្ស ក្នុងបរិបទសង្គម។ កាលដើមឡើយ មនុស្សរស់នៅជាកុលសម្ព័ន្ធ ព្រោះងាយស្រួលក្នុងការការពារពីប្រភពវាយប្រហារផ្សេងៗ។ ការរស់នៅជាកុលសម្ព័ន្ធនេះ ហើយវាក៏ជាមូលដ្ឋានក្នុងការរៀបចំក្រុមខ្លួនឱ្យទៅជាសង្គមនិងរៀបចំបង្កើតភាសាសម្រាប់ទំនាក់ទំនងគ្នា។ ដូចនេះ ប្រភពឬដើមកំណើតនៃភាសាអាចកើតឡើងដំណាលគ្នានឹងមនុស្សដែលបានចងក្រងគ្នាជាក្រុមដើម្បីរស់នៅ។ ទ្រឹស្ដីនេះគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសិក្សាឬនិយាយពីប្រភពភាសា។ ដូច្នេះ ទ្រឹស្ដីនេះ ក៏អាចឆ្លើយទៅនឹងសំណួរដែលសួរថា តើភាសាមានប្រភពមកពីណា។

**១.២.៤. កត្តាសរីរៈ**

បន្ទាប់ពីសិក្សាអំពីប្រភេទសូរសំឡេង និងប្រភពឬដើមកំណើតសូរសំឡេងមនុស្សតាមរយៈប្រភពផ្សេងៗរួចមក បន្តទៀតយើងនឹងសិក្សាដើមកំណើតវាទៅតាមដំណើរការនៃលក្ខណៈសរីរាង្គមនុស្ស ពោលគឺពួកវាមានលក្ខណៈទីទៃពីគ្នា ហើយមុខងារវាក៏ទ្រទ្រង់ដល់ការបង្កើតពាក្យសម្ដីផងដែរ។ ដូចនេះ យើងចាប់ផ្ដើមសង្កេតទៅលើមុខងារនីមួយៗនៃសរីរាង្គកាយយើង ដែលជាតំណតាំងពីបុព្វបុរសដ៏ល្អឯកនិងថាមពលដូចតទៅនេះ។

**ធ្មេញ បបូរមាត់ មាត់ កន្លើត សរីរៈសំឡេង**

ធ្មេញជាសរីរៈនៅក្នុងប្រហោងមាត់ផ្នែកខាងមុខ មានតួនាទីយ៉ាងសំខាន់សម្រាប់ខាំឬទំពារ។ លើសពីនេះទៀត វាក៏មានមុខងារដ៏ពិសេសជាងនេះ នោះគឺមុខងារក្នុងការបង្កើតសូរសំឡេងនៃព្យញ្ជនៈ វ៉ [w] និង តទ[t] នៅក្នុងភាសា។ បបូរមាត់គឺរង្វះនៅត្រង់មុខសម្រាប់បញ្ចេញវាចា សម្រាប់បរិភោគ សម្រាប់ផឹក សម្រាប់ស្រូប និងអាចបិទ ដើម្បីទប់ខ្យល់ពីក្នុងមកបាន។ វាមានមុខងារក្នុងការបង្កើតសូរសំឡេងបបិ [b] និងប៉ព [p] នៅក្នុងភាសា។ មាត់គឺអាចបើកនិងបិទបានយ៉ាងរហ័ស ហើយមានអណ្ដាតសម្រាប់សម្របសូរសំឡេងទៅតាមបរិបទក្នុងប្រហោងមាត់។ បំពង់ខ្យល់ដើមកមនុស្សមានមុខងារទីទៃពីបំពង់ខ្យល់ដើមកសត្វ ជាពិសេសសត្វស្វា ហើយវាក៏អាចធ្វើចលនាឡើងនិងចុះទៅតាមបរិបទនៃលំហូរខ្យល់ចេញនិងចូលពីសួត។ ប្រអប់សំឡេងដើមកមានមុខងារយ៉ាងសំខាន់ណាស់ក្នុងការរៀបចំ និងបន្ថែមកម្រិតសូរសំឡេងដែលចេញពីក្នុងសួតមកក្រៅ ដើម្បីឱ្យសម្ដីមានភាពច្បាស់លាស់។

**១.២.៥. កត្តាវត្ថុនានា**

នៅក្នុងចំណុចសរីរៈ ដែលជាកត្តានៃការបង្កើតសូរសំឡេងផងដែរនោះ ពោលគឺមានធ្មេញនិងបបូរមាត់ដោយពីមុនពួកវាមានកម្មវត្ថុសម្រាប់តែទំពាររបស់អ្វីផ្សេងៗប៉ុណ្ណោះ។ បន្ថែមលើសនេះ ការសិក្សាមួយយល់ថាកាយវិការដៃមនុស្សដែលតាងឱ្យសញ្ញាផ្សេងៗទៅតាមបរិបទនៅក្នុងសង្គម ត្រូវបានគេជឿថា ក៏ជាដើមកំណើត ឬ

ប្រភពនៃភាសាផងដែរ។ ប្រហែលជាពីរលានឆ្នាំមុន កត្តាទាំងនេះ វាក៏ជាភស្តុតាងមួយផងដែរ ព្រោះការវិវត្តនៃការបង្កើតឧបករណ៍ប្រើប្រាស់ក្នុងសង្គម គឺបុព្វបុរសបានយកវត្ថុផ្សេងៗមកធ្វើ និងបង្កើតឡើងដោយដៃទៅតាមការយល់ឃើញនិងចំណង់ចំណូលចិត្តខ្លួន។

ខួរក្បាលមនុស្សគឺវាមិនធំដូចទៅនឹងដងខ្លួនមនុស្សនោះទេ ហើយវាត្រូវបានបែងចែកជាពីរផ្នែកគឺ ផ្នែកខាងស្តាំនិងខាងឆ្វេង ដោយពួកវាមានមុខងារទីទៃពីគ្នា។ ផ្នែកខាងស្តាំនិងខាងឆ្វេងមានមុខងារក្នុងការទទួល គ្រប់គ្រងទិន្នន័យនិងការប្រើប្រាស់ភាសាក្នុងខួរក្បាល។ ភាសាទាំងអស់ រួមទាំងកាយវិការផងដែរ តែងតែរៀបចំនិងបន្សំសូរ ឬសញ្ញាទៅតាមលក្ខណៈពិសេសនៃបរិបទភាសានីមួយៗ។ ការបន្សំសូរក្នុងភាសាបែបនេះ ហាក់បីដូចជាបានបន្សំក្នុងខួរក្បាលយើងដោយធម្មជាតិតែម្តង។ ប្រសិនបើ យើងសិក្សាតែអំពីប្រភព ឬដើមកំណើតនៃភាសា ដោយយោងទៅតាមតែប្រភពបឋមទាំងនេះ ទិន្នន័យវាពិតជាមិនគ្រប់គ្រាន់នោះទេ ព្រោះប្រភពនៃភាសា ក៏អាចត្រាប់សំឡេងធម្មជាតិដែលនៅជិតស្និទ្ធនឹងពួកគេ។ ចំពោះ របនាសម្ព័ន្ធភាសាដំបូង គឺមនុស្សមានសមត្ថភាពបន្លឺសំឡេងដូចជាសំឡេងកកែកករ ក្នុងករណីភាសាអង់គ្លេសគឺប៊ី (bEEr) ដើម្បីបង្ហាញពីវត្ថុផ្សេងៗ ក្រោយមក ពួកគេអាចអភិវឌ្ឍសមត្ថភាពបន្លឺសូរស្រដៀងទៅនឹងពាក្យ ដូចជាពាក្យ ហ្គូត (gOOd) ជាដើម។ ក្រោយមកទៀត ពួកគេអាចបន្សំសូរ ឬយើងអាចហៅថា ពាក្យបន្សំក៏បាន ដូចជាប៊ីហ្គូត (bEEr gOOd) ដើម្បីស្តែងសារអ្វីមួយ។ បន្ទាប់មក ពួកគេក៏អាចយកពាក្យទៅផ្សំជាឈ្មោះ សម្រាប់បម្រើក្នុងជីវិតប្រចាំថ្ងៃ។

### ១.២.៦. កត្តាហ្សែន

យើងអាចសង្កេតទៅលើទារកឬកុមារផ្សេងៗអាយុមួយឬពីរឆ្នាំ ដើម្បីទុកជាឧទាហរណ៍ក្នុងការសង្កេតទៅលើការវិវឌ្ឍនៃសរីរៈពួកគេ។ ខួរក្បាលទារកគឺទទេ ពោលគឺមានតែទម្ងន់នៃផ្នែកនីមួយៗប៉ុណ្ណោះ ហើយបំពង់ខ្យល់ដើមកខ្ពស់ក្នុងបំពង់ក។ ដូចនេះ ទារកគឺដកដង្ហើមនិងផឹកក្នុងពេលតែមួយជាមួយគ្នា។ ក្រោយមួយរយៈមក បំពង់ខ្យល់ដើមកដំណើរការតាមធម្មតាវិញហើយខួរក្បាលចាប់ផ្តើមវិវឌ្ឍ ពួកគេក៏ចាប់ផ្តើមរៀនធ្វើកាយវិការនិងរៀនដើរ។

ចំពោះការវិវឌ្ឍនៃទារកគឺជារឿងធម្មជាតិ រួមទាំងភាសាពួកគេផងដែរ។ ដូចនេះការសិក្សាពីប្រភពនៃភាសាតាមរយៈទារកលូតលាស់តែងតែជួបសេចក្តីលំបាកក្នុងការសិក្សាស្រាវជ្រាវ ព្រោះទោះបីជាពួកគេកើតមកគថ្លង់ ក៏នៅតែមានការអភិវឌ្ឍសមត្ថភាសាតាមតែធម្មជាតិពួកគេ ហើយពួកគេប្រើប្រាស់ភាសាសញ្ញាជាមធ្យោបាយប្រចាំថ្ងៃ។ សរុបមក យើងអាចសន្និដ្ឋានបានថា មនុស្សកើតមកគឺមានសមត្ថភាពពិសេសសម្រាប់ភាសាដោយស្វ័យប្រវត្តិ។ វាជាធម្មជាតិ ហើយគ្មាននរណាជាអ្នកបង្កើតវាឡើងនោះទេ ហើយវាក៏មិនបានកំណត់ដែនកំណត់ណាមួយឡើយ ហើយភាសាប្រែប្រួលទៅតាមធម្មជាតិសង្គមមនុស្ស។ តើវាពិតទេ ដែលថាសមត្ថភាពអភិវឌ្ឍន៍ភាសានេះជាប់ទាក់ទងនឹងហ្សែនមនុស្សពីជំនាន់មុនទៅជំនាន់ក្រោយ?

ដើម្បីងាយរកដំណោះស្រាយពីប្រភពភាសា មនុស្សយល់ឃើញថា ហ្សែនគឺជាកត្តាយ៉ាងសំខាន់មួយក្នុងចំណោមកត្តាផ្សេងទៀតនៃដើមកំណើតភាសា។ វាមិនប្រែប្រួលអ្វីនោះទេ ប៉ុន្តែជួនកាលក៏កើតឡើងយ៉ាងឆាប់រហ័ស ហើយយើងក៏មិនអាចកំណត់បាន តើពេលណាហ្សែនប្រែប្រួល ហើយសម្របយ៉ាងម៉េច។ ការសន្និដ្ឋាននេះ គឺពឹងផ្អែកទៅលើភស្តុតាងនៃហ្វូស៊ីលនិងសរីរៈនៃសូរភាសា ដែលធ្វើពិសោធន៍តាមបច្ចេកវិទ្យាទំនើបក្នុងសម័យបច្ចុប្បន្នប៉ុណ្ណោះ។ ដូចនេះហើយ ទើបការសិក្សាស្រាវជ្រាវប្រភពភាសាត្រឡប់ទៅរកកត្តាហ្សែនវិញ (George Yule, ២០១០: ១-៦)។

លោក អ៊ីវ៉ាន់ ប៉ាវឡូវ (Ivan Pavlov) ជាភាសាវិទូជាតិរុស្ស៊ីបានពោលថា «ដោយពឹងផ្អែកលើចំណាប់អារម្មណ៍លើរូបភាពពិតដែលជាសញ្ញាតថភាពទី១ (វត្ថុឬអ្វីៗដែលមាននៅក្នុងលោកៈ) យើងក៏បានបង្កើតនូវសញ្ញាទី២ គឺការបង្កើតពាក្យ»។ លោកចាត់ទុកសញ្ញាទី២ ជាសំឡេងនៃបញ្ញត្តិ ដែលនាំទៅរកការកកើតនៃភាសាមនុស្ស។

លោក ហ្វេរឌីណង់ ដឺ សូសៀរ ( Ferdinand de Saussure ) ជាភាសាវិទូស្វីសបានលើកឡើងថា «មនុស្សនិយាយតែភាសារបស់អ្នកដែលនៅជុំវិញ»។ អាទិទេពបានផ្តល់ដល់មនុស្សនូវសម្បទាក្នុងការប្រើប្រាស់សញ្ញាបន្លឺប៉ុណ្ណោះ ប៉ុន្តែសញ្ញាបន្លឺមិនអាចកើតឡើងក្នុងធម្មជាតិទេ។

## ១.៣. ភាសាមនុស្សនិងទំនាក់ទំនងរបស់សត្វ

វាមានរឿងច្រើនដែលទាក់ទងនឹងសត្វលោកដែលអាចនិយាយភាសាបាន។ យើងតែងតែសន្មតថា ពួកវាជារឿងពិតឬរឿងប្រឌិត ឬក៏ថាពួកវាទាក់ទងនឹងបក្សាបក្សី ឬសត្វផ្សេងៗដែលធ្វើត្រាប់តាមអ្វីៗដែលពួកវាស្តាប់ឮមនុស្សនិយាយ។ យើងគិតថាសត្វលោកមានសមត្ថភាពទំនាក់ទំនងជាមួយនឹងសមាជិកផ្សេងៗទៀត ដែលរស់នៅជាមួយគ្នា។ តើវាអាចកើតឡើងដែរទេថា សត្វអាចទាក់ទងជាមួយមនុស្សដោយការប្រើប្រាស់ភាសា? តើភាសាមនុស្សមានញាណសក្តិនៃភាសា ដែលអាចបង្កើតឡើងតែមួយគត់សម្រាប់មនុស្សលោក ហើយវាមានលក្ខណៈខុសគ្នាពីប្រព័ន្ធទំនាក់ទំនងដទៃទៀត ដូច្នេះហើយសត្វមិនអាចរៀនភាសាមនុស្សបានទេឬ? ដើម្បីឆ្លើយសំណួរទាំងនេះ ដំបូងយើងត្រូវមើលលក្ខណៈពិសេសមួយចំនួននៃភាសាមនុស្ស បន្ទាប់មកយើងពិនិត្យមើលឡើងវិញពីទិន្នន័យនៃការពិសោធដែលពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងរវាងមនុស្សនិងសត្វ។ យើងនឹងប្រៀបធៀបលក្ខណៈខុសគ្នាមួយចំនួនរវាងភាសាមនុស្សនិងទំនាក់ទំនងរបស់សត្វដូចខាងក្រោមនេះ៖



ប្រភព៖ https://www.google.com/search?q=animal+talk

### ក. ការប្រើសញ្ញាសូរ

បណ្តូរទំនាក់ទំនងដោយមិនប្រើសំឡេង គឺមិនទូលំទូលាយដូចការប្រើសំឡេងទេ ឧទាហរណ៍ដូចជាករណីឃ្មុំរាំ ការប្រើសំឡេងរបស់ត្រីដូហ្វីន បក្សី គោ មនុស្ស..។ សញ្ញាសូរមានគុណសម្បត្តិច្រើនដូចជាវាអាចប្រើនៅទីងងឹត ទីឆ្ងាយពីគ្នា ឬអាចទុកដៃជើងទំនេរសម្រាប់ធ្វើសកម្មភាពអ្វីផ្សេងទៀតបានផងដែរ។

### ខ. អាថ្វាភាព

ទំនាក់ទំនងរបស់សត្វ មានភាពស្អិតរមួតរវាងសញ្ញានិងសារ។ ឧទាហរណ៍ សត្វចង់បង្អើលសត្រូវវាឱ្យចេញឆ្ងាយពីវា វាត្រូវធ្វើលក្ខណៈកាច ដូចជាធ្មេញ ខ្លា គោ ជាដើម។ ភាសាមនុស្សមិនមានទំនាក់ទំនងរវាងសញ្ញានិងសារទេ។ សញ្ញាដែលប្រើ គឺមានលក្ខណៈអាថ្វាភាព (មិនអាចបកស្រាយបាន)។

### គ. ការផ្ទេរវប្បធម៌

សត្វភាគច្រើនចេះទំនាក់ទំនងដោយស្វ័យប្រវត្តិតាមសភាវគតិពីកំណើត ដោយមិនចាំបាច់រៀននោះទេ។ ឧទាហរណ៍ករណីឃ្មុំរាំដដែល នៅតំបន់ផ្សេងៗលើលោក គឺដូចគ្នា។ ភាសាមនុស្សមានវប្បធម៌បន្តវេនពីជំនាន់មួយទៅជំនាន់មួយហើយមនុស្សត្រូវរៀនទំនៀមទម្លាប់ប្រពៃណី នៅក្នុងសង្គមដែលពួកគេរស់នៅតាំងពីកំណើតមក ដូចជាការស្លៀកពាក់ ការប្រតិបត្តិជំនឿសាសនា ម្ហូបអាហារ ជាដើម។ មនុស្សដែលយកទៅដាក់ឱ្យនៅដាច់ពីគេ គឺមិនអាចចេះភាសានោះទេ។ នេះជាលក្ខណៈធម្មជាតិនៃការចាប់យកភាសារបស់ក្មេង។

### ឃ. សន្និយោគពីរជាន់

តាមការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថាគោមានសញ្ញាសូរក្រោម១០ មាន់មានសញ្ញាសូរប្រហែល ២០ ហើយត្រីដូហ្វីនមានសញ្ញាសូរចន្លោះពី២០ទៅ៣០។ សត្វភាគច្រើនអាចប្រើសូរមូលដ្ឋាននីមួយៗតែម្តងគត់។ ដូច្នេះហើយចំនួនសារដែលសត្វអាចបញ្ជូនមានកម្រិតអាស្រ័យលើចំនួនសូរមូលដ្ឋាន។ ភាសាមនុស្សមានសូរសព្ទ (សទ្ទតា) ចន្លោះពី៣០-៤០។ សទ្ទតានីមួយៗ គឺមិនមានន័យទេ ពេលនៅតែឯង ហើយវាមានន័យ ពេលដែលចូល

រួមជាមួយសទ្ទតាដទៃទៀត។ ឧទាហរណ៍ សទ្ទតាស្រៈនិងព្យញ្ជនៈ ក, ◌ា, ង, ត, ◌ោ, គ្មានន័យទេ សទ្ទតាទាំងនេះមានន័យបាន នៅពេលដែលពួកវាចូលរួមផ្សំគ្នាជាមួយសទ្ទតាផ្សេងៗទៀតដូចជា ក + ◌ា > កា, ក + ◌ា + ង > កាង , ត + ◌ា > តា, ត + ◌ោ > តោ,  ត + ◌ោ + ង > តោង, ង + ◌ា + ក > ងាក, ង + ◌ោ + ក > ងោក ជាដើម។ ស្រទាប់ទី១ គឺជាសូរ  ហើយស្រទាប់ទី២ គឺជាការផ្សំសូរ (ប្រព័ន្ធសូរ)។

**ង. ការជំនួស**

សត្វទាក់ទងតែក្នុងស្ថានភាពភ្លាមៗ។ ឧទាហរណ៍ បក្សីស្រែកប្រកាសអាសន្នតែពេលវាជួបប្រទះនឹងគ្រោះអ្វីមួយ។ ភាសាមនុស្សអាចដោះស្រាយបានគ្រប់រឿងហើយមិនចាំបាច់ខ្វល់ថាប្រធានរឿងដែលត្រូវសន្ទនានៅចំពោះមុខឬនៅឆ្ងាយ (រឿងទាំងនេះអាចកើតឡើងនៅពេលឥឡូវ មុន ឬក្រោយការសន្ទនា)។

**ច. ការច្នៃប្រឌិត**

សត្វមានសារតិច ដែលអាចបញ្ជូននិងទទួល។ មនុស្ស អាចបង្កើតពាក្យសម្ដីដោយគ្មានដែនកំណត់ ដូចជា ប្រលោមលោក កំណាព្យ ចម្រៀង អត្ថបទផ្សេងៗ។ មនុស្សអាចនិយាយឃ្លាឬល្បះមួយដែលមិនធ្លាប់និយាយពីមុនមក។

## ១.៤. ប្រវត្តិនិងបណ្ដុំទំនាក់ទំនងនៃភាសា

ភាសា ជាឧបករណ៍ឆ្លុះបញ្ចាំងឱ្យឃើញអំពីប្រាជ្ញាញាណដ៏ប្រសើររបស់មនុស្ស ដែលអាចអភិវឌ្ឍសំឡេងចេញមកបានតាមធម្មជាតិ ឱ្យក្លាយជាដៃគូជាមួយនឹងគំនិត អារម្មណ៍ និងសេចក្ដីត្រូវការរបស់ខ្លួន ឱ្យអ្នកដទៃបានដឹង និងទំនាក់ទំនងគ្នាបាន រហូតកើតបានជាភាសា។ មនុស្សប្រើប្រាស់ភាសាធ្វើជាឧបករណ៍សម្រាប់ទំនាក់ទំនងគ្នា និងឈ្វេងយល់ចិត្តគ្នាទៅវិញទៅមក នៅក្នុងសហគមន៍នៃអ្នកប្រើប្រាស់ភាសាដូចគ្នា។ ភាសាធ្វើឱ្យមនុស្សចេះអភិវឌ្ឍជីវិត ការរស់នៅ សមត្ថភាពចិញ្ចឹមជីវិត និងពង្រឹងសមត្ថភាពផ្សេងៗទៀតជាច្រើន។ មនុស្សអាចអភិវឌ្ឍវិជ្ជា គំនិត សីលធម៌ ជំនឿ សិល្បៈ។ល។ រហូតធ្វើឱ្យមានភាពខុសប្លែកគ្នាអំពីសត្វគ្រប់ប្រភេទ និងក្លាយជាអ្នកគ្រប់គ្រងលោកបាន ក៏ព្រោះភាសារបស់មនុស្សនេះឯង។ ទើបភាសាជាវត្ថុសំខាន់បំផុតនៃភាពជាមនុស្ស។ មិនថាពួកជនមានភាពរីកចម្រើនឈានមុខ រហូតក្លាយជាអ្នកមានមហាអំណាច ឬពួកជនដែលឱនថយបំផុត គ្រប់គ្នាសុទ្ធតែប្រើប្រាស់ភាសា សម្រាប់ទាក់ទងគ្នាទៅវិញទៅមក។ ហើយភាសានីមួយៗ អាចមានភាពពេញលេញគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់នៅក្នុងសហគមន៍របស់ខ្លួនទៅបាន កាលណាមនុស្សបានទាក់ទងជាមួយនឹងសហគមន៍ផ្សេងៗ និងទាក់ទងជាមួយអ្នកប្រើប្រាស់ភាសាមិនដូចខ្លួន។ ការខ្ចីភាសាទៅវិញទៅមក អាចមានតិចឬច្រើន វាអាស្រ័យតម្រូវការចាំបាច់ និងសេចក្ដីត្រូវការរបស់មនុស្សនៅក្នុងសង្គមនោះ។ មនុស្សយើងប្រើប្រាស់ភាសាផ្សារភ្ជាប់នឹងការចិញ្ចឹមជីវិត ទើបភាសាអាចទទួលរងឥទ្ធិពលអំពីការអភិវឌ្ឍ ឬហាយនភាពនៃសង្គមមនុស្ស ហើយភាសាក៏អាចមានឥទ្ធិពលចំពោះវឌ្ឍនភាព ឬហាយនភាពនៃសង្គមមនុស្សបានដែរ (សួន ឱសថ, ២០១៣: ៦០)។

### ១.៤.១. កាយវិការនិងភាសាសញ្ញា

កាលពីអតីតកាលដ៏យូរលង់ មនុស្សនៅមិនទាន់ដឹងអំពីរបៀបនៃការប្រើប្រាស់ភាសាដូចសម័យសព្វថ្ងៃទេ។ គ្រានោះ ប្រាកដជាមានការប្រើប្រាស់ភាសាគ ជាក់ជាមិនខាន ដូចជាការសម្ដែងអាការកម្រើកអវយវៈលើកដៃបក់ដៃ លើកដៃចង្អុល អង្រួនក្បាល ញាក់មុខ ញាក់ចិញ្ចើម ជាដើម។ ក្រោយមក ក៏បន្លឺសំឡេងឱ្យលាន់ឮឡើងបែបសូរឧទាន ដោយពុំបានយល់អំពីអត្ថន័យអ្វីឡើយ គ្រាន់តែបន្លឺឡើងចេញមកតាមសញ្ជាតញ្ញាណ (អារម្មណ៍ដែលកើតឡើងដោយឯងៗ) របស់មនុស្ស កាលណាកើតមានអារម្មណ៍ដូចជា សប្បាយចិត្ត លំបាកចិត្ត ចម្លែកក្នុងចិត្ត ភ័យរន្ធត់ តក់ស្លុត ជាដើម។ លុះក្រោយមកទៀត កាលពួកគេប្រើសំឡេងទាំងអស់នោះរឿយៗ ក៏យល់អំពីបំណងគ្នាទៅវិញទៅមកនៅក្នុងក្រុមរបស់ពួកគេ ទើបក្លាយជាភាសាឡើង។ តែជាភាសាដែលស្ថិតនៅក្នុងកម្រិតតូចនិងមិន

ទាន់មានអត្ថន័យច្បាស់លាស់ទេ ព្រោះនៅមានលក្ខណៈជាក្រុមតូចៗ។ ចំណេរកាលតមក ភាសាក៏ចេះតែកើតមានច្រើនឡើងៗ ទៅតាមភាពចាំបាច់ និងសេចក្តីចម្រើនរបស់មនុស្សជាលំដាប់ (សួន ឱសថ, ២០១៣: ៣៧)។

មនុស្សគប្មមនុស្សដែលភាសាផ្សេងគ្នាស្តាប់គ្នាពុំបាន យកដៃទះពោះ ហើយចង្អុលមាត់ ដើម្បីសម្តែងសេចក្តីស្រេកឃ្លាន ឬលាតបាតដៃដាក់អែបទៅនឹងត្រចៀក ហើយផ្អៀងក្បាលទៅលើដៃនោះ ដើម្បីសម្តែងសេចក្តីថាដេក (អៀវ កើស, ១៩៩៥: ៧)។

យើងសង្កេតឃើញថា កុមារៗមានសមត្ថភាពអភិវឌ្ឍនៃដំណើរការចាប់យកភាសារបស់ពួកគេ តាមបែបលក្ខណៈធម្មជាតិ។ ចំពោះកុមារគ្មានពិការភាព ពួកគេចាប់យកភាសាតាមរយៈអ្នកនៅជុំវិញខ្លួនពួកគេ រីឯកុមារពិការភាព (ពួកគាត់ជាមនុស្សគថ្លង់ពីធម្មជាតិ) ពួកគេចាប់យកភាសាសញ្ញា។ តាមពិតទៅ ភាសាសញ្ញាជាភាសាធម្មជាតិដូចភាសាសម្រាប់មនុស្សទូទៅដែរ ប៉ុន្តែមនុស្សភាគច្រើនយល់ថាមិនមែនជាភាសា ហើយវាគ្រាន់តែជាកាយវិការឬសញ្ញាតែប៉ុណ្ណោះ។

ទាក់ទងនឹងកាយវិការ ឬក៏សញ្ញា ពួកវាសម្តែងតាមរយៈដៃដូចគ្នាដើម្បីបង្ហាញពីបរិបទអ្វីមួយ ប៉ុន្តែពួកវាមានលក្ខណៈមិនដូចគ្នានោះទេ។ សញ្ញាគឺតាងឱ្យសម្តីមនុស្សហើយប្រើប្រាស់សម្រាប់និយាយទាក់ទងគ្នា ចំណែកឯកាយវិការគឺគ្រាន់តែប្រើប្រាស់ក្នុងពេលដែលយើងកំពុងនិយាយគ្នាតែប៉ុណ្ណោះ។ ដូចនេះ កាយវិការគ្រាន់តែជាវិធីមួយដែលគេប្រើដើម្បីបញ្ជាក់បន្ថែមពីន័យសេចក្តីក្នុងពេលកំពុងនិយាយ ពោលគឺយើងអាចសង្កេតមើលពេលយើងកំពុងនិយាយគ្នាជាឧទាហរណ៍ស្រាប់។

ចំពោះកាយវិការដែលយើងប្រើក្នុងពេលដែលយើងកំពុងនិយាយ ពោលគឺយើងអាចបែងចែកទៅជាច្រើនប្រភេទដូចជាអាយកូនិក (iconics) គឺជាកាយវិការដែលតាងឱ្យសារសម្តីរបស់មនុស្ស។ ដេកទិក (deictics) គឺជាកាយវិការដែលប្រើសម្រាប់ចង្អុលបង្ហាញពីរបស់អ្វីមួយ។ ប៊ីត (beat) គឺជាសភាពនៃកាយវិការយ៉ាងរហ័សដែលសម្តែងឡើងស្របពេលយើងកំពុងនិយាយ។

ចំណែកឯភាសាសញ្ញា (យើងអាចហៅថា សញ្ញាក៏បាន) អាចបែងចែកជាពីរប្រភេទ គឺនិមិត្តសញ្ញានិងសញ្ញា។ និមិត្តសញ្ញា គឺជាប្រភេទនៃប្រព័ន្ធសញ្ញា ដែលអភិវឌ្ឍដោយអ្នកនិយាយក្នុងការកំណត់ ដើម្បីស្តែងពីការទំនាក់ទំនងក្នុងស្ថានភាពណាមួយ ដែលពួកគេមិនអាចនិយាយគ្នាបាន ហើយសញ្ញាឬភាសាសញ្ញាជាភាសាកំណើតមួយរបស់ជនពិការ (ពួកគាត់ គឺជាមនុស្សគថ្លង់) ព្រោះពួកគាត់មិនអាចប្រើប្រាស់ភាសានិយាយសម្រាប់ទំនាក់ទំនងគ្នា (George Yule, ២០១០: ១០៨-២០៧)។

បច្ចុប្បន្ននេះ ភាសាគ (ភាសាសញ្ញា) ចាត់ទុកថា ជាភាសាមានរបៀប (តន្តិភាសា) មួយប្រភេទ ដែលប្រើម្រាមដៃសម្តែងអត្ថន័យរវាងគ្នានិងគ្នា។ ក្រៅពីប្រើជាមួយមនុស្សគដូចគ្នាហើយ មនុស្សធម្មតាក៏អាចនាំយក ទៅប្រើជាមួយមនុស្សគបានដែរ ព្រោះប្រើម្រាមដៃជំនួសតួអក្សរ អាចប្រកបជាពាក្យនិយាយដូចសរសេរជាអក្សរឱ្យយល់អត្ថន័យគ្នាបាន។ វិធានប្រើម្រាមដៃជាសញ្ញាជំនួសពាក្យនិយាយនេះ មានអ្នករកឃើញក្បួនកម្រិតអន្តរជាតិមុនគេនៅក្នុងប្រទេសអេស្ប៉ាញ។ បន្ទាប់មក បារាំងបាននាំយកក្បួននោះមកកែសម្រួល ប្រើនៅក្នុងប្រទេសរបស់ខ្លួន។ បន្ទាប់មកទៀត អាមេរិកបាននាំយកក្បួនពីបារាំងនោះមកប្រើ និងបង្កើតជាសាលារៀនសម្រាប់បង្ហាត់បង្រៀនដល់មនុស្សគថ្លង់យ៉ាងទូលំទូលាយ (សួន ឱសថ, ២០១៣: ៤៨)។

គេអាចសរសេរភាសាសញ្ញាទាំងអស់ដែរ។ ភាសានិយាយទាំងអស់ពាំនាំអត្ថន័យតាមរយៈសំឡេង ដូច្នេះហើយប្រព័ន្ធសំណេរសម្រាប់ភាសានិយាយ ភាគច្រើនមាននិមិត្តសញ្ញាខ្លះសម្រាប់តំណាងឱ្យសំឡេងតាមរបៀបដែលគេនិយាយ។ តាមពិតភាសាសញ្ញាមិនមានសំឡេងទេ ប៉ុន្តែវាពិតជាមានប៉ារ៉ាម៉ែត្រ (ការកំណត់របៀបអ្វីមួយ) មិនកែប្រែ។ វាមានប៉ារ៉ាម៉ែត្រសំខាន់ៗចំនួន៥នៅក្នុងការបង្កើតសញ្ញានៅក្នុងគ្រប់ភាសាសញ្ញាទាំងអស់៖ ទី១ រាងដៃដែលគេប្រើក្នុងការធ្វើសញ្ញា, ទី២ ទីតាំងបាតដៃនៃរាងដៃទាំងនេះ, ទី៣ ទីតាំងដែលគេធ្វើសញ្ញា, ទី៤ ចលនាដែល

គេប្រើក្នុងការធ្វើសញ្ញា, ទី៥ សំនួនវោហារសព្ទដែលគេមិនប្រើដៃក្នុងការបង្កើតសញ្ញា (ភាសាសញ្ញាកម្ពុជា, ២០០៨: ៦៧)។




ប្រភព៖ https://www.google.com/search?

## ១.៤.២. ភាសានិយាយ

ភាសានិយាយ គឺជាការបន្លឺសូរសំឡេងចេញមកតាមមាត់ដោយមិនមានប្រើអក្សរ ឬសញ្ញាសម្គាល់អ្វីឡើយ ហើយមនុស្សអាចចាប់យកសំឡេងនេះបានតាមរយៈត្រចៀក។ ភាសានិយាយមានការវិវឌ្ឍយ៉ាងលឿន ហើយត្រូវបានគេប្រើច្រើនបំផុតនៅក្នុងសង្គមមនុស្សសម្រាប់ទំនាក់ទំនងគ្នា។

ភាសាពិតប្រាកដរបស់មនុស្ស គឺភាសានិយាយដែលប្រកបដោយបរិមាណភាសាមានចំនួនច្រើន យកមករៀងគ្នាជាលំដាប់ តាមលក្ខណៈនៃភាសានីមួយៗ។ បរិមាណភាសាមាន សូរនិយាយនិងអត្ថន័យ។ បើមានតែសូរនិយាយ មិនមានអត្ថន័យ ឬយកន័យមិនបាន (ស្តាប់គ្នាមិនបាន) សូរនិយាយនោះ ក៏មិនមែនជាភាសាដែរ។ បើមានតែអត្ថន័យ មិនមានសូរនិយាយ ក៏ត្រឹមតែជាគំនិត មិនមែនជាភាសា ឬជាភាសាមិនពេញលេញ។ មនុស្សប្រើប្រាស់ភាសានិយាយជាយូរយារណាស់មកហើយ មុននឹងគិតគូរកតួអក្សរ ឬសញ្ញាសម្គាល់ ដើម្បីរក្សាទុកនូវភាសាបាន។ ដូច្នេះ ទើបទម្រង់អក្សរនិងការសរសេរមិនមែនជាភាសាពិតប្រាកដ ត្រឹមតែជាវត្ថុតំណាង (សញ្ញា) ឬជំនួសភាសាប៉ុណ្ណោះ។ ភាសានិយាយជាភាសាពិតប្រាកដរបស់មនុស្ស។ សូម្បីអ្នកដែលមិនបានរៀនអក្សរ ឬមិនចេះអានសៀវភៅ ក៏មានភាសាសម្រាប់និយាយ និងទំនាក់ទំនងជាមួយបុគ្គលដទៃបានដែរ (សួន ឱសថ, ២០១៣: ៦១)។

មនុស្សប្រើមធ្យោបាយបណ្តូរទំនាក់ទំនងតាមរយៈភាសានិយាយដូចជា៖

**ក. នៅទល់មុខគ្នា**

កាលណាគេនៅទល់មុខគ្នា គេនិយាយគ្នាទៅវិញទៅមក ដើម្បីទាក់ទងគ្នា។ ម្នាក់ជាអ្នកនិយាយ ឬជាអ្នកផ្សាយដំណឹង ឯម្នាក់ទៀតជាអ្នកស្តាប់ ឬអ្នកទទួលដំណឹង។ អ្វីដែលឆ្លងពីម្នាក់ទៅម្នាក់ទៀតគឺ «សារ»។ ឧបករណ៍សម្រាប់ប្តូរការទាក់ទងគ្នាគឺ «ភាសា» ហើយពាក្យទាំងឡាយដែលគេរៀបចំឡើងទៅតាមរបៀបណាមួយធ្វើឱ្យសារច្បាស់លាស់ឡើង។ បណ្តូរទំនាក់ទំនងអាចប្រព្រឹត្តទៅបាន លុះត្រាតែគូរសន្ទនាទាំងសងខាង គឺអ្នកនិយាយ និងអ្នកស្តាប់ នៅក្នុងសហគមន៍នៃភាសាជាមួយគ្នា ឬក៏ចេះនិយាយភាសាណាមួយដូចគ្នា។ បើពុំដូចនោះទេ បណ្តូរទំនាក់ទំនងនឹងមានឧបសគ្គ ហើយមិនបានប្រយោជន៍។

**ខ. នៅឆ្ងាយពីគ្នា**

កាលណាគេនៅឆ្ងាយពីគ្នា គេអាចប្តូរទំនាក់ទំនងគ្នាបានដោយប្រដាប់បំពងសំឡេង ដូចជា មេក្រូ ទូរស័ព្ទ វិទ្យុ ទូរទស្សន៍ អ៊ីនធឺណិត ជាដើម។ ការបណ្តូរទំនាក់ទំនងពុំមែនសុទ្ធតែសាសងចុះឡើងបានទាំងអស់ទេ។ ក្នុងករណីខ្លះ វាប្រើបានទិសតែមួយ ដូចជា វិទ្យុ ទូរទស្សន៍ ជាដើម។

ភាសានិយាយតែងតែប្រែប្រួលទៅតាម៖

-បុគ្គលិកលក្ខណៈនៃអ្នកនិយាយនិងអ្នកស្តាប់ (ការនិយាយទៅមិត្តភក្តិឬទៅលោកគ្រូ មានការប្រើពាក្យខុសគ្នា)។

-កាលៈទេសៈនៃបណ្តូរទំនាក់ទំនងជាដើម។

ភាសាអាចជាបែបធម្មតា បែបគ្រួសារ ឬ ជាបែបថ្លៃថ្នូរ។ ដូចនេះពាក្យបជិរូប វេយ្យាករណ៍ សំនៀងតែងតែប្រែប្រួលពីល្បាក់ភាសាមួយទៅល្បាក់ភាសាមួយទៀត។

**១.៤.៣. ភាសាសរសេរ**

ភាសាសរសេរ គឺជាភាសាដែលគេប្រើអក្សរ ឬសញ្ញាសម្គាល់ផ្សេងៗ ដោយមិនមានសូរសំឡេងនោះទេ។ ភាសាសរសេរមានការវិវឌ្ឍយឺតជាងភាសានិយាយ ហើយពាក្យដែលគេយកមកសរសេរខ្លះមានលក្ខណៈខុសពីភាសានិយាយ។ មធ្យោបាយនៃបណ្តូរទំនាក់ទំនងនៃភាសាសរសេរ គឺអក្សរ សារព័ត៌មាន សៀវភៅ ជាដើម។ អក្សរមានសារៈសំខាន់ណាស់សម្រាប់ប្តូរទំនាក់ទំនងគ្នាបានរហ័សក្នុងទិសទាំងពីរ។ ភាសានិយាយរស់រវើកសម្រាប់ប្រើដោយផ្ទាល់ អាចមានកាយវិការ ឬលំញាក់ជួយផង កាលណាគេនៅទល់មុខគ្នា។ ឯភាសាសរសេរវិញ ច្បាស់លាស់តែស្មុគស្មាញជាង ព្រោះគេអាចគិត រួចកែសម្រួលបាន។ ដើម្បីសរសេរ «សារ» គេប្រើសំណេរដៃ វង្វាយអង្គុលីលេខ កុំព្យូទ័រ របៀបអក្សរពុម្ពជាដើម។

ក្នុងការសរសេរ «សារ» គេពុំមែនចេះតែសរសេរមិនដឹងអំពីអ្វីនោះទេ ហើយក៏ពុំសរសេរតាមឱ្យតែបាននោះដែរ។ សំណេរដៃត្រូវតែច្បាស់លាស់ ហើយងាយយល់។ គេប្រើពាក្យទៅតាមប្រភេទនៃសារ ជាសំបុត្រគ្រួសារ សំបុត្រផ្លូវការ ប័ណ្ណប្រៃសនីយ៍ ឬទូរលេខជាដើម។ គេត្រូវចេះកែលម្អកពាក្យឱ្យត្រូវតាមបំណង។ ក្រៅពីសំណេរស្អាតច្បាស់ គេត្រូវគិតដល់ការដកបន្ទាត់ ការដកឃ្លា ខណ្ឌ អក្ខរាវិរុទ្ធត្រឹមត្រូវ ល្បះត្រូវតាមក្បួនវេយ្យាករណ៍...(ក្រសួងអប់រំ, ១៩៨៦: ៣-៨)។

ការបញ្ជូនភាសា ចាត់ទុកថា ជាផ្នែកសំខាន់ក្នុងការយល់អំពីរឿងភាសា។ អ្នកបញ្ជូនភាសា ត្រូវស្គាល់សញ្ញានិងអត្ថន័យនៃភាសាឱ្យបានល្អ។ តែបើមិនមានអ្នកទទួលភាសាទេ ក៏មិនអាចសម្រេចជាប្រយោជន៍បានដែរ ឬអ្នកទទួលភាសាមានហើយ តែបើខ្វះចំណេះដឹងមូលដ្ឋានក្នុងការប្រែអត្ថន័យនៃភាសា ក៏មិនអាចស្តាប់គ្នាបានដែរ។ ព្រោះហេតុនោះ ទើបអ្នកបញ្ជូននិងអ្នកទទួល ចាំបាច់ត្រូវស្គាល់អំពីសញ្ញានិងអត្ថន័យនៃភាសា ព្រមជាមួយនឹងកម្មវត្ថុ (គោលបំណង) ថែមទៀត។ ភាសាដែលមានលក្ខណៈជាសញ្ញាឱ្យអ្នកបញ្ជូននិងអ្នកទទួលដឹងអំពីអត្ថន័យឬកម្មវត្ថុ (គោលបំណង) រវាងគ្នានិងគ្នាបាន ហៅថាភាសាសរសេរ (សួន ឱសថ, ២០១៣: ៥០)។

**១.៥. ថែបនៃភាសាតាមការប្រើប្រាស់**

គេអាចចែកភាសាទៅតាមប្រវត្តិ ឬទៅតាមបម្រើបម្រាស់របស់វាដូចជា៖

ក. ភាសាមេ គឺជាភាសាដើមដែលឱ្យកំណើតដល់ភាសាច្រើនទៀតក្នុងការវិវត្តរបស់ខ្លួននៃប្រវត្តិសាស្ត្រ។ ឧទាហរណ៍: ក្រុមខ្មែរ-មន ជាភាសាមេនៃភាសាខ្មែរ។

ខ. ភាសាញាតិ គឺជាភាសាទាំងឡាយណាដែលបែកចេញមកពីភាសាមេជាមួយគ្នា។ ឧទាហរណ៍ ភាសាខ្មែរ និងភាសាមន ជាភាសាញាតិនឹងគ្នា។

គ. ភាសាកំណើត (មាតុភាសា) គឺជាភាសាដែលគេប្រើប្រាស់ក្នុងប្រទេសកំណើតរបស់អ្នកនិយាយ ហើយអ្នកនិយាយបានចេះចាំតាំងពីកុមារមក។ ឧទាហរណ៍ សុកកើតនៅស្រុកខ្សាច់កណ្ដាល។ សុកនិយាយភាសាខ្មែរតាំងពីដឹងក្ដីមកម្ល៉េះ។ ភាសាខ្មែរជាភាសាកំណើតរបស់សុក។

ឃ. ភាសារស់ឬជីវភាសា គឺភាសាដែលគេកំពុងប្រើសព្វថ្ងៃក្នុងការទាក់ទងគ្នា តាមមាត់ក្ដី តាមអក្សរក្ដី នៅក្នុងប្រទេសផ្សេងៗ។ ភាសាខ្មែរជាភាសារស់ ព្រោះពលរដ្ឋកម្ពុជាទូទាំងប្រទេសប្រើភាសានេះ ដើម្បីប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ។ ឯភាសាវៀតណាម ភាសាឡាវ ភាសាថៃ ភាសារុស្ស៊ី ភាសាអង់គ្លេស ភាសាបារាំង ភាសាអាល្លឺម៉ង់ ។ល។ ក៏ជាភាសារស់ដែរ។ តែបើយើងយកភាសាទាំងនោះមកគិត ក្នុងក្របខណ្ឌប្រជាជាតិខ្មែរ យើងហៅថាជីវភាសាបរទេសទៅវិញ ព្រោះជាសម្ដីរបស់បរទេស គឺពុំមែនជាភាសារបស់ជនជាតិខ្មែរយើងទេ។

ង. ភាសាស្លាប់ គឺជាភាសាដែលគេពុំយកមកប្រើជាមធ្យោបាយទាក់ទងគ្នាទេ ទាំងក្នុងការសរសេរក្ដី ទាំងក្នុងការនិយាយក្ដី។ ប៉ុន្តែភាសាទាំងនេះជាភាសាបុរាណ ដែលគេប្រើយូរយារណាស់មកហើយ។ ឧទាហរណ៍ ភាសាបាលី ភាសាសំស្ក្រឹត ភាសាឡាតាំង...។

ច. ភាសាយាន គឺជាភាសាដែលប្រជាជាតិណាមួយយកមកប្រើជាឧបករណ៍ ជាយាន ក្នុងការសិក្សាយកវិជ្ជាផ្សេងៗ។ ឧទាហរណ៍ ក្នុងសម័យអាណានិគមនិយមបារាំង ភាសាបារាំងជាភាសាយានសម្រាប់ប្រទេសយើង។ សព្វថ្ងៃនេះ ភាសាខ្មែរជាភាសាយានក្នុងការសិក្សា។

នៅក្នុងភាសានីមួយៗ ការប្រើប្រាស់តែងប្រែប្រួលតាមល្បាក់ភាសា ឬបញ្ជិកាភាសា ដូចជា ភាសាធម្មតា ភាសាសម្រិតសម្រាំង ភាសាអក្សរសាស្ត្រ ភាសាអ្នកប្រាជ្ញ ភាសាបច្ចេកទេស...។ ហើយភាសាក៏អាចត្រូវគេប្រើខុសគ្នាខ្លះៗ ទៅតាមតំបន់ថែមទៀត។

ឆ. គ្រាមភាសា គឺជាភាសាតំបន់ដែលប្រើឃ្លាតពីគ្នាបន្តិចៗ តែមិនខុសគ្នារហូតដល់ស្ដាប់ពុំបាន រកអ្នកមកបកប្រែនោះទេ។ ភាសាតំបន់ល្បៀងគ្នាដោយសារសំនៀងឬសំឡេងដែលមានការបញ្ចេញសូរសៀងខុសគ្នាបន្តិច។ ឧទាហរណ៍ អ្នកសៀមរាប និយាយទ្រង់រដើន អ្នកភ្នំពេញអានច្រើនមិនត្រូវស្រៈ «អ៊ា» រីឯអ្នកតាកែវ អានសំឡេង «រ» ត្រឹមត្រូវជាងគេ ហើយអ្នកបាត់ដំបងអានសំឡេង «អ៊ី អ៊ែ» មិនត្រូវ ដូចជា គ្រប់និងគ្រុប នំនិងនុំ មែននិងម៉េន។ តាមធម្មតា គ្រាមភាសារបស់ទីក្រុងធំរមែងចំជាភាសារបស់ជាតិជាងគ្រាមភាសាឯទៀត ត្បិតគ្រាមភាសាទីក្រុងរមែងពង្រីកផ្សាយចេញទៅព្រមនឹងអំណាចរដ្ឋាភិបាលទូទៅក្នុងប្រទេស។

ជ. ទេសភាសា គឺជាភាសាដែលប្រើសម្រាប់ប្រាស្រ័យទាក់ទងគ្នាតែក្នុងរង្វង់តូចនៃជនជាតិរបស់ខ្លួន។ ដើម្បីទាក់ទងជនជាតិដទៃទៀត គេប្រើភាសាកណ្ដាលមួយ។ ឧទាហរណ៍ ជនជាតិព័រទាក់ទងជនជាតិកួយ គេត្រូវប្រើភាសាកណ្ដាលមួយ «ភាសាខ្មែរ» (ក្រសួងអប់រំ, ១៩៨៦: ៩)។

## ១.៥.១. អំពីភាសាខ្មែរ

យើងជាជនជាតិខ្មែររមែងយកចិត្តទុកដាក់នឹងភាសាខ្មែរ។ ជាធម្មតារមែងចង់ឱ្យភាសាយើង ទទួលសេចក្ដីរាប់អានពីប្រជាពលរដ្ឋទាំងអស់។ ខ្មែរតែងតែចង់ឱ្យភាសាខ្មែរមានសារៈសំខាន់និងមានវិសាលភាពក្នុងកិច្ចការគ្រប់យ៉ាង ដូចជាកិច្ចការជំនួញ ប្រាស្រ័យទាក់ទង កិច្ចការរាជការ ជាដើម។ កាលបើភាសាយើងមានប្រើការកាន់តែច្រើនឡើង ក៏នឹងត្រូវមានអ្នកខិតខំរៀនសូត្រភាសាជាតិ ក៏កាន់តែច្រើនឡើងដែរ ហើយអ្នកដែលស្វែងរកចំណេះ បានមកពីភាសានោះមានភាសាអង់គ្លេស បារាំង ចិនជាដើម កាលណាបើចេះភាសាខ្មែរជ្រាលជ្រៅច្បាស់លាស់នឹងអាចនាំយកវិជ្ជាដែលខ្លួនរកបាននោះមករៀបរៀងសរសេរជាភាសាខ្មែរ ចែកចាយផ្សាយសព្វដល់បងប្អូនជនរួមជាតិទាំងអស់ឱ្យបានចេះដឹងនិងយល់ដោយសារយើងផងដែរ។ ភាសាខ្មែរ គឺជាភាសាផ្លូវការមួយដែលប្រើប្រាស់ជាផ្លូវការនៅប្រទេសកម្ពុជា។

### ១.៥.២. ដើមកំណើតនៃភាសាខ្មែរ

ភាសាមានដើមកំណើតប្រហែលគ្នានឹងកំណើតមនុស្ស។ តាមប្រវត្តិសាស្ត្រខ្មែរបានបញ្ជាក់ថា ជនជាតិខ្មែរមានយូរយារមកហើយ គឺប្រមាណ ១លានឆ្នាំ និង ៦៨០.០០០ឆ្នាំ មុនគ.ស មកហើយ ជាជនជាតិមួយដែលមានអារ្យធម៌រុងរឿងក្នុងចំណោមជាតិសាសន៍ដទៃទៀតនៃភូមិភាគអាស៊ីអាគ្នេយ៍។ មតិខ្លះយល់ថា ភាសាខ្មែរមានដើមកំណើតពីភាសាសំស្ក្រឹតនិងភាសាបាលី ព្រោះគេយល់ឃើញថា នៅក្នុងភាសាយើងសព្វថ្ងៃមានលាយច្របល់ដោយពាក្យបាលីនិងសំស្ក្រឹតជាច្រើន ដូចជា កល ផល ហេតុ ភេទ គេហដ្ឋាន ស្រី ប្រព្រឹត្ត មិត្រ គ្រឹះ...។ល។ តាមឯកសារអរិយធម៌ខ្មែរ-មនរបស់លោកកែប វ៉ាន់ឌី បោះពុម្ពឆ្នាំ១៩៧១ ទំព័រ១១៩ បានបញ្ជាក់ថា: ក្នុងចំណោមពាក្យទាំង ១៧៧៤៦ម៉ាត់ដែលមាននៅក្នុងវចនានុក្រមភាគ១និងភាគ២ បោះពុម្ពផ្សាយលើកទី៤ ឆ្នាំ១៩៦២ មានពាក្យខ្មែរសុទ្ធតែ១០៥០០ ស្មើ៥៩.១៦% ប៉ុណ្ណោះ។ ក្រៅពីនេះ គឺជាពាក្យដែលមានប្រភពមកពីបរទេស គឺខ្ចីពីបាលី-សំស្ក្រឹត ចំនួន៦៥.៧៣ ស្មើ៣៧.០៣% , ខ្ចីពីសៀម ចំនួន៤៧៦ពាក្យ, ខ្ចីពីចិន ចំនួន៦៧ពាក្យ, ខ្ចីពីបារាំង ចំនួន ៥៩ពាក្យ ស្មើ៣.៧៩%, ខ្ចីពីយួន ចំនួន៤៤ពាក្យ, ខ្ចីពីភាសាដទៃមានលាវ អង់គ្លេស ស្មើ១៨ពាក្យ។

ប៉ុន្តែយើងអាចដោះស្រាយវិញដោយងាយថា ពាក្យទាំងឡាយដែលក្លាយមកពីបាលី សំស្ក្រឹតនេះ មិនមែនកើតឡើងតាំងពីមុនសម័យជនជាតិឥណ្ឌាចូលស្រុកខ្មែរនោះទេ ពោលគឺមុនរាជ្យព្រះបាទកៅណ្ឌិន្យ។ ពាក្យទាំងនេះសុទ្ធតែចូលមកជាមួយអារ្យធម៌ឥណ្ឌាក្នុងរវាងសតវត្សទី២ ក្រោយដែលព្រះបាទកៅណ្ឌិន្យ កសាងអាណាចក្រនគរភ្នំរួចហើយ។ ដូចនេះ ភាសាខ្មែរមិនមែនមានដើមកំណើតពីភាសាបាលី សំស្ក្រឹត ដែលជាមូលដ្ឋានលទ្ធិសាសនាផ្សេងៗដែលហូរចូលមកស្រុកខ្មែរយើងនាសម័យក្រោយនោះទេ គឺខ្មែរពិតជាមានភាសាកំណើតរបស់ខ្លួនតាំងពីយូរអង្វែងណាស់មកហើយ ប៉ុន្តែភាសានោះមិនសូវសម្បូរបែបនិងវិវត្តខ្លាំងក្លាប៉ុន្មានទេ។

### ១.៥.៣. ការវិវត្តនៃភាសាខ្មែរ

ភាសាខ្មែរមានការវិវត្តជាបីដំណាក់កាលធំៗគឺ៖

-ភាសាខ្មែរបុរាណចាប់តាំងពីកំណកំណើតដល់សតវត្សទី១៦

-ភាសាខ្មែរកណ្ដាលចាប់តាំងពីសតវត្សទី១៦ដល់សតវត្សទី១៩

-ភាសាខ្មែរទំនើបចាប់តាំងពីសតវត្សទី២០មកដល់បច្ចុប្បន្ន។

### ១.៥.៤. លក្ខណៈនៃភាសាខ្មែរ

ភាសាជាតិសាសន៍នីមួយៗមានលក្ខណៈពិសេសសម្រាប់សម្គាល់នូវភាសារៀងៗខ្លួន យ៉ាងណាមិញ ភាសាខ្មែរមានលក្ខណៈសម្គាល់ខុសប្លែកពីភាសាដទៃទៀតដូចតទៅ៖

-ការបន្លឺសំឡេងពុំមានការឡើងចុះក្នុងសំនៀង មានសំឡេងស្មើ

-មានការបង្រួមព្យាង្គច្រើនមកព្យាង្គតិច

ឧទាហរណ៍: ប្រអប់ > ប្អប់, ត្របែក> តបែក, ក្រមា > កមា, សៀវភៅ > សភៅ។ល។

-មូលភេទ អ និង អ៊ិ ចែកស្រៈជាពួក អ និង ពួក អ៊ិ ជាគូជាប់គ្នា គឺខ្យល់ អ ៖ ា ិ ី ឹ...។

ស្រៈរូបតែមួយតែកត់សូរ «អ» ផង និង«អ៊ិ» ផង គឺខ្យល់ អ៊ិ ៖ ា ិ ី ឹ ឺ ុ ូ ួ... និងខ្យល់ អ ៖ ក ខ ច ឆ...។ ព្យញ្ជនៈរូបខុសគ្នាតែកត់សូរ «អ» ផង និង«អ៊ិ» ផង ដូចជា ខ្យល់ អ៊ិ ៖ គ ឃ ជ ឈ...។

-វិធីកម្លាយពាក្យមានផ្នត់ដើមនិងផ្នត់ដែក ឧទាហរណ៍: [ប់ង] + កើត > បង្កើត (ផ្នត់ដើម), កើត + [-អំម/ណ-] > កំណើត (ផ្នត់ដែក)។

### ១.៦. ប្រភេទនៃភាសាតាមភាសាវិទ្យា

ប្រភេទភាសានៅក្នុងទីនេះ គឺការបែងចែកភាសានៅក្នុងភាសាវិទ្យាជាប្រភេទនានា ដោយផ្អែកលើអត្ថរូបសព្ទ(Morpheme) នៅក្នុងប្រភេទមួយៗ។ ការធ្វើចំណាត់ថ្នាក់ភាសាទៅតាមប្រភេទគឺជាចរន្តនៃការស្រាវជ្រាវ

ភាសាវិទ្យា ដែលចាប់កំណើតឡើងនៅដើមសតវត្សទី១៩ ហើយបានអភិវឌ្ឍឡើងនៅពាក់កណ្ដាលសតវត្សទី១៩។ ជាដំបូងឡើយការស្រាវជ្រាវនេះ ធ្វើឡើងក្នុងរូបភាពជាការស្រាវជ្រាវទៅលើចំណាត់ថ្នាក់រូបសព្ទភាសា ហើយមានបំណងកំណត់ភាពដូចគ្នានិងភាពខុសគ្នា(រចនាសម្ព័ន្ធភាសា) ដែលមានមូលដ្ឋានយ៉ាងសំខាន់និងចាំបាច់នៅក្នុងសារធាតុនៃភាសាទាំងឡាយរបស់ភាសា និងដែលមិនទាក់ទងទៅនឹងខ្សែញាតិព័ន្ធនៃភាសាទាំងឡាយនោះឡើយ។ ការធ្វើចំណាត់ថ្នាក់ភាសាផ្អែកទៅលើលំដាប់ថ្នាក់ភាសាទៅតាមសន្ទស្សន៍នានា ដែលគេលើកយកមកដើម្បីបង្ហាញឱ្យរឹតតែច្បាស់នូវលក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធភាសាទាំងនោះ (ដូចជាបង្ហាញពីរបៀបផ្សេងៗក្នុងការភ្ជាប់រូបតាជាមួយគ្នា)។

**១.៦.១. ភាសាសំយោគឬភាសាមិនមែនអ៊ីសូឡង់**

បើតាមចំណាត់ថ្នាក់ក្នុងភាសាវិទ្យា ភាសាសំយោគគឺជាប្រភេទភាសាមួយ ដែលមានអត្រារូបសព្ទច្រើនលើសលប់នៅក្នុងពាក្យនីមួយៗ។ ចំណាត់ថ្នាក់តាមបែបភាសាវិទ្យាទៅលើភាសាប្រភេទនេះ ភាគច្រើនមិនទាក់ទងទៅនឹងចំណាត់ថ្នាក់នៃការប្រើប្រាស់រូបសព្ទក្នុងពាក្យនីមួយៗនៃភាសាទាំងនោះទេ។ ដោយសារតែហេតុនេះហើយទើបគេចែកភាសាសំយោគជា ប្រភេទភាសាហ្វ៊ុយស្យុង ភាសាអាគ្លុយទីណង់ ក្នុងការបង្ហាញធាតុសំយោគនៅក្នុងភាសាប្រភេទនេះ។

ជារឿយៗភាសាសំយោគតែងតែមានលក្ខណៈផ្ទុយគ្នានឹងភាសាអ៊ីសូឡង់ជានិច្ច ដោយសារតែក្នុងធាតុទាំងឡាយក្នុងភាសាសំយោគមានការទាក់ទងបន្តគ្នា ចំណែកភាសាដែលមានលក្ខណៈសុទ្ធសាធនោះគឺជាភាសាដែលមានអត្រារូបសព្ទមួយសម្រាប់ពាក្យមួយ។

ក្នុងភាសាសំយោគ ពាក្យមានចំនួនព្យាង្គច្រើន និងមានភាពច្បាស់លាស់។ ជាទូទៅ ភាសាដែលគេច្រើនរាប់បញ្ចូលទៅក្នុងប្រភេទភាសាសំយោគនោះមាន អម្បូរភាសាឥណ្ឌូ-អឺរ៉ុប ដូចជា ភាសាក្រិក ភាសាឡាតាំង ភាសាអាល្លឺម៉ង់ ភាសាអ៊ីតាលី ភាសារុស្ស៊ី ភាសាប៉ូឡូញ ភាសាបារាំង ភាសាឆែកជាដើម ក៏ដូចភាសាមួយចំនួនទៀតនៅអាមេរិកដែលក្នុងនោះមាន ភាសាណាវ៉ាយោ ភាសាណាហាត ភាសាម៉ូហាក ភាសាកេជូ ជាដើម។

**១.៦.១.១. ភាសាអាគ្លុយទីណង់**

ភាសាអាគ្លុយទីណង់ជាប្រភេទភាសាមួយ ដែលប្រើប្រាស់យ៉ាងខ្លាំងក្លានូវការ «បិទភ្ជាប់» បានន័យថាពាក្យជាច្រើនកកើតឡើងដោយការភ្ជាប់រូបសព្ទជាមួយគ្នា។ ពាក្យថា អាគ្លុយទីណង់នេះ បង្កើតឡើងដោយលោកវីលហែម វ៉ុន ហាំបុល (Wilhem Von Humboldt) ជាភាសាវិទូនិងជាអ្នកនយោបាយអាល្លឺម៉ង់ក្នុងឆ្នាំ១៨៣៦ ក្នុងបំណងធ្វើចំណាត់ថ្នាក់ភាសាដោយយកទស្សនៈរូបសព្ទមកធ្វើជាមូលដ្ឋាន។ ពាក្យអាគ្លុយទីណង់នេះ មកពីកិរិយាសព្ទឡាតាំង «agglutinar» ប្រែថា «**ស្អិតជាមួយគ្នា**»។

ភាសាអាគ្លុយទីណង់គឺជាសមាសធាតុមួយនៃភាសាសំយោគ ជាទូទៅផ្នត់នីមួយៗ គឺជាធាតុដែលមានន័យដូចជាធាតុខ្លះមានន័យថា «ស្ដួចស្ដើងតិចតួច» បង្ហាញអតីតកាល ពហុវចនៈជាដើម ហើយផ្នត់ទាំងនេះបង្ហាញនូវព្រំប្រទល់រូបសព្ទ (មិនមែនដោយការប្រែប្រួលនៅខាងក្នុងពាក្យ ឬការប្រែប្រួលនៅក្នុងការសង្កត់សូរ ឬសៀងទេ)។ លើសពីនេះទៅទៀត អ្វីដែលរឹតតែសំខាន់ទៅទៀតនោះ នៅក្នុងភាសាអាគ្លុយទីណង់ ផ្នត់ទាំងឡាយមិនលាយចូលគ្នា ជាមួយធាតុដទៃនិងធាតុមិនអាចផ្លាស់ប្ដូរទម្រង់ ឬរូបរាងផ្នត់ទាំងនោះបានដែរ ទោះក្នុងលក្ខខណ្ឌណាក៏ដោយ។

ភាសាអាគ្លុយទីណង់នៅទ្វីបអឺរ៉ុបមានភាសាហ្វាំងឡង់ ភាសាអេស្តូនី និងភាសាហុងគ្រី។ នៅអាមេរិកមានភាសាណាហាតជាដើម។ នៅអាស៊ីមានភាសាជប៉ុន តួកគី តាមីល កូរ៉េ ជាដើម។ ឧទាហរណ៍ពីលក្ខណៈអាគ្លុយទីណង់ក្នុងភាសាជប៉ុន tabetakunakatta ប្រែថា «(ជាប្រធាន) មានន័យថា មិនចង់ធីអាហារ» ការបំបែកកិរិយាសព្ទក្នុងអតីតកាល។ លក្ខណៈអាគ្លុយទីណង់ក្នុងភាសាតួកគី avustralyaliasttiramdiklarimiz dan ប្រែថា

«មនុស្សម្នាក់ក្នុងចំណោមពួកនោះ យើងមិនអាចថា មានលក្ខណៈដូចជនជាតិអូស្ត្រាលីបានឡើយ»។ ពាក្យខាងលើនេះ គេត្រូវអានដូចជាពាក្យមួយម៉ាត់នៅក្នុងភាសាតួកគី។ ភាសាតាមីល sevvaanam ប្រែថា «មេឃក្រហម»។

### ១.៦.១.២. ភាសាហ្វ៊ុយស្យុង

ហ្វ៊ុយស្យុងមានន័យថា «រលាយបញ្ចូលគ្នា»។ ភាសាទាំងនេះនៅពេលខ្លះបង្រួមផ្នត់ទាំងឡាយដោយការច្របាច់បញ្ចូលគ្នា ហើយផ្នត់មួយអាចមានន័យច្រើន។ ឧទាហរណ៍ ក្នុងភាសាអេស្ប៉ាញ ពាក្យថា «comi» ប្រែថា «ខ្ញុំ បានបរិភោគបាយ» គេឃើញថា ផ្នត់ចុងមានន័យថាជាបែបផែនចង្អុលបង្ហាញផង មានន័យថាជាកត្តុវចកៈផង បង្ហាញកាល (អតីតកាល)ផង បង្ហាញពីបុរសទីមួយឯកវចនៈផង និងបង្ហាញពីទិដ្ឋភាពសម្រេចផង ក៏ដូចជាពាក្យ noeay [poyedu] ក្នុងភាសារុស្ស៊ី ប្រែថា «ខ្ញុំនឹងទៅ» ក្នុងនេះផ្នត់ដើម [po-] បង្ហាញពីទិដ្ឋភាពសម្រេចនៃកិរិយាសព្ទ [it'i] ឯផ្នត់ចុង[-u] បង្ហាញអនាគតកាលផង បង្ហាញបុរសទីមួយឯកវចនៈផង។

### ១.៦.២. ភាសាវិភាគឬភាសាអ៊ីសូឡង់

ភាសាវិភាគ បើយោលទៅតាមប្រភេទរូបសព្ទ គឺជាភាសាទាំងឡាយណាដែលក្នុងនោះមានរូបសព្ទតែមួយបានន័យថា រូបសព្ទមួយស្មើនឹងពាក្យមួយ។

ជាទូទៅ ភាសាវិភាគជាភាសាភាគច្រើននៅអាស៊ីអាគ្នេយ៍ដូចជាភាសាវៀតណាមនិងភាសាចិនបុរាណ។ ភាសាភាគច្រើននៅលើដីគោកនៃតំបន់អាស៊ីអាគ្នេយ៍ជាភាសាវិភាគ លើកលែងតែភាសាម៉ាឡាយូ។ តំបន់ដីគោកនៃតំបន់អាស៊ីអាគ្នេយ៍ជាទីតាំងនៃក្រុមភាសាវិភាគនៃអាស៊ីខាងកើត ដែលក្នុងនោះមានក្រុមភាសាទីបេត៍-ភូមា តៃ-កាដៃ ហ្មុង-មេន និង ខ្មែរ-មន។ មានភាសាអម្បូរអូស្ត្រូនេស៊ីមួយចំនួនដែលមាននៅក្នុងអម្បូរនេះ។ ភាសាភូមា ថៃ ខ្មែរ ឡាវ និងវៀតណាមជាភាសាវិភាគសំខាន់ ដែលគេនិយាយនៅតំបន់ដីគោកនៃតំបន់អាស៊ីអាគ្នេយ៍ (នៅ ស៊ុន, ២០១០: ៦)។

### ១.៧. មុខងារនៃភាសា

មុខងារនៃភាសាត្រូវបានបែងចែកទៅតាមគោលបំណង តួនាទី និងបម្រើបម្រាស់របស់វា។ ក្នុងចំណោមនោះ ភាសាមានមុខងារសំខាន់ៗដូចខាងក្រោមនេះ៖

### ១.៧.១. មុខងារផ្ដល់ព័ត៌មាន

មុខងារផ្ដល់ព័ត៌មាន គឺសម្រាប់ទំនាក់ទំនងព័ត៌មាន។ មុខងារផ្ដល់ព័ត៌មានអះអាង ឬបដិសេធសេចក្ដីអះអាង ដូចជានៅក្នុងវិទ្យាសាស្ត្រ ឬពំនោលលើកឡើងពីហេតុការណ៍។ ប្រព័ន្ធមុខងារនេះ ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីពិភព ឬទស្សនៈអំពីវា ឧទាហរណ៍ ថាតើកិច្ចការដែលគេអះអាងឡើងនោះបានសម្រេច ឬមិនបាន ហើយអ្វីដែលនាំឱ្យវាអាចធ្វើទៅបាន។ ប្រយោគទាំងនេះ មានគុណតម្លៃពិតប្រាកដ ពោលគឺថា ប្រយោគត្រឹមត្រូវ ឬមិនត្រឹមត្រូវ (ជាការពិតណាស់គឺទទួលស្គាល់ ដែលយើងមិនអាចដឹងថា អ្វីទៅជាគុណតម្លៃនៃភាសានោះទេ)។ ហេតុដូច្នេះ ប្រយោគទាំងនោះមានសារៈសំខាន់ផ្នែកតក្កវិទ្យា។

### ១.៧.២. មុខងារសម្ដែងផ្លូវចិត្ត

មុខងារសម្ដែងផ្លូវចិត្ត បញ្ជាក់ពីស្ថានអារម្មណ៍ ឬអាកប្បកិរិយាណាមួយដែលអ្នកនិពន្ធ(ឬអ្នកនិយាយ) ប្រធានបទ ឬខាបអន្ទងដួងព្រលឹងនៅក្នុងអារម្មណ៍អ្នកអាន (ឬអ្នកស្ដាប់)។ កំណាព្យនិងអក្សរសិល្ប៍ ស្ថិតនៅក្នុងចំណោមឧទាហរណ៍ដ៏ល្អៗបំផុត ប៉ុន្តែក្នុងបណ្ដាបញ្ហាអស់ទាំងនោះ ប្រហែលជាសំនួនវោហារភាសាធម្មតា គឺជាការបង្ហាញនូវការរំជួលចិត្ត អារម្មណ៍ ឬអាកប្បកិរិយា។ កត្តាពីរសំខាន់នៃមុខងារនេះ ត្រូវបានកត់សម្គាល់ជាទូទៅ៖ (១) ការខាបអន្ទងអារម្មណ៍យ៉ាងពិតប្រាកដ (២) ការបង្ហាញអារម្មណ៍។ សំនួនបង្ហាញអារម្មណ៍ អាចចាត់ទុកជាកត្តាមួយសំខាន់បំផុត មិនថាវាត្រឹមត្រូវ ឬមិនត្រឹមត្រូវក្ដី។

### ១.៧.៣. មុខងារបង្គាប់បញ្ជា

ភាសាដែលប្រើសម្រាប់បង្ហាញគោលបំណងចំពោះបុព្វហេតុ (ឬការបង្ការ) សកម្មភាពដែលស្ដែងឡើង។ មុខងារផ្ទាល់របស់ភាសា ត្រូវបានរកឃើញជាទូទៅបំផុតនៅក្នុងបញ្ជា ឬសំណើ។ ភាសាផ្ទាល់ មិនត្រូវបានពិចារណាថា ត្រូវ ឬខុស (ទោះបីជាតក្កវិទ្យានានានៃបទបញ្ជាត្រូវបានបង្កើតឡើងក៏ដោយ)។ ឧទាហរណ៍នៃមុខងារនេះ ដូចជា «បិទបង្អួច» ប្រយោគ «អ្នកកំពុងជក់បារីនៅក្នុងបរិវេណដែលហាមមិនឱ្យជក់បារី» ថ្វីត្បិតថាជាការប្រកាស អាចត្រូវបានប្រើដើម្បីបង្ហាញអត្ថន័យមួយថា «ហាមជក់បារីនៅក្នុងបរិវេណនេះ»។

## ២. ភាសាវិទ្យា

### ១. និយមន័យ

ភាសាវិទ្យាគឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីភាសារបស់មនុស្ស។ ភាសាវិទ្យាត្រូវបានបែងចែកជាបីផ្នែកធំៗគឺ ទម្រង់ភាសា ន័យភាសា និងភាសានៅក្នុងបរិបទ។ សកម្មភាពនានាដែលគេបានស្គាល់ដំបូងបង្អស់គឺភាសាវិទ្យាពិពណ៌នា បានត្រូវកំណត់ថា មាននៅក្នុងក្បួនវេយ្យាករណ៍សំស្ក្រឹតរបស់លោក បាណិនី (Pāṇini) រវាង៥០០ឆ្នាំ មុន គ.ស. ជាមួយនឹងការវិភាគទៅលើភាសាសំស្ក្រឹត។ ការសិក្សាន័យរបស់ភាសា គឺផ្តោតទៅលើបែបបទដែលភាសាប្រើទម្រង់តក្កវិទ្យា ហើយនិងសេចក្ដីយោងនៃលោកៈ ដើម្បីនាំទៅរកន័យ ដំណើរការន័យនិងការកំណត់ន័យ ព្រមទាំងចាត់ចែងនិងដោះស្រាយនូវបញ្ហាន័យពាំគ្រណោតនៅក្នុងភាសា។ អនុវិស័យនេះ គ្របដណ្ដប់លើន័យវិទ្យា (ដោយបង្ហាញថា ន័យរបស់ភាសាកើតឡើងពីពាក្យនិងបញ្ញត្តិ) និងការណ៍វិទ្យា ដោយបង្ហាញថា ន័យរបស់ភាសាកើតឡើងអាស្រ័យបរិបទ។

ភាសាវិទ្យានៅក្នុងបរិបទដ៏ទូលំទូលាយរបស់ខ្លួន រួមបញ្ចូលនូវ ភាសាវិទ្យាវិវត្តដែលពិចារណាលើប្រភពដើមនៃភាសា។ ភាសាវិទ្យាប្រវត្តិដែលស្វែងយល់ពីបម្រែបម្រួលនៃភាសា។ សង្គមភាសាវិទ្យាដែលពិនិត្យមើលទៅលើទំនាក់ទំនងរវាងការប្រែប្រួលនៃភាសានិងរចនាសម្ព័ន្ធសង្គម។ ចិត្តភាសាវិទ្យាដែលស្វែងយល់ពីសេចក្ដីតំណាងនិងមុខងារនៃភាសានៅក្នុងចិត្ត។ ប្រព័ន្ធប្រសាទភាសាវិទ្យាដែលពិនិត្យលើដំណើរការភាសានៅក្នុងខួរក្បាល។ ការចាប់យកភាសាដែលស្វែងយល់ពីរបៀបរបស់កុមារនិងមនុស្សពេញវ័យទទួលយកភាសា។ ការវិភាគកថាដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃអត្ថបទនិងការសន្ទនា។

ថ្វីត្បិតថា ភាសាវិទ្យាគឺជាការសិក្សាបែបវិទ្យាសាស្ត្រទៅលើភាសាក្ដី អត្រានៃវិធានដ៏ចម្រុងៗផ្សេងទៀតក៏ជាប់ពាក់ព័ន្ធនឹងភាសា ហើយនិងបំណែងចែកភាសាផងដែរ។ ជាក់ស្ដែង សញ្ញាវិទ្យាគឺជាការសិក្សាទូទៅនៃសញ្ញានិងនិមិត្តសញ្ញានៅក្នុងនិងក្រៅភាសា។ អ្នកទ្រឹស្ដីខាងអក្សរសិល្ប៍ សិក្សាអំពីការប្រើប្រាស់ភាសានៅក្នុងអត្ថបទអក្សរសិល្ប៍។ បន្ថែមពីលើនេះ ភាសាវិទ្យា ប្រើប្រាស់ធនធានដែលមានស្រាប់និងផ្នែកពាក់ព័ន្ធផ្សេងទៀតដែលប្រឈមគ្នា ដូចជាអាគូស្ទិក នរវិទ្យា ជីវវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ កាយវិភាគសាស្ត្រមនុស្ស ព័ត៌មានវិទ្យា វិទ្យាសាស្ត្រប្រព័ន្ធប្រសាទ ទស្សនវិជ្ជា ចិត្តវិទ្យា សង្គមវិទ្យា និងភាសារោគសាស្ត្រ។

ភាសាវិទ្យាគឺជាការសិក្សាលើភាសាហើយមិនសំដៅចំពោះភាសាពិសេសណាមួយនោះទេ ប៉ុន្តែវាជាប្រព័ន្ធនៃទំនាក់ទំនងរបស់មនុស្ស។ បញ្ហាចម្បងៗមួយចំនួនដែលពាក់ព័ន្ធនឹងផ្នែកនេះមាន៖

-អ្វីជាភាសា? តើភាសាផ្គុំឡើងដោយរបៀបណា?

-តើគេវិភាគភាសាដោយរបៀបណា? តើគេស្វែងយល់និងពិសោធវាដោយរបៀបណា?

-តើភាសាត្រូវបានផ្ទុកនិងធ្វើឱ្យដំណើរការនៅតំបន់ណានៃខួរក្បាល? តើគេរៀនវាដោយរបៀបណា?

-តើអ្វីដែលគ្រប់ភាសាទាំងអស់ រួមទាំងប្រព័ន្ធគ្មានសូរសំឡេងនៃការទំនាក់ទំនង(ឧទាហរណ៍ ដូចជាភាសាសរសេរនិងភាសាសញ្ញា) មានលក្ខណៈដូចគ្នា? តើព័ត៌មានទាំងនេះបង្ហាញឱ្យយើងយល់ពីពុទ្ធិរបស់មនុស្សយ៉ាងដូចម្ដេច?

-តើភាសាបានកើតឡើងយ៉ាងដូចម្ដេច? តើភាសាមានលក្ខណៈដូចគ្នាទៅនឹងការទំនាក់ទំនងរបស់សត្វយ៉ាងណាខ្លះ? តើមានចំណុចខុសគ្នាអ្វីខ្លះ?

-តើមានអម្បូរភាសាខុសៗគ្នាចំនួនប៉ុន្មាននៅក្នុងចំណោមភាសាចំនួន៦០០០ ឬភាសាដែលគេបានស្គាល់នាបច្ចុប្បន្ននេះ? តើភាសាដំបូងៗមានប្រភពចេញមកពីណា? តើភាសាទាំងនោះមានបម្រែបម្រួលយ៉ាងដូចម្ដេចពីពេលមួយទៅពេលមួយ?

-តើបម្រែបម្រួលនៃគ្រាមភាសានិងសង្គមបង្ហាញឱ្យយើងដឹងពីការប្រើប្រាស់នៃភាសាយ៉ាងដូចម្ដេច? តើភាពប្រាសគ្នានេះបានជះឥទ្ធិពលលើបញ្ហាគោលនយោបាយសង្គម នយោបាយ និងការអប់រំយ៉ាងដូចម្ដេច?

-តើអ្វីជាទំនាក់ទំនងរវាងភាសានិងវប្បធម៌? ភាសានិងគំនិត?

## ២.២. ប្រវត្តិភាសាវិទ្យា

### ២.២.១. មិនមែនប្រពៃណីបស្ចិមប្រទេស

ការពិចារណានិងការស្វែងយល់ពីភាសាវិទ្យា បានកើតមានឡើងមកយូរហើយ ហើយបានប្រព្រឹត្តទៅនៅក្នុងសង្គមមួយចំនួនតូច ដើម្បីពង្រីកបន្ថែមលើការសិក្សាភាសាមេសូប៉ូតាមៀ (Mesopotamian) ចិន (Chinese) និងអារ៉ាប់ (Arabic) ប៉ុន្តែផ្ដោតសំខាន់លើវេយ្យាករណ៍។ ប្រព្រឹត្តកម្មរបស់ពួកគេមានភាពជំពាក់ជំពិនគ្នាយ៉ាងខ្លាំងនៅក្នុងភាពប្លែកគ្នានានានៃភាសាទាំងនោះ ហើយគេបានស្គាល់តិចតួចចំពោះពិភពអឺរ៉ុបរហូតមកទល់នឹងបច្ចុប្បន្ន ដែលកត្តាទាំងនោះមិនបានជះឥទ្ធិពលជាដុំកំភួនលើប្រពៃណីភាសានៃបស្ចិមប្រទេសនោះទេ។ ភាសាវិទ្យាចិននិងការសិក្សានិរុត្តិសាស្ត្របានត្រឡប់ថយក្រោយអស់រយៈកាលជាងពីរសហស្សវត្សរ៍ ប៉ុន្តែចំណាប់អារម្មណ៍នៃអ្នកសិក្សាទាំងនោះ បានផ្ដោតជាសំខាន់បំផុតលើសូរវិទ្យា ការសរសេរ និងវចនានុក្រមវិទ្យា។ ការពិចារណារបស់ពួកគេទៅលើបញ្ហាវេយ្យាករណ៍បានជំពាក់ជំពិននឹងការសិក្សានៃតក្កវិទ្យាយ៉ាងខ្លាំង។

ជាការពិតណាស់ វេយ្យាករណ៍ប្រពៃណីដែលមិនមែនជារបស់បស្ចិមប្រទេស គឺមានការចាប់អារម្មណ៍បំផុត ហើយប្រភពដើមនិងឯករាជ្យបំផុតនោះគឺនៅឥណ្ឌា ដែលមានអាយុកាលប្រមាណជាជាងពីរសហស្សវត្សរ៍មកហើយ និងចាប់ផ្ដើមជាមួយនឹងក្បួនវេយ្យាករណ៍របស់លោក **បាណីនី** (Pāṇini) នាសតវត្សរ៍ទី៥មុនគ.ស.។ វាមានវិធីសំខាន់ៗបីដែលប្រពៃណីភាសាសំស្ក្រឹតបានជះឥទ្ធិពលលើអ្នកសិក្សាភាសាវិទ្យាទំនើប។ នៅពេលដែលភាសាសំស្ក្រឹតបានក្លាយជាទីចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការសិក្សារបស់ភាសាវិទូឬអ្នកភាសាវិទ្យានៃបស្ចិមប្រទេសរួចមក ដំណោះស្រាយនៃការប្រៀបធៀបវេយ្យាករណ៍ឥណ្ឌូ-អឺរ៉ុប បានលេចចេញឡើង ហើយមូលដ្ឋានបញ្ញត្តិនានា ត្រូវបានលាតត្រដាងទូទាំងសតវត្សរ៍ទី១៩ លើការប្រៀបធៀបផ្នែកនិរុត្តិសាស្ត្រនិងភាសាវិទ្យាប្រវត្តិ។ ប៉ុន្តែសម្រាប់បញ្ហានេះភាសាសំស្ក្រឹតបានក្លាយជាផ្នែកមួយដ៏សាមញ្ញនៃទិន្នន័យទាំងអស់នេះ។ ការសិក្សាវេយ្យាករណ៍ឥណ្ឌា បានធ្វើឡើងដោយប្រយោល។ ទោះជាយ៉ាងណាក៏ដោយ អ្នកធ្វើការនាសតវត្សរ៍ទី១៩ បានទទួលស្គាល់ថា ប្រពៃណីកំណើតនៃសូរវិទ្យានៃឥណ្ឌាបុរាណ បានក្លាយជាអាទិភាពចម្បងជាងគេសម្រាប់ចំណេះដឹងនាបស្ចិមប្រទេស ហើយសូរវិទ្យានេះ បានបង្ហាញលទ្ធផលដ៏សំខាន់សម្រាប់ការរីកចម្រើនវិទ្យាសាស្ត្រនៃការសិក្សាពីសូរវិទ្យានៅពិភពបស្ចិម។ ចំណុចទីបី វាមាននៅក្នុងវិធាន ឬនិយមន័យ (សូត្រា) របស់ **បាណីនី** នូវភាពច្បាស់លាស់គួរជាទីចាប់អារម្មណ៍ និងទិន្នន័យនៃការជ្រៀតចូលវេយ្យាករណ៍សំស្ក្រឹត។ សំណង់ប្រយោគ កន្សោមនាម និងចំណុចប្រហាក់ប្រហែលគ្នានេះ ត្រូវបានពន្យល់តាមរយៈវិធាននៃលំដាប់ដែលមានដំណើរការលើការវិភាគសម្ព័ន្ធ ប្រហាក់ប្រហែលគ្នាក្នុងទ្រឹស្ដីសម័យទំនើបផងដែរ។ ក្នុងខណៈពេលនៃការគិតវិភាគ កិច្ចការវេយ្យាករណ៍ឥណ្ឌាដែលប្រកបដោយទស្សនវិស័យនេះ បានកែលម្អដល់អ្នកនិយមទ្រឹស្ដីភាសាវិទ្យានាសតវត្សរ៍ទី២០។ ការសិក្សានៃតក្កវិទ្យាឥណ្ឌា ក្នុងទំនាក់ទំនងទៅនឹងក្បួនវេយ្យាករណ៍របស់ បាណីនី ស្របជាមួយនឹងតក្កវិទ្យារបស់អារីស្តូត និងតក្កវិទ្យាបស្ចិមប្រទេសក្នុងទំនាក់ទំនងទៅនឹងវេយ្យាករណ៍ក្រិក ហើយនិងដូនតារបស់គេអាចនាំមកនូវពន្លឺផ្នែកបញ្ញាស្មារតី។






លោក បាណីនី , ប្រភព៖ https://en.wikipedia.org/wiki/Pāṇini

ចំណែកឯ ការសិក្សាពីភាសាចិនបុរាណដែលមានមុខជំនាញដោយឡែកពីគ្នានោះ អាចត្រូវបានគេឱ្យឈ្មោះថា វេយ្យាករណ៍ដ៏កម្រដែលបានចាក់ឫសឡើង។ នៅតំណាបុរាណការវិភាគអត្ថបទនៃមុខវិជ្ជានេះបានរីកដុះដាលភ្លាមស្របនឹងការរីកចម្រើននៃវិទ្យាសាស្ត្រដទៃទៀត។ ទោះបីជាយ៉ាងនេះក្តី ការសិក្សាពីវេយ្យាករណ៍សំស្ក្រឹត ពិតជាអាចមានគោលបំណងស្នូលក្នុងការរក្សាអត្ថបទវេទដ៏ពិសិដ្ឋ ហើយការពិចារណារបស់ពួកគេបានត្រឹមត្រូវនិងគ្មានភាពសៅហ្មង។

## ២.២.២. បុរាណកាលនៃក្រិកនិងរ៉ូម៉ាំង

ការលេចឡើងនៃការសិក្សាវេយ្យាករណ៍ក្នុងភាសាក្រិក មានភាពច្បាស់លាស់តិចជាង ភាពជំពាក់ជំពិន ហើយប្រធានបទមានលក្ខណៈសាំញ៉ាំជាងការសន្មត។ ក្នុងបញ្ហានេះ មានតែខ្សែវិញផ្លុងប្រទាក់ក្រឡាគ្នាតែប៉ុណ្ណោះដែលអាចយកមកធ្វើជាបែបបទគំរូបាន។ ពាក្យ «សិល្បៈនៃអក្សរ» មានការពិចារណាចំនួនពីរ។ វាផ្តល់ខ្លឹមសារនៃការលើកគុណតម្លៃនៃអក្សរ បម្រើបម្រាស់សញ្ញា និងកាព្យសាស្ត្រ ហើយបន្ថែមពីលើនេះ ក្នុងបញ្ហានេះវាជាមុខវិជ្ជាមួយដែលពោរពេញដោយកត្តាអរូបី។ វាអាចកំណត់ផងដែរថា ជាបំណិននៃអក្ខរកម្មវិទ្យា (ការរៀននិងបង្រៀនអក្សរ) ដែលមានបញ្ចូលទាំងការអនុវត្តជាក់ស្តែងនៃគុរុកោសល្យផង។ ផ្នែកមួយនៃមុខវិជ្ជានេះបានក្លាយជាការសិក្សា «វេយ្យាករណ៍» ត្រូវបានអនុវត្តដោយច្បាស់លាស់ ជាពិសេសត្រូវបានឱ្យតម្លៃជាងគេបើប្រៀបធៀបជាមួយមុខវិជ្ជាផ្សេងៗ។ ការវិវត្តជាច្រើនដែលទាក់ទងនឹងទ្រឹស្តីវេយ្យាករណ៍បានចេញចាកពីទស្សនវិជ្ជានិងការរិះគន់ ហើយការវិវត្តទាំងនេះ មានភាពទ្វេដងនៃការតាក់តែងស្នាដៃ ដែលបានកើតមានឡើងនិងជាប់ទាក់ទងគ្នា។ ទស្សនវិជ្ជាក្រិកជាច្រើន បានស្ថិតនៅក្រោមការត្រួតត្រាជាមួយនឹងភាពខុសគ្នារវាងកត្តាពីរ គឺវត្តមានភាពនៃកត្តាកើតឡើងដោយ «ធម្មជាតិ» និងវត្តមានភាពនៃកត្តាដែលកើតចេញពីគំនិត «បង្កើតថ្មី»។ ដូច្នេះនៅក្នុងភាសា វាជាធម្មតាដែលត្រូវពន្យល់នូវពាក្យនិងទម្រង់ដែលបញ្ញត្តិដោយធម្មជាតិ (តាមការគ្រាប់សូរ ឬដោយការគ្រាប់តាមសំឡេងធម្មជាតិ) ឬបានមកអំពីការបង្កើតថ្មីនៅក្នុងសង្គម។ ជម្លោះដែលកើតឡើងអាស្រ័យដោយប្រភពនៃភាសានិងន័យនៃភាសា បានបើកផ្លូវឱ្យមានការរីកចម្រើននៃការខ្វែងយោបល់គ្នារវាងទិដ្ឋភាពនៃ «អ្នកប្រៀបធៀប» ដែលនិយមក្រឡេកមើលភាសាក្នុងលក្ខណៈជាកម្មសិទ្ធិនៃនិយតភាពពិសេសមួយជាលទ្ធផលស្រដៀងៗគ្នា។ ការបង្កើតថ្មីបានផ្តល់ឱ្យមានទស្សនៈនៃ «អ្នកចូលចិត្តអ្វីដែលប្លែកក្នែក» ដែលចង្អុលបង្ហាញនូវកង្វះខាតនៃភាសាថា ជាភាពសាមញ្ញមួយដូចទៅនឹងការច្នៃទម្រង់លើភាពមិនទៀងទាត់ដែលមិនអាចគេចរួចនៃធម្មជាតិ។ ទោះជាយ៉ាងនេះក្តី ស្ថានភាពទាំងនេះមានលក្ខណៈសាំញ៉ាំជាងអ្វីដែលគេបានលើកឡើងនេះទៅទៀត។ ឧទាហរណ៍ វាហាក់ដូចជាអ្នកចូលចិត្តអ្វីដែលប្លែកក្នុងចំណោមអ្នកដែលពូកែអត់ធ្មត់ បានជឿទៅលើគុណភាពដែលមិនសមហេតុផលនៃភាសា ក្នុងបំណងជាក់លាក់ដើម្បីអះអាងថា ភាសាពិតជាមិនបានឆ្លុះបញ្ចាំងពីធម្មជាតិ។ ក្នុងករណីខ្លះ វិធីដែលអ្នកចូលចិត្តអ្វីដែលប្លែកនៅក្នុងកណ្តាប់ដៃនៃអ្នកដែលពូកែអត់ធ្មត់ បាននាំឱ្យក្បួនវេយ្យាករណ៍មានផលចំណេញ ក្នុងការងារផ្នែកតក្កវិទ្យានិង

វោហារសព្ទរបស់ពួកគេ។ កត្តានេះបានញ៉ាំងឱ្យមានភាពខុសគ្នាដែលនៅក្នុងទ្រឹស្តីទំនើប ត្រូវបានបង្កើតឡើងជាមួយនឹងវាក្យសព្ទ ន័យករ (អ្វីដែលធ្វើឱ្យយើងដឹង) ន័យបញ្ញត្តិ (អ្វីដែលត្រូវបានបង្ហាញឱ្យដឹង) ឬអ្វីមួយដែលខុសប្លែកគ្នានិងសាំញ៉ាំច្រើនជាងមុន ជាមួយនឹងសំនួននិងខ្លឹមសារ ហើយវាលាតត្រដាងនូវមូលដ្ឋានទ្រឹស្តីទំនើបនៃការផ្លាស់ប្តូរពាក្យ ទោះជាគ្មានមធ្យោបាយណាអាចដោះស្រាយជាមួយនឹងភាពនឿយណាយនិងការរិះគន់ដែលធ្វើឡើងចំៗបានតាមទាន់ពីសំណាក់វេយ្យាករណ៍វិទូទាំងឡាយនៃភាសាសំស្ក្រឹត។

ក្រុមអាឡិចហ្សង់ឌ័រ (Alexandrians) ជាអ្នកប្រៀបធៀបដែលបានធ្វើកិច្ចការយ៉ាងច្រើនលើការរិះគន់ផ្នែកអក្សរសិល្ប៍និងអត្ថបទនិរុត្តិសាស្ត្រ បានបំពេញចប់សព្វគ្រប់នូវការរីកចម្រើននៃវេយ្យាករណ៍ប្រពៃណីរបស់ភាសាក្រិកបុរាណ។ ឌីយូនីស៊ីស ត្រាស (Dionysius Thrax)ដែលជាអ្នកវេយ្យាករណ៍របស់ក្រិកនៅសតវត្សទី២ បានបង្កើតប្រព័ន្ធវេយ្យាករណ៍ប្រពៃណីដំបូងបំផុតនៃបណ្តាបស្ចិមប្រទេស។ ប្រព័ន្ធវេយ្យាករណ៍នេះ ក៏បានដោះស្រាយជាមួយនឹងរូបសព្ទរបស់ពាក្យ។ ការសិក្សានៃសម្ព័ន្ធល្បះ ត្រូវតែចាំឈ្មោះលោក អាប៉ូឡូនីស ឌីស្កូឡុស (Apollonius Dyscolus) ដែលជាអ្នកវេយ្យាករណ៍របស់ក្រិកផងដែរនាសតវត្សទី២នៃគ.ស.។ ឌីយូនីស៊ីស (Dionysius) បានហៅវេយ្យាករណ៍ថា «អ្នកជ្រួតជ្រាបជាមួយនឹងការសង្កេតលើអ្វីដែលបន្លឺឡើងដោយកវីនិងអ្នកនិពន្ធ» ដោយការប្រើប្រាស់នូវខ្លឹមសារនៃពាក្យប្លែកពីធម្មតា ពោលគឺវាចេញឆ្ងាយពីអ្វីដែលគេហៅថា «វិទ្យាសាស្ត្រ»។ គោលបំណងដែលមានលំនាំតាមក្រុមអាឡិចហ្សង់ឌ័រ (Alexandrian) របស់គាត់ត្រូវបានលើកឡើងនៅក្នុងក្បាលទំព័រនៃស្នាដៃរបស់លោក៖ ការបញ្ចេញសំឡេង ភាសាអត្ថបដិរូបនៃកាព្យ ពាក្យពិបាក ខ្លឹមសារជាក់ស្តែង និងខ្លឹមសារខាងក្នុងនៃពាក្យការតាំងបង្ហាញថ្នាក់ទម្រង់ពាក្យ និងការរិះគន់អក្សរសិល្ប៍។ ឌីយូនីស៊ីស (Dionysius) កំណត់និយមន័យល្បះថា ជាធាតុនៃវិចារណញ្ញាណឬគំនិត ប៉ុន្តែវាគឺជាការពិបាកក្នុងការបកស្រាយនិយមន័យរបស់គាត់ណាស់។



ប្រភព៖https://www.google.com/search?q=Dionysius

ជនជាតិរ៉ូម៉ាំងដែលផ្តោតតែទៅលើការត្រាប់តាមគ្នា ហើយពួកគេមិនមានមូលដ្ឋានរឹងមាំចំពោះភាពប្រហាក់ប្រហែលគ្នានៃភាសារបស់ពួកគេទេ ការងាររួមរបស់ក្រិកមិនមានសារៈសំខាន់ចំពោះអ្នកបង្កើតក្បួនមុនៗទេ ប៉ុន្តែមានសារៈសំខាន់ក្នុងនាមជាអ្នកផ្ទេរក្បួនទៅវិញ។ លោក អេលីស ដូណាទុស (Aelius Donatus) ដែលជាអ្នកវេយ្យាករណ៍របស់រ៉ូម៉ាំងនាសតវត្សទី៤នៃគ.ស.និងលោក ព្រីសៀន (Priscian) ជាជនជាតិអាហ្វ្រិកនិងជាអ្នកជំនាញវេយ្យាករណ៍ឡាតាំងនាសតវត្សទី៦ និងបក្សពួករបស់គាត់ មានលក្ខណៈប្រព័ន្ធច្បាស់លាស់ជាងប្រព័ន្ធភាសាក្រិក ប៉ុន្តែនាពេលនោះ វាជាអតីតកាលពិសេសជាងក្បួនមុនៗ។ យោងទៅតាមចំណុចនេះ ជំនាញដែលសំខាន់នាពេលនោះ គេឱ្យឈ្មោះថា វេយ្យាករណ៍ ពោលគឺជាការរួមបញ្ចូលនៃការសង្កេត ទាំងផ្នែកទ្រឹស្តីនិងអនុវត្តន៍ ដោយតក្កវិទ្យា ជាតិពន្ធុវិទ្យា វោហារសព្ទ ទស្សនវិជ្ជាវែកញែក កំណាព្យ/ពាក្យកាព្យ និងការរិះគន់អក្សរសិល្ប៍ជាដើម។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញសម័យទំនើបនៅតែចែករំលែកនូវក្តីបារម្ភនិងចំណាប់អារម្មណ៍របស់គេផងដែរ។ អ្នកចូលចិត្តអ្វីដែលប្លែក ដែលផ្តល់ស្មារតីលើភាពមិនទៀងទាត់នៃផ្ទៃខាងក្រៅ ហើយមើលរំលងនូវភាពទៀងទាត់ (ក្នុងខណៈដែលអ្នកមិនខ្វល់ពីអ្វីសោះបានស្វែងរកនៅក្នុងផ្នែកតក្កវិទ្យា) បានចាក់ឫសទៅក្នុងបណ្តាអ្នកប្រាជ្ញនៃសាលាសម្រាប់អ្នកកែប្រែ។ ចំណែកអ្នកប្រៀបធៀបនិរុត្តិសាស្ត្រជាមួយបំណែកពាក្យដែលមានសណ្ឋានទៀងទាត់ បង្ហាញទំនាក់ទំនងជាសាច់ញាតិយ៉ាងជិតស្និទ្ធអំពីព្រលឹង នៃសាលាទំនើបរបស់អ្នកទ្រឹស្តីវេយ្យាករណ៍ទម្រង់និយម (ឬការរៀបអក្ខរក្រមឬរៀបចំសទ្ទានុក្រមន័យ)។

### ២.២.៣. មជ្ឈិមសម័យអឺរ៉ុប

វាជាការពិត ដែលបង្ហាញឱ្យឃើញថាការរីកចម្រើនវិស័យវេយ្យាករណ៍ក្នុងអំឡុងមជ្ឈិមសម័យ បង្កើតឱ្យមានភាពស្រពិចស្រពិលមួយក្នុងចំណោមភាពស្រពិចស្រពិលជាច្រើនលើមុខជំនាញភាសាវិទ្យា។ វាជាការពិបាកក្នុងការបង្ហាញថា អំឡុងពេលនេះពិតជាមានទំនាក់ទំនងទៅនឹងអំឡុងពេលដទៃទៀត និងចំណាប់អារម្មណ៍នៃសម័យទំនើបណាស់ ពីព្រោះថា ការចាប់អារម្មណ៍នោះមានតិចតួចពេក ជាហេតុនាំឱ្យមានការវិភាគតែមួយប៉ុណ្ណោះដែលសមស្រប។ នាដើមទសវត្សឆ្នាំ១៩៧០ មុខជំនាញដែលគេបានស្គាល់ថា ជាអភិប្រាយវេយ្យាករណ៍ មិនទាន់ត្រូវបានធ្វើឡើងពេញលេញនៅក្នុងការសិក្សាស្រាវជ្រាវសម័យទំនើបនៅឡើយទេ ហេតុដូច្នេះហើយសូម្បីការសិក្សាពង្រីកជំនាញនេះពិតប្រាកដ ក៏ពុំទាន់បានធ្វើការវែកញែកច្បាស់លាស់គួរឱ្យទុកចិត្តនៅឡើយដែរ។ កិច្ចការទាំងនេះត្រូវតែវិភាគនិងសិក្សានៅក្នុងពន្លឺនៃការសិក្សានៃមជ្ឈិមសម័យ ជាពិសេស ការសិក្សានៅសាលាទស្សនវិជ្ជាដែលមានចរន្តដំណើរការនាពេលនោះ ដើម្បីស្វែងយល់នូវគុណតម្លៃមូលដ្ឋានពិតប្រាកដរបស់វា។

មុខវិជ្ជាភាសាវិទ្យា ស្ទើរតែត្រូវបានគេទុកចោលទាំងស្រុងនៅក្នុងអំឡុងពេលនេះ។ សិស្ស/និស្សិតផ្នែកវេយ្យាករណ៍ បានប៉ុនប៉ងក្រឡេកមើលនូវកត្តាចម្បងបំផុតនៅក្នុងមុខវិជ្ជារបស់គេ គឺសមិទ្ធផលនៃភាសាក្រិក ការរីកចម្រើននៃបុនសម័យ ការលូតលាស់ជាប្រចាំនៃការសិក្សាទ្រឹស្តី និងការរកឃើញជាថ្មីនៃការសិក្សា (ដែលនាំទៅរកប្រពៃណីសាលាទំនើបដោយផ្ទាល់) ការលូតលាស់ជាប្រចាំនៃការសិក្សាទ្រឹស្តីទំនើប (បុរសជាទូទៅបានចាត់ទុកខ្លួនគេថា សំខាន់និងអស្ចារ្យ) ហើយក្នុងទសវត្សថ្មីៗនេះ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺជាបូជនីយកិច្ចរបស់ **បាជីនី** (អ្នកសរសេរក្បួនវេយ្យាករណ៍សំស្ក្រឹត)។ ភាសាវិទូជាច្រើនក៏បានរកឃើញនូវសណ្ឋានខុសៗគ្នាលើការសិក្សាភាសាឡាតាំងនាមជ្ឈិមសម័យ និងទស្សនវិជ្ជាមុនសម័យទំនើប។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រាជ្ញមជ្ឈិមសម័យទំនងជាត្រូវបានគេជឿជាក់ថា ជាអ្នកបន្សល់ទុកកេរមត៌កសម្រាប់ការសិក្សាសម័យទំនើបប្រកបដោយផ្លែផ្កា ជាងអ្វីដែលគេបានដឹងនោះទៅទៀត។ អ្នកប្រាជ្ញទាំងនេះ ប្រើប្រាស់ការសរសេរស្នាដៃជាភាសាឡាតាំង ទោះបីជាភាសានេះមិនមែនជាភាសាកំណើតរបស់ពួកគេក៏ដោយ តែវាជាភាសាមួយក្នុងចំណោមភាសាដែលពួកគេប្រើនៅផ្ទះ។ អ្នកប្រាជ្ញទាំងនោះ ក្នុងកិច្ចការក្រុម ពួកគេត្រូវតែតំណាងឱ្យអ្នកមានប្រវត្តិភាសាពីកំណើតខុសគ្នាខ្លាំងឬទាំងស្រុង។

សេចក្តីអភិប្រាយមួយចំនួនក្នុងចំណោមសេចក្តីអភិប្រាយនាមជ្ឈិមសម័យ បានបន្តវេយ្យាករណ៍ប្រពៃណីបុរាណសម័យចុងក្រោយ ហេតុដូចនេះមានអត្ថបទជាច្រើនផ្អែកលើ ស្នាដៃរបស់លោក ដូណាទុស (Donatus) និងលោក ព្រីសៀន (Priscian) ដែលមានការចូលរួមតិចតួចពីសំណាក់កវីនិងអ្នកនិពន្ធបុរាណ។ អត្ថបទសំណេរផ្សេងទៀតទាក់ទងនឹងការពិចារណាប្រហាក់ប្រហែលគ្នាលើភាពខុសគ្នានៃវេយ្យាករណ៍និងវិទ្យាសាស្ត្រស្រាវជ្រាវ។ ភាសាវិទូទំនើប ទំនងជាមិនត្រូវបានទទួលការបណ្តុះបណ្តាលដើម្បីអាចដោះស្រាយជាមួយនឹងសំណេរទាំងអស់នោះទេ។




លោក **Priscianus Caesariensis** , ប្រភព៖https://en.wikipedia.org/wiki/Priscian

ជាការពិតណាស់ ការកំណត់ទ្រឹស្ដីដែលគួរឱ្យចាប់អារម្មណ៍ពិតប្រាកដដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងទម្រង់វេយ្យាករណ៍មិនច្បាស់លាស់របស់ក្រុមអ្នកប្រាជ្ញម៉ូឌីស្ដា (modistae) ដែលកន្លងមកនៅក្នុងស្នាដៃរបស់ពួកគេ តែងតែសរសេរថា «ចំណាប់អារម្មណ៍ នៃសេចក្ដីអត្ថិប្រាយនូវទម្រង់នៃការធ្វើសញ្ញាកម្ម»។ សម្រាប់ការរីកចម្រើននៃវេយ្យាករណ៍ប្រពៃណីបស្ចិមប្រទេស ស្នាដៃនៃអត្ថបទនេះ គឺជាបង្គោលសំខាន់ទី២ បន្ទាប់ពីភាពត្រចះត្រចង់នៃភាសាក្រិកបានធ្វើឡើងដោយ ក្រុមស្តូអ៊ិក (Stoics) និងក្រុមអាឡិចហ្សង់ឌ័រ (Alexandrians)។ ទស្សនវិទូដែលជាអ្នកសិក្សាស្រាវជ្រាវ ត្រូវគ្របដណ្ដប់ជាមួយពាក្យនិងវត្ថុ។ល។ ប្រព័ន្ធនៃល្បះជាមួយធម្មជាតិនៃពិភពជាក់ស្ដែងទាំងអស់នេះសុទ្ធតែគ្របដណ្ដប់ដោយទ្រឹស្ដីសញ្ញាកម្ម។ គោលបំណងរបស់អ្នកវេយ្យាករណ៍ គឺដើម្បីស្វែងយល់អំពីពាក្យ (ធាតុផ្សំនៃភាសា) បានជាប់ទាក់ទងនឹងអារម្មណ៍ ហើយបង្ហាញថា តើវាមានសញ្ញាបង្ហាញតថភាពយ៉ាងដូចម្ដេច។ ចាប់តាំងពីគេដឹងថា ពាក្យមិនអាចគូសបញ្ជាក់ធម្មជាតិនៃតថភាព វាត្រូវជំនួសវត្ថុដែលវាគូសបញ្ជាក់នៅក្នុងទម្រង់មួយនៃទម្រង់ទាំងអស់។ វាគឺជាការប្រកាន់នូវទម្រង់ដែលផ្ដោតសំខាន់ចំពោះការសិក្សាលើចំណែកថ្នាក់និងថ្នាក់ពាក្យដែលវាផ្ដោតទៅលើប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ការសិក្សាពីល្បះ គួរនាំទៅរកធម្មជាតិនៃតថភាពតាមការចង្អុលបង្ហាញនៃសញ្ញា។

ទ្រឹស្ដីម៉ូឌីស្ដា (modistae) មិនបានបង្កើតថ្មីក្នុងការបែងចែកចំណែកថ្នាក់ជម្រើស និងថ្នាក់ពាក្យនោះទេ ពួកគេបានទទួលស្គាល់ថាការចាត់ថ្នាក់ទាំងនោះ បានមកពីក្រិកតាមរយៈស្នាដៃរបស់លោក ដូណាទុសនិងលោកព្រីសៀន។ វិភាគទានដ៏អស្ចារ្យរបស់អ្នកវេយ្យាករណ៍ដែលបានធ្វើនៅរវាងពាក់កណ្ដាលសតវត្សទី១៣ និងពាក់កណ្ដាលសតវត្សទី១៤ គឺជាការទទួចចង់ដឹងលើផ្នែកវេយ្យាករណ៍ ដើម្បីពន្យល់នូវលក្ខណៈខុសគ្នាដែលបានរកឃើញដោយអ្នកជំនាន់មុននៅក្នុងភាសាដែលពួកគេបានចេះដឹងពីមុនស្រាប់។ មិនប្រាកដថាតើពួកគេបានបង្កើតនូវជម្រើសដ៏ល្អបំផុតនៅក្នុងការជ្រើសរើសតក្កវិទ្យា បរមត្ថវិទ្យា វត្ថុវិទ្យានិយម (ការដែលគេស្គាល់វត្ថុទាំងនោះ) ក្នុងខណៈជាមុខវិជ្ជាដែលត្រូវគេបញ្ចូលជាមួយវេយ្យាករណ៍ ជាមូលដ្ឋានសម្រាប់កត់ត្រានូវចំណេះដឹងជាសកលដែលមានសារៈសំខាន់តិចជាងទំហំនៃការបញ្ញត្តនូវមូលដ្ឋានវេយ្យាករណ៍។ មុនសម័យម៉ូឌីស្ដា វេយ្យាករណ៍ពុំទាន់ត្រូវបានបង្ហាញជាមុខវិជ្ជាដាច់ដោយឡែកនៅឡើយ ប៉ុន្តែវាត្រូវបានពិចារណានៅក្នុងសន្ទានសព្វជាមួយនឹងការសិក្សា និងបំណិនផ្សេងទៀត (ដូចជាការរិះគន់ ការរក្សាទុកនូវអត្ថបទចាស់ៗ ការសិក្សាភាសាបរទេស)។ ការបកស្រាយនៃវេយ្យាករណ៍មានភាពតូចចង្អៀត ហើយនិងដាច់ដោយឡែកពីគ្នា។ បំណកស្រាយរបស់អ្នករ៉ូម៉ាំង មានលក្ខណៈបច្ចេកទេសខ្លាំង។ វេយ្យាករណ៍វិទូមជ្ឈិមសម័យជាក់លាក់ (អ្នកដែលពិចារណាភាសាថា ជាភាពមិនច្បាស់លាស់ ឬ «កញ្ចក់» នៃតថភាព) ដែលដាក់ចម្ងល់នៅក្នុងមូលដ្ឋាននៃការវិភាគភាសានិងវេយ្យាករណ៍។ ពួកគេមានចម្ងល់ថា តើវេយ្យាករណ៍វិទូ ឬភាសាវិទូ បានរកឃើញវេយ្យាករណ៍ដូចម្ដេច តើវេយ្យាករណ៍មានលក្ខណៈដូចគ្នាយ៉ាងណាសម្រាប់ភាសាទាំងអស់ តើអ្វីជាប្រធានបទសំខាន់នៃវេយ្យាករណ៍ តើអ្វីជាមូលដ្ឋាន និងមិនអាចខ្វះបាននៃវេយ្យាករណ៍ពីមុនៗ។ ការចង្អុលបង្ហាញ ត្រូវបានជាប់ជំពាក់ជាមួយនឹងការបញ្ចូលលក្ខណៈពាក្យទៅលើវត្ថុ។ល។ សញ្ញាជាចំណុចកណ្ដាលមួយ។ សំណួរទាំងនោះ ហាក់បីដូចជាបញ្ហាបច្ចុប្បន្ននៃភាសាវិទ្យា ដែលជួយក្នុងការគូសបញ្ជាក់ថា តើល្បឿននិងការលេចឡើងសារជាថ្មីនៃការរីកចម្រើននៅក្នុងមុខវិជ្ជានោះកើតឡើងយ៉ាងដូចម្ដេច។ នៅពេលដែលទ្រឹស្ដីរបស់ក្រុមម៉ូឌីស្ដា ត្រូវបានទទួលស្គាល់ ដោយបទដ្ឋានទំនើបនោះ ការបែងចែកជាក់លាក់បានកើតឡើង ហើយបំណែងចែកទាំងនោះ មានចំនួនកាន់តែច្រើន និងបានសម្រួលដល់ការបកស្រាយលើការសង្កេតនៃសម្ព័ន្ធ។ ការសិក្សាយ៉ាងហ្មត់ចត់ក្នុងអំឡុងមជ្ឈិមសម័យ ពិតជាធ្វើឱ្យមានការពិភាក្សាយ៉ាងច្រើនលើសំណួរបច្ចុប្បន្នយើងនេះ។

### ២.២.៤. បុនសម័យ

គេមានទម្លាប់ក្នុងការគិតអំពីបុនសម័យថា ជាពេលវេលានៃការរីកចម្រើនដ៏អស្ចារ្យ។ គ្មានអ្វីគួរឱ្យសង្ស័យទេ ដែលថាភាសាវិទ្យានិងការរីកចម្រើននៃនិរុត្តិសាស្ត្រ នាអំឡុងពេលនេះគួរជាទីចាប់អារម្មណ៍ ហើយនិងគួរឱ្យកត់សម្គាល់។ កម្រងទិន្នន័យថ្មីចំនួនពីរ ដែលភាសាវិទូសម័យទំនើបប្រាថ្នាដើម្បីកំណត់យកមកសិក្សា បានកើតមានចំពោះអ្នកវេយ្យាករណ៍ក្នុងអំឡុងពេលនេះ៖ ទី១ ភាសាតំបន់ប្រើប្រាស់ដោយអ្នកស្រុកកំណើត ដែលទើបទទួលស្គាល់ថ្មីៗនៅអឺរ៉ុប សម្រាប់ការថែរក្សានិងការប្រើងប្រែង មានការចាប់អារម្មណ៍កម្មវិធីសិក្សាទូទាំងជាតិ ជាបន្តបន្ទាប់ ហើយនិងស្ថាប័នសិក្សាដែលបន្តវត្តមានរហូតដល់សព្វថ្ងៃនេះ។ ទី២ ភាសាស្រុកឆ្ងាយដែលមិនមែនជាភាសាកំណើតនៃប្រទេសអាហ្វ្រិក ដូចជាភាសាបូព៌ាប្រទេស ភាសាពិភពលោកថ្មី និងក្រោយមកទៀតមាន ភាសាស៊ីប៊ីរី ភាសាក្នុងទ្វីបអាស៊ី ភាសាប៉ាពូ ភាសានៃមហាសមុទ្រអូសេអានី ភាសានៃមហាសមុទ្រអាក់ទិក និងភាសានៃទ្វីបអូស្ត្រាលី ដែលការធ្វើដំណើរដ៏វែងឆ្ងាយត្រូវបានបើកចំហរ។ ពីដំបូងៗ មានតែវេយ្យាករណ៍ភាសាមិនមែនឥណ្ឌូអឺរ៉ុបប៉ុណ្ណោះ គ្រប់កាលៈទេសៈគឺថាដូចជាភាសាហេប្រ៊ូ (និងបណ្ដាភាសានៅអារ៉ាប់មួយចំនួនទៀត) និងអម្បូរសេមីទិក បានចែករំលែកចំណែកថ្នាក់ក្រុមជាច្រើនជាមួយនឹងភាសាឥណ្ឌូអឺរ៉ុបនៅក្នុងក្បួនវេយ្យាករណ៍របស់ខ្លួន។ ជាការពិតណាស់ សម្រាប់ការសិក្សាស្រាវជ្រាវភាសាស្រុកនាយជាច្រើន បានឆ្លងកាត់នូវការស្មានដោយយោងទៅតាមការប្រមូលចងក្រងដំបូងៗបំផុតនៃតារាងពាក្យ ហើយការវិភាគវេយ្យាករណ៍ត្រូវបានធ្វើឡើងភ្លាមដោយពុំបានគិតពិចារណា។

នៅក្នុងការសិក្សាមុខវិជ្ជាវេយ្យាករណ៍ បុនសម័យមិនបានបង្កើតនូវគំនិតថ្មីគួរឱ្យចាប់អារម្មណ៍ ឬកត្តាឈានមុខនោះឡើយ។ ជាទូទៅ ការនិយាយមានការល្មៀងឆ្ងាយពីវេយ្យាករណ៍ និងការលើកឡើងដដែលៗមិនអាចរិះគន់បាននៃទស្សនៈភាសារ៉ូម៉ាំងចុងក្រោយ (ដូចដែលថ្លែងដោយលោក ព្រីសៀន)។ នេះគឺជាអ្វីដែលគេអាចយល់បាននៅក្នុងវេយ្យាករណ៍ឡាតាំងនិងក្រិក នៅពេលដែលកិច្ចការទាំងនេះពុំមានភស្តុតាងបញ្ជាក់ឱ្យរឹងមាំសម្រាប់មជ្ឈដ្ឋានអ្នកស្រាវជ្រាវនិងនៅតាមសាលារៀន ជាមួយនឹងគោលបំណងសំខាន់អាចធ្វើឡើងសម្រាប់ការរុករកអតីតកាលដែលទើបសិក្សាមកថ្មីៗ។ អ្វីដែលកើតចេញអំពីព្រឹត្តិការណ៍នេះ ចាប់ផ្ដើមនៅក្នុងសតវត្សទី១៥ ក្បួនវេយ្យាករណ៍សំខាន់នៃភាសាប្រើប្រាស់ទូលំទូលាយនៅអឺរ៉ុប ត្រូវបានរៀបរៀងឡើង គឺគ្រាន់តែករណីពិសេស និងសម្រាប់សេចក្ដីលម្អិតជាក់ស្ដែង (ឧ. ការប្រែប្រួលដ៏ខ្លាំងនៅក្នុងចំនួននៃថ្នាក់ពាក្យឬវិភត្តិនាម) ដែលការចាកចេញដំណើរពិតប្រាកដពីវេយ្យាករណ៍រ៉ូម៉ាំងអាចត្រូវបានកត់សម្គាល់។ ជាមួយគ្នានេះដែរ រហូតដល់ចុងបញ្ចប់សតវត្សទី១៩ វេយ្យាករណ៍ភាសាស្រុកនាយត្រូវបានសរសេរយ៉ាងទូលំទូលាយដោយសាសនិកនិងឈ្មួញ ស្ទើរតែដូចទៅនឹងទម្រង់ភាសារ៉ូម៉ាំង ពោលគឺជាអ្វីដែលបុនសម័យបានបន្ថែមគ្រឿងផ្សំផ្នែកសម្ព័ន្ធ។

ចាប់ពីពេលមួយទៅពេលមួយ កម្រិតនៃភាពខ្លាំងក្លាអាចត្រូវបានឃើញនៅក្នុងភាសាបារាំង ជាពិសេសនៅក្នុងស្នាដៃរបស់លោក ប៉េត្រុស រ៉ាមុស (Petrus Ramus) ជាតក្កវិទូនាសតវត្សទី១៦ បានធ្វើការនៅក្នុងវិទ្យាសាស្ត្រចាត់ថ្នាក់ក្រុម (taxonomy) នៃផ្នែទម្រង់របស់ពាក្យនិងបម្រែបម្រួលរូបរាងរបស់ពាក្យ កិច្ចការដែលហាក់ដូចជាការធ្វើអ្វីមួយមិនសំខាន់ ដែលភាសាវិទូសម័យទំនើបបានទទួលបទពិសោធ។ នៅក្នុងសតវត្សទី១៧ ចំនួនពួកឥសីដែលរស់នៅលើឆ្នេរខ្សាច់ជិតកំពង់ផែរ៉ូយ៉ាល់ (Port-Royal) នៃប្រទេសបារាំង បានបង្កើតក្បួនវេយ្យាករណ៍ដែលបានជះឥទ្ធិពលមកសម័យក្រោយគួរឱ្យចាប់អារម្មណ៍ សូម្បីតែនៅក្នុងការពិភាក្សាដេញដោលផ្នែកទ្រឹស្ដីនាបច្ចុប្បន្ននេះក្ដី។ កំណត់សម្គាល់លើទស្សនៈមូលដ្ឋាន ដែលកើតចេញពីតក្កវិទ្យាចំពោះការស្រាវជ្រាវនូវអ្វីដែលបានគូសបញ្ជាក់ដោយក្រុមអ្នកវិចារណញ្ញាណនិយម មនុស្សទាំងអស់នេះ មានបំណងបង្កើតក្បួនវេយ្យាករណ៍បែបទស្សនវិជ្ជាដែលអាចចាប់យកនូវអ្វីដែលមានភាពសាមញ្ញសម្រាប់វេយ្យាករណ៍នៃភាសាទូទៅ ពោលគឺវេយ្យាករណ៍ទូទៅ ប៉ុន្តែវាមានលក្ខណៈប្លែកជាសកល។ ក្បួនវេយ្យាករណ៍នេះបានទាក់ទាញចំណាប់អារម្មណ៍នាពេលថ្មីៗ ពីព្រោះវាបាន

បម្រើឱ្យទម្រង់សម្ព័ន្ធជាក់លាក់ ដូចទៅនឹងវិធានបំប្លែងជាអចិន្ត្រៃយ៍ ដែលបង្កើតបានជាទំនាក់ទំនងរវាងសមាសធាតុផ្សេងៗនៃឈ្មោះ។

ទោះបីជាយ៉ាងណាក៏ដោយ ភ្លាមៗបន្ទាប់ពីសតវត្សទី១៥ ដល់សង្គ្រាមលោកលើកទី២ ស្នាដៃវេយ្យាករណ៍មានវត្តមានសម្រាប់សាធារណជនបស្ចិមប្រទេស (ជាមួយនឹងការពង្រីកដែនដីអាណានិគម) បានបន្សល់ទុកនូវមូលដ្ឋានដែលលោក ព្រីសៀន បានធ្វើការចង្អុលបង្ហាញនូវចំណេះដឹងពីភាសាថ្មី និងបាននាំយកនូវការពិចារណាតិចតួចសម្រាប់ការសិក្សាឱ្យបានស៊ីជម្រៅផ្នែកវេយ្យាករណ៍។ ក្នុងខណៈដែលវិស័យអប់រំ បានក្លាយជាគោលដៅសំខាន់ ទូលំទូលាយនៅក្នុងសង្គម តាមរយៈសាលារៀន ចំណាប់អារម្មណ៍បានលើកកម្ពស់ពីវេយ្យាករណ៍បែបទ្រឹស្តី ឬបច្ចេកទេសក្នុងឋានៈជាការពិចារណាយ៉ាងហ្មត់ចត់ ទៅជាវេយ្យាករណ៍ណែនាំឬពន្យល់ ដែលផ្តោតទៅលើគោលបំណងផ្នែកគុកោសល្យ ចាប់ផ្តើមជាមួយជាតិនិយមលើភាសាក្នុងស្រុក (គ្រាមភាសា) នាបុនសម័យ។ វេយ្យាករណ៍បានបែងចែកក្រុមពួកជាច្រើនឡើងៗ ជាមួយនឹងវិធានដែលមានពីយូរមកហើយនៅក្នុងទស្សនវិជ្ជា ក្នុងខណៈដែលវិធានទាំងនោះ មានចលនាទៅលើក្រឹត្យក្រមដែលគេស្គាល់ថាជាវិទ្យាសាស្ត្រធម្មជាតិ ហើយការសិក្សាក្បួនវេយ្យាករណ៍ជាមុខវិជ្ជាបច្ចេកទេស បានក្លាយជាកត្តាជាប់ទាក់ទងជាមួយនឹងបញ្ហាតំណាងឱ្យការប្រព្រឹត្តដែលប្រឈមនឹងវិចារណញ្ញាណ ព្រមទាំងបុព្វជនរបស់ពួកគេដែលបង្កើតស្នាដៃក្នុងការសិក្សាស្រាវជ្រាវ។

បើគេគិតមកទល់នឹងសព្វថ្ងៃនេះ ក្បួនវេយ្យាករណ៍នៅសាលាមានទំនាក់ទំនងតែជាមួយនឹងការសិក្សាដែលបន្តពីភាសាវិទូជំនាញប៉ុណ្ណោះសម្រាប់មនុស្សភាគច្រើន វេយ្យាករណ៍ពិពណ៌នា បានក្លាយមកជាសទិសន័យនឹងពាក្យថា «វេយ្យាករណ៍» ហើយចរន្តទស្សនៈដែលមានក្នុងចំណោមអ្នកទទួលការអប់រំ ចាត់ទុកវេយ្យាករណ៍ថា ជាបញ្ជីនៃចំណេះដឹងបែបប្រជាប្រិយដោយបើកចំហសម្រាប់មនុស្សទូទៅ និងក្នុងទម្រង់ជាបញ្ហាទូទៅមួយនៃវិទ្យាសាស្ត្រដែលទាមទារឱ្យមានវិធីសាស្ត្រវិភាគដូចដែលគេបានសន្មតឡើងក្នុងគីមីវិទ្យា។

**២.២.៥. ការរីកចម្រើននៃវិធីសាស្ត្រប្រៀបធៀប (សតវត្សទី១៩)**

គេជឿជាក់ថា សមិទ្ធផលដែលលេចធ្លោបំផុតនៃការសិក្សាស្រាវជ្រាវផ្នែកភាសាវិទ្យានៅក្នុងសតវត្សទី១៩ គឺជាការរីកចម្រើននៃវិធីសាស្ត្រប្រៀបធៀប ដែលបញ្ចូលនូវសំណុំក្បួនដែលភាសាអាចត្រូវបានប្រៀបធៀបជាប្រព័ន្ធជាមួយនឹងគោលការណ៍ប្រព័ន្ធសំឡេង រចនាសម្ព័ន្ធវេយ្យាករណ៍ និងវាក្យសព្ទ ព្រមទាំងបង្ហាញនូវ «ភាពជាសាច់ញាតិផ្សេងៗ» ដែលពាក់ព័ន្ធ។ ក្នុងខណៈដែលភាសាបារាំង អ៊ីតាលី ព័រទុយហ្គាល់ រ៉ូម៉ានី អេស្ប៉ាញ និងភាសារ៉ូម៉ាំងឯទៀត មានប្រភពមកពីភាសាឡាតាំង ដូច្នេះភាសាឡាតាំង ក្រិក សំស្ក្រឹត រួមបញ្ចូលទាំងភាសាសែលទិក អាល្លឺម៉ង់ និងស្លាវិក និងភាសានានាជាច្រើនទៀតនៅអឺរ៉ុបនិងអាស៊ីបានចេញមកអំពីភាសាដំបូងៗ ក្នុងឈ្មោះអម្បូរឥណ្ឌូ-អឺរ៉ុប ឬឥណ្ឌូ-អឺរ៉ុបដើម ដែលឥឡូវនេះត្រូវបានប្រើប្រាស់ជាទម្លាប់។ ដោយហេតុថា ក្រុមភាសារ៉ូម៉ាំងទាំងអស់នោះចាប់កំណើតមកពីភាសាឡាតាំង ហេតុនេះហើយក៏បង្កើតបានជា «គ្រួសារភាសាមួយ» ដែលត្រូវបានគេស្គាល់រាប់សតវត្សមកហើយ។ ប៉ុន្តែវត្តមាននៃអម្បូរភាសាឥណ្ឌូអឺរ៉ុបនិងធម្មជាតិនៃទំនាក់ទំនងជាសាច់ញាតិរបស់ភាសាទាំងនោះ បានត្រូវចង្អុលបង្ហាញច្បាស់ដោយអ្នកប្រៀបធៀបនិរុត្តិសាស្ត្រជាលើកដំបូងនាសតវត្សទី១៩។ បច្ចេកសព្ទ «និរុត្តិសាស្ត្រ» ក្នុងបរិបទនេះ មិនបានកំណត់ជាច់ខាតចំពោះការសិក្សាភាសាអក្សរសិល្ប៍នោះទេ។

សន្ទុះមួយទៀតសម្រាប់ការរីកចម្រើននៃនិរុត្តិសាស្ត្រប្រៀបធៀប បានឈានទៅរកទីបញ្ចប់នាសតវត្សទី១៨ ពេលដែលគេបានរកឃើញថា ភាសាសំស្ក្រឹត បានធ្វើឱ្យមានភាពរីកវរដល់ភាសាក្រិកនិងឡាតាំង។ អ្នកតម្រង់ទិសជាតិអង់គ្លេសម្នាក់ឈ្មោះ ស៊ី វិលីយាម ចន (Sir William Jones) ទោះបីជាគាត់មិនមែនជាបុគ្គលទីមួយដែលសង្កេតទៅលើភាពមិនច្បាស់លាស់នោះមែន ប៉ុន្តែគាត់គឺជាអ្នកបាននាំយកសារនេះមកឱ្យពិភពលោកចាប់អារម្មណ៍និងបន្តស្វែងរកសម្មតិកម្មនានាក្នុងឆ្នាំ១៧៨៦ ដែលថា គ្រប់ភាសាទាំងបីត្រូវតែមាន «ការលូតលាស់ចេញពីប្រភពធម្មតាខ្លះៗដែលប្រហែលជាគ្មានវត្តមានយូរទៀតទេ»។ ក្នុងពេលជាមួយគ្នានេះចំនួននៃអត្ថបទ និងសទ្ទានុក្រមនៃ

ភាសាអាល្លឺម៉ង់បុរាណមួយចំនួនដូចជា (ហ្គូទិក អាល្លឺម៉ង់បុរាណ និងណូស៍បុរាណ) ត្រូវបានបោះពុម្ពផ្សាយ ហើយលោក ចន បានដឹងច្បាស់ថា ភាសាអាល្លឺម៉ង់រួមទាំងភាសាពៃក្យបុរាណ និងប្រហែលជាភាសាសែលទិកផងដែរ ចេញមកពី «ប្រភពរួមគ្នា»។ ជំហានសំខាន់បន្ទាប់បានកើតមានក្នុងឆ្នាំ១៨២២ ពេលអ្នកស្រាវជ្រាវជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ ចាកុប ហ្គ្រីម (Jacob Grimm) បន្តបន្ទាប់មកមានភាសាវិទូជាតិដាណឺម៉ាក រ៉ាសមុស រ៉ាស្ក (Rasmus Rask) (កិច្ចការរបស់គាត់សរសេរជាភាសាដាណឺម៉ាក គឺជាស្នាដៃដែលអ្នកស្រាវជ្រាវនៅអាល្លឺម៉ង់មិនសូវនិយមចូលចិត្តប៉ុន្មានទេ) បានចង្អុលបង្ហាញនៅក្នុងស្នាដៃបោះពុម្ពលើកទី២ ស្ដីអំពីវេយ្យាករណ៍ប្រៀបធៀបភាសាអាល្លឺម៉ង់របស់គាត់ថាមានចំណុចទាក់ទងគ្នាជាប្រព័ន្ធជាច្រើនរវាងសូរសំឡេងភាសាអាល្លឺម៉ង់និងសូរសំឡេងភាសាក្រិក ឡាតាំង និងសំស្ក្រឹតនៅក្នុងពាក្យដែលទាក់ទងគ្នា។ លោក ហ្គ្រីម បានកត់សម្គាល់ថា ជាឧទាហរណ៍ នៅទីណាដែលមានភាសាហ្គូទិក (ភាសារស់របស់អាល្លឺម៉ង់ដែលមានចំណាស់ជាងគេ) មានព្យញ្ជនៈ *f* ចំណែកឡាតាំង ក្រិក



លោក ចាកុប ហ្គ្រីម, ប្រភព៖https://en.wikipedia.org/wiki/Jacob_Grimm

និងសំស្ក្រឹតតែងមានព្យញ្ជនៈ *p* (ឧ. ហ្គូទិក [*fotus*] ឡាតាំង [*pedis*] ក្រិក [*podós*] សំស្ក្រឹត [*pāda*] ទាំងអស់នេះមានន័យថា ជើង (foot) នៅពេលដែលភាសាហ្គូទិក (Gothic) មាន *p* ភាសាអាល្លឺម៉ង់មាន *b* នៅពេលដែល ភាសាហ្គូទិក មាន *b* ភាសាអាល្លឺម៉ង់មានអ្វីដែលលោក ហ្គ្រីម ហៅថា «ការបញ្ចេញសូរអឃោសៈ (aspirate)» (ឡាតាំង *f* ក្រិក *ph* សំស្ក្រឹត *bh*) ដើម្បីពន្យល់អំពីចំណងទាក់ទងរវាងកត្តាទាំងអស់នេះ គាត់បានលើកសម្មតិកម្មអំពីការលើកដាក់សំឡេងនៅក្នុងភាសាអាល្លឺម៉ង់តាំងពីបុរេប្រវត្តិសាស្ត្រ ក្នុងប្រការដែលការបញ្ចេញសំឡេងសូរធនិត ក្លាយទៅជាការបញ្ចេញសំឡេងសូរសិថិល (*bh* ក្លាយជា *b* ។ល។) សូរសំឡេងដើមជាឃោសៈក្លាយជាអឃោសៈ (*b* ក្លាយជា *p* ។ល។) ឯសូរសំឡេងដើមអឃោសៈក្លាយជាសូរធនិត (*p* ក្លាយជា *f*)។ ក្នុងវាក្យសព្ទរបស់ ហ្គ្រីម ពាក្យ «សូរធនិត» នឹងកត់សម្គាល់ ហើយគ្របដណ្ដប់ដល់ភាពខុសប្លែកគ្នាខាងសូរសាស្ត្រ ដូចជាមានខ្យល់ស្ទះធនិត (*bh, ph*) បានបង្កើតឡើងជាមួយនឹងសូរផ្ដុំដង្ហើម ហើយសូរត្រង់បបូរមាត់បង្កើតឡើងជាមួយនឹងបង្ហូរត្រដុស (f) ជាលទ្ធផលនៃការបិទខ្សែសំឡេង។

ក្នុងកិច្ចការដែលបានកើតមាននៅ៥០ឆ្នាំបន្ទាប់មក គំនិតទាក់ទងនឹងបម្រែបម្រួលសូរបានលេចឡើងគួរឱ្យកត់សម្គាល់ ហើយនៅទសវត្សឆ្នាំ១៨៧០អ្នកស្រាវជ្រាវមួយក្រុមដែលគេស្គាល់ថា ក្រុមនវវេយ្យាករណិក បានលើកឡើងនូវសម្មតិកម្មនៅក្នុងសារណាថា រាល់ការប្រែប្រួលនៅក្នុងប្រព័ន្ធសូរសំឡេងនៃភាសាពេលរីកចម្រើននាគ្រាណាមួយ គឺជាប្រធានបទនៃដំណើរការច្បាប់សូរសំឡេងជាប្រក្រតី។ ទោះជាយ៉ាងនេះក្ដី សារណាដែលថាច្បាប់សូរសាស្ត្រ គឺពិតជាប្រក្រតីនៅក្នុងដំណើរការរបស់ពួកគេនោះ(លុះត្រាពួកគេ ត្រូវបានហាមឃាត់នៅក្នុងការជំទាស់ពីសំណាក់ឥទ្ធិពលនៃការប្រដូច) ពីដំបូងជាភាពចម្រូងចម្រាស់ខ្លាំងក្លាបំផុតនោះ ហើយនៅចុងសតវត្សទី១៩ ទ្រឹស្ដីនោះត្រូវបានទទួលស្គាល់ពិតប្រាកដ ព្រមទាំងក្លាយទៅជាជ្រុងមួយនៃវិធីសាស្ត្រប្រៀបធៀប។ ដោយមានបម្រើបម្រាស់វិធាននៃបម្រែបម្រួលសូរជាទៀងទាត់ អ្នកស្រាវជ្រាវអាចបង្កើតឡើងវិញនូវទម្រង់ធម្មតារបស់អ្នកជំនាន់មុនដែលទម្រង់បន្ទាប់រកឃើញនៅក្នុងភាសាផ្សេងៗអាចត្រូវបានបំប្លែង។ ដោយមានការសន្មតទម្រង់ដែលគេបង្កើតឡើងវិញ ត្រូវបានគូសបញ្ជាក់នៅក្នុងអក្សរសិល្ប៍ជាមួយនឹងសញ្ញាផ្កាយ។ ដូច្នេះ ចេញពីពាក្យដែលបង្កើតឡើងវិញនៅក្នុងបុព្វភាសាឥណ្ឌូអឺរ៉ុប ដូចជាពាក្យ «ten» **dekm* វាមកអំពីភាសាសំស្ក្រឹត [*dasa*] ក្រិក [*déka*] ឡាតាំង [*decem*] និង ហ្គូទិក [*taihun*] ដោយលើកជាសម្មតិកម្មថា ចំនួនច្បាប់សូរសំឡេងខុសគ្នា ដែលដំណើរការយ៉ាងឯករាជ្យនៅក្នុងមែកធាងខុសៗគ្នានៃអម្បូរភាសាឥណ្ឌូអឺរ៉ុប។ សំណួរទាក់ទងនឹងបម្រែបម្រួលសូរសំឡេងនឹងបង្ហាញជាមួយនឹង

សេចក្ដីលម្អិតច្បាស់លាស់ជាងនេះ នៅក្នុងផ្នែកបន្ទាប់ដែលមានចំណងជើងថា ភាសាវិទ្យាប្រវត្តិ ឬគេអាចហៅថា ភាសាវិទ្យាប្រវត្តិកាល។

**២.២.៦. វិធានដំណូច**

ដំណូច បានកត់សម្គាល់នៅក្នុងទំនាក់ទំនងជាមួយនឹងបម្រាមនៃដំណើរការច្បាប់សូរសំឡេងនៃពាក្យក្នុងទម្រង់ពិសេសរបស់វា។ នេះគឺអ្វីដែលនវវេយ្យាករណិកបានគិតពីវា។ នៅក្នុងមុខវិជ្ជានាសតវត្សទី២០ គេបានស្គាល់ថាដំណូច ដែលវាបានចូលមកជាមួយនឹងទម្រង់ពិចារណាទូទៅមួយ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍភាសាជាជាងការជំទាស់ ឬបដិសេធអ្វីដែលកែប្រែភាពទៀងទាត់នៃប្រព័ន្ធសូររបស់ភាសា។ នៅពេលដែលកុមាររៀននិយាយ គេប្រាថ្នាចង់ដឹងអ្វីដែលប្លែក ឬមិនធម្មតា ដែលបង្កើតឡើងដោយការប្រៀបប្រដូចជាមួយអ្វីដែលធម្មតានិងងាយយល់នៅក្នុងទម្រង់ភាសាឧទាហរណ៍ គេនឹងប្រាថ្នាក្នុងការនិយាយថា «comed» ជាង«came» ឬ«dived» ជាង«dove»។ល។ ហើយគេគ្រាន់តែនិយាយថា «talked,loved...និងពាក្យផ្សេងៗទៀត»។ ស្ថានភាពដែលកុមារធ្វើបែបនេះ គឺជាភស្តុតាងបញ្ជាក់ថា គេបានរៀន ឬកំពុងរៀនពីក្បួន ឬច្បាប់នៃភាសារបស់គេ។ គេនឹងបន្ត «ការរៀន» ទម្រង់ដំណូចផ្សេងៗទៀតនិងជំនួសពាក្យប្រដូចនោះ នៅក្នុងទម្រង់ប្លែក ពិសេសនៅក្នុងសម្ដីនិយាយដែលគេធ្លាប់ឮពីមនុស្សចាស់ជាង។ ប៉ុន្តែក្នុងករណីខ្លះ គេនឹងរក្សាដំណូច «ថ្មី» (ឧ. «dived» ជាជាង«dove») ហើយបន្ទាប់មកទៀតបញ្ហានេះនឹងក្លាយជាទម្រង់ដែលគេស្គាល់និងទទួលយក។

**២.២.៧. ទ្រឹស្ដីនិងការអភិវឌ្ឍផ្សេងៗទៀតនៅសតវត្សទី១៩**

**ក-ទម្រង់ខាងក្នុងនិងទម្រង់ខាងក្រៅ**

ទម្រង់មួយដែលមានលក្ខណៈដើមគេបង្អស់ ប្រសិនបើមិននិយាយពីឥទ្ធិពលថ្មីៗបំផុតទេនោះ ភាសាវិទូនៃសតវត្សទី១៩ គឺជាការរៀនតាមទស្សនៈរបស់លោក ព្រឺសៀន (Prussian) និងលោក វីហែម វ៉ុន ហាំបូលត៍ (Wilhelm von Humboldt)។ ចំណាប់អារម្មណ៍របស់គាត់ មិនដូចអ្នកដែលស្រាវជ្រាវស្រែកគាត់ទេ ពោលគឺគាត់មិនចោលក្បួនសិក្សាតាមប្រវត្តិសាស្ត្រនោះទេ។ តាមគន្លងទស្សនវិទូជាតិអាល្លឺម៉ង់ ចូហាន់ ហ្គូតហ្វ្រីត វ៉ុន ហេដេរ៍ (Johann Gottfried von Herder) (១៧៤៤-១៨០៣) គាត់បានសង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងភាសាជាតិនិងអក្សរជាតិ នេះគឺបែបហ្នឹងហើយ ប៉ុន្តែជាភាពធម្មតានៃមនោសញ្ចេតនា។ ប្រភពដើមផ្សេងទៀតគឺជាទ្រឹស្ដីរបស់ ហាំបូលត៍ ស្ដីពីទម្រង់ «ខាងក្នុង» និង «ខាងក្រៅ» នៃភាសា។ ទម្រង់ខាងក្រៅនៃភាសា គឺជាសារជាតុដើម (សូរសំឡេង) ដែលភាសាផ្សេងៗគ្នាតែងមាន ឯទម្រង់ខាងក្នុងនៃភាសា គឺជាគំរូពុម្ពឬរចនាសម្ព័ន្ធនៃវេយ្យាករណ៍និងន័យដែលដាក់បញ្ចូលទៅក្នុងសារជាតុដើម ដើម្បីបង្កើតភាសាមួយខុសពីភាសាដទៃទៀត។ បញ្ញត្តិ «រចនាសម្ព័ន្ធ» នៃភាសានេះ ត្រូវក្លាយទៅជាអំណាចគ្របដណ្ដប់នៅក្នុងអំឡុងពេលណាមួយ ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលដ៏សំខាន់នៃភាសាវិទ្យានាពាក់កណ្ដាលសតវត្សទី២០។ ទស្សនៈមួយទៀតរបស់ហាំបូលត៍ គឺថា ភាសា គឺជាអ្វីមួយដែលមានថាមពល (Dynamic) ជាងលំនឹង (Static) ហើយជាសកម្មភាពផ្ទាល់របស់វា ជាជាងការបង្កើតសកម្មភាព។ ភាសាមួយមិនមែនជាសំណុំនៃសកម្មភាពទាំងស្រុងដែលបង្កើតដោយអ្នកនិយាយនោះទេ ក៏ប៉ុន្តែវាគឺជាការគូសបញ្ជាក់នូវគោលការណ៍ឬវិធានដែលធ្វើឱ្យអ្នកនិយាយបង្កើតភាពច្បាស់លាស់ និងលើសពីនេះទៅទៀតចំនួនដែលរាប់មិនអស់នៃវិធាននោះ។ ទស្សនៈនេះ ត្រូវបានដកស្រង់ដោយនិរុត្តិវិទូជាតិអាល្លឺម៉ង់ឈ្មោះ ហេម៉ាន់ ស្ទេនថល (Heymann Steinthal) និងសំខាន់ជាងនេះទៀតដោយចិត្តវិទូ វីហែម វ៉ុន (Wilhelm Wundt) និងជះឥទ្ធិពលលើទ្រឹស្ដីចិត្តភាសាវិទ្យា នាចុងសតវត្សទី១៩និងដើមសតវត្សទី២០។ ឥទ្ធិពលរបស់វា ដូចអ្វីដែលហៅថា ភាពខុសគ្នានៃទម្រង់ខាងក្នុងនិងទម្រង់ខាងក្រៅ អាចត្រូវបានមើលឃើញនៅក្នុងគោលគំនិតរបស់លោក ហ្វែរឌីណង់ ដឺ សូសៀរ (Ferdinand de Saussure) ភាសាវិទូជនជាតិស្វីស។ ប៉ុន្តែការចង្អុលបង្ហាញដ៏ពេញលេញរបស់ទ្រឹស្ដី ទំនងជាមិនត្រូវបានដឹងដោយអារម្មណ៍ទេ រហូតដល់ពាក់កណ្ដាលសតវត្សទី២០ នៅពេលដែលភាសាវិទូ

អាមេរិក លោក ណម ឆមស្គី (Noam Chomsky) បានគូសបញ្ជាក់ឡើងវិញនូវទ្រឹស្តីនេះ និងបានធ្វើវាឱ្យក្លាយទៅជាការកត់សម្គាល់មូលដ្ឋានមួយនៃវេយ្យាករណ៍បំប្លែង (generative grammar)។

**ខ-សូរវិទ្យានិងគ្រាមភាសាវិទ្យា**

ការអភិវឌ្ឍដែលគួរឱ្យចាប់អារម្មណ៍និងមានសារៈសំខាន់ច្រើន ដែលលេចឡើងនៅក្នុងការសិក្សាស្រាវជ្រាវភាសាវិទ្យាសតវត្សទី១៩ ក្នុងចំណោមកិច្ចការទាំងនេះបានដំណើរការនៅក្នុងជំនាញសូរវិទ្យានិងគ្រាមភាសាវិទ្យា។ ការស្រាវជ្រាវនៅក្នុងជំនាញទាំងពីរនេះ ត្រូវបានផ្សព្វផ្សាយដោយយកចិត្តទុកដាក់ពីក្រុមនវវេយ្យាករណិក ជាមួយនឹងបម្រែបម្រួលសូរ និងតាមរយៈការស្នើរបស់ពួកគេដែលថាការអភិវឌ្ឍនៃបុរេប្រវត្តិក្នុងភាសាដូចទៅនឹងការអភិវឌ្ឍដែលកើតឡើងក្នុងភាសានិងក្នុងគ្រាមភាសាដែលត្រូវបាននិយាយនាបច្ចុប្បន្ន។ ការអភិវឌ្ឍនៃសូរវិទ្យានៅបស្ចិម ត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លានៅអំឡុងពេលនោះ ដូចដែលមានសេចក្តីលម្អិតជាច្រើននៃការវិភាគផ្នែកនិរុត្តិវិទ្យារបស់អម្បូរភាសាឥណ្ឌូអឺរ៉ុបតាមរយៈការរកឃើញនូវបណ្តាស្នាដៃរបស់វេយ្យាករណិកជាតិឥណ្ឌា ចាប់ពីពេលដែលមានលោក បានីនី (Pāṇini) ជាអ្នកបង្កើតវេយ្យាករណ៍សំស្ក្រឹត (នាអំឡុងសតវត្សទី៥ ឬទី៦មុនគ.ស.) ហើយបានមកដល់ដំណាក់កាលដែលយល់បានច្រើននិងមានទ្រឹស្តីវិទ្យាសាស្ត្រអំពីសូរវិទ្យា សទ្ទតាវិទ្យា និងរូបសព្ទវិទ្យា ជាងអ្វីមួយដែលគេបានទទួលនៅតំបន់បស្ចិមរហូតមកដល់សម័យទំនើប។

**២.២.៨. ទម្រង់និយម (សតវត្សទី២០)**

បច្ចេកសព្ទ «ទម្រង់និយម» ត្រូវបានប្រើប្រាស់ជាពាក្យស្លោក និងការស្រែកយំចំអកឡកឡឺយពីសំណាក់សាលាបង្រៀនភាសាវិទ្យាខុសៗគ្នា ហើយវាជាការចាំបាច់ក្នុងការស្វែងយល់ថា វាមានចំណងទាក់ទងអ្វីមួយខុសៗគ្នា អាស្រ័យទៅតាមបរិបទដែលវាបម្រើឱ្យ។ វាជាការសមស្រប ក្នុងការកត់សម្គាល់ពីលក្ខណៈខុសគ្នាយ៉ាងទូលំទូលាយជាលើកដំបូងរវាងទម្រង់និយមបែបអឺរ៉ុបនិងអាមេរិក បន្ទាប់មកធ្វើការវែកញែកវាចេញពីគ្នាឱ្យដាច់ស្រឡះ។

**ក. ភាសាវិទ្យាទម្រង់និយមនៅអឺរ៉ុប**

ភាសាវិទ្យាទម្រង់និយមនៅអឺរ៉ុប ត្រូវបានគេជឿជាក់ថា បានចាប់ផ្តើមក្នុងឆ្នាំ១៩១៦ ជាមួយនឹងការបោះពុម្ពផ្សាយនូវស្នាដៃមួយ បន្ទាប់ពីមរណភាពរបស់លោក ហ្វេរឌីណង់ ដឺ សូសៀរ (Ferdinand de Saussure) ដែលមានចំណងជើងថា ការសិក្សាមុខវិជ្ជាភាសាវិទ្យាទូទៅ (*Course in General Linguistics*) ។ ក្នុងអ្វីដែលគេហៅថា អ្នកសូសៀរនិយម ទោះបីជាពុំសូវមានអ្វីបញ្ជាក់ច្បាស់លាស់នៅក្នុងស្នាដៃដំបូងៗរបស់ ហាំបូលត៍ ព្រមជាមួយនឹងគោលការណ៍ទម្រង់និយមទូទៅដែល លោក ហ្វេរឌីណង់ ដឺ សូសៀរ បានបង្កើតឡើងដោយទោរទន់ទៅរកភាសាវិទ្យាសហកាល (synchronic linguistics) នៅក្នុងសិក្សាកថា ត្រូវបានអនុវត្តស្ទើរអស់រយៈកាល៤០ឆ្នាំដោយសូសៀរផ្ទាល់ នៅក្នុងការស្តាបនាឡើងវិញនូវប្រព័ន្ធស្រៈក្នុងអម្បូរភាសាឥណ្ឌូអឺរ៉ុប។ សញ្ញាណពេញលេញនៃកិច្ចការនេះ មិនបានជាទីចាប់អារម្មណ៍និងពេញចិត្តទេនាពេលនោះ។ ទម្រង់និយមរបស់សូសៀរ អាចត្រូវបានពុះកាត់ជាពីរផ្នែក (ដែលគ្របដណ្តប់ដោយអ្វីមួយដែល ហាំបូលត៍ ចង់សំដៅទៅរកនៅក្នុងបច្ចេកសព្ទរបស់គាត់ គឺទម្រង់ខាងក្នុងនិងទម្រង់ខាងក្រៅ)៖ (១) ភាសានិងសម្តី (*langue* versus *parole*) និង(២) ទម្រង់និងខ្លឹមសារ (*form* versus *substance*)។ ភាសា (*langue*) បកប្រែឱ្យចំទៅគឺសម្រាប់បច្ចេកសព្ទដែលសូសៀរ (Saussure) បានសំដៅទៅរក គឺជាប្រព័ន្ធភាសា ពោលគឺគ្រប់សមាសធាតុនៃច្បាប់កំណត់និងគំរូនៃទម្រង់ដែលគូសបញ្ជាក់នូវសូរសព្ទនៃភាសា។ តាមរយៈសម្តី (*parole*) អាចបកប្រែថា អាកប្បកិរិយានៃភាសា មានន័យថា គឺជាសូរសំឡេងដែលចេញពីមាត់អ្នកនិយាយផ្ទាល់។ គេអាចប្រៀបប្រដូចទៅនឹងការសម្តែងពីរផ្សេងគ្នានូវបទភ្លេងតែមួយនៃក្រុមតន្ត្រីផ្សេងៗគ្នានៅក្នុងកាលៈទេសៈខុសៗគ្នា នឹងនាំឱ្យមានសេចក្តីយោងលម្អិតផ្សេងគ្នា ទោះបីគោលបំណងនៃខ្លឹមសារនោះដូចគ្នាក៏ដោយ។ ហេតុនេះអ្វីដែលយើងបានឮចេញមកពីមាត់អ្នកនិយាយនាំឱ្យមានន័យពីរផ្សេងគ្នា។ អ្វីដែលការសម្តែងចេញពីរផ្សេងគ្នានៃតូរ្យតន្ត្រី និងសូរសំឡេងដែលចេញពីមាត់ពីរយ៉ាងមានលក្ខណៈដូចគ្នា គឺជា

ការគូសបញ្ជាក់នូវទម្រង់ ហើយទម្រង់ឬប្រព័ន្ធ ឬគំរូពុម្ពនេះ ស្ថិតនៅក្នុងភាពឯករាជ្យនៃគោលវិធានសារធាតុផ្សំ ឬ «សារធាតុដើម» យោងទៅតាមអ្វីដែលមាន។ «ទម្រង់និយម» នៅក្នុងផ្នត់គំនិតអឺរ៉ុប សំដៅទៅដល់ទស្សនៈដែលថា មានទម្រង់ដែលទាក់ទិនជាមួយនឹងចំណុចអរូបីដែលគូសបញ្ជាក់ និងត្រូវកត់សម្គាល់ចេញពីប្រព័ន្ធសូរបន្លឺពីក្នុងមាត់ ដែលបង្ហាញនូវអាកប្បកិរិយាជាក់ស្តែង ហើយនេះជាកម្មវត្ថុដំបូងនៃការសិក្សារបស់ភាសាវិទូ។

ចំណុចសំខាន់ពីរដែលបានលេចឡើងនាពេលនេះ៖ ទីមួយលើកឡើងថា វិធីសាស្រ្តទម្រង់និយមមិនស្ថិតនៅក្នុងការដាក់កំណត់ចំពោះភាសាវិទ្យាសហកាលនោះទេ។ ទីពីរ លើកឡើងថា គឺជាការសិក្សាន័យរួម ទាំងការសិក្សាអំពីសទ្ទតាវិទ្យានិងវេយ្យាករណ៍ អាចជាទម្រង់និយមនៅក្នុងការតម្រង់ទិស។ ក្នុងករណីទាំងពីរនេះ «ទម្រង់និយម» ផ្ទុយទៅនឹង អាតូមនិយម (atomism) នៅក្នុងអក្សរសិល្ប៍អឺរ៉ុប។ ទាំងនេះគឺសូសៀរនេះឯង ដែលគូសបញ្ជាក់ពីភាពខុសគ្នានៃបច្ចេកសព្ទ រវាងភាសាវិទ្យាសហកាលនិងប្រវត្តិកាលនៅក្នុងសិក្សាកថា។ ទោះជាយ៉ាងណាក្តី ការចង្អុលបង្ហាញនូវទម្រង់ដែលមិនអាចសង្ស័យបាននៃស្នាដៃដំបូងៗរបស់គាត់នៅក្នុងផ្នែកប្រវត្តិសាស្រ្តនិងការប្រៀបធៀប គាត់បានឱ្យដឹងថា នៅពេលណាដែលភាសាវិទ្យាសហកាលត្រូវដោះស្រាយជាមួយនឹងទម្រង់នៃភាសានាកាលៈទេសៈណាមួយ ភាសាវិទ្យាប្រវត្តិកាលត្រូវយកចិត្តទុកដាក់ជាមួយនឹងការរីកចម្រើនខាងប្រវត្តិសាស្រ្តនៃសមាសធាតុដាច់ដោយឡែកពីគ្នា គួរជាសមាសធាតុផ្សំចេញពីចំនួនអាតូម។ មិនប្រកាន់ថា តើទស្សនៈអ្វីដែលញ៉ាំងឱ្យសូសៀរជ្រើសរើសយកនូវបដិមតិនេះទេ ការបង្រៀនរបស់គាត់លើចំណុចនេះ មិនត្រូវបានទទួលស្គាល់ទូលំទូលាយនោះទេ ហើយភ្លាមៗនោះអ្នកស្រាវជ្រាវចាប់ផ្តើមអនុវត្តបញ្ញត្តិនៃទម្រង់ទៅលើការសិក្សាពីប្រព័ន្ធប្រវត្តិកាលនៃភាសា។ ចំណុចសំខាន់បំផុតនៃសាលាផ្នែកភាសាវិទ្យាទម្រង់និយម ដែលរកឃើញនៅអឺរ៉ុប នាពាក់កណ្តាលទី១នៃសតវត្សទី២០ បានរួមបញ្ចូលទាំងសាលាប្រាក (Prague) ដែលមានតំណាងគួរឱ្យកត់សម្គាល់បំផុតគឺលោក នីកូឡាយ សើយីវិច ទ្រូបឹស្កយ (Nikolay Sergeyevich Trubetskoy) ហើយនិងលោក រ៉ូម៉ាន ចាកុបសុន (Roman Jakobson) និងសាលាកូផែនហាហ្គេន (Copenhagen school) ដែលមានលោក លូ្វី ដេមស្លេវ (Louis Hjelmslev) លោក ចន រូប៊ឺត ហ្វឺត (John Rupert Firth) និងទាយាទរបស់គាត់ ពេលខ្លះគេសំដៅទៅដល់សាលាឡុងដ៏ (London school) មិនសូវនិយមវិធីសាស្រ្តរបស់សូសៀរប៉ុន្មានទេ ប៉ុន្តែនៅក្នុងការពិចារណាទូទៅអំពីបច្ចេកសព្ទវិធីសាស្រ្តរបស់គេ អាចត្រូវបានពិពណ៌នាយ៉ាងសមល្មមថាជាភាសាវិទ្យាទម្រង់និយម។

### ខ. ភាសាវិទ្យាទម្រង់និយមនៅអាមេរិក

ភាសាវិទ្យាទម្រង់និយមរបស់អឺរ៉ុបនិងអាមេរិក បានចែករំលែកគ្នា នូវចំណុចសំខាន់ៗមួយចំនួន។ ក្នុងការទទូចលើភាពចាំបាច់នៃភាសាដោយការគោរពគ្នាទៅវិញទៅមក ក្នុងខណៈជាទំនាក់ទំនងតិចឬច្រើន និងប្រព័ន្ធដាក់បញ្ចូលគ្នាតែមួយ ទាំងភាសាវិទូអឺរ៉ុបនិងអាមេរិកនាអំឡុងពេលនោះ ដោយប្រាថ្នាគូសបញ្ជាក់ថា បើសិនមិនមានការបំផ្លើសនោះទេ នឹងមានភាពរួមប្រសព្វតែមួយនៃទម្រង់ភាសានីមួយៗ។ វាមានទស្សនៈសំខាន់មួយក្នុងការពិចារណាទៅលើកត្តាដែលបានលេចឡើង ដែលភាសាវិទ្យាអាមេរិក បានអភិវឌ្ឍចាប់ពីចុងសតវត្សទី១៩ មកម្ល៉េះ។ វាមានភាសាអន្តោគ្រាម (ភាសាដែលកើតក្នុងស្រុក) បែបអាមេរិក-ឥណ្ឌារាប់រយ ដែលគេមិនធ្លាប់ធ្វើការសិក្សាស្វែងយល់ពីមុនៗមក។ ក្នុងចំណោមភាសាទាំងនេះ មានតែក្រុមមនុស្សដែលប្រើប្រាស់វាប៉ុណ្ណោះដែលនិយាយ ហើយប្រសិនបើភាសាទាំងនោះមិនទាន់ត្រូវបានកត់ត្រាទុកទេនោះ វានឹងអាចបាត់បង់ទៅជារៀងរហូត។ ស្ថិតនៅក្រោមកាលៈទេសៈបែបនេះ តួយ៉ាងដូចជាភាសាវិទូ ហ្វ្រង់ បូអាស (Franz Boas) បានពិចារណាតិចតួចទៅលើសំណង់ នៃទ្រឹស្តីទូទៅលើទម្រង់ភាសាមនុស្សជាតិជាងលើការពន្យល់លម្អិតលើវិធាន នៃវិធីសាស្រ្តដែលទាក់ទិននឹងសូរសំឡេង សម្រាប់ការវិភាគវែកញែកទៅលើភាសាដែលគេពុំសូវស្គាល់ ឬពុំសូវប្រើប្រាស់។ ពួកគេក៏ស្ថិតនៅក្នុងការភ័យខ្លាចផងដែរថា ការពិពណ៌នាទៅលើភាសាទាំងនេះ អាចទទួលការខូចខាត ដោយសារការវិភាគ

ក្នុងសភាពជាថ្នាក់ក្រុម ដែលក្លាយចេញមកពីការវិភាគវែកញែកនៃភាសានានាដែលល្បីៗក្នុងអម្បូរភាសាឥណ្ឌូ-អឺរ៉ុប នោះ។

បន្ទាប់ពីមរណភាពរបស់លោក បូអាស (Boas) រួចមក គឺនៅមានភាសាវិទូដ៏មានឥទ្ធិពលរបស់អាមេរិកពីររូបទៀតគឺលោក អេដវ៉ាត សាពៀរ៍ (Edward Sapir) និងលោក ឡេអូណាត ប្លូមហ្វៀល (Leonard Bloomfield) ដែលបានបន្តកិច្ចការនេះ។ ទស្សនៈដូចជាលោក បូអាស ដែលជាគ្រូរបស់គាត់ផងដែរ លោក សាពៀរ៍ បានស្ថិតនៅក្នុងរង្វង់នៃនរវិទ្យានិងភាសាវិទ្យា ដែលចំណងទាក់ទងនៃវិធានភាសាបានតាំងនៅស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ នៅក្នុងសាកលវិទ្យាល័យអាមេរិកជាច្រើន។ លោក បូអាស និងលោក សាពៀរ៍ ទាំងពីរនាក់បានចាប់អារម្មណ៍លើទស្សនៈហាំបូលត៍និយម (Humboldtian) ស្ដីអំពីទំនាក់ទំនងរវាងភាសានិងគំនិត ហើយថែមទាំងបន្សល់ទុកទៅដល់សិស្សរបស់ សាពៀរ៍ គឺលោក បែនចាមិន លី ហ្វ័ស (Benjamin Lee Whorf) ដែលបង្ហាញទស្សនៈនោះក្នុងទម្រង់ប្រណាំងប្រជែងច្បាស់លាស់ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត ដើម្បីសិក្សាបន្ត។ ក្រោយពីមានការបោះពុម្ពនូវស្នាដៃល្អៗរបស់ លោក ហ្វ័ស នៅក្នុងឆ្នាំ១៩៥៦ ជានិក្ខេបបទដែលនិយាយថា ភាសាជាអ្នកកំណត់នូវវិញ្ញាណនិងគំនិត បានត្រូវគេទទួលស្គាល់ថា ជាសម្មតិកម្មរបស់លោក ហ្វ័សនេះឯង។

ស្នាដៃរបស់ លោក សាពៀរ៍ តែងតែបានទាក់ទាញចំណាប់អារម្មណ៍ជាខ្លាំងទៅដល់បណ្ដាភាសាវិទូអាមេរិក ដែលទោរទន់ទៅលើបញ្ហានរវិទ្យា។ ចំណែកឯលោក ប្លូមហ្វៀល ដែលជាអ្នករៀបចំផ្លូវសម្រាប់អ្នកដើរតាមក្រោយទៀតទៅលើអ្វីដែលឥឡូវនេះគេហៅថា ជាគំនិតសម្ដែងចេញខុសៗគ្នានៃ «ទម្រង់និយម» របស់អាមេរិក។ នាអំឡុងពេលនៃការបោះពុម្ពសៀវភៅ ទីមួយរបស់លោកក្នុងឆ្នាំ១៩១៤ លោក ប្លូមហ្វៀល បានទទួលឥទ្ធិពលជាច្រើនពីសំណាក់ទ្រឹស្ដីចិត្តភាសាវិទ្យារបស់លោក វុន (Wundt)។ ទោះជាយ៉ាងនេះក្ដី នៅឆ្នាំ១៩៣៣ គាត់បានបោះពុម្ពបន្ថែមលើអត្ថបទដែលបានបោះពុម្ពពីមុនជាមួយនឹងការរំឭកទ្រឹស្ដីច្បាស់លាស់ ព្រមជាមួយនឹងចំណងជើងថ្មីថា «ភាសា»។ សៀវភៅនេះ បានគ្របដណ្ដប់លើមុខវិជ្ជាភាសាវិទ្យានេះអស់រយៈពេល៣០ឆ្នាំ។ ក្នុងសៀវភៅនេះ លោក ប្លូមហ្វៀល បានកំណត់យ៉ាងច្បាស់លាស់នូវគោលការណ៍បែបអាកប្បកិរិយា (behavioristic approach) ក្នុងការសិក្សាភាសា ដោយគេចចេញពីឈ្មោះនៃគោលបំណងផ្នែកវិទ្យាសាស្ត្រ ដែលយោងទៅលើចំណែកថ្នាក់ក្រុមតាមរូបរាងនិងតាមបញ្ញត្តិ។ រាល់លទ្ធផលសំខាន់ៗ គឺជាការទទួលស្គាល់នូវទ្រឹស្ដីបែបអាកប្បកិរិយានៃន័យវិទ្យា ដោយអាស្រ័យទៅលើអត្ថន័យ ដែលកើតចេញពីទំនាក់ទំនងរវាងរំញោចនិងការឆ្លើយតបដោយពាក្យសម្ដី។ ដោយហេតុថា វិទ្យាសាស្ត្រ ពុំទាន់អាចចូលខ្លួនមកបកស្រាយឱ្យមានលក្ខណៈងាយយល់នោះ គ្មានលទ្ធផលណាមួយដែលបានកើតឡើងគួរឱ្យកត់សម្គាល់ ឬគួរឱ្យចាប់អារម្មណ៍ឡើយ តាមរយៈការសិក្សាពីន័យវិទ្យាសម្រាប់ពេលវេលានៃការពិចារណានោះ ហើយវាទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីចៀសវាងការផ្ដោតលើការវិភាគវេយ្យាករណ៍នៃភាសាផ្អែកលើការពិចារណាបែបន័យវិទ្យាខ្លាំងពេក។ អ្នកនិយមតាម ប្លូមហ្វៀល បានជំរុញបន្ថែមទ្រឹស្ដី ក្នុងបំណងបន្តអភិវឌ្ឍវិធីសាស្ត្រនៃការវិភាគភាសាវិទ្យា ដែលមិនបានផ្ដោតទៅលើន័យវិទ្យា។ កត្តាគួរឱ្យកត់សម្គាល់បំផុតរបស់អ្នកទម្រង់និយមអាមេរិក បន្ទាប់ពី ប្លូមហ្វៀល គេស្ទើរតែបោះបង់ចោលទាំងស្រុងនូវន័យវិទ្យា។

កត្តាសំខាន់ផ្សេងទៀត ដែលត្រូវបានទទួលការរិះគន់យ៉ាងច្រើនពីភាសាវិទូ ណម ឆមស្គី (Noam Chomsky) គឺជាគោលបំណងរបស់ទ្រឹស្ដីដែលប្រើជារូបមន្ត «នីតិវិធីនៃការរុករក» ដែលអាចត្រូវបានអនុវត្តតាមយន្តការតិច ឬច្រើនចំពោះអត្ថបទ ហើយអាចត្រូវបានធានាថា អនុលោមតាមការពិពណ៌នាបែបសទ្ទតាវិទ្យា និងវេយ្យាករណ៍សមស្របលើភាសារបស់អត្ថបទ។ ភាសាវិទ្យាទម្រង់និយម ក្នុងន័យចង្អៀតចង្អល់នៃវាក្យសព្ទខ្លួន ត្រូវបានជំនួសដោយសេចក្ដីបញ្ជាក់ ឬសេចក្ដីលម្អិតខុសៗគ្នា នៅក្នុងសៀវភៅសិក្សាគោលរបស់អាមេរិក ដែលបានបោះពុម្ពនាអំឡុងទសវត្សឆ្នាំ១៩៥០។

## ២.២.៩. វេយ្យាករណ៍បំប្លែង

ការអភិវឌ្ឍគួរឱ្យកត់សម្គាល់ផ្នែកទ្រឹស្ដីភាសាវិទ្យា និងការសិក្សាស្រាវជ្រាវរាល់ឆ្នាំកន្លងទៅថ្មីៗនេះ គឺជាការលេចឡើងនៃវេយ្យាករណ៍បំប្លែង (generative grammar) ហើយជាពិសេសជាងនេះទៅទៀតនោះ គឺវេយ្យាករណ៍បំប្លែងទម្រង់ (transformational-generative grammar) ឬវេយ្យាករណ៍បំប្លែង ដូចទៅនឹងអ្វីដែលគេបានស្គាល់នេះឯង។ អត្ថបទពីរនៃវេយ្យាករណ៍បំប្លែង គឺបានដាក់ចេញជាបន្តបន្ទាប់នៅពាក់កណ្ដាលទសវត្សឆ្នាំ ១៩៥០ ដែលអត្ថបទទី១ គឺនិពន្ធដោយលោក ហ្សេលីក សាប់ប៊ីតៃ ហារីស៍ (Zellig S. Harris) និងអត្ថបទទី២ គឺនិពន្ធដោយ ណម ឆមស្គី (Noam Chomsky) ដែលជាសិស្សរបស់គាត់។ វាគឺជាប្រព័ន្ធបែប ឆមស្គី ដែលបានទាក់ទាញចំណាប់អារម្មណ៍អ្នកសិក្សាស្រាវជ្រាវនាពេលកន្លងមកនេះ។ នៅពេលដំបូង អ្វីដែលបង្ហាញដោយឆមស្គី គឺនៅក្នុងទម្រង់វាក្យសម្ព័ន្ធ (*Syntactic Structures*) (ឆ្នាំ១៩៥៧) ដែលវេយ្យាករណ៍បំប្លែងអាចត្រូវបានមើលឃើញជាផ្នែកៗ ក្នុងខណៈជាប្រតិកម្មប្រឆាំងនឹងអ្នកទម្រង់និយមដែលជាអ្នកជំនាន់ក្រោយរបស់ លោក ប្លូមហ្វៀល និងផ្នែកតំណភ្ជាប់នៃទ្រឹស្ដីរបស់ខ្លួនផងដែរ។ អ្វីដែលលោក ឆមស្គី បានប្រតិកម្មប្រឆាំងយ៉ាងខ្លាំងក្លាបំផុតនោះ គឺកង្វល់នៃអ្នកជំនាន់ក្រោយរបស់ ប្លូមហ្វៀល ទៅលើតែនីតិវិធីនៃការរុករកខ្លាំងពេក។ តាមទស្សនៈគាត់ ភាសាវិទ្យាត្រូវកំណត់ខ្លួនឯងឱ្យមានទម្រង់បែបបទនិងគោលបំណងជាក់លាក់ លើការកំណត់រូបមន្តលក្ខន្តិកៈ ដើម្បីវាយតម្លៃលើការពិពណ៌នាចុះឡើងៗនៃភាសា កុំឱ្យមានសំណួរជាច្រើនចោទសួរថា តើការពិពណ៌នានោះបានមកអំពីកត្តាអ្វីខ្លះ ឬក៏បានមកពីណា។ ទោះជាយ៉ាងណាក៏ដោយ មតិយោបល់ដែលធ្វើឡើងដោយភាសាវិទូ ក្នុងការពិពណ៌នាភាសា គួរតែឆ្លុះបញ្ចាំងជាមួយពុម្ពគំរូ នៃទ្រឹស្ដីវេយ្យាករណ៍ដែលគេត្រូវការជាជាងអ្វីដែលគេលើកឡើង ហើយទ្រឹស្ដីនេះ គួរត្រូវបានចងជារូបមន្តគោលមួយ នៅក្នុងខណៈពេលនៃការកត់សម្គាល់នានា ដែលត្រូវកំណត់ជាតួលេខបែបគណិតវិទ្យាទំនើប។ ក្នុងអំឡុងពីរបីឆ្នាំ លោក ឆមស្គី បានធ្វើការវាយប្រហារអ្នកជំនាន់ក្រោយរបស់លោក ប្លូមហ្វៀល ទៅលើចំណុចជាច្រើនផ្សេងៗទៀតផងដែរ។ គាត់បានទទួលស្គាល់ថា អ្វីដែលគាត់ហៅថា ទ្រឹស្ដីផ្នែក «សតិបញ្ញា» នៃភាសា ហើយតាមវាក្យសព្ទដែលគាត់លើកឡើងនេះ គាត់បានកែតម្រូវថា ភាសាវិទ្យាគួរត្រូវផ្ដោតចំណាប់អារម្មណ៍ ជាពិសេសលើការប្រកួតប្រជែងភាសាវិទ្យា ពោលមិនមែនជាការសម្ដែងចេញជាសកម្មភាពរបស់ពួកគេ ដែលជាសូរចេញមកពីមាត់ជាក់ស្ដែងនោះទេ។ គាត់បានទទូចដេញដោលចំពោះបញ្ញត្តិរបស់អ្នកនិយម ប្លូមហ្វៀល អំពីសទ្ទតាដែលអ្នកសិក្សាស្រាវជ្រាវជាច្រើនសំអាងថា ជាលទ្ធផលដ៏រឹងមាំ និងនៅសេសសល់ពីស្នាដៃជំនាន់មុនៗនោះ។ គាត់បានរិះគន់ទៅលើការទទូចចង់បានរបស់អ្នកទម្រង់និយម ទៅលើឯកត្តភាព (ភាពមានតែមួយ) នៃគ្រប់ភាសាដោយអះអាងជំនួសថា គ្រប់ភាសាទាំងអស់សម្រាប់កម្រិតនៃការពិចារណា ត្រូវកាត់ផ្ដាច់ពីទម្រង់ដែលអាចចែករំលែកនូវចំនួនជាក់លាក់នៃពិភពផ្លូវការ និងមានសារៈសំខាន់។

## ២.៣. ភាសាវិទូ

ភាសាវិទូ (linguist) អាចជាបុគ្គលម្នាក់ដែលមានច្រើនជំនាញ ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ភាសាវិទូគឺជាបុគ្គលម្នាក់មានជំនាញខ្ពស់ផ្នែកភាសាដែលគេបានរៀន រួមទាំងភាសាតាំងពីបុរាណកាលផង។ ពាក្យថា ភាសាវិទូ អាចត្រូវប្រើដើម្បីពិពណ៌នាពីមនុស្សម្នាក់ដែលមានជំនាញខាងភាសាវិទ្យា ដែលជាវិស័យសិក្សាអំពីភាសា ឬមួយភាសាវិទូអាចជាបុគ្គលម្នាក់មានជំនាញប្រសប់លើការបកប្រែ ការបកប្រែផ្ទាល់មាត់ និងការអនុវត្តនៃភាសា។ ស្របពេលជាមួយគ្នានេះភាសាវិទូអាចជាបុគ្គលម្នាក់ដែលមានចំណេះជំនាញច្បាស់លាស់នៅក្នុងភាសាជាច្រើនផងដែរ។

នៅក្នុងផ្នែកសិក្សាធិការ ភាសាវិទូ គឺជាបុគ្គលម្នាក់ដែលពាក់ព័ន្ធនឹងការសិក្សាអំពីភាសាវិទ្យា។ ផ្អែកលើករណីនេះ ភាសាវិទ្យាសម្ដៅទៅលើការសិក្សាភាសាបែបវិទ្យាសាស្ត្រ ទាំងផ្នែកទ្រឹស្ដីនិងការអនុវត្ត។ បុគ្គលម្នាក់ដែលសិក្សា ឬអនុវត្តជំនាញក្នុងផ្នែកនេះ ទាំងទ្រឹស្ដីនិងការអនុវត្ត ឬក៏ភាសាវិទ្យាអនុវត្តត្រូវបានគេកំណត់ថាជាភាសាវិទូ។

ឧទាហរណ៍នានានៃទ្រឹស្តីភាសាវិទ្យា រួមមាន វេយ្យាករណ៍ សម្ព័ន្ធវិទ្យា ន័យវិទ្យា ដែលជាប្រភពដើម និងសូរវិទ្យា។ ភាសាវិទ្យាអនុវត្ត ក្តោបលើការប្រើប្រាស់ចំណេះដឹងនៃភាសា ដូចជាអ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែឯកសារ អ្នកព្យាបាលផ្នែកសំឡេង គ្រូបង្រៀនភាសា ឬសាស្ត្រាចារ្យ។

តាមរយៈពាក្យនិយាយនិងពាក្យសរសេរតែងត្រូវលើកឡើងព្រមគ្នា ហើយភាសាវិទូផ្តោតចំណាប់អារម្មណ៍លើពាក្យនិយាយច្រើនជាងពាក្យសរសេរ។ ជាឧទាហរណ៍ អ្នកចេះភាសាច្រើន ឬបុគ្គលដែលមានជំនាញក្នុងភាសាជាច្រើនអាចចាត់ទុកជាភាសាវិទូ។ បុគ្គលម្នាក់មានជំនាញក្នុងភាសាសរសេរអាចត្រូវចាត់ទុកជាភាសាវិទូ ក៏ប៉ុន្តែអ្នកនោះអាចពឹងផ្អែកច្រើនលើប្រវែងនិងជម្រៅនៃវិស័យដែលគាត់សិក្សាក្នុងភាសាវិទ្យា។

វាមានបញ្ហាខុសគ្នាច្រើនដែលបានកើតឡើងក្នុងចំណោមភាសាវិទូផ្ទាល់ ប៉ុន្តែនៅក្នុងការពិចារណាជាទូទៅភាសាវិទូ គឺជាបុគ្គលម្នាក់ដែលបានទទួលការបណ្តុះបណ្តាលខ្ពង់ខ្ពស់ ទាំងសមាសភាពនៃការអនុវត្តនិងទ្រឹស្តីលើភាសាមួយឬច្រើន។ វាមានទាំងសមាគមនិងស្ថាប័នជំនាញ ដែលភាសាវិទូអាចចូលរួមជាមួយអ្នកជំនាញការដទៃទៀតដែលអ្នកនោះអាចចែករំលែកនូវផលប្រយោជន៍របស់គេ។ តួយ៉ាងមានស្ថាប័នមួយមានឈ្មោះថា វិទ្យាស្ថានជជែកវែកញែកនៃភាសាវិទូ (The Chattered Institute of Linguists) ដែលបោះពុម្ពផ្សាយដោយទស្សនាវដ្តីផ្ទាល់របស់គេមានចំណងជើងថាភាសាវិទូរៀងមក។

ភាសាវិទូ ខុសពីវាក្យវិទូដែលជាបញ្ញត្តិថ្មីសម្រាប់អ្នកនិយមពាក្យ ពីព្រោះភាសាវិទូអាចរៀននៅក្នុងភាសាដែលទាក់ទងគ្នាជាប្រព័ន្ធ មិនមែនគ្រាន់តែសិក្សាលើពាក្យណាមួយជាក់លាក់ និងមានចំណេះដឹងផ្នែកទ្រឹស្តីនៃភាសាច្រើនជាងការចេះពាក្យច្រើននោះ។

ភាសាវិទូ ពាក្យទូទៅសម្រាប់និស្សិត ជាអ្នកអនុវត្តនៃមុខវិជ្ជាភាសាវិទ្យា។ ពាក្យថា អ្នកភាសាវិទ្យា (linguisticians) តែងត្រូវបានគេដកស្រង់មកដាក់ក្នុងគោលបំណងនេះ ប៉ុន្តែវាមិនធ្លាប់ត្រូវបានប្រើប្រាស់ដោយភាសាវិទូជំនាញសម្រាប់ហៅខ្លួនគេទាំងអស់នោះទេ។ ដោយការចំអកឡកឡឺយ ពេលខ្លះការភ័ន្តច្រឡំបានលេចឡើងពីពេលដំបូងៗ និងបន្តដល់បច្ចុប្បន្ន គឺហៅបុគ្គលណាម្នាក់ដែលមានចំណេះដឹងច្បាស់លាស់នៅក្នុងភាសាជាច្រើន។

### ២.៣.១. ប្រវត្តិភាសាវិទូល្បីៗមួយចំនួន

#### ២.៣.១.១. ហ្វែរឌីណង់ ដឺ សូស៊ៀរ



ប្រភព៖ https://www.google.com/search?q=Ferdinand

លោក ហ្វែរឌីណង់ ម៉ុនហ្គីន ដឺ សូសៀរ (Ferdinand Mongin de Saussure) កើតនៅទីក្រុងហ្សឺណែវ (Geneva) ប្រទេសស្វីស ក្នុងឆ្នាំ ១៨៥៧។ បិតារបស់លោកមានឈ្មោះថា ហង់រី លួីស ហ្វ្រេដេរិក ដឺ សូសៀរ (Henri Louis Frederic de Saussure) មានអាជីពជាខនិជវិទ្យា (វិជ្ជាខាងសិលាជាតិ ឬវត្ថុធាតុនៅក្នុងដី) ផង ជាអ្នកបាណកសាស្ត្រ (វិជ្ជាខាងសត្វល្អិត) ផង និងជាអ្នកខាងវគ្គីករណ៍(ដាក់ឈ្មោះសត្វ រុក្ខជាតិទៅតាមប្រភេទក្រុម) ផងដែរ។ លោក សូសៀរ បានបង្ហាញនូវសញ្ញានៃភាពវៃឆ្លាតដ៏គួរឱ្យចាប់អារម្មណ៍ និងប្រាជ្ញាស្មារតីដ៏ឆ្លាតវាងវៃ ចាប់តាំងពីអាយុ១៤ឆ្នាំមកម្ល៉េះ។ បន្ទាប់ពីលោកបានសិក្សារៀនសូត្រភាសាឡាតាំង ភាសាក្រិក ភាសាសំស្ក្រឹតអស់រយៈកាលមួយឆ្នាំ និងមុខវិជ្ជាជាច្រើនទៀត នៅឯសាកលវិទ្យាល័យហ្សឺណែវរួចមក គាត់បានចាប់ផ្តើមការងារជាលើកដំបូងនៅសាកលវិទ្យាល័យលេបហ្ស៊ីក(University of Leipzig) ក្នុងឆ្នាំ១៨៧៦។ ពីរឆ្នាំក្រោយមក ក្នុងពេលលោកមានអាយុ២១ឆ្នាំ សូសៀរ លោកបានបោះពុម្ពសៀវភៅមួយក្បាល ដែលមាន

ចំណងជើងថា «បញ្ជីនៃប្រព័ន្ធមូលសព្ទស្រៈនៅក្នុងអម្បូរភាសាឥណ្ឌូ-អឺរ៉ុប» (Dissertation on the Primitive Vowel System in Indo-European Languages)។ បន្ទាប់ពីនោះមក គាត់បានចំណាយពេលសិក្សារយៈពេលមួយឆ្នាំនៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ ដែលទីនោះហើយលោកបានសរសេរបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតលើប្រធានបទ «វិភត្តិពេញលេញ» (Genitive absolute) ដែលមាននៅក្នុងភាសាសំស្ក្រឹត។ គាត់បានត្រឡប់ទៅកាន់លេបហ្ស៊ីក (Leipzig) វិញ ហើយបានការពារបញ្ចប់ថ្នាក់បណ្ឌិតរបស់លោកនាឆ្នាំ១៨៨០។ បន្ទាប់ពីលោកបានបញ្ចប់ថ្នាក់បណ្ឌិតរបស់លោកភ្លាម លោកបានផ្លាស់ទីលំនៅទៅកាន់ទីក្រុងប៉ារីស ប្រទេសបារាំង ជាកន្លែងដែលលោកបង្រៀនភាសាសំស្ក្រឹត ភាសាហ្គូទិក (ភាសាដែលប្រើក្នុងភាពយន្ត) និងភាសាអាល្លឺម៉ង់បុរាណ ហើយនិងមុខវិជ្ជាមួយចំនួនទៀតម្តងម្កាលផងដែរ។ គាត់បានបង្រៀននៅឯសាលាមួយដែលមានឈ្មោះថា Ecole Pratique des Hautes Etudes អស់ជាច្រើនឆ្នាំ ក្នុងខណៈដែលលោកបានទទួលគោរមងារជាមហាអ្នកប្រាជ្ញ (Knight of the Legion of Honor)។ ក្នុងពេលដែលលោកបំពេញតួនាទីជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យហ្សឺណែវ ក្នុងឆ្នាំ១៨៩១ គាត់បានត្រឡប់មកវិញ។ លោក សូសៀរ បានបង្រៀនភាសាសំស្ក្រឹត និងភាសាឥណ្ឌូ-អឺរ៉ុប នៅឯសាកលវិទ្យាល័យហ្សឺណែវ ស្ទើរតែពេញមួយជីវិតគាត់។ ទើបតែមកដល់ឆ្នាំ១៩០៧ប៉ុណ្ណោះ ដែលសូសៀរ បានចាប់ផ្តើមបង្រៀនមុខវិជ្ជាភាសាវិទ្យាទូទៅ (Course of General Linguistics) ដែលពេលនោះគាត់បានបង្រៀនរហូតដល់បីដំណាក់កាល ហើយបញ្ចប់នៅរដូវក្តៅឆ្នាំ១៩១១។ លោក ហ្វេរឌីណង់ ដឺ សូសៀរ បានទទួលមរណភាពនៅឆ្នាំ១៩១៣ នៅទីក្រុងវូហ្វហ្លេនឡឺសាតូ (Vufflens-le-Chateau) ប្រទេសស្វីស។

### ២.៣.១.២. ណាម ឆមស្គី

លោក អាវ្រាម ណាម ឆមស្គី (Avram Noam Chomsky) គឺជាភាសាវិទូ ទស្សនវិទូ អ្នកវិទ្យាសាស្ត្រពុទ្ធិ និងអ្នកតក្កវិទ្យា។ លោកជាជនជាតិអាមេរិក។ គាត់ជាវិទូម្នាក់ក្នុងចំណោមវិទូដ៏ល្បីបំផុត១០រូបនៅលើលោក។ គាត់ឈរនៅលំដាប់ទី៨បន្ទាប់ពីប្លាតុង (Plato) និងស៊ីម៉ុនហ្វ្រឺដ (Sigmun Freud)។ លោក ណាម ឆមស្គី កើតនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩២៨ នៅក្រុងភីលឡាដេលភៀ (Philladelphia) រដ្ឋពេនស៊ីលវ៉ានៀ (Pennsylvania) សហរដ្ឋអាមេរិក។ នៅវ័យកុមារ គាត់សិក្សានៅសាលាពិសោធន៍ជឿនលឿន (Experimental Progressive School)។ អាយុ១២ឆ្នាំ គាត់បាននិពន្ធសៀវភៅឈ្មោះ ប្រវត្តិសង្គ្រាមស៊ីវិលអេស្ប៉ាញ (History of Spanish Civil War) និងបទវិចារណកថាការដួលរលំនៃទីក្រុងបាសឺឡូណា (The fall of Barcelona)។ ពេលទំនេរ គាត់តែងតែទៅលេងតូបកាសែតពូរបស់គាត់ ហើយគាត់ចូលចិត្តអានកាសែតនិងជជែកវែកញែកពីបញ្ហាសង្គមផ្សេងៗ។ ការណ៍នេះធ្វើឱ្យគាត់ទទួលបានចំណេះដឹងខាងនយោបាយ។ គាត់ធ្លាប់បោះបង់ការសិក្សានៅសាកលវិទ្យាល័យ។ ក្រោយមក គាត់ទទួលបានសញ្ញាបត្របណ្ឌិត ពីសាកលវិទ្យាល័យផែនស៊ុលវីនៀ នៅឆ្នាំ១៩៥៥។ គាត់រៀបការជាមួយនាងការ៉ូល សាត (Carol Schatz) ដែលជាអ្នកជំនាញខាងអប់រំនិងភាសាវិទ្យា នៅឆ្នាំ១៩៤៩ និងមានកូន៣នាក់។ គាត់ជាសមាជិកនៃបណ្ឌិត្យសភាសិល្បៈនិងវិទ្យាសាស្ត្រអាមេរិក និងជាសមាជិកនៃបណ្ឌិត្យសភាវិទ្យាសាស្ត្រជាតិ។ គាត់តែងទទួលបានការអញ្ជើញទៅចូលរួមបាឋកថានៅតាមសាកលវិទ្យាល័យល្បីៗលើពិភពលោក។ សព្វថ្ងៃនេះ គាត់បម្រើការជាសាស្ត្រាចារ្យជាន់ខ្ពស់ខាងផ្នែកភាសាវិទ្យានៅវិទ្យាស្ថានបច្ចេកវិទ្យា ម៉ាសាឈូសេត (Massachusetts Institute of Technology)។



ប្រភព៖ https://www.google.com/search?

### ២.៣.១.៣. ឡេអូណាត ប្លូមហ្វៀល

លោក ឡេអូណាត ប្លូមហ្វៀល (Leonard Bloomfield) កើតនៅទីក្រុងជីកាហ្គោ (Chicago) រដ្ឋអ៊ីលីន័រ (Illinois) នៃសហរដ្ឋអាមេរិក។ លោក ប្លូមហ្វៀល កើតនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៨៨៧ ដែលមានឪពុកម្ដាយជាជនជាតិជ្វីហ្វ (Jewish)។ ឪពុកគាត់ឈ្មោះស៊ីកមុន ប្លូមហ្វៀល (Sigmund Bloomfield) ដែលបានធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក តាំងពីកុមារ នាឆ្នាំ១៨៦៨។ ឈ្មោះដើមនៃគ្រួសារគឺ ប្លូមិនហ្វែល (Blumenfeld) ប្ដូរទៅជា ប្លូមហ្វៀល (Bloomfield) ពេលទៅដល់សហរដ្ឋអាមេរិក។ នៅឆ្នាំ១៨៩៦ គ្រួសារគាត់បានប្ដូរទៅតំបន់អេខាតឡេក(Elkhart Lake) រដ្ឋវីស្កនស៊ីន (Wisconsin) ជាកន្លែងដែលគាត់បានចូលរៀនបឋមសិក្សា ហើយក៏បានត្រឡប់មកជីកាហ្គោ (Chicago) វិញ ព្រមទាំងចូលរៀនអនុវិទ្យាល័យ។ ឪពុកមាគាត់ឈ្មោះ ម៉ៅរីស ប្លូមហ្វៀល (Maurice Bloomfield) គឺជានិរុត្តិវិទូដ៏ល្បីល្បាញម្នាក់នៅសាកលវិទ្យាល័យចន ហុបគីន (Johns Hopkins University) ហើយម្ដាយមីងលោក ហ្វាននី ប្លូមហ្វៀល ហ្សេស្លឺ (Fannie Bloomfield Zeisler) ជាតន្ត្រីករព្យ៉ាណូដ៏ល្បីល្បាញមួយរូប។ ប្លូមហ្វៀល (Bloomfield) បានចូលមហាវិទ្យាល័យហាវ៉ដ (Harvard College) ពីឆ្នាំ១៩០៣ដល់ឆ្នាំ១៩០៦ ហើយបានទទួលបរិញ្ញាបត្រ។ គាត់បានបន្តនៅសាកលវិទ្យាល័យវីស្កនស៊ីន-ម៉ាឌីសុន (Wisconsin–Madison) ផ្នែកនិរុត្តិវិទ្យាភាសាអាល្លឺម៉ង់និងភាសាជឺម៉ានិក និងព្រមទាំងអម្បូរភាសាឥណ្ឌូ-អឺរ៉ុប (Indo-European) ដទៃទៀត។ ដោយជួបជាមួយភាសាវិទូ អេដាត ប្រូកុស (Eduard Prokosch) ដែលជាសមាជិកគ្រូបង្រៀននៅសាកលវិទ្យាល័យវីស្កនស៊ីន បានណែនាំ ប្លូមហ្វៀល (Bloomfield) ឱ្យចាប់អាជីពក្នុងផ្នែកភាសាវិទ្យា។ នៅឆ្នាំ១៩០៨ ប្លូមហ្វៀល (Bloomfield) ប្ដូរទៅសាកលវិទ្យាល័យជីកាហ្គោ (Chicago) ដែលគាត់ចាប់ជំនាញនិរុត្តិវិទ្យាភាសាអាល្លឺម៉ង់និងអម្បូរភាសាឥណ្ឌូ-អឺរ៉ុបផ្សេងទៀត ជាមួយជនជាតិបារាំងឈ្មោះ អា វូត (A. Wood) និង ខា ដាលីង ប៊ុក (Carl Darling Buck)។ នៅឆ្នាំ១៩០៩ គាត់បានបញ្ចប់ថ្នាក់បណ្ឌិត ដែលសារណារបស់គាត់និយាយអំពីភាសាវិទ្យាប្រវត្តិនៃភាសាជឺម៉ានិក (Germanic historical linguistics) ដែលដឹកនាំដោយលោក វូត (Wood)។ គាត់បន្តសិក្សាទៀតនៅសាកលវិទ្យាល័យលេបហ្សីក (Leipzig) និងហ្គោតទីហ្គេន (Göttingen) ឆ្នាំ១៩១៣ និងឆ្នាំ១៩១៤ ដែលដឹកនាំដោយលោក អូហ្គុស ឡេស្មៀន (August Leskien) (ជាអ្នកជំនាញអម្បូរភាសាឥណ្ឌូ-អឺរ៉ុប) លោក ខា ប្រុកម៉ាន់ (Karl Brugmann) និងលោក ហេម៉ាន់ អូលដេនប៊ឹក (Hermann Oldenberg) ដែលជាអ្នកជំនាញគម្ពីរវេទសំស្រ្កឹត (Vedic Sanskrit) ផងដែរ។ គាត់បានសិក្សានៅហ្គោតទីហ្គេន (Göttingen) ជាមួយអ្នកជំនាញភាសាសំស្ក្រឹត (Sanskrit) ឈ្មោះ ចាកុប វ៉ាគឺណាហ្គេ (Jacob Wackernagel) ហើយនិងបានធ្វើការពិចារណាទៅលើការវិភាគវេយ្យាករណ៍ភាសាសំស្រ្កឹតយ៉ាងល្អឥតខ្ចោះ ដែលមានស្នាដៃរបស់លោក បានីនី (Pāṇini) ដែលជាស្នាដៃមានឥទ្ធិពលយ៉ាងសំខាន់ក្នុងការងារបែបភាសាវិទ្យាប្រវត្តិនិងភាសាវិទ្យាពិពណ៌នា (historical and descriptive linguistics) របស់គាត់។ ការបណ្ដុះបណ្ដាលនៅអឺរ៉ុបដទៃទៀត គឺដើម្បីលើកកម្ពស់នៅសាកលវិទ្យាល័យអ៊ីលីន័រ (Illinois) ពីអ្នកបង្ហាត់ទៅកាន់ឋានៈជាសាស្រ្តាចារ្យជំនួយ។

### ២.៤. មែកធាងភាសាវិទ្យា

ភាសាវិទ្យាបែងចែកជាពីរផ្នែកធំៗគឺ ទី១ **មីក្រូភាសាវិទ្យា** (Micro Linguistics) មានដូចជា សូរវិទ្យា (Phonetics) សទ្ទតាវិទ្យា (Phonology) រូបសព្ទវិទ្យា (Morphology) សម្ពន្ធវិទ្យា (Syntax) ន័យវិទ្យា (Semantics) វចនវិទ្យា (Lexicology) ការណ៍វិទ្យា (Pragmatics) និងទី២ **ម៉ាក្រូភាសាវិទ្យា** (Macro Linguistics) មានដូចជា និរុត្តិវិទ្យា (Philology) ចិត្តភាសាវិទ្យា (Psycholinguistics) ភាសាវិទ្យាអនុវត្ត (Applied Linguistics) ភាសាវិទ្យាប្រព័ន្ធប្រសាទ (Neurolinguistics) ជីវភាសាវិទ្យា (Biolinguistics) វិភាគកថា (Discourse Analysis) គ្រាមភាសាវិទ្យា (Dialectology) ជាតិពន្ធុភាសាវិទ្យា (Ethnolinguistics) ភាសាវិទ្យាប្រវត្តិ

(Historical Linguistics) សង្គមភាសាវិទ្យា (Sociolinguistics) ភាសាវិទ្យាកុំព្យូទ័រ (Computational Linguistics) នរភាសាវិទ្យា (Anthropological Linguistics)...។

សូរវិទ្យា ពិពណ៌នាពីរបៀបនៃសូរសម្ដីដែលត្រូវបានបន្លឺឡើងនិងស្ដាប់ឮ។

សទ្ទតាវិទ្យា សិក្សាពីរបៀបនៃភាសាដែលរៀបចំជាឯកតានៃសម្ដីទៅក្នុងប្រព័ន្ធ។

រូបសព្ទវិទ្យា សិក្សាពីទម្រង់បន្សំនៃពាក្យនិងការផ្លាស់ប្ដូរពាក្យ។

សម្ព័ន្ធវិទ្យា ជាការសិក្សាពីរចនាសម្ព័ន្ធនៃឃ្លា និងការគូសបញ្ជាក់វិធានដើម្បីបង្កើតនិងធ្វើឱ្យវាដំណើរការ។

ន័យវិទ្យា គឺជាការសិក្សាពីន័យរបស់ពាក្យនិងន័យរបស់ឃ្លា។

វចនវិទ្យា គឺជាមុខវិជ្ជាមួយចំណុះឱ្យភាសាវិទ្យាដែលសិក្សាអំពីទុនពាក្យសព្ទនៅក្នុងភាសា។ ផ្នែកសំខាន់ៗនៃពាក្យដែលគេត្រូវលើកយកមកសិក្សាវិភាគ គឺទាក់ទងនឹងសំណេរ សំណួរ ន័យ ប្រភព ប្រវត្តិ កំណើត ការវិវត្ត ការបង្កើតពាក្យ ធាតុវេយ្យាករណ៍សម្រាប់បង្កើតពាក្យ និងនិមិត្តរូបជាដើម។

ការណ៍វិទ្យា គឺជាការសិក្សាពីយុទ្ធសាស្ត្រដែលមនុស្សប្រើភាសាដើម្បីអនុវត្តការទាក់ទងផ្នែកធុរកិច្ចនៅក្នុងបរិបទជាក់លាក់។

ចិត្តភាសាវិទ្យា គឺជាការសង្កេតលើភាសាដោយផ្ដោតលើអាកប្បកិរិយាផ្អែកលើមូលដ្ឋានពុទ្ធិនិងនិយាយពីអ្វីដែលទទួលបាន និងអាចដំណើរការទៅបាន។

ការចាប់យកភាសាទី២ គឺជាការសិក្សាអំពីរបៀបដែលអ្នកសិក្សាវ័យចាស់ទទួលយកភាសា និងវិធីដើម្បីអភិវឌ្ឍវា។

សង្គមភាសាវិទ្យា គឺជាការសិក្សាពីនានាភាពនៃសង្គមក្នុងភាសា ជាពិសេសគឺទំនាក់ទំនងរវាងរចនាសម្ព័ន្ធសង្គមនិងបម្រើបម្រាស់ភាសាហើយនិងបញ្ហាសង្គមដែលទាក់ទងនឹងភាសា។

និរុត្តិវិទ្យា គឺជាការសិក្សាអំពីរបៀបភាសាដែលបានប្រើប្រាស់នៅក្នុងស្នាដៃអក្សរសិល្ប៍ ជាពិសេសនៅក្នុងសៀវភៅសរសេរដៃចាស់ៗ។

ភាសាវិទ្យាអនុវត្ត គឺជាការអនុវត្តចំពោះវិស័យមួយចំនួនដូចជាបញ្ហានៃការប្រើសម្ដី ការអាន សង្គមកិច្ច កិច្ចការសាសនា ការបកប្រែ ការចងក្រងវចនានុក្រម ការបង្រៀនភាសា ការវិភាគលើការភ័ន្តច្រឡំ ដំណើរការភាសាក្នុងកុំព្យូទ័រ។

គ្រាមភាសាវិទ្យា ត្រួតពិនិត្យនូវភាពខុសគ្នានៃភាសាតាមតំបន់។

ជាតិពន្ធុភាសាវិទ្យា (នរភាសាវិទ្យា) ត្រួតពិនិត្យលើទំនាក់ទំនងរវាងវប្បធម៌និងភាសារបស់មនុស្ស។

ភាសាវិទ្យាប្រវត្តិ គឺជាការសិក្សានៃបម្រែបម្រួលនិងការវិវត្តនៃភាសាហើយធ្វើការបែងចែកអម្បូរភាសា។

ភាសាវិទ្យាប្រព័ន្ធប្រសាទ គឺជាការសិក្សាស៊ីជម្រៅអំពីទីតាំង ជាក់លាក់នៃភាសានៅក្នុងខួរក្បាល។

ប៉ារ៉ាភាសាវិទ្យា គឺជាការសិក្សានូវការសន្ទនារបស់មនុស្សដោយមិនប្រើវាចា។

## ២.៥. ការងារក្នុងវិស័យភាសាវិទ្យា

និស្សិតដែលមានចំណេះខាងភាសាវិទ្យា អាចយកចំណេះដឹងរបស់ខ្លួនទៅអនុវត្តក្នុងវិស័យផ្សេងៗដូចជាវិស័យសិក្សាស្រាវជ្រាវ អប់រំ អក្សរសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ ច្បាប់ បច្ចេកវិទ្យា ពាណិជ្ជកម្ម នយោបាយ សារព័ត៌មាន បោះពុម្ពផ្សាយ សុខាភិបាល...។ យ៉ាងណាមិញមានស្ថាប័នមួយចំនួនកំពុងត្រូវការជាចាំបាច់នូវជំនាញខាងភាសាវិទ្យានេះ ដើម្បីបម្រើការងារក្នុងវិស័យផ្សេងៗដូចជា៖

**ការងារផ្នែកអប់រំ៖** និស្សិតដែលបានសិក្សាជំនាញនេះ អាចពង្រឹងសមត្ថភាពចំណេះដឹងទាំងភាសាខ្មែរនិងភាសាបរទេស។ លើសពីនេះទៀត និស្សិតចេះវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការបង្រៀនភាសានិងមុខវិជ្ជាដែល

ពាក់ព័ន្ធនឹងភាសានៅគ្រប់មជ្ឈដ្ឋាន។ ចំពោះនិស្សិតដែលមានបំណងចង់បង្រៀនភាសាខ្មែរដល់ជនបរទេស ឬបង្រៀនភាសាបរទេសណាមួយ គេគ្រាន់តែបំពេញបន្ថែមនូវជំនាញគរុកោសល្យជាការស្រេច។

**ការងារផ្នែកបកប្រែ៖** បច្ចុប្បន្ននេះ គេត្រូវការអ្នកដែលមានជំនាញបកប្រែច្បាស់លាស់ (ទាំងបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ) នៅគ្រប់ទីកន្លែង។ អ្នកដែលមានជំនាញច្បាស់លាស់ផ្នែកភាសា មានអាទិភាពច្រើនក្នុងការក្លាយខ្លួនជាអ្នកបកប្រែអាជីព ដោយគ្រាន់តែបំពេញបន្ថែមជំនាញខ្លះទៀត។

**ការងារផ្នែកស្រាវជ្រាវនិងចងក្រងទិន្នន័យភាសា៖** ស្ថាប័នមួយចំនួនកំពុងត្រូវការអ្នកជំនាញភាសាមកធ្វើជាទីប្រឹក្សាឬជំនួយការដើម្បីចងក្រង វិភាគ និងអភិរក្សភាសាដែលប្រឈមនឹងការបាត់បង់ដូចជា ភាសាជនជាតិដើមភាគតិចជាដើម។ មិនត្រឹមតែប៉ុណ្ណោះ អង្គការខ្លះទៀតកំពុងស្រាវជ្រាវភាសា បង្កើតកម្មវិធីអក្ខរកម្ម និងបកប្រែឯកសារទាក់ទងនឹងមត៌កវប្បធម៌យ៉ាងសកម្ម ហើយត្រូវការធនធានមនុស្សផ្នែកភាសាវិទ្យាជាចាំបាច់។

**ការងារផ្នែកឧស្សាហកម្មបោះពុម្ពផ្សាយ៖** ក្នុងនាមជាអ្នកកាសែត អ្នកនិពន្ធ ឬនិពន្ធនាយក ជំនាញច្បាស់លាស់ក្នុងការប្រើប្រាស់ភាសា គឺមិនអាចខ្វះបានទេ។

**ការងារផ្នែកវចនានុក្រម៖** ដើម្បីបង្កើតវចនានុក្រមដ៏ល្អមួយបានគឺត្រូវការប្រឹក្សាយោបល់ដោយខានមិនបានពីអ្នកជំនាញភាសាវិទ្យាចំណានៗ។ ដោយហេតុថា វចនានុក្រមល្អមួយត្រូវការចំណេះដឹងខាងសូរសព្ទ អត្ថន័យ ប្រវត្តិពាក្យសព្ទ ភាសាតាមតំបន់ និងបរិបទផ្សេងៗក្នុងការប្រើប្រាស់ពាក្យតាមមជ្ឈដ្ឋាននានាជាដើម ចំណេះដឹងភាសាវិទ្យាគឺចាំបាច់បំផុតមិនអាចខ្វះបាន។

**ការងារផ្នែកពាណិជ្ជកម្ម៖** ក្នុងវិស័យពាណិជ្ជកម្ម គេត្រូវការចាំបាច់នូវចំណេះដឹងផ្នែកភាសាវិទ្យាដើម្បីដាក់ឈ្មោះ ឬសរសេរពាក្យស្លោកដើម្បីពពាយនាយលក់ផលិតផល។ ផលិតផលមួយដែលទាក់ទាញចំណាប់អារម្មណ៍អតិថិជនច្រើនឬតិច គឺអាស្រ័យមួយផ្នែកលើការចេះជ្រើសរើសឈ្មោះនិងពាក្យស្លោកដ៏មានឥទ្ធិពល ទាំងសូរសព្ទ ទាំងអត្ថន័យ ទាំងរូបារម្មណ៍។

**ការងារផ្នែកនយោបាយ៖** ការសរសេរសុន្ទរកថាសម្រាប់អ្នកដឹកនាំ គឺត្រូវការជាចាំបាច់ណាស់នូវចំណេះផ្នែកភាសាវិទ្យា ដ្បិតអ្នកជំនាញភាសាវិទ្យា ដឹងពីរបៀបប្រើប្រាស់ពាក្យពេចន៍និងឃ្លាប្រយោគត្រឹមត្រូវ តាមបរិបទដើម្បីទាញយកប្រជាប្រិយភាពពីអ្នកស្តាប់។ ហេតុនេះ ដើម្បីឱ្យសុន្ទរកថារបស់អ្នកដឹកនាំក្លាយជាសារមួយដ៏មានអត្ថន័យនិងដក់ជាប់ក្នុងចិត្តរបស់មហាជន ស្មេរគួរតែយកចំណេះដឹងខាងផ្នែកភាសាវិទ្យាមកប្រើប្រាស់។

**ការងារផ្នែកព័ត៌មានវិទ្យា៖** អភិវឌ្ឍកម្មវិធីបកប្រែស្វ័យប្រវត្តិ បង្កើតកម្មវិធីកែអក្ខរាវិរុទ្ធ ឃ្លា ឬល្បះស្វ័យប្រវត្តិ បង្កើតទិន្នន័យនិងវិភាគទិន្នន័យតាមគេហទំព័រនានា។

**ការងារផ្នែកសារព័ត៌មាន៖** និស្សិតដែលបានបញ្ចប់ជំនាញនេះ នឹងមានសមត្ថភាពខ្ពស់ខាងភាសាខ្មែរ ទាំងការនិយាយ ការសរសេរ ការអាន ការស្តាប់ ដែលអាចធ្វើឱ្យពួកគេក្លាយជាអ្នកសារព័ត៌មានលើផ្នែកសរសេរ អត្ថបទកាសែត ទស្សនាវដ្តី និងអានអត្ថបទសារព័ត៌មានបានល្អ ហើយជាពិសេសទៅទៀត ពួកគេក៏អាចធ្វើជាពិធីករតាមវិទ្យុ ឬទូរទស្សន៍ទៀតផង។

## សំណួរ

១. តើភាសាមានដើមកំណើតមកពីណាខ្លះ?
២. ចូរឱ្យនិយមន័យផ្សេងៗនៃភាសាតាមទស្សនៈផ្សេងៗ។
៣. ចូរបង្ហាញពីភាពខុសគ្នារវាងភាសានិយាយនិងភាសាសរសេរ។
៤. តើមានមធ្យោបាយទំនាក់ទំនងអ្វីទៀត ក្រៅពីភាសានិងអក្សរ?
៥. តើកាយវិការនិងភាសាសញ្ញាដូចគ្នាដែរឬទេ? ហេតុអ្វី?

៦. តើភាសាមានមុខងារអ្វីខ្លះ ?
៧. ចូរបង្ហាញពីភាពខុសគ្នារវាងភាសាសំយោគនិងភាសាវិភាគ។
៨. តើបែបផ្សេងៗនៃភាសាមានអ្វីខ្លះ ?
៩. តើភាសានិងសម្ដីខុសគ្នាដូចម្ដេចខ្លះ ?
១០. តើភាសាខ្មែរមានការវិវត្តបែបណាខ្លះ ?
១១. ចូរបង្ហាញពីលក្ខណៈនៃភាសាខ្មែរ។
១២. តើភាសាមានសារប្រយោជន៍អ្វីខ្លះសម្រាប់ជាតិសាសន៍នីមួយៗ ?
១៣. តើអ្នកមានគំនិតបែបណាខ្លះដើម្បីលើកស្ទួយភាសាជាតិរបស់អ្នក ?
១៤. តើអ្នកយល់បែបណារវាងភាសានិងគំនិត ? ចូរពន្យល់។
១៥. តើភាសាវិទ្យាមានដើមកំណើតមកពីណា ?
១៦. ភាសាវិទ្យាជាអ្វី ?
១៧. ភាសាវិទូជាអ្វី ? ចូរអ្នករៀបរាប់ភាសាវិទូល្បីៗឱ្យបាន៥នាក់។
១៨. តើមែកធាងសំខាន់ៗនៃភាសាវិទ្យាមានអ្វីខ្លះ ?
១៩. តើភាសាវិទ្យាត្រូវបានគេយកទៅប្រើក្នុងវិស័យអ្វីខ្លះ ?
២០. ចូររៀបរាប់អំពីជីវប្រវត្តិរបស់ លោក ហ្វេរឌីណង់ ដឺ សូស៊ៀរ។
២១. ចូររៀបរាប់អំពីជីវប្រវត្តិរបស់ លោក ណម ឆមស្គី។
២២. តើលោក បាធីនី បានរកឃើញអ្វីខ្លះ ដែលទាក់ទងនឹងការសិក្សាអំពីភាសា ?
២៣. ចូររៀបរាប់អំពីការសិក្សាអំពីភាសានៅសម័យបុរាណនៃក្រិកនិងរ៉ូម៉ាំង។
២៤. តើនៅមជ្ឈិមសម័យនៃអឺរ៉ុប គេយល់ឃើញបែបណាខ្លះចំពោះការសិក្សាអំពីភាសាវិទ្យា ?
២៥. តើនៅបុនសម័យ ការសិក្សាអំពីភាសាមានលក្ខណៈបែបណាខ្លះ ?
២៦. តើការរកឃើញនូវវិធីសាស្ត្រប្រៀបធៀបភាសាបានជះឥទ្ធិពលអ្វីខ្លះដល់ការសិក្សាអំពីភាសាវិទ្យា ?
២៧. ចូរបង្ហាញពីវិធានដំណូច។
២៨. តើនៅស.វ.ទី១៩ មានទ្រឹស្ដីអ្វីខ្លះដែលគេបានបង្កើតឡើងសម្រាប់សិក្សាអំពីភាសាវិទ្យា ?
២៩. តើភាសាវិទ្យាទម្រង់និយមបង្កើតឡើងដោយនរណា ?
ចូរសង្ខេបនូវភាសាវិទ្យាទម្រង់និយម ព្រមទាំងប្រាប់ឈ្មោះភាសាវិទូមួយចំនួនផង។
៣០. ចូររៀបរាប់អំពីវេយ្យាករណ៍បំប្លែង និងប្រាប់ឈ្មោះភាសាវិទូដែលបង្កើតវេយ្យាករណ៍នេះ។
៣១. តើអ្នកយល់ឃើញបែបណាចំពោះគោលការណ៍នៃភាសាវិទ្យា ?

# មេរៀនទី២
# ប្រព័ន្ធសំណេរ

## ១. សំណេរនិងការនិយាយ

យើងអាចកំណត់សំណេរជាតំណាងនិមិត្តរូបនៃភាសាតាមរយៈការប្រើប្រាស់សញ្ញាគំនូររូបភាព។ វាមិនដូចការនិយាយទេ សំណេរគឺជាប្រព័ន្ធមួយដែលមិនត្រូវបានទទួលជាធម្មតានោះទេ ប៉ុន្តែត្រូវតែមានការរៀនតាមរយៈការខិតខំប្រឹងប្រែងនិងមានស្មារតីប្រកបដោយនិរន្តរភាព។ គ្រប់ភាសាទាំងអស់មិនមែនសុទ្ធតែមានប្រព័ន្ធសំណេរទេ ហើយសូម្បីតែនៅក្នុងចំណោមមនុស្សដែលភាសារបស់ពួកគេបានបង្កើតប្រព័ន្ធសំណេរ បានយ៉ាងល្អក៏ដោយ ក៏វាមានមនុស្សមួយចំនួនធំមិនអាចប្រើប្រព័ន្ធសំណេរនេះបានដែរ។

តាមការអភិវឌ្ឍនៃចំណេះដឹងរបស់មនុស្ស ការសរសេរគឺជាបាតុភូតថ្មីមួយ។ យើងអាចតាមដានការបង្កើតឡើងពីប្រព័ន្ធសំណេររបស់មនុស្សក្នុងការតំណាងឱ្យព័ត៌មានក្នុងគំនូរល្អាងដែលត្រូវបានធ្វើឡើងយ៉ាងហោចណាស់ ២០០០០ឆ្នាំមុន ឬភស្តុតាងដីឥដ្ឋពី១០០០០ឆ្នាំកន្លងមក ដែលមើលទៅដូចជាការខិតខំដំបូងនៅកន្លែងរក្សាសៀវភៅ ប៉ុន្តែភាពវៃឆ្លាតទាំងអស់នេះត្រូវបានពិពណ៌នាថា ល្អបំផុតសម្រាប់ប្រព័ន្ធសំណេរបុរាណមុនគេបង្អស់។ សំណេរដំបូងបំផុតដែលយើងមានភស្តុតាងច្បាស់លាស់ នោះគឺជាអក្សរដែកគោល «Cuneiform» ដែលត្រូវបានសម្គាល់នៅលើបន្ទះដីឥដ្ឋប្រហែលជា ៥០០០ឆ្នាំមុនគ.ស.។ អក្សរបុរាណដែលមានទំនាក់ទំនងកាន់តែច្បាស់ចំពោះប្រព័ន្ធសំណេរដែលកំពុងប្រើប្រាស់សព្វថ្ងៃ អាចត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងសិលាចារឹកចុះកាលបរិច្ឆេទប្រហែល ៣០០០ឆ្នាំមុនគ.ស.។





៣១០០-២៧០០ឆ្នាំ មុនគ.ស. ប្រភព៖ https://en.wikipedia.org/wiki/Cuneiform

៦០០ ឆ្នាំមុនគ.ស.

ភស្តុតាងជាច្រើនដែលត្រូវបានប្រើក្នុងការបង្កើតប្រព័ន្ធសំណេរបុរាណឡើងវិញ ជាពិសេសសិលាចារឹកនៅលើថ្មឬបន្ទះលោហធាតុ។ ប្រសិនបើមនុស្សបុរាណទាំងនោះបានប្រើអក្សរពិបាកៗនៅលើឈើ ស្បែកសត្វ ឬវត្ថុធាតុផ្សេងៗ ដែលយើងបានបាត់បង់ទៅនោះ។ សំណេរដែលចារលើផ្ទាំងសិលាចារឹកគឺនៅបន្សល់ទុក ហើយយើងអាចតាមដានការអភិវឌ្ឍនៃសំណេរប្រពៃណីដ៏យូរអង្វែងពីរបីពាន់ឆ្នាំមុនដែលមនុស្សបានព្យាយាមបង្កើត កំណត់ត្រាទុកពីអ្វីដែលបានកើតឡើងរហូតមកដល់សព្វថ្ងៃនេះ។

## ២. ប្រភេទនៃប្រព័ន្ធសំណេរ

### ២.១. អក្សររូបភាពឬអក្សរគំនូរ

ប្រមាណជាង៤០០០០ ទៅ១០០០០ ឆ្នាំមុនគ.ស. មានមនុស្ស ក្រូ ម៉ុងហ្គុង (Cro Mangon) អាចគូររូបភាពបានល្អទាំងដែលគេនៅមិនទាន់ចេះប្រើអវយវៈសម្រាប់បញ្ចេញសំឡេងមកម្ល៉េះ។ រូបភាពដែលគេបានគូរនៅ

លើផ្ទាំងជញ្ជាំងល្អាង ជាសក្ខីភាពចែករំលែកចំណេះដឹងដែលគេមាន ជាមួយនឹងមិត្តភក្តិរួមល្អាង ដូច្នេះ ទើបរូបភាព (គំនូរ) កើតមានមុនតួអក្សរ។ ហើយនៅពេលដែល មនុស្សគិតប្រឌិតតួអក្សរឡើង ដើម្បីបន្តចំណេះដឹងរបស់ពួកគេទៅឱ្យមិត្តភក្តិតៗគ្នា តួអក្សរនោះជារូបភាពធម្មតាប៉ុណ្ណោះ នោះគឺអក្សររូបភាព (សួន ឱសថ, ២០១៣: ៣)។

ប្រមាណជា ៧០០០ឆ្នាំកន្លងមកហើយ មនុស្សគ្រប់ជាតិគ្រប់សាសន៍មិនមានអក្សរប្រើទេ លុះចំណេរកាលមក ប្រហែលជាប្រាំមួយពាន់ឆ្នាំកន្លងមកហើយនេះ ទើបមានជនជាតិអេហ្ស៊ីប (Egypt) ជាជាតិនាំបង្កើតអក្សរនេះមុនគេបង្អស់ តែអក្សរដែលអេហ្ស៊ីបបង្កើតឡើងនោះ មិនមែនជាតួអក្សរទេ គឺជារូបភាពផ្សេងៗ ជាគ្រឿងសម្គាល់ដូចយ៉ាងគូររូបមនុស្ស ឈរយកដៃស្តាំបិទមាត់ដៃឆ្វេង ចង្អុលទៅរកផ្ទះ ដោយសេចក្តីថា នៅឯផ្ទះមិនមានអាហារបរិភោគជាដើម។



ប្រភព៖ https://www.google.com/search?q=egyptian

ព្រោះហេតុនោះ រូបភាពទើបអាចស្តែងសេចក្តីប៉ុនប៉ងបានដោយមិនបាច់សរសេរតួអក្សរ តែការគូរជារូបភាពនេះ ក៏ស្រេចនៅលើសេចក្តីចូលចិត្ត ឬគ្រឿងសម្គាល់ក្នុងសង្គមមួយៗ លុះដល់សម័យខាងក្រោយមក ទើបមានព្រះមហាក្សត្រអេហ្ស៊ីបដដែលនោះ ព្រះអង្គទ្រង់រួបរួមរូបភាពទាំងនោះ ឱ្យចូលគ្នាជាពួកជាក្រុមឡើង ដើម្បីធ្វើឱ្យគ្រឿងសម្គាល់នោះមានន័យធំទូលាយបន្តិចឡើង។

តែរូបភាពទាំងអស់នោះ ក៏មិនទាន់ឈ្មោះថាជាតួអក្សរទេ។ លុះកន្លងពេលយូរមកទៀត ទើបគេអាចធ្វើជាតួអក្សរឱ្យមានសំឡេងផ្សេងៗគ្នាបាន ជាន់ដំបូងរូបភាពដែលគូរឡើងមានសេចក្តីសម្គាល់ចំពោះរបស់មួយៗ ឬក៏រូបភាពជាអ្វី ក៏នៅជារបស់នោះដរាបទៅ មិនអាចផ្លាស់ប្តូរទៅជារបស់ដទៃបានឡើយ សន្មតថា គូររូបគោ ក៏ជាទំនៀមត្រូវឱ្យអានថា គោ និងអានទៅជាអ្វីដទៃក្រៅពីគោពុំបានឡើយ (ខៀវ ជុំ, ១៩៦២: ១-២)។

## ២.២. អក្សរគំនិត




ប្រភព៖ https://www.google.com/search? q=ideograph

ប្រមាណជា៣០០០ឆ្នាំមុនគ្រិស្តសករាជ ចិននិងអេហ្ស៊ីប បានគិតរិះរកអក្សររូបភាពនេះឡើង ប៉ុន្តែការសរសេរ (គូរ) ឱ្យដូចការពិតនោះ គេធ្វើដោយលំបាក។ ម្យ៉ាងទៀត ការគូររូបភាពតំណាងឱ្យអ្វីៗគ្រប់យ៉ាង រមែងមិនអាចប្រព្រឹត្តទៅបានឡើយ។ ទើបមានការគិតប្រឌិតផ្សំអក្សររូបភាពឡើង ដើម្បីសរសេរ (គូរ) ជំនួសនូវអ្វីៗ ដែលគេចង់បង្ហាញឱ្យកាន់តែច្បាស់លាស់ថែមទៀត។ ដូចជា រូបភាពដំបូលផ្ទះផ្សំជាមួយរូបភាពជ្រូក ប្រើជំនួសពាក្យថា «ផ្ទះ» ជាដើម។ អក្សររូបភាពដែលកើតពីការផ្សំនេះ ហៅថា អក្សរគំនិត ពីព្រោះវាជារូបភាពប្រៀបធៀប មិនមែនរូបភាពមានពិត (សួន ឱសថ, ២០១៣ : ៤)។

## ២.៣. អក្សរព្យាង្គ

ជាន់ទីពីររូបភាពទាំងនោះ រូបមួយៗ ក្លាយទៅជាគ្រឿងសម្គាល់សម្រាប់តួអក្សរមួយព្យាង្គៗ ដូចរូបភាពស្លឹកឈើ ក៏បញ្ចេញសំឡេងថា លីហ្វ (Leaf ស្លឹកឈើ) ជាអក្សរមួយព្យាង្គក្នុងទំនងដូចគ្នានេះ រូបភាពសត្វឃ្មុំ ក៏បញ្ចេញសំឡេងថា ប៊ី (Bee សត្វឃ្មុំ) មួយព្យាង្គដែរ។ លុះជាន់ក្រោយតមក ក៏យកព្យាង្គនេះផ្សំចូលជាមួយគ្នា ដូចយករូបសត្វឃ្មុំ (Bee) និងរូបស្លឹកឈើ (Leaf) រៀងគ្នារួមជាពាក្យមួយ ព្យាង្គពីរ ហើយអានថា ប៊ីលីហ្វ (Be life ជំនឿ)។

កាលបើរូបគំនូរក្លាយជាតួអក្សរមានព្យាង្គ ហើយមានមាត្រាបញ្ចេញសំឡេងបានដូចនេះ ពេលនោះហើយដែលកំណត់បានថា ពិភពលោកមានអក្សរប្រើ មានការប្រាស្រ័យទាក់ទងគ្នាដោយអក្សរ ព្រោះថា បើចង់សរសេរ

ពាក្យឱ្យចេញសំឡេងយ៉ាងណា ក៏អាចនឹងប្រើគ្រឿងសម្គាល់ឱ្យចេញសំឡេងយ៉ាងនោះបាន ដូចគូរជារូបក្អែកឱ្យបញ្ចេញសំឡេងថា ក្អែក បើត្រូវការប្រើទៅជាពាក្យដទៃ មានសំឡេងថា «ក្អែក» ដូចគ្នា តែមិនដៅសេចក្តីថា សត្វក្អែក ក៏ត្រូវយករូបក្អែកមកប្រើជំនួសបាន។ អ្នកអានឃើញរូបក្អែក ក៏អានថា ក្អែកបានភ្លាម ដោយមិនសំដៅសេចក្តីថា ជាសត្វក្អែកក៏បានដែរ។

តួអក្សររបស់ជាតិអេហ្ស៊ីប មានគ្រឿងសម្គាល់ជារូបភាពទាំងអស់ ជាងប្រាំមួយរយរូប តួខ្លះប្រើជាប់តែឯង តួខ្លះជារូបផ្សំគ្នា ហេតុនោះ ការសរសេរអក្សររបស់ជនជាតិអេហ្ស៊ីប ទើបជាវិធីគូររូបជាពួកៗ ពួកមួយៗ ជាពាក្យមួយយកពាក្យមករៀងគ្នាជាពួក ជាក្រុម ក៏ទៅជាប្រយោគមួយ ឯរូបភាពនោះ គេគូរនៅលើផែនដីស្អិត លុះប្រទេសបានទទួលសេចក្តីចម្រើនបន្តិចឡើង គេគូរលើផែនសិលា ជាលំដាប់មក (ខៀវ ជុំ, ១៩៦២ : ២-៣)។

អក្សររូបភាពតែងមានការវិវឌ្ឍឥតឈប់ឈរ អាស្រ័យដោយអក្សររូបភាពមួយតួៗ ជំនួសឱ្យសំឡេងនីមួយៗ ដែលមានន័យច្រើនយ៉ាង ដូចសំឡេងថា «ហ្វេង» មានន័យច្រើនយ៉ាងគឺ «ទូក ទី ទ ក្លិន សួរ...» នឹងពាក្យផ្សេងៗទៀតតាមការនិយមប្រើ។ ហេតុនេះ ទើបយើងប្រើអក្សររូបភាព «ទូក» ជំនួសឱ្យពាក្យផ្សេងៗដែលបញ្ចេញសំឡេង «ហ្វេង» ដូចខាងលើ។ តែឥឡូវនេះ ត្រូវប្រើអក្សររូបភាពផ្សេងប្រកបជាមួយ ដើម្បីឱ្យមានន័យត្រូវត្រង់ចំពោះពាក្យណាមួយ ក្នុងចំណោមបណ្តាពាក្យទាំងនោះ។ ដូចជា សរសេរ(គូរ) អក្សររូបភាពជំនួសពាក្យថា «ទី» គេក៏សរសេរ (គូរ) អក្សររូបភាពជំនួសឱ្យសំឡេង «ហ្វេង» រួចថែមអក្សររូបភាពនៃពាក្យថា «ដី» បញ្ចូលទៅ។ កាលបើយើងឃើញអក្សររូបភាពនៃសំឡេង «ហ្វេង» និងឃើញអក្សររូបភាពនៃពាក្យថា «ដី» នៅរួមជាមួយផង ក៏គិតដៅថា ជាពាក្យ «ទី» ពុំមែនពាក្យផ្សេងទេ។ ជំនួសពាក្យថា «ត្បាញ» យើងសរសេរ (គូរ) អក្សររូបភាព «ហ្វេង» ផ្សំជាមួយអក្សររូបភាព «សូត្រ» អក្សរមួយគូនេះ គួរយល់ថា «កីតម្បាញ» ដែលជំនួសឱ្យពាក្យថា «ត្បាញ»។ ជំនួសពាក្យថា «សួរ» យើងសរសេរ (គូរ) អក្សររូបភាព «ហ្វេង» ផ្សំជាមួយអក្សររូបភាព «ពាក្យ» ដូចនេះ «ហ្វេង» ដែលទាក់ទងនឹង «ពាក្យ» មានតែពាក្យថា «សួរ» តែម្យ៉ាងប៉ុណ្ណោះ។ អក្សររូបភាពដែលប្រាកដមានយ៉ាងនេះ ហៅថា ហ្វូណូក្រាមស៍ ឬប្រព័ន្ធសំណេរព្យាង្គ (Phonograms) គឺជាអក្សររូបភាពជំនួសឱ្យសូរឬសំឡេង ពុំមែនជំនួសឱ្យរូបភាពដើមទេ។ ចិនមានវិធីសរសេរដូចនេះ ទើបមានតួអក្សរច្រើន ចាំបាច់ត្រូវតែចងចាំឱ្យបានច្បាស់មុននឹងអាន (សួន ឱសថ, ២០១៣: ៥)។

## ២.៤. អក្សរសូរសំឡេងឬសំណេរអក្ខរក្រម

តមកខាងក្រោយទៀត ជនជាតិអេហ្ស៊ីប ក៏គិតរកឧបាយធ្វើជារូបមួយៗ ប្រើជំនួសពាក្យមួយៗឡើងទៀត ហើយក្នុងរូបមួយៗប្រើជំនួសពាក្យមួយៗ គឺតួអក្សរហ្នឹងឯង។ ឯតួអក្សររបស់គេមាន២៤តួ។ អេហ្ស៊ីបជាជាតិដែលបានប្រើតួអក្សរមកក្នុងលោក មុនពុទ្ធសករាជប្រហែលជាងពីរពាន់ឆ្នាំ ឬ២៥៤៣ឆ្នាំមុនគ.ស.។ អេហ្ស៊ីបអាចប្រើអក្សរ២៤តួនេះ សម្រាប់សរសេរក្នុងភាសារបស់ខ្លួនបានដោយគ្រប់គ្រាន់។

តែដោយអាស្រ័យជនជាតិនេះ ធ្លាប់គូររូបភាពប្រើជំនួសតួអក្សរមកថ្នឹកនិស្ស័យណាស់ទៅហើយ ទើបមិនអាចប្រើអក្សរបែបថ្មីនេះឱ្យលឿនរហ័សទៅបាន។ លុះចំណេរកាលមក ជនជាតិនេះ បានរកមធ្យោបាយធ្វើទឹកខ្មៅសម្រាប់សរសេរ ដោយយកជ័រឈើមកលាយជាមួយទឹក និងធ្វើក្រដាសអំពីសំបកឈើម្យ៉ាង ហៅថា ប៉េប៉ាយរ៉ាស (Papyrus)។ តមកខាងក្រោយជនជាតិបាប៊ីឡូន (Babilonien) ក៏បានយកអក្សរបែបនោះមកប្រើ ហើយផ្សាយចេញទៅពួកហ្វេនីសៀង (Phenishian) ទៀត តែជនជាតិទាំងពីរនៅសរសេរអក្សរលើផែនដីស្អិតនៅឡើយ។

### ២.៤.១. ការផ្សាយតួអក្សរចូលទៅក្នុងទ្វីបអឺរ៉ុប

សម័យតមក ជាតិហ្វេនីបានបោះបង់ឈប់ប្រើតួអក្សររបស់បាប៊ីឡូន ដែលចម្លងមកពីអេហ្ស៊ីប ហើយដែលសរសេរនៅលើផែនដីស្អិតនោះ ព្រោះយល់ឃើញថា អក្សរបែបនេះ ប្រើមិនសូវស្រួល ហើយក៏បានទៅយកក្រដាសដែលធ្វើអំពីដើមប៉េប៉ាយរ៉ាសពីប្រទេសអេហ្ស៊ីប មកប្រើជំនួសផែនដីស្អិត រួចហើយក៏គិតអានធ្វើតួអក្សរជាគ្រឿង

សម្គាល់របស់ខ្លួនឡើងថ្មីមួយបែបទៀត តួអក្សរនេះមានត្រឹមតែ២២តួ គ្រឿងសម្គាល់ទាំងនោះមិនប្រាកដថា ប្រើជំនួសពាក្យមួយព្យាង្គដូចអក្សររបស់អេហ្ស៊ីបទេ។ គ្រឿងសម្គាល់មួយតួ ក៏នៅជាមួយតួដដែល ហើយមិនប្រាកដថាមានតួស្រៈទេ ដោយហេតុនេះ ទើបរាប់ថាជនជាតិហ្វេនី ជាជាតិដែលគិតរកតួអក្សរជាដំបូង ពោលគឺតួអក្សរសុទ្ធៗនេះឯង។ សេចក្តីអង់អាចរបស់ជនជាតិហ្វេនី ក្នុងរឿងនេះ មតិសកលលោកភាគច្រើនឃើញថា យកអេហ្ស៊ីបជាគ្រូ។

ជាតិហ្វេនី បានរៀបរៀងតួអក្សរបែបថ្មីនេះ ឱ្យមានលំដាប់លំដោយល្អ ដើម្បីឱ្យអក្សរ២២តួនេះ មានរបៀបនិងមានលក្ខណៈត្រឹមត្រូវស្រួលរៀន ស្រួលទន្ទេញ ដូចយ៉ាង ក ខ គ ឃ ង ...របស់យើងក្នុងបច្ចុប្បន្នដែរ លុះរៀបរៀងជាលំដាប់គ្នាដូច្នោះហើយ ក៏ឱ្យឈ្មោះតួអក្សរទាំងនោះដោយយក «គោ» មកឱ្យឈ្មោះតួអក្សរដើម ដោយពាក្យថា «គោ» ភាសាហ្វេនីសៀងថា អេឡហ្វ (A leph) ដែលគេរាប់ A ជាដំបូងបង្អស់ អក្សរទីពីរឱ្យឈ្មោះថា «ផ្ទះ» ដែលហ្វេនីសៀង ហៅថា បេថ (Beth) ដែលមានដើមជាតួ B ហើយឱ្យឈ្មោះរៀងតាមលំដាប់ទៅ ដូច្នេះ បើកូនក្មេងហ្វេនីសៀងរៀនអានអក្សរ វាក៏អានថា អេឡហ្វ បេថ។ល។

អក្សរ២២តួរបស់ជនជាតិហ្វេនី ជាអក្សរមានតួតិច ប្រើការមិនគ្រប់គ្រាន់ ប្រើបានតែពួកឈ្មួញកត់ត្រាបញ្ជីបន្តិចបន្តួចប៉ុណ្ណោះ។ តែជនជាតិនេះ បានផ្សាយចេញទៅក្នុងដែនដែលនៅក្បែរសមុទ្រមេឌីទែរ៉ាណេ រៀងទៅភាគខាងលិច រហូតដល់ទៅអឺរ៉ុប។ ឯជាតិអឺរ៉ុប ដែលទទួលយកអក្សរហ្វេនីសៀងមកប្រើមុនគេនោះ គឺជាតិក្រិក តែសម័យតមក ជនជាតិក្រិកនេះ មានគំនិតប្រាជ្ញាច្រើន គេពិចារណាឃើញថា អក្សរហ្វេនីសៀង មានតួចំនួនតិចពេកហើយថែមទាំងមិនមានស្រះផង ប្រើការមិនបានគ្រប់គ្រាន់ ហើយតួអក្សរខ្លះ មិនមានសំនៀងក្នុងភាសាក្រិកផង ទើបគេកែប្រែរៀបរៀងតួអក្សរជាថ្មីឡើងទៀត ហើយក៏ផ្សាយទូទៅពេញទាំងប្រទេសក្រិក សម្រាប់ប្រើក្នុងកិច្ចការជំនួញនិងការគ្រប់គ្រង។ លុះដល់សម័យពុទ្ធសករាជ ១៥០ឆ្នាំ (ឆ្នាំ៦៩៣ គ.ស.) វិជ្ជាអក្សរសាស្ត្រនេះ ក៏ផ្សាយទូទៅទាំងទ្វីបអឺរ៉ុប គឺផ្សាយទៅដល់ អ៊ីតាលី អេស្ប៉ាញ បារាំង និងអង់គ្លេសជាដើម។

ឯវិធីដែលកូនក្មេងក្រិករៀនអាន ក៏ហៅឈ្មោះតួអក្សរតាមភាសាហ្វេនីសៀង អានតួអក្សរបាន តែស្តាប់សេចក្តីមិនបាន ម្ល៉ោះហើយពាក្យមួយៗក៏វិបត្តិចាកសំឡេងដើមអស់ទៅ ដូចពាក្យដែលអានថា អេឡហ្វ បេថ។ល។ ក៏ក្លាយទៅជា អាលហ្វៈ បេតៈ (A lpha, béta) ទៅ។ ឯពាក្យបារាំងថា (Alphabét) គឺក្លាយមកពីពាក្យនេះដែរ មិនតែប៉ុណ្ណោះសោត គ្រឿងសម្រាប់សរសេរ ដូចក្រដាសជាដើម ក៏ផ្សាយចូលទៅអឺរ៉ុបដែរ បានជាពួកអឺរ៉ុប មានបារាំងនិងអង់គ្លេសជាដើម ហៅឈ្មោះក្រដាសនេះតាមភាសាអេហ្ស៊ីប ដែលហៅថា ប៉េប៉ាយ៉ាស គ្រាន់តែវិបត្តិសំឡេងប៉ុណ្ណោះ ដូចបារាំង ហៅថា ប៉ាប្យេរ (papier) អង់គ្លេស ហៅថា ប៉េប៉ឺរ៍ (paper)រហូតមកដល់សព្វថ្ងៃនេះ។ ក្រដាសប៉េប៉ាយ៉ាស ដែលក្រិកនាំយកមកប្រើ ពួកហ្វេនីសៀងបាននាំយកមកពីស្រុក បៃប្លូស៍ (Byblos) ដែលជាស្រុករបស់ហ្វេនីសៀង ហេតុនោះកាលបើក្រិកទទួលយកក្រដាសនោះទៅប្រើប្រាស់សម្រាប់សរសេរអក្សរ ក៏ឱ្យឈ្មោះថា បៃប្លៀ (Biblia) លុះចំណេរកាលមក ក៏យាវក្លាយទៅជាពាក្យអស់គ្លេសថា បៃប៊្លឺ បារាំងថា ប៊ិប្លឹ (Bible) ដែលជាពាក្យសម្រាប់ហៅឈ្មោះគម្ពីររបស់សាសនាគ្រិស្ត ក្នុងសម័យបច្ចុប្បន្ន។ តាមការពិត ពាក្យថា ប៊ិប្លឹ (Bible) មានន័យថាសៀវភៅ (ខៀវ ជុំ, ១៩៦២ : ៥-៨)។

### ២.៤.២. ការផ្សាយតួអក្សរចូលមកក្នុងទ្វីបអាស៊ី

សម័យមុនពុទ្ធសករាជ ៤៥០ ឆ្នាំ (៩៩៣ឆ្នាំមុនគ.ស.) ជនជាតិអាមែនី (Armenian) ជាជាតិមានអារ្យធម៌យ៉ាងខ្ពស់ ដោយបានទទួលអក្សរមកពីជនជាតិហ្វេនី ដែលជាជាតិប្រើតួអក្សរមុនគេបង្អស់ ហើយបានផ្សាយតៗមកដល់ដែនដីក្បែរទន្លេយូប្រាទិស ចូលរហូតទៅដល់ប្រទេសពែក្ស និងទ្វីបអាស៊ីភាគក្នុង រហូតដល់ព្រំដែនប្រទេសឥណ្ឌា។ តែមុនដែលអក្សរជនជាតិនេះផ្សាយចូលទូទៅក្នុងទ្វីអាស៊ី ក្នុងសម័យនោះ មានអក្សររូបសត្វរបស់ជនជាតិបាប៊ីឡូន ផ្សាយចូលមកមួយលើកហើយ ហេតុនេះ ជនជាតិទ្វីបអាស៊ី ទោះណាជាបានទទួលអក្សរមានតួសុទ្ធរបស់ជនជាតិអាមែនី មកប្រើហើយក៏ដោយ តែដោយខ្លួនមាននិស្ស័យពេញចិត្តនឹងអក្សររូបសត្វខ្លះ ក៏នៅ

តែកែសម្រួលឱ្យទៅជាអក្សរមានតួសុទ្ធសាធមិនកើត គឺនាំគ្នាកែសម្រួលខ្លះដែរ តែមិនអស់ ដូចចិនបានកែសម្រួលតួអក្សរពីរូបសត្វខ្លះ មកជាអក្សរមានតួសុទ្ធៗ តែក៏នៅរញ៉េមរញ៉ៃមានសណ្ឋានដូចជារូបសត្វដដែល ព្រោះតែនៅជាប់និស្ស័យនឹងអក្សររូបសត្វដែលជាអក្សរផ្សាយចូលមកក្នុងជាន់មុន។

ហេតុនេះ អក្សររបស់ជនជាតិក្នុងទ្វីបទាំងពីរគឺអាស៊ីនិងអឺរ៉ុបនេះមានសណ្ឋានខុសគ្នា ពោលគឺអក្សររបស់ជនជាតិក្នុងទ្វីបអឺរ៉ុប ជាអក្សរមានទ្រង់ទ្រាយរលីងស្អាត ដោយគេបានទទួលពីជនជាតិហ្វេនី ហើយក្រិកយកទៅកែឱ្យមានរបៀបមួយលើកទៀត។ ឯអក្សររបស់ជនជាតិអាស៊ី ជាអក្សរមានទ្រង់ទ្រាយមិនរលីងស្អាត ដោយបានទទួលពីជនជាតិបាប៊ីឡូន ដែលបានផ្សាយមកមុនគេ។

ហេតុការណ៍ទាំងនេះ នាំឱ្យយើងសន្និដ្ឋានបានថា ជនជាតិអឺរ៉ុប ចូលចិត្តខាងការសាងឫទ្ធិអំណាច ហេតុនោះទើបគេប្រើអក្សររលីងស្អាតឱ្យសមទៅតាមអ្នកសាងឫទ្ធិអំណាច ព្រោះអក្សរបែបនេះ ប្រើការបានឆាប់រហ័ស។ ឯជនជាតិភាគអាស៊ីចូលចិត្តខាងសិល្បវិជ្ជា មានចម្លាក់ក្បាច់ក្បូរជាដើម ហេតុនោះទើបចូលចិត្តប្រើអក្សរបែបនេះ ព្រោះស្រួលក្នុងការរចនាជាក្បាច់ក្បូរផ្សេងៗ (ខៀវ ជុំ, ១៩៦២: ៨-១០)។

សរុបមក ប្រព័ន្ធសំណេរទាំងនោះចែកជាបួនប្រភេទ គឺអក្សររូបភាពឬអក្សរគំនូរ អក្សរគំនិត អក្សរព្យាង្គ និងអក្សរអក្ខរក្រមឬអក្សរសូរសំឡេង។ អក្សររូបភាព អក្សរគំនិត និងអក្សរព្យាង្គមានការលំបាកសម្រាប់កត់ត្រាព្រឹត្តិការណ៍ឬរឿងរ៉ាវផ្សេងៗ ព្រោះវាត្រូវការសញ្ញារាប់សិបលាន ហើយចេះតែកើនជាលំដាប់សម្រាប់សម្គាល់បញ្ញត្តិថ្មី។ ចំណែកអក្សរអក្ខរក្រម ឬអក្សរសូរសំឡេងដែលជាសញ្ញាអក្សរកើតឡើងចុងក្រោយគេ ត្រូវបានគេបង្កើតឡើងតាមសំឡេងសម្តីរបស់មនុស្ស ដែលគេចែកជាសញ្ញាព្យញ្ជនៈសម្រាប់កត់ត្រាសូរព្យញ្ជនៈ សញ្ញាស្រៈសម្រាប់កត់ត្រាសូរស្រៈ។ ផ្តើមចេញពីសញ្ញាទាំងពីរនេះ គេយកទៅកត់ត្រាបានពាក្យពេចន៍រាប់សិបលានទៅតាមសូររបស់ពាក្យទាំងនោះ និងកត់ត្រាសូរសំឡេងនៃភាសាផ្សេងៗបានថែមទៀត។ អក្សរត្រូវបានចាប់កំណើតឡើងតាមការរីកចម្រើននៃសង្គមមនុស្ស ពិសេសគឺសង្គមមួយដែលត្រូវបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ ក្បួនច្បាប់សម្រាប់គ្រប់គ្រងទឹកដី ពោលគឺការបង្កើតរដ្ឋ។ ពេលនេះ អក្សរបានបំពេញតួនាទីយ៉ាងសកម្មក្នុងវិស័យអប់រំ រដ្ឋបាល ពាណិជ្ជកម្ម និងវិស័យសាសនាជាដើម។

## ៣. អក្សរខ្មែរនិងអក្ខរាវិរុទ្ធនៃភាសាខ្មែរ

### ៣.១. អក្សរខ្មែរ

#### ៣.១.១. ប្រវត្តិអក្សរខ្មែរ

អក្សរខ្មែរមិនមែនកើតឡើងស្មើនឹងភាសាខ្មែរទេ ព្រោះសម័យដែលមនុស្សស្ថិតនៅលើកោះគោកធ្លកដំបូងនោះ គ្រាន់តែបង្កើតបាននូវភាសាសម្រាប់និយាយប្រាស្រ័យគ្នាប៉ុណ្ណោះ ចំណែកអក្សរសម្រាប់ជាគ្រឿងចារឹកសម្គាល់មិនទាន់មានកើតនៅឡើយទេ។ ដូចនេះមនុស្សជំនាន់នោះមិនអាចចេះសរសេរសំបុត្រស្នាម ផ្ញើទៅមករកគ្នា ឬចេះកត់ត្រាអ្វីៗឡើយ។ បើគេចង់កត់ចំណាំអ្វីមួយ គេមានតែគ្រឿងចងចាំក្នុងចិត្តប៉ុណ្ណោះ។ មនុស្សសម័យនោះ ទំនងជាយកហេតុភេទផ្សេងៗ ជាគ្រឿងចំណាំ ដូចជាយករដូវស្លឹកឈើលាស់ ឬឈើផ្លែធ្វើជាគ្រឿងចំណាំខាងពេលវេលាជាដើម។

លុះចំណេរតមក ដល់គ្រាដែលខ្មែរបានទទួលអារ្យធម៌ឥណ្ឌា ក៏បង្កើតដោយសន្និដ្ឋានជារូបរាងអក្សរ ដោយអ្នកប្រាជ្ញសម័យនោះ ប្រឌិតយកតាមបែបអក្សរឥណ្ឌាមួយបែបនៅខាងទក្ខិណាបថ (ភូមិភាគផ្នែកខាងត្បូងលើខ្ពង់រាបដេកកៅ «Dekkau»)។ អក្សរឥណ្ឌាមានច្រើនយ៉ាងណាស់ ប៉ុន្តែបែបអក្សរដែលមានអាយុចាស់ជាងគេ គឺអក្សរ «ព្រាហ្មី» អ្នកស្រុកឥណ្ឌាបុរាណបានសន្មតថា ជាអក្សរដែលព្រះព្រហ្មបានបង្កើតមក ទុកសម្រាប់ឱ្យមនុស្សប្រើប្រាស់ តែតាមពិតគឺមនុស្សខ្លួនឯងទេ ដែលជាអ្នករកមធ្យោបាយបង្កើតតួអក្សរ ដែលជាគំនូសសម្គាល់សម្រាប់សរសេរប្រាស្រ័យគ្នាទៅវិញទៅមក។ អក្សរព្រាហ្មីនេះ មានរូបរាងជាតួមួយអង្គៗ ប្លែកៗពីគ្នា តែវាមានវិធីផ្សំស្រៈ

ព្យញ្ជនៈ ទំនងដូចអក្សរដែលខ្មែរយើងប្រើសព្វថ្ងៃនេះ។ វាមានអក្សរច្រើនបែបទៀត ដែលកើតបន្តមកពីអក្សរព្រាហ្មី ហើយមានវិធីប្រើប្រហាក់ប្រហែលគ្នា ខុសមួយតែត្រង់រូបភាពប៉ុណ្ណោះ។ ព្រះបាទកៅណ្ឌិន្យដែលជាបឋមក្សត្រខ្មែរ ទ្រង់បានដឹកនាំ មិនត្រឹមតែទំនៀមទម្លាប់ ប្រពៃណី សាសនាឥណ្ឌា អ្នកសាបព្រោះឱ្យសាយភាយលើប្រទេសយើងប៉ុណ្ណោះទេ ទ្រង់បាននាំទាំងបែបអក្សរឥណ្ឌា[2] នៅផ្នែកទក្ខិណាបថ (ខាងត្បូង) មកផ្សាយនៅក្នុងប្រទេសយើងផង។ អក្សរនោះមានបែបភាពរាងមូលៗ ដែលយើងប្រឌិត យកលំនាំតាមឱ្យកើតបានជារូបរាងអក្សរជាតិយើងសព្វថ្ងៃនេះ។ យើងគួរចាំទុកថា ប្រជាជាតិខ្មែរយើងតាំងពីបុរាណមក ជាជាតិមួយមានសិល្បៈនិងទេពកោសល្យជាប់នឹងខ្លួនជានិច្ច គឺថាបើធ្វើអ្វីមួយ លុះណាតែខ្លួនចេះរចនា ទើបសុខចិត្តសន្និដ្ឋានថាបានការ។ ដូចជាការប្រើអក្សរឥណ្ឌាប៉ែកខាងត្បូងនេះជាដើម បុព្វបុរសយើង មិនមែនប្រើតាមបែបឥណ្ឌាសុទ្ធៗទេ លោកបានប្រឹងរចនាកាឡៃបែបអក្សរនេះបន្តិចម្តងៗ ត្រាតែកើតបានជាបែបពិសេសដោយឡែក គឺធ្វើឱ្យមានលក្ខណៈជាអក្សររបស់ជាតិខ្លួនពិតៗ (លី ធាមតេង, ១៩៦០: ៦-៧)។

ដូចគ្នានឹងការបង្កើតរដ្ឋនានាដែរ ការបង្កើតរដ្ឋខ្មែរ គឺត្រូវការជាចាំបាច់នូវតួអក្សរសម្រាប់ប្រើប្រាស់ក្នុងវិស័យនយោបាយ រដ្ឋបាល និងការផ្សព្វផ្សាយសាសនា។ ដូច្នេះ ហ៊ុន ទៀន ដែលជាព្រាហ្មណ៍មកពីឥណ្ឌាភាគខាងត្បូងនោះ ក៏សម្រេចយកប្រព័ន្ធសំណេររបស់ឥណ្ឌាខាងត្បូងមកអនុវត្តនៅរដ្ឋខ្មែរដំបូងតែម្តង។ ផ្អែកតាមសិលាចារឹកដែលបានរកឃើញនៅក្នុងប្រទេសខ្មែរនិងផ្ទៀងផ្ទាត់ទៅនឹងបណ្តាទម្រង់អក្សរឥណ្ឌាភាគខាងត្បូងធ្វើឱ្យយើងដឹងថាអក្សរខ្មែរមានជាប់ទាក់ទងនឹងអក្សរឥណ្ឌាមួយចំនួន ដូចជាអក្សរព្រាហ្មី អក្សរខរោស្ត្រី អក្សរទេវនាគរី អក្សរតាមិលអក្សរកលិង្គជាដើម។ ព្រឹត្តិការណ៍ខាងលើនេះ ជារឿងធម្មតានៅក្នុងដំណាក់កាលដំបូងនៃការទទួលឥទ្ធិពលប្រព័ន្ធសំណេរ មុននឹងឈានទៅរកឯកភាពមួយខាងសំណេរនៅពេលក្រោយ គឺការសម្រេចប្រើប្រាស់តួអក្សរព្រាហ្មីតែមួយគត់។ នៅក្នុងស.វ.ទី១ ប្រព័ន្ធសំណេរខ្មែរមិនទាន់លេចរូបភាពច្បាស់លាស់នៅឡើយ ដោយសារតែសិលាចារឹកដែលគេរកឃើញនៅពេលនោះ គ្រាន់តែជាកាក់ ដុំថ្ម ឬបន្ទោងខ្សែក ដែលមានចារឹកតួអក្សរតិចតួចបំផុត។ គេត្រូវរង់ចាំរហូតដល់ចន្លោះស.វ.ទី២ ទៅស.វ.ទី៣ ទើបគេឃើញមានសិលាចារឹកមួយច្បាស់លាស់ ប៉ុន្តែប្រើភាសាសំស្ក្រឹតនៅឡើយ នោះគឺសិលាចារឹកវ៉ូកាញ់ ដែលប្រើតួអក្សរព្រាហ្មី។ ចំណែកភាសាខ្មែរ ត្រូវបានគេកត់ត្រានៅលើសិលាចារឹកនៅបួនសតវត្សក្រោយមកទៀត គឺតាមរយៈសិលាចារឹកអង្គរបុរី ដែលមានចុះកាលបរិច្ឆេទឆ្នាំ៦១១ (គេន រង្សី, ២០១៥)។



អក្សរព្រាហ្មី

ប្រភព៖ https://www.google.com/search?q=brahmi+script




អក្សរទេវនាគរី

ប្រភព៖ https://www.google.com/search? q=devanagari+script

[2] មានអ្នកស្រាវជ្រាវខ្លះថា អក្សរនោះឈ្មោះអក្សរគ្រិន្ថៈ តែយើងរកពុំទាន់បានប្រទះឃើញរូបរាងអក្សរនោះសោះ។

វាមានអ្នកប្រាជ្ញស្រាវជ្រាវតួអក្សរជាច្រើនរូប បានផ្ទៀងអក្សរសិលាចារឹកខ្មែរបុរាណ ជាមួយនឹងអក្សរឥណ្ឌាប៉ែកខាងត្បូងក៏ឃើញថា មានទ្រង់ទ្រាយដូចគ្នាមែន ដូចជាសិលាចារឹកខ្មែរនៅវ៉ូកាញ់ (ញ៉ាត្រាង-យៀកណាម) និងសិលាចារឹកនៅភ្នំហាន់ជ័យ (កំពង់ចាម) ជាដើម។ ប៉ុន្តែតួអក្សរទាំងនោះមិនមែនដូចគ្នានឹងអក្សរយើងសព្វថ្ងៃទេ ព្រោះបុព្វបុរសយើងចេះតែរកវិធីកែប្រែ ដូចបានពោលរួចមកហើយខាងលើ (លី ធាមតេង, ១៩៦០: ៨)។

### ៣.១.២. វិវត្តន៍នៃអក្សរខ្មែរ

អក្សរដែលខ្មែរយកគំរូតាមអក្សរឥណ្ឌាខាងត្បូងមកប្រើប្រាស់ក្នុងសម័យនោះ ពុំដូចគ្នានឹងអក្សរសម័យបច្ចុប្បន្ននេះទេ គឺត្រូវបានកែប្រែទ្រង់ទ្រាយចំនួន១០ ដង រួចមកហើយ ទើបបានជារូបរាងពិតប្រាកដ ដូចតួអក្សរដែលយើងប្រើប្រាស់សព្វថ្ងៃ។ ដំណើរវិវត្តមានច្រើនលើកច្រើនគ្រា តួអក្សររឹតតែច្រើនឡើង រឹតតែងាយសរសេរឡើង ហើយរឹតតែល្អឡើង ប្រកបដោយក្បូរក្បាច់យ៉ាងសមរម្យ។ នេះហើយជាស្នាដៃបុព្វបុរសខ្មែរ ដែលមានទេពកោសល្យខាងកែសម្រួល និងខាងបង្កើតថ្មី ដើម្បីបំពេញនូវកង្វះខាតនេះឯង។



ការវិវត្តនៃអក្សរខ្មែរបំនួន១០លើក

ប្រភព៖ ក្រសួងអប់រំ, វេយ្យាករណ៍ថ្នាក់ទី៨ បោះពុម្ពឆ្នាំ១៩៨៦

### ៣.១.៣. លក្ខណៈនៃអក្សរខ្មែរ

អក្សរមិនមែនជាសញ្ញាដាច់ដោចចេញពីគ្នា ដែលគេចេះតែយកមកកត់សម្គាល់សំឡេងក្នុងភាសានីមួយៗនោះឡើយ ប៉ុន្តែអក្សរ គឺជាកម្រងសញ្ញា ដែលទាក់ទងគ្នាជាក្បួន ជាវិធី ស្ថិតនៅលើមូលដ្ឋាន ឬគោលណាមួយជាដរាប។ យ៉ាងណាមិញ អក្សរខ្មែរក៏ដូចនោះដែរ ពោលគឺជាក្បួននៃតួសញ្ញាដែលទាក់ទងគ្នាទៅនឹងមូលវិធីដ៏សំខាន់។

នៅក្នុងអក្សរខ្មែរ គេនិយមភ្ជាប់ស្រៈនិងព្យញ្ជនៈឱ្យជាប់គ្នា ដែលជាហេតុនាំឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងស្រៈនិងព្យញ្ជនៈ។ ទំនាក់ទំនងនេះបណ្តាលឱ្យកើតមានស្រៈកប់តួឬស្រៈអនុស័យ ក្នុងព្យញ្ជនៈនេះឯង។ ស្រៈកប់តួខ្មែរមានពីរប្រភេទ គឺ អ-អ៊។ ឯស្រៈកប់តួបាលីមានតែមួយគឺ អៈ។ ដោយមានស្រៈអនុស័យពីរបែបកប់តួនៅក្នុងព្យញ្ជនៈនេះហើយ ទើបនាំឱ្យមានព្យញ្ជនៈអនុស័យពីរបែបដែរ គឺព្យញ្ជនៈអនុស័យពួកអនិងពួកអ៊។ ចំណែកស្រៈនិស្ស័យដូចជា ា ិ ី ឹ ឺ ុ ូ ក៏ចែកជាពីរប្រភេទស្របទៅនឹងព្យញ្ជនៈអនុស័យពួកអ និងពួកអ៊ ដូចនេះទៀត ប៉ុន្តែមានសញ្ញាសម្គាល់តែមួយបែប (ឧ. សញ្ញា «ា» សម្គាល់សូរ «អា» ផងនិង«អ៊ា» ផង)។ អាស្រ័យដោយមានស្រៈអនុស័យ ក្នុងព្យញ្ជនៈនេះហើយ ទើបព្យញ្ជនៈអនុស័យមួយតួៗ អាចទៅជាព្យាង្គមួយបាន។ ឧទាហរណ៍ ត (តទល់) ឧ (ឧត្រី) ស(ពណ៌ស)។

លក្ខណៈពិសេសនេះខុសប្លែកអំពីអក្សររ៉ូម៉ាំង (Roman) មានអក្សរបារាំង អង់គ្លេស ជាដើម ដែលព្យញ្ជនៈមួយតួពុំអាចទៅជាព្យាង្គបានទេ ដូចជា P, B, K, I ជាដើម។ ក្នុងអក្សរខ្មែរ ព្យញ្ជនៈពីរតួនៅរៀងគ្នា ក៏អាចទៅជា

ព្យាង្គឬពាក្យមួយបានដែរ ដូចពាក្យ មក បង កក...។ ចំណែកនៅក្នុងអក្សររ៉ូម៉ាំង ដែលនិយមផ្ដាច់ស្រៈចេញពីព្យញ្ជនៈ ហើយដែលមិននិយមប្រើស្រៈអនុស័យ ព្យញ្ជនៈអនុស័យដូចខ្មែរនោះ ព្យញ្ជនៈ ២ ឬ៣តួនៅជិតគ្នា ពុំអាចទៅជាព្យាង្គ ឬពាក្យបានទេ ប៉ុន្តែជាព្យញ្ជនៈសំយោគ (ព្យញ្ជនៈផ្សំ) ទៅវិញ ឧ. Tr (tree), spl (splice=ត, បន្ត)។ ក្រោយដែលបានសិក្សាអំពីប្រភព ការវិវត្ត និងលក្ខណៈពិសេសនៃអក្សរខ្មែរមក យើងឃើញថា ខ្មែរបានយកលំនាំអក្សរឥណ្ឌាមកប្រើប្រាស់ជាលើកដំបូងក៏ពិតមែន ប៉ុន្តែជនជាតិខ្មែរមានទេពកោសល្យខាងច្នៃឱ្យបានសមស្ងួនខាងបង្កើតថ្មីឱ្យសម្បូរគ្រប់គ្រាន់ ព្រមទាំងមានក្បួនខ្នាត មានវិធីច្បាស់លាស់ សម្រាប់ជាតិខ្មែរយកទៅប្រើប្រាស់ក្នុងការកត់ត្រាគំនិត សញ្ចេតនា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាដើម (អ្នកស្រី ត្រឹង ងា, ១៩៧៤: ៥២)។

## ៣.២. អក្ខរាវិរុទ្ធនៃភាសាខ្មែរ

ស្នាដៃអក្សរសាស្ត្រនិងភាសានៅសតវត្សទី១៩ គឺជាលទ្ធផលនៃការវិវត្តតាមធម្មតានៃភាសា តាំងពីសតវត្សមុនៗ។ ភាសាខ្មែរមានពាក្យគ្រប់គ្រាន់ មានពាក្យវេយ្យាករណ៍គ្រប់គ្រាន់សម្រាប់ប្រើការក្នុងគ្រប់វិស័យ ដូចជាតុលាការ ប្រវត្តិសាស្ត្រ រដ្ឋការ អក្សរសិល្ប៍។ល។ សម្រាប់ឆ្លើយនឹងសេចក្ដីត្រូវការក្នុងការរស់នៅរាល់ថ្ងៃនៃប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់។ ការដែលប្រើប្រាស់ភាសានេះជាយូរមកហើយ នៅក្នុងដែនដីប្រទេសកម្ពុជាសព្វថ្ងៃ ហើយនិងនៅក្នុងដែនដីថៃនិងវៀតណាម គឺមកពីការអប់រំនិងការសិក្សាដែលរៀបចំឡើងដោយព្រះសង្ឃខ្មែរនៅតាមវត្តអារាម។ នៅសតវត្សទី២០ ភាសាខ្មែរពុំមានការវិវត្តដោយសេរីជាងពីសម័យមុនឡើយ។

ការបញ្ចូលវប្បធម៌និងភាសាទៅក្នុងកម្មវិធីសិក្សា ធ្វើឱ្យមានផលវិបាកផងនិងគុណប្រយោជន៍ផង។ ផលវិបាកជាក់ស្ដែងគឺរឿងបែបសាស្ត្រាល្បែងដែលសរសេរជាពាក្យកាព្យលោយបាត់សូន្យ ហើយគេឃើញមានរឿងប្រលោមលោកសរសេរជាពាក្យរាយចូលមកជំនួសវិញ។ ម្យ៉ាងទៀត ពាក្យខ្មែរ ឃ្លាខ្មែរ ល្បះខ្មែរ លែងមានការវិវត្តទៅមុខទៀតហើយ ជាពិសេសអ្នកចេះដឹងជាតិខ្មែរលែងចេះនិយាយភាសាខ្មែរ ព្រោះគេប្រើតែភាសាបារាំង គេឱ្យតម្លៃទៅលើអ្នកដែលចេះភាសាបារាំង។ ប៉ុន្តែភាសាបារាំងជាចំណេះចាំបាច់ចំពោះយុវជនខ្មែរ ដែលត្រូវសិក្សាពីវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេសនៅក្នុងបស្ចិមប្រទេស (ឃីន សុខ, ២០០៧: ២១-២២)។

### ៣.២.១. ស្ថាប័នពិនិត្យអក្ខរាវិរុទ្ធនៃភាសាខ្មែរ

នៅក្នុងប្រទេសខ្មែរ ពុំមានស្ថាប័នជាផ្លូវការសម្រាប់ពិនិត្យលើការប្រើប្រាស់ភាសាទេ។ បើកាលណាគេមានការងឿងឆ្ងល់ចំពោះអក្ខរាវិរុទ្ធ គេមើលវចនានុក្រមពុទ្ធសាសនបណ្ឌិត្យតែមួយមុខប៉ុណ្ណោះ។

មុនគ.ស. ១៩៣៨ ឆ្នាំដែលគេបោះពុម្ពវចនានុក្រមខ្មែរ កាលណាគេមានបញ្ហាក្នុងការធ្វើឃ្លា គេសួរទៅអ្នកធ្លាប់បួសរៀន ទៅគ្រូបង្រៀន ព្រោះអ្នកទាំងនោះស្គាល់ឃ្លាខ្មែរដោយសារគេប្រើរាល់ថ្ងៃ និងដោយសារគេបានអានអត្ថបទជាច្រើន កាលពីគេនៅរៀននៅវត្ត។

ក្រោយគ.ស. ១៩៣៨ ការពិនិត្យលើភាសាខ្មែរបន្តិចម្ដងៗ ជាភារកិច្ចរបស់សម្ដេច ជួន ណាត ព្រះសង្ឃរាជគណៈមហានិកាយ ដែលលោកជាសមាជិកមួយរូបក្នុងគណៈកម្មការតែងវចនានុក្រម។ មុនដំបូង លោកគ្រាន់តែជាសមាជិកនៃគណៈកម្មការ។ នៅថ្ងៃទី៦ មករា គ.ស. ១៩២៧ ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី បានតែងតាំងសម្ដេច ជួន ណាត និងឧកញ៉ា ស៊ូ ទីប្រឹក្សាសាលាឧទ្ធរណ៍ឱ្យត្រួតពិនិត្យការបោះពុម្ពវចនានុក្រម ក្រោមការមើលខុសត្រូវរបស់នាយករដ្ឋមន្ត្រី។ ដោយលោកមានស្នាដៃជាច្រើន ទាក់ទងនឹងការសិក្សាពីព្រះពុទ្ធសាសនា ការបដិបត្តិព្រះពុទ្ធសាសនា សមាគមអ្នកនិពន្ធខ្មែរ បានសុំនិមន្តលោកទៅធ្វើអត្ថាធិប្បាយនៅវិទ្យុជាតិអំពីអក្សរសាស្ត្រខ្មែរ រាល់ថ្ងៃសុក្រចាប់តាំងពីគ.ស.១៩៦១។ ចាប់តាំងពីពេលនោះ ប្រជាពលរដ្ឋខ្មែរក៏ទទួលស្គាល់សម្ដេចជាអ្នកប្រាជ្ញខាងភាសាខ្មែរ។ តាមការពិតសម្ដេចពន្យល់នៅវិទ្យុជាតិតែអំពីអក្ខរាវិរុទ្ធនិងដើមកំណើតរបស់ពាក្យតែប៉ុណ្ណោះ។ ហេតុនេះហើយបានជាវចនានុក្រមខ្មែរ ដែលលោកជាអ្នកទទួលខុសត្រូវ គេចាត់ទុកជាឯកសារគោលក្នុងការសរសេរ និង

ការនិយាយភាសាខ្មែរសព្វថ្ងៃ។ ក្រោយមកនៅគ.ស. ១៩៦៧ គណៈកម្មការខេមរយានកម្មក្នុងការសិក្សាសម្រេចប្រើអក្ខរាវិរុទ្ធតាមវចនានុក្រមនោះ។

ការកែប្រែអក្ខរាវិរុទ្ធនៅជាប់ជាមួយនឹងការចងក្រងវចនានុក្រម។ ការកែប្រែអក្ខរាវិរុទ្ធនេះ ធ្វើឱ្យមានការបារម្ភជាខ្លាំងនៅពេលនោះ ព្រោះអាចបង្កើតជម្លោះរវាងព្រះសង្ឃ ឧបាសក ខាងគណៈធម្មយុត្តិ និងព្រះសង្ឃឧបាសកខាងគណៈមហានិកាយ។ អ្នកខ្លះយករឿងនេះទៅប្រើជាលេសចោទថា សមាជិកគណៈកម្មការចងក្រងវចនានុក្រម ជាអ្នកបំផ្លាញវប្បធម៌ខ្មែរ។ បើគេយករឿងនេះមកពិនិត្យមើលឱ្យល្អិតល្អន់ គេឃើញថា មានរឿងជម្លោះផ្ទាល់ខ្លួន ជារឿងបក្សពួក ហើយយកបញ្ហាភាសាមកធ្វើជាឡប់ឡែ (ឃីន សុខ, ២០០៧: ២៣)។

### ៣.២.២. វចនានុក្រមខ្មែរ

បន្ទាប់ពីសោកនាដកម្មនៅគ.ស. ១៩៧៥ មក វចនានុក្រមខ្មែរត្រូវចាត់ទុកជាឯកសារទីមួយសម្រាប់ភាសាខ្មែរ។ គណៈកម្មការរៀបចំវចនានុក្រមមានសមាជិក១៨នាក់ ព្រះរាជវង្សានុវង្ស២អង្គ រដ្ឋមន្ត្រីឬតំណាងរដ្ឋមន្ត្រី៤រូប អ្នកច្បាប់១រូប អ្នកប្រាជ្ញរាជបណ្ឌិត៤រូប និងព្រះសង្ឃ៧អង្គ។ ក្នុងចំណោមអ្នកប្រាជ្ញរាជបណ្ឌិតនិងព្រះសង្ឃមួយភាគធំជាសាស្ត្រាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ហេតុនេះហើយបានជា ពាក្យថ្មីយកមកពីបាលីនិងសំស្ក្រឹត ហើយអត្ថបទខ្លះនៅក្នុងវចនានុក្រម ជិតជាប់ទស្សនៈព្រះពុទ្ធសាសនា។ បរទេសដែលចូលរួមក្នុងកិច្ចការនេះ មានលោក សឺដេស (G. Coedès) ពេលនោះលោកជាចាងហ្វាងសាលាបារាំងសេសចុងបូព៌ាប្រទេស តែលោកបាននៅជួយតែនៅពេលដំបូងប៉ុណ្ណោះ។ ចាប់តាំងពីគ.ស. ១៩២៧ តរៀងមក ព្រះគ្រូ ជួន ណាត បានទទួលបន្ទុកពិនិត្យសេចក្ដីពន្យល់ទាំងអស់ ហើយនិងការរៀបចំសម្រាប់បោះពុម្ពលើកទី១។

នៅសម័យតាក់តែងវចនានុក្រមនោះ សមាជិកទាំងអស់ពុំមានចំណេះខាងភាសាវិទ្យាទេ។ ម្យ៉ាងទៀតឯកសារសំខាន់ៗ សម្រាប់យកមកប្រើការក៏គ្មាន ដូចជា សៀវភៅវេយ្យាករណ៍ភាសាខ្មែរ អត្ថបទសិក្សាពីឫសគល់នៃពាក្យ និងប្រវត្តិនៃភាសាជាដើម។ ដោយហេតុនេះ បានជាគេឃើញមានការខ្វះខាតខ្លះ ដែលជៀសមិនរួចដូចជា នៅខ្វះពាក្យជាច្រើនដែលគេប្រើប្រាស់នៅសម័យនោះ អត្ថន័យនៃពាក្យមិនច្បាស់លាស់ មានការភាន់ច្រឡំចំពោះឫសគល់នៃពាក្យខ្លះ ហើយរបៀបរៀបតួអក្សរនៅក្នុងវចនានុក្រមនោះ មិនទាន់ត្រឹមត្រូវ។ល។ ភាគទី១បោះពុម្ពនៅគ.ស. ១៩៣៨ ឯភាគទី២ បោះពុម្ពនៅគ.ស. ១៩៤៣។ បន្ទាប់មកគេបោះពុម្ពពីរលើកទៀត ដោយពុំបានកែប្រែអ្វីច្រើនទេ។ នៅគ.ស. ១៩៦២ គេបោះពុម្ពជាលើកទី៤ ដែលមានបញ្ចូលពាក្យថ្មី ដោយស្នាព្រះហស្តរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត និងអ្នកប្រាជ្ញ ២រូបទៀត គឺ កិម តូរ និងញូង សឿង។ នៅគ.ស. ១៩៦៧ វចនានុក្រមនេះ គេបោះពុម្ពមួយលើកទៀត ហើយជាលើកចុងក្រោយ។ លើកនេះមានគណៈកម្មការមួយ មានសមាជិក៤រូប ជួយពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ។ ដោយចង់ឱ្យវចនានុក្រមនោះ នៅមានលក្ខណៈវិទ្យាសាស្ត្រ ត្រឹមត្រូវតាមភាសាវិទ្យា លោកលាង ហាប់អាន ចាងហ្វាងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលទទួលបន្ទុកបោះពុម្ពវចនានុក្រម សុំឱ្យសម្ដេចព្រះសង្ឃរាជ ជួន ណាត ពេលនោះព្រះជន្ម៨៤ ព្រះវស្សា ជួយពិនិត្យថែមលើគណៈកម្មការនោះទៀត (ឃីន សុខ, ២០០៧: ២៨)។

### ៣.២.៣. មូលហេតុដែលនាំឱ្យអក្សរខ្មែរមានជើង

បើគេពិចារណា វរជនខ្មែរណាក៏អាចយល់បានដែលថា អក្សរខ្មែរមាន «ជើង» ពីព្រោះអក្សរនេះមានស្រៈកប់ ឧទាហរណ៍ក្នុងអក្ខរាវិរុទ្ធនៃពាក្យ «កង» យើងពុំឃើញមានសញ្ញាស្រៈទេ ទោះជាមួយព្យញ្ជនៈ «ក» ក្ដី ឬជាមួយព្យញ្ជនៈ «ង» ក្ដី ប៉ុន្តែតាមទម្លាប់ យើងដឹងថា ក្នុងចំណោមព្យញ្ជនៈទាំងពីរនេះ ព្យញ្ជនៈទី១ ជាព្យញ្ជនៈបង្គោល ហើយបុព្វបុរសយើងបានសន្មតថា មានស្រៈ «អ» កប់ក្នុងនោះ រីឯព្យញ្ជនៈ «ង» វិញ វាជាព្យញ្ជនៈប្រកបឬតួប្រកបដែលគ្មានស្រៈកប់ទេ។ បើផ្អែកលើអក្ខរក្រមសូរវិទ្យាអន្តរជាតិ «International Phonetic Alphabet» (IPA) នោះស្រៈកប់តួត្រូវចេញជារូបមកក្រៅ ដែលភាសាវិទូគ្រប់សាសន៍អាចអានបានដែរ ថា [kɒːŋ] ។ ប្រសិនបើយើងអាច

សន្ទតបណ្ដោះអាសន្នមួយពេល (ចាំបាច់ក្នុងនិទស្សន៍) ថាព្យញ្ជនៈខ្មែរឈប់មានស្រៈកប់ ហើយប្រសិនបើយើងអាចសុំសេចក្ដីអនុញ្ញាតប្រើ «អ» ជាស្រៈ (បណ្ដោះអាសន្ន) នោះ យើងត្រូវសរសេរ «កអង» ទើបអាចអានថា [kɒːŋ] បាន ហើយបើគេសរសេរ «កង» នោះ វាត្រូវនឹង «ព+ព ឬកន្សោមព្យញ្ជនៈ» ទៅវិញទេ ដែលយើងអាចដាក់ជាអក្ខរក្រមសូរវិស័យអន្តរជាតិ ដូចនេះ៖ [kŋ] ឬ [ក្ង]។ ក្នុងសម្មតិកម្មនេះ គេឥតត្រូវការ «ជើង ្ង » ទេ (តាមសម្មតិកម្មនេះ ជើងអក្សរខ្មែរឯទៀតទាំងប៉ុន្មានក៏ឈប់មានប្រយោជន៍ដូចគ្នាដែរ) (ព្រុំ ម៉ល់, ២០១២: ១)។

ម្យ៉ាងទៀតគួរកត់សម្គាល់ថា នៅសម័យមុនអង្គរនិងសម័យអង្គរ គេដាក់វិរាម (អាន «វិរាមៈ») នៅលើតួប្រកបដើម្បីសម្គាល់ថា តួប្រកបនោះគ្មានស្រៈកប់ទេ ឧទាហរណ៍ ទូកិង កុកិសក...។ ដោយសារវិរាម គេអាចដឹងថា ក្នុងពាក្យ «ទូកិង» ព្យញ្ជនៈ «ក» ជាតួប្រកប (ឥតមានស្រៈកប់) ហើយគេត្រូវអានថា «ទូក-ង»។ រីឯចំពោះពាក្យ «កុកិសក» គេត្រូវដឹងថា ព្យញ្ជនៈ «ក» ជាតួប្រកប (ឥតមានស្រៈកប់) ហើយអក្សរ «ស» និង «ក» សុទ្ធតែមិនមែនជាតួប្រកប ដូច្នេះគេត្រូវអានថា «កុក-ស-ក»។

សម្មតិកម្មនេះមានភាពស្របនិងភាពជាក់ស្ដែងនៅក្នុងអក្សរថៃដែលមានស្រៈ [ɒː] (សរសេរជាស្រៈថៃដូចនេះ « ะ »)។ គេគ្មានស្រៈកប់ទេ ដែលជាហេតុធ្វើឱ្យអក្សរគេឥតមានជើង ហើយក៏ឥតមានព្យាង្គតម្រួតដែរ។ ការពិពណ៌នាទាំងប៉ុន្មាន (ទាំងសម្មតិកម្ម ទាំងភាពជាក់ស្ដែងក្នុងអក្សរថៃ) បង្ហាញឱ្យឃើញថា អក្ខរាវិរុទ្ធថៃមិនបាច់ខ្វីព្យាង្គរាយពីអក្ខរាវិរុទ្ធខ្មែរទេ ពីព្រោះគេគ្មានស្រៈកប់និងគ្មានជើងព្យញ្ជនៈដើម្បីដាក់ខាងក្រោមតួព្យញ្ជនៈ (ព្យាង្គតម្រួតមិនអាចទៅរួចទេ ហើយព្យាង្គរាយជាច្រកតែមួយគត់សម្រាប់អក្ខរាវិរុទ្ធថៃ) (ព្រុំ ម៉ល់, ២០១២: ២)។

## សំណួរ

១. តើប្រព័ន្ធសំណេររបស់មនុស្សដំបូងមានលក្ខណៈបែបណា?

២. តើប្រព័ន្ធសំណេររបស់មនុស្សជំនាន់នោះ គេកត់ត្រាលើសម្ភារៈអ្វីខ្លះ?

៣. តើជនជាតិណាបង្កើតប្រព័ន្ធសំណេរមុនគេ? តើប្រព័ន្ធសំណេរទាំងនោះមានលក្ខណៈដូចម្ដេច?

៤. ចូររៀបរាប់អំពីអក្សររូបភាព អក្សរគំនិត។

៥. ចូររៀបរាប់អំពីអក្សរព្យាង្គ។

៦. តើអក្សរព្យាង្គ មានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ដែរឬទេ? ហេតុអ្វី?

៧. តើអក្សរសូរសំឡេងឬសំណេរអក្ខរក្រមបង្កើតឡើងដោយជនជាតិណា?

៨. ចូររៀបរាប់អំពីការផ្សព្វផ្សាយតួអក្សរចូលទៅទ្វីបអឺរ៉ុប។

៩. ចូររៀបរាប់អំពីការផ្សព្វផ្សាយតួអក្សរចូលទៅទ្វីបអាស៊ី។

១០. តើអក្សរខ្មែរមានដើមកំណើតមកពីណា ហើយវិវត្តប៉ុន្មានលើក?

១១. ហេតុអ្វីបានជាអក្សរខ្មែរមានជើង?

១២. ចូររៀបរាប់អំពីការកំណត់អក្ខរាវិរុទ្ធនៃភាសាខ្មែរ។

១៣. ចូររៀបរាប់អំពីអក្សរខ្មែរនាពេលបច្ចុប្បន្ន។

# មេរៀនទី៣
# សូរនិងប្រព័ន្ធសូរនៃភាសា

## ១. សូរនៃភាសា

ប្រទេសក្រិកសម័យបុរាណ ប្រមាណ១៥០០ឆ្នាំមុនគ្រិស្តសករាជដល់គ្រិស្តសករាជ៥០០ ឃើញមានគន្លង (តឹកតាង) នៃការសិក្សាអំពីភាសាប្រមាណ៥០០ឆ្នាំមុនគ្រិស្តសករាជ។ សម័យនោះអ្នកប្រាជ្ញក្រិកបានសិក្សាអំពីសូរនៃភាសា ដោយបានកំណត់អក្សរធ្វើជាបទដ្ឋាននៃសូរ ទាំងដែលសម័យនោះនៅមិនទាន់មានឧបករណ៍វិភាគសំឡេងនៅឡើយ។ ប៉ុន្តែអ្នកប្រាជ្ញក្រិកបុរាណ អាចចាត់របៀបនៃក្រុមអក្សរឱ្យមានលក្ខណៈជាប្រព័ន្ធ ដោយការសង្កេតពិនិត្យទៅលើអវយវៈដែលប្រើនៅក្នុងការនិយាយ និងដំណើរដែលធ្វើឱ្យសំឡេងកើតឡើង។ ទោះបីជាយ៉ាងណា ការសិក្សាអំពីសំឡេងនៅក្នុងសម័យនោះ ផ្តោតទៅលើសរីរៈក្នុងការបញ្ចេញសំឡេង (ដែលបច្ចុប្បន្នហៅថា សរីរៈសទ្ទតាវិទ្យា) ដោយយកអក្សរជនជាតិហ្វេនីសៀង (បច្ចុប្បន្នគឺនៅក្បែរឆ្នេរសមុទ្រមេឌីទែរ៉ាណេ) អំឡុងសម័យមុនគ្រិស្តសករាជមកកែតម្រូវប្រើប្រាស់។ អក្សរទាំងអស់នោះមានឈ្មោះហៅស្របជាមួយនឹងការបញ្ចេញសូរ (សួន ឱសថ, ២០១៣: ៨៦)។

ក្នុងអំឡុងពេលចូលកៀកសម័យក្រិក គឺប្រមាណ៥០០-៦០០ឆ្នាំមុនគ្រិស្តសករាជ នៅឥណ្ឌាមានការសិក្សាស្រាវជ្រាវអំពីភាសាសំស្ក្រឹត និងមានការលេចធ្លោខាងផ្នែកសូរ ប្រព័ន្ធវាក្យសព្ទ និងវេយ្យាករណ៍។ ចំណែកដែលជាប់ពាក់ព័ន្ធជាមួយនឹងសូរនាពេលនោះ មានការកំណត់តួអក្សរតាមគន្លងនៃការបញ្ចេញសំឡេងដូចគ្នា។ វិធានសិក្សាអំពីសូរនៃភាសាសំស្ក្រឹតរបស់ឥណ្ឌា បានបន្តមករហូតដល់សម័យសិក្សាអំពីសូរដែលមានលក្ខណៈជាវិទ្យាសាស្ត្រ (ឬហៅថា សទ្ទតាវិទ្យា)។ ចំណែកខ្លឹមសារមួយចំនួនដែលជាប់ពាក់ព័ន្ធជាមួយនឹងការអធិប្បាយសូរនៅក្នុងភាសាសំស្ក្រឹត ក៏មានប្រើនាពេលបច្ចុប្បន្ននេះដែរ (សួន ឱសថ, ២០១៣: ៨៧)។

សូរវិទ្យាមូលដ្ឋាន គឺជាសូរវិទ្យាដែលផ្តល់សញ្ញាណខ្លះៗ ដើម្បីឱ្យយើងអាចយល់សូរវិទ្យាឯទៀត។ សូរវិទ្យាអាគូស្ទិកសិក្សាអំពីការកកើតសូរដោយយកម្លាំងមួយដែលបានប៉ះទង្គិចជាមួយវត្ថុអ្វីមួយ និងបានធ្វើឱ្យវត្ថុនោះមានលំញ័រ។ លំញ័រនោះបានក្លាយទៅជារលក ហើយរលកនោះក៏រសាត់ទៅប៉ះនឹងត្រចៀកអ្នកស្តាប់។ សូរវិទ្យានេះជួយឱ្យយើងយល់ថា ហេតុអ្វីក៏ខ្យល់ដែលចេញពីសួតអាចបង្កើតបានជាសូរវិទ្យាបន្លឺ យល់អំពីការលើកដាក់សំឡេងក្នុងសូរសៀងវិទ្យាដែលមានសូរទាបឬសូរខ្ពស់ទៅតាមចង្វាក់នៃល្បះ។ សូរវិទ្យាបន្លឺឬសូរវិទ្យាសរីរសាស្ត្រជាមូលដ្ឋានដ៏សំខាន់ ដើម្បីជួយយើងឱ្យយល់អំពីសូរដែលត្រូវបានបន្លឺឡើងដោយប្រដាប់ដកដង្ហើម (ប្រើជាប្រដាប់បន្លឺសូរ)។ សូរវិទ្យាបន្សំជាតុបង្ហាញអំពីឥទ្ធិពលរវាងសូរក្នុងករណីខ្លះ កាលណាសូរទាំងនោះ ត្រូវបានគេផ្គុំជាមួយគ្នា ដូចជាការសម្របសូរ ការប្រើអាគម ការប្រើសន្ធិក្នុងភាសាខ្លះជាដើម។

ការពិសោធដែលប្រើអូស៊ីឡូក្រាម (oscillogramme) ស្ប៉ិចតូក្រាម (spectogramme) សូណូក្រាម (sonogramme) ជាជំនួយដល់សូរវិទ្យាអាគូស្ទិក ដើម្បីឱ្យអ្នកសូរវិទ្យាយល់អំពីលក្ខណៈអាគូស្ទិកផ្សេងៗនៃសូរ។

ប្រដាប់ពិសោធន៍ដែលប្រើគីម៉ូក្រាហ្វ (kymographe) សម្រាប់ពិនិត្យមើលវត្តមានឬអវត្តមាននៃលំញ័រខ្សែសំឡេង ប៉ាឡាតូក្រាហ្វ (palatographe) សម្រាប់ពិនិត្យមើលកន្លែងដែលអណ្តាតទៅប៉ះនឹងក្រអូម វិទ្យុលេខន៍ (radiographie) សម្រាប់វាស់បំណើកមាត់ (តូចឬធំទៅតាមប្រភេទនៃសូរ) ជាបច្ចេកវិទ្យាដែលជួយដល់សូរវិទ្យាបន្លឺ ដែលគេទទួលស្គាល់ថា ជាបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាពនៅសករាជ មុនសករាជអេឡិចត្រូនិក។ ឧបករណ៍ទាំងនេះជួយឱ្យយើងយល់អំពីទីបន្លឺសូរ របៀបបន្លឺសូរ ផ្លូវខ្យល់ចេញពីសួតមកក្រៅ (តាមមាត់ឬតាមច្រមុះ) លំញ័រខ្សែសំឡេង (ញ័រឬមិនញ័រ)។

នៅពេលបច្ចុប្បន្ន គេប្រើប្រអប់អេឡិចត្រូនិក (ផ្គុំជាមួយកុំព្យូទ័រនិងមីក្រូហ្វូន) ដែលមានកម្មវិធីរៀបចំឡើង ដើម្បីថតយកលក្ខណៈអាគូស្ទិកផ្សេងៗនៃសូរ ដូចជាឆាយាភូត (ស្ពាមស្ប៊ិចនៃសូរ) និងលក្ខណៈអាគូស្ទិកឯទៀត ព្រមទាំងបន្ទាត់បង្ហាញការឡើងចុះនៃកម្ពស់របស់សូរក្នុងការលើកដាក់សំឡេង កាលណាយើងអានល្បះផងទៀត (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ១-២)។

## ១.១. និយមន័យសូរវិទ្យា

សូរវិទ្យា គឺជាវិទ្យាសាស្ត្រមួយដែលសិក្សាអំពីសូរសំឡេងរបស់ភាសា។ ក្នុងផ្នែកបញ្ចេញសូរដោយសរីរាង្គសម្រាប់និយាយ និងផ្នែកទទួលសូរដោយសរីរាង្គសម្រាប់ស្ដាប់។

សូរវិទ្យា គឺជាវិទ្យាសាស្ត្រដែលសិក្សាពីលក្ខណៈនៃការបង្កើតសូរសំឡេងរបស់ភាសាមនុស្ស ជាពិសេសគឺសូរសំឡេងទាំងឡាយណាដែលមនុស្សប្រើក្នុងការនិយាយ។

លោក ទ្រូបេតស្កយ (Troubetzkoy) ភាសាវិទូជាតិរុស្ស៊ី ជាអ្នកនិពន្ធស្នាដៃភាសាវិទ្យាដ៏ល្បីមួយឈ្មោះថា «គោលការណ៍សទ្ទតាវិទ្យា» ឱ្យនិយមន័យសូរវិទ្យាថា ជាវិទ្យាសាស្ត្ររបស់សូរទាំងឡាយដែលជាផ្នែកមួយនៃរូបធាតុរបស់សកម្មភាពសម្ដីរបស់មនុស្ស (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ១)។

សូរវិទ្យា ជាទូទៅ សិក្សាពីកន្សោមលទ្ធភាពសូរភាសារបស់មនុស្ស (សិក្សាតែសូរភាសាមនុស្ស) តាមរយៈភាសាធម្មជាតិ។ ម្យ៉ាងទៀត កាលណាគេសិក្សាពីសូរវិទ្យា គេត្រូវចែកឱ្យបានជ្រះស្រឡះរវាងសូរនិងសញ្ញាអក្សរ ដោយហេតុថា សញ្ញាអក្សរមួយមិនអាចជាតំណាងសូរមួយឬក៏សូរមួយមិនអាចតាងដោយតួអក្សរមួយ បានគ្រប់ពេលនោះឡើយ បានន័យថា ជួនកាលសញ្ញាមួយអាចជាតំណាងសូរពីរឬក៏ច្រើន ឬសូរពីរអាចតាងដោយសញ្ញាតែមួយក៏មាន ឧទាហរណ៍ ក្នុងភាសាខ្មែរ ក្នុងពាក្យ [kɒː] យើងឃើញមានសញ្ញា «ក» (គេសរសេរបែបនេះ ដោយគេសន្មតថា ស្រៈ «អ» គ្មានរូប ហើយកប់ក្នុងតួព្យញ្ជនៈ «ក») តែមានសូរពីរគឺ សូរ[k] និងសូរស្រៈ [ɒː]។ ក្នុងពាក្យ «កក» គេឃើញមានសញ្ញាពីរ តែមានសូរបី គឺ [k] + [ɒː] + [ʔ] (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ១)។

មុខវិជ្ជានេះក៏បានបង្ហាញពីរបៀបនៃការពណ៌នានិងការចាត់ថ្នាក់សូរ ការកត់សូរសំឡេងនៃភាសាផងដែរ។ ការបែងចែកមែកធាងសូរវិទ្យា អាចធ្វើទៅបានដោយយោលទៅតាមធម្មជាតិសាំញ៉ាំរបស់សូរ និងនានាភាពនៃវិធីសាស្ត្រដែលគេប្រើសម្រាប់ពណ៌នា។ តាមទម្លាប់ គេចែកសូរវិទ្យាជាមែកធាងសំខាន់ៗគឺ៖

-សូរវិទ្យាបន្លឺ (articulatory phonetics) ឬសូរវិទ្យាសរីរសាស្ត្រ (physiological phonetics) ដែលសិក្សាពីការបន្លឺក្នុងការបន្លឺសូរសម្ដី ទីតាំង ទម្រង់និងចលនានៃសរីរាង្គបន្លឺដូចជា បបូរមាត់ អណ្ដាត របត់សំឡេង (vocal fold)។

-សូរវិទ្យាអាគូស្ទិក (acoustic phonetics) ទាក់ទងនឹងអាគូស្ទិកសម្ដីក្នុងនោះមានលក្ខណៈនៃរលកសូរដែលកើតចេញពីសម្ដីដូចជាប្រេកង់ អំព្លីទូត រយៈពេលជាដើម។

-សូរវិទ្យាល្បឺ (auditory phonetics) ទាក់ទងនឹងការទទួលសូរសម្ដីក្នុងនោះមានការចែក ប្រភេទសូរការស្គាល់សូរនិងតួនាទីរបស់ប្រព័ន្ធល្បឺនិងខួរក្បាល។

-សូរវិទ្យាពិសោធន៍ (Experimental phonetics) គឺជាមែកធាងរបស់សូរវិទ្យាដែលទាក់ទងនឹងការសិក្សាឯកតាសូរសម្ដីមនុស្សដោយអនុវត្តវិធីពិសោធន៍។ សូរវិទ្យាពិសោធន៍ជាមូលដ្ឋាននៃសូរវិទ្យាដទៃទៀត ដូចជាសូរវិទ្យាបន្លឺ សូរវិទ្យាល្បឺ សូរវិទ្យាអាគូស្ទិក។ លើសពីនេះទៀត សូរវិទ្យាពិសោធន៍ប្រើប្រាស់វិធីពិសោធន៍ដើម្បីសិក្សាពីសូរវិទ្យាសិចម៉ង់និងសូរវិទ្យាស៊ុបប្រាសិចម៉ង់ផងដែរ។ គេប្រើប្រាស់វិធីសាស្ត្រពិសោធន៍ដើម្បីធ្វើតេស្តលើទ្រឹស្ដីឬសម្មតិកម្មនានា សម្រាប់គាំទ្រឬបដិសេធទ្រឹស្ដីឬសម្មតិកម្មទាំងនោះ។ ដូច្នេះ ក្នុងអត្ថបទនេះ យើងធ្វើការសិក្សាតែលើលក្ខណៈទូទៅនៃសូរវិទ្យាអាគូស្ទិក និងសូរវិទ្យាបន្លឺប៉ុណ្ណោះ។

## ១.២. សូរវិទ្យាអាគូស្ទិក

### ១.២.១. និយមន័យ

សូរវិទ្យាអាគូស្ទិក សិក្សាអំពីលក្ខណៈនៃសូរសម្ដីដែលបញ្ជូនពីមាត់ទៅកាន់ត្រចៀក។ មុខវិជ្ជានេះក៏ផ្ដោតលើការសិក្សាពីលក្ខណៈរលកសូរតាមរូបវិទ្យា ដែលបង្កើតឡើងដោយបំពង់កនិងបំពង់សូរផងដែរ។ ការសិក្សាដែលសំខាន់នៃសូរវិទ្យាអាគូស្ទិក គឺសិក្សាអំពីរលកសូរ។





ប្រភព៖ https://www.google.com/search?q=Acoustic+phonetic

### ១.២.២. កំណកំណើតសូរនិងលក្ខណៈនៃសូរ

**ក. លំញ័រ**

កាលណាកម្លាំងមួយមានទំនាញ ការគោះ ការផ្លុំ ការបក់បោក...បានប៉ះទង្គិចទៅលើវត្ថុមួយដូចជា ខ្សែ ស្គរ ខ្លុយ ស្លឹកឈើ... វាបណ្ដាលឱ្យវត្ថុនោះមានលំញ័រ។

**ខ. វេលាឬវដ្ដ**

លំញ័រជាការកម្រើកជាចលនា វាត្រូវការស៊ីពេលដែលគេហៅថា វេលាឬវដ្ដ។ វេលាឬវដ្ដ ជាពេលដែលលំញ័រឆ្លងកាត់ទៅវិញទៅមកពីចំណុចមួយទៅចំណុចមួយទៀត។

**គ. រលក**

លំញ័របង្កើតជារលកដែលចាកចេញពីចំណុចកំណើតទៅតាមអាកាសដោយល្បឿន ៣៤០ម/វិនាទី ទៅគ្រប់ទិសទី។ កាលណារលកនោះមកប៉ះនឹងក្រដាសត្រចៀកយើង វាទៅជាសូរ ហើយគេអាចធ្វើការប្រៀបធៀបដោយយកត់សម្គាល់ឃើញថា ពន្លឺមានល្បឿន ៣០០ ០០០ គ.ម./វិនាទី។

**ឃ. លំញាប់ឬប្រេកង់ និងហឺត្ស**

លំញាប់គឺជាចំនួននៃរលកសូរក្នុងរយៈពេល១វិនាទី។ កាលណាលំញ័រមានល្បឿនរហ័ស វាមានលំញាប់ខ្ពស់។ កាលណាល្បឿនវាយឺត លំញាប់ក៏ត្រូវទាបទៅតាមនោះដែរ។ គេរាប់លំញាប់ដោយប្រើខ្នាតមួយគឺ ហឺត្ស (Hertz ឬ Hz ជាអក្សរកាត់)។

ហឺត្ស ជាការសម្គាល់លំញ័រដែលមាន១វេលាឬ១វដ្ដក្នុងរយៈពេល១វិនាទី។ កាលណាលំញ័រមានលំញាប់ខ្ពស់ធ្វើឱ្យសូរវាស្រួយ ឆ្មារ គ្រលួច ហើយកាលណាវាមានលំញាប់ខ្ពស់ ធ្វើឱ្យសូរវាស្រួយឆ្មារ គ្រលួច ហើយកាលណាវាមានលំញាប់ទាបសូរវាធំគ្រលរ។




ប្រភព៖ https://www.google.com/search?q=Acoustic+phonetic

### ង. កម្ពស់

កាលណាសូរមានលំញាប់ខ្ពស់ វាក៏មានកម្ពស់ខ្ពស់ដែរ ហើយបើសូរមានលំញាប់ទាប ក៏មានកម្ពស់ទាបទៅតាមនោះដែរ។ ត្រចៀកចាប់ឮសូរទៅតាមមាត្រដ្ឋានឡូការីត គឺថាត្រចៀក អាចឮសូរប្លែកគ្នាពីចន្លោះមួយទៅចន្លោះមួយ។ បើនៅចន្លោះដដែល ត្រចៀកក៏ឮសូរដដែលដែរ ទោះសូរនោះប្ដូរលំញាប់ក៏ដោយ (យើងអាចឮសូរផ្សេងលុះណាមានការឆ្លងផុតពីចន្លោះមួយទៅចន្លោះមួយ)។

### ច. ល្បឿង (អំព្លីទូត)

ល្បឿងគឺជាកម្ពស់នៃលំញាប់រលកសូរឡើងចុះឬជាចំណុចខ្ពស់បង្អស់។ កម្ពស់ខ្ពស់ឬទាបនៃសូរវាអាស្រ័យទៅលើកម្លាំងដែលបានប្រព្រឹត្តទៅលើវត្ថុលំញ័រ។




ប្រភព៖ https://www.google.com/search?q=Acoustic+phonetic

### ឆ. ប្រពលភាព (អាំងតង់ស៊ីតេ)

ប្រពលភាព គឺជាមាឌ (Volume) នៃសូរដែលស្របទៅតាមការឡើងចុះ។ វាខ្លាំង កាលណាការឡើងមានកម្រិតកម្ពស់ និងវាខ្សោយ កាលណាការឡើងមានកម្រិតទាប។

### ជ. ល្បឺ

ល្បឺ គឺជាគុណភាពដែលបណ្ដាលឱ្យសូរពីរផ្សេងគ្នាមានភាពខុសគ្នា ទោះសូរទាំងពីរនោះមានកម្ពស់និងប្រពលភាពស្មើគ្នាក៏ដោយ ពីព្រោះវត្ថុលំញ័រទាំងពីរដែលបានបង្កើតសូរទាំងពីរនោះមានកម្មវរខុសគ្នា មកពីវាមានធាតុខុសគ្នា (ព្រុំ ម៉ល់, ២០១៣: ២-៩)។

## ១.៣. សូរវិទ្យាបន្លឺ

សូរវិទ្យាបន្លឺ ជាផ្នែកមួយនៃសូរវិទ្យាដែលសិក្សាអំពីការបន្លឺសូរ។ តាមរយៈការសិក្សានេះ សូរវិទូពន្យល់ពីរបៀបនៃការផលិតឬបង្កើតសូរសេម្ដីរបស់មនុស្សដោយគិតពីទំនាក់ទំនងនៃរចនាសម្ព័ន្ធសរីរាង្គ។

សូរវិទ្យាបន្លឺ សិក្សាអំពីរបៀបនៃការបង្កើត (បន្លឺ) សូរសម្ដីដោយសរីរាង្គសំឡេង។

ជាទូទៅ សូរវិទ្យាបន្លឺទាក់ទងនឹងបម្រែបម្រួលនៃថាមពលនៃថាមវន្តខ្យល់ (aerodynamic energy) ទៅជាថាមពលអាគូស្ទិក។ ថាមពលនៃថាមវន្តខ្យល់សំដៅលើលំហូរខ្យល់តាមខ្សែសំឡេង។ ទម្រង់សំខាន់នៃថាមពលនៃថាមវន្តខ្យល់គឺសម្ពាធខ្យល់ ចំណែកថាមពលអាគូស្ទិកជាការប្រែប្រួលនៃសំពាធខ្យល់ដែលគេធ្លាប់ស្គាល់ថាជារលកសូរដែលមនុស្សទទួលបានតាមរយៈប្រព័ន្ធឈ្នួ គឺសូរហ្នឹងឯង។

### ១.៣.១. ការបន្លឺសំឡេង

សូរសំឡេងសម្ដី អាចកើតឡើងបានដោយសារសកម្មភាពសាំញ៉ាំនៃប្រដាប់បន្លឺសូររបស់មនុស្សនិងប្រព័ន្ធមណ្ឌលប្រសាទនានា។ លំហូរខ្យល់ដែលចេញពីសួតធ្វើឱ្យមានលំញ័រខ្សែសំឡេង ហើយទៅប៉ះនឹងសរីរាង្គបញ្ចេញសំឡេងនៅក្នុងគុហាមាត់និងគុហាច្រមុះ(ដោយការបិទបបូរមាត់ឬដោយការបិតជិតនៃបបូរមាត់និងធ្មេញ ការប៉ះគ្នារវាងអណ្ដាតនិងក្រអូម អណ្ដាតនិងធ្មេញជាដើម។

ការបន្លឺសំឡេងមានតួនាទីសម្រាប់បង្កើតសូរសំឡេង ហើយវាត្រូវតែពឹងផ្អែកទៅលើការរៀបចំនៃប្រដាប់សំឡេង ចលនាខ្យល់ និងភាពឮ។ សូរសំឡេងត្រូវប្រកបដោយលក្ខណៈបីយ៉ាងគឺ លក្ខណៈបន្លឺ លក្ខណៈខ្យល់ និងលក្ខណៈឮ។

១. ប្រហោងច្រមុះ
២. ក្រអូមកណ្ដាល
៣. គន្លាក់ក្រអូម
៤. តំបន់បបូរមាត់
៥. គល់អណ្ដាត
៦. ខ្សែសំឡេង
៧. បំពង់ខ្យល់
៨. ក្រអូមក្រោយ
៩. មុខអណ្ដាត
១០. ចុងអណ្ដាត
១១. ខ្នងអណ្ដាត
១២. កន្លើត
១៣. គ្រសនី (ដើមក)
១៤. ចន្លោះខ្សែសំឡេង
១៥. បំពង់អាហារ




#### ក. លក្ខណៈបន្លឺ

លក្ខណៈបន្លឺ ចែកចេញជាពីរគឺ ទីបន្លឺនិងប្រដាប់បន្លឺ។

-***ទីបន្លឺ*** ជាកន្លែងដែលសរីរាង្គខាងលើ និងសរីរាង្គខាងក្រោមជួបគ្នាដើម្បីច្នៃឱ្យទៅជាសូរផ្សេងៗ។ ទីបន្លឺ គឺសំដៅយកប្រដាប់សំឡេងគ្មានចលនា ពុំអាចកម្រើក និងផ្លាស់ប្ដូរកន្លែងបាន ហើយវាឋិតនៅផ្នែកខាងលើនៃប្រហោងមាត់។ ទីបន្លឺមានដូចជា បបូរមាត់លើ ធ្មេញលើ (ដោយគិតទាំងជើងធ្មេញនិងផ្ទៃខាងក្នុង) គន្លាក់ក្រអូម

(តាំងនៅតំបន់ចន្លោះខាងមុខក្រអូមរឹងនិងជើងធ្មេញ) ក្រអូមរឹង (តំបន់ក្រអូមដែលមានឆ្អឹង) ក្រអូមទន់ (តំបន់ខាងក្រោយក្រអូមរឹង គឺតំបន់ក្រអូមដែលមានសាច់ទន់) រនាំងក្រអូម (តំបន់ដែលធ្លាក់ចុះទៅផ្លូវចូលបំពង់ក) កន្លើត (នៅត្រង់កន្លែងផ្លូវចូលទៅបំពង់ខ្យល់ ស្ថិតនៅខាងលើប្រអប់សំឡេង) គ្រសនី (ដើមកឬតំបន់បំពង់ក) និងចន្លោះខ្សែសំឡេង។ ដូចនេះ ទីបន្លឺប្រភេទនេះ ជាទីតាំងសូរបបូរមាត់ សូរធ្មេញ សូរគន្លាក់ក្រអូម សូរក្រោយគន្លាក់ក្រអូម សូរក្រអូមក្រោយ សូររនាំងក្រអូម សូរដើមក និងសូរកន្លើត។










*-ប្រដាប់បន្លឺ* គឺសំដៅយកប្រដាប់សំឡេងដែលមានចលនាកម្រើកនិងផ្លាស់ប្ដូរកន្លែងបាន។ វាស្ថិតនៅផ្នែកខាងក្រោមនៃប្រហោងមាត់។ ប្រដាប់បន្លឺមានដូចជា បបូរមាត់ក្រោម (ជាសរីរាង្គដែលអាចធ្វើចលនាបានច្រើនយ៉ាង និងធ្វើឱ្យសំឡេងខុសគ្នាបានច្រើន ហើយវាមានមុខងារសម្រាប់បង្កើតសូរបបូរមាត់) ធ្មេញក្រោម (ជាសរីរាង្គទ្រ ឬជាប្រភពនៃសំឡេងច្រើនប្រភេទ បើធ្មេញលើសង្កត់ធ្មេញក្រោម ខ្យល់ដែលឆ្លងកាត់ចេញមក នឹងធ្វើឱ្យមានសំឡេងជ្រែកកើតត្រង់ប្រទល់ធ្មេញជាដើម) អណ្ដាត (ជាសរីរាង្គដែលអាចធ្វើចលនាបានលឿនរហ័សបំផុតក្នុងការបញ្ចេញសំឡេងនិយាយ ហើយរាល់ការធ្វើចលនានៃអណ្ដាតសុទ្ធតែមានប្រយោជន៍ដល់ការបញ្ចេញសំឡេង។ អណ្ដាតចែកចេញជាបីផ្នែកគឺ ចុងអណ្ដាត ខ្នងអណ្ដាត និងគល់អណ្ដាត) និងខ្សែសំឡេង (ជាសរីរាង្គសំខាន់មួយសម្រាប់ធ្វើឱ្យកើតសំឡេង)។

**ខ. លក្ខណៈខ្យល់**

ដំណើរខ្យល់ចេញពីសួតឬបឺតចូលតាមមាត់ (តាមច្រមុះ) តែងតែឆ្លងកាត់តាមបំពង់ខ្យល់និងសន្ទះខ្សែសំឡេង។ ក្នុងចលនាចេញចូលខ្យល់នេះប៉ះនឹងទីបន្លឺផងនិងប្រដាប់បន្លឺផង។ តាមលក្ខណៈខ្យល់សូរសំឡេងចែកចេញជា សូរមានខ្យល់និងគ្មានខ្យល់ សូរខ្យល់បង្ហូរត្រដុស សូរខ្យល់ស្ទះ សូរខ្យល់វែងនិងខ្យល់ខ្លី និងសូរខ្យល់ច្រមុះ។

**គ. លក្ខណៈឮ**

ភាពឮនៃសូរសំឡេងមានពីរយ៉ាងគឺ ឮតាមត្រចៀក និងឮតាមភាពញ័រនៃខ្សែសំឡេង។ ដូចនេះសូរសំឡេងដែលបន្លឺឡើងធ្វើឱ្យខ្សែសំឡេងញាប់ញ័រ ហៅថាសូរឮ (ឃោសៈ)។ រីឯសូរសំឡេងណាដែលបន្លឺឡើងពុំធ្វើឱ្យខ្សែសំឡេងញាប់ញ័រ ហៅថាសូរថ្លង់ (អឃោសៈ)។

**១.៣.២. ព្យញ្ជនៈ**

ក្នុងផ្នែកនេះ យើងនឹងសិក្សាអំពីសូរព្យញ្ជនៈនិងសញ្ញាព្យញ្ជនៈនៅក្នុងភាសាខ្មែរ។

**១.៣.២.១. សូរព្យញ្ជនៈ**

សូរព្យញ្ជនៈកើតឡើងដោយការតៀ្បត ឬបិទលំហូរខ្យល់ពីសួតនៅក្នុងបំពង់សំឡេង។ ចំណែកថ្នាក់ព្យញ្ជនៈធ្វើឡើងទៅតាមកន្លែងដែលលំហូរខ្យល់ត្រូវតៀ្បតឬបិទខ្ទប់។ ទីនេះហើយដែលគេហៅថា «ទីបន្លឺ»។ គេបែងចែកសូរព្យញ្ជនៈឬឱ្យឈ្មោះសូរព្យញ្ជនៈទៅតាមទីបន្លឺសំខាន់ៗដែលគេធ្លាប់ស្គាល់។

តាមការសិក្សាបែបអាគូស្ទិក គេមិនងាយចាប់សូរព្យញ្ជនៈ ជាពិសេស សូរព្យញ្ជនៈស្ទះអឃោសៈបានទេ ជាពិសេសទៅទៀត ក្នុងករណីដែលសូរព្យញ្ជនៈទាំងនោះផ្សំជាមួយសូរស្រៈ។ ទោះជាយ៉ាងនេះក៏ដោយ ក៏គេត្រូវតែជ្រើសយកស្រៈដែលមានសូរខ្លីជាងគេបំផុតមកផ្សំជាមួយសូរព្យញ្ជនៈ ដើម្បីឱ្យងាយស្រួលស្តាប់នឹងត្រចៀក។ សូរស្រៈខ្លីបំផុតដែលគេនិយមប្រើគឺ [ə]។

**១.៣.២.១.១. និយមន័យ**

សូរព្យញ្ជនៈ គឺជាសូរសំឡេងដែលកើតឡើងពីដំណើរខ្យល់តាមបំពង់សំឡេង បន្លឺឡើងដោយមានទំនប់ប្រកបដោយភាពមិនច្បាស់លាស់។ សូរព្យញ្ជនៈកើតឡើងដោយសារការបិទឬការខិតជិតគ្នានៃប្រដាប់បន្លឺក្នុងគុហាមាត់និងគុហាច្រមុះ។

**១.៣.២.១.២. សូរព្យញ្ជនៈគោល**

សូរព្យញ្ជនៈអាចចែកទៅតាមលក្ខណៈបីយ៉ាងគឺ៖ លក្ខណៈបន្លឺ (តាមទីបន្លឺ) លក្ខណៈខ្យល់ (តាមរង្វះខ្យល់ឬរបៀបបន្លឺ) និងលក្ខណៈឮ (សូរឃោសៈឬសូរឮ និងសូរអឃោសៈឬសូរថ្លង់)។

**ក. តាមទីបន្លឺ**

ទីបន្លឺ គឺជាចំណុចនៅផ្នែកខាងលើនៃគុហាមាត់ (ធ្មេញលើ ជើងធ្មេញលើ ក្រអូម រនាំងក្រអូម ចុងរនាំងក្រអូមឬកន្ទើត...) ដែលអណ្តាតធ្វើចលនាទៅប៉ះ ដើម្បីបង្កើតសូរណាមួយ។

តាមទីបន្លឺសូរព្យញ្ជនៈចែកជា៖

(១)-សូរព្យញ្ជនៈបបូរមាត់

សូរព្យញ្ជនៈបបូរមាត់ជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ បបូរមាត់ក្រោមប៉ះនឹងបបូរមាត់លើទាំងស្រុងហើយលំហូរខ្យល់ចេញពីសួតមកក្រៅក៏បើកបបូរមាត់ឱ្យឃ្លាតចេញពីគ្នាវិញ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈបបូរមាត់មាន [p] ប៉ ព, [b] ប ប៊ និង [m] ម៉ ម ។

(២)-សូរព្យញ្ជនៈបបូរមាត់ត្រដុស

សូរព្យញ្ជនៈបបូរមាត់ត្រដុសជាសូរព្យញ្ជនៈដែលក្នុងការបន្លឺបបូរមាត់បើកចំហបន្តិច ដើម្បីឱ្យខ្យល់ដែលចេញពីសួតទៅត្រដុសនឹងបបូរមាត់ទាំងពីរ។ ក្នុងភាសាខ្មែរ ព្យញ្ជនៈបបូរមាត់ត្រដុសមាន [w] វ៉ វ ។

(៣)-សូរព្យញ្ជនៈធ្មេញ

សូរព្យញ្ជនៈធ្មេញជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ចុងអណ្តាតទៅប៉ះនឹងធ្មេញឬគន្លាក់ជើងធ្មេញ។ ក្នុងភាសាខ្មែរ ព្យញ្ជនៈធ្មេញមាន [d] ដ ឌ, [t] ត ទ និង [n] ណ ន ។

(៤)-សូរព្យញ្ជនៈជើងធ្មេញ

សូរព្យញ្ជនៈជើងធ្មេញជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ចុងអណ្តាតទៅជិតឬប៉ះនឹងជើងធ្មេញលើ។ ក្នុងភាសាខ្មែរ ព្យញ្ជនៈជើងធ្មេញមាន [s] ស ស៊, [l] ល ឡ និង [r] រ៉ រ។

(៥)-សូរព្យញ្ជនៈក្រអូម

សូរព្យញ្ជនៈក្រអូមជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ខ្នងអណ្តាតទៅជិតឬប៉ះនឹងផ្នែកនានានៃក្រអូម (ផ្នែកខាងមុខ ផ្នែកកណ្តាល និងផ្នែកខាងក្រោយ)។ ក្នុងភាសាខ្មែរ ព្យញ្ជនៈក្រអូមមាន [c] ច ជ, [ɲ] ញ៉ ញ និង [j] យ៉ យ។

(៦)-សូរព្យញ្ជនៈរនាំងក្រអូម

សូរព្យញ្ជនៈរនាំងក្រអូមជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ខ្នងអណ្តាតទៅប៉ះនឹងរនាំងក្រអូម។ ក្នុងភាសាខ្មែរ ព្យញ្ជនៈរនាំងក្រអូមមាន [k] ក គ និង [ŋ] ង៉ ង ។

(៧)-សូរព្យញ្ជនៈដើមក

សូរព្យញ្ជនៈដើមក គឺជាសូរព្យញ្ជនៈមួយពួក ដែលក្នុងការបន្លឺ គល់អណ្ដាតខិតទៅជិតផ្ទៃខាងក្រោយនៃដើមក។ ក្នុងភាសាខ្មែរ ព្យញ្ជនៈដើមកមាន [h] ហ ហ៊។

(៨)-សូរព្យញ្ជនៈចន្លោះខ្សែសំឡេង

សូរព្យញ្ជនៈចន្លោះខ្សែសំឡេងជាសូរព្យញ្ជនៈដែលកើតឡើង កាលណាមានបំណើកមួយភ្លែត នៃគន្លាក់កណ្ឋ (glotte)។ ក្នុងភាសាខ្មែរ ព្យញ្ជនៈចន្លោះខ្សែសំឡេងមាន [ʔ] អ អ៊ ។

**ខ. តាមរង្វះខ្យល់ ឬរបៀបបន្លឺ**

របៀបបន្លឺ គឺជាបែបផែននៃលំហូរខ្យល់ដែលធ្វើឱ្យមានរង្វះខ្យល់ដំណាកដង្ហើមធំឬតូច។

តាមរបៀបបន្លឺ គេចែកសូរព្យញ្ជនៈជា៖

(១)-សូរព្យញ្ជនៈស្ទះឬសូរផ្ទុះ

សូរព្យញ្ជនៈស្ទះឬសូរផ្ទុះជាសូរព្យញ្ជនៈដែលបន្លឺឡើងដោយមានដំណើរខ្យល់ចេញពីសួត មកប៉ះខ្ទាំងនឹងប្រដាប់បន្លឺសំឡេងបណ្ដាលឱ្យមានបន្ទុះ។ ក្នុងភាសាខ្មែរ ព្យញ្ជនៈស្ទះឬសូរផ្ទុះ មាន [k] ក គ, [ŋ] ង៉ ង, [c] ច ជ, [ɲ] ញ៉ ញ, [d] ដ ឌ, [t] ត ទ, [n] ណ ន, [b] ប ប៊, [p] ប៉ ព, និង [ʔ] អ អ៊។

(២)-សូរព្យញ្ជនៈត្រដុស

សូរព្យញ្ជនៈត្រដុសជាសូរព្យញ្ជនៈដែលក្នុងពេលបន្លឺ ដំណើរខ្យល់ចេញពីសួត ត្រដុសនឹងដើមក ផ្ទៃគុហាមាត់(ធ្មេញ អណ្ដាត ក្រអូម) និងបបូរមាត់ ហើយបង្កើតបានជាសូរបង្ហូរត្រដុស។ សូរព្យញ្ជនៈត្រដុសក្នុងភាសាខ្មែរមាន [j] យ៉ យ, [w] វ៉ វ , [s] ស ស៊ និង [h] ហហ៊។

(៣) សូរព្យញ្ជនៈលំហូរ

សូរព្យញ្ជនៈលំហូរ គឺជាសូរព្យញ្ជនៈដែលក្នុងពេលបន្លឺ ចុងអណ្ដាតប៉ះនឹងជើងធ្មេញលើ ដោយទុកចន្លោះឱ្យដំណើរខ្យល់ចេញពីសួតហូរចេញមកក្រៅ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈលំហូរមាន ល ឡ [l] និង រ៉ រ [r]។ ពិតមែនតែសូរព្យញ្ជនៈទាំងពីរនេះនៅក្នុងក្រុមជាមួយគ្នា ក៏ក្នុងការបន្លឺសូរព្យញ្ជនៈ [l] អណ្ដាតប៉ះនឹងជើងធ្មេញលើច្រើនជាងក្នុងការបន្លឺសូរព្យញ្ជនៈ [r] ដោយទុកចន្លោះសងខាងអណ្ដាតឱ្យដំណើរខ្យល់ចេញពីសួតបន្តដំណើរមកក្រៅ។ យើងហៅសូរព្យញ្ជនៈ [l] ថាសូរព្យញ្ជនៈលំហូរខាង។ ចំពោះសូរព្យញ្ជនៈ [r] វិញ ចុងអណ្ដាតប៉ះស្រាលនឹងជើងធ្មេញលើហើយរលាស់។ យើងហៅសូរព្យញ្ជនៈ [r] នេះ ថាសូរព្យញ្ជនៈលំហូរញ័រ។ ក្នុងភាសាខ្លះគ្មាន [l] និង [r] ទេ។

**គ. តាមលក្ខណៈឮ**

តាមលក្ខណៈឮ សូរព្យញ្ជនៈចែកចេញជា សូរឃោសៈឬសូរឮ និងសូរអឃោសៈឬសូរថ្លង់។

សូរឃោសៈឬសូរឮ ជាសូរដែលក្នុងការបន្លឺ គេសង្កេតឃើញមានរំញ័រខ្សែសំឡេង។ ចំណែកសូរអឃោសៈក្នុងការបន្លឺសូរគ្មានរំញ័រខ្សែសំឡេងទេ។ ក្នុងករណីគ្មានឧបករណ៍ពិសោធន៍ គេអាចប្រើវិធី២យ៉ាង ដើម្បីថាសូរណាជាសូរឃោសៈ សូរណាជាសូរអឃោសៈ។

-វិធីទី១ គឺយកចុងម្រាមដៃដាក់លើគ្រាប់ពោន ត្រង់បំពង់ករួចបន្លឺ។ ក្នុងពេលបន្លឺសូរឃោសៈ (ក្នុងនោះមានសូរព្យញ្ជនៈនិងសូរស្រៈ) យើងទទួលអារម្មណ៍ថាមានរំញ័រនៅចុងម្រាមដៃ ចំណែកឯសូរអឃោសៈគ្មានរំញ័រឡើយ។ ជួនកាល យើងមានការលំបាក ក្នុងការរកភាពប្លែកគ្នារវាងសូរឃោសៈនិងសូរអឃោសៈតាមរយៈការអនុវត្តវិធីទី១។ វិធីមួយបែបទៀតអាចជួយយើងបាន។

-វិធីទី២ គឺយកក្រដាសស្ដើងបន្តិចដាក់នៅខាងមុខមាត់។ ក្រដាសកម្រើកខ្លាំងក្នុងការបន្លឺសូរអឃោសៈជាងក្នុងការបន្លឺសូរឃោសៈ។

តាមការពិសោធរបស់យើងផ្ទាល់ ការដាក់បាតដៃពីមុខមាត់ រួចបន្លឺសូរណាដែលគេចាត់ចូលជាសូរឃោសៈ និងសូរណាដែលគេចាត់ចូលជាសូរអឃោសៈ។ ក្នុងការបន្លឺសូរអឃោសៈ ខ្យល់ពីក្នុងមាត់មកប៉ះបាតដៃខ្លាំងជាង

ការបន្លឺសូរឃោសៈ។ សាកល្បងបន្លឺសូរ [p] vs [b], [f] vs [v], [t] vs [d], [s] vs [z], [š] vs [ž], [k] vs [g] ជាដើម។

(១)-សូរព្យញ្ជនៈឃោសៈឬសូរឮ ក្នុងភាសាខ្មែរមាន [d] ដ ឌ, [b] ប ប៊, [ŋ] ង៉ ង, [ɲ] ញ៉ ញ, [n] ណ ន, [m] ម៉ ម, [j] យ៉ យ, [r] រ៉ រ, [w] វ៉ វ , [l] ល ឡ ។

(២)-សូរព្យញ្ជនៈអឃោសៈឬសូរថ្លង់ ក្នុងភាសាខ្មែរមាន [k] ក គ, [c] ច ជ, [t] ត ទ, [p] ប៉ ព, [s] ស ស៊ , [h] ហ ហ៊, [ʔ] អ អ៊។

**<u>តារាងសូរព្យញ្ជនៈប្រកប</u>**

| សូរនៅចុងពាក្យ (IPA) | ព្យញ្ជនៈប្រកប | ពាក្យ | IPA / API |
|---|---|---|---|
| k | ក គ ខ឴ ឃ | មុខ | [muk] |
| c | ច ជ | គេច | [kec] |
| ŋ | ង | គាំង | [kɛaŋ] |
| ɲ | ញ | គេញ | [keɲ] |
| t | ត ទ ឋ ឍ ថ ធ ដ | សិត | [sɜt] |
| n | ណ ន | មែន , ពិណ | [mɛːn] , [pən] |
| p | ភ ផ ប ព | លុប, លាភ | [lup] , [liɜp] |
| m | ម | គែម | [kɛːm] |
| j | យ | យាយ | [jiɜj] |
| l | ល ឡ | គោល | [koːl] |
| w | វ | បាវ | [baːw] |
| h | ស | សេស | [sɛh] |

### ១.៣.២.១.៣. សូរព្យញ្ជនៈផ្សំ

ឧទាហរណ៍៖ អ្នកស្រែ ច្រូវស្រូវ ដោយទឹកមុខស្រស់។

ក្នុងឧទាហរណ៍ខាងលើ សូរ «ប្រ ស្រ» គឺជា៖

-សូររួមនៃព្យញ្ជនៈនិងព្យញ្ជនៈ

-ជាសូរគ្មានស្រៈនៅចន្លោះព្យញ្ជនៈទាំងពីរ។

ដូចនេះ សូរព្យញ្ជនៈផ្សំគឺជាសូររួមនៃព្យញ្ជនៈពីរ (ឬបី) ដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ។

សូរព្យញ្ជនៈផ្សំមានដូចជា៖

**ក. ស្នះ+ស្នះ**

ឧទាហរណ៍៖ ប្តូរ ផ្ញើ ផ្តល់ ផ្ទាញ់ ផ្កា ផ្អក ខ្ពស់ ខ្ចង់ ត្បូង ថ្កាម ឆ្ពោះ ច្បា ឆ្កោ ឆ្កែ ក្បាល ខ្ចត ក្តាន់ ខ្ទី។

**ខ. ស្នះ+ប្រមុះ**

ឧទាហរណ៍៖ ភ្នំ ផ្ញើ ផ្គារ ភ្លី ភ្ញា ថ្ម ធ្ន ថ្ងូរ ឆ្មា ឆ្នាំ ចូល់ ក្មេង ក្នុង ខ្ញុំ ក្ងាន ឆ្នោត ខ្មោច ខ្នាយ។

**គ. ស្នះ+បង្ហូរត្រដុស**

ឧទាហរណ៍៖ ផ្សា ផ្លូវ ព្រៃ ព្យួរ ធ្វើ ថ្លា ទ្រុង គ្រែ ធ្យូង ឆ្វេង ឈ្លី ជ្រេ ឃ្វាល ខ្សែ ឃ្លេ ខ្យល់។

**ឃ. ប្រមុះ+ស្មុះ**

ឧទាហរណ៍៖ ម្ដែ ម្ទេស ម្ដាយ ម្ចាស់ ម្កាក់ ម្ខាង។

**ង. ប្រមុះ+ប្រមុះ**

ឧទាហរណ៍៖ ម្នាស់ ម្និកម្ញ៉ក់ ម្ង៉ៃ។

**ច. ប្រមុះ+បង្គួរត្រដុស**

ឧទាហរណ៍៖ ម្សៅ ម្លូ ម្រេច ម្យ៉ាង ម្ហូប។

**ឆ. បង្គួរត្រដុស+ប្រមុះ**

ឧទាហរណ៍៖ ស្នា ស្មា ស្មោរ ស្ងាត់ ល្មម ល្ង។

**ជ. បង្គួរត្រដុស+បង្គួរត្រដុស**

ឧទាហរណ៍៖ ស្វាយ ស្លាប ស្រា ស្យាម ល្ហុង ល្វត។

**ឈ. បង្គួរត្រដុស, ប្រមុះ, ស្មុះ + ស្មុះចន្លោះខ្សែសំឡេង**

ឧទាហរណ៍៖ ក្អេងក្អាង ឆ្អិនឆ្អៅ ត្អូញត្អែរ ធ្អាល ប្អូន ផ្អោះ ម្អម ល្អិតល្អ ស្អកស្អា។

សង្កេត៖ បន្សំព្យញ្ជនៈខ្យល់ស្មុះ ចន្លោះខ្សែសំឡេងនឹងព្យញ្ជនៈឯទៀត មានតែបន្តិចបន្តួចប៉ុណ្ណោះ។

ឧទាហរណ៍៖ អ្វី អ្ហូ អ្ហ៊ះ ជាដើម។

### ១.៣.២.២. សញ្ញាព្យញ្ជនៈ

សញ្ញាព្យញ្ជនៈសម្រាប់កត់សូរព្យញ្ជនៈ។ សញ្ញាព្យញ្ជនៈចែកចេញជាពីរ គឺសញ្ញាព្យញ្ជនៈទោលនិងសញ្ញាព្យញ្ជនៈផ្សំ។

### ១.៣.២.២.១. សញ្ញាព្យញ្ជនៈទោល

សញ្ញាព្យញ្ជនៈទោលអាចចែក៖

-តាមមូលភេទ អ-អ៊។

-តាមបម្រើបម្រាស់។

**ក. បញ្ចែកតាមមូលភេទ អ-អ៊**

| | | | | |
|---|---|---|---|---|
| ឧទាហរណ៍៖ | កេរ | ចាក់ | តើ | ប៉ើង |
| | គេ | ជាក់ | ទើ | ពើង។ |

ឧទាហរណ៍ខាងលើបញ្ជាក់ថា៖

-ពាក្យ «កេរនិងគេ» ប្រើសញ្ញាស្រៈ «េ» ដូចគ្នា

-តែ «េ» នៅជាមួយ «ក» មើលថា [អេ]

-ហើយ «េ» នៅជាមួយ «គ» មើលថា [អ៊េ]។

នេះគឺថា៖

-ស្រៈពួក អ ដឹងដោយសារសញ្ញាព្យញ្ជនៈពួក អ

-ស្រៈពួក អ៊ ដឹងដោយសារសញ្ញាព្យញ្ជនៈពួក អ៊។

ដូចនេះ សញ្ញាព្យញ្ជនៈមានពីរពួកគឺ សញ្ញាព្យញ្ជនៈពួក អ និងសញ្ញាព្យញ្ជនៈពួក អ៊។

សញ្ញាព្យញ្ជនៈពួក អ ៖ ក ខ ង៉ ច ឆ ញ៉ ដ ឋ ណ ត ថ ប ប៉ ផ ម៉ យ៉ រ៉ ឡ វ៉ ស ហ អ។

សញ្ញាព្យញ្ជនៈពួក អ៊ ៖ គ ឃ ង ជ ឈ ញ ឌ ឍ ទ ធ ន ប៊ ព ភ ម យ រ ល វ ស៊ ហ៊ អ៊។

**ខ. បញ្ចែកតាមបម្រើបម្រាស់**

ខ.១. សញ្ញាព្យញ្ជនៈផ្គុំតួ

ឧទាហរណ៍៖ ប្រយុទ្ធ ពង្រឹង ជំហរ កសាង។
ប្រទេសខ្ពង់ខ្ពស់ព្រោះប្រជាជន។

ឧទាហរណ៍ខាងលើបង្ហាញឱ្យឃើញថា៖

-ក្នុង «ប្រ ក» មានស្រៈកប់តួ «អ» នៅជាមួយ។

-ក្នុង «ជំហរ ជន» មានស្រៈកប់តួ «អ៊» នៅជាមួយ។

នេះគឺថា សញ្ញាព្យញ្ជនៈ «ប្រ ក ជ...» មានស្រៈផ្ដប់តួក្នុងតួរបស់ខ្លួន។

ដូចនេះសញ្ញាព្យញ្ជនៈផ្ដប់តួជាសញ្ញាព្យញ្ជនៈណាដែលមានសូរស្រៈកប់តួណានៅជាមួយ។ សញ្ញាព្យញ្ជនៈទាំងអស់អាចជាសញ្ញាព្យញ្ជនៈផ្ដប់តួ។

ខ.២. សញ្ញាព្យញ្ជនៈភ្ជាប់តួ

ឧទាហរណ៍៖ ជាតិ ត្រូវការ ទឹកចិត្ត ស្នេហា និងស្មោះត្រង់ ចំពោះ មាតុ ភូមិ។

ឧទាហរណ៍ខាងលើបង្ហាញឱ្យឃើញថា៖

ក្នុង «ជាតិ ត្រូវការ ទឹក និង...» មានសញ្ញាស្រៈភ្ជាប់តួ «ា ូ ឹ ិ ...» នៅជាមួយ។

នេះគឺថា សញ្ញាព្យញ្ជនៈ «ជ ត្រ ទ ន ...» ភ្ជាប់តួស្រៈជាមួយខ្លួន។

ដូចនេះ សញ្ញាព្យញ្ជនៈភ្ជាប់តួ គឺជាសញ្ញាព្យញ្ជនៈណាដែលប្រើជាមួយសញ្ញាស្រៈភ្ជាប់តួ។ សញ្ញាព្យញ្ជនៈទាំងអស់អាចជាសញ្ញាព្យញ្ជនៈភ្ជាប់តួ។

**១.៣.២.២.២. សញ្ញាព្យញ្ជនៈផ្សំ**

សញ្ញាព្យញ្ជនៈផ្សំសម្រាប់កត់សូរព្យញ្ជនៈផ្សំ។

ឧទាហរណ៍៖ ក្រុមខាងនេះប្រឹងប្រែងប្រយុទ្ធដូចក្រុមខាងនោះដែរ។
គេព្រមៗគ្នាធ្វើការ។

ឧទាហរណ៍នេះបង្ហាញថា៖

-ក្នុងពាក្យ «ក្រុម ប្រឹង ...» ប្រើសញ្ញាស្រៈ «ុ ឹ» ដែលកត់សូរ [អុ] និង [អឹ]។

-ក្នុងពាក្យ «គ្នា ធ្វើ» ប្រើសញ្ញាស្រៈ «ា ើ» ដែលកត់សូរ [អ៊ា] [អ៊ើ]។

-ក្នុងពាក្យ «ប្រ ព្រម» ប្រើស្រៈកប់តួ «អ-អ៊» ដែលកត់សូរ [អ] [អ៊]។

នេះគឺថា៖

-សញ្ញា «ក្រ ប្រ» ជាពួក អ។

-សញ្ញា «គ្ន ធ្វ» ជាពួក អ៊។

-សញ្ញា «ក្រ (ក្រុម)...» ជាភ្ជាប់តួ។

-សញ្ញា «ព្រ (ព្រម) ...» ជាផ្ដប់តួ។

ដូចនេះ សញ្ញាព្យញ្ជនៈផ្សំអាចជាពួក[អ] ពួក[អ៊] ហើយអាចជាសញ្ញាព្យញ្ជនៈភ្ជាប់តួ និងសញ្ញាព្យញ្ជនៈផ្ដប់តួថែមទៀត។

<u>**កំណត់សម្គាល់៖**</u>

យើងមានសញ្ញាព្យញ្ជនៈមួយបែបទៀតឈ្មោះថា «ជើងព្យញ្ជនៈ» ជើងព្យញ្ជនៈសម្រាប់ប្រើក្នុងសំណេរព្យញ្ជនៈផ្សំនិងក្នុងសំណេរព្យាង្គតម្រួត។ សញ្ញាជើងព្យញ្ជនៈមានដូចជា ្ក ្ខ ្គ ្ឃ ្ង ្ច ្ឆ ្ជ ្ឈ ្ញ ញ ្ដ ្ឋ ្ឌ ្ឍ្ណ ្ត ្ថ ្ទ ្ធ ្ន ្ប ្ផ ្ព ្ភ ្ម ្យ ្រ ្ល ្វ ្ស ្ហ ្អ។

# តារាងព្យញ្ជនៈផ្សំ

| សំណេរ | សំណេរ (IPA/API) | សំណួរ (IPA/API) | ពាក្យ |
|---|---|---|---|
| ក្រ | kr | [kr] | ក្រោម [kraɔm] ក្រម [krɒːm] ក្រោយ [kraɔj] |
| គ្រ | kr | [kr] | គ្រង [krɔːŋ] គ្រប [krɔːp] គ្រក [krɔːk] |
| ប្រ | cr | [cr] | ច្រើន [craɜn] ច្រាំង [craŋ] ច្រវា [crɒwaː] |
| ជ្រ | cr | [cr] | ជ្រក [crɔːk] ជ្រញ់ [cruɲ] ជ្រើស [crəːh] |
| ត្រ/ទ្រ | tr | [tr] | ត្រង [trɒːŋ] ទ្រ [trɔː] ទ្រូង [truːŋ] |
| ប្រ/ព្រ | pr | [pr] | ព្រោះ [pruɜh] ប្រៀប [priɜp] ព្រាន [priɜn] |
| ស្ក/ស្គ | sk | [sk] | ស្ករ [skɒː] ស្គរ [skɔː] ស្គម [skɔːm] |
| ស្ង | sŋ | [sŋ] | ស្ងាប [sŋaːp] ស្ងោរ [sŋaɔ] ស្ងាត់ [sŋat] |
| ស្ញ | sɲ | [sɲ] | ស្នេញ [sɲɛɲ] ស្ញាញ [sɲaːɲ] |
| ស្ដ | sd | [sd] | ស្ដាប់ [sdap] ស្ដាយ [sdaːj] |
| ស្ន | sn | [sn] | ស្នេហ៍ [snaɛ] ស្នប់ [snɑp] |
| ស្ទ | st | [st] | ស្ទាប [stiɜp] ស្ទះ [stɛah] ស្ទង [stɔːŋ] |
| ស្ប | sb | [sb] | ស្បថ [sbɒt] ស្បោង [sbaɔŋ] ស្បង់ [sbɒŋ] |
| ស្ម | sm | [sm] | ស្មា [smaː] ស្មាញ [smaɲ] ស្មាច់ [smac] |
| ស្ល | sl | [sl] | ស្ល [slɒː] ស្លាប់ [slap] ស្លាប [slaːp] |
| ស្រ | sr | [sr] | ស្រា [sraː] ស្រី [srɜj] ស្រែ [sraɛ] |
| ស្វ | sw | [sw] | ស្វា [swaː] ស្វិត [swɜt] ស្វាយ [swaːj] |
| ស្អ | sʔ | [sʔ] | ស្អាត [sʔaːt] ស្អប់ [swɒp] ស្អិត [sʔɜt] |

**ព្យញ្ជនៈផ្សំដែលមានខ្យល់ [ʰ] នៅចន្លោះព្យញ្ជនៈទាំងពីរ**

| | | | |
|---|---|---|---|
| ក្ន | kn | [kʰn] | ក្នុង [kʰnɔŋ] /[kʰnoŋ] ក្នាញ់ [kʰnaɲ] |
| ក្ត | kt | [kʰt] | ក្ដម្ភទេស [kʰtumteh] |
| ក្ប | Kb | [kʰb] | ក្បាល [kʰbaːl] ក្បែរ [kʰbaɛ] ក្បូន [kʰbɔon] |
| ក្ម | km | [kʰm] | ក្មេង [kʰmɛeŋ] |
| ក្ល | kl | [kʰl] | ក្លាយ [kʰlaːj] |
| ក្វ | kw | [kʰw] | ក្វាង [kʰwaːŋ] ក្វែន [kʰwaɛn] |
| ក្ស | ks | [kʰs] | ក្ស័យ [kʰsaj] ក្សត្រ [kʰsat] |
| ខ្ច | kʰc | [kʰc] | ខ្ជិល [kʰcəl] ខ្ចី [kʰcɜj] ខ្ចប់ [kʰcɒp] |
| ខ្ទ | kʰt | [kʰt] | ខ្ទាត [kʰtiɜt] ខ្ទះ [kʰtɛah] ខ្ទើយ [kʰtəːj] |
| ខ្ម | kʰm | [kʰm] | ខ្មែរ [kʰmaɛ] ខ្មោច [kʰmaɔc] ខ្មាំង [kʰmaŋ] |
| ខ្យ | kʰj | [kʰc] | ខ្យង [kʰcɒːŋ] ខ្យល់ [kʰcɒl] |
| ខ្ល | kʰl | [kʰl] | ខ្លាំង [kʰlaŋ] ក្លាយ [kʰlaːj] ឃ្លាន [kʰliɜn] |
| ខ្វ | kʰw | [kʰw] | ខ្វះ [kʰwah] ខ្វល់ខ្វាយ [kʰwɒl kʰwaːj] |

| | | | |
|---|---|---|---|
| ខ្ស | kʰs | [kʰs] | ខ្សោយ [kʰsaɔj] ខ្សត់ [kʰsɒt] |
| គ្ន | kn | [kʰn] | គ្នា [kʰniɜ] គ្នាន់ [kʰnoan] |
| គ្ម | km | [kʰm] | គ្មាន [kʰniɜn] |
| ច្ន | cn | [cʰn] | ច្នេះ [cʰnɛh] ច្នៃ [cʰnaj] |
| ឆ្ក | cʰk | [cʰk] | ឆ្កែ [cʰkaɛ] ឆ្កួត [cʰkuɜt] |
| ឆ្ង | cʰŋ | [cʰŋ] | ឆ្ងាញ់ [cʰŋaɲ] ឆ្ងាយ [cʰŋaːj] |
| ឆ្ន | cʰn | [cʰn] | ឆ្នាំ [cʰnam] ឈ្នះ [cʰnɛah] ឆ្នោត [cʰnaɔt] |
| ឆ្ម | cʰm | [cʰm] | ឆ្មារ [cʰmaː] ឆ្មាំ [cʰmam] ឆ្មប [cʰmɒːp] |
| ឆ្វ | cʰw | [cʰw] | ឆ្វេង [cʰwɛeɲ] |
| ឆ្អ | cʰʔ | [cʰʔ] | ឆ្អាប [cʰʔaːp] ឆ្អើរ [cʰʔaɜ] ឆ្អិន [cʰʔɜn] |
| ជ្វ | cw | [cʰw] | ជ្វា [cʰwiɜ] |
| ឈ្ង | cʰŋ | [cʰŋ] | ឈ្ងុយ [cʰŋuj] ឈ្ងោក [cʰŋoːk] |
| ឈ្ន | cʰn | [cʰn] | ឈ្នាង [cʰniɜŋ] ឈ្នួល[cʰnuɜl] |
| ឈ្ម | cʰm | [cʰm] | ឈ្មួញ [cʰmuɜɲ] ឈ្មោះ [cʰmuɜh] |
| ឈ្ល | cʰl | [cʰl] | ឈ្លើយ [cʰləːj] ឈ្លានពាន [cʰliɜnpiɜn] |
| ឈ្វ | cʰw | [cʰw] | ឈ្វាត [cʰwiɜt] |
| ដ្ប | db | [tʰb] | ដ្បិត [tʰbɜt] |
| ត្ន | tn | [tʰn] | ត្នោត [tʰnaɔt] |
| ត្ម | tm | [tʰm] | ត្មាត [tʰmaːt] ត្មោង [tʰmaɔŋ] |
| ត្ល | tl | [tʰl] | ត្លុក [tʰloʔ] ត្លៃ [tʰlaɛ] |
| ត្វ | kw | [tʰw] | ត្វា [tʰwaː] ត្វាង [tʰwaːŋ] |
| ថ្ក | tʰk | [tʰk] | ថ្កើងថ្កាន [tʰkaɜŋ tʰkaːn] |
| ថ្ម | tʰm | [tʰm] | ថ្ម [tʰmɒː] ថ្មី [tʰmɜj] |
| ទ្វ | [tw] | [tʰw] | ទ្វារ [tʰwiɜ] ទ្វេ [tʰweː] |
| ប្ដ | bd | [pʰd] | ប្ដី [pʰdɜj] ប្ដូរ [pʰdɔo] |
| ប្ល | bl | [pʰl] | ប្លូន់ [pʰdɒn] ប្លប់ [pʰdɒp] ប្លាច់ [pʰdɑc] |
| ផ្ក | pʰk | [pʰk] | ផ្កា [pʰkaː] ផ្កាយ [pʰkaːj] |
| ផ្ង | pʰŋ | [pʰŋ] | ផ្ងារ [pʰŋaː] |
| ផ្ច | pʰc | [pʰc] | ផ្ចាញ់ [pʰcaɲ] ភ្ជាប់ [pʰcoap] |
| ផ្ដ | pʰd | [pʰd] | ផ្ដល់ [pʰdɒl] ផ្ដើម [pʰdaɜm] ផ្ដួល [pʰduɜl] |
| ផ្ទ | pʰt | [pʰt] | ផ្ទះ [pʰtɛah] ផ្ទុះ [pʰtuh] |
| ផ្ន | pʰn | [pʰn] | ផ្នែក [pʰnaɛc] ផ្នត់ [pʰnɑt] |
| ផ្ល | pʰl | [pʰl] | ផ្លិត [pʰlɜt] ផ្លែ [pʰlaɛ] ផ្លាន [pʰlaːn] |
| ផ្ស | pʰs | [pʰs] | ផ្សិត [pʰsɜt] ផ្សារ [pʰsaː] ផ្សាយ [pʰsaːj] |
| ពុក | pk | [pʰk] | ពុល [pʰkol] |

| | | | |
|---|---|---|---|
| ព្ន | pn | [pʰn] | ព្នង [pʰnɔːŋ] ព្នាយ [pʰniɜj] |
| ព្យ | pj | [pʰj] | ព្យុះ [pʰjuh] ព្យាយាម [pʰjiɜ jiɜm] |
| ព្ល | pl | [pʰl] | ព្លិការ [pʰlikaː] ព្លុក [pʰluk] |
| ភ្ញាក់ | pʰɲ | [pʰɲ] | ភ្ញាក់ [pʰɲɛaʔ] ភ្ញាស់ [pʰɲoah] |

## ព្យញ្ជនៈផ្សំដែលមានស្រៈខ្សោយនៅកណ្ដាល shwa [ᵊ]

| | | | |
|---|---|---|---|
| ក្ដ | Kd | [kᵊd] | ក្ដារ [kᵊdaː] ក្ដាន់ [kᵊdan] ក្ដាម [kᵊdaːm] |
| ក្ង | kŋ | [kᵊŋ] | ក្ងាន [kᵊŋaːn] ក្ងោក [kᵊŋaɔk] |
| ក្ឌ | Kd | [kᵊd] | ក្ឌាំង [kᵊdɛaŋ] ក្ឌុក [kᵊduʔ] |
| ក្អ | kʔ | [kᵊʔ] | ក្អែក [kᵊʔaɛc] ក្អក [kᵊʔɒː ʔ] |
| ច្ប | cb | [cᵊb] | ច្បាប់ [cᵊbap] ច្បាំង [cᵊbaŋ] |
| ត្ប | tb | [tᵊb] | ត្បាល់ [tᵊbal] ត្បូង [tᵊbɔoŋ] ត្បាញ [tᵊbaːɲ] |
| ត្អ | tʔ | [tᵊʔ] | ត្អើក [tᵊʔaɜk] ត្អូញ [tᵊʔɔoɲ] |
| ប្អ | pʔ | [pᵊʔ] | ប្អូន [pᵊʔɔon] ផ្អក [pᵊʔɒːʔ] |
| ម្ក | mk | [mᵊk] | ម្កាក់ [mᵊkaʔ] ម្កាល [mᵊkaːl] |
| ម្ខ | mkʰ | [mᵊkʰ] | ម្ខាង [mᵊkʰaːŋ] |
| ម្ច | mc | [mᵊc] | ម្ចាស់ [mᵊcah] ម្ជូរ [mᵊcuː] |
| ម្ដ | md | [mᵊd] | ម្ដង [mᵊdɒːŋ] ម្ដាយ [mᵊdaːj] |
| ម្ន | mn | [mᵊn] | ម្នាក់ [mᵊnɛa ʔ] ម្នាស់ [mᵊnoah] |
| ម្យ | mj | [mᵊj] | ម្យ៉ាង [mᵊjaːŋ] |
| ម្រ | mr | [mᵊr] | ម្រាក់ [mᵊrɛa ʔ] ម្រះ [mᵊrɛah] |
| ម្ល | ml | [mᵊl] | ម្លិះ [mᵊlih] ម្ល៉េះ [mᵊlɛh] |
| ម្ស | ms | [mᵊs] | ម្សិល [mᵊsɜl] ម្សាញ់ [mᵊsaɲ] |
| ល្ក | lk | [lᵊk] | ល្កក់ [lᵊkɑʔ] ល្កម [lᵊkɒːm] |
| ល្ខ | lkʰ | [lᵊkʰ] | ល្ខោន [lᵊkʰaɔn] |
| ល្គ | lk | [lᵊk] | ល្គង [lᵊkɔːŋ] ល្គឹក [lᵊkək] |
| ល្ង | lŋ | [lᵊŋ] | ល្ងង់ [lᵊŋʊŋ] ល្ងាច [lᵊŋiɜc] |
| ល្ប | lb | [lᵊb] | ល្បិច [lᵊbɛc] ល្បែង [lᵊbaɛɲ] |
| ល្ម | lm | [lᵊm] | ល្មម [lᵊmɔːm] ល្មោភ [lᵊmoːp] |
| ល្វ | lw | [lᵊw] | ល្វែង [lᵊwɛːɲ] ល្វើយ [lᵊwəːj] |
| ល្ហ | lh | [lᵊh] | ល្ហាច [lᵊhaːc] ល្ហុង [lᵊhoŋ] |
| ល្អ | lʔ | [lᵊʔ] | ល្អ [lᵊʔɒː] ល្អក់ [lᵊʔɑʔ] |

## តារាងសញ្ញាព្យញ្ជនៈនិងសូរព្យញ្ជនៈខ្មែរ

| សញ្ញាព្យញ្ជនៈ | ជើងព្យញ្ជនៈ | សូរព្យញ្ជនៈ (IPA/ API) |
|---|---|---|
| ក | ◌្ក | kɒː |
| ខ | ◌្ខ | kʰɒː |
| គ | ◌្គ | kɔː |
| ឃ | ◌្ឃ | kʰɔː |
| ង | ◌្ង | ŋɔː |
| ច | ◌្ច | cɒː |
| ឆ | ◌្ឆ | cʰɒː |
| ជ | ◌្ជ | cɔː |
| ឈ | ◌្ឈ | cʰɔː |
| ញ | ◌្ញ | ɲɔː |
| ដ | ◌្ដ | dɒː |
| ឋ | ◌្ឋ | tʰɒː |
| ឌ | ◌្ឌ | dɔː |
| ឍ | ◌្ឍ | tʰɔː |
| ណ | ◌្ណ | nɒː |
| ត | ◌្ត | tɒː |
| ថ | ◌្ថ | tʰɒː |
| ទ | ◌្ទ | tɔː |
| ធ | ◌្ធ | tʰɔː |
| ន | ◌្ន | nɔː |
| ប | ◌្ប | bɒː |
| ផ | ◌្ផ | pʰɒː |
| ព | ◌្ព | pɔː |
| ភ | ◌្ភ | pʰɔː |
| ម | ◌្ម | mɔː |
| យ | ◌្យ | jɔː |
| រ | ◌្រ | rɔː |
| ល | ◌្ល | lɔː |
| វ | ◌្វ | wɔː |
| ស | ◌្ស | sɒː |
| ហ | ◌្ហ | hɒː |
| ឡ | ø | lɒː |
| អ | ◌្អ | ʔɒː |

**១.៣.៣. ស្រះ**

ក្នុងផ្នែកនេះ យើងនឹងសិក្សាអំពីសូរស្រៈនិងសញ្ញាស្រៈនៅក្នុងភាសាខ្មែរ។

**១.៣.៣.១. សូរស្រះ**

**១.៣.៣.១.១. និយមន័យ**

តាមនិយមន័យទូទៅ សូរស្រៈ គឺជាសូរមួយប្រភេទដែលគ្មានឧបសគ្គ ឬទំនប់អ្វីមួយមករារាំងក្នុងការបន្លឺ។ ក្នុងការបន្លឺសូរស្រៈទៀតសោត ខ្សែសំឡេងញ័រខ្លាំង រង្វះខ្យល់បើកធំ ហើយនិងគ្មានបម្រឹងសាច់ដុំរបស់ប្រដាប់បន្លឺ (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ៨)។

បើគិតតាមសូរវិទ្យា ស្រៈគឺជាសូរភាសាដែលក្នុងការបន្លឺបំពង់សំឡេងបើកចំហ ហើយក្នុងពេលបន្លឺអណ្ដាត មិនប៉ះនឹងបបូរមាត់ មិនប៉ះនឹងធ្មេញ មិនប៉ះនឹងក្រអូមជាដើម។ ក្នុងការបន្លឺសូរស្រៈទៀតសោត ក៏គ្មានសំពាធខ្យល់ដែរ។ បើគិតតាមសទ្ទតាវិទ្យា ស្រៈគឺជាធាតុចាំបាច់សម្រាប់បង្កើតព្យាង្គ ដែលគេហៅថា «ស្នូលព្យាង្គ»ឬ «ណ្វៃយ៉ូ»។

ភាសាខ្មែរក៏ដូចជាភាសាដទៃទៀតក្នុងក្រុមមន-ខ្មែរ (ក្នុងនោះមានភាសាព្រៅ ជាដើម) ជាភាសាដែលមានសូរស្រៈច្រើនជាងសូរព្យញ្ជនៈ គឺមានលើសពី៣០សូរ ទោះបីអ្នកស្រាវជ្រាវមិនទាន់យល់ស្របគ្នាទាំងស្រុងចំពោះចំនួនសូរនេះក៏ដោយ ប៉ុន្តែការខ្វែងគំនិតគ្នាមានតិចតួច។

គេអាចចែកសូរស្រៈតាម៖

-មូលភេទ អ-អ៊

-ប្រភេទវែង-ខ្លី និងទោល-ផ្សំ

-ទីបន្លឺ (ស្រៈមុខ ស្រៈកណ្ដាល ស្រៈក្រោយ)។

**១.៣.៣.១.២. មូលភេទ អ-អ៊**

តាមមូលភេទ សូរស្រៈអាចចែកជាបីពួកគឺ៖

-សូរស្រៈពួក [អ] ឧទាហរណ៍៖ ដី កាប់ ផ្ការ ដាំ ថ្នាំ។

ក្នុងពាក្យខាងលើ «ី ា» (ប្រើជាមួយតួព្យញ្ជនៈពួក អ) កត់សូរស្រៈពួក អ «[ី] [ា]»។

សូរស្រៈពួក អ មាន៖ [អ] [អ់] [អា] [អ៉ា] [អិ] [អី] [អឹ] [អឺ] [អុ] [អូ] [អើ] [អេ] [អែ] [អៃ] [អោ] [អៅ] ។

-សូរស្រៈពួក [អ៊] ឧទាហរណ៍៖ ពង្រឹង ជានិច្ច រាល់ពេល។

ក្នុងពាក្យខាងលើស្រៈ «ឹ ា ិ េ » (ប្រើជាមួយតួព្យញ្ជនៈពួក អ៊) កត់សូរស្រៈពួក អ៊ «[អ៊ឹ] [អ៊ា] [អ៊ិ] [អ៊េ]» ។

សូរស្រៈពួក [អ៊] មាន៖ [អ៊] [អ៊ំ] [អ៊ា] [អ៊ាំ] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ើ] [អ៊េ] [អ៊ែ] [អ៊ែំ] [អ៊ៃ] [អ៊ោ] [អ៊ៅ] [អ៊័រ] ។

-សូរស្រៈពួក [អ-អ៊] ឧទាហរណ៍៖ កួរ គួរ ទិតៀន ទៀន តឿន លឿន។

ក្នុងពាក្យខាងលើ «ួ ឿ ៀ» (ប្រើជាមួយតួព្យញ្ជនៈពួក អ ក៏បាន អ៊ ក៏បាន) កត់សូរស្រៈពួក អ-អ៊៖ «[អួ] [អឿ] [អៀ]» ។ សូរស្រៈពួក អ-អ៊ មាន៖ [អួ] [អឿ] [អៀ] ។

<u>តារាងស្រៈតាមបញ្ចេក អ-អ៊</u>

| សញ្ញា | សូរ | | ឧទាហរណ៍ | | | |
|---|---|---|---|---|---|---|
| ស្រៈ | ពួក អ | ពួក អ៊ | សំណេរ | សំណូរ | សំណេរ | សំណូរ |
| «ា» | អ | អ៊ | ស | [ស] | ពរ | [ព] |

| | | | | | | |
|---|---|---|---|---|---|---|
| | អ់ | អ៊់ | បក់ | [ប់ក] | ដក់ | [ដ់ក] |
| ◌ា | អា | អ៊ា | សារ | [សា] | ពារ | [ពា] |
| | អា់ | អ៊ា់ | ដាក់ | [ដា់ក] | ទាក់ | [ទា់ក] |
| ◌ិ | អិ | អ៊ិ | ហិប | [ហិប] | ទិញ | [ទិប] |
| ◌ី | អី | អ៊ី | កី | [កី] | ទី | [ទី] |
| ◌ឹ | អឹ | អ៊ឹ | ផឹក | [ផឹក] | ទឹក | [ទឹក] |
| ◌ឺ | អឺ | អ៊ឺ | បឺត | [បឺត] | ឃឺត | [ឃឺត] |
| ◌ុ | អុ | អ៊ុ | ដុត | [ដុត] | ពុធ | [ពុត] |
| ◌ូ | អូ | អ៊ូ | តូប | [តូប] | ស៊ូ | [ស៊ូ] |
| ◌ើ | អើ | អ៊ើ | សើ | [សើ] | ស្មើរ | [ស្មើ] |
| ◌េ | អេ | អ៊េ | កេរ | [កេ] | រេ | [រេ] |
| ◌ែ | អែ | អ៊ែ | តែ | [តែ] | គែ | [គែ] |
| | | អ៊ែ់ | | | ល្មែះ | [ល្មែ់ហ] |
| ◌ៃ | អៃ | អ៊ៃ | ហៃ | [ហៃ] | គៃ | [គៃ] |
| ◌ោ | អោ | អ៊ោ | តោ | [តោ] | គោ | [គោ] |
| ◌ៅ | អៅ | អ៊ៅ | ដៅ | [ដៅ] | ពៅ | [ពៅ] |
| ◌័ ឬ ◌ា◌់ | | អ៊័ | | | ពណ៌ | [ព័រ] |
| | | | | | ទាល់ | [ទ័ល] |

| សញ្ញាស្រៈ | សូរពួក អ-អ៊ | ឧទាហរណ៍ | |
|---|---|---|---|
| ◌ួ | អួ | កួរ | គួរ |
| ◌ឿ | អឿ | តឿ | ជឿ |
| ◌ៀ | អៀ | ចៀន | ជៀន |

### ១.៣.៣.១.៣. សូរស្រៈវែងនិងសូរស្រៈខ្លី

ក. **សូរស្រៈវែង** គឺជាសូរស្រៈដែលបន្លឺឡើងដោយដំណើរខ្យល់បង្ហូរវែង។

សូរស្រៈវែងមានដូចជា៖

អ [ɒː]　អា [aː]　អឺ [œː]　អូ [ɔo]　អើ [aɜ]　អេ [ɛe]

អែ [aɛ]　អោ [aɔ]　អ៊ [ɔː]　អ៊ា/អៀ [iɜ]　អ៊ី [iː]　អ៊ឺ [ɨː]

អ៊ូ [uː]　អួ [uɜ]　អ៊ើ [əː]　អ៊េ [eː]　អ៊ែ [ɛː]　អ៊ោ [oː]

អ័រ [oa]　អឿ [ɨɜ]។

ខ. **សូរស្រៈខ្លី** គឺជាសូរស្រៈដែលបន្លឺឡើងដោយដំណើរខ្យល់បង្ហូរខ្លី (កាត់យ៉ាងរហ័សដោយបិទខ្សែសំឡេង)។

សូរស្រៈខ្លីគឺជាសូរស្រៈដែលក្នុងការបន្លឺ គេឃើញថា រយៈពេលនៃការបន្លឺមានរយៈពេលខ្លី។ ក្នុងភាសាមួយចំនួនដែលក្នុងនោះមានភាសាខ្មែរផងដែរ គេឃើញមានវត្តមានសូរស្រៈខ្លីនៅក្នុងព្យាង្គខ្សោយ គឺព្យាង្គដែលមិនទទួលការសង្កត់សូរ (សូរសង្កត់) ដូចជា ក្នុងពាក្យ «កករ» [kɒkɒː] សូរស្រៈ [ɒ] ក្នុងព្យាង្គទីមួយដែលជាព្យាង្គខ្សោយឮសូរកញ្ឆក់ខ្លីជាងសូរស្រៈ [ɒː] ក្នុងព្យាង្គទីពីរដែលជាព្យាង្គខ្លាំងឬព្យាង្គដែលទទួលការសង្កត់សូរ។

សូរស្រៈខ្លីមានដូចជា៖

| | | | | | |
|---|---|---|---|---|---|
| អ់ [ɒ] | អ៉ា [a] | អិ [e] | អឹ [ɜ] | អុ [o] | អ៉ំ [ɔ] |
| អ៊ា [ɛa] | អ៊ិ [i] | អ៊ឹ [ɘ] | អ៊ុ [u] | អ៊ែ [ɛ] ។ | |

**<u>កំណត់សម្គាល់</u>** ក្នុងភាសាសរសេរ សូរស្រៈខ្លីខ្មែរសម្គាល់ដោយ៖

| | |
|---|---|
| -សញ្ញាបន្តក់ «់» | ឧ. កក់ សង់ បន់ កាក់ ចាស់ |
| -សញ្ញាដំលើ «ំ» | ឧ. ដំ ចាំ សំ ទំ |
| -សញ្ញារះមុខ «ះ» | ឧ. បះ សះ ខ្លះ កោះ សោះ |
| -ព្យាង្គដើមក្នុងពាក្យច្រើនព្យាង្គ | ឧ. បបរ ប្រអប់ ញញួរ |
| -សញ្ញាចុចពីរ ឬយុគ្គលពិន្ទុ «ៈ» | ឧ. សុខៈ ធុរៈ កាលៈទេសៈ |
| -សញ្ញាលេខប្រាំបី «៏» | ឧ. ក៏ ដ៏ ន៏ |
| -សញ្ញាផាត់លើ «៍» | ឧ. ជ័យ ភ័យ សម័យ |

### ១.៣.៣.១.៤. សូរស្រៈទោលនិងសូរស្រៈផ្សំ

**ក. សូរស្រៈទោល** គឺជាសូរស្រៈដែលកើតឡើងតែម្នាក់ឯង។

សូរស្រៈទោលមានដូចជា៖

| | | | | | |
|---|---|---|---|---|---|
| អ [ɒː] | អ់ [ɒ] | អ៊ិ [ɔː] | អ៉ំ [ɔ] | អា [aː] | អ៉ា [a] |
| អិ [e] | អ៊ី [iː] | អ៊ិ [i] | អឹ [ɜ] | អឺ [œː] | អ៊ឹ [ɘ] |
| អ៊ឺ [ɨː] | អុ [o] | អ៊ុ [u] | អ៊ូ [uː] | អ៊ើ [ɘː] | អេ [eː] |
| អ៊ែ [ɛː] | អ៊ែ់ [ɛ] | អ៊ោ [oː]។ | | | |

**ខ. សូរស្រៈផ្សំ** កើតឡើងដោយស្រៈទោលពីរយ៉ាងតិចលាយបញ្ចូលគ្នា។

សូរស្រៈផ្សំមានដូចជា៖

| | | | | |
|---|---|---|---|---|
| អើ [aɜ] | អៃ [aɛ] | អោ [aɔ] | អ៊ា/អៀ [iɜ] | អ៊ា [ɛa] |
| អ៊ំវ [oa] | អួ [uɜ] | អូ [ɔo] | អឿ [ɨɜ] | អេ [ɛe]។ |

### ១.៣.៣.១.៥. សូរស្រៈមុខ សូរស្រៈកណ្ដាល និងសូរស្រៈក្រោយ

តាមចលនាមុខក្រោយនៃអណ្ដាត ក្នុងការបន្លឺ គេបែងចែកសូរស្រៈជា សូរស្រៈមុខ សូរស្រៈកណ្ដាល និងសូរស្រៈក្រោយ។ ដោយផ្អែកលើចលនាលើក្រោមនៃអណ្ដាតវិញ គេចែកសូរស្រៈជា សូរស្រៈលើ សូរស្រៈមធ្យម និងសូរស្រៈក្រោម។ ក្នុងភាសាខ្មែរ សូរស្រៈ អ៊ិ [i]និងអ៊ី [iː] ជាដើម ជាសូរស្រៈមុខផង ជាសូរស្រៈលើផង ព្រោះថា ក្នុងការបន្លឺ បើគិតតាមចលនាមុខក្រោយនៃអណ្ដាត យើងឃើញថា អណ្ដាតរុញទៅមុខ។ បើគិតតាមចលនាលើក្រោម គេឃើញចលនាអណ្ដាតឡើងលើហួសអ័ក្សកណ្ដាលនៃគុហាមាត់។ សូរស្រៈ អ៊ុ [u] និង អ៊ូ [uː] ជាសូរស្រៈក្រោយ និងជាសូរស្រៈលើ។ ក្នុងការបន្លឺសូរស្រៈទាំងពីរនេះ គេឃើញថា ខ្នងអណ្ដាតរុញទៅក្រោយទៅរកនាំងក្រអូមនិងទៅលើ។

**ក. សូរស្រៈមុខ** ជាសូរស្រៈដែលមានទីបន្លឺនៅផ្នែកខាងមុខនៃក្រអូម។

សូរស្រៈមុខមានដូចជា៖

អា [aː] អ៉ា [a] អ៊ី [iː] អ៊ិ [i]

អិ [e] អេ៊ [eː] អែ៊ [ɛː] អែ៊ំ [ɛ]។

**ខ. សូរស្រៈកណ្តាល** ជាសូរស្រៈដែលមានទីបន្លឺនៅផ្នែកកណ្តាលនៃក្រអូម។

សូរស្រៈកណ្តាលមានដូចជា៖

អឺ [ɜ] អឺ [œː] អ៊ឹ [ɘ] អ៊ឺ [ɨː]។

**គ. សូរស្រៈក្រោយ** ជាសូរស្រៈដែលមានទីបន្លឺនៅផ្នែកខាងក្រោយនៃក្រអូម។

សូរស្រៈក្រោយមានដូចជា៖

អ [ɒː] អ់ [ɒ] អ៊ី [ɔː] អ៊ំ [ɔ]

អ៊ុ [u] អ៊ូ [uː] អូ [ɔo] អ៊ោ [oː]។

**តារាងបែងចែកសូរស្រៈតាមចលនាអណ្តាត**




## ១.៣.៣.២. សញ្ញាស្រៈ

សញ្ញាស្រៈសម្រាប់កត់សូរស្រៈ។ ដើម្បីកត់សូរស្រៈ ខ្មែរយើងប្រើសញ្ញាស្រៈពីរយ៉ាងគឺ សញ្ញាស្រៈនិស្ស័យ និងសញ្ញាស្រៈពេញតួ។

### ១.៣.៣.២.១. សញ្ញាស្រៈនិស្ស័យ

សញ្ញាស្រៈនិស្ស័យ គឺជាសញ្ញាស្រៈដែលអាចប្រើបានជាមួយនឹងសញ្ញាព្យញ្ជនៈពួក[អ]ផងនិងពួក[អ៊]ផង។

សញ្ញាស្រៈនិស្ស័យមានដូចជា ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ ◌េះ ◌ោះ ។

បើតាមសៀវភៅវេយ្យាករណ៍ថ្នាក់ទី៥ របស់ក្រសួងអប់រំ បោះពុម្ពឆ្នាំ១៩៨៣ សញ្ញាស្រៈនិស្ស័យមានដូចជា ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ។

វាកត់សូរពួកអ៖ [អា] [អិ] [អី] [អឹ] [អឺ] [អុ] [អូ] [អួ] [អើ] [អឿ] [អៀ] [អេ] [អែ] [អៃ] [អោ] [អៅ] ។

វាកត់សូរពួកអ៊៖ [អ៊ា] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ួ] [អ៊ើ] [អ៊ឿ] [អ៊ៀ] [អ៊េ] [អ៊ែ] [អ៊ៃ] [អ៊ោ] [អ៊ៅ] ។

**<u>សង្កេត</u>**៖ សញ្ញាស្រៈ «◌ួ ◌ឿ ◌ៀ» កត់សូរ [អួ] [អឿ] [អៀ] តែមួយពួកប៉ុណ្ណោះ។

បើតាមសៀវភៅវេយ្យាករណ៍ភាសាខ្មែរ របស់សាស្ត្រាចារ្យ ឃីន សុខ ដែលបោះពុម្ពផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៧ សញ្ញាស្រៈនិស្ស័យមាន ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ ◌េះ ◌ោះ ◌ិះ ◌ឹះ។

**<u>កំណត់សម្គាល់</u>៖**

សញ្ញាស្រៈ ◌ើ ◌ឿ ◌ៀ ◌ែ ◌ៃ ◌ោ ◌ៅ ជាស្រៈផ្សំ។ ចំពោះរូប (◌េ+◌ី, ◌េ+◌ា) នេះ គ្រាន់តែជាការផ្សំរូបសុទ្ធសាធ ឥតមានសូរជាមូលដ្ឋានទេ៖ ◌េ+◌ី មិនមែនសូរស្រៈ◌េ សូរស្រៈ◌ី ទេ។ ហើយ ◌េ+◌ា ក៏មិនមែនសូរស្រៈ◌េ សូរស្រៈ◌ាដែរ។ ផ្ទុយពីនេះសញ្ញាស្រៈ ◌ុំ ◌ំ ◌ាំ ◌ះ ◌ិះ ◌ឹះ ◌ុះ ◌េះ ◌ោះ ពិតជាមានសូរផ្សំមែន គឺផ្សំជាមួយនឹង[ម] កាលណាមានដំលើ ហើយផ្សំជាមួយនឹង [ហ] កាលណាមានរះមុខ។

ឈ្មោះសញ្ញាស្រៈខ្លះដែលបុព្វបុរសខ្មែរបានកំណត់មកដូចជា៖

| | |
|---|---|
| ◌ា យារ (ទាញយារ) | ◌ិ ក្បៀស (ស្លឹកឈើ, ស្លឹក) |
| ◌ី ក្បៀសមួយ (ស្លឹកបន្តក់) | ◌ឹ ស្លឹកធំ |
| ◌ឺ ស្លឹកក្បៀស | ◌ុ រុកជើង ឬបុកជើង |
| ◌ូ រុកជើងអូ (បុក២) | ◌ួ រុកជើងបញ្ចូច (សញ្ញាអួ) |
| ◌ើ បាំងឈើក្បៀសមួយ (បាំងស្លឹក) | ◌ឿ សញ្ញាអឿ |
| ◌ៀ បាំងឈើរុកជើង (សញ្ញាអៀ) | ◌េ បាំងឈើ |
| ◌ែ គួច (បាំងជើប) | ◌ៃ លា (បាំងងប់) |
| ◌ោ បាំងយារ | ◌ៅ បាំងយារលើ |
| ◌ំ ដំលើ | ◌ះ រះមុខ |

ឧទាហរណ៍៖ យើង ទៅ សាលារៀន។ ក្នុងល្បះ «យើង ទៅ សាលារៀន»។ យើងឃើញថា ស្រៈ«◌ើ ◌ៅ ◌ា ◌ៀ» ភ្ជាប់តួរបស់ខ្លួនទៅនឹងតួព្យញ្ជនៈ «យ ទ ស ល រ» ។

### ១.៣.៣.២.២. សញ្ញាស្រៈពេញតួ

សញ្ញាស្រៈពេញតួ គឺជាសញ្ញាស្រៈសម្រាប់ប្រើជាពិសេសក្នុងកំណត់សូរពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹត។ វាអាចប្រើតែឯកឯងបានដោយពុំបាច់ភ្ជាប់នឹងសញ្ញាព្យញ្ជនៈ។

សញ្ញាស្រៈពេញតួមានដូចជា អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឲ ឳ។

ឧទាហរណ៍៖ ឥសូរ ឱកាស ឯង អវយវៈ អាយាត ឰដ៏ ឫស្សី។

**<u>កំណត់សម្គាល់</u>៖**

-សញ្ញាស្រៈភ្ជាប់តួប្រើនៅកណ្ដាលឬចុងព្យាង្គ។ ឧទាហរណ៍ កើត បណ្ដើរ ទៅ តា...។

-សញ្ញាស្រៈពេញតួពីរតួនេះ(ឮ ឳ) ពុំមានក្នុងភាសាបាលី-សំស្ក្រឹតទេ។

-សញ្ញាស្រៈពេញតួមួយតួនេះ(ឬ) ពុំឃើញមានប្រើក្នុងពាក្យកម្ចីភាសាបាលី-សំស្ក្រឹតណាមួយ ដែលមានក្នុងវចនានុក្រមទេ។

## ២. ប្រព័ន្ធសូរនៃភាសា

ប្លែកពីសូរវិទ្យាដែលសិក្សាពីសូររូបសាស្ត្រនៃសម្ដី សទ្ទតាវិទ្យាសិក្សាអំពីសូរភាសាក្នុងចរន្តសម្ដី។ តាមន័យនេះ សូរវិទ្យាទាក់ទងភាគច្រើននឹងវិទ្យាសាស្ត្រពិត ចំណែកសទ្ទតាវិទ្យាទាក់ទងនឹងមុខងារទំនាក់ទំនងរបស់ភាសា ដែលជាផ្នែកមួយនៃវិទ្យាសាស្ត្រសង្គម។

សទ្ទតាវិទ្យាសិក្សាអំពីគំរូសូររបស់ភាសាណាមួយជាកំណត់។ ពាក្យថា គំរូសូរ (sound patterns) សំដៅលើអ្វីដែលថាភាសានីមួយៗមានគំរូសូរដោយឡែកៗនិងច្បាស់លះរបស់ខ្លួន។ ភាសាខ្មែរមានគំរូសូរខុសពីគំរូសូរភាសាអង់គ្លេស។ បើធៀបគំរូសូរស្រះ ភាសាខ្មែរមានសូរស្រះច្រើនជាងភាសាអង់គ្លេស ភាសាខ្មែរគ្មានសូរព្យញ្ជនៈស្នះ-ត្រដុសទេ រីឯភាសាអង់គ្លេសមានសូរបែបនេះ។ ក្នុងភាសារុស្ស៊ី [a] ជាស្រះក្រោម-កណ្ដាល ក្នុងភាសាខ្មែរ [a] ជាស្រះក្រោម-មុខ។ ភាសាខ្មែរគ្មានព្យញ្ជនៈមាត់ ស្នះ ក្រអូមក្រោយ ឃោសៈ ភាសាបារាំងមានព្យញ្ជនៈដែលមានសូរក្នុងលក្ខណៈបែបនេះ។ ដោយសារតែ ភាសានីមួយៗមានគំរូសូរជាក់លាក់របស់ខ្លួន ទើបក្នុងភាសាទាំងនោះ គេរៀបគំរូសូរទាំងនោះជាប្រព័ន្ធ។ ការសិក្សាពីប្រព័ន្ធសូរទាំងនោះក៏ជាកម្មវត្ថុរបស់សទ្ទតាវិទ្យាដែរ។

### ២.១. និយមន័យសទ្ទតាវិទ្យា

បើតាមសៀវភៅ « A Dictionary of Linguistics and Phonetics» បានសរសេរថា សទ្ទតាវិទ្យា គឺជាសាខាមួយនៃភាសាវិទ្យាដែលសិក្សាពីប្រព័ន្ធសូរនៅក្នុងភាសាទាំងឡាយ។ សូរទាំងនោះត្រូវរៀបចំនៅក្នុងភាពប្រឈមគ្នា ដែលត្រូវវិភាគតាមសទ្ទតា លក្ខណៈបន្លែកជាដើម ដោយអនុលោមទៅតាមទ្រឹស្ដីដែលគេប្រើប្រាស់។ គោលបំណងនៃសទ្ទតាវិទ្យា គឺចង់ពន្យល់បកស្រាយពីគំរូសូរខុសៗគ្នា(សូរប្រឈមគ្នា)នៅក្នុងភាសានីមួយៗ និងដើម្បីបង្កើតគំហាទូទៅតាមដែលអាចធ្វើទៅបានស្ដីអំពីធម្មជាតិនៃប្រព័ន្ធសូររបស់ភាសានានានៅក្នុងពិភពលោក។

សទ្ទតាវិទ្យា ជាវិជ្ជាដែលយកចិត្តទុកដាក់តែលើបន្លែកណាដែលមានមុខងារបង្កើតពាក្យផ្សេងៗគ្នាក្នុងបរិបទដដែលណា/ទាំងឡាយណា របស់ភាសាណាមួយ (ព្រុំ ម៉ល់, ២០១៣: ៣២)។

### ២.២. សទ្ទតា

#### ២.២.១. ប្រវត្តិទាក់ទងនឹងការសិក្សាអំពីសទ្ទតា

ពាក្យថា «សទ្ទតា» ត្រូវបាន អា. ឌុយហ្វ្រីស-ដេហ្សេណែត (A. Dufriche-Desgenette) ប្រើប្រាស់ដំបូងគេបង្អស់ក្នុងឆ្នាំ១៨៧៣ ក៏ប៉ុន្តែ ក្នុងពេលនោះ គេនិយាយសំដៅតែលើសូរសម្ដីប៉ុណ្ណោះ។ សទ្ទតាជាអ្វីមួយអរូបីត្រូវលើកយកមកសិក្សាបន្ថែមដោយលោក បូដ្វាំង ដឺ គួតឺនេ (Jan Niecislaw Baudouin de Courtenay) ភាសាវិទូជាតិប៉ូឡូញនិងសិស្សរបស់គាត់ គឺលោក មីកូឡាយ គ្រូសែវស្គី (Mikolaj Kruszewski) ក្នុងអំឡុងឆ្នាំ១៨៧៥-១៨៩៥។ ពាក្យដែលភាសាវិទូទាំងពីរប្រើក្នុងពេលនោះ គឺពាក្យ fonema (សទ្ទតា) ដែលពួកគាត់ចាត់ទុកថា ជាឯកតាមូលដ្ឋាននៃអ្វីដែលពួកគាត់ហៅថាចិត្តសូរវិទ្យា (psychophonetic)។ បញ្ញត្តិនៃសទ្ទតា ត្រូវបានលោកនីកូឡាយ ទ្រូបេតស្កយ (Nikolai Trubetzkoi) និងសាលាភាសាវិទ្យាប្រាកក្នុងអំឡុងឆ្នាំ១៩២៦-១៩៣៥ ហើយក្រុមអ្នកទម្រង់និយមទាំងនោះ រួមមានលោក ហ្វេរឌីណង់ ដឺ សូស្សៀរ (Ferdinand de Saussure) លោក អេដវ៉ាតសាពៀរ (Edward Sapir) និងលោក ឡេអូណាត ប្លូមហ្វៀល (Leonard Bloomfield) យកមកធ្វើឱ្យមានសុក្រឹតភាពបន្ថែមទៀត។ ក្រោយមកទៀត ការសិក្សាពីសទ្ទតារឹតតែស៊ីជម្រៅថែមទៀតនិងជាមូលដ្ឋានសំខាន់នៃសទ្ទតាវិទ្យា គឺក្រុមភាសាវិទ្យាវេយ្យាករណ៍បំប្លែងដែលក្នុងនោះមានលោក ណម ឆមស្គី (Noam Chomsky) ម៉ូរិស ហាលេ (Moris Halle) រ៉ូម៉ែន ចាកុបសុន (Roman Jakobson) ជាដើម។

#### ២.២.២. និយមន័យសទ្ទតា

ក្នុងការប្រើប្រាស់ភាសាដើម្បីទាក់ទងគ្នា ជាដំបូងគេត្រូវដឹងពីការបន្លឺសូរនៃពាក្យនីមួយៗនិងដឹងពីន័យនៃពាក្យនោះ។ គេអាចថា ការបន្លឺសូរជាទម្រង់ (form) ឯន័យជាខ្លឹមសារ(content)។ ឧទាហរណ៍ ពាក្យក្នុងភាសាខ្មែរ ដូចជា «កា» «កូរ» «កត់» «កាត់» «សង» «សូម» ជាដើម គេអាចដឹងឬអាចចេះប្រើពាក្យទាំងនោះក្នុងភាសាខ្មែរក្នុងការនិយាយទៅកាន់គូសន្ទនាដើម្បីឱ្យគូសន្ទនាស្ដាប់បាននិងយល់ន័យពាក្យនោះ ទាល់តែអ្នកនិយាយបន្លឺសូរបានត្រឹមត្រូវ។ ប្រសិនបើមានការល្មៀងក្នុងការបន្លឺសូរនោះន័យនៃពាក្យនោះក៏ឃ្លាងឃ្លាតន័យដើមដែរ ដូចជា «កូរ»

បើយើងបន្លឺថា «គោ» នោះអ្នកស្ដាប់យល់ថាជា «សត្វគោ» មិនមែន «កូរសម្ល» នោះឡើយ។ អ្វីដែលនាំឱ្យន័យប្លែកគ្នានោះគឺជាសទ្ទតា។

សទ្ទតា ជាឯកតានៃរចនាសម្ព័ន្ធសូរភាសាដែលមានមុខងារធ្វើអត្តសញ្ញាណកម្មនិងញែកឯកតាមានន័យទាំងឡាយរបស់ភាសា(ក្នុងនោះរាប់ទាំងមូលតា)។ សទ្ទតាជាធាតុសិចម៉ង់តូចបំផុតនិងជាធាតុមិនប្រែប្រួលរបស់ភាសា។ បំប្លែកន័យរវាង [ka:t] និង [kat] ក្នុងភាសាខ្មែរ កើតឡើងដោយការប្ដូរសទ្ទតា /a:/ និង /a/ [bat] និង [kat] ក្នុងភាសាខ្មែរ កើតឡើងដោយការប្ដូរសទ្ទតា /b/ និង /k/។ ពាក្យពីរដែលមានន័យប្លែកគ្នាតាមរយៈការប្រឈមសទ្ទតាទោល ហៅថាគូអប្បបរិមាណ (minimal pair)។

ចំណែកសៀវភៅ « A Dictionary of Linguistics and Phonetics» បានសរសេរថា សទ្ទតាជាឯកតាតូចបំផុតនៅក្នុងប្រព័ន្ធសូរនៃភាសា។ ជាការពិត ពុំមានភាសាណាមួយមានប្រព័ន្ធសទ្ទតាដូចគ្នានោះទេ។ ភាសាខ្លះមានសទ្ទតាតិចតួចបំផុត ភាសាខ្លះទៀត មានសទ្ទតាត្រឹមតែ១៥ប៉ុណ្ណោះ រីឯភាសាខ្លះទៀតមានសទ្ទតាច្រើនរហូតដល់៨០។

សទ្ទតា គឺជាឯកតាអប្បបរមាគ្មានន័យរបស់ភាសា ហើយមានមុខងារញែក/មុខងារបំប្លែកនៅក្នុងរូបតានិងវចនតា។ សទ្ទតាជារូបធាតុគ្រឹះសម្រាប់បង្កើតរូបតានិងវចនតា ដូចជា /t/ និង /n/ ដែលមានមុខងារញែក/មុខងារបំប្លែកនៅចុងព្យាង្គ /ba:t/ និង /ba:n/ ជាសទ្ទតា (ក្រុមប្រឹក្សាភាសាជាតិ, ២០១៨: ១៣)។

តាមសៀវភៅវេយ្យាករណ៍ថ្នាក់ទី៨ របស់ក្រសួងអប់រំបានសរសេរថា «សទ្ទតា គឺជាឯកតាតូចបំផុតនៃសូរអាចប្ដូរន័យនៃពាក្យមួយបានដោយគ្រាន់តែផ្លាស់គ្នាបន្តិចប៉ុណ្ណោះ ហើយពុំមានន័យដោយខ្លួនឯងទេ»។ សទ្ទតា គឺជាភាគល្អិតតូចបំផុតនៃសម្ដី។ វាគ្មានន័យដោយខ្លួនវាទេ ហើយមិនអាចបំបែកតទៅទៀតបាន។

## ២.៣. សូរនិងកាឡាសូរ

សទ្ទតាខ្លះ មានភាពប្លែកគ្នាក្នុងការបញ្ចេញសំឡេង (សូរ) ហើយសូរខុសៗគ្នានៃសទ្ទតាតែមួយនោះ គេហៅថាកាឡាសូរ (allophone)។ សូមមើលឧទាហរណ៍ខាងក្រោម ដែលបង្ហាញពីសូរផ្សេងៗនៃសទ្ទតាព្យញ្ជនៈ(ក្នុងភាសាអង់គ្លេស)៖




ដើម្បីកំណត់លក្ខខណ្ឌសទ្ទតា គេត្រូវតែពិនិត្យលើករណីដែលថា បើគេដាក់សូរមួយជំនួស សូរមួយទៀត សូរនោះនាំឱ្យមានការប្ដូរន័យពាក្យ សូរនោះជាសទ្ទតា បើដាក់ជំនួសទៅមិនបាន ធ្វើឱ្យដូរន័យពាក្យ សូរជាបំណែបសូរសេរី(free variant) ឬជាកម្លែមសូរ (complementary distribution)។ កម្លែមសូរជាកាឡាសូរមួយប្រភេទដែលមានគម្លាតសូរពីសទ្ទតាដើមនៃភាសាណាមួយ ដោយអាស្រ័យនឹងបរិបទសូរវិទ្យាដែលនៅជុំវិញវា ដូចជា ក្នុងភាសាអង់គ្លេស សទ្ទតា [k] [c] [p] [t] ជាដើម បន្លឺជា [k$^h$] [c$^h$] [p$^h$] [t$^h$] កាលណាវាជាធាតុដើមព្យាង្គ។ ដូច្នេះ [k$^h$] [c$^h$] [p$^h$] [t$^h$] ជាកម្លែមសូរនៃសទ្ទតា [k] [c] [p] [t] ក្នុងបរិបទសូរវិទ្យាមួយ គឺក្នុងបរិបទដែលសូរទាំងនោះជាធាតុដើមព្យាង្គ។

សូរពីរនៃភាសាមួយ ថ្វីបើមានភាពខុសគ្នាតាមត្រចៀកយើង អាចគ្មានមុខងារសម្រាប់ធ្វើឱ្យមានពាក្យពីរម៉ាត់ប្លែកគ្នា សម្គាល់អ្វីប្លែកគ្នា ក្នុងបរិបទដដែលណាមួយទេ។ ក្នុងករណីនេះ សូរទាំងពីរជាកាឡាសូរនៃសទ្ទតាតែមួយ គឺមិនមែនសទ្ទតាពីរដាច់គ្នាទេ។

## ២.៤. គូអប្បបរិមាណ

ដូចយើងដឹងខ្លះហើយថា សទ្ទតាជាឯកតាតូចបំផុតនៃភាសាដែលទាក់ទងនឹងលក្ខណៈប្រឈម ឬធ្វើឱ្យយើងដឹងពីន័យខុសៗគ្នារបស់ពាក្យនៅក្នុងភាសានីមួយៗ។ តើយើងអាចស្គាល់សទ្ទតានៃភាសាមួយដោយរបៀបណា? យើងអាចស្គាល់សទ្ទតាបានតាមរយៈការប្រើប្រាស់វិធីវិភាគម្យ៉ាងដែលគេហៅថាគូអប្បបរិមាណ (minimal pair) ដែលជាពាក្យពីរផ្សេងគ្នាកើតពីការជំនួសសូរ នៅក្នុងបរិបទដូចគ្នា។

សូមពិនិត្យមើលឧទាហរណ៍ខាងក្រោម(ក្នុងភាសាអង់គ្លេស)៖

| គូនៃពាក្យ | សទ្ទតាដែលគេរកឃើញ |
|---|---|
| seen [sin] mean [min] | /s/ និង /m/ (សូរប្រឈមគ្នារវាងព្យញ្ជនៈ /s/ និង /m/) |
| boot [but] beat [bit] | /u/ និង /i/ (សូរប្រឈមគ្នារវាងស្រៈ អ៊ុ /u/ និង អ៊ិ /i/) |
| need [nid] neat [nit] | /d/ និង /t/ (សូរប្រឈមគ្នារវាងព្យញ្ជនៈ /d/ និង /t/) |

*គូអប្បបរិមាណ (minimal pairs)*

ក្នុងសទ្ទតាវិទ្យា បើទម្រង់ពីរផ្សេងគ្នា តែទម្រង់ទាំងពីរនោះមានលក្ខណៈដូចគ្នា (ដូចជា ក្នុងភាសាខ្មែរ «កូត» និង «កាត់» ជាទម្រង់ពីរផ្សេងគ្នា តែទម្រង់ទាំងពីរនេះមានលក្ខណៈដូចគ្នាត្រង់ថា មានទម្រង់ «ពសព» ដូចគ្នា) បើសូរណាមួយក្នុងទម្រង់ទាំងពីរនោះស្ថិតក្នុងទីតាំងដូចគ្នា (ស្ថិតនៅដើមព្យាង្គឬដើមពាក្យដូចគ្នា ជាណ្នៃយ៉ូដូចគ្នា ស្ថិតនៅចុងព្យាង្គដូចគ្នា) ខុសពីសូរមួយទៀតដែលស្ថិតក្នុងទីតាំងដូចគ្នា ហើយសូរទាំងពីរនោះហៅថាគូអប្បបរិមាណ។ នេះជាឧទាហរណ៍ គូអប្បបរិមាណក្នុងពាក្យខ្មែរ។

គួរកត់សម្គាល់ដែលថា «សង» [sɒːŋ] និង «សុក» [sok] មិនមែនជាគូអប្បបរិមាណទេ ដោយសារតែក្នុងពាក្យទាំងនេះមានសូរពីរខុសគ្នាក្នុងពេលតែមួយ គឺសូរស្រៈ [ɒː] និង [o] ដែលជាណ្នៃយ៉ូ ក៏វាខុសគ្នាដែរ និងសូរព្យញ្ជនៈ [ŋ] និង [k] ដែលជាធាតុចុងព្យាង្គក៏ខុសគ្នា។ ដូចគ្នានេះដែរ ក្នុងពាក្យ «លង់» [lɔŋ] និង «ងល់» [ŋɔl] ក៏មិនមែនជាគូអប្បបរិមាណដែរ ដោយសារតែសូរ [l] ក្នុងពាក្យ [lɔŋ] កើតមាននៅដើមព្យាង្គ ឯ [l] ក្នុងពាក្យ [ŋɔl] កើតនៅចុងព្យាង្គ ចំណែកសូរ [ŋ] ក៏ដូចគ្នាដែរ។

សទ្ទតាវិទ្យា គឺជាការសិក្សាអំពីប្រព័ន្ធនៃសទ្ទតានៅក្នុងភាសា ហើយប្រព័ន្ធនៃសទ្ទតានេះ គឺបានមកពីបណ្ដុំនៃភាពប្រឈមគ្នានៃសទ្ទតាផ្សេងៗ ឬភាពប្រឈមគ្នារវាងសូរពីរក្នុងករណីដែលសូរទាំងពីរនោះស្ថិតនៅក្នុងបរិបទដូចគ្នា។ សទ្ទតាវិទ្យាវិភាគមុខងារនៃសូរនៅក្នុងភាសា។

ឧទាហរណ៍ទី១៖ ចាប [caːp] គឺ c-p និង ចាប់ [cap] គឺ c-p (បរិបទដូចគ្នា) ពាក្យទាំងពីរនេះ មានសទ្ទតាពីរគឺ /c/ និង /p/ ។

ឧទាហរណ៍ទី២៖ ដូច [dɔoc] តូច [tɔoc] នៅក្នុងពាក្យទាំងពីរនេះ មានសទ្ទតាពីរគឺ /d/ និង/t/។ ដូច្នេះ /d/ គឺជាព្យញ្ជនៈខ្យល់ស្ទះ ធ្មេញ ឃោសៈ។ /t/ គឺជាព្យញ្ជនៈខ្យល់ស្ទះ ធ្មេញ អឃោសៈ។

## ២.៥. សទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈក្នុងភាសាខ្មែរ

### ២.៥.១. សទ្ទតាព្យញ្ជនៈ

សទ្ទតាព្យញ្ជនៈដូចសទ្ទតាឯទៀតដែរ គឺមិនមែនជាវត្ថុជាតុធម្មជាតិទេ តែអ្នកភាសាវិទ្យាបានបង្កើតជាតុទាំងអស់នេះឡើងដោយផ្អែកទៅតាមទ្រឹស្ដីសទ្ទតាវិទ្យា។ តាមធម្មតា គេធ្វើការចាត់ថ្នាក់ព្យញ្ជនៈផ្សេងៗ នៅក្នុង

តារាងមួយដែលមានអ័ក្សពីរគឺ៖ អ័ក្សបន្ទាត់ផ្ដេក ជាអ័ក្សដែលគេបង្ហាញអំពីទីកន្លែងនៃការបន្លឺ។ រីឯអ័ក្សបញ្ឈរបង្ហាញអំពីរបៀបនៃការបន្លឺ។

| ទីបន្លឺ / របៀបបន្លឺ | បបូរមាត់ Bilabial | ធ្មេញគន្លាក់ក្រអូម Dental Alveolar | ក្រអូម Palatal | នៅងក្រអូម Velar | ចន្លោះខ្សែសំឡេង Glottal |
|---|---|---|---|---|---|
| ព្យញ្ជនៈខ្យល់ស្ទះ (Plosive) | p b | t d | c | k | ʔ |
| ព្យញ្ជនៈច្រមុះ (Nasal) | m | n | ɲ | ŋ | |
| ព្យញ្ជនៈញ័រ (Trill) | | r | | | |
| ព្យញ្ជនៈខ្យល់ត្រដុស (Fricative) | | s | | | h |
| ព្យញ្ជនៈខ្យល់ត្រដុសបើក (Approximant) | w | | j | | |
| ព្យញ្ជនៈខ្យល់ត្រដុសបើកខាង Lateral Approximant | | l | | | |

សរុបមកសទ្ទតាព្យញ្ជនៈមានចំនួន១៧ គឺ /p/, /b/, /t/, /d/, /c/, /k/, /m/, /n/, /ɲ/, /ŋ/, /s/, /h/, /r/, /l/, /w/, /j/ និង /ʔ/។

**ការកត់ត្រាសទ្ទតាព្យញ្ជនៈដោយអក្សរខ្មែរ**

(១) សទ្ទតា /p/ កត់ត្រាដោយសញ្ញា ប៉និងព ឧទាហរណ៍ ពីរ /piː/, ប៉ា /paː/, ពូ /puː/ ។

(២) សទ្ទតា /b/ កត់ត្រាដោយសញ្ញា បនិងប៊ ឧទាហរណ៍ បង /bɒːŋ/, សាប៊ូ /sabuː/។

(៣) សទ្ទតា /t/ កត់ត្រាដោយសញ្ញា តនិងទ ឧទាហរណ៍ តាម /taːm/, ទី /tiː/។

(៤) សទ្ទតា /d/ កត់ត្រាដោយសញ្ញា ដនិងឌ ឧទាហរណ៍ ដើរ /daɜ/, ឌុន /dun/។

(៥) សទ្ទតា /c/ កត់ត្រាដោយសញ្ញា ចនិងជ ឧទាហរណ៍ ចាន /caːn/, ជី /ciː/។

(៦) សទ្ទតា /k/ កត់ត្រាដោយសញ្ញា កនិងគ ឧទាហរណ៍ កាន /kaːn/, គូរ /kuː/។

(៧) សទ្ទតា /m/ កត់ត្រាដោយសញ្ញា មនិងម៉ ឧទាហរណ៍ មុត /mut/, ម៉ែ /maɛ/។

(៨) សទ្ទតា /n/ កត់ត្រាដោយសញ្ញា ននិងណ ឧទាហរណ៍ នាំ /noam/, ណា /naː/។

(៩) សទ្ទតា /ɲ/ កត់ត្រាដោយសញ្ញា ញនិងញ៉ ឧទាហរណ៍ ញី /ɲiː/, ញ៉ាំ /ɲam/។

(១០) សទ្ទតា /ŋ/ កត់ត្រាដោយសញ្ញា ងនិងង៉ ឧទាហរណ៍ ងរ /ŋɔː/, ង៉ាង /ŋaːŋ/។

(១១) សទ្ទតា /s/ កត់ត្រាដោយសញ្ញា សនិងស៊ ឧទាហរណ៍ សាប /saːp/, ស៊ី /siː/។

(១២) សទ្ទតា /h/ កត់ត្រាដោយសញ្ញា ហនិងហ៊ ឧទាហរណ៍ ហត់ /hɒt/, ហ៊ឹង /hiːŋ/។

(១៣) សទ្ទតា /r/ កត់ត្រាដោយសញ្ញា រនិងរ៉ ឧទាហរណ៍ រីក /riːc/, រ៉ា /raː/។

(១៤) សទ្ទតា /l/ កត់ត្រាដោយសញ្ញា លនិងឡ ឧទាហរណ៍ លីង /liːɲ/, ឡាន /laːn/។

(១៥) សទ្ទតា /w/ កត់ត្រាដោយសញ្ញា វនិងវ៉ ឧទាហរណ៍ វា /wiɜ/, វ៉ា /waː/។

(១៦) សទ្ទតា /j/ កត់ត្រាដោយសញ្ញា យនិងយ៉ ឧទាហរណ៍ យាយ /jiɜj/, យ៉ាប់ /jap/។

(១៧) សទ្ទតា /ʔ/ មិនអាចមានតម្លៃជាសទ្ទតាដើមព្យាង្គទី១ ក្នុងទម្រង់ «ពស» និង «ពសព» បានទេ តែវាមានតម្លៃជាសទ្ទតាដើមព្យាង្គទី២ ក្នុងទម្រង់ ព$_១$ព$_២$សព$_៣$ ឧទាហរណ៍ ស្អាត /sʔaːt/ (ក្នុងពាក្យនេះ /ʔ/ ជាព$_២$) និងព$_១$ព$_២$សព$_៣$ ឧទាហរណ៍ ផ្អាក /pʰʔaːʔ/ (ក្នុងពាក្យនេះ /ʔ/ ជាព$_២$និងជាព$_៣$ផង) និងមានតម្លៃជាសទ្ទតាចុងព្យាង្គក្នុងទម្រង់ព$_១$ព$_២$សព$_៣$ ឧទាហរណ៍ ក្រាក់ /kraʔ/ (ក្នុងពាក្យនេះ /ʔ/ ជាព$_៣$)។

**កំណត់សម្គាល់៖**

ក្នុងចំណោមអក្សរខ្មែរ សញ្ញាព្យញ្ជនៈមួយចំនួនកត់ត្រាដូចជា៖

(១) សញ្ញា ខ ឃ កត់ត្រាដោយសញ្ញា [kʰ] ឧទាហរណ៍ ខាង [kʰaːŋ],ឃើញ [kʰəːɲ]។

(២) សញ្ញា ឆ ឈ កត់ត្រាដោយសញ្ញា [cʰ] ឧទាហរណ៍ ឆាប [cʰaːp], ឈាន [cʰiən]។

(៣) សញ្ញា ឋ ឍ ថ ធ កត់ត្រាដោយសញ្ញា [tʰ] ឧទាហរណ៍ ឋាន [tʰaːn], ឍាល [tʰiəl], ថយ [tʰɒːj], ធុង [tʰuŋ]។

(៤) សញ្ញា ផ ភ កត់ត្រាដោយសញ្ញា [pʰ] ឧទាហរណ៍ ផើង [pʰaəŋ], ភរ [pʰɔː]។

**សេចក្តីបញ្ជាក់៖** សញ្ញា អ ទទួលស្រៈនិស្ស័យដូចសញ្ញាព្យញ្ជនៈឯទៀតដែរ ព្រមទាំងមានជើងផង គឺ ្អ (ដូចជើង ្ក, ជើង ្ខ ...ដែរ)។ បើយើងមើលនឹងភ្នែក វាមានលក្ខណៈដូចសញ្ញាព្យញ្ជនៈឯទៀតដែរ។ ប៉ុន្តែ បើយើងស្តាប់តាមត្រចៀកវិញ វាមានសូរដូចសូរស្រៈឬសទ្ទតាស្រៈ ឧទាហរណ៍ អ [ɒː], អា [aː]...។

### ២.៥.២. សទ្ទតាស្រៈ

-សទ្ទតាស្រៈទោលមានដូចជា អ /ɒː/, អ់ /ɒ/, អ៊/ɔː/, អ៊ំ /ɔ/, អា /aː/, អ់ា /a/, អិ /e/, អី /iː/, អ៊ិ /i/, អឹ /ɜ/, អឺ /œː/, អ៊ឹ /ə/, អ៊ឺ /ɨː/, អុ /o/, អ៊ុ /u/, អ៊ូ /uː/, អ៊ើ /əː/, អេ /eː/, អ៊េ /ɛː/, អោ /oː/។

-សទ្ទតាស្រៈផ្សំមានដូចជា អើ /aɜ/, អែ /aɛ/, អៅ /aɔ/, អ៊ា /អៀ /iɜ/, អ៊ា /ɛa/, អ៊ំរ /oa/, អួ /uɜ/, អូ /ɔo/, អឿ /ɨɜ/, អេ /ɛe/។

### ក. ការកត់ត្រាសទ្ទតាស្រៈទោល

(១) សទ្ទតា /ɒː/ (អ) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ឧទាហរណ៍ កក /kɒːʔ/, សក /sɒːʔ/។

(២) សទ្ទតា /ɒ/ (អ់) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ឧទាហរណ៍ បក់ /bɒʔ/, តក់ /tɒʔ/។

(៣) សទ្ទតា /ɔː/ (អ៊) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ឧទាហរណ៍ មង /mɔːŋ/, ទង /tɔːŋ/។

(៤) សទ្ទតា /ɔ/ (អ៊ំ) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ឧទាហរណ៍ ទង់ /tɔŋ/, លង់ /lɔŋ/។

(៥) សទ្ទតា /aː/ (អា) កត់ត្រាដោយសញ្ញាស្រៈ «ា» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ តា /taː/ , កា /kaː/។

(៦) សទ្ទតា /a/ (អ់ា) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ប៉ុន្តែក្នុងព្យាង្គឬក្នុងពាក្យ គេប្រើសញ្ញាស្រៈ «ា» ជាមួយព្យញ្ជនៈពួកអ ដោយដាក់សញ្ញាបន្តក់លើព្យញ្ជនៈចុងព្យាង្គ ឧទាហរណ៍ ចាក់ /caʔ/, បាក់ /baʔ/។

(៧) សទ្ទតា /e/ (អិ) កត់ត្រាដោយសញ្ញាស្រៈ «ិ» ប្រើជាមួយព្យញ្ជនៈពួកអ ឬដោយសញ្ញាស្រៈពេញតួ«ឥ» ឧទាហរណ៍ តិច /tec/, កិច្ច /kec/, ឥត /et/។

(៨) សទ្ទតា /iː/ (អី) កត់ត្រាដោយសញ្ញាស្រៈ «ី» ប្រើជាមួយព្យញ្ជនៈពួកអ៊ ឧទាហរណ៍ ទី /tiː, ស៊ី /siː។

(៩) សទ្ទតា /i/ (អ៊ិ) កត់ត្រាដោយសញ្ញាស្រៈ «ិ» ប្រើជាមួយព្យញ្ជនៈពួកអ៊ ឧទាហរណ៍ ពិសា /pisaː/, ពិសេស /pisɛh/។

(១០) សទ្ទតា /ɜ/ (អឹ) កត់ត្រាដោយសញ្ញាស្រៈ «ឹ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ ដឹក /dɜk/, សឹន /sɜn/។

(១១) សទ្ទតា /œː/ (អឺ) កត់ត្រាដោយសញ្ញាស្រៈ «ឺ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ កឺ /kœː/, ណឺ /nœː/។

(១២) សទ្ទតា /ə/ (អ៊ឹ) កត់ត្រាដោយសញ្ញាស្រៈ «ឹ» ប្រើជាមួយព្យញ្ជនៈពួកអ៊ ឧទាហរណ៍ ទឹក /tək/, ពិត /pət/។

(១៣) សទ្ទតា /ɨː/ (អឺ) កត់ត្រាដោយសញ្ញាស្រះ «ឺ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ ឭ /lɨː/, គឺ /kɨː/, យឺត /jɨːt/ ។

(១៤) សទ្ទតា /o/ (អុ)កត់ត្រាដោយសញ្ញាស្រះ «ុ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ សុខ /sok/, បុណ្យ /bon/ ។

(១៥) សទ្ទតា /u/ (អ៊ុ) កត់ត្រាដោយសញ្ញាស្រះ «ុ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ គុក /kuk/, ពុក /puk/ ។

(១៦) សទ្ទតា /uː/ (អ៊ូ) កត់ត្រាដោយសញ្ញាស្រះ «ូ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ ពូ /puː/, យូរ /juː/, ស៊ូ /suː/ ។

(១៧) សទ្ទតា /əː/ (អឺ) កត់ត្រាដោយសញ្ញាស្រះ «ើ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ លើ /ləː/, មើល /məːl/ ។

(១៨) សទ្ទតា /eː/ (អ៊េ) កត់ត្រាដោយសញ្ញាស្រះ «េ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ មេ /meː/, គេ /keː/ ។

(១៩) សទ្ទតា /ɛː/ (អ៊ែ) កត់ត្រាដោយសញ្ញាស្រះ «ែ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ គ្រែ /krɛː/ , មែន /mɛːn/ ។

(២០) សទ្ទតា /oː/ (អ៊ោ) កត់ត្រាដោយសញ្ញាស្រះ «ោ» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ ឧទាហរណ៍ គោ /koː/ , លោក /loːk/ ។

**ខ. ការកត់ត្រាសទ្ទតាស្រះផ្សំ**

(១) សទ្ទតា /aɜ/ (អើ) កត់ត្រាដោយសញ្ញាស្រះ «ើ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ ដើរ /daɜ/, កើត /kaɜt/ ។

(២) សទ្ទតា /aɛ/ (អែ) កត់ត្រាដោយសញ្ញាស្រះ «ែ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ តែ /taɛ/, សែន /saɛn/ ។

(៣) សទ្ទតា /aɔ/ (អោ) កត់ត្រាដោយសញ្ញាស្រះ «ោ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ តោ /taɔ/, បោក /baɔk/ ។

(៤) សទ្ទតា /iɜ/ (អ៊ា/អៀ) កត់ត្រាដោយសញ្ញាស្រះ «ា» ប្រើជាមួយព្យញ្ជនៈពួកអ៊ិ និង «ៀ» ប្រើជាមួយព្យញ្ជនៈពួកអ-អ៊ិ ឧទាហរណ៍ ទា /tɜ, មាន /miɜn/, លាត /liɜt/, ចៀន /ciɜn/, កៀន /kiɜn/, រៀន /riɜn/, ទៀង /tiɜŋ/ ។

(៥) សទ្ទតា /ɛa/ (អ៊ា) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ប៉ុន្តែក្នុងព្យាង្គឬពាក្យ គេប្រើសញ្ញាស្រះ «ា» ជាមួយព្យញ្ជនៈពួកអ៊ិ ដោយដាក់សញ្ញាបន្តក់ពីលើព្យញ្ជនៈចុងព្យាង្គ ឧទាហរណ៍ ទាក់ /tɛaʔ/, ពាក់ /pɛaʔ/, ជាក់ /cɛaʔ/ ។

(៦) សទ្ទតា /oa/ (អ៊័រ) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ប៉ុន្តែភាគច្រើន គេប្រើសំយោគសញ្ញាលើព្យញ្ជនៈពួកអ៊ិ ប្រកបនឹង រ, ឧទាហរណ៍ ជ័រ /coa/, ទំព័រ /tumpoa/ ជាដើម ហើយក្នុងពាក្យមួយចំនួន គេប្រើរបាទលើព្យញ្ជនៈ «ណ» ឧទាហរណ៍ ពណ៌ /poa/។

(៧) សទ្ទតា /uɜ/ (អួ) កត់ត្រាដោយសញ្ញាស្រះ «ួ» ប្រើជាមួយព្យញ្ជនៈពួកអផង និងពួកអ៊ិផង ឧទាហរណ៍ តួ /tuɜ/, គួរ /kuɜ/ ។

(៨) សទ្ទតា /ɔo/ (អូ) កត់ត្រាដោយសញ្ញាស្រះ «ូ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ ដូរ /dɔo/, កូរ /kɔo/។

(៩) សទ្ទតា /ɨɜ/ (អឿ) កត់ត្រាដោយសញ្ញាស្រៈ «ឿ» ប្រើជាមួយព្យញ្ជនៈពួកអផង និងពួកអ៊ផង ឧទាហរណ៍ តឿ /tɨɜ/, ជឿ /cɨɜ/ ។

(១០) សទ្ទតា /ɛe/ (អេ) កត់ត្រាដោយសញ្ញាស្រៈ «េ» ប្រើជាមួយព្យញ្ជនៈពួកអ ឧទាហរណ៍ ដេរ /dɛe/, កេរ /kɛe/ ។

**កំណត់សម្គាល់៖**

ក្នុងចំណោមអក្សរខ្មែរ សញ្ញាស្រៈមួយចំនួនកត់ត្រាសូរស្រៈល្បាយ(ស្រៈផ្សំ) នឹងព្យញ្ជនៈ រួមមាន៖

(១) សញ្ញា «ី» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ «ឦ», «ឰ» កត់សូរ [ɜ] + [j] > [ɜj] (អី) ឧទាហរណ៍ សី [sɜj], ដី [dɜj], ឦឡូវ [ɜjlɔw] ។

(២) សញ្ញា «ៃ» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ«ឰ» កត់សូរ [a] + [j] > [aj] (អៃ) ឧទាហរណ៍ ដៃ [daj], ឰដ៏ [ajdɒ] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [ə] + [j] > [əj] ឧទាហរណ៍ ព្រៃ /prəj/, ម្ភៃ /mpʰəj/ , នៃ /nəj/ ។

(៣) សញ្ញា «ៅ» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ «ឪ» កត់សូរ [a] + [w] > [aw] (អៅ) ឧទាហរណ៍ ចៅ [caw], ក្រឪ [krɒʔaw] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [ɔ] + [w] > [ɔw] ឧទាហរណ៍ នៅ [nɔw], ទៅ [tɔw]។

(៤) សញ្ញា «ុំ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [o] + [m] > [om] (អុំ) ឧទាហរណ៍ កុំ [kom] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [u] + [m] > [um] (អ៊ុំ) ឧទាហរណ៍ ទុំ [tum], ជុំ [cum]។

(៥) សញ្ញា «ំ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [ɒ] + [m] > [ɒm] (អំ) ឧទាហរណ៍ ដំ [dɒm] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [ɔ] + [m] > [ɔm] ឧទាហរណ៍ នំ [nɔm] ។

(៦) សញ្ញា «ាំ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [a] + [m] > [am] (អាំ) ឧទាហរណ៍ ចាំ [cam], កាំ [kam] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [oa] + [m] > [oam] ឧទាហរណ៍ នាំ [noam], ជាំ [coam], រាំ [roam] ។

(៧) សញ្ញា «ះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [a] + [h] > [ah] (អះ) ឧទាហរណ៍ ខ្លះ [kʰlah], ចាស់ [cah] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ ទះ /tɜəh/, ព្រះ /prɜəh/ ។

(៨) សញ្ញា «ុះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [o] + [h] > [oh] (អុះ) ឧទាហរណ៍ ចុះ [coh], ដុស [doh] និងប្រើជាមួយពួកអ៊ កត់សូរ [u] + [h] > [uh] ឧទាហរណ៍ ជ្រុះ [cruh] ។

(៩) សញ្ញា «េះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [ɛ] + [h] > [ɛh] (អេះ) ឧទាហរណ៍ ចេះ [cɛh], សេស [sɛh], បេះ [bɛh] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [i] + [h] > [ih] (អ៊ិះ) ឧទាហរណ៍ នេះ [nih], ជិះ [cih] ។

(១០) សញ្ញា «ោះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [ɒ] + [h] > [ɒh] (អោះ) ឧទាហរណ៍ កោះ [kɒh], បោះ [bɒh] និងប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [uɜ] + [h] > [uɜh] (អ៊ោះ) ឧទាហរណ៍ គោះ /kuɜh/, ពោះ /puɜh/ ។

(១១) សញ្ញា «ឱ» កត់សូរ [ow] ឧទាហរណ៍ ឱពុក [owpuk], ឱម៉ាល់ [owmal] ។

(១២) សញ្ញា «ឫ» កត់សូរ [rə] ឧទាហរណ៍ ឫកពា [rəkpiɜ] ។

(១៣) សញ្ញា «ឬ» កត់សូរ [rɨː] ឧទាហរណ៍ ឬ [rɨː] ។

(១៤) សញ្ញា «ឭ» កត់សូរ [lə] ឧទាហរណ៍ រឭក [rɔlək] ។

(១៥) សញ្ញា «ឮ» កត់សូរ [lɨː] ឧទាហរណ៍ ឮ [lɨː] (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ១៥-២០)។

## ២.៦. សទ្ទតាវិទ្យាស៊ុបប្រាសិចម៉ង់និងវិធានសទ្ទតាវិទ្យា

### ២.៦.១. សទ្ទតាវិទ្យាស៊ុបប្រាសិចម៉ង់

មុននឹងឈានដល់ការសិក្សាពីសទ្ទតាវិទ្យាស៊ុបប្រាសិចម៉ង់ យើងគួររំលឹកពីសិចម៉ង់សិន។ ក្នុងភាសាវិទ្យា សិចម៉ង់ជាឯកតាអប្បបរមា ដែលខណ្ឌដាច់ៗគ្នា និងដែលគេដឹងបាននិងស្តាប់ឮក្នុងចរន្តសម្តី។ ពាក្យនេះ គេច្រើនប្រើក្នុងមុខវិជ្ជាសូរវិទ្យានិងសទ្ទតាវិទ្យា។ សម្រាប់សូរវិទ្យា សិចម៉ង់សំដៅលើសទ្ទ (phone) ដែលយើងនិយមហៅថា «សូរ» និងសម្រាប់សទ្ទតាវិទ្យាសំដៅលើសទ្ទតា។ ក៏ប៉ុន្តែ សម្រាប់សិចម៉ង់ក៏សម្រាប់សំដៅលើឯកតាដទៃទៀតដែរ ដូចជាព្យាង្គ រូបតាជាដើម។

ខុសប្លែកពីសិចម៉ង់ ស៊ុបប្រាសិចម៉ង់ជាធាតុនៃសម្តីដែលរួមជាមួយសិចម៉ង់ ហើយមិនអាចផ្តាច់ខ្លួនពីសិចម៉ង់ក្នុងពេលបន្លឺសម្តី។ ធាតុនៃសម្តីទាំងនោះមាន ស្នៀង ការសង្កត់សូរ ការលើកដាក់សំឡេងជាដើម ដែលគេអាចឱ្យឈ្មោះមួយទៀតថា ប្រូសូឌី (prosody)។

ក្នុងភាសាវិទ្យា ជាទូទៅ ប្រូសូឌីមិនទាក់ទងអ្វីនឹងសិចម៉ង់សូរវិទ្យា(ព្យញ្ជនៈនិងស្រៈ)ដាច់ដោយឡែកពីគ្នានោះទេ តែទាក់ទងនឹងព្យាង្គ(ការសង្កត់សូរ) ទាក់ទងនឹងពាក្យ(ស្នៀង) ទាក់ទងនឹងល្បះ(ការលើកដាក់សំឡេង)ជាដើម។ ប្រសូឌីរួមចំណែកក្នុងមុខងារភាសាដែលជាមធ្យោបាយសម្រាប់ការទាក់ទងគ្នារបស់មនុស្សក្នុងសហគមន៍ភាសាណាមួយ ក្នុងនោះមានការលើកដាក់សំឡេងស្នៀង ការសង្កត់សូរឬស្ទួរសង្កត់ និងចង្វាក់ (កំណាព្យ)។ ប្រូសូឌីក៏ទាក់ទងនឹងសញ្ចេតនានិងចរិតរបស់អ្នកនិយាយ ដែលស្តែងចេញតាមទម្រង់សម្តីដូចជាការពោលពាក្យ (ទន់ភ្លន់ គំរោះគំរើយ) របៀបសួរ ការផ្តល់មតិឬអធិប្បាយជាដើម ដោយមិនបានគិតលើក្រឹត្យក្រមវេយ្យាករណ៍ឬវាក្យសព្ទឡើយ។

ការសិក្សាលើទិដ្ឋភាពប្រូសូឌី ជាធម្មតា គេសិក្សាលើវិធានពីរ គឺទី១៖ វិធានសណ្តាប់ (auditory measure) ដែលបង្ហាញអារម្មណ៍របស់អ្នកស្តាប់ បង្ហាញពីអ្វីដែលអ្នកស្តាប់មានក្នុងចិត្តគេផ្ទាល់។ ទី២៖ វិធានអាគូស្ទិកដែលទាក់ទងនឹងលក្ខណៈរូបសាស្ត្រនៃរលកសូរដែលស្ថិតក្រៅពីប្រធានវិស័យភាពរបស់គូសន្ទនា។ ដូច្នេះ ប្រសូឌីជាប់ទាក់ទងនឹងវត្ថុវិស័យភាព (អាគូស្ទិក) ផង និងជាប់ទាក់ទងនឹងប្រធានវិស័យភាព (សញ្ចេតនាអារម្មណ៍) របស់អ្នកនិយាយនិងអ្នកស្តាប់ផង។

ដោយផ្អែកលើវិធានទាំងពីរខាងលើ ការសិក្សាអំពីប្រូសូឌី គឺការចាប់យកនូវបម្រែបម្រួលសូរតាមរយៈវិធានសណ្តាប់ផងនិងតាមរយៈវិធានអាគូស្ទិកផង។ បម្រែបម្រួលសំខាន់ៗដែលគេចាប់បានក្នុងវិធានសណ្តាប់មាន៖

-កម្ពស់សំឡេង ប្រែប្រួលពីទាប់ទៅខ្ពស់ឬបញ្ច្រាសមកវិញ។

-ប្រវែងសូរ ប្រែប្រួលពីខ្លីទៅវែងឬបញ្ច្រាសមកវិញ។

-ល្បឺសូរ ប្រែប្រួលពីខ្សោយទៅខ្លាំងឬបញ្ច្រាសមកវិញ។

-គុណភាពនៃសូរ គឺផ្តោតលើបរិមាណសូរ។

ក្នុងវិធានអាគូស្ទិក គេឃើញមានបម្រែបម្រួលសំខាន់ៗដូចនេះ៖

-ប្រេកង់ មានខ្នាតជាហឺត្ស (Hz) ឬជាវដ្តក្នុង១វិនាទី។

-រយៈពេល មានរង្វាស់ជាវិនាទី។

-ប្រពលភាព (អាំងតង់ស៊ីតេឬកម្រិតនៃសម្ពាធសូរ) មានឯកតារង្វាស់ជាដេស៊ីបែល។

ការបូកផ្សំនៃវិធានទាំងពីរ (វិធានសណ្តាប់និងវិធានអាគូស្ទិក) ទើបក្នុងប្រូសូឌីមានធាតុសំខាន់ៗមួយចំនួនដូចជាការលើកដាក់សំឡេង (intonation) និងការសង្កត់សូរឬស្ទួរសង្កត់(stress)។

**ក. ការលើកដាក់សំឡេង**

ក្នុងភាសាវិទ្យា ការលើកដាក់សំឡេង គឺជាបម្រែបម្រួលសូរសម្ដី តែមិនបានញែកន័យពាក្យទេ នៅពេលដែលគេប្រើប្រាស់វាក្នុងតួនាទីសម្រាប់បង្ហាញពីអាកប្បកិរិយានិងសញ្ចេតនារបស់អ្នកនិយាយ នៅពេលដែលគេបង្ហាញពីភាពប្លែកគ្នារវាងប្រកាសនិងសំណួរ និងបង្ហាញភាពប្លែកគ្នារវាងប្រភេទសំណួរនីមួយៗ និងបង្ហាញពីចំណាប់អារម្មណ៍លើធាតុសំខាន់ៗ (ការប្រើពាក្យ ការប្រើសំឡេងក្នុងការនិយាយជាដើម) ដែលជាខ្លឹមសារនៃការនិយាយសាសងគ្នារវាងគូសន្ទនា។

ការចែកចំនួនមុខងារនៃការលើកដាក់សំឡេង មានអ្នកសូរវិទ្យាខ្លះចែកជា១០មុខងារ អ្នកសូរវិទ្យាខ្លះទៀតចែកជា៦មុខងារ។ យើងនឹងលើកមុខងារនៃការលើកដាក់សំឡេងមួយចំនួនយកមកធ្វើជាឧទាហរណ៍។

-មុខងារបង្ហាញអាកប្បកិរិយានិងសញ្ចេតនា (បម្រើបម្រាស់ការលើកដាក់សំឡេងក្នុងកំហឹង ភាពសប្បាយ ភាពរំភើប ភាពទុក្ខព្រួយជាដើម)។

-មុខងារវេយ្យាករណ៍ ជាមុខងារសម្រាប់សម្គាល់ទម្រង់វេយ្យាករណ៍ (ក្នុងបម្រើបម្រាស់ការលើកដាក់សំឡេងខុសគ្នា អាចឱ្យគេដឹងបានពីប្រភេទល្បះ ដូចជាគេអាចដឹងថា ល្បះមួយជាល្បះប្រកាសដោយសារតែមានការលើកដាក់សំឡងដោយឡែកមួយ គេអាចដឹងថា ល្បះមួយជាល្បះសំណួរដោយមានការលើកដាក់សំឡងមួយដោយឡែកទៀត)។

-មុខងារសង្កត់ មុខងារនេះបង្ហាញពីការផ្ដល់ព័ត៌មានរបស់អ្នកនិយាយថាតើព័ត៌មាននោះជាព័ត៌មានថ្មីឬជាព័ត៌មានដែលគេធ្លាប់ដឹងមកហើយ ដូចជា «មកដល់ហើយ! មកដល់ហើយ!» (ព័ត៌មានថ្មី) «រឿងហ្នឹងឬ? ខ្ញុំបានដឹងជាយូរមកហើយ!»។

**ខ. ការសង្កត់សូរ**

ក្នុងភាសាវិទ្យា ការសង្កត់សូរជាការរំលេចសូរព្យាង្គណាមួយក្នុងពាក្យឱ្យប្លែកជាងសូរព្យាង្គ ដែលនៅជាប់ក្បែរព្យាង្គនោះ។ ការសង្កត់សូរទាក់ទងភាគច្រើនតែនឹងព្យាង្គ។ បំប្លែកសូរក្នុងព្យាង្គដែលទទួលការសង្កត់សូរ កើតឡើងដោយបំប្លែកនៃល្បឿសូរ ប្រវែងសូរជាដើម។ អ្នកភាសាវិទ្យាមួយចំនួនឱ្យឈ្មោះព្យាង្គដែលទទួលការសង្កត់សូរថាជាព្យាង្គខ្លាំង ចំណែកព្យាង្គដែលមិនទទួលការសង្កត់សូរជាព្យាង្គខ្សោយ។

តាមក្របខណ្ឌសូរវិទ្យា ការសង្កត់សូរលេចចេញជារូបរាងផ្ទាល់មកតាមច្រើនរបៀបផ្សេងៗគ្នានៅក្នុងចរន្តសម្ដី ហើយរបៀបទាំងនេះអាស្រ័យនឹងវិសាលភាពនៃភាសានិយាយនីមួយៗ។ ព្យាង្គដែលទទួលការសង្កត់សូរភាគច្រើន និងជារឿយៗ មានសូរខ្លាំងជាងព្យាង្គ ដែលមិនទទួលការសង្កត់សូរ និងអាចមានកម្ពស់សូរទាបឬខ្ពស់។ ជួនកាល ក្នុងការបន្លឺ ព្យាង្គដែលទទួលការសង្កត់សូរបន្លឺវែងជាងព្យាង្គដែលមិនទទួលការសង្កត់សូរ។ ក្នុងពេលខ្លះព្យាង្គទទួលការសង្កត់សូរខុសប្លែកពីព្យាង្គមិនទទួលការសង្កត់ទៅតាមសញ្ញាអាគូស្ទិកផងដែរ ដូចជាការសង្កត់សូរថាមវន្ត (dynamic stress) អាំងតង់ស៊ីតេនៃព្យាង្គទទួលការសង្កត់សូរខ្លាំងជាងអាំងតង់ស៊ីតេនៃព្យាង្គមិនទទួលការសង្កត់សូរ។

គួរកត់សម្គាល់ដែរថា កាលណាគេនិយាយពីការសង្កត់សូរ គេនិយាយតែលើពាក្យដែលមានពីរព្យាង្គឡើងទៅ។ គេមិនដែលនិយាយពីការសង្កត់សូរលើពាក្យមួយព្យាង្គឡើយ ដោយសារតែពាក្យមួយព្យាង្គជានិច្ចកាលជាព្យាង្គខ្លាំង ដោយសារតែសូរស្រៈដែលជាធាតុសំខាន់សម្រាប់ទ្រទ្រង់ព្យាង្គឬជាធាតុចាំបាច់ក្នុងការបង្កើតព្យាង្គ នៅរក្សាគុណភាពនិងបរិមាណសូររបស់វាដដែល។

ការសង្កត់សូរដែលមាននៅក្នុងពាក្យ (ពាក្យលើសពីពីរព្យាង្គ) ឡើងទៅ គេហៅការសង្កត់សូរបែបនោះថាជាការសង្កត់សូរលើពាក្យ (word stress)។ ការសង្កត់សូរក្នុងភាសាមួយចំនួនស្ថិតនៅតែលើព្យាង្គណាមួយជាក់លាក់ គឺថាបើស្ថិតនៅលើព្យាង្គណាមួយនៃពាក្យពហុព្យាង្គ (ពហុព្យាង្គទីនេះរាប់ទាំងពាក្យ២ព្យាង្គដែរ) ជានិច្ចកាល

ការសង្កត់សូរមិនផ្លាស់ប្តូរឡើយ។ ការសង្កត់សូរពេលនេះ ហៅថាការសង្កត់សូរអចល័ត (fixed stress) ដូចជាក្នុងភាសាខ្មែរ ការសង្កត់សូរជាប្រភេទនៃការសង្កត់សូរអចល័ត គឺការសង្កត់សូរមានជានិច្ចកាលនៅតែលើព្យាង្គទី២នៃពាក្យទោល២ព្យាង្គនិងក្នុងពាក្យកម្លាយ២ព្យាង្គ។ ភាសាឆែក ភាសាហ្វាំងឡង់ ភាសាអ៊ីស្លង់ ភាសាហុងគ្រី ជាដើម ជានិច្ចកាលការសង្កត់សូរធ្លាក់លើព្យាង្គទី១។ ភាសាខ្លះទៀត ដូចជាភាសាប៉ូឡូញជាដើម ការសង្កត់សូរធ្លាក់តែលើព្យាង្គដែលស្ថិតនៅបន្តបន្ទាប់ពីព្យាង្គទី១។

ក្នុងភាសាមួយចំនួនទៀត ការសង្កត់សូរមិនស្ថិតតែលើព្យាង្គណាមួយជាក់លាក់ទេ គឺចល័តទៅតាមតម្រូវការនៃវិធានវេយ្យាករណ៍ឬវិធានវចនសព្ទ (grammatical rules or lexical rules) នៃភាសានោះ។ ការសង្កត់សូរប្រភេទនេះ ហៅថាការសង្កត់សូរចល័តឬការសង្កត់សូរប្រែប្រួល (variable stress)។ ជួនកាល គេឃើញថាក្នុងពាក្យពហុព្យាង្គ ជាពិសេសពីបីព្យាង្គឡើងទៅ មានការសង្កត់សូរគោល (primary stress) និងការសង្កត់សូរបន្ទាប់បន្សំ (secondary stress) ដូចជាក្នុងភាសាអង់គ្លេស ភាសាខ្មែរ (សម្រាប់អ្វីដែលហៅថាពាក្យ៣ព្យាង្គ ៤ព្យាង្គ ដូចជា កន្ទាទូក គ្រលេងគ្រលោង ជាដើម)។ ភាសាខ្លះគ្មានការបែងចែកការសង្កត់សូរជាការសង្កត់សូរគោល ជាការសង្កត់សូរបន្ទាប់បន្សំនោះទេ ទោះជាព្យាង្គមានប្រវែងវែងក៏ដោយ ដូចជាភាសារុស្ស៊ីជាដើម។

នៅក្នុងភាសាដែលមានការសង្កត់សូរអចល័តឬមិនប្រែប្រួល និងចល័តឬប្រែប្រួល ការសង្កត់សូរអាចជាការសង្កត់សូរសទ្ទតា (phonemic stress) ព្រោះការសង្កត់សូរបែបនេះអាចញែកន័យពាក្យពីរដែលបន្លឺសូរដូចគ្នាបាន។ ឧទាហរណ៍ពាក្យ *insight* (ប្រាជ្ញាវាងវៃ) និង *incite* (ញុះញង់) ក្នុងភាសាអង់គ្លេស គេអាចដឹងបានថាពាក្យទាំងពីរខុសគ្នា ដោយសារការអាន គេដាក់ការសង្កត់សូរខុសគ្នា។ ក្នុងពាក្យ *insight* ការសង្កត់សូរធ្លាក់លើព្យាង្គទី១ [ˈɪnsaɪt] ឯ *incite* ការសង្កត់សូរធ្លាក់លើព្យាង្គទី២ [ɪnˈsaɪt] ។

ក្នុងភាសាមួយចំនួនទៀត ក្នុងនោះមានភាសាអង់គ្លេសជាដើម ការសង្កត់សូរអាចញែកន័យរបស់អ្វីដែលហៅថាពាក្យបន្សំបានដែរ ដូចជា *paper bag* បើការសង្កត់សូរធ្លាក់លើ bag នោះមានន័យថា «ស្បោងធ្វើពីក្រដាស» បើការសង្កត់សូរធ្លាក់លើព្យាង្គទី១ នៃពាក្យ *paper* នោះមានន័យថា «ស្បោងសម្រាប់ដាក់កាសែត»។

ក្នុងភាសាខ្មែរ យើងឃើញថា ក្នុងករណីមួយចំនួន ការសង្កត់សូរអាចញែកពាក្យកម្លាយពីពាក្យបន្សំ។ ឧទាហរណ៍ «ទទឹក» បើការសង្កត់សូរធ្លាក់លើ «ទឹក» ពាក្យនេះជាពាក្យកម្លាយដែល «ទ» ជាផ្នត់ និង «ទឹក» ជាពាក្យឫស តែបើការសង្កត់សូរធ្លាក់លើ «ទ» និងធ្លាក់លើ «ទឹក» ផងនោះ វាជាពាក្យបន្សំ មានន័យថា «ទសម្រាប់បង្ហូរឬត្រងទឹក»។

**គ. ស្នៀង**

ក្នុងភាសាមួយចំនួន គេប្រើប្រាស់ស្នៀង (tone) ដើម្បីធ្វើឱ្យមានបម្រែបម្រួលកម្ពស់សូរក្នុងគោលបំណងញែកវចនន័យនិងន័យវេយ្យាករណ៍របស់ពាក្យ ជាពិសេស គឺពាក្យឯកព្យាង្គ។ ឧទាហរណ៍ ពាក្យ ma ក្នុងភាសាចិនស្តង់ដារ មាន៤ស្នៀង គឺ mā (ម្តាយ) má (ដើមក្រចៅ) mǎ (សេះ) mà (ស្រែក) ដែលឱ្យន័យពាក្យនេះ ភាសាណាដែលប្រើប្រាស់ស្នៀងក្នុងគោលបំណងខាងលើហៅថាភាសាស្នៀង (tonal language)។ ប្លែកៗពីគ្នាទៅតាមកម្ពស់សូរខ្ពស់ទាបឬកម្ពស់សូរថ្នាក់កណ្តាលនៃព្យាង្គ។ គេរកឃើញភាសាស្នៀងក្នុងតំបន់មួយចំនួននៃទ្វីបអាហ្វ្រិក អាស៊ី អាមេរិកកណ្តាល។ នៅជិតខាងភាសាខ្មែរ ភាសាស្នៀងមានភាសាវៀតណាម ភាសាថៃ ភាសាឡាវ ភាសាចិន ភាសាភូមាជាដើម។

## ២.៦.២. វិធានសទ្ទតាវិទ្យា

វិធានសទ្ទតាវិទ្យា គឺជាការបង្ហាញពីដំណើរការបម្រែបម្រួលសូរក្នុងក្របខណ្ឌសទ្ទតាវិទ្យា និងរូប-សទ្ទតាវិទ្យា (morphophonology)។

វិធានសទ្ទតាវិទ្យា ជាទូទៅ ត្រូវបានក្រុមសទ្ទតាវិទ្យាបំប្លែង (generative phonology) ដើម្បីកត់ត្រានូវទំនួលសូរដែលគេចាប់បានពីប្រតិបត្តិការរបស់ខួរក្បាលមនុស្ស និងទំនួលសូរភាសាណាមួយ ដែលខួរក្បាលរបស់មនុស្សស្តុកទុក។ ការទទួលសូរ សំដៅដល់ការទទួលនូវតំណាងសូរអរូបីដែលស្តុកទុកក្នុងខួរក្បាលអ្នកនិយាយបញ្ចេញសូរនោះមកក្រៅតាមរយៈសម្ដីរបស់អ្នកនិយាយ។ សូរសម្ដីដែលអ្នកនិយាយបញ្ចេញមកក្រៅនេះ គេហៅថាតំណាងរូបី បានន័យថា វិធានសទ្ទតាវិទ្យាពណ៌នាពីរបៀបដែលអ្នកនិយាយទាញយកតំណាងអរូបីដែលស្តុកទុកក្នុងខួរក្បាលរបស់ខ្លួនឬថាកប់ទុកក្នុងខួរក្បាលរបស់អ្នកនិយាយ មកបន្លឺជាសូររូបីក្នុងពេលដែលគេនិយាយ។ បើកាលណាសូររូបីមានទម្រង់ច្រើន គេហៅថាកាឡាសូរ។ នេះជាឧទាហរណ៍ពីវិធានសទ្ទតាវិទ្យាភាសាអង់គ្លេស រូបតាពហុវចនៈ [-s] ក្នុងភាសាអង់គ្លេសអាចបន្លឺជាសូរ [s] ក្នុងពាក្យ «cats» អាចបន្លឺជាសូរ [z] ក្នុងពាក្យ«cabs» ឬជាសូរ [ɘz] ក្នុងពាក្យ «buses» ជាដើម។ បើតាមពិតទៅ ក្នុងសតិរបស់អ្នកនិយាយដឹងថាមានតែ [-s] តែមួយទេ តែដល់ពេលបញ្ចេញមកក្រៅផ្សំនឹងមជ្ឈដ្ឋានជុំវិញផង ទើបក្នុងការនិយាយជាក់ស្ដែង លេចចេញជា [z] ផងឬជា [ɘz] ផង។

## ២.៧. ព្យាង្គ

ព្យាង្គជាឯកតាសម្រាប់កាត់សូរសម្ដីជាសង្កាត់ៗ (sequence)។ ជាទូទៅ ព្យាង្គកើតដោយណ្វៃយ៉ូ (ស្នូលព្យាង្គ) ភាគច្រើននិងញឹកញាប់ជាស្រៈ ដោយសទ្ទតាដើមព្យាង្គនិងសទ្ទតាចុងព្យាង្គដែលតាមធម្មតាជាព្យញ្ជនៈ។

ជាទូទៅ គេសង្កេតឃើញថាព្យាង្គទាក់ទងភាគច្រើននឹងសទ្ទតាវិទ្យា ព្រោះវាមានឥទ្ធិពលលើចង្វាក់ភាសាដូចជាប្រូសូឌី កំណាព្យ ការសង្កត់សូរ ស្នៀងជាដើម។

### ២.៧.១. និយមន័យ

ឧទាហរណ៍៖ យើងខិតខំធ្វើការដើម្បីប្រទេសជាតិ។
ចូរថែទាំសួនច្បារ។

ឧទាហរណ៍ខាងលើបញ្ជាក់ថា សូរ «យើង» កើតមកពីព្យញ្ជនៈ [យ] ផ្សំនឹងស្រៈ [អើ] ហើយប្រកបនឹងព្យញ្ជនៈ [ង]។ សូរ «ថែ» កើតមកពីព្យញ្ជនៈ [ថ] ផ្សំនឹងស្រៈ [ែ]។ នេះគឺថា [យើង] < [យ] + [អើ] + [ង], [ថែ] < [ថ] + [ែ]។

សូរដែលបន្លឺឡើងដូចជា «យើង ថែ» ហៅថាព្យាង្គ។

តាមឧទាហរណ៍ខាងលើ យើងអាចឱ្យនិយមន័យព្យាង្គដូចតទៅ៖

ព្យាង្គ គឺជាសូររួមនៃសទ្ទដែលបន្លឺឡើងតែមួយបន្ទាយសំឡេង។

ព្យាង្គ គឺជាសូរបន្លឺឡើងក្នុងមួយបន្ទាយសំឡេងឯករាជ្យ ដែលកើតឡើងដោយសំណុំសទ្ទតា (ព្យញ្ជនៈនិងស្រៈ) ហើយជាទម្រង់គ្រឹះនៃខ្សែសម្ដី (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ២១)។

ព្យាង្គ គឺជាក្រុមមួយនៃសូរដែលនៅជុំវិញសូរឃោសៈ។ ដូច្នេះ ណ្វៃយ៉ូឬស្នូលព្យាង្គ (nucleus) នៃព្យាង្គទាក់ទងនឹងសំឡេង។ មានភាសាផ្សេងៗដែលសូរឃោសៈជាស្រៈ ឬព្យញ្ជនៈ ឯភាសាខ្មែរវិញ ណ្វៃយ៉ូនៃព្យាង្គ គឺជាស្រៈជានិច្ច។ នៅក្នុងការពណ៌នាពីភាសា ទ្រឹស្ដីនៃព្យាង្គមានគោលបំណងមួយ គឺបង្ហាញក្បួនផ្សេងៗ ដែលអនុញ្ញាតឱ្យអ្នកនិយាយបង្កើតព្យាង្គត្រឹមត្រូវផ្សេងៗនៅក្នុងភាសាមួយបាន (ហ្សង់ មីសែល ហ្វីលីពី និង ហៀប ច័ន្ទវិចិត្រ, ២០០៩)។

ពាក្យណាដែលមានព្យាង្គតែមួយ បានន័យថាមានណ្វៃយ៉ូតែមួយ គេហៅពាក្យមួយព្យាង្គ។ ដូចគ្នាដែរ មានពាក្យពីរព្យាង្គ បីព្យាង្គ ច្រើនព្យាង្គ (ពហុព្យាង្គ) ជាដើម។

### ២.៧.២. ធាតុរបស់ព្យាង្គ

តាមទ្រឹស្ដីនៃទម្រង់ព្យាង្គ ជាទូទៅទម្រង់ព្យាង្គ (ɕ) មានសិចម៉ង់បី គឺ ធាតុដើមព្យាង្គ ណ្វៃយ៉ូ និងធាតុចុងព្យាង្គ។




**ក. ធាតុដើមព្យាង្គ**

ធាតុដើមព្យាង្គ ភាគច្រើនជាសូរព្យញ្ជនៈឬកន្សោមព្យញ្ជនៈ (consonant cluster) នៅខាងដើមព្យាង្គ គឺកើតមានឡើងនៅមុខណ្វៃយ៉ូ។ ព្យាង្គភាគច្រើនមានធាតុដើមព្យាង្គតែមួយ។ ព្យាង្គណាដែលគ្មានធាតុដើមព្យាង្គហៅថាព្យាង្គដែលមានធាតុដើមព្យាង្គសូន្យឬធាតុដើមព្យាង្គទទេ។

ក្នុងភាសាមួយចំនួន កម្រិតឱ្យធាតុដើមព្យាង្គមានតែសូរព្យញ្ជនៈទោលប៉ុណ្ណោះ ក៏ប៉ុន្តែ ភាសាមួយចំនួនទៀតអនុញ្ញាតឱ្យធាតុដើមព្យាង្គមានសូរព្យញ្ជនៈច្រើន។ ចំណែកភាសាខ្លះទៀតដូចភាសាខ្មែរជាដើម កម្រិតធាតុដើមព្យាង្គឱ្យមានសូរព្យញ្ជនៈមិនលើសពីពីរ វៀរលែងពាក្យកម្ចីមួយចំនួនដូចជាស្ត្រី ស្ត្រេស (stress) ជាដើម។

**ខ. ណ្វៃយ៉ូ**

តាមធម្មតា ណ្វៃយ៉ូជាសូរស្រៈនៅកណ្ដាលព្យាង្គ។ ជាទូទៅ ព្យាង្គនីមួយៗទាមទារដាច់ខាតថាត្រូវតែមានណ្វៃយ៉ូ។ ស្រៈដែលជាណ្វៃយ៉ូព្យាង្គអាចជាស្រៈសូរទោល (monophthong) ស្រៈទ្វេសូរ (diphthong) ឬត្រីសូរ (triphthong)។

**គ. ធាតុចុងព្យាង្គ**

ធាតុចុងព្យាង្គ ភាគច្រើនជាសូរព្យញ្ជនៈដែលនៅជាប់បន្ទាប់ណ្វៃយ៉ូ។ ក្នុងទម្រង់ព្យាង្គ ខ្នែងដែលស្ថិតនៅខាងស្ដាំធាតុដើមព្យាង្គហៅថាចុងចួនព្យាង្គ (rhyme)។ ចុងចួនព្យាង្គមានណ្វៃយ៉ូនិងធាតុចុងព្យាង្គ។

ចុងចួនព្យាង្គ គឺជាសូររួមរវាងណ្វៃយ៉ូនិងធាតុចុងព្យាង្គ ដែលមានទម្រង់ [សព] (ក្នុងនោះ [ស] ជាស្រៈ [ព] ជាព្យញ្ជនៈ)។ សូររួមណ្វៃយ៉ូនិងធាតុចុងព្យាង្គនេះ ប្រសិនបើមាននៅក្នុងពាក្យណាមួយ អាចចួននឹងសូររួមនៃធាតុទាំងពីរនេះក្នុងពាក្យដទៃទៀត។ ក្នុងកំណាព្យ គេប្រទះឃើញចុងចួនព្យាង្គ ដូចជា [at] ក្នុងពាក្យ «កាត់» ចួននឹង [at] ក្នុងពាក្យ «បាត់» ក្នុងពាក្យ «ក្ដាត់» ក្នុងពាក្យ «សត្វ» ជាដើម។

**២.៧.៣. ធាតុរបស់ព្យាង្គខ្មែរ**

ក្នុងព្យាង្គខ្មែរ គេឃើញមានធាតុបីសំខាន់ គឺជាតុដើមព្យាង្គ ណ្វៃយ៉ូ និងធាតុចុងព្យាង្គ។ ខុសប្លែកពីភាសាមួយចំនួនដែលធាតុដើមព្យាង្គអាចជាព្យញ្ជនៈនិងអាចជាព្យញ្ជនៈកន្លះ ធាតុដើមព្យាង្គនៃព្យាង្គខ្មែរមានតែព្យញ្ជនៈប៉ុណ្ណោះ។ ចំពោះកន្សោមព្យញ្ជនៈដើមព្យាង្គ (consonant cluster) មិនលើសពីពីរសូរឡើយ វៀរលែងតែក្នុងពាក្យកម្ចីមួយចំនួនដែលមានកន្សោមព្យញ្ជនៈដល់ទៅបីសូរ ដូចជា «ស្ត្រី» [strej] «ស្ត្រេស្ត» [streh] «ស្ត្រូក» [strɔok] ជាដើម ដែលប្លែកពីភាសាមួយចំនួនដែលមានកន្សោមព្យញ្ជនៈដើមព្យាង្គលើសពីពីរសូរ ដូចជា street [stri:t] (ផ្លូវ), strong [strɒ:ŋ] (ខ្លាំង) ក្នុងភាសាអង់គ្លេស។ ចំពោះណ្វៃយ៉ូវិញ ព្យាង្គខ្មែរមានណ្វៃយ៉ូជាស្រៈប៉ុណ្ណោះ (ភាសាមួយចំនួនអាចមានណ្វៃយ៉ូជាស្រៈផង អាចជាស្រៈកន្លះផង អាចជាសូរលំនាំស្រៈ (shwa) ផង ដូចជាសូរ [ə] ជាដើម។ ធាតុចុងព្យាង្គក្នុងព្យាង្គខ្មែរមានតែសូរព្យញ្ជនៈ ហើយមានតែមួយសូរព្យញ្ជនៈទៀត ដែលខុសពីព្យាង្គក្នុងភាសាមួយចំនួនដែលធាតុចុងព្យាង្គអាចជាព្យញ្ជនៈផង អាចជាព្យញ្ជនៈកន្លះផង ហើយអាចមានព្យញ្ជនៈលើសពីមួយសូរ។

## ២.៧.៤. ទម្រង់ព្យាង្គ

ព្យាង្គខ្មែរចែកជាទម្រង់ដូចខាងក្រោម៖

-ទម្រង់បីសទ្ទតាជាទម្រង់ដែលមានផ្នែកដើមព្យាង្គ ណ្វៃយ៉ូ និងផ្នែកចុងព្យាង្គ តាងដោយ «ពសព» ក្នុងនេះ«ព» ជាព្យញ្ជនៈ (ផ្នែកដើមព្យាង្គ) «ស» ជាស្រៈ (ណ្វៃយ៉ូ) «ព» ជាព្យញ្ជនៈ (ផ្នែកចុងព្យាង្គ) ដូចជា [kap] «កាប់» ក្នុងនោះ [k] ជា «ព» [a] ជា«ស» និង [p] ជា «ព» ។

-ទម្រង់ពីរសទ្ទតាដែលតាងដោយ «ពស» និង «សព» ក្នុងនេះ «ព» ជាព្យញ្ជនៈ (ផ្នែកដើមព្យាង្គឬផ្នែកចុងព្យាង្គ) «ស» ជាណ្វៃយ៉ូ ដូចជាក្នុងទម្រង់ «ពស» [ka:] «កា» ក្នុងនោះ [k] ជា «ព» និង [a:] ជា «ស» និងក្នុងទម្រង់ «សព» [a:n] «អាន» ក្នុងនោះ [a:] ជា «ស» និង [n] ជា «ព»។

គេឃើញមានទម្រង់ «ពពសព» ដែលជាខ្នែងនៃទម្រង់ «ពសព» ដូចជា [kʰba:l] «ក្បាល» និងទម្រង់ «ពពស» ដែលជាខ្នែងនៃទម្រង់ «ពស» ដូចជា [pʰdɔo] «ប្ដូរ» ។

-ទម្រង់មួយសទ្ទតា «ស» ដូចជា [ɔo] «អូរ» , [a:] «អារ» , [ɒ:] «អរ»...(ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ២២)។

សរុបមកយើងអាចចែកព្យាង្គក្នុងភាសាខ្មែរជាទម្រង់៤ គឺទម្រង់ [ពស] ដែលបែកចេញជា [ពពស] ទម្រង់ [ពសព] ដែលបែកចេញជា [ពពសព] ទម្រង់ [ស] និងទម្រង់ [សព]។

ទម្រង់ពីរចុងក្រោយ (ទម្រង់ [ស] និង [សព]) មិនទាន់មានការទទួលស្គាល់ភាគច្រើនទេ ដោយសារអ្នកសិក្សាស្រាវជ្រាវទាំងនោះ ភាគច្រើនចាត់ទុកតួ«អ»ជាព្យញ្ជនៈ ដោយយោងតាមទម្លាប់រាប់ថាព្យញ្ជនៈខ្មែរមាន ៣៣តួ គឺ កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម យរលវសហឡអ នេះម្យ៉ាង។ ម្យ៉ាងទៀត គេឃើញថា «អ» មានជើងដូចព្យញ្ជនៈដទៃទៀតដែរ ហើយជើង «អ» ដែលមានរាងជា «្អ» មានតួនាទី ផ្ដាច់សូរស្រៈពីសូរព្យញ្ជនៈដូចជើងព្យញ្ជនៈឯទៀតដែរ ដូច «ក្អាត់» ជាដើម ជើង «អ» ផ្ដាច់ស្រៈ [a] ចេញពី [k] ដូចជាក្នុងពាក្យ «ក្ដាត់» ដែលជើង «ដ» ផ្ដាច់ [a] ចេញពី [k] កុំឱ្យអានថា «កាត់» (នេះយើងនិយាយតែពីសំណេរទេ ថ្វីត្បិតតែមានទំនាក់ទំនងនឹងសូរក៏ដោយ។ បើនិយាយពីសូរសុទ្ធសាធនោះ គេមិននិយាយពីជើងអក្សរទេ)។ ការយល់បែបនេះទើបអ្នកសិក្សា ស្រាវជ្រាវទាំងនោះចាត់ទុកថាព្យាង្គខ្មែរមានតែទម្រង់ [ពស] [ពពស] [ពសព] និង[ពពសព]។ ដូច្នេះ «អា» ក៏ គេចាត់ទុកថាជាទម្រង់ [ពស] ដែរ។

ក៏ដូចជាព្យាង្គក្នុងភាសាទូទៅ ក្នុងភាសាខ្មែរក៏មានបន្សំជាតុក្នុងព្យាង្គដែរ គ្រាន់តែការផ្សំឬការទាក់ទងគ្នាជាតុក្នុងព្យាង្គមិនកម្រិតខុសៗគ្នាពីភាសាមួយទៅភាសាមួយប៉ុណ្ណោះ។ នៅក្នុងភាសាខ្មែរ អ្នកដែលលើកពីបន្សំឬទំនាក់ទំនងជាតុក្នុងព្យាង្គ គឺលោក យូរី ហ្គោរហ្គោញីយ៉េវ និងលោក ឃួន សុខម្ភូ។ ក៏ប៉ុន្តែ ការលើកឡើងរបស់អ្នកសិក្សាស្រាវជ្រាវទាំងពីររូបនេះ ហាក់ដូចជាមិនទាន់ចែកដាច់ស្រឡះពីសូរវិទ្យានៅឡើយ (លោក ឃួន សុខម្ភូ)។ ចំណែកលោក ហ្គោរហ្គោញីយ៉េវ លើកយកបន្សំនិងទំនាក់ទំនងជាតុក្នុងព្យាង្គដោយភ្ជាប់ច្រើននឹងសទ្ទតាវិទ្យាដែរ តែយើងមើលឃើញថា លោកហាក់ដូចជាមានការច្របូកច្របល់ជាមួយអក្សរច្រើន ជាពិសេសក្នុងចំណុចបន្សំឬចំណុចទំនាក់ទំនងណ្វៃយ៉ូនិងជាតុចុងព្យាង្គ។

នេះជាការលើកពីបន្សំឬទំនាក់ទំនងជាតុក្នុងព្យាង្គក្នុងភាសាខ្មែររបស់អ្នករៀបរៀងអត្ថបទនេះ។ និយាយដល់បន្សំជាតុក្នុងព្យាង្គក្នុងភាសាខ្មែរ គេផ្ដោតជាសំខាន់លើបន្សំឬទំនាក់ទំនងជាតុដើមព្យាង្គ និងជាតុដើមព្យាង្គ (ដែលសម្រាប់ភាសាខ្មែរ ជាព្យញ្ជនៈ) និងបន្សំឬទំនាក់ទំនងណ្វៃយ៉ូ (ដែលសម្រាប់ភាសាខ្មែរជាស្រៈ) និងជាតុចុងព្យាង្គ (ដែលក្នុងភាសាខ្មែរជាព្យញ្ជនៈ) ព្រោះថាបន្សំជាតុទាំងនេះក្នុងព្យាង្គខ្មែរមានការកម្រិតខ្លាំង មិនមែនចេះតែ

ផ្សំតាមតែបាននោះទេ។ ចំពោះបន្សំឬទំនាក់ទំនងជាតុដើមព្យាង្គនិងណ្វៃយ៉ូមានភាពទូលំទូលាយជាង (មិនសូវមានកម្រិត) ម្ល៉ោះហើយ យើងក៏មិនចាំបាច់លើកយកមកបង្ហាញដែរ។

**ក. ទម្រង់ «ពស ឬ ពសព»**

ឧទាហរណ៍៖ តា ដីក ដី ដាំ ដូង ថា ទឹក កើត។ ព្យញ្ជនៈ «ត ដ ដ ថ ទ ក» ជាព្យញ្ជនៈដើមព្យាង្គ។




នៅក្នុងករណីដែលមានណ្វៃយ៉ូវែង (ស្រៈវែង ឬស្រៈផ្សំវែង) ផ្នែកចុងមិនចាំបាច់មានរហូតទេ:




ប៉ុន្តែពេលដែលមានណ្វៃយ៉ូខ្លី ផ្នែកចុងចាំបាច់ត្រូវតែមានរហូត:




**ខ. ទម្រង់ «ពពស ឬ ពពសព»**

ឧទាហរណ៍៖ ឆ្គង ផ្លុំ ឆ្កែ ប្រឹង ប្រែង ផ្កា ផ្គត់ផ្គង់ ផ្តុំ ស្រស់ ក្រីក្រ ក្រង។ ព្យញ្ជនៈ «ឆ្គ ផ្ល ឆ្ក ប្រ ផ្ក ផ្គ ស្រ ក្រ» ជាព្យញ្ជនៈផ្សំដើមព្យាង្គ។






**២.៧.៥. លក្ខណៈព្យាង្គ**

ព្យាង្គអាចចែកតាមមូលភេទអ-អ៊ និងលក្ខណៈខ្យល់។

**ក. តាមមូលភេទអ-អ៊** ព្យាង្គមានពីរយ៉ាងគឺៈ

-ព្យាង្គ អ មានសញ្ញាព្យញ្ជនៈដើមព្យាង្គពួកអ។ ឧទាហរណ៍ៈ ចង់ចេះ ឱ្យ សម្លាប់ អាចារ្យ។ យើងឃើញថា «ច អ ស» ជាពួកអ នាំឱ្យ«ចង់ ឱ្យ សំ» ជាព្យាង្គអ។

-ព្យាង្គ អ៊ មានសញ្ញាព្យញ្ជនៈដើមព្យាង្គពួកអ៊។ ឧទាហរណ៍ៈ ពាក្យ ពិត វែង ស្លែង។ យើងឃើញថា «ព វ» ជាពួកអ៊ នាំឱ្យ «ពិត វែង» ជាព្យាង្គអ៊។

**ខ. តាមលក្ខណៈខ្យល់** ព្យាង្គមានបួនយ៉ាងគឺៈ

-ព្យាង្គបើក មានស្រៈនៅខាងចុង «ពស ឬពពស»។ ឧទាហរណ៍ៈ ដើរ ទៅ ធ្វើ ការ ឯ ស្រែ ផ្លែ ឈើ ខ្ញី ធី គួរ ដែរ។ យើងឃើញថា «[អើ] [អៅ]» នៅខាងចុងព្យាង្គនាំឱ្យ «ដើរ ទៅ» ជាព្យាង្គបើក។

-ព្យាង្គបិទ មានព្យញ្ជនៈនៅខាងចុង «ពសព ឬពពសព»។ ឧទាហរណ៍ៈ តក់ៗ ពេញ បំពង់ ធុងៗ កំពប់។ យើងឃើញថា «ក ញ» នៅខាងចុងព្យាង្គនាំឱ្យ «តក់ ពេញ» ជាព្យាង្គបិទ។

-ព្យាង្គវែង មានស្រៈវែង។ ឧទាហរណ៍ៈ សូម ធ្វើ ការងារ ឱ្យបានល្អ។ យើងឃើញថា «[អូ]» ស្រៈវែង នាំឱ្យ «សូម» ជាព្យាង្គបិទវែង។ រីឯ «[អើ] ស្រៈវែង នាំឱ្យ «ធ្វើ» ជាព្យាង្គបើកវែង។

-ព្យាង្គខ្លី មានស្រៈខ្លី។ ឧទាហរណ៍ៈ សុំប្រឹង បំពេញ ភារកិច្ចនេះទៅ។ យើងឃើញថា «[អុ] ស្រៈខ្លីនាំឱ្យ «សុំ» ជាព្យាង្គបិទខ្លី។ រីឯ «[អៅ]» ស្រៈខ្លី នាំឱ្យ «ទៅ» ជាព្យាង្គបើកខ្លី។

## សំណួរ

១. តើសូរវិទ្យាជាអ្វី?
២. តើគេចែកសូរវិទ្យាជាប៉ុន្មានផ្នែក? អ្វីខ្លះ?
៣. តើសូរវិទ្យាបន្លឺជាអ្វី?
៤. តើសូរសំឡេងមានលក្ខណៈប៉ុន្មានយ៉ាង? អ្វីខ្លះ?
៥. តើការបន្លឺសំឡេងជាអ្វី?
៦. តើសរីរាង្គនៃការបន្លឺសំឡេងមានអ្វីខ្លះ?
៧. ចូររៀបរាប់អំពីលក្ខណៈបន្លឺសំឡេងនៃភាសា។
៨. តាមលក្ខណៈខ្យល់ តើសូរសំឡេងមានអ្វីខ្លះ?
៩. តើសូរវិទ្យាអាគូស្ទិកជាអ្វី?
១០. ចូររៀបរាប់អំពីកំណកំណើតសូរនិងលក្ខណៈនៃសូរតាមសូរវិទ្យាអាគូស្ទិក។
១១. តើសូរព្យញ្ជនៈជាអ្វី?
១២. ចូររៀបរាប់អំពីសូរព្យញ្ជនៈទោលតាមលក្ខណៈបន្លឺ។

១៣. ចូររៀបរាប់អំពីសូរព្យញ្ជនៈទោលតាមលក្ខណៈខ្យល់។
១៤. ចូររៀបរាប់អំពីសូរព្យញ្ជនៈទោលតាមលក្ខណៈឮ។
១៥. ចូររៀបរាប់អំពីសូរព្យញ្ជនៈផ្សំនៃភាសាខ្មែរ។
១៦. ចូររៀបរាប់អំពីសញ្ញាព្យញ្ជនៈទោលនិងព្យញ្ជនៈផ្សំនៃភាសាខ្មែរឱ្យបានក្បោះក្បាយ។
១៧. តើសូរស្រៈជាអ្វី?
១៨. ចូររៀបរាប់អំពីសូរស្រៈតាមមូលភេទ អ-អ៊។
១៩. ចូររៀបរាប់អំពីសូរស្រៈតាមប្រភេទវែង-ខ្លី និងទោល-ផ្សំ។
២០. តើគេអាចសម្គាល់សូរស្រៈខ្លីខ្មែរក្នុងភាសាសរសេរបានយ៉ាងម៉េចខ្លះ?
២១. ចូររៀបរាប់អំពីសញ្ញាស្រៈនិស្ស័យនិងសញ្ញាស្រៈពេញតួក្នុងភាសាខ្មែរ។
២២. តើសទ្ទតាវិទ្យាជាអ្វី? តើសទ្ទតាជាអ្វី?
២៣. តើគេប្រើវិធីអ្វីខ្លះដើម្បីវិភាគរកសទ្ទតានីមួយៗនៃភាសា?
២៤. តើព្យាង្គជាអ្វី?
២៥. តើព្យាង្គនៃភាសាខ្មែរមានទម្រង់អ្វីខ្លះ?
២៦. ចូររៀបរាប់អំពីសទ្ទ (សទ្ទតា) ដែលមាននៅក្នុងព្យាង្គ។
២៧. ចូររៀបរាប់អំពីលក្ខណៈនៃព្យាង្គ។

# មេរៀនទី៤
# ការបង្កើតពាក្យនិងរូបសព្ទវិទ្យា

## ១. ការបង្កើតពាក្យ

លោកបណ្ឌិត កេង វ៉ាន់សាក់ (១៩៦៤) នៅក្នុងឯកសារ «មូលភាពនៃការបង្កើតពាក្យថ្មី» មិនបានធ្វើការសិក្សាពីវិធីបង្កើតពាក្យទូទៅនោះទេ គឺលោកសិក្សាតែទៅលើវិធីបង្កើតពាក្យថ្មីប៉ុណ្ណោះ ដូចសេចក្ដីបញ្ជាក់ «ពាក្យនៅក្នុងភាសាតែងតែកកើតឡើងដោយសារវិធីផ្សេងៗ។ វិធីបង្កើតពាក្យមានឈ្មោះហៅថាសព្ទវិធី។ ពាក្យថ្មីក៏មានកំណើតឋិតនៅលើសព្ទវិធីដែរ។ ការសិក្សាអំពីសព្ទវិធីទូទៅមានទំហំទូលំទូលាយពេក។ ហេតុដូច្នេះ យើងនឹងសិក្សាតែអំពីវិធីបង្កើតពាក្យថ្មីប៉ុណ្ណោះទេ»។

នៅក្នុងឯកសារដដែលនេះ លោកបានបង្ហាញតែវិធីតែមួយប៉ុណ្ណោះក្នុងការបង្កើតពាក្យថ្មី គឺវិធីផ្សំដែលមានពីរបែប បែបខ្មែរនិងបែបបាលី-សំស្ក្រឹត។

លោក អៀវ កើស (១៩៦៧) នៅក្នុងឯកសារ «ភាសាខ្មែរ ការល្បងពិនិត្យដោយរកហេតុផល» បានធ្វើការសិក្សាលម្អិតលើវិធីបង្កើតពាក្យដែលខ្មែរធ្លាប់បានប្រើកន្លងមកដូចជាវិធីផ្សំ វិធីកម្លាយ និងវិធីគន្លាស់កាត់។

ដើម្បីបង្កើតពាក្យ គេត្រូវស្គាល់កត្តាបីជាចម្បងគឺ លក្ខខណ្ឌនៃការបង្កើតពាក្យ វិធីបង្កើតពាក្យ និងធាតុដែលត្រូវយកមកប្រើសម្រាប់បង្កើតពាក្យ។ គោលការណ៍នៃការបង្កើតពាក្យ គឺជាក្បួនទូទៅមួយ ដែលអាចផ្ដល់ដល់អ្នកបង្កើតពាក្យនូវភាពងាយស្រួលក្នុងការបង្កើតពាក្យ នៅពេលគេប្រឈមនឹងបញ្ញត្តិថ្មីមួយ។ វាក៏ជាមធ្យោបាយមួយដែលអាចរក្សាបាននូវឯកភាពក្នុងភាសាជាតិផងដែរ (ច័ន្ទ សំណព្វ, ២០១០: ៧)។

### ១.១. និយមន័យ

ការបង្កើតពាក្យ គឺជាវិធីបន្ថែមពាក្យថ្មីទៅលើភាសា ដោយការនាំយកពាក្យ ដែលមានប្រើស្រាប់នៅក្នុងភាសាមករួមផ្សំគ្នា (សួន ឱសថ, ២០១៣: ២៧៦)។

ការបង្កើតពាក្យ (word formation) នៅក្នុងគំនិតទូទៅបំផុត បញ្ញត្តិនេះសំដៅដល់ដំណើរប្រព្រឹត្តទៅទាំងស្រុងនៃបម្រែបម្រួលរូបសព្ទនៅក្នុងរចនាសម្ព័ន្ធពាក្យដែលបូករួមផ្នែកពីរសំខាន់ គឺជាការផ្លាស់ប្ដូរ (inflection) (ទំនាក់ទំនងវេយ្យាករណ៍ពិសេសលើផ្នែកកាលនិងវចនៈ) និង ការប្រែប្រួល (derivation) (ទំនាក់ទនងវចនៈពិសេសលើប្រភេទពាក្យ)។ នៅក្នុងន័យចង្អៀតជាងនេះបន្តិច ការបង្កើតពាក្យសំដៅត្រឹមតែដំណើរប្រព្រឹត្តទៅថ្នាក់បន្ទាប់បន្សំប្រភេទបន្សំរវាងរូបសព្ទឯករាជ្យនិងរូបសព្ទឯករាជ្យ ឬការប្រែប្រួលដោយសារការបន្ថែមអញ្ញាសបទដែលជាធាតុចំណុះ ។

ឧ. Child > children, woman > women, write > wrote... ជាការផ្លាស់ប្ដូរ

កើយ > ខ្មើយ, ខូច > បង្ខូច, ធំ > ទំហំ, play > playing... ជាការប្រែប្រួល។

ជាទូទៅ ការបង្កើតពាក្យ (បម្រែបម្រួលពាក្យ) គឺជាដំណើរប្រព្រឹត្តទៅឬជាលទ្ធផលនៃការកកើតពាក្យថ្មីដែលត្រូវបានប្រែប្រួលចេញពីពាក្យឬសំណុំពាក្យដែលមានឫសដូចគ្នា។ ម្យ៉ាងទៀតការបង្កើតពាក្យត្រូវផ្ដល់និយមន័យថា ជាវិធីដែលពាក្យថ្មីត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋានពាក្យឬរូបសព្ទផ្សេងទៀត (គេន រង្សី, ២០២០: ៩០-៩១)។

### ១.២. វិធីបង្កើតពាក្យ

វិធីបង្កើតពាក្យ គឺជាក្បួនដែលបានប្រើរួចមកហើយ ហើយអាចប្រើបន្តទៅទៀតបាន ដោយអនុលោមទៅតាមភាពសមស្របនៃតម្រូវការចំពោះមុខ។ វិធីបង្កើតពាក្យអាចជាវិធីដែលកើតចេញពីការសំយោគបាតុភូតនានា

ដែលបានកើតឡើងក្នុងដំណើរវិវត្តនៃភាសានិងក្បួនវេយ្យាករណ៍ផ្សេងៗ ហើយដែលការសំយោគនោះបានក្លាយជាយន្តការនៃការបង្កើតពាក្យថ្មី (ច័ន្ទ សំណព្វ, ២០១០: ១២)។

គេបានប្រើវិធីជាច្រើនដើម្បីការបង្កើតពាក្យ។ វិធីទាំងនោះរួមមានវិធីសន្មត វិធីកម្លាយ វិធីតម្រាប់សូរ វិធីបន្សំ វិធីកម្ចី វិធីសមាស វិធីគន្លាស់ វិធីគន្លាស់កាត់ វិធីអក្សរកាត់ វិធីនិរុត្តិសាស្ត្រ...។

**១.២.១. វិធីសន្មត**

វិធីសន្មត គឺជាវិធីមួយនៃការបង្កើតពាក្យដែលគេប្រើ នៅពេលដែល គេគ្មានលទ្ធភាពបង្ហាញពីហេតុផល ឧទាហរណ៍ ទៅ មក ដើរ លេង ស លឿង...។ សន្មតបង្កើតពាក្យថ្មីមួយដើម្បីស្តែងពីបញ្ញត្តិមួយដែលទើបនឹងជួបប្រទះ ដោយគ្មានលទ្ធភាពបញ្ជាក់ពីហេតុផលស្តីពីទំនាក់ទំនងរវាងពាក្យដែលបង្កើតឡើងនិងបញ្ញត្តិនោះ។ ក្នុងករណីខ្លះអាចសន្មតយកឈ្មោះមនុស្សដែលជាអ្នកផលិត អ្នករកឃើញ អ្នកផ្តល់គំនិត ឬជាឥស្សរជន មកស្តែងពីបញ្ញត្តិនោះតែម្តង ដូចជា ចាយសៀងអ៊ី កេតសាណា ។ល។ វិធីនេះ គេច្រើនប្រើនៅសម័យបុរេអង្គរ។ នាពេលឥឡូវនេះ គេកម្រនឹងប្រើវាណាស់។ យើងត្រូវចៀសវាងវិធីនេះ ប្រសិនបើអាចធ្វើទៅបាន ព្រោះសម័យបច្ចុប្បន្ន យើងមានពាក្យច្រើនណាស់ដែរហើយ ដែលសមល្មមអាចឱ្យយើងប្រើដើម្បីផ្សំបង្កើតជាពាក្យសម្រាប់ស្តែងពីបញ្ញត្តិផ្សេងៗបានតាមតម្រូវការ (ច័ន្ទ សំណព្វ, ២០១០: ៤២)។

**១.២.២. វិធីកម្លាយ**

វិធីកម្លាយជាវិធីបង្កើតពាក្យដោយប្រើផ្នត់ (ផ្នត់ដើម ផ្នត់ដែក) ហើយជួនកាល គេក៏មានប្រើកាឡូរូបរបស់ផ្នត់ខ្លះផងដែរ។

ផ្នត់ គឺជាកន្ទេចពាក្យដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរ ហើយមានរូបនឹងនរនិងមានន័យនឹងនរ លើកលែងតែមានការវិវត្តសូរនិងការវិវត្តន័យចំពោះផ្នត់ខ្លះ។ ទោះផ្នត់គ្មានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរក្តី ក៏ខ្មែរទូទៅបានស្គាល់និងអាចប្រើប្រាស់សម្រាប់ដាក់ភ្ជាប់ជាមួយពាក្យឫសក្នុងភាសាខ្មែរ (ឬពាក្យកម្ចីដែលចូលស៊ប់ក្នុងភាសាខ្មែរ) ដើម្បីបង្កើតពាក្យកម្លាយ (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ២៧-២៨)។

| | | | |
|---|---|---|---|
| ឧទាហរណ៍ | កម្លាយដោយផ្នត់ដើម៖ | [ក-]+ បាំង > ក្បាំង | [គ-]+ វាង > ឃ្វាង |
| | | [ក-] + កោក > កកោក | [ង-] + ងុយ > ងងុយ។ |
| | កម្លាយដោយផ្នត់ដែក៖ | ខ្វល់ + [-អ`ង-] > កង្វល់ | ឃ្វាល + [-អ៊`ង-] > គង្វាល |
| | | ត + [-អ`ម/ណ-] > តំណ | បន់ + [-អ`ម/ណ-] > បំណន់។ |

**១.២.៣. វិធីតម្រាប់សូរ**

វិធីតម្រាប់សូរ ជាវិធីបង្កើតពាក្យដោយត្រាប់តាមសូរដែលបានឮ ឧទាហរណ៍ តក់ៗ តាវ៉ៅ ផាំងៗ ទីទុយ ។ល។ ចំពោះវិធាននៃការត្រាប់សូរនេះ គឺគេយកសូរដែលឮមកកត់ត្រាបង្កើតជាពាក្យ ដើម្បីស្តែងពីបញ្ញត្តិដែលកើតមានតាមរយៈសូរនោះ។ គេច្រើនតែត្រាប់សូរតាមសំឡេងស្រែកឬយំរបស់សត្វដើម្បីដាក់ឈ្មោះសត្វនោះ ឬក៏ត្រាប់តាមសូរបាតុភូតមួយដែលបានកើតឡើង ដើម្បីស្តែងពីបាតុភូតនោះ។ ឧទាហរណ៍ ក្ងាំង តុកកែ ផាំង គ្រឹមៗ។ល។ សុទ្ធតែជាពាក្យដែលបង្កើតឡើងតាមវិធីតម្រាប់សូរទាំងអស់។ ពាក្យតម្រាប់សូរដែលមានលក្ខណៈជាវចនសព្ទ ត្រូវបានកត់ត្រាទុកក្នុងវចនានុក្រម ហើយមិនអនុញ្ញាតឱ្យសរសេរប្រែប្រួលទៅតាមសូរដែរឮផ្សេងៗគ្នានោះទេ។ ពាក្យតម្រាប់សូរ តុកកែ តាវ៉ៅ ត្រូវតែសរសេរនិងអានបែបនេះជារៀងដរាបទៅ បើទោះបីជាពេលខ្លះសត្វទាំងនោះយំឮសូរផ្សេងយ៉ាងណាក៏ដោយចុះ (ច័ន្ទ សំណព្វ, ២០១០: ៣៤)។

**១.២.៤. វិធីបន្សំ**

វិធីបន្សំ ជាវិធីដែលកើតឡើងពីការផ្គុំពាក្យឯករាជ្យនិងពាក្យឯករាជ្យ។ ជាទូទៅ ពាក្យដែលគេផ្គុំដើម្បីឱ្យបានជាពាក្យបន្សំ ជាពាក្យខ្មែរសុទ្ធឬពាក្យកម្ចីដែលបានចូលស៊ប់ក្នុងភាសាខ្មែរ។ ក្នុងពាក្យបន្សំមានពាក្យគោលនិងពាក្យ

រណប ដូចជាក្នុងពាក្យ «រទេះភ្លើង» រទេះជាពាក្យគោល និងពាក្យភ្លើងជាពាក្យរណប។ ប៉ុន្តែពាក្យបន្សំមួយចំនួនឥត មានពាក្យគោលនិងពាក្យរណបទេ ដូចជា ឪពុកម្ដាយ បងប្អូន កូនចៅ គោក្របី រៀបរៀង ធំធាត់... ហើយពាក្យបន្សំខ្លះទៀត មានន័យប្លែកពីន័យនៃធាតុនីមួយៗ ដូចជា ជើងល្អ ត្រចៀកស... (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨: ៥៣)។

វិធីបន្សំត្រូវបានធ្វើឡើងតាមវិធីសាស្ត្រពីរ គឺបន្សំតាមបែបខ្មែរនិងបន្សំតាមបែបបាលី-សំស្ក្រឹត។

**ក. បន្សំតាមបែបខ្មែរ**

បន្សំតាមបែបខ្មែរ គឺជាវិធីសាស្ត្រមួយប្រភេទដើម្បីបង្កើតពាក្យបន្សំដោយប្រើប្រាស់ធាតុផ្សំក្នុងភាសាខ្មែរឬជាធាតុផ្សំចេញពីភាសាដទៃទៀតមកផ្សំជាមួយគ្នា ដោយរៀបទៅតាមលំដាប់សម្ព័ន្ធស្របនឹងន័យ ដែលស្ដែងឡើងមានន័យថាបើគេចង់ពន្យល់ន័យកន្សោមពាក្យដែលកើតតាមបន្សំនេះ គេត្រូវពន្យល់ន័យស្របតាមលំដាប់នៃធាតុផ្សំ គឺក្នុងទិសដៅពីខាងឆ្វេងមកខាងស្ដាំ ដោយបន្ថែមពាក្យដូចជា នៃ របស់ ធ្វើអំពី ដែល សម្រាប់ ជាដើម។ ក្នុងបន្សំនេះ ភាគច្រើនបំផុត ធាតុផ្សំដែលមានប្រភេទពាក្យជានាមសព្ទត្រូវនៅពីខាងស្ដាំគេបង្អស់ ធាតុផ្សំដែលគេដាក់តម្រៀបជាបន្តបន្ទាប់អាចមានប្រភេទពាក្យជានាម គុណនាម និងកិរិយា។ ពាក្យបន្សំតាមបែបខ្មែរតិចតួចបំផុតដែលផ្ដើមដោយកិរិយា (គេន វង្សី, ២០១៥: ៤៣)។

**ក១. ទម្រង់ពាក្យបន្សំតាមបែបខ្មែរ ដែលប្រើធាតុផ្សំក្នុងភាសាខ្មែរ**

-នាម+បរិវារសព្ទ ៖ ក្ដីក្ដាំ ផ្សារផ្សោ ផ្ទះសម្បែង ចានក្បាន បារាំងបារាំ ក្មេងក្មាង
-នាម+នាម ៖ ទឹកទន្លេ ផ្ទះបាយ បន្ទប់ទឹក ប្រហុកគ្រឿង ដំឡូងឈាមមាន់
-នាម+នាម+នាម ៖ កាហ្វេទឹកដោះគោទឹកកក
-នាម+នាម+សំខ្យា ៖ ផ្កាម៉ោងដប់
-នាម+កិរិយា ៖ បន្ទប់រៀន ទឹកកក ច្រកចេញ លុយសន្សំ គោជុត ប្រហុកចិញ្ច្រាំ ចំណេះដឹង
-នាម+កិរិយា+គុណកិរិយា ៖ បន្ទប់សង្គ្រោះបន្ទាន់
-នាម+កិរិយា+នាម ៖ ផ្ទះដាក់ធ្មេញ ផ្កាយដុះកន្ទុយ ជាងកាត់សក់
-នាម+គុណនាម ៖ សាច់ជូរ ឈើអែម អំពិលផ្អែម ខ្លង់រាប ស្កសេ កន្ទេលក្រហម រង្វង់មូល
-នាម+ធ្នាក់+នាម ៖ ផ្លូវក្រោមដី កូនក្នុងផ្ទៃ ចាបក្នុងទ្រុង កណ្ដុរក្នុងសោរ ចោរក្នុងផ្ទះ
-សព្វនាម+នាម ៖ អ្នកស្រែ អ្នកដំណើរ
-សព្វនាម+គុណនាម ៖ អ្នកក្រ អ្នកធំ អ្នកតូច
-កិរិយា+នាម ៖ សៀតផ្កា កណ្ដៀតក្អម បោះដៃផុត ចង្កូលខ្មោច បង្ហាន់ដៃ រលាកក្រពះ
-កិរិយា+កិរិយា ៖ រីករាយ ផ្សះផ្សា បោះបង់ ដេញដោល បោកបែន ដើរហើរ
-កិរិយា+បរិវារសព្ទ ៖ ដាច់ដោច ប្រកាច់ប្រកិន ត្រឡប់ត្រឡិន
-បរិវារសព្ទ+កិរិយា ៖ ផ្សែផ្សំ ឈ្លានពាន ប្រកែប្រកាន់
-គុណនាម+បរិវារសព្ទ ៖ ល្អិតល្អោច អាក្រក់អាក្រី ណែនណាន់ តាន់តាប់
-បរិវារសព្ទ+គុណនាម ៖ ក្រីក្រ គគ្រឹមគគ្រេីម

**ក២. ទម្រង់ពាក្យបន្សំតាមបែបខ្មែរ ដែលប្រើធាតុផ្សំក្នុងភាសាបាលី-សំស្ក្រឹត**

-នាម+នាម ៖ គណៈរដ្ឋមន្ត្រី អាសនៈសភា យានយន្ត បុណ្យសមុទ្រ ប្រធានរដ្ឋសភា
-នាម+កិរិយា+នាម ៖ លិខិតឧទ្ទេសនាម
-នាម+កិរិយា+នាម+នាម ៖ គណៈបញ្ជាការឯកភាព
-នាម+កិរិយា ៖ វគ្គសិក្សា កិច្ចពិភាក្សា អគារសិក្សា ពិធីសម្ពោធ ជនសង្ស័យ

-នាម+គុណនាម ៖ មិត្តភក្តិ

-នាម+គុណនាម+កិរិយា ៖ សាលាបឋមសិក្សា

-នាម+សំខ្យា ៖ វរសេនីយ៍ត្រី ឧត្តមសេនីយ៍ឯក

**ក៣. ទម្រង់ពាក្យបន្សំតាមបែបខ្មែរ ដែលប្រើធាតុផ្សំក្នុងភាសាខ្មែរនិងធាតុផ្សំក្នុងភាសាបាលី-សំស្ក្រឹត**

-នាម+នាម ៖ សាលាក្តី ស្ថានអាកាស គូសង្សារ នគរបាលសណ្តាប់ធ្នាប់ មេជីវិត កូនធម៌

-នាម+កិរិយា ៖ យន្តហោះ សាលប្រជុំ កិច្ចព្រមព្រៀង លិខិតអញ្ជើញ

-នាម+កិរិយា+នាម ៖ សេចក្តីប្រកាសព័ត៌មាន អ្នកនាំពាក្យ មេបញ្ជាការ លិខិតឆ្លងដែន

-នាម+បរិវារសព្ទ ៖ មនុស្សម្នា វត្ថុរ៉ា ស្នេហ៍ស្នង ជាតិជៅ

-នាម+គុណនាម ៖ វរសេនាតូច ទឹកបរិសុទ្ធ ជីវចម្រុះ

-នាម+នាម+គុណនាម ៖ កងវរសេនាធំ

-កិរិយា+នាម+កិរិយា ៖ ស្នងការរង

-នាម+នាម+នាម ៖ ទីស្តីការគណៈរដ្ឋមន្ត្រី

-នាម+ធ្នាក់+នាម ៖ ផលិតផលក្នុងស្រុក អង្គការក្រៅរដ្ឋាភិបាល ទូរសព្ទលើតុ

-សព្វនាម+នាម ៖ អ្នកភូមិ

**ក៤. ទម្រង់ពាក្យបន្សំតាមបែបខ្មែរ ដែលប្រើធាតុផ្សំមកពីភាសាដទៃទៀត**

-នាម+នាម ៖ ហាងកាហ្វេ បុណ្យណូអែល តាក់ស៊ីម៉ែត្រ ស្ថានកុងស៊ុល ប៉ូលីសអាំងទែប៉ូល

-នាម+នាម+កិរិយា ៖ វីឡាកូនកាត់

-នាម+នាម+សំខ្យា ៖ រ៉ឺម៉កកង់បី ម៉ូតូកង់បី

-នាម+កិរិយា ៖ ម៉ូតូឌុប ភ្លើងស្តុប ម៉ាស៊ីនថត

-នាម+ធ្នាក់+នាម ៖ កុំព្យូទ័រលើតុ

-សព្វនាម+នាម ៖ អ្នកកាសែត។ល។

**ខ. បន្សំតាមបែបបាលី-សំស្ក្រឹត**

បន្សំតាមបែបបាលី-សំស្ក្រឹត គឺជាវិធីសាស្ត្រមួយប្រភេទដើម្បីបង្កើតពាក្យបន្សំដោយប្រើប្រាស់ធាតុផ្សំក្នុងភាសាខ្មែរឬធាតុផ្សំក្នុងភាសាដទៃទៀតមកផ្សំជាមួយគ្នា ដោយរៀបទៅតាមលំដាប់សម្ព័ន្ធបញ្ច្រាសនឹងន័យដែលស្តែងឡើង មានន័យថាបើគេចង់ពន្យល់ន័យកន្សោមពាក្យដែលកើតតាមបន្សំនេះ គេត្រូវពន្យល់ន័យតាមទិសដៅពីខាងស្តាំមកខាងឆ្វេងវិញ។ ធាតុផ្សំនៅក្នុងបន្សំតាមបែបបាលី-សំស្ក្រឹតយ៉ាងហោចណាស់មានធាតុផ្សំមួយជាពាក្យទោល ឯធាតុផ្សំដទៃទៀតអាចជាពាក្យបន្សំ ពាក្យទោល បុព្វបទ ឬបច្ច័យបទ។

**ខ១. ទម្រង់ពាក្យបន្សំតាមបែបបាលី-សំស្ក្រឹត ដែលប្រើធាតុផ្សំក្នុងភាសាបាលី-សំស្ក្រឹត**

-នាម+នាម ៖ រដ្ឋមន្ត្រី រាជបុត្រ ព្រហ្មលិខិត ចក្ខុរូបារម្មណ៍ សមាហរណកម្ម កាយវប្បកម្ម

-នាម+នាម+នាម ៖ ព្រហ្មវិហារធម៌

-គុណនាម+នាម ៖ សាកលវិទ្យាល័យ សាកលភាវូបនីយកម្ម

-បុព្វបទ+នាម ៖ អគ្គនាយក អភិជន យុវវ័យ អត្តចរិត អន្តរជាតិ អនុវិទ្យាល័យ

-នាម+បច្ឆិមបទ ៖ សិល្បករ កម្មករ សមាជិក នាយិកា កីឡាការិនី នាយកដ្ឋាន ទារកដ្ឋាន

-បុព្វបទ+នាម+បច្ឆិមបទ ៖ សុទិដ្ឋិនិយម ទុទិដ្ឋិនិយម

-បុព្វបទ+នាម+នាម ៖ យុវនីតិសម្បទា

-កិរិយា+នាម ៖ សិក្សាកថា ផលិតផល

-កិរិយា+បច្ឆិមបទ ៖ អភិរក្សដ្ឋាន

**ខ២. ទម្រង់ពាក្យបន្សំតាមបែបបាលី-សំស្ក្រឹត ដែលប្រើជាតុផ្សំក្នុងភាសាខ្មែរ**

-គុណនាម+នាម ៖ ក្រពុំឈូក

-កិរិយា+នាម ៖ ចែងថ្លៃ

**ខ៣. ទម្រង់ពាក្យបន្សំតាមបែបបាលី-សំស្ក្រឹត ដែលប្រើជាតុផ្សំក្នុងភាសាខ្មែរនិងភាសាបាលី-សំស្ក្រឹត**

-គុណនាម+កិរិយា ៖ មហារីក

-គុណនាម+កិរិយា+នាម ៖ មហារីកថ្លើម

-កិរិយា+នាម+បច្ច័យបទ ៖ បញ្ជាការដ្ឋាន ស្នងការដ្ឋាន

-បុព្វបទ+នាម ៖ អគ្គបញ្ជាការដ្ឋាន

**ខ៤. ទម្រង់ពាក្យបន្សំតាមបែបបាលី-សំស្ក្រឹត ដែលប្រើជាតុផ្សំក្នុងភាសាបរទេសផ្សេងៗទៀត**

-នាម+នាម ៖ អុកស៊ីតកម្ម រេដុកកម្ម ភ្នំពេញស្ព័តក្លិប

-នាម+បច្ឆិមបទ ៖ អ៊ីស្លាមនិយម រេដុកករ អុកស៊ីតករ

-បុព្វបទ+នាម ៖ អនុកុងស៊ុល

សរុបមក បន្សំតាមបែបខ្មែរនិងបន្សំតាមបែបបាលី-សំស្ក្រឹត យកគ្រប់ជាតុផ្សំមកប្រើប្រាស់ដោយមិនប្រកាន់ប្រភេទពាក្យឬប្រភពរបស់ជាតុផ្សំឡើយ ប៉ុន្តែអ្វីដែលខុសគ្នានៅត្រង់ថា ន័យដែលស្តែងឡើងក្នុងបន្សំតាមបែបខ្មែរ មានទិសដៅស្របតាមលំដាប់ជាតុផ្សំ គឺពីឆ្វេងទៅស្តាំ ឯន័យដែលស្តែងឡើងក្នុងបន្សំតាមបែបបាលី-សំស្ក្រឹត មានទិសដៅបញ្ច្រាសនឹងលំដាប់ជាតុផ្សំ គឺពីស្តាំមកឆ្វេងវិញ។

វិធីបន្សំ ជាវិធីមួយដែលពេញនិយមពីសំណាក់ប្រជាជនខ្មែរយកទៅប្រើដើម្បីបង្កើតពាក្យថ្មី ព្រោះវិធីនេះមានលក្ខណៈងាយស្រួលក្នុងការអនុវត្តដោយមិនទាមទារក្បួនច្បាប់អ្វីច្រើនឡើយ ហើយមិនរើសប្រភេទពាក្យឬប្រភពពាក្យរបស់ជាតុផ្សំផងដែរ ទោះបីជាអ្នកដែលមិនបានរៀនសូត្រជ្រៅជ្រះលើផ្នែកអក្សរសាស្ត្រក៏គេអាចបង្កើតពាក្យតាមវិធីបន្សំនេះបានដែរ សំខាន់គឺការយល់ដឹងទៅលើទំនាក់ទំនងរវាងពាក្យនិងគំនិត។

វិធីបន្សំបានជួយឱ្យកើតមាននូវពាក្យថ្មីៗរាប់មិនអស់ក្នុងភាសាខ្មែរដើម្បីសម្គាល់នូវបញ្ញត្តិថ្មី។ ពាក្យដែលត្រូវបានបង្កើតឡើងតាមវិធីនេះមានទម្រង់ខ្លី ងាយស្រួលប្រើ ងាយចងចាំ ប៉ុន្តែក្នុងនោះឃើញថា បើបន្សំតាមបែបខ្មែរមានចំនួនពាក្យច្រើនជាងបន្សំតាមបែបបាលី-សំស្ក្រឹត តែចំពោះន័យដែលស្តែងឡើងវិញ ន័យរបស់បន្សំតាមបែបខ្មែរមានលក្ខណៈងាយស្រួលយល់ជាងបន្សំតាមបែបបាលី-សំស្ក្រឹត។ ចំពោះបន្សំតាមបែបខ្មែរ បើយើងចេះប្រើជាតុផ្សំដែលជាពាក្យកម្លាយ នោះនឹងធ្វើឱ្យចំនួនជាតុផ្សំក្នុងបន្សំតាមបែបខ្មែរកាន់តែមានចំនួនតិច។

វិធីបន្សំជួយដល់អ្នកប្រើប្រាស់ភាសាគេចផុតពីភាពទាល់ច្រកក្នុងការបង្កើតពាក្យ។ តាមរយៈពាក្យថ្មីៗដែលកើតឡើងក្នុងភាសាខ្មែរ ប្រជាជនខ្មែរបានប្រើប្រាស់អស់លទ្ធភាពនូវជាតុផ្សំដែលមានក្នុងភាសារបស់ខ្លួនរួមទាំងពាក្យកម្ចីពីភាសាខាងក្រៅផង មកផ្សំបញ្ចូលគ្នាដោយឥតរើសអើង ហើយពាក្យថ្មីដែលកើតឡើងនោះបានសម្គាល់នូវបញ្ញត្តិមួយច្បាស់លាស់ និងត្រូវបានប្រើប្រាស់ជាប្រព័ន្ធនៅក្នុងសង្គម។

ដោយសារតែមានលក្ខណៈងាយស្រួលក្នុងការបង្កើតពាក្យ វិធីបន្សំអាចជួយកាត់បន្ថយកម្ចីពាក្យពីភាសាខាងក្រៅមកប្រើទាំងដុលបានមួយចំនួនធំផងដែរ។ ការបង្កើតពាក្យតាមវិធីបន្សំមានច្រើនជម្រើសតាំងពីយន្តការនៃការបង្កើតនិងប្រភពនៃជាតុផ្សំ។ បើជម្រើសមួយទៅមិនរួច គេអាចជ្រើសយកជម្រើសមួយផ្សេងទៀត ទាល់តែអាចបង្កើតពាក្យសម្គាល់បញ្ញត្តិថ្មីនោះបាន (គេន រង្សី, ២០១៥: ៤៩)។

### ១.២.៥. វិធីកម្ចី

វិធីកម្ចី ជាវិធីមួយដែលគ្រាន់តែធ្វើខ្មែរភាវូបនីយកម្មទៅលើពាក្យបរទេស ដោយរក្សាទុកទាំងស្រុង ឬមាន

ការកែប្រែខ្លះៗនូវសូរដើមរបស់ពាក្យបរទេសនោះ។ រីឯអត្ថន័យវិញក៏យ៉ាងដូច្នោះដែរ។ ឧទាហរណ៍ ម៉ូតូ កាណូត ស៊ីម៉ង់ត៍ ចាប់ហួយ ហាងឆេង ភាសា អន្តរជាតិ ហេតុ អេតចាយ។ល។ សុទ្ធតែជាពាក្យខ្ចីពីភាសាបរទេសទាំងអស់។

ការខ្ចីពាក្យពីភាសាបរទេស គឺជាការកត់ត្រាពាក្យនោះដោយអក្សរខ្មែរ ពោលគឺគ្រាន់តែធ្វើវាឱ្យមានភាពជាខ្មែរដោយរក្សាជាតិសព្ទវាទាំងស្រុងឬស្ទើរតែទាំងស្រុង។ ពាក្យដែលបានធ្វើខ្មែរភាវូបនីយកម្មហើយនោះ បានក្លាយជាពាក្យកម្ចីដែលមានក្នុងភាសាខ្មែរ (ច័ន្ទ សំណព្វ, ២០១០: ៤៦)។

**១.២.៦. វិធីសមាស**

វិធីសមាសជាវិធីបន្សំមួយបែបដែលមានសម្ព័ន្ធផ្ទុយគ្នាពីសម្ព័ន្ធនៃពាក្យបន្សំបែបខ្មែរ ឧទាហរណ៍ ធន + អគារ > ធនាគារ, សព្វ + អាវុធ > សព្វាវុធ, សិក្សា + អធិការ > សិក្សាធិការ, វិទ្យា + អាល័យ > វិទ្យាល័យ, រូប + អារម្មណ៍ > រូបារម្មណ៍, អាហារ + ឋាន > អាហារដ្ឋាន, យុទ្ធ + ឧបករណ៍ > យុទ្ធោបករណ៍, ជាតិ + ឧបនីយកម្ម > ជាតូបនីយកម្ម, បណ្ណ + អាល័យ > បណ្ណាល័យ...។

**១.២.៧. វិធីគន្លាស់**

វិធីគន្លាស់ ជាវិធីបង្កើតពាក្យថ្មីដោយការផ្លាស់ព្យញ្ជនៈនិងស្រៈនៃព្យាង្គផ្សេងៗ (ច័ន្ទ សំណព្វ, ២០១០)។

ពាក្យគន្លាស់ គឺជាពាក្យដែលកើតឡើងតាមវិធីគន្លាស់ដោយប្រើប្រាស់ធាតុនៅក្នុងភាសាខ្មែរឬក្នុងភាសាបរទេស (បីស្រុក ស្រុកខ្ញុំបាទ ម៉ាឡេសៀន លក់ឡេផ្តាច់សិទ្ធិ)។ ធាតុដែលគេអាចយកមកគន្លាស់បាន ត្រូវជាពាក្យទោលឬជាសំណុំពាក្យដែលមានសូរចាប់ពីពីរព្យាង្គឡើងទៅ ហើយក្នុងចំណោមព្យាង្គទាំងអស់ក្នុងសំណុំពាក្យ ត្រូវមានព្យាង្គមួយដែលមានសូរព្យញ្ជនៈនិងសូរស្រៈឬសូរស្រៈនិងព្យញ្ជនៈប្រកបខុសប្លែកពីសូរព្យាង្គឯទៀត។ គោលការណ៍នៃការគន្លាស់ គឺគេគិតតែទៅលើសូរនិយាយមិនមែនសូរអានឡើយ ហើយសម្រេចសំណេរពាក្យដោយតម្រូវទៅតាមអក្ខរាវិរុទ្ធ។ ពាក្យឫសដែលគេយកមកគន្លាស់អាចមានចំនួនពីរព្យាង្គ បីព្យាង្គ ឬបួនព្យាង្គ។ បែបបទនៃការគន្លាស់ គឺគេផ្លាស់ប្តូរសូរស្រៈឬសូរស្រៈនិងព្យញ្ជនៈប្រកបរវាងព្យាង្គនិងព្យាង្គក្នុងសំណុំ ដែលការផ្លាស់ប្តូរសូរនេះវាអាស្រ័យលើចំនួនព្យាង្គក្នុងសំណុំពាក្យឫស។

-បើពាក្យឫសមានចំនួនពីរព្យាង្គ ៖ គេត្រូវផ្លាស់ប្តូរសូរស្រៈឬសូរស្រៈនិងព្យញ្ជនៈប្រកបរវាងព្យាង្គទី១ និងព្យាង្គទី២ ឧទាហរណ៍ ផ្កាយស្វា < ផ្កាស្វាយ, សាយប៊ី<ស៊ីបាយ, អ៊ុយឡត់ <អត់លុយ, ចាយបាន <ចានបាយ...។

-បើពាក្យឫសមានចំនួនបីព្យាង្គ ៖ គេមានលទ្ធភាពពីរ គឺផ្លាស់ប្តូរសូរស្រៈឬសូរស្រៈនិងព្យញ្ជនៈប្រកបរវាងព្យាង្គទី១ និងព្យាង្គទី៣ ឬរវាងព្យាង្គទី២ និងព្យាង្គទី៣ ឧទាហរណ៍ បាទអូនស្រី <បីអូនស្រាត, ស៊ុបកន្ត្រើយ <សើយកន្ទ្រប់, សំបុកសត្វ <សម្បត្តិសុខ...។

-បើពាក្យឫសមានចំនួនបួនព្យាង្គ ៖ គេមានលទ្ធភាពពីរ គឺផ្លាស់ប្តូរសូរស្រៈឬសូរស្រៈនិងព្យញ្ជនៈប្រកបរវាងព្យាង្គទី២ និងព្យាង្គទី៤ ឬរវាងព្យាង្គទី៣ និងព្យាង្គទី៤ ឧទាហរណ៍ ក្រឡានចង្រ្កឹង<ក្រឡឹងចង្ក្រាន ខ្មោចលងទាញពូក<ខ្មោចលូកទាញពង, នាយករងពិត<នាយករឹតពង...។

**១.២.៨. វិធីគន្លាស់កាត់**

វិធីគន្លាស់កាត់ ជាវិធីបង្កើតពាក្យដោយយកពាក្យមកគន្លាស់ហើយកាត់ពាក្យណាមួយចោល ដោយទុកតែពាក្យណាដែលគេចង់បានតែប៉ុណ្ណោះ។ ឧទាហរណ៍ ផេះធង់ - ផង់ធេះ > ផេះ, វង់រាំង - រាំងវង់ > រាំង, ឆ្នើទ្បាក់ - ថ្នាក់លើ > ឆ្នើ, ទ្រុងមូស - ទ្រូសមុង > មុង។ ពាក្យ *មុង* ដែលបានមកពីវិធីគន្លាស់កាត់នេះ គឺគេប្រើរបៀបកាត់ព្យាង្គនៅក្នុងពាក្យណាមួយ ដែលមានសំណេរនិងសំណូរដូចគ្នា ហើយនិងគេទុកតែព្យាង្គណា ដែលគេត្រូវការប៉ុណ្ណោះ ឧទាហរណ៍ *ទ្រុងមូស* (~~ទ~~ + ~~្រ~~ + ុ + ង ម + ~~ូ~~ + ~~ស~~ «មុង») គន្លាស់បានទៅជា *ទ្រុសមុង* (~~ទ~~ + ~~្រ~~ + ~~ូ~~ + ~~ស~~ ម + ុ + ង «មុង») គឺគេកាត់ *ទ្រូស* ចោល នៅសល់តែ *មុង* (អៀវ កើស, ១៩៦៧)។

## ២. រូបសព្ទវិទ្យា

### ២.១. និយមន័យ

រូបសព្ទវិទ្យា (Morphology) គឺសិក្សាអំពីទម្រង់ឬរូបរាងរបស់ពាក្យ។ រូបសព្ទវិទ្យាក្នុងភាសាវិទ្យាសំដៅទៅលើប្រព័ន្ធខួរក្បាលដែលមានពាក់ព័ន្ធនឹងទម្រង់ពាក្យ ឬក៏ជាមែកធាងនៃភាសាវិទ្យាដែលទាក់ទងនឹងពាក្យ រចនាសម្ព័ន្ធខាងក្នុងរបស់វា ហើយនិងវិធីបង្កើតពាក្យ។

រូបសព្ទវិទ្យា ជាវិជ្ជាដែលសិក្សាពីការផ្គុំរូបសព្ទ (morpheme) ជាមួយឫស ឬពាក្យឫស ដើម្បីបង្កើតពាក្យ។ ពាក្យដែលកើតដោយវិធីនេះ គឺជាពាក្យកម្លាយ ប៉ុន្តែការបង្កើតពាក្យមានវង្វង់ធំធេងជាងនេះឆ្ងាយទៅទៀត គឺមានការបង្កើតពាក្យសមាស ពាក្យរណ្ដំ ពាក្យកាត់ ពាក្យកន្សោមកាត់ ដែលស្ថិតនៅក្នុងវិធីមួយដ៏ធំទូលាយតទៅទៀត ហៅថា «វិធីរូប-សទ្ទតានិយម» ដូច្នេះហើយ រូបសព្ទវិទ្យាត្រូវនៅក្រោមវិជ្ជាដែលសិក្សាពីការបង្កើតពាក្យយ៉ាងទូលំទូលាយគឺ វចនវិទ្យា (ព្រុំ ម៉ល់, ២០០៣: ១៩)។

### ២.២. រូបសព្ទ

#### ២.២.១. និយមន័យ

រូបសព្ទជាធាតុអម ប្រើជាមួយបូរណសព្ទឬជាមួយល្បះ ឬប្រើជាមួយវចនតា ធ្នាក់ឈ្នាប់/អព្ភាសបទ និងវិភត្តិជាដើម។ ក្នុងអព្ភាសបទមាន បុព្វបទ អន្តេបទ បច្ឆិមបទ។ ក្នុងវិភត្តិមាន វិភត្តិរបស់នាមសព្ទនិងវិភត្តិរបស់កិរិយាសព្ទ (ភាសាខ្មែរឥតមានវិភត្តិទេ) (ព្រុំ ម៉ល់, ២០០៣: ១០)។

រូបសព្ទ គឺជា «ពាក្យដែលតូច(ខ្លី) បំផុតនៅក្នុងភាសាជាមួយអត្ថន័យ»។ កាលបើប្រៀបធៀបនិយមន័យនៃពាក្យ នឹងឃើញថា រូបសព្ទមាននិយមន័យប្រិតប្រៀងនិងច្បាស់លាស់ជាងពាក្យ។ នៅក្នុងការសិក្សាឈ្វេងយល់អំពីគម្រោងនៃពាក្យ អ្នកអក្សរសាស្ត្រផ្ដោតទៅលើលក្ខណៈនៃប្រភេទរូបសព្ទនិងការប្រកបរូបសព្ទ ឱ្យក្លាយទៅជាពាក្យ (សួន ឱសថ, ២០១០: ២៨០)។

រូបសព្ទ គឺជាឯកតាតូចបំផុតនៃភាសាដែលគេមិនអាចបំបែកតទៅទៀតបាន ហើយវាមានន័យនិងមុខងារវេយ្យាករណ៍សម្រាប់បង្កើតពាក្យ (គេន រង្សី, ២០២០: ២៤)។

រូបសព្ទជាឯកតាដែលមានន័យ ហើយប្រើសម្រាប់បង្កើតពាក្យ។ ឧទាហរណ៍ ពាក្យ «ក្មេងប្រុស» មានរូបសព្ទពីរ គឺ *ក្មេង* និង*ប្រុស* ។ រីឯពាក្យ «អ្នកដំណើរ» មានរូបសព្ទបីគឺ*អ្នក ដើរ* និងផ្នត់ដែក *[-អំម/ណ-]* ។

#### ២.២.២. ប្រភេទរូបសព្ទ

ភាសាវិទូបែងចែករូបសព្ទជាពីរប្រភេទ គឺរូបសព្ទឯករាជ្យនិងរូបសព្ទចំណុះ។

##### ២.២.២.១. រូបសព្ទឯករាជ្យ

រូបសព្ទឯករាជ្យ (free morphemes) ជារូបសព្ទដែលអាចឈរតែឯងបាន ដូចជាពាក្យ ឬប្រើផ្ទាល់ដោយមិនចាំបាច់ត្រូវការរូបសព្ទដទៃទៀតមកផ្សំជាមួយឡើយ។ រូបសព្ទឯករាជ្យមានដូចជា ដើរ មក ទៅ ធ្វើ និយាយ មុខ រក មើល តុ ទូ ទឹក ភ្លើង ដី ។ល។

##### ២.២.២.២. រូបសព្ទចំណុះ

រូបសព្ទចំណុះ (bound morphemes) ជាទម្រង់មួយដែលត្រូវប្រើភ្ជាប់ជាមួយរូបសព្ទដទៃទៀតនៅក្នុងពាក្យមួយ។ រូបសព្ទចំណុះមិនអាចឈរតែឯងបានទេ។ ឧទាហរណ៍ រូបសព្ទ (អនុ-) មានន័យថា «បន្ទាប់ រង តូច ក្រោយ តាម...» មិនអាចប្រើដោយខ្លួនឯងបានទេ ពោលគឺត្រូវមានរូបសព្ទដទៃមកភ្ជាប់ពីខាងក្រោយ ដូចជា អនុប្រធាន អនុគណៈកម្មការ អនុរក្ស អនុការី អនុក្រម អនុគណ អនុគ្រោះ អនុម័ត អនុប្រធានាធិបតី។

រូបសព្ទចំណុះទាំងនោះមានដូចជា បុព្វបទ អន្តរបទ (ផ្នត់ដែក) បច្ឆិមបទ ជាដើម។

**ក. បុព្វបទ** ជាធាតុវេយ្យាករប្រើសម្រាប់ដាក់នៅខាងដើមនៃពាក្យឫស ឬវចនសព្ទដើម្បីឱ្យពាក្យឫស ឬ

វចនសព្ទនោះប្រែប្រួលប្រភេទពាក្យ កម្រិតគុណធាតុ ឬន័យ។ល។ បុព្វបទចែកចេញជាបីផ្នែកទៀតគឺ បុរេបទ បុរេសព្ទ និងផ្នត់ដើម (ច័ន្ទ សំណព្វ, ២០១០: ៨៨)។

**ក១. បុរេបទ**

បុរេបទជាធាតុវេយ្យាករដែលមានលក្ខណៈស្ទើរតែស្វយ័ត ហើយប្រើដាក់នៅខាងដើមវចនសព្ទណាមួយ ដែលជាគុណនាម ឬជាកិរិយាសព្ទ ដើម្បីឱ្យវាក្លាយទៅជានាម។ បុរេបទ មានជាអាទិ៍ *ការ ភាព អ្នក សេចក្តី អំពើ*...។ អាស្រ័យលើលក្ខណៈរបស់វចនសព្ទ គេប្រើបុរេបទផ្សេងៗគ្នាដើម្បីបង្កើតជានាមដែលមានលក្ខណៈខុសៗគ្នាដែរ។

-បុរេបទ «*ការ*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជាកិរិយាសព្ទ ដើម្បីឱ្យកិរិយាសព្ទនោះក្លាយជានាម ឧទាហរណ៍៖ ការ + ដើរ > ការដើរ, ការ + រស់នៅ > ការរស់នៅ, ការ + រាំ > ការរាំ, ការ + ជួបជុំ > ការជួបជុំ...។

-បុរេបទ «*សេចក្តី*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជាគុណនាមឬកិរិយាសព្ទ ដើម្បីឱ្យគុណនាមឬកិរិយាសព្ទនោះក្លាយជានាម ឧទាហរណ៍៖ សេចក្តី + សុខ > សេចក្តីសុខ, សេចក្តី + លំបាក > សេចក្តីលំបាក, សេចក្តី + ព្រួយ > សេចក្តីព្រួយ, សេចក្តី + ពន្យល់ > សេចក្តីពន្យល់, សេចក្តី + គោរព > សេចក្តីគោរព, សេចក្តី + ស្លាប់> សេចក្តីស្លាប់, សេចក្តី + អធិប្បាយ > សេចក្តីអធិប្បាយ, សេចក្តី + សន្និដ្ឋាន > សេចក្តីសន្និដ្ឋាន...។

-បុរេបទ «*ភាព*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជាគុណនាម ដើម្បីឱ្យគុណនាមនោះក្លាយជានាម ឧទាហរណ៍៖ ភាព + ក្លាហាន > ភាពក្លាហាន, ភាព + ងងឹត > ភាពងងឹត, ភាព + ល្ងង់ខ្លៅ > ភាពល្ងង់ខ្លៅ, ភាព + បរិសុទ្ធ> ភាពបរិសុទ្ធ, ភាព + ល្អ > ភាពល្អ, ភាព + ធាត់ > ភាពធាត់, ភាព + ស្គម > ភាពស្គម, ភាព + ត្រឹមត្រូវ> ភាពត្រឹមត្រូវ, ភាព + សមរម្យ > ភាពសមរម្យ, ភាព + ព្រហើន > ភាពព្រហើន...។

-បុរេបទ «*អ្នក*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជាកិរិយាសព្ទ នាម គុណនាម ដើម្បីឱ្យប្រភេទពាក្យទាំងនោះក្លាយជានាម ឧទាហរណ៍៖

«*អ្នក*» ប្រើជាមួយកិរិយា ដូចជា៖ អ្នក + ដើរ > អ្នកដើរ, អ្នក + និយាយ > អ្នកនិយាយ, អ្នក + បញ្ញា > អ្នកបញ្ញា, អ្នក + ស្រាវជ្រាវ > អ្នកស្រាវជ្រាវ, អ្នក + ស្តាប់ > អ្នកស្តាប់...។

«*អ្នក*» ប្រើជាមួយនាម ដូចជា៖ អ្នក + ស្រែ > អ្នកស្រែ, អ្នក + ក្រុង > អ្នកក្រុង, អ្នក + ជំនួញ > អ្នកជំនួញ , អ្នក + ចម្រៀង > អ្នកចម្រៀង, អ្នក + ជំងឺ > អ្នកជំងឺ, អ្នក + ភូមិ > អ្នកភូមិ, អ្នក + ស្រុក > អ្នកស្រុក, អ្នក + ដំណើរ > អ្នកដំណើរ...។

«*អ្នក*» ប្រើជាមួយគុណនាម ដូចជា៖ អ្នក + ក្រ > អ្នកក្រ, អ្នក + មាន > អ្នកមាន, អ្នក + ខ្លាំង > អ្នកខ្លាំង, អ្នក + ខ្សោយ > អ្នកខ្សោយ, អ្នក + តូច > អ្នកតូច, អ្នក + ស្គម > អ្នកស្គម, អ្នក + ធាត់ > អ្នកធាត់, អ្នក + ក្លាហាន > អ្នកក្លាហាន, អ្នក + ពូកែ > អ្នកពូកែ, អ្នក + កំសាក > អ្នកកំសាក...។

-បុរេបទ «*អំពើ*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជាគុណនាម ដើម្បីឱ្យគុណនាមនោះក្លាយជានាម ឧទាហរណ៍៖ អំពើ + ឃោរឃៅ > អំពើឃោរឃៅ, អំពើ + ល្អ > អំពើល្អ, អំពី + អាក្រក់ > អំពើអាក្រក់ , អំពើ + បាប > អំពើបាប, អំពើ + ថោកទាប > អំពើថោកទាប, អំពើ + ព្រៃផ្សៃ > អំពើព្រៃផ្សៃ, អំពើ + ល្ងង់ខ្លៅ > អំពើល្ងង់ខ្លៅ...។

**ក២. បុរេសព្ទ**

បុរេសព្ទ ជារូបសព្ទទាំងឡាយណាដែលប្រើដាក់ភ្ជាប់ខាងដើមព្យាង្គនៃវចនសព្ទមួយ ដើម្បីបញ្ជាក់ពីកម្រិតគុណធាតុនៃបញ្ញត្តិដែលស្តែងតាមរយៈវចនសព្ទនោះ។ វាពុំមានតួនាទីផ្លាស់ប្តូរប្រភេទពាក្យនៃវចនសព្ទនោះទេ។ បុរេសព្ទមានជាអាទិ៍ វិ ទុ សុ បុព្វ បុរេ អតិ ឧប មហា អប្ប...។

-បុរេសព្ទ «*អតិ*» មានន័យថា កន្លង, ក្រៃ, ពេក, ពន់ពេក, ក្រៃលែង, លើស, បំផុត, ណាស់, ហួសពេក, ផុត...។ បុរេសព្ទ «*អតិ*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាមនិងគុណនាម ឧទាហរណ៍៖ អតិ + ចរិយា > អតិចរិយា, អតិ + រេក > អតិរេក, អតិ + គុណ > អតិគុណ, អតិ + បរិមាណ > អតិបរិមាណ, អតិ + វិសេស > អតិវិសេស, អតិ + ទាន > អតិទាន, អតិ + ទេព > អតិទេព...។

-បុរេសព្ទ «*អភិ*» មានន័យថា ក្រៃ, ក្រៃពេក, ឆ្ពោះ, ក្រៃលែង, សង្កត់, គ្របពីលើ...។ បុរេសព្ទ «អភិ» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាមនិងគុណនាម ឧទាហរណ៍៖ អភិ + ក្រម > អភិក្រម, អភិ + ជាត > អភិជាត, អភិ + រក្ស > អភិរក្ស, អភិ + ឃាត > អភិឃាត, អភិ + រូប > អភិរូប, អភិ + មុខ> អភិមុខ, អភិ + ធម្មជាតិ > អភិធម្មជាតិ, អភិ + វឌ្ឍន > អភិវឌ្ឍន, អភិ + ជន > អភិជន...។

-បុរេសព្ទ «*អនុ*» មានន័យថា តាម, រឿយៗ, រង, បន្ទាប់, ក្រោយ, ខាងក្រោយ, តូច...។ បុរេសព្ទ «*អនុ*» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាម ឧទាហរណ៍៖ អនុ + ក្រឹត្យ> អនុក្រឹត្យ, អនុ + ប្រធាន > អនុប្រធាន, អនុ + គណ > អនុគណ, អនុ + សញ្ញា > អនុសញ្ញា, អនុ + រដ្ឋមន្ត្រី> អនុរដ្ឋមន្ត្រី, អនុ + គណៈកម្មការ > អនុគណៈកម្មការ, អនុ + គ្រោះ > អនុគ្រោះ, អនុ + រក្ស > អនុរក្ស...។

-បុរេសព្ទ « *ឧប* » មានន័យថា ជិត, ចូល, ចូលទៅជិត, មាំ...។ បុរេសព្ទ « *ឧប* » ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាម ឧទាហរណ៍៖ ឧប + ភោគ > ឧបភោគ, ឧប + ហេតុ > ឧបហេតុ, ឧប+ ទ្វីប > ឧបទ្វីប , ឧប + នាយករដ្ឋមន្ត្រី > ឧបនាយករដ្ឋមន្ត្រី, ឧប + កិច្ច > ឧបកិច្ច, ឧប + ការី > ឧបការី, ឧប + ទិស > ឧបទិស, ឧប + និស្ស័យ > ឧបនិស្ស័យ...។

-បុរេសព្ទ « *ទុ* » មានន័យថា អាក្រក់, ក្រ, កម្រ, លំបាក...។ បុរេសព្ទ «ទុ» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាម ឧទាហរណ៍៖ ទុ + ឆន្ទៈ > ទុច្ឆន្ទៈ, ទុ + ចរិត > ទុច្ចរិត, ទុ + ទិដ្ឋិ> ទុទ្ទិដ្ឋិ, ទុ + ពល > ទុព្វល , ទុ + ភាសិត > ទុព្ភាសិត, ទុ + វិជ្ជា > ទុព្វិជ្ជា...។

-បុរេសព្ទ «*សុ*» មានន័យថា ងាយ, ស្រួល, ស្រណុក, ល្អ, ប្រពៃ, ណាស់...។ បុរេសព្ទ «សុ» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាម ឧទាហរណ៍៖ សុ + គតិ > សុគតិ, សុ + ចរិត > សុចរិត, សុ + គន្ធ > សុគន្ធ, សុ + វិជ្ជា > សុវិជ្ជា, សុ + វោហារ > សុវោហារ, សុ + ទិដ្ឋិ > សុទិដ្ឋិ...។

-បុរេសព្ទ «*វិ*» មានន័យថា ផ្សេង, ប្លែក, ច្បាស់, ប្រាកដ...។ បុរេសព្ទ «វិ» ប្រើដាក់ខាងដើមវចនសព្ទដែលមានប្រភេទពាក្យជានាមនិងគុណនាម ឧទាហរណ៍៖ វិ + កល > វិកល, វិ + សាមញ្ញ > វិសាមញ្ញ, វិ + បុល > វិបុល , វិ + ញាណ > វិញ្ញាណ, វិ + ចិត្រ > វិចិត្រ, វិ + សេស > វិសេស...។

**ក៣. ផ្នត់ដើម**

ផ្នត់ដើមជាធាតុវេយ្យាករដែលប្រើដាក់នៅខាងដើមព្យញ្ជនៈដើមព្យាង្គនៃឫស ដើម្បីកម្លាយឫសនោះឱ្យកើតបានជាពាក្យថ្មីមួយ។ វាមានលក្ខណៈខុសពីបុរេបទនិងបុរេសព្ទ ដោយសារតែវាមានទម្រង់ច្រើន និងមានតួនាទីទៅតាមទម្រង់នីមួយៗ ហើយលក្ខណៈសម្ព័ន្ធរបស់វាក៏ប្លែកដែរ។ នៅក្នុងទម្រង់នីមួយៗ មានផ្នត់ជាច្រើន ហើយផ្នត់នីមួយៗត្រូវបានប្រើប្រាស់ដោយអនុលោមទៅតាមឫសដែលគេយកមកកម្លាយ។ ដោយផ្អែកទៅលើទម្រង់របស់វា ផ្នត់ដើមខ្លះអាចបង្កើតពាក្យកម្លាយដែលមានប្រភេទពាក្យដូចពាក្យឫស ហើយខ្លះទៀតបង្កើតបានជាពាក្យកម្លាយដែលមានប្រភេទខុសពីពាក្យឫស (ច័ន្ទ សំណព្វ, ២០១០: ៩៤)។

ផ្នត់ដើមមានបួនទម្រង់ គឺទម្រង់ [ព-] [ពស-] [ពសព-] និង[ពពស-]។ ក្នុងទម្រង់នីមួយៗមានផ្នត់ដើមជាច្រើនដែលការប្រើប្រាស់របស់វាអាស្រ័យទៅនឹងព្យញ្ជនៈដើមព្យាង្គនៃឫស។

**-ផ្នត់ដើមទម្រង់ [ព-]**

ផ្នត់ដើមទម្រង់ [ព-] ជាទម្រង់មួយដែលផ្នត់ដើមទាំងអស់សុទ្ធតែកើតឡើងដោយព្យញ្ជនៈទោល ពោលគឺ

គ្មានស្រៈកប់តួ នៅជាមួយទេ។ ផ្នត់ដើមទម្រង់ [ព-] នេះ ប្រើសម្រាប់តែបង្កើតពាក្យមួយព្យាង្គប៉ុណ្ណោះ។ វាស្ថិតនៅខាងដើមពាក្យឫសដែលមានក្នុងទម្រង់[ពស]ឬ[ពសព]។ ក្នុងពាក្យកម្លាយ វាជាព្យញ្ជនៈជាតុទីមួយនៃព្យញ្ជនៈផ្សំដើមព្យាង្គ។ ផ្នត់ដើមទម្រង់[ព-] បញ្ចូលខាងដើមពាក្យឫសទម្រង់[ពស]ឬ[ពសព] បង្កើតបានជាពាក្យកម្លាយទម្រង់ [ពពស]ឬ[ពពសព] ផ្នត់ដើមទម្រង់[ព-] នេះ មានផ្នត់ដើមដូចជា [ក-] [គ-] [ច-] [ជ-] [ត-] [ទ-] [ប-] [ព-] [ម-] [ល-] [ស-] (សូ មុយឃៀង, ២០០៤: ៦-៧)។

ឧទាហរណ៍៖

| **ផ្នត់ដើម** | | **ពាក្យឫស** | | **ពាក្យកម្លាយ** | **ផ្នត់ដើម** | | **ពាក្យឫស** | | **ពាក្យកម្លាយ** |
|---|---|---|---|---|---|---|---|---|---|
| [ក-] | + | បាំង | > | ក្បាំង | [ក-] | + | ដួល | > | ក្ដួល |
| [ក-] | + | បង់ | > | ក្បង់ | [ក-] | + | ងក់ | > | ក្ងក់ |
| [គ-] | + | វាង | > | ឃ្វាង | [គ-] | + | រង | > | គ្រង |
| [គ-] | + | រោង | > | គ្រោង | [គ-] | + | លា | > | ឃ្លា |
| [ច-] | + | រេះ | > | ច្រេះ | [ច-] | + | បង | > | ច្បង |
| [ច-] | + | បូត | > | ច្បូត | [ច-] | + | រាល | > | ច្រាល |
| [ជ-] | + | ងោក | > | ឈ្ងោក | [ជ-] | + | រាំង | > | ជ្រាំង |
| [ជ-] | + | រុល | > | ជ្រុល | [ជ-] | + | រុះ | > | ជ្រុះ |
| [ត-] | + | បៀត | > | ត្បៀត | [ត-] | + | បក | > | ត្បក |
| [ត-] | + | កល់ | > | ថ្កល់ | [ត-] | + | រៀប | > | ត្រៀប |
| [ទ-] | + | រាប | > | ទ្រាប | [ទ-] | + | រឹង | > | ទ្រឹង |
| [ទ-] | + | រេល | > | ទ្រេល | [ទ-] | + | លោ | > | ថ្លោ |
| [ប-] | + | អាប់ | > | ផ្អាប់ | [ប-] | + | ដឹង | > | ប្ដឹង |
| [ប-] | + | រៀន | > | ប្រៀន | [ប-] | + | គួប | > | ផ្គួប |
| [ព-] | + | រាង | > | ព្រាង | [ព-] | + | ង៉ើយ | > | ភ្ងើយ |
| [ព-] | + | ញាក់ | > | ភ្ញាក់ | [ព-] | + | រាយ | > | ព្រាយ |
| [ម-] | + | ចាស់ | > | ម្ចាស់ | [ម-] | + | ជូរ | > | ម្ជូរ |
| [ម-] | + | ហូប | > | ម្ហូប | [ម-] | + | ដុល | > | ម្ដុល |
| [ល-] | + | គាយ | > | ល្គាយ | [ល-] | + | វែង | > | ល្វែង |
| [ល-] | + | ហក់ | > | ល្ហក់ | [ល-] | + | អៀង | > | ល្អៀង |
| [ស-] | + | កក | > | ស្កក | [ស-] | + | បង់ | > | ស្បង់ |
| [ស-] | + | គាល់ | > | ស្គាល់ | [ស-] | + | អាប់ | > | ស្អាប់ |

**-ទម្រង់ [ពស-]**

ផ្នត់ដើមទាំងអស់ដែលស្ថិតក្នុងទម្រង់នេះសុទ្ធតែកើតឡើងដោយការផ្សំរវាងព្យញ្ជនៈទោល និង ស្រៈកប់តួដែលមានសូរវែង។ ផ្នត់ដើមក្នុងទម្រង់នេះ ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ។ ផ្នត់ដើមនេះបញ្ចូលខាងដើមពាក្យឫសមួយព្យាង្គទម្រង់ [ពស-] [ពសព-] [ពពស-] ឬ[ពពសព-] បង្កើតបានជាពាក្យកម្លាយពីរព្យាង្គ។ ក្នុងពាក្យកម្លាយ ផ្នត់នេះជាព្យាង្គទីមួយ នៅខាងដើមពាក្យពីរព្យាង្គ។ ក្នុងសំណេរ ផ្នត់នេះជាព្យញ្ជនៈមួយតួ ព្រោះស្រៈ«អ» ឬ «អ៊» ជាស្រៈកប់តួក្នុងព្យញ្ជនៈ (សូ មុយឃៀង, ២០០៤: ២៩)។

ផ្នត់ដើមនៅក្នុងទម្រង់នេះមានផ្នត់ដើមដូចជា ៖ [ក-] [គ-] [ង-] [ច-] [ជ-] [ញ-] [ត-] [ទ-] [ប៉-] [ព-]

[ម-] [រ-] [ស-]។

ឧទាហរណ៍៖

| ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ | ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| [ក-] | + | កោក | > | កកោក | [ក-] | + | កូរ | > | កកូរ |
| [ក-] | + | កិត | > | កកិត | [ក-] | + | កាយ | > | កកាយ |
| [គ-] | + | គ្រេីម | > | គគ្រេីម | [គ-] | + | គេីម | > | គគេីម |
| [គ-] | + | គ្រុក | > | គគ្រុក | [គ-] | + | គ្រឹម | > | គគ្រឹម |
| [ង-] | + | ងុយ | > | ងងុយ | [ង-] | + | ងុះ | > | ងងុះ |
| [ង-] | + | ងីស | > | ងងីស | [ង-] | + | ងឹត | > | ងងឹត |
| [ច-] | + | ចេះ | > | ចចេះ | [ច-] | + | ចឹក | > | ចចឹក |
| [ច-] | + | ចាក់ | > | ចចាក់ | [ច-] | + | ចុច | > | ចចុច |
| [ជ-] | + | ជីក | > | ជជីក | [ជ-] | + | ជុះ | > | ជជុះ |
| [ជ-] | + | ជ្រក | > | ជជ្រក | [ជ-] | + | ជែក | > | ជជែក |
| [ញ-] | + | ញាក់ | > | ញញាក់ | [ញ-] | + | ញ៉េះ | > | ញញ៉េះ |
| [ញ-] | + | ញ័រ | > | ញញ័រ | [ញ-] | + | ញ៉ោះ | > | ញញ៉ោះ |
| [ត-] | + | ត្រឹក | > | តត្រឹក | [ត-] | + | តោង | > | តតោង |
| [ត-] | + | តុប | > | តតុប | [ត-] | + | តូង | > | តតូង |
| [ទ-] | + | ទះ | > | ទទះ | [ទ-] | + | ទ្រេត | > | ទទ្រេត |
| [ទ-] | + | ទាក់ | > | ទទាក់ | [ទ-] | + | ទ្រោត | > | ទទ្រោត |
| [ប៉-] | + | ប៉ាច់ | > | ប៉ប៉ាច់ | [ប៉-] | + | ប្រាវ | > | ប៉ប្រាវ |
| [ប៉-] | + | ប៉ប់ | > | ប៉ប៉ប់ | [ប៉-] | + | ប៉ះ | > | ប៉ប៉ះ |
| [ព-] | + | ពុះ | > | ពពុះ | [ព-] | + | ពួក | > | ពពួក |
| [ព-] | + | ភ្លី | > | ពភ្លី | [ព-] | + | ភ្លើ | > | ពភ្លើ |
| [ម-] | + | មាំង | > | មមាំង | [ម-] | + | ម៉េះ | > | មម៉េះ |
| [ម-] | + | ម៉ោះ | > | មម៉ោះ | [ម-] | + | មិង | > | មមិង |
| [រ-] | + | ដក | > | រដក | [រ-] | + | បត់ | > | របត់ |
| [រ-] | + | មួល | > | រមួល | [រ-] | + | អ៊ូ | > | រអ៊ូ |
| [រ-] | + | សាច | > | រសាច | [រ-] | + | ខក | > | រខក |
| [ស-] | + | សោះ | > | សសោះ | [ស-] | + | សិត | > | សសិត |
| [ស-] | + | សៀរ | > | សសៀរ | [ស-] | + | ស្រាក់ | > | សស្រាក់ |

**-ទម្រង់ [ពពស-]**

ផ្នត់ដើមទម្រង់ [ពពស-] កើតមកអំពីសទ្ទតាបីគឺ ព្យញ្ជនៈ + ព្យញ្ជនៈ + ស្រៈ។ ផ្នត់ដើមទម្រង់នេះ ប្រើសម្រាប់បង្កើតពាក្យកម្លាយពីរព្យាង្គ។ ផ្នត់ដើមទម្រង់[ពពស-]នេះ បញ្ចូលខាងដើមពាក្យឫសមួយព្យាង្គ ទម្រង់ [ពស-] [ពសព-] [ពពស-] ឬ[ពពសព-] បង្កើតបានជាពាក្យកម្លាយពីរព្យាង្គ។ ក្នុងពាក្យកម្លាយពីរព្យាង្គ ផ្នត់ដើមទម្រង់[ពពស-] ជាព្យាង្គទី១ នៅខាងដើមពាក្យកម្លាយ។ ក្នុងសំណេរ ផ្នត់ដើមទម្រង់[ពពស-] ជាព្យញ្ជនៈត្រួតគ្នា ព្រោះស្រៈ «អ» ឬ ស្រៈ«អិ» ជាស្រៈកប់តួក្នុងព្យញ្ជនៈ។

ផ្នត់ដើមទម្រង់ [ពពស-]នេះ មានផ្នត់ដើមដូចជា [ក្រ-] [គ្រ-] [ប្រ-] [ជ្រ-] [ត្រ-] [ទ្រ-] [ប្រ-] [ព្រ-] [ស្រ-]។

ឧទាហរណ៍៖

| ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ | ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| [ក្រ-] | + | ពាត់ | > | ក្រពាត់ | [ក្រ-] | + | ចាប់ | > | ក្រចាប់ |
| [ក្រ-] | + | ហល់ | > | ក្រហល់ | [ក្រ-] | + | វៀច | > | ក្រវៀច |
| [គ្រ-] | + | ដាំ | > | គ្រដាំ | [គ្រ-] | + | ញឹក | > | គ្រញឹក |
| [គ្រ-] | + | វី | > | គ្រវី | [គ្រ-] | + | វែង | > | គ្រវែង |
| [ច្រ-] | + | បូក | > | ច្របូក | [ច្រ-] | + | លោត | > | ច្រលោត |
| [ច្រ-] | + | អូស | > | ច្រអូស | [ច្រ-] | + | បូញ | > | ច្របូញ |
| [ជ្រ-] | + | មុជ | > | ជ្រមុជ | [ជ្រ-] | + | ងក់ | > | ជ្រងក់ |
| [ត្រ-] | + | ដុស | > | ត្រដុស | [ត្រ-] | + | កង | > | ត្រកង |
| [ត្រ-] | + | បក | > | ត្របក | [ត្រ-] | + | ឈឹង | > | ត្រឈឹង |
| [ទ្រ-] | + | ទន់ | > | ទ្រទន់ | [ទ្រ-] | + | ហ៊ឹង | > | ទ្រហឹង |
| [ទ្រ-] | + | វៀច | > | ទ្រវៀច | [ទ្រ-] | + | ហ៊ោ | > | ទ្រហោ |
| [ប្រ-] | + | ខាំ | > | ប្រខាំ | [ប្រ-] | + | កាប់ | > | ប្រកាប់ |
| [ប្រ-] | + | ចាក់ | > | ប្រចាក់ | [ប្រ-] | + | ដែង | > | ប្រដែង |
| [ប្រ-] | + | សាច | > | ប្រសាច | [ប្រ-] | + | វែង | > | ប្រវែង |
| [ព្រ-] | + | ងើយ | > | ព្រងើយ | [ព្រ-] | + | រឹត | > | ព្ររឹត |
| [ព្រ-] | + | វារ | > | ព្រវារ | [ព្រ-] | + | លប់ | > | ព្រលប់ |
| [ស្រ-] | + | កាក | > | ស្រកាក | [ស្រ-] | + | ពេច | > | ស្រពេច |
| [ស្រ-] | + | ងាក | > | ស្រងាក | [ស្រ-] | + | អាប់ | > | ស្រអាប់ |

**-ទម្រង់ [ពសព-]**

ផ្នត់ដើមទម្រង់ [ពសព-] កើតមកអំពីសទ្ទតាបីគឺ ព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ។ ផ្នត់ដើមទម្រង់ [ពសព-] នេះ ប្រើសម្រាប់បង្កើតពាក្យកម្លាយពីរព្យាង្គ។ ផ្នត់ដើមទម្រង់ [ពសព-]នេះ បញ្ចូលខាងដើមពាក្យឫសមួយព្យាង្គ ទម្រង់ [ពស-] [ពសព-] [ពពស-] ឬ[ពពសព-] បង្កើតបានជាពាក្យកម្លាយពីរព្យាង្គ។ ក្នុងពាក្យកម្លាយពីរព្យាង្គ ផ្នត់ដើមទម្រង់ [ពសព-] ជាព្យាង្គទី១ នៅខាងដើមពាក្យកម្លាយ។ ក្នុងសំណេរ ផ្នត់ដើមទម្រង់ [ពសព-] ជាព្យញ្ជនៈពីរតួ ព្រោះស្រៈ «អ» ឬស្រៈ «អ៊» ជាស្រៈកប់តួក្នុងព្យញ្ជនៈ។

ផ្នត់ដើមទម្រង់នេះមានផ្នត់ច្រើនជាងគេ។ ផ្នត់ដើមទាំងនោះរួមមានដូចជា [ក´ង-] [ក´ញ-] [ក´ន-] [ក´ម-] [ច´ង-] [ប´ង-] [ប´ញ-] [ប´ន-] [ប´ម-] [ស´ង-] [ស´ន-] [ស´ម-] [អ´ង-] [អ´ម-] ។ល។

ឧទាហរណ៍៖

| ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ | ផ្នត់ដើម | | ពាក្យឫស | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| [ក´ង-] | + | ក្ងួច | > | កង្គួច | [ក´ង-] | + | វល់ | > | កង្វល់ |
| [ក´ញ-] | + | ចាស់ | > | កញ្ចាស់ | [ក´ញ-] | + | ជួ | > | កញ្ជួ |
| [ក´ន-] | + | ជាត់ | > | កន្ទាត់ | [ក´ន-] | + | លង | > | កន្លង |
| [ក´ម-] | + | ប៉ោង | > | កំប៉ោង | [ក´ម-] | + | បាក់ | > | កំបាក់ |
| [ច´ង-] | + | គ្រោង | > | ចង្ក្រោង | [ច´ង-] | + | អូរ | > | ចង្អូរ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| [ច´ម-] | + | កោង | > | ចំកោង | | [ច´ម-] | + | បែង | > | ចំបែង |
| [ជ´ម-] | + | ទប់ | > | ជំទប់ | | [ជ´ម-] | + | ទាស់ | > | ជំទាស់ |
| [ប´ង-] | + | កក | > | បង្កក | | [ប´ង-] | + | វិល | > | បង្វិល |
| [ប´ញ-] | + | ឈរ | > | បញ្ឈរ | | [ប´ញ-] | + | ចប់ | > | បញ្ចប់ |
| [ប´ន-] | + | ទន់ | > | បន្ទន់ | | [ប´ន-] | + | ថយ | > | បន្ថយ |
| [ប´ម-] | + | បាត់ | > | បំបាត់ | | [ប´ម-] | + | ផត | > | បំផត |
| [ប´ម-] | + | ភ័យ | > | បំភ័យ | | [ប´ម-] | + | ពង | > | បំពង |
| [ប´ម-] | + | បាក់ | > | បំបាក់ | | [ប´ម-] | + | បែប | > | បំបែក |
| [រ´ង-] | + | វង់ | > | រង្វង់ | | [រ´ង-] | + | វាស់ | > | រង្វាស់ |
| [រ´ម-] | + | កិល | > | រំកិល | | [រ´ម-] | + | អុក | > | រំអុក |
| [ល´ន-] | + | លឹម | > | លន្លឹម | | [ល´ន-] | + | លង់ | > | លន្លង់ |
| [ល´ម-] | + | នឹង | > | លំនឹង | | [ល´ម-] | + | នាច | > | លំនាច |
| [ស´ង-] | + | រួម | > | សង្រួម | | [ស´ង-] | + | កត់ | > | សង្កត់ |
| [ស´ន-] | + | សើម | > | សន្សើម | | [ស´ន-] | + | ដក | > | សណ្ដក |
| [ស´ម-] | + | ចត | > | សំចត | | [ស´ម-] | + | បក | > | សំបក |
| [អ´ង-] | + | កុញ | > | អង្កុញ | | [អ´ង-] | + | គប់ | > | អង្គប់ |
| [អ´ន-] | + | ទាក់ | > | អន្ទាក់ | | [អ´ន-] | + | ទ្រក់ | > | អន្ទ្រក់ |
| [អ´ម-] | + | ពល់ | > | អំពល់ | | [អ´ម-] | + | បោស | > | អំបោស |

**ខ. ផ្នត់ដែក**

-ផ្នត់ដែក ជារូបសព្ទប្រើដាក់នៅចន្លោះធាតុនៃពាក្យឫសមួយ ដើម្បីកម្លាយវាឱ្យកើតបានទៅជាពាក្យថ្មីមួយ។ ដោយអនុលោមទៅតាមលក្ខណៈនៃពាក្យឫស និងទម្រង់ផ្នត់ដែលគេប្រើពាក្យកម្លាយដែលបានមកអាចមានប្រភេទពាក្យដូចគ្នាឬមិនដូចគ្នានឹងពាក្យឫស (ច័ន្ទ សំណព្វ, ២០១០: ១១២)។

បើផ្អែកទៅលើការសិក្សាស្រាវជ្រាវនិងការប្រមូលទិន្នន័យនៅក្នុងភាសាខ្មែរបច្ចុប្បន្ន ផ្នត់ដែកទាំងអស់មាន ៤ទម្រង់គឺ៖ ទម្រង់ [-ព-] [-សព-] [-ស/ព-] និង[-សព/ព-]។

**ផ្នត់ដែកទម្រង់ [-ព-]**

ផ្នត់ដែកទម្រង់ [-ព-] កើតមកអំពីព្យញ្ជនៈទោលតែមួយ គ្មានស្រៈកប់តួនៅជាមួយឡើយ។ ផ្នត់ដែកទម្រង់ [-ព-]នេះ ប្រើសម្រាប់បង្កើតតែពាក្យមួយព្យាង្គប៉ុណ្ណោះ។ ផ្នត់ដែកទម្រង់ [-ព-]នេះ ស្ថិតនៅតែខាងក្នុងពាក្យឫសមួយព្យាង្គដែលមានទម្រង់ [ពស]ឬ[ពសព]។ ក្នុងពាក្យកម្លាយ វាជាព្យញ្ជនៈជាតុទីពីរនៃព្យញ្ជនៈផ្សំដើមព្យាង្គ។ ផ្នត់ដែកទម្រង់[-ព-] បញ្ចូលខាងក្នុងពាក្យឫសទម្រង់[ពស]ឬ[ពសព] បង្កើតបានជាពាក្យកម្លាយមួយព្យាង្គទម្រង់[ពពស]ឬ[ពពសព]។

ផ្នត់ដែកក្នុងពេលនេះ គឺការយកផ្នត់ដែកទៅភ្ជាប់នៅខាងក្នុងពាក្យឫសត្រង់ចន្លោះព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសនិងស្រៈនៃពាក្យឫស ដោយផ្សំព្យញ្ជនៈនៃផ្នត់ដែកទម្រង់ [-ព-] និងព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសទម្រង់[ពស]ឬ[ពសព] ឱ្យទៅជាព្យញ្ជនៈផ្សំដើមព្យាង្គនៃពាក្យកម្លាយ។ ក្នុងពាក្យកម្លាយ ព្យញ្ជនៈផ្សំដើមព្យាង្គមានជាតុពីរ ផ្នត់ដែកក្លាយជាជាតុទីពីរនៃព្យញ្ជនៈផ្សំដើមព្យាង្គនៃពាក្យកម្លាយ ឯព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសក្លាយជាជាតុទីមួយ នៃព្យញ្ជនៈផ្សំដើមព្យាង្គនៃពាក្យកម្លាយ (សូ មុយឃៀង, ២០០៤:១-២)។

ផ្នត់ដែកនៅក្នុងទម្រង់នេះមានផ្នត់ដែកដូចជា [-ង-] [-ន-] [-ប-] [-ម-] [-រ-] [-ល-] [-វ-]។

ឧទាហរណ៍៖

| ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ | ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| កុក | + | [-ង-] | > | ក្ងុក | កង់ | + | [-ង-] | > | ក្ងង់ |
| កែង | + | [-ង-] | > | ក្ងែង | សោយ | + | [-ង-] | > | ស្ងោយ |
| កាយ | + | [-ន-] | > | ខ្នាយ | កោស | + | [-ន-] | > | ខ្នោស |
| ធូត | + | [-ន-] | > | ធ្នូត | ជាន់ | + | [-ន-] | > | ឈ្នាន់ |
| ដេរ | + | [-ន-] | > | ថ្នេរ | សប់ | + | [-ន-] | > | ស្នប់ |
| កាច់ | + | [-ប-] | > | ក្បាច់ | លឿន | + | [-ប-] | > | ល្បឿន |
| លប់ | + | [-ប-] | > | ល្បប់ | ចូក | + | [-ប-] | > | ច្បូក |
| ចាំ | + | [-ម-] | > | ឆ្មាំ | ជួញ | + | [-ម-] | > | ឈ្មួញ |
| សិត | + | [-ម-] | > | ស្មិត | សូម | + | [-ម-] | > | ស្មូម |
| ចាល់ | + | [-រ-] | > | ប្រាល់ | ជួញ | + | [-រ-] | > | ជ្រួញ |
| ដែក | + | [-រ-] | > | ជ្រែក | បោះ | + | [-រ-] | > | ប្រោះ |
| កែម | + | [-ល-] | > | ក្លែម | កៀក | + | [-ល-] | > | ក្លៀក |
| កេះ | + | [-វ-] | > | ខ្វេះ | កែង | + | [-វ-] | > | ខ្វែង |

**ផ្នត់ដែកទម្រង់ [-សព-]**

ផ្នត់ដែកទម្រង់ [-សព-] កើតមកអំពីសទ្ទតាពីរគឺ ស្រៈ + ព្យញ្ជនៈ។ ស្រៈអាចជាស្រៈ «អ»ឬស្រៈ «អ៊» (ស្រៈខ្លី)។ ក្នុងសំណេរ ស្រៈនេះកប់ក្នុងព្យញ្ជនៈ។ ផ្នត់ដែកទម្រង់ [-សព-]នេះ ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ ប៉ុណ្ណោះ។ ផ្នត់ដែកទម្រង់ [-សព-]នេះ បញ្ចូលខាងក្នុងពាក្យឫសមួយព្យាង្គទម្រង់ [ពពស]ឬ[ពពសព] បង្កើតបានជាពាក្យកម្លាយពីរព្យាង្គទម្រង់[ពសព/ពស]ឬ[ពសព/ពសព]។ ក្នុងពាក្យកម្លាយ ផ្នត់ដែកទម្រង់[-សព-]និងព្យញ្ជនៈជាតុទីមួយនៃព្យញ្ជនៈផ្សំដើមព្យាង្គនៃពាក្យឫស បង្កើតបានជាព្យាង្គទីមួយនៅខាងដើមពាក្យពីរព្យាង្គ។ ក្នុងសំណេរពាក្យកម្លាយ ផ្នត់នេះជាព្យញ្ជនៈមួយតួ ព្រោះស្រៈ «អ»ឬ«អ៊» ជាស្រៈកប់តួក្នុងព្យញ្ជនៈ (សូ មុយឃៀង, ២០០៤: ២៦-២៧)។

ផ្នត់ដែកនៅក្នុងទម្រង់នេះមានផ្នត់ដូចជា [-អ ង-] [-អ៊ ង-] [-អ ញ-] [-អ ន-] [-អ៊ ន-] [-អ ម-] [-អ៊ ម-]។

ឧទាហរណ៍៖

| ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ | ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| ខ្វល់ | + | [-អ ង-] | > | កង្វល់ | ខ្វះ | + | [-អ ង-] | > | កង្វះ |
| ឆ្អើរ | + | [-អ ង-] | > | ចង្អើរ | ថ្វាយ | + | [-អ ង-] | > | តង្វាយ |
| ឃ្វាល | + | [-អ៊ ង-] | > | គង្វាល | ធ្វើ | + | [-អ៊ ង-] | > | ទង្វើ |
| ព្រាត់ | + | [-អ៊ ង-] | > | ពង្រាត់ | ព្រោះ | + | [-អ៊ ង-] | > | ពង្រោះ |
| ផ្ញើ | + | [-អ ញ-] | > | បញ្ញើ | ខ្ទប់ | + | [-អ ញ-] | > | កញ្ចប់ |
| ខ្ជោត | + | [-អ ញ-] | > | កញ្ជោត | ខ្ចក | + | [-អ ញ-] | > | កញ្ចក |
| ខ្លាស់ | + | [-អ ន-] | > | កន្លាស់ | ស្ទះ | + | [-អ ន-] | > | សន្ទះ |
| ផ្ទុក | + | [-អ ន-] | > | បន្ទុក | ផ្លាស់ | + | [-អ ន-] | > | បន្លាស់ |
| ប្ដឹង | + | [-អ ន-] | > | បណ្ដឹង | ផ្ដាំ | + | [-អ ន-] | > | បណ្ដាំ |
| ភ្លឺ | + | [-អ៊ ន-] | > | ពន្លឺ | ធ្លាក់ | + | [-អ៊ ន-] | > | ទន្លាក់ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ភ្លឹក | + | [-អ៊´ន-] | > | ពន្លឹក | ភ្លូក | + | [-អ៊´ន-] | > | ពន្លូក |
| ត្រូវ | + | [-អ´ម-] | > | តម្រូវ | ខ្លាំង | + | [-អ´ម-] | > | កម្លាំង |
| ឆ្ងាយ | + | [-អ´ម-] | > | ចម្ងាយ | ប្រើ | + | [-អ´ម-] | > | បម្រើ |
| ស្តី | + | [-អ´ម-] | > | សម្តី | ស្រាយ | + | [-អ´ម-] | > | សម្រាយ |
| ឃើញ | + | [-អ៊´ម-] | > | គំហើញ | គ្រោង | + | [-អ៊´ម-] | > | គម្រោង |
| ជ្រៅ | + | [-អ៊´ម-] | > | ជម្រៅ | ធ្ងន់ | + | [-អ៊´ម-] | > | ទម្ងន់ |
| ជ្រក | + | [-អ៊´ម-] | > | ជម្រក | ឈាន | + | [-អ៊´ម-] | > | ជំហាន |

**ផ្នត់ដែកទម្រង់ [-ស/ព-]**

ផ្នត់ដែកទម្រង់ [-ស/ព-] កើតមកអំពីសទ្ទតាពីរដែលបំបែកគ្នាដោយគំនូសឬបារទ្រេត (/) គឺស្រៈនិងព្យញ្ជនៈ។ ស្រៈអាចជាស្រៈ «អ៊ិ» (ស្រៈខ្លី) ។ នៅក្នុងសំណេរ ស្រៈនេះកប់ក្នុងព្យញ្ជនៈ។ ផ្នត់ដែកទម្រង់ [-ស/ព-] នេះ ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ។ ផ្នត់ដែកទម្រង់ [-ស/ព-]នេះ បញ្ចូលខាងក្នុងពាក្យឫសមួយព្យាង្គទម្រង់ [ពស]ឬ[ពសព] បង្កើតបានជាពាក្យកម្លាយទម្រង់ [ពស/ពស] ឬ[ពស/ពសព]។ ក្នុងពាក្យកម្លាយ ស្រៈនៃផ្នត់ដែកទម្រង់ [-ស/ព-] ផ្សំនឹងព្យញ្ជនៈដើមព្យាង្គនៃពាក្យឫស ឯព្យញ្ជនៈនៃផ្នត់ដែកទម្រង់ [-ស/ព-] ផ្សំនឹងស្រៈនៃពាក្យឫស។

ផ្នត់ដែកសំខាន់ៗស្ថិតក្នុងទម្រង់នេះមានដូចជា [-អ៊ិ/ន-] [-អ៊ិ/ប-] [-អ៊ិ/ម-] [-អ៊ិ/ល-]។

ឧទាហរណ៍៖

| **ពាក្យឫស** | | **ផ្នត់ដែក** | | **ពាក្យកម្លាយ** | **ពាក្យឫស** | | **ផ្នត់ដែក** | | **ពាក្យកម្លាយ** |
|---|---|---|---|---|---|---|---|---|---|
| រាំង | + | [-អ៊ិ/ន-] | > | រនាំង | រាស់ | + | [-អ៊ិ/ន-] | > | រនាស់ |
| រាប | + | [-អ៊ិ/ន-] | > | រនាប | រុក | + | [-អ៊ិ/ន-] | > | រនុក |
| រង | + | [-អ៊ិ/ន-] | > | រនង | រូត | + | [-អ៊ិ/ន-] | > | រនូត |
| រោយ | + | [-អ៊ិ/ប-] | > | របោយ | រង | + | [-អ៊ិ/ប-] | > | របង |
| រៀន | + | [-អ៊ិ/ប-] | > | របៀន | រាំ | + | [-អ៊ិ/ប-] | > | របាំ |
| រៀប | + | [-អ៊ិ/ប-] | > | របៀប | រាប់ | + | [-អ៊ិ/ប-] | > | របាប់ |
| រត់ | + | [-អ៊ិ/ម-] | > | រមត់ | រៀល | + | [-អ៊ិ/ម-] | > | រមៀល |
| រែង | + | [-អ៊ិ/ម-] | > | រមែង | ទ្រក់ | + | [-អ៊ិ/ម-] | > | ទ្រមក់ |
| ជ្រង | + | [-អ៊ិ/ល-] | > | ជ្រលង | ជ្រួស | + | [-អ៊ិ/ល-] | > | ជ្រលួស |
| រេ | + | [-អ៊ិ/ល-] | > | រលេ | រឹង | + | [-អ៊ិ/ល-] | > | រលឹង |

**ផ្នត់ដែកទម្រង់ [-សព/ព-]**

ផ្នត់ដែកទម្រង់[-សព/ព-] កើតមកអំពីសទ្ទតាបីដែលបំបែកគ្នាដោយគំនូសឬបារទ្រេត(/)គឺស្រៈ+ព្យញ្ជនៈនិងព្យញ្ជនៈ។ ស្រៈអាចជាស្រៈ «អ» ឬស្រៈ«អ៊ិ» (ស្រៈខ្លី)។ ក្នុងសំណេរ ស្រៈនេះកប់ត្លក្នុងព្យញ្ជនៈដើមព្យាង្គ។ ផ្នត់ដែកទម្រង់ [-សព/ព-]នេះ ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ។ ផ្នត់ដែកទម្រង់ [-សព/ព-]នេះ បញ្ចូលខាងក្នុងពាក្យឫសមួយព្យាង្គទម្រង់ [ពស]ឬ[ពសព] បង្កើតបានជាពាក្យកម្លាយទម្រង់ [ពសព/ពស] ឬ [ពសព/ពសព]។ ក្នុងពាក្យកម្លាយ ជាតុទីមួយ (ស្រៈ) នៃផ្នត់ដែកទម្រង់ [-សព/ព-] ផ្សំនឹងព្យញ្ជនៈដើមព្យាង្គនៃពាក្យឫស។ ឯជាតុទីបីនៃផ្នត់ដែកទម្រង់[-សព/ព-] ផ្សំនឹងស្រៈនៃពាក្យឫស (សូ មុយឃៀង, ២០០៤: ៣១-៣២)។

ផ្នត់ដែកនៅក្នុងទម្រង់នេះមានដូចជា [-អ´ម/ណ-] [-អ៊´ម/ន-] និង[-អ´ម/ប-]។

ឧទាហរណ៍៖

| ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ | ពាក្យឫស | | ផ្នត់ដែក | | ពាក្យកម្លាយ |
|---|---|---|---|---|---|---|---|---|---|
| កាច | + | [-អ´ម/ណ-] | > | កំណាច | កាត់ | + | [-អ´ម/ណ-] | > | កំណាត់ |
| កើន | + | [-អ´ម/ណ-] | > | កំណើន | ចោទ | + | [-អ´ម/ណ-] | > | ចំណោទ |
| ចាស់ | + | [-អ´ម/ណ-] | > | ចំណាស់ | ចង | + | [-អ´ម/ណ-] | > | ចំណង |
| ត | + | [-អ´ម/ណ-] | > | តំណ | កើត | + | [-អ´ម/ណ-] | > | កំណើត |
| បន់ | + | [-អ´ម/ណ-] | > | បំណន់ | ដើរ | + | [-អ´ម/ណ-] | > | ដំណើរ |
| ចាយ | + | [-អ´ម/ណ-] | > | ចំណាយ | ដេក | + | [-អ´ម/ណ-] | > | ដំណេក |
| បន់ | + | [-អ´ម/ណ-] | > | បំណន់ | សើម | + | [-អ´ម/ណ-] | > | សំណើម |
| សាង | + | [-អ´ម/ណ-] | > | សំណាង | អាច | + | [-អ´ម/ណ-] | > | អំណាច |
| គាប | + | [-អ៊ិ´ម/ន-] | > | គំនាប | គូរ | + | [-អ៊ិ´ម/ន-] | > | គំនូរ |
| គុំ | + | [-អ៊ិ´ម/ន-] | > | គំនុំ | គូស | + | [-អ៊ិ´ម/ន-] | > | គំនូស |
| ជាន់ | + | [-អ៊ិ´ម/ន-] | > | ជំនាន់ | ជូន | + | [-អ៊ិ´ម/ន-] | > | ជំនូន |
| ជួយ | + | [-អ៊ិ´ម/ន-] | > | ជំនួយ | ជោរ | + | [-អ៊ិ´ម/ន-] | > | ជំនោរ |
| ទាក់ | + | [-អ៊ិ´ម/ន-] | > | ទំនាក់ | ទាស់ | + | [-អ៊ិ´ម/ន-] | > | ទំនាស់ |
| ទាញ | + | [-អ៊ិ´ម/ន-] | > | ទំនាញ | ទិញ | + | [-អ៊ិ´ម/ន-] | > | ទំនិញ |
| ទុក | + | [-អ៊ិ´ម/ន-] | > | ទំនុក | ទួញ | + | [-អ៊ិ´ម/ន-] | > | ទំនួញ |
| ពូត | + | [-អ៊ិ´ម/ន-] | > | ពំនូត | ពោល | + | [-អ៊ិ´ម/ន-] | > | ពំនោល |
| ចាប់ | + | [-អ´ម/ប-] | > | ចំបាប់ | ដង | + | [-អ´ម/ប-] | > | ដំបង |
| ដុត | + | [-អ´ម/ប-] | > | ដំបុត | ដួច | + | [-អ´ម/ប-] | > | ដំបួច |

**គ. បច្ឆិមបទ**

បច្ឆិមបទ គឺជារូបសព្ទដែលគេប្រើបន្ថែមភ្ជាប់ពីខាងក្រោយជាតុឫសណាមួយ ដើម្បីកែប្រែន័យដើមនៃជាតុឫសនេះ ហើយបង្កើតបានជាពាក្យផ្សេងៗទៀត។ បច្ឆិមបទ ត្រូវបានគេប្រើជាមួយនឹងជាតុឫសកម្ចីពីភាសាបាលី-សំស្ក្រឹត ចំណែកឯនៅក្នុងភាសាខ្មែរសុទ្ធៗ ពុំមានបច្ឆិមបទទេ។ វាគ្មានស្វ័យភាពផ្នែកសម្ព័ន្ធទេ ហើយវាត្រូវបានប្រើសម្រាប់ដាក់ផ្សំនៅខាងចុងជាតុឫសតាមបន្សំបែបបាលី-សំស្ក្រឹតដើម្បីបង្កើតពាក្យថ្មី។ បច្ឆិមបទក៏មានតួនាទីធ្វើឱ្យជាតុឫសប្រែប្រួលប្រភេទពាក្យ ភេទ ឬន័យ។ល។

បច្ឆិមបទ មានដូចជា ភាព ការ កិច្ច កម្ម ករ ការិនី ជន វិទូ សាស្ត្រ វិទ្យា និយម ។ល។

ឧទាហរណ៍៖

| | | | | | |
|---|---|---|---|---|---|
| សកម្ម + ភាព | > សកម្មភាព | តថ + ភាព > | តថភាព | សច្ច + ភាព | > សច្ចភាព |
| កុមារ + ភាព | > កុមារភាព | ជីវ + ភាព > | ជីវភាព | គុណ + ភាព | > គុណភាព |
| វិក្រឹត + ការ | > វិក្រឹតការ | ក្រម + ការ > | ក្រមការ | ពលិ + ការ | > ពលិការ |
| ពល + ករ | > ពលករ | កសិ + ករ > | កសិករ | ពាណិជ្ជ + ករ | > ពាណិជ្ជករ |
| បាតុ + ករ | > បាតុករ | វិចិត្រ + ករ > | វិចិត្រករ | ឧស្សាហ + ករ | > ឧស្សាហករ |
| ហត្ថ + កម្ម | > ហត្ថកម្ម | កសិ + កម្ម > | កសិកម្ម | ពាណិជ្ជ + កម្ម | > ពាណិជកម្ម |
| ភារ + កិច្ច | > ភារកិច្ច | សេដ្ឋ + កិច្ច > | សេដ្ឋកិច្ច | ទស្សន + កិច្ច | > ទស្សនកិច្ច |
| សកម្ម + ជន | > សកម្មជន | បេក្ខ + ជន > | បេក្ខជន | បេសក + ជន | > បេសកជន |
| ភាសា + វិទូ | > ភាសាវិទូ | គីមី + វិទូ > | គីមីវិទូ | ទស្សន + វិទូ | > ទស្សនវិទូ |

| | | | | | |
|---|---|---|---|---|---|
| ភាសា + វិទ្យា | > ភាសាវិទ្យា | រូប + វិទ្យា | > រូបវិទ្យា | សង្គម + វិទ្យា | > សង្គមវិទ្យា |
| សង្គម + និយម | > សង្គមនិយម | រាជា+និយម | > រាជានិយម | សម្ភារ + និយម | > សម្ភារនិយម។ |

**២.៣. ភាឡារូប**

ពាក្យ «កាឡារូប» សមមូលទៅនឹងពាក្យ «Allomorph» នៃភាសាអង់គ្លេស និង «Allomorphe» នៃភាសាបារាំង។ គណៈកម្មាធិការជាតិភាសាខ្មែរក៏បានអនុម័តនិងកំណត់និយមន័យថា៖ «រូបផ្សេងៗរបស់រូបតាដែលអាចប្ដូររូបទៅតាមបរិបទ ដូចរូបសព្ទ /-s/ នៃពហុវចនៈរបស់នាមសព្ទអង់គ្លេសដែលអាចមានកាឡារូប [-s] ក្នុងពាក្យ books, [-z] ក្នុងពាក្យ dogs, [-iz] ក្នុងពាក្យ boxes» ។

លោក ថូម៉ាស ផេនី ក៏បានកំណត់និយមន័យស្រដៀងគ្នានេះផងដែរ ដោយលោកបានឱ្យនិយមន័យថា៖ «រូបផ្សេងៗរបស់រូបតាដែលមានលក្ខណៈជាប្រព័ន្ធ»។ លោកបានអះអាងថែមទៀតថា៖ «ការបញ្ជាក់បរិបទនៃកាឡារូបគឺទាក់ទងទៅនឹងដំណាក់កាលពីរ៖ (១) ធ្វើបញ្ជីបរិបទនិង(២) ធ្វើឱកាសកម្មបរិបទ»។

ចំពោះការវិភាគកាឡារូបវិញ គេអាចធ្វើទៅតាមវិធីពីរយ៉ាងផ្សេងគ្នា។ លោកស្រី ជីន អាជីសិន (Jean Aitchison) បានអះអាងថា «គេអាចវិភាគរកកាឡារូបតាមវិធីពីរយ៉ាងគឺលក្ខខណ្ឌសទ្ទតានិងលក្ខខណ្ឌវចនសព្ទ»។ ចំណែកលោក វ៉ាយ បូលីងជើ វិញក៏បានអះអាងថាមានវិធីពីរយ៉ាង នៅក្នុងវិភាគនិងពិពណ៌នាកាឡារូបផងដែរ។ លោកបានលើកឡើងថា «យើងមានវិធីសាស្ត្រពីរយ៉ាងផ្សេងគ្នា ដើម្បីពិពណ៌នាកាឡារូប។ ទីមួយ គឺលក្ខខណ្ឌសទ្ទតានិងទីពីរ លក្ខខណ្ឌរូបសាស្ត្រ»។

លក្ខខណ្ឌសទ្ទតានៅក្នុងភាសាអង់គ្លេស អាចធ្វើឱ្យយើងដឹងបានថា តើរូបតាមានលក្ខណៈពិសេសបែបណា។ លក្ខខណ្ឌនេះអាចអនុវត្តបានចំពោះការបញ្ចេញសំឡេងរបស់ពាក្យមួយ បានពីរសំឡេងអាស្រ័យទៅតាមបរិបទ។ ជាពិសេសទៅទៀតនោះ លក្ខខណ្ឌនេះមានជាប់ទាក់ទងទៅនឹងការបញ្ចេញសំឡេងពាក្យពហុវចនៈរបស់នាមសព្ទ ចំណែកភាសាខ្មែរទម្រង់ពហុវចនៈ មិនអាចកើតមានឡើងបានដូចភាសាអង់គ្លេសនោះបានទេ ពីព្រោះថាពាក្យមួយនៅក្នុងភាសាខ្មែរ យើងអាចអានឬបញ្ចេញសំឡេងបានតែមួយ ទោះបីជាវានៅក្នុងបរិបទបែបណាក៏ដោយ។ ម្យ៉ាងវិញទៀត ភាសាខ្មែរមិនមានទម្រង់ពាក្យនៅក្នុងនាមសព្ទជាពហុវចនៈទេ អាស្រ័យហេតុនេះការបញ្ចេញសំឡេងនាមសព្ទក៏មិនមានអ្វីប្រែប្រួលដែរ ពោលគឺទាំងឯកវចនៈនិងពហុវចនៈនៅរក្សាសំឡេងនិងរូបដដែល។ ជាលទ្ធផល លក្ខខណ្ឌខាងលើមិនអាចកត់សម្គាល់កាឡារូបបានពិតប្រាកដនៅក្នុងភាសាខ្មែរបានទេ។

លក្ខខណ្ឌវចនសព្ទនិងលក្ខខណ្ឌរូបសាស្ត្រ គឺមានលក្ខណៈនិងដំណើរការដូចគ្នា ក៏ប៉ុន្តែអ្នកនិពន្ធបានប្រើបច្ចេកសព្ទខុសគ្នា នៅក្នុងការបកស្រាយរបស់ខ្លួន។ លក្ខខណ្ឌរូបសាស្ត្រ គឺមានការជាប់ទាក់ទងទៅនឹងទម្រង់ពាក្យឯកវចនៈនិងពហុវចនៈរបស់ភាសាឥណ្ឌូ-អឺរ៉ុបដែលមានការប្រែប្រួល ខាងស្រៈនិងការប្រែប្រួលទម្រង់ពាក្យ ទាំងនៅក្នុងបច្ចុប្បន្នកាល អតីតកាល និងកិរិយាសព្ទនៅក្នុងទម្រង់ទីបី។ ឧទាហរណ៍ goose (ឯកវចនៈ) > geese (ពហុវចនៈ), do (ទម្រង់បច្ចុប្បន្នកាល) > did (ទម្រង់អតីកាល) > done (ទម្រង់ទីបី)។

ចំពោះភាសាខ្មែរ ទម្រង់ពាក្យមិនមានការប្រែប្រួលដូចមានការបង្ហាញជូនខាងលើទេ ពីព្រោះភាសាខ្មែរជាភាសាមិនមានទម្រង់ពាក្យដែលប្រែប្រួលទៅតាមកាល ភេទ វចនៈនោះទេ អាស្រ័យហេតុនេះភាសាខ្មែរមិនមានលក្ខខណ្ឌដូចរៀបរាប់ខាងលើនោះទេ (វង្ស មេង, ២០២០: ៤២-៤៨)។

រូបតា /ប˙ន/ មានកាឡារូបជាច្រើនទៅតាមបរិបទដូចជា [ប˙ង-] [ប˙ញ-] [ប˙ណ-] [ប˙ន-] [ប˙ម-]...។

ឧទាហរណ៍៖

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខំ | + | [ប˙ន-] | > | បង្ខំ | កាច់ | + | [ប˙ន-] | > | បង្កាច់ |
| ខូច | + | [ប˙ន-] | > | បង្ខូច | ចេញ | + | [ប˙ន-] | > | បញ្ចេញ |
| ចូល | + | [ប˙ន-] | > | បញ្ចូល | ឈប់ | + | [ប˙ន-] | > | បញ្ឈប់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ដុះ | + | [ប´ន-] | > | បណ្ដុះ | ដេញ | + | [ប´ន-] | > | បណ្ដេញ |
| ដើរ | + | [ប´ន-] | > | បណ្ដើរ | ត | + | [ប´ន-] | > | បន្ត |
| ថោក | + | [ប´ន-] | > | បន្ថោក | បាក់ | + | [ប´ន-] | > | បំបាក់ |
| បាត់ | + | [ប´ន-] | > | បំបាត់ | បៅ | + | [ប´ន-] | > | បំបៅ |

## ២.៤. ក្បួនរូបសព្ទវិទ្យា

មកដល់ចំណុចនេះ យើងបាននិយាយអំពីក្បួនរូបសព្ទវិទ្យា (morphological rule) សម្រាប់ អព្ភាសបទ/ផ្នត់ (affixation) ការផ្សំបញ្ចូលគ្នា (compounding) ការផ្លាស់ប្តូរឫស (stem) ខាងក្នុងនិងមធ្យោបាយផ្សេងទៀតនៃការបង្កើតពាក្យថ្មី ប៉ុន្តែយើងបានកំណត់តែក្បួនទាំងនោះបានតែក្រៅផ្លូវការប៉ុណ្ណោះ។ ផ្នែកមួយក្នុងចំណោមផ្នែកសំខាន់ៗនៃការធ្វើគំរូសទ្ទានុក្រមក្នុងវចនញាណ (mental lexicon) គឺដើម្បីកំណត់ក្បួននៃរូបសព្ទវិទ្យាក្នុងទម្រង់ផ្លូវការ។ នៅក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលទម្រង់ប្រព័ន្ធខុសៗគ្នា អំពីលក្ខណៈក្បួននៃរូបសព្ទវិទ្យា និងព្យាយាមពិនិត្យមើលរបៀបដែលពួកវាបង្កើតនូវអំណះអំណាងខុសៗគ្នាអំពីប្រភេទនៃរូបសព្ទវិទ្យា ដែលយើងនឹងស្វែករកនៅក្នុងភាសានានា របស់ពិភពលោក។

### ២.៤.១. រូបសព្ទជាធាតុនៃវចនសព្ទនានា: ធាតុនិងការរៀបចំរូបសព្ទវិទ្យា

សូមក្រឡេកមើលក្បួនក្រៅផ្លូវការមួយទៀតនៃការបង្កើតពាក្យ (word formation) ដែលយើង បានលើកឡើងនៅក្នុងផ្នែកនេះ៖

(១) - ize ដែលភ្ជាប់ទៅនឹងគុណនាមឬនាមនៃព្យាង្គពីរឬច្រើន ដែលទីតាំងនៃព្យាង្គចុងក្រោយ ដែលមិនលេបការសង្កត់សំឡេងព្យាង្គទី១ (primary stress)។ ចំពោះមូលដ្ឋាន «X» វាបង្កើតកិរិយាសព្ទដែលមានន័យថា «បង្កើត / ដាក់ ដល់ X»។

វិធីមួយក្នុងការធ្វើឱ្យក្បួនប្រភេទនេះក្លាយជាក្បួនផ្លូវការនោះគឺត្រូវទទួលស្គាល់ថានៅក្នុងវចនៈញាណរបស់យើង រូបសព្ទ «-ize» មានចម្រកវចនសព្ទ (lexical entry) មួយ ដូចអ្វីដែលរូបសព្ទឯករាជ្យធ្វើ ហើយផ្នែកចម្រកវចនសព្ទរបស់វានោះ គឺមានដូចខាងក្រោម៖

(២) ក្បួន -ize (កំណែថ្មីដែលផ្លូវការជាង)

| | | |
|---|---|---|
| -ize | ព័ត៌មានរចនាសម្ព័ន្ធ: | $[[\ ]_{A,N}\ __\ ]_V$ |
| | ព័ត៌មានន័យ: | «បង្កើត A; បង្កើត /ដាក់ចូល N» |
| | ព័ត៌មានប្រព័ន្ធសូរសព្ទ: | $[...\sigma\sigma_w$ aiz] |

បន្ទាត់ទីមួយនៃក្បួននេះ ផ្តល់នូវព័ត៌មានរចនាសម្ព័ន្ធ: វាបង្ហាញថា «-ize» គឺជាបច្ច័មបទ (suffix) មួយដែលភ្ជាប់ទៅនាមឬគុណនាម និងបង្កើតបានជាកិរិយាសព្ទ។ ជាការពិត វាបង្ហាញអ្វីមួយដែលលើសពីនេះ ដូចដែលតង្កៀប (brackets) បង្ហាញនៅពេលដែលបច្ច័មបទត្រូវបានបន្ថែម។ ករណីនេះ គេឃើញមានរចនាសម្ព័ន្ធឋានានុក្រមតិចតួចប៉ុណ្ណោះត្រូវបានបង្កើតឡើង៖

(៣)




បន្ទាត់ទីពីរនៃក្បួននេះ ប្រាប់យើងអំពីអ្វីដែលជាលទ្ធផលនៃន័យពាក្យ។ ផ្នែកនៃក្បួននេះអាចក្លាយជាក្បួនផ្លូវការផងដែរ ដោយការប្រើប្រាស់នូវការកំណត់ពិសេស ប៉ុន្តែនៅផ្នែកនេះ យើងនឹងមិនកំណត់ដូច្នេះទេ។ យើងនឹងគ្រាន់តែនិយាយថា នៅពេលដែលបំណែក «-ize» បន្ថែមចូលពាក្យមូលដ្ឋានណាមួយ បំណែកនេះ ក៏នឹងបន្ថែម

ន័យដូចថា ដាក់ A ឬបង្កើត/ដាក់ចូល N (make A or make/put into N)។ ចុងក្រោយបន្ទាត់ទីបីដែលប្រើសញ្ញាអក្សរក្រិកស៊ិកម៉ា (σ) ដើម្បីតំណាងព្យាង្គ ហើយនិងដាក់អក្សរតូច «w» តំណាងឱ្យព្យាង្គខ្សោយឬព្យាង្គមិនសង្កត់សូរ។ ដូច្នេះទម្រង់នេះ បំប្លែងព័ត៌មានដែលបច្ច័យបទ «-ize» ទាមទារមូលដ្ឋានដែលមានយ៉ាងហោចណាស់ពីរព្យាង្គ។ ព្យាង្គចុងក្រោយត្រូវតែមិនសង្កត់សំឡេងទេ។

ទ្រឹស្តីប្រភេទនេះ គឺមានផលប៉ះពាល់ដល់ការអះអាងថា អក្ខសបទ គឺគ្រាន់តែដូច រូបសព្ទឯករាជ្យ ដែលនៅក្នុងទម្រង់នេះ ពួកវាមានចម្រកវចនសព្ទ ដែលរួមបញ្ចូលទាំងប្រភេទផ្សេងៗនៃព័ត៌មាន។ ភាពខុសគ្នាតែម្យ៉ាងរវាងការបញ្ចូលអក្ខសបទមួយនិងសម្រាប់ពាក្យមូលដ្ឋានគឺថា អក្ខសបទ គឺជារូបសព្ទចំណុះមួយ ដូច្នេះហើយក្នុងឋានៈជាផ្នែកមួយនៃព័ត៌មានសម្ព័ន្ធរបស់វា ដែលទាមទារដោយធាតុផ្សេងទៀតដើម្បីភ្ជាប់ជាមួយវា។ ទ្រឹស្តីជាច្រើនដែលស្នើលើកឡើងនៃក្បួនប្រភេទនេះ គឺជាប្រពៃណីសំដៅដល់ទ្រឹស្តីធាតុនិងការរៀបចំនានា (Item and Arrangement (IA)) ព្រោះពួកវាអះអាងថា រូបសព្ទមានអត្ថិភាពឯករាជ្យនៅក្នុងវចនញ្ញាណ រួមជាមួយនឹងរចនាសម្ព័ន្ធផ្ទាល់ខ្លួនរបស់វា ន័យ និងព័ត៌មានប្រព័ន្ធសូរសព្ទ។ រចនាសម្ព័ន្ធនេះ បានសម្រួលឱ្យធាតុទាំងនេះត្រូវបានរៀបចំឋានានុក្រមទៅជាពាក្យ។

## ២.៤.២. រូបសព្ទក្នុងនាមជាដំណើរការផ្សេងៗនិងរូបសព្ទវិទ្យាជាក់ស្តែង

ពិតណាស់ នេះមិនមែនជាមធ្យោបាយតែមួយក្នុងការធ្វើឱ្យទៅជាផ្លូវការនៃក្បួនរូបសព្ទវិទ្យានោះទេ។ គ្មានអ្វីជាមន្ទិលនោះទេ អ្នករូបសព្ទវិទ្យាជាច្រើនជឿងថា វាគឺជាកំហុសឆ្គងក្នុងការរាប់រូបសព្ទជា «អ្វីៗ» ដែលមានវត្តមានឯករាជ្យផ្ទាល់ខ្លួនវា នៅក្នុងវចនញ្ញាណរបស់យើង។ ជម្រើសបែបនេះ បានធ្វើឱ្យអ្នករូបសព្ទវិទ្យាទាំងនោះ ពិភាក្សាគ្នា ក្នុងន័យថា គេអនុញ្ញាតឱ្យតែរូបសព្ទឯករាជ្យប៉ុណ្ណោះ ដើម្បីអាចមានចម្រកវចនសព្ទផ្ទាល់ខ្លួនរបស់វា និងណែនាំអំពីរូបសព្ទចំណុះ ប្រើប្រាស់ក្បួនដែលមានទម្រង់ប្រព័ន្ធសូរសព្ទ និងន័យខាងក្នុងនៃរូបសព្ទចំណុះណាមួយ។ ចំពោះក្បួន «-ize» គឺមើលទៅហាក់ដូចជានៅក្នុងក្របខ័ណ្ឌទ្រឹស្តី។ សូមមើលឧទាហរណ៍ខាងក្រោមនេះ៖

(១) ក្បួន «-ize» គឺថា X → Xize, ដែលជាទីតាំង X = N,A និង Xize = V ដែលមានន័យថា «បង្កើត, ដាក់» ចូលទៅក្នុង X។

ក្នុងករណីនៃក្បួន «-ize» នេះប្រហែលជាមិនខុសគ្នាជាងចម្រកវចនសព្ទ ដែលយើងបានលើកឡើងពីខាងដើមនោះទេ។ ប៉ុន្តែគួរពិចារណាពីប្រភេទនៃក្បួន ដែលយើងត្រូវតែស្នើឡើងសម្រាប់ទម្រង់អតីតកាលនៃកិរិយាសព្ទដែលប្រែប្រួលមួយ ដូចជា *sang* ដែលជាកិរិយាសព្ទរបស់ភាសាអង់គ្លេស។ ដោយសារតែទម្រង់អតីតកាលនៃកិរិយាសព្ទ គឺត្រូវបានបង្កើតឡើងដោយដំណើរការនៃពាក្យដែលមានបន្លាស់ប្តូរស្រៈ (ablaut) យើងអាចស្នើឡើងនូវក្បួនដែលផ្លាស់ប្តូរស្រៈ [ɪ] ទៅ [æ] ដើម្បីបង្កើតទម្រង់អតីតកាលនៃកិរិយាសព្ទ *sing* ទៅជា *sang* នៅក្នុងភាសាអង់គ្លេស។

(២) ក្បួនអតីតកាលនៃកិរិយាសព្ទប្រែប្រួល សម្រាប់ sing, swim, ring ដែលជាចំណាត់ថ្នាក់នៃកិរិយាសព្ទផ្សេងៗ ដូចជា CɪN [-past] → CæN [+past] ។

ប្រសិនបើ C តំណាងឱ្យគ្រប់ព្យញ្ជនៈនានា ហើយ N តំណាងឱ្យគ្រប់ព្យញ្ជនៈច្រមុះ យើងអាចបញ្ជាក់ពីស្រៈដែលប្តូរនោះថា មានទីតាំងនៅក្នុងកាលអតីតកាលនៃកិរិយាសព្ទ ដែលវាសមរម្យចំពោះក្បួនមួយនេះ។ វាមិនងាយស្រួលក្នុងការមើលដឹងពីរបៀបដែលបញ្ជាក់ពីបណ្តូលស្រៈក្នុង ដោយប្រើប្រាស់គំរូរូបសព្ទជាវត្ថុនោះទេ។ វាហាក់ដូចជាមិនសមរម្យក្នុងការនិយាយថា អតីតកាលក្នុងទម្រង់កិរិយាសព្ទបែបនេះ គឺជារូបសព្ទមួយ ដែលមានវត្តមានតែ [æ] មួយនោះទេ។ ប្រភេទនៃក្របខ័ណ្ឌទ្រឹស្តី ដែលចាត់ទុក រូបសព្ទនានា ជាផ្នែកនៃក្បួន គឺពេលខ្លះវាត្រូវបានគេហៅថាទ្រឹស្តីធាតុនិងដំណើរការ (an Item and Process (IP)) ព្រោះក្បួនរូបសព្ទវិទ្យា គឺត្រូវបានចាត់ទុកថាជាប្រតិបត្តិការឬដំណើរការ ដែលសម្តែងនៅលើរូបសព្ទឯករាជ្យ។

ទាក់ទងនឹងគំរូធាតុនិងដំណើរការ (the Item and Process) គឺគំរូពាក្យ (Word) និង ស្រឡាយពាក្យ (Paradigm) (WP)។ គំរូពាក្យនិងស្រឡាយពាក្យ (WP) ពេលខ្លះត្រូវបានគេស្គាល់ថា ជាគំរូបុរេសម្គាល់ (realizational)។ ជារឿយៗ ពួកគេត្រូវបានគេស្នើសុំឱ្យទទួលខុសត្រូវចំពោះការបង្កើតពាក្យដែលមានការផ្លាស់ប្តូរទម្រង់ នៅក្នុងភាសាដែលមានស្រឡាយពាក្យស្មុគស្មាញ ពិសេសគឺប្រភេទស្រឡាយពាក្យដែលបង្ហាញពីលក្ខណៈអ្វីមួយ ដែលគេតែងហៅថា ពហុនិទស្សន៍ (multiple exponence)។ ពហុនិទស្សន៍ កើតឡើង នៅពេលដែលលក្ខណៈបំលាស់ប្តូរទម្រង់ពិសេស ដែលបង្ហាញពីទម្រង់អតីតកាលឬក៏ទម្រង់បុរសទី៣ គឺជាសញ្ញាដែលកើតមានឡើងដោយរូបសព្ទលើសពីមួយ នៅក្នុងពាក្យមួយ។ ឧទាហរណ៍ នៅក្នុងភាសាឡាតាំង ទម្រង់កិរិយាសព្ទអតីតកាលបុរសទីពីរឯកវចនៈ amāvisti «you-sg loved» យើងអាចនឹងនិយាយថាពាក្យឫសគឺ am និងបែងជាងជាមួយនឹងមូលតាស្រះ amā។ ទម្រង់អតីតកាលត្រូវបានបង្ហាញដោយ រូបសព្ទ «-v» ចំណែកឯរូបសព្ទបុរសទីពីរ ឯកវចនៈ គឺ «-isti»។ ប៉ុន្តែបែបនេះគឺមិនត្រឹមត្រូវទាំងស្រុងនោះទេ ព្រោះរូបសព្ទ «-isti» គឺបញ្ចប់សំដៅទៅលើមនុស្ស/លេខដែលត្រូវបានប្រើប្រាស់នៅក្នុងទម្រង់អតីតកាល។ ក្នុងន័យខ្លះ «-isti» បដិសេធអត្ថន័យនៃអតីតកាល រួមជាមួយនឹងអត្ថន័យសំដៅដល់ មនុស្ស/លេខរបស់វា។ ន័យប្រាប់ពីអតីតកាលគឺបានបង្ហាញពីរដងនៅក្នុងពាក្យ «–māvisti» តែមួយ។ នេះគឺជាអ្វីដែលយើងចង់មានន័យសំដៅដល់ ពហុនិទស្សន៍។ នៅក្នុងទ្រឹស្តី ធាតុនិងការរៀបចំធាតុ (IA)) នៃរូបសព្ទវិទ្យា ពហុនិទស្សន៍គឺជាចំណោទបញ្ហា។ គំរូធាតុនិងការរៀបចំធាតុ (IA) អាចត្រឹមត្រូវយកជាការបាននៅពេលដែលមានការឆ្លងឆ្លើយមួយទល់មួយរវាងរូបសព្ទនិងន័យ។ ក្នុងន័យផ្សេងទៀត រូបសព្ទនីមួយៗ បង្ហាញន័យបានតែមួយ ឬក៏ន័យបានមកពីកម្លាយមួយ។ ផ្ទុយទៅវិញពាក្យនិងស្រឡាយពាក្យ (WP) ឬក៏គំរូបុរេសម្គាល់ គឺមិនបានបំបែករូបសព្ទឱ្យទៅជាបំណែកដាច់ពីគ្នានោះទេ ប៉ុន្តែវាអាចបង្កើតក្បួនដែលមានទំនាក់ទំនងន័យ (ឯកវចនៈឬពហុវចនៈ) ជាមួយទម្រង់ស្មុគស្មាញជាច្រើន។ ឧទាហរណ៍ ប្រហែលជាក្បួនបុរេសម្គាល់មួយ សម្រាប់ទម្រង់អតីតកាលបុរសទីពីរឯកវចនៈ នៃកិរិយាសព្ទក្នុងភាសាឡាតាំង៖

(៣) X > [Xvisti]

+past tense

2nd person singular

គំរូបុរេសម្គាល់ គឺមិនអាចបែងចែង «-v» និង «-isti» ជារូបសព្ទបានទេ។ ជំនួសមកវិញ ទម្រង់ amāvisti ត្រូវបានចាប់កំណើតជាឯកតា ដែលបញ្ជាក់ពីអតីតកាល បុរសទីពីរ និងដែលភ្ជាប់លេខឯកវចនៈ។ អត្ថិភាពនៃពហុនិទស្សន៍ គឺមិនបង្កបញ្ហានៅក្នុងគំរូបុរេសម្គាល់នោះទេ ព្រោះពាក្យដែលឆ្លុះបញ្ចាំងនោះ មិនចាំបាច់ត្រូវបែងចែកជាបំណែកដាច់ពីគ្នានោះទេ។

### ២.៤.៣. តើយើងអាចសម្រេចរវាងពួកវាទាំងពីរយ៉ាងដូចម្តេច?

មកដល់ចំណុចនេះ អ្នកប្រហែលជាមានចម្ងល់ថា ប្រសិនជាវាបង្កើតឱ្យមានភាពខុសគ្នាមួយរវាង ថាតើយើងបង្កើតរូបសព្ទនានាជាវត្ថុផ្សេងៗ ជាមួយនឹងន័យដាច់ៗពីគ្នា និងចម្រកវចនសព្ទរបស់ពួកវាផ្ទាល់ ឬក៏ជាផ្នែកណាមួយនៃក្បួនរូបសព្ទវិទ្យា ដែលគេអាចដឹងបានដោយមិនចាំបាច់វិភាគពាក្យជាមួយនឹងន័យដ៏ស្មុគស្មាញនានានោះឡើយ។ គំនិតរបស់យើង ដែលយល់ថាតើក្បួនរូបសព្ទវិទ្យា មានរូបរាងលក្ខណៈបែបណានោះ គឺពិតជាបញ្ហាមួយពិបាកណាស់ ព្រោះវាបង្កើតជាការប៉ាន់ស្មានច្រើននានា អំពីប្រភេទថាអ្វីនៃរូបសព្ទវិទ្យា ដែលយើងរំពឹងថានឹងរកឃើញនៅក្នុងភាសាទាំងឡាយលើពិភពលោក។ ផ្ទុយទៅវិញ ទ្រឹស្តីធាតុនិងការរៀបចំធាតុ បានព្យាករណ៍ថា ជាការយល់ឃើញពីរូបសព្ទវិទ្យា គួរតែជាការបង្កើតពាក្យដែលលើសលុប ដោយការច្របាច់បញ្ចូលគ្នាជាជាងការឆ្លុះបញ្ចាំងឬដោយប្រើធាតុដាច់តែឯង ជាមួយពាក្យនានាដែលអាចញែកបានជាច្រើនចម្រៀក។ ផ្ទុយទៅវិញ ទ្រឹស្តីជាច្រើនអំពីពាក្យនិងស្រឡាយពាក្យ ទោះបីទ្រឹស្តីទាំងនោះមិនតឹងតែងក្នុងការបញ្ចៀសរូបសព្ទវិទ្យានៃការបង្កើតពាក្យ

ដែលលើសលុប ដោយការប្រចាប់បញ្ចូលគ្នាជាជាងការឆ្លុះបញ្ចាំងឬដោយប្រើធាតុដាច់តែឯងបាននាំឱ្យយើងរំពឹងថាជាធម្មតា រូបសព្ទវិទ្យា មិនគួរក្លាយជាទម្រង់នៃការបង្កើតពាក្យដែលលើសលុប ដោយការប្រចាប់បញ្ចូលគ្នាជាជាងការឆ្លុះបញ្ចាំងឬដោយប្រើធាតុដាច់តែឯង។ វាគួរមានផ្ទុកពហុនិទស្សន៍ ជាច្រើន ដូចក្នុងករណីភាសាឡាតាំង ប៉ុន្តែនៅក្នុងភាសាទួគី គឺអត់មានទេ។ ពិតណាស់ បញ្ហាគឺត្រង់ថា ការព្យាករណ៍ទាំងអស់នេះ គឺមិនសុទ្ធតែត្រឹមត្រូវនោះទេ។ នៅក្នុងភាសាមួយចំនួន គឺការបង្កើតពាក្យដែលលើសលុប ដោយការប្រចាប់បញ្ចូលគ្នាជាជាងការឆ្លុះបញ្ចាំងឬដោយប្រើធាតុដាច់តែឯង គឺជាភាសាដទៃទៀត។ ភាសាខ្លះមានពហុនិទស្សន៍ ជាច្រើន ខណៈដែលភាសាខ្លះមានតិចតួចឬគ្មានតែម្តង។

ដូច្នេះ វាបាននាំឱ្យមានជម្រើសផ្សេងគ្នាក្នុងការជ្រើសរើសទ្រឹស្តីណាមួយយកមកវិភាគ។ ប៉ុន្តែជម្រើសគឺត្រូវធ្វើឡើងយ៉ាងពិបាក ប្រកបដោយភាពស្មុគ្រស្មាញ និងប្រភេទផ្សេងៗនៃរូបសព្ទ ដែលដំណើរនេះគឺយើងតែងតែជួបប្រទះនៅក្នុងភាសានានានៃពិភពលោក។ វាកាន់តែត្រូវបានធ្វើឱ្យពិបាកថែមទៀត ដោយតាមពិតគំរូនានាអស់ទាំងនេះ គឺមិនមែនជាទ្រឹស្តីតែឯកឯងមួយនោះទេ ប៉ុន្តែប្រភេទនៃមែងជាង ដែលរួមបញ្ចូលចំនួនមួយក្នុងចំណោមទ្រឹស្តីផ្សេងៗជាច្រើន។ ឧទាហរណ៍ នៅក្នុងទម្រង់ដ៏សាមញ្ញរបស់ទ្រឹស្តីទាំងនោះ គំរូធាតុនិងការរៀបចំធាតុ និយាយថាការឆ្លើយឆ្លងរវាងន័យនិងផ្នែកផ្សេងៗ គួរតែមួយទល់មួយ ប៉ុន្តែពួកវាមិនចាំបាច់និយាយបែបនេះទេ។ វាអាចទៅរួចដែលស្មើគំរូធាតុនិងការរៀបចំធាតុ មួយដែលទំនាក់ទំនងរវាងផ្នែកផ្សេងៗ និងន័យ គឺប្រហាក់ប្រហែលគ្នា ប៉ុន្តែមិនតឹងរឹងរហូតទាល់តែដូចគ្នាបេះដាក់ ឬដាក់មួយទល់មួយនោះទេ។ ស្រដៀងគ្នានេះដែរ មានមួយក្នុងចំណោមកំណែថ្មីនានានៃពាក្យនិងស្រឡាយពាក្យ ឬក៏គំរូបុរេសម្គាល់ ដែលអាចជឿទុកចិត្តបាន។ នៅទីនេះ អ្នកមិនអាចមានលទ្ធភាពទៅផ្តោតលើគ្រប់ទ្រឹស្តីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាបាននោះទេ ប៉ុន្តែអ្នកនឹងអស់ចម្ងល់នៅពេលដែលអ្នកឈានទៅសិក្សាដល់កម្រិតកាន់តែខ្ពស់នៅក្នុងមេរៀនរូបសព្ទវិទ្យា។ ទោះបីជា វាហាក់បីដូចជាត្រឹមត្រូវសុវត្ថិភាព ក្នុងការលើកឡើងថា ទ្រឹស្តីនីមួយៗត្រូវបានសាកល្បងប្រឈមទៅនឹងភាសាផ្សេងៗដ៏ច្រើន ជាមួយនឹងប្រភេទនានានៃការបង្កើតពាក្យ និងប្រភេទនានានៃបំលាស់ប្តូរទម្រង់និងដំណើរការបង្កើតពាក្យកម្លាយដែលមិនត្រឹមតែជាការរួមបញ្ចូលនៃអញ្ញាសបទ ប៉ុន្តែក៏នៅមាន បន្សំ បំប្លែង ការបង្កើតឡើងទ្វេដង និងកម្រិតរូបសព្ទ។ យើងនឹងបញ្ចប់ផ្នែកនេះដោយការលើកឡើងដោយសាមញ្ញថាការវិនិច្ឆ័យនៅតែមិនទាន់ច្បាស់ការ មិនថាតែជាតុនិង ការរៀបចំធាតុ ធាតុនិងដំណើរការធាតុ ឬគំរូនានារបស់បុរេសម្គាល់ នៃរូបសព្ទវិទ្យា បង្កើតបានជាគំរូកាន់តែប្រសើរជាងមុននៃរបៀបដែលរូបសព្ទវិទ្យាត្រូវបានចាត់ចែងនៅក្នុងចិត្តមនុស្ស។

### ២.៤.៤. បូរណភាពនៃវចនៈ

យើងបានពិចារណាពីទំនាក់ទំនងរវាង រូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា ហើយយើងបានឃើញនូវមធ្យោបាយមួយចំនួន ដែលកំណាត់ពាក្យ (segments) ទាំងពីរនេះនៃវេយ្យាករណ៍ គឺមានទំនាក់ទំនងគ្នាជិតស្និទ្ធ។ ជាការពិតទំនាក់ទំនងរវាង រូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា បានបង្កើតឱ្យមានវិវាទទ្រឹស្តីមួយដែលគួរឱ្យចាប់អារម្មណ៍ និងអូសបន្លាយវេលាយូរបំផុតក្នុងចំណោមរូបសព្ទវិទូ។ ប្រវត្តិដំបូងនៃរូបសព្ទវិទ្យាបំប្លែង មានអ្នកទ្រឹស្តីមួយចំនួនបានស្នើឡើងនូវអ្វីដែលគេហៅថា សម្មតិកម្មបូរណភាពនៃវចនៈ (Lexical Integrity Hypothesis)។ កំណែប្រែមួយនៃសម្មតិកម្មនេះ គឺ «គ្មានក្បួនសម្ព័ន្ធ (syntactic rule) អាចសំដៅដល់ធាតុនៃរចនាសម្ព័ន្ធរូបសព្ទវិទ្យាបានទេ»។

ន័យនៅទីនេះ គឺចង់មានន័យថាក្បួននៃសម្ព័ន្ធវិទ្យា គឺជាក្បួននៃការប្រែប្រួលឬក៏ជាក្បួនរចនាសម្ព័ន្ធឃ្លា។ ឧទាហរណ៍ សម្ព័ន្ធវិទ្យាមិនអាចឆ្លុះបញ្ចាំងពីពាក្យសព្ទនានា និងរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួនឯងបានទេ។ សម្មតិកម្មបូរណភាពនៃវចនៈទាមទារថា ក្បួនរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា ត្រូវតែមានមូលដ្ឋានផ្សេងពីគ្នា។ ក្បួនរូបសព្ទវិទ្យា គឺមានការបារម្ភចំពោះអញ្ញាសបទនិងឫសពាក្យ ជាមួយក្បួននៃទ្វេធាតុ និងបន្លាស់ប្តូរសំឡេង។ល។ សមាសភាពទាំងនេះ គឺប៉ះពាល់ដល់រចនាសម្ព័ន្ធខាងក្នុងនៃពាក្យនានា។ ក្បួននានានៃសម្ព័ន្ធវិទ្យាបានចាត់ទុកពាក្យ

ទាំងឡាយថា សុទ្ធតែមិនអាចវិភាគបានទាំងអស់ ហើយបង្កើតពាក្យទាំងឡាយទៅជាឃ្លាឬល្បះ។ វិធីមួយដើម្បីធានាបាននូវការបែងចែករវាង រូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា ដែលត្រូវបានលើកឡើងដំបូងៗនៃប្រវត្តិនៃការសិក្សាពីរូបសព្ទវិទ្យាបំប្លែង ហើយត្រូវបានគេចាត់ថាក្បួនរូបសព្ទវិទ្យា គឺឋិតនៅលំដាប់មុនសម្ព័ន្ធវិទ្យា ហាក់បីដូចជាមានអ្វីមួយដូចបន្ទប់ឬមែកធាងនៃបណ្ដុំភាសាវិទ្យា ដែលចាប់ផ្ដើមពីធាតុតូចល្អិតនៃរចនាសម្ព័ន្ធនិងវិវត្តិទៅរកធាតុកាន់តែធំទៅៗ។

គំរូដែលបង្ហាញនៅនេះ ធានាពីការបែងចែករូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា ព្រោះសម្ព័ន្ធវិទ្យាគ្រាន់តែពិនិត្យមើលលើការបង្កើតពាក្យរួចទៅហើយ។ ភាសាវិទូជាច្រើនលែងមានជំនឿតទៅទៀតហើយ លើដំណើរការក្បួននៃភាពរឹតត្បិត ប៉ុន្តែទោះជាយ៉ាងនេះក្ដី ភាសាវិទូទាំងនោះនៅបន្តរក្សាដដែល ដូច្នេះថាក្បួនរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យាត្រូវតែបែងចែកឱ្យដាច់ពីគ្នា។

សម្មតិកម្មបូរណភាពនៃវចនៈ មានរឿងពីរដើរទន្ទឹមគ្នា គឺថាយើងអាចជឿទុកចិត្តវាបាន ហើយនិងក៏គ្រាន់តែអាចសាកល្បងក៏បាន។ តាមពិត វាបង្កើតការព្យាករណ៍ប្រាកដជាក់ថា យើងនឹងមិនអាចស្វែងរកឃើញពេញលេញនូវការបង្កើតកន្សោមពាក្យ ឃ្លា ឬល្បះនៅក្នុងពាក្យទាំងឡាយបានឡើយ។ ប្រសិនបើឃ្លាត្រូវបានបង្កើតឡើងដោយក្បួនសម្ព័ន្ធវិទ្យា ហើយក្បួនសម្ព័ន្ធវិទ្យា គឺញែកចេញពីក្បួនរូបសព្ទវិទ្យា នោះពាក្យទាំងឡាយមិនគួរមានផ្ទុកកន្សោមពាក្យ ឃ្លា ឬល្បះ (មិនគួរឋិតក្នុងរូបភាពបន្សំឃ្លាឬល្បះច្រើន) នោះទេ។ យ៉ាងណាក៏ដោយ ដូចដែលបានបង្ហាញនៅក្នុងចំណុចខាងលើ គឺមានប្រភេទពាក្យមួយចំនួនដែលពិតហាក់ដូចជាមានផ្ទុកកន្សោមពាក្យច្រើន និងថែមទាំងមានផ្ទុកល្បះច្រើនផងដែរ។

ភាសាវិទូជាច្រើននាក់បានស្នើជ្រើសរើសសម្មតិកម្មនៃចម្រុះវចនសព្ទផ្សេងៗទៀត។ ភាសាវិទូខ្លះបានស្នើនូវក្បួនជាច្រើនដែលកំណត់អន្តរកម្មរវាងរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា ដែលអាចឱ្យសម្មតិកម្មដំណើរការទៅរួច។ ប៉ុន្តែភាសាវិទូខ្លះទៀត បានជ្រើសយកវិធីសាស្ត្រទម្រង់ផ្លាស់ប្ដូរបន្ថែម ហើយបានបដិសេធថា មិនគួរមានការបែងចែករវាងរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា នោះទេ ហើយពួកគេបានលើកឡើងថា ក្បួនសម្ព័ន្ធវិទ្យា គួរតែទទួលខុសត្រូវយ៉ាងហោចណាស់សម្រាប់ប្រភេទនៃការបង្កើតពាក្យ។ វាមានរឿងជាច្រើនដែលអាចនិយាយបានអំពីគុណសម្បត្តិនិងគុណវិបត្តិជាច្រើននៃការវិភាគនេះ ទោះបីជាយ៉ាងណាយើងមិនអាចលើកយកមកវែកញែកបានទាំងអស់នៅទីនេះនោះទេ។ ទោះយ៉ាងណាយើងគួរតែចង្អុលបង្ហាញថា ខណៈដែលភាសាវិទូខ្លះបានរកកស្តុតាង សម្រាប់បញ្ចុះបញ្ចូលឱ្យគេជឿលើការវិភាគនេះ ប៉ុន្តែភាសាវិទូខ្លះវិញទៀត មិនសូវបញ្ចុះបញ្ចូលឱ្យគេជឿលើការវិភាគនេះ ហើយពួកគាត់ចង់សិក្សាលើគំរូនានានៃទ្រឹស្តីដែលចាត់ទុកថា ការបង្កើតពាក្យ ជាលទ្ធផលដែលបានមកពីក្បួនរូបសព្ទវិទ្យា ហើយអនុញ្ញាតឱ្យមានការសិក្សាលើអន្តរកម្មរវាងរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យា។ ដូចទ្រឹស្តីដទៃៗទៀតជាច្រើនបានបង្ហាញនៅក្នុងរូបសព្ទវិទ្យា ការវិនិច្ឆ័យនៅតែមិនទាន់អាចបញ្ជាក់បានច្បាស់លាស់ពីទំនាក់ទំនងរវាងរូបសព្ទវិទ្យានិងសម្ព័ន្ធវិទ្យានៅឡើយ (Rochelle Lieber, 2009: 180)។

## ២.៥. រចនាសម្ព័ន្ធពាក្យ

### ២.៥.១. និយមន័យ

និយមន័យរបស់ពាក្យ គឺជាបញ្ហាដ៏លំបាកបំផុតក្នុងភាសាវិទ្យា ព្រោះពាក្យខ្លះមានទិដ្ឋភាពផ្សេងៗពីគ្នា។ វាកើតឡើងដំណាលគ្នានូវឯកតាន័យ វេយ្យាករណ៍ និងសូរ។ យោងតាមកត្តានេះ ពាក្យអាចត្រូវបានគេឱ្យនិយមន័យដូចជា ធាតុមូលដ្ឋាននៃលទ្ធផលភាសា ដែលត្រូវបានផ្ដល់ឱ្យចេញពីការចូលរួមនៃន័យផ្សេងៗជាមួយក្រុមផ្សេងៗលទ្ធភាពសូរ និងមុខងារវេយ្យាករណ៍ផ្សេងៗពីគ្នា។ យើងអាចទទួលយកនិយមន័យបន្ថែមថា ពាក្យគឺជាឯកតាដ៏សំខាន់នៃសមត្ថភាពភាសាដែលផ្ដល់ឱ្យនៃមុខងារទោល និងបង្ហាញលក្ខណៈតាមរយៈការចល័តទីតាំងនៅក្នុងល្បះការតភ្ជាប់ផ្នែករូបសព្ទ និងបូរណភាពន័យ។

ដូច្នេះពាក្យ គឺជាអង្គភាពសម្ព័ន្ធនិងន័យនៅក្នុងប្រព័ន្ធភាសា។ ពាក្យ គឺជាឯកតាមូលដ្ឋាននៃប្រព័ន្ធភាសា ដែលជាកម្រិតរូបសព្ទធំបំផុត និងជាកម្រិតសម្ព័ន្ធតូចបំផុតនៃការវិភាគអំពីភាសា។ ដូចជានៅក្នុងឯកតាភាសាខ្លះ ពាក្យគឺជាឯកតាមុខពីរដែលមានទម្រង់ខាងក្រៅរបស់វាពីរ គឺទម្រង់សូរ (sound form) និងខ្លឹមសារ (meaning) ដែលមិនមែនកើតឡើងតាមរយៈសម្ដី ប៉ុន្តែកើតឡើងតាមរយៈការប្រើប្រាស់កន្លងមក (គេន រង្សី, ២០១៨: ៣២)។

ពាក្យនីមួយៗមានលក្ខណៈបីយ៉ាងគឺ សំណូរ សំណេរ និងន័យសេចក្ដី។

### ២.៥.២. សំណូរពាក្យ

សំណូរ ជាទុនមួយនៃពាក្យសព្ទដែលមានបែបបទផ្សេងៗពីគ្នាទៅតាមភាសានីមួយៗ។ ភាសាខ្លះបញ្ចេញសូរពាក្យសព្ទដោយមានសូរព្យញ្ជនៈចុងព្យាង្គដូចជាភាសាបារាំងឬអង់គ្លេសជាដើម។ ភាសាមួយចំនួនទៀតបញ្ចេញសូរស្រៈខ្លីនៅចុងព្យាង្គដូចជាភាសាបាលី-សំស្ក្រឹតជាដើម។ ភាសាខ្លះទៀតមានទំនោរបញ្ចេញសូរខ្លីៗបញ្ចប់ត្រឹមសូរព្យញ្ជនៈប្រកបគ្មានសូរស្រៈនៅខាងចុងឡើយដូចជាភាសាខ្មែរជាដើម។ ភាសាមួយចំនួនមានស្នៀងដែលនាំឱ្យមានការប្រែប្រួលន័យដូចជាភាសាវៀតណាម ភាសាថៃ ចំណែកភាសាមួយចំនួនទៀតគ្មានស្នៀងឡើយ គឺពាក្យអានស្មើគ្មានការលើកដាក់សំឡេងដែលនាំឱ្យមានការប្រែប្រួលន័យឡើយ ដូចជាភាសាខ្មែរជាដើម ប៉ុន្តែភាសាខ្មែរមានចម្បាស់សូរព្យាង្គទៅតាមពាក្យនីមួយៗដែលមានចំនួនព្យាង្គខុសៗគ្នា។

សំណូរពាក្យសព្ទនៃភាសាមួយតែងមានអត្តសញ្ញាណរៀងៗខ្លួន ដែលខុសប្លែកពីភាសាដទៃទៀត ហើយអត្តសញ្ញាណនេះមានសភាពរឹងមាំណាស់មិនទោរទន់ទៅរកភាសាបរទេសណាមួយឡើយ ផ្ទុយទៅវិញរាល់ពាក្យពេចន៍បរទេសដែលចូលមកត្រូវសម្រួបតាមសំណូរពាក្យនៃភាសាម្ចាស់ស្រុកជាដរាប។ តួយ៉ាងរាល់ពាក្យកម្ចីដែលចូលមកក្នុងភាសាខ្មែរមានដូចជាបាលី-សំស្ក្រឹត បារាំង អង់គ្លេសជាដើម ត្រូវទទួលរងនូវខ្មែរនីយកម្ម ជាពិសេសលើផ្នែកសូរនៅពេលប្រើប្រាស់ក្នុងភាសាខ្មែរ។

សំណូរពាក្យខ្មែរផ្សំឡើងពីសូរសទ្ទនិងសូរសទ្ទឬសូរព្យាង្គនិងសូរព្យាង្គ។ បើគិតទៅលើចំនួនព្យាង្គ ពាក្យខ្មែរអាចចែកជាពាក្យមួយព្យាង្គ ពាក្យពីរព្យាង្គ ពាក្យបីព្យាង្គ ពាក្យបួនព្យាង្គ ពាក្យច្រើនព្យាង្គលើសពីបួនព្យាង្គ។ ពាក្យមួយព្យាង្គ គឺជាពាក្យដែលមានមួយបន្សាយសំឡេង។ ដូចនេះទម្រង់ពាក្យមួយព្យាង្គដូចគ្នានឹងទម្រង់ព្យាង្គ ឧទាហរណ៍ ដី នៅ ផ្ការ ព្រៃ។ ពាក្យពីរព្យាង្គ គឺជាពាក្យដែលមានពីរបន្សាយសំឡេង។ ព្យាង្គទី១ ជាព្យាង្គដើម ឯព្យាង្គទី២ ជាព្យាង្គចុង។ សំណូរព្យាង្គក្នុងពាក្យ គឺព្យាង្គដើមជាព្យាង្គបន្ធើរ ឯព្យាង្គចុងជាព្យាង្គសង្កត់ ឧទាហរណ៍ កកូរ ទទឹក គគ្រឹម។ ពាក្យបីព្យាង្គ គឺជាពាក្យដែលមានបីបន្សាយសំឡេង។ សំណូរព្យាង្គក្នុងពាក្យ គឺព្យាង្គដើមជាព្យាង្គបន្ធើរ ព្យាង្គកណ្ដាលជាព្យាង្គសង្កត់ ព្យាង្គចុងជាព្យាង្គសង្កត់ដែរ ឧទាហរណ៍ ដង្កូវនាង កន្ទុំរុយ។ ពាក្យបួនព្យាង្គ គឺជាពាក្យដែលមានបួនបន្សាយសំឡេង។ សំណូរព្យាង្គក្នុងពាក្យ គឺព្យាង្គដើមជាព្យាង្គបន្ធើរ ព្យាង្គទី២ ជាព្យាង្គសង្កត់ ព្យាង្គទី៣ ជាព្យាង្គបន្ធើរ ព្យាង្គទី៤ ឬព្យាង្គចុងជាព្យាង្គសង្កត់ ឧទាហរណ៍ កន្ទាលត្រអាក គ្រលេងគ្រលោង អំពិលអំពែក (គេន រង្សី, ២០១៨: ៥២-៥៣)។

### ២.៥.៣. សំណេរពាក្យ

សំណេរជាបែបបទនៃគំនូសស្នាមអក្សរ (ព្យញ្ជនៈ ស្រៈ និងសញ្ញាវណ្ណយុត្ត។ល។) ដែលចូលផ្សំគ្នាតាមក្បួនខ្នាតមួយជាក់លាក់ដើម្បីបង្កើតបានជាពាក្យឬអត្ថបទមួយ។ សំណេរវាកើតចេញមកពីការសរសេរ ហើយវាអាចស្តែងឡើងពីទម្រង់រូបរាងនៃអក្សរឬពាក្យដែលយើងសរសេរ ដូចជាមូល ជ្រុង ទ្រេត ឈរ អក្សរដៃ អក្សរពុម្ព... (ច័ន្ទ សំណព្វ, ២០១២)។

ប្រព័ន្ធសំណេរ គឺជាប្រព័ន្ធនៃនិមិត្តសញ្ញាមួយដែលត្រូវបានប្រើដើម្បីបង្ហាញភាសា។ មានប្រព័ន្ធសំណេរច្រើនប្រភេទខុសៗគ្នាជាមួយនឹងនិមិត្តសញ្ញាតំណាងឱ្យវត្ថុផ្សេងគ្នា សញ្ញាតួអក្សរ ព្យាង្គ និងអក្ខរក្រម។ ប្រព័ន្ធ

សំណេរក៏សំដៅផងដែរទៅដល់អក្ខរៈឬអក្ខរាវិរុទ្ធ គឺជាការសន្មតសម្រាប់បង្ហាញឯកតានៃភាសានិយាយ ដោយការបង្កើតស្លាកស្នាមនៅលើថ្ម ស្លឹកឈើ ដីឥដ្ឋ សំបកឈើ លោហធាតុ ឬក្រដាស...។

ដោយឡែកអក្សរខ្មែរ គឺជាប្រព័ន្ធសំណេរដំបូងបំផុតត្រូវបានប្រើក្នុងអាស៊ីអាគ្នេយ៍ ដែលលេចឡើងដំបូងនៅសតវត្សទី៧ នៃគ្រិស្តសករាជ។ ប្រព័ន្ធសំណេរនេះវិវត្តិចេញពីអក្សរបល្លវៈ ប្រភេទមួយនៃអក្សរគ្រន្ថៈនៃឥណ្ឌាខាងត្បូង ដែលចុងក្រោយចេញពីអក្សរព្រាហ្មីបុរាណនៃឥណ្ឌា។

ក្នុងពាក្យពីរព្យាង្គជាពិសេស គេអាចសរសេររាយព្យាង្គក៏មាន សរសេរគ្រួតព្យាង្គក៏មាន។

-ព្យាង្គរាយ ជាសំណេរព្យាង្គដោយដាក់សទ្ទ (តួព្យញ្ជនៈឬស្រៈ) ឱ្យនៅបន្តបន្ទាប់គ្នា។ ឧទាហរណ៍ ក្របី នោស់ ពូថៅ កាំបិត កំណើត របៀប...។

-ព្យាង្គតម្រួត ជាសំណេរព្យាង្គដោយដាក់តួព្យញ្ជនៈប្រកបនៃព្យាង្គដើមលើតួព្យញ្ជនៈ (ជើងព្យញ្ជនៈ) ដើមនៃព្យាង្គចុង។ ឧទាហរណ៍ បង្ហំ បង្ហាញ បញ្ចេញ បន្លែ ពន្យល់ បណ្ដើរ បន្ត សន្សើម...។

## ២.៥.៤. ន័យពាក្យ

ន័យជាធាតុដ៏សំខាន់នៃភាសាដែលអាចនាំឱ្យគេអាចយល់ដឹងនិងប្រើប្រាស់ភាសាមួយបាន។ ន័យ គឺជាខ្លឹមសារដែលស្តែងចេញពីការប្រើភាសាទាំងក្នុងសម្តីទាំងក្នុងសំណេរ។ ការយល់ដឹងទៅលើន័យរបស់ពាក្យមានលក្ខណៈជាប្រព័ន្ធនៅក្នុងភាសាមួយ ដែលមិនទាមទារការសិក្សានោះឡើយ។ ជាក់ស្តែងប្រជាជនសាមញ្ញដែលមិនបានឆ្លងកាត់ការសិក្សាអំពីភាសា ក៏ពួកគាត់អាចយល់ពីន័យនៅក្នុងសម្តីដែលពួកគាត់និយាយប្រាស្រ័យទាក់ទងប្រចាំថ្ងៃនោះដែរ ព្រោះន័យកើតឡើងដោយសារទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសម្តីនឹងវត្ថុក្នុងលោកៈនិងសកម្មភាពប្រចាំថ្ងៃ។ ការប្រើប្រាស់ដដែលជាដដែលយូរៗទៅ ធ្វើឱ្យមនុស្សអាចចាប់បាននូវខ្លឹមសារនៃសម្តី ហើយប្រើប្រាស់បានយ៉ាងងាយស្រួល។

ន័យរបស់សម្តី ផ្ដុំឡើងឬកើតពីន័យរបស់ពាក្យចងសម្ព័ន្ធនឹងគ្នាទៅតាមក្បួនខ្នាតមួយច្បាស់លាស់។ ន័យពាក្យសព្វអាចប្រែប្រួលទៅតាមបរិបទ សម័យកាល នយោបាយ ឬសម្ព័ន្ធឃ្លាល្បះ។ ដូច្នេះហើយទើបន័យរបស់ពាក្យដែលផ្តល់ដោយវចនានុក្រមមិនអាចគ្របដណ្តប់ឱ្យបានសព្វគ្រប់ទៅលើន័យរបស់ពាក្យនោះ ដែលស្តែងឡើងនៅក្នុងភាសាឡើយ។

ន័យរបស់ពាក្យតែងតែប្រែប្រួលមិនទៀងទាត់ ហើយអ្នកប្រើប្រាស់ពាក្យអាចនឹងរងគ្រោះដោយសារការប្រែប្រួលនេះ (ដូចជាមានការយល់ច្រឡំរវាងពាក្យ *បបរកូនខ្ចី* និង *បបរកូនក្មេង*)។ ពេលខ្លះការព្យាយាមប្រើប្រាស់ពាក្យវប្បធម៌ជំនួសឱ្យពាក្យសាមញ្ញៗ ក៏អាចធ្វើឱ្យការប្រើប្រាស់ពាក្យនេះនៅក្នុងភាសាមិនបានជោគជ័យដែរ (ដូចជាការប្រើប្រាស់ពាក្យ *រាជាយស្ម័យាន* ជំនួសឱ្យ *ស្ថានីយរថភ្លើង*, *ត្រីចក្រយាន* ជំនួសឱ្យ *ស៊ីក្លូ*)។ មិនត្រឹមតែពាក្យទេដែលប្រែប្រួល សូម្បីតែវត្ថុដែលវាសម្គាល់ក៏ផ្លាស់ប្តូរលឿនផងដែរ (ដូចជាពាក្យ *ទូរស័ព្ទ* ពីមុនបំពេញមុខងារត្រឹមតែសំឡេង តែបច្ចុប្បន្ន *ទូរស័ព្ទ* បំពេញមុខងារច្រើនយ៉ាង)។

## ២.៥.៥. ប្រភេទពាក្យ

ប្រភេទពាក្យ គឺជាការបែងចែកពាក្យនៅក្នុងភាសាណាមួយជាក្រុមផ្សេងៗពីគ្នាដោយពឹងផ្អែកជាពិសេសលើមុខងាររបស់ពាក្យនៅក្នុងប្រយោគ ព្រមទាំងអាចពឹងផ្អែកលើរូបសាស្ត្ររបស់ពាក្យផង។

ពាក្យទាំងឡាយដែលស្ថិតនៅក្នុងប្រភេទជាមួយគ្នា គឺជាពាក្យដែលអាចជំនួសគ្នាទៅវិញទៅមកបានក្នុងទីតាំងណាមួយនៃប្រយោគ ហើយមិនធ្វើឱ្យប្រយោគទាំងនោះប្រាសចាកឬខុសពីរចនាសម្ព័ន្ធផ្នែកសម្ព័ន្ធវិទ្យានៃភាសាឡើយ ថ្វីដ្បិតតែប្រយោគទាំងនោះអាចមានន័យខុសប្លែកពីគ្នាឬមានន័យមិនសមហេតុផលក៏ដោយ។

ប្រភេទពាក្យនៅក្នុងភាសាខ្មែរត្រូវបានអ្នកសិក្សាឯកភាពគ្នាបែងចែកជា៨ គឺនាម គុណនាម កិរិយា គុណកិរិយា សព្វនាម ធ្នាក់ ឈ្នាប់ និងឧទាន។

-នាម ជាពាក្យស្តែងពីមនុស្ស សត្វ រុក្ខជាតិ ទីកន្លែង ស្ថានភាព សកម្មភាព គំនិត...។ ក្នុងករណីខ្លះនាមមានរូបសាស្ត្រប្លែកពីរូបសាស្ត្រនៃពាក្យដទៃទៀតនិងជាពាក្យដែលអាចបំពេញមុខងារជាប្រធានឬកម្មរងនៅក្នុងឃ្លា។ នាមជាធាតុចាំបាច់នៃកន្សោមនាម។ ឧទាហរណ៍ និស្សិត ចាន ពូសុខ តុ គោ ដំណើរ...។

-សព្វនាម ជាពាក្យប្រើសម្រាប់ស្តែងពីអ្នកនិយាយនិងអ្នកដែលគេនិយាយទៅរកឬសម្រាប់ជំនួសកន្សោមនាមដែលគេនិយាយរួចហើយដើម្បីជៀសវាងការប្រើពាក្យច្រំដែល។ នៅក្នុងឃ្លាសព្វនាមបំពេញមុខងារដូចជានាមឬកន្សោមនាមដែរ គឺវាអាចជាប្រធានឬកម្មរងនៃកិរិយា។ ឧទាហរណ៍ ខ្ញុំ យើង អ្នក វា គាត់ នេះ នោះ អ្វី នរណា ដែល ខ្លះ...។

-គុណនាម ជាពាក្យសម្រាប់ប្រើជាពាក្យរណបឱ្យនាម។ គុណនាមជាធាតុមិនចាំបាច់នៃកន្សោមនាមនិងជាធាតុនៃកន្សោមកិរិយា។ គុណនាមចែកជាពីរយ៉ាង គឺគុណនាមប្រក្រតីនិងគុណនាមកំណត់។ គុណនាមប្រក្រតីមានដូចជា ធំ តូច ខ្ពស់ ទាប ក្រាស់ ស្តើង ស ក្រហម ថ្មី ចាស់ ស្អាត...។ គុណនាមកំណត់មានដូចជា នេះ នោះ មួយ ពីរ ខ្លះ មួយចំនួន ណាមួយ អ្វីខ្លះ អ្នកណា...។

-កិរិយាសព្ទ ជាពាក្យដែលសម្តែងអំពើឬប្រាប់សភាពរបស់មនុស្ស សត្វ រុក្ខជាតិ វត្ថុ អ្វីមួយ និងជាពាក្យដែលគេអាចដាក់ឱ្យទៅជាទម្រង់បដិសេធន៍បាន។ កិរិយាសព្ទមានដូចជា ដេក ហៅ ទៅ ស៊ី ផឹក ច្រៀង...។

-គុណកិរិយា ជាពាក្យដែលប្រើសម្រាប់សម្តែងលក្ខណៈឱ្យកិរិយាសព្ទ គុណនាម និងគុណកិរិយាដូចគ្នា។ គុណកិរិយាមានដូចជា ពូកែ ខ្លាំង លឿន យឺត ច្រើន រហ័ស តិច បំផុត...។

-ធ្នាក់ ជាពាក្យប្រើជាមួយនឹងនាម កន្សោមនាម កិរិយា កន្សោមកិរិយា ដើម្បីបង្កើតកន្សោមមានធ្នាក់។ ធ្នាក់មានដូចជា ប្រហែល ចាប់ពី បន្ទាប់ពី ក្រោម លើ ក្នុង ក្រៅ ក្បែរ របស់ ដើម្បី សម្រាប់ ...។

-ឈ្នាប់ ជាពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យ កន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬឃ្លាទៅនឹងឃ្លា។ ឈ្នាប់ចងមានដូចជា និង ឬ ឯ ចំណែក តែ ប៉ុន្តែ ហើយ...។ ឈ្នាប់ឃ្លាមានដូចជា ថា ដើម្បី ពេលណា កាលណា បើ ប្រសិនបើ ព្រោះ ពីព្រោះ លុះត្រាតែ...។

-ឧទានសព្ទ គឺជាពាក្យឬកន្សោមពាក្យដែលគេប្រើភ្ជាប់ជាមួយកន្សោមពាក្យឬឃ្លាសម្រាប់សម្តែងការភ្ញាក់ផ្អើល ត្រេកអរ តក់ស្លុត ងឿងឆ្ងល់ កោតសរសើរ ខឹង បញ្ចេញកំហឹង... ដែលកើតឡើងភ្លាមៗ។ ឧទានសព្ទមានដូចជា យី! យើស! អ៊ា! នែ! ពុទ្ធោ! អុញ!... ។

## ២.៥.៦. មុខងារពាក្យ

ឥឡូវ យើងអាចស្វែងយល់ដោយខ្លួនឯងដោយតម្រៀបពាក្យខាងក្រោមដើម្បីបង្កើតបានជាឃ្លាមួយដែលមានន័យពេញលេញ *ក្នុង សៀវភៅ បណ្ណាល័យ និស្សិត នៅ អាន* ។ យើងអាចតម្រៀបពាក្យតាមក្បួនដាក់លាក់មួយដើម្បីនាំទៅដល់ន័យមួយ៖ និស្សិតអានសៀវភៅនៅក្នុងបណ្ណាល័យ ។

ក្បួនដែលយើងរៀបចំពាក្យដើម្បីនាំទៅដល់ន័យត្រូវបានហៅថា សម្ព័ន្ធវិទ្យា។ ដោយអាស្រ័យលើទីតាំងនៅក្នុងឃ្លា ពាក្យអាចមានមុខងារផ្សេងៗពីគ្នា។ មុខងារទាំងនោះមានដូចជា៖

-ប្រធាន (subject)៖ ប្រធាន គឺជាអ្នកធ្វើឬអ្នកសម្តែងអំពើ។ នៅក្នុងឃ្លាខាងលើ និស្សិត មានមុខងារជាប្រធាន។

-កិរិយាសព្ទ (verb)៖ កិរិយាសព្ទ គឺជាអំពើកំពុងប្រព្រឹត្ត។ នៅក្នុងឃ្លាខាងលើ អាន មានមុខងារជាកិរិយាសព្ទ។

-កម្មបទផ្ទាល់ (direct object) ៖ កម្មបទផ្ទាល់ គឺជាអ្នកទទួលរងអំពើ។ នៅក្នុងឃ្លាខាងលើ *សៀវភៅ* គឺជាកម្មបទផ្ទាល់។

ក្រៅពីនេះ ពាក្យអាចមានមុខងារជាកម្មបទមិនផ្ទាល់ គុណកម្មបទ គុណបទ គុណប្រធាន និងឧបបទជាដើម។

## សំណួរ

១. តើការបង្កើតពាក្យជាអ្វី?
២. ចូរលើកយកទស្សនៈនៃអ្នកសិក្សាមួយចំនួនដែលទាក់ទងនឹងការបង្កើតពាក្យ។
៣. តើវិធីបង្កើតពាក្យជាអ្វី?
៤. តើគេប្រើវិធីអ្វីខ្លះដើម្បីបង្កើតពាក្យ?
៥. តើវិធីបង្កើតពាក្យណាមួយដែលខ្មែរប្រើប្រាស់ច្រើនជាងគេ? ចូររៀបរាប់ឱ្យបានក្បោះក្បាយ។
៦. តើវិធីតម្រាប់សូរនិងវិធីសន្ទតខុសគ្នាដូចម្ដេច?
៧. តើវិធីបន្សំបែបខ្មែរនិងបន្សំបែបបាលី-សំស្រ្កឹតមានលក្ខណៈដូចគ្នានិងខុសគ្នាដូចម្ដេចខ្លះ?
៨. តើវិធីគន្លាស់និងវិធីគន្លាស់កាត់ដូចគ្នាដែរឬទេ? ចូរពន្យល់។
៩. តើរូបសព្ទវិទ្យាជាអ្វី?
១០. តើរូបសព្ទជាអ្វី?
១១. តើរូបសព្ទចែកចេញជាប៉ុន្មានប្រភេទ? អ្វីខ្លះ?
១២. តើបុព្វបទជាអ្វី? បុព្វបទមានអ្វីខ្លះ?
១៣. តើបុរេបទជាអ្វី? ចូរបង្ហាញពីតួនាទីបុរេបទមួយចំនួនក្នុងការចូលរួមបង្កើតពាក្យនៅក្នុងភាសាខ្មែរ។
១៤. តើបុរេសព្ទជាអ្វី? ចូរបង្ហាញពីតួនាទីបុរេសព្ទមួយចំនួនក្នុងការចូលរួមបង្កើតពាក្យនៅក្នុងភាសាខ្មែរ។
១៥. តើផ្នត់ដើមជាអ្វី?
១៦. តើផ្នត់ដើមមានប៉ុន្មានទម្រង់? អ្វីខ្លះ? ចូររៀបរាប់អំពីទម្រង់នីមួយៗឱ្យបានក្បោះក្បាយ។
១៧. តើផ្នត់ដែកជាអ្វី?
១៨. តើផ្នត់ដែកមានប៉ុន្មានទម្រង់? អ្វីខ្លះ? ចូររៀបរាប់អំពីទម្រង់នីមួយៗឱ្យបានក្បោះក្បាយ។
១៩. តើបច្ឆិមបទជាអ្វី? ចូរបង្ហាញពីតួនាទីបច្ឆិមបទមួយចំនួនក្នុងការចូលរួមបង្កើតពាក្យនៅក្នុងភាសាខ្មែរ។
២០. តើកាឡរូបជាអ្វី? ចូរបង្ហាញពីលក្ខណៈនៃកាឡរូបនៅក្នុងភាសាខ្មែរឱ្យបានច្បាស់លាស់។
២១. តើក្បួនរូបសព្ទវិទ្យាបានជួយដោះស្រាយបញ្ហាអ្វីខ្លះចំពោះរូបសព្ទដែលចូលរួមបង្កើតពាក្យ?
២២. ចូរបង្ហាញពីបូរណភាពនៃវចនៈតាមក្បួនរូបសព្ទវិទ្យា។
២៣. តើពាក្យជាអ្វី? ពាក្យនីមួយៗត្រូវមានលក្ខណៈអ្វីខ្លះ?
២៤. តើសំណួរពាក្យនៅក្នុងភាសាខ្មែរមានលក្ខណៈដូចម្ដេចខ្លះ?
២៥. តើសំណេរពាក្យនៅក្នុងភាសាខ្មែរមានលក្ខណៈដូចម្ដេចខ្លះ?
២៦. តើន័យរបស់ពាក្យមានលក្ខណៈដូចម្ដេចខ្លះ?
២៧. ចូររៀបរាប់អំពីប្រភេទពាក្យនៅក្នុងភាសាខ្មែរ។
២៨. តើពាក្យមានមុខងារអ្វីខ្លះ?

# មេរៀនទី៥
# សម្ព័ន្ធវិទ្យា

## ១. និយមន័យ

សម្ពន្ធ ឬសម្ព័ន្ធ (សំ-ព័ន) ន. (សំ.បា. សម្ពន្ធ) ការចងភ្ជាប់គ្នា, ការតភ្ជាប់គ្នា; ដំណើរទាក់ទងរកគ្នា: មានសម្ពន្ធនឹងគ្នា មានដំណើរទាក់ទងគ្នា។ ព.វ. ចំណងបទ ឬចំណងប្រយោគ គឺការចងបទក្នុងសង្កាត់មួយៗ ឬក្នុងប្រយោគមួយៗឱ្យដឹងថា បទណាចូលទៅរកបទណា, បទណាជាប្រធាន, ណាជាកិរិយា, ណាជាអំពើ ជាដើម; ដូចជា ខ្ញុំទៅធ្វើការឯសាលាស្រុក, សម្ព័ន្ធថា : ខ្ញុំ ជាប្រធានរបស់ ទៅ, ទៅ ជាកិរិយាសព្ទរបស់ ខ្ញុំ, ធ្វើ ជាកិរិយាប្រាប់បំណងរបស់ ទៅ (ទៅដើម្បីធ្វើ); ការ ជាអំពើរបស់ ធ្វើ, ឯសាលាស្រុក ជាអាយតនិបាតប្រាប់ទី (ដែលត្រូវធ្វើការ) (វចនានុក្រមខ្មែរ ភាគ១និង២, ១៩៦៧-១៩៦៨: ១២៩៤)។

សម្ព័ន្ធវិទ្យា សិក្សាពីបន្សំសម្ព័ន្ធនិងទំនាក់ទំនងសម្ព័ន្ធ រវាងពាក្យនិងរវាងឃ្លាក្នុងអង្គធាតុភាសា។ ទំនាក់ទំនងសម្ព័ន្ធនេះ មានន័យពិសេស និងមានរូបភាពបង្ហាញនូវន័យទាំងនោះ។ អាស្រ័យហេតុនេះ ក៏អាចនិយាយថា សម្ព័ន្ធវិទ្យាសិក្សាពីប្រភេទឬថ្នាក់សម្ព័ន្ធ អំពីទីកន្លែងរបស់ពាក្យនិងបន្សំពាក្យ សិក្សាពីសម្ព័ន្ធទម្រង់ប្រភេទ ឬថ្នាក់ទាំងនោះ (អុក ចួន, ១៩៨៧: ៣៤)។

សម្ព័ន្ធវិទ្យា ជាផ្នែកមួយនៃវេយ្យាករណ៍ដែលក្នុងនោះ សទ្ទតាវិទ្យានិងវចនវិទ្យាជាផ្នែកពីរទៀត។ សម្ព័ន្ធវិទ្យាសិក្សាអំពីវិធីចងក្រងពាក្យឱ្យទៅជាឃ្លា ដែលក្នុងនោះប្រភេទពាក្យឥតមានលំដាប់ដូចគ្នាទេ ពីភាសាមួយទៅភាសាមួយ។ បើគេពិនិត្យមើលសម្ព័ន្ធពីភាសាមួយទៅភាសាមួយ គឺគេសិក្សាអំពីសម្ព័ន្ធវិទ្យាទូទៅ។ បើគេសិក្សាអំពីសម្ព័ន្ធវិទ្យារបស់ភាសាមួយ សម្ព័ន្ធវិទ្យាមានឈ្មោះថា សម្ព័ន្ធវិទ្យានៃភាសានោះឯង។ ដោយសម្ព័ន្ធវិទ្យាសិក្សាអំពីឃ្លានិងដោយឃ្លាមានច្រើនប្រភេទ ដូចនេះសម្ព័ន្ធវិទ្យាត្រូវសិក្សាអំពីប្រភេទឃ្លា អំពីវាចកៈ (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៣: ៤៨)។

សរុបមក សម្ព័ន្ធវិទ្យា ជាវិទ្យាសាស្ត្រមួយដែលសិក្សាអំពីរចនាសម្ព័ន្ធនិងមុខងារពាក្យនៅក្នុងឃ្លា។

## ២. ប្រវត្តិនៃការសិក្សាសម្ព័ន្ធវិទ្យា

ស្នាដៃលើផ្នែកវេយ្យាករណ៍ត្រូវបានសរសេរតាំងពីយូរយារណាស់មកហើយ មុនវត្តមាននៃសម្ព័ន្ធវិទ្យាទំនើប ជាពិសេសវាមាននៅក្នុងស្នាដៃរបស់លោក បាំនីនី (ស.វ.ទី៤ មុនគ.ស.)។ នៅបស្ចិមប្រទេស បានបង្កើតសាលាបង្រៀនទាក់ទងនឹងវេយ្យាករណ៍ប្រពៃណី ដែលមានឈ្មោះថា ឌីយ៉ូនីស៊ីស ត្រាស (Dionysius Thrax) (170-90 BC) នៃប្រទេសក្រិក។ អស់រយៈពេលរាប់សតវត្ស ការសិក្សាអំពីសម្ព័ន្ធវិទ្យា ត្រូវបានគេចាត់ទុកជាវេយ្យាករណ៍ទូទៅ ដែលបានអធិប្បាយដោយលោក អង់ទាន់ អាណូល (Antoine Arnauld) ជាទស្សនវិទូបារាំង ក្នុងឆ្នាំ១៦៦០។

នៅសតវត្សទី១៩ គេបានបង្កើតឡើងនូវភាសាវិទ្យាប្រវត្តិនិងប្រៀបធៀប។ ភាសាវិទូបានចាប់ផ្ដើមយល់ដឹងច្បាស់ពីភាពផ្សេងៗគ្នានៃភាសាមនុស្ស ហើយបានសន្មតពីភាពទាក់ទងគ្នារវាងភាសានិងតក្កវិទ្យា។ គេបានយល់ថា តក្កវិទ្យាមិនអាចធ្វើជាមូលដ្ឋានសម្រាប់សិក្សាអំពីរចនាសម្ព័ន្ធនៃភាសាបានទេ។

ក្រោយមកទៀត គេបានយកវេយ្យាករណ៍ផតរ៉ូយ៉ាល់ (Port-Royal) ធ្វើជាគំរូនៃការសិក្សាសម្ព័ន្ធវិទ្យាដោយផ្ដោតលើតក្កវិទ្យា (តាមពិត មួយផ្នែកធំនៃតក្កវិទ្យាផតរ៉ូយ៉ាល់ បានចម្លងពីវេយ្យាករណ៍ទូទៅ) ។ ថ្នាក់វាក្យសម្ព័ន្ធ (syntactic categories) បានបង្កើតឡើងជាមួយតក្កវិទ្យា ហើយគ្រប់ឃ្លាទាំងអស់ត្រូវបានវិភាគជា ប្រធាននិងបម្រាប់ប្រធាន។ ក្រុមភាសាវិទូផ្នែកភាសាវិទ្យាប្រៀបធៀប បានយល់ស្របទស្សនៈនេះ ដូចជា លោក ហ្វ្រង់ បូប (Franz Bopp) ជាភាសាវិទូអាល្លឺម៉ង់ (1791 –1867) ជាដើម។

លោក អារីស្តូត បានបែងចែកល្បះជា ប្រធាន និងបម្រាប់ប្រធាន។ ការសិក្សាអំពីសម្ព័ន្ធវិទ្យាមានការរីកចម្រើនយឺតណាស់ ហើយមកដល់ពាក់កណ្តាលសតវត្សទី២០ គេបានផ្តោតលើតែសទ្ទតាវិទ្យានិងរូបសព្ទវិទ្យា ចំណែកឯសម្ព័ន្ធវិទ្យា មិនបានរំលេចឱ្យឃើញជាក់ច្បាស់នោះទេ។ នៅសតវត្សទី២០ សម្ព័ន្ធវិទ្យាបានដើរតួនាទីសំខាន់នៅក្នុងទ្រឹស្តីភាសាវិទ្យា ដែលគេហៅថា សតវត្សនៃទ្រឹស្តីសម្ព័ន្ធវិទ្យា។

នៅទសវត្សទី៥០ នៃសតវត្សទី២០ ភាសាវិទូម្នាក់ឈ្មោះ ហ្សេលីក ហារីស៍ (Zellig Harris) បានចាប់ផ្តើមអភិវឌ្ឍនូវវិធីថ្មីដែលមានការចាប់អារម្មណ៍ចំពោះសម្ព័ន្ធវិទ្យានេះឡើង។ អស់រយៈកាលជាងមួយទសវត្សក្រោយមកទើបកូនសិស្សរបស់លោក ដែលមានឈ្មោះថា ណម ឆមស្គី (Noam Chomsky) បានបកស្រាយបន្ថែមលើគំនិតគ្រូរបស់លោក គឺវេយ្យាករណ៍បំប្លែង (Generative Grammar) ហើយនិងផ្នែកពិសេសៗនៃវេយ្យាករណ៍នេះ ដែលហៅថា វេយ្យាករណ៍បំប្លែង (Transformational Grammar)។ លោក ឆមស្គី បានអះអាងថា សម្ព័ន្ធវិទ្យាគឺមិនត្រឹមតែងាយស្រួលបង្រៀននោះទេ ថែមទាំងមានការពេញចិត្តយ៉ាងខ្លាំងក្នុងការសង្កេតពិនិត្យលើភាសា ហើយគាត់បានបញ្ចុះបញ្ចូលឱ្យភាសាវិទូជំនាន់ក្រោយៗមកទៀតយល់ថា អ្វីដែលគាត់បានលើកឡើង គឺត្រឹមត្រូវ។ ជាលទ្ធផលការសិក្សាអំពីសម្ព័ន្ធវិទ្យាបានក្លាយទៅជាការសិក្សាយ៉ាងលេចធ្លោបំផុតជាងកាលពីមុន ហើយរហូតមកដល់សព្វថ្ងៃនេះ មានភាសាវិទូជាច្រើនដែលដើរតាមទ្រឹស្តីរបស់លោក ណម ឆមស្គី។ ពួកគេយល់ឃើញថាសម្ព័ន្ធវិទ្យាគឺស្នូលនៃរចនាសម្ព័ន្ធភាសា។

## ៣. និមិត្តសញ្ញាក្នុងសម្ព័ន្ធវិទ្យា

ក្នុងការវិភាគសម្ព័ន្ធវិទ្យា គេប្រើគំនូសនិងនិមិត្តសញ្ញាមួយចំនួនដូចជា៖

* សញ្ញាផ្កាយនេះ មានន័យថាល្បះមិនត្រឹមត្រូវតាមក្បួនវេយ្យាករណ៍។ ឧទាហរណ៍: ធីតាទៅសាលា។ * សាលាទៅធីតា។ ល្បះនេះជាល្បះមិនត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ក្នុងភាសាខ្មែរទេ។

→ សញ្ញាព្រួញនេះ មានន័យថា សរសេរជា (ឧ. កន → ន + ព)។

\+ សញ្ញាលេខបូកនេះ មានន័យថា ផ្សំជាមួយនឹង (ឧ. ល→ កន + កកិ)។

= ស្មើ (ឧ. កន=កន្សោមនាម)។

ø សញ្ញានេះ មានន័យថាសំណុំទទេ ឬគ្មានធាតុ។ ក្នុងល្បះមិនពេញលេញមួយ អាចមានតែកន្សោមនាម ឬកន្សោមកិរិយា។ ឧទាហរណ៍: ***ចេញទៅ***! យើងអាចសរសេរល្បះនេះដូចតទៅ៖ ល→ ø + កកិ។

□ សញ្ញានេះ មានន័យថា ការតាងល្បះជាប្រអប់។

∧ សញ្ញានេះ ប្រើសម្រាប់តាងល្បះជាមែកធាង។

ន = នាម, គុ = គុណនាម, សព្វ = សព្វនាម, កិ = កិរិយាសព្ទ, គុណ ឬគុកិ = គុណកិរិយា, ធ = ធ្នាក់, ឈ = ឈ្នាប់, កំ = កំណត់(គុណនាមកំណត់), ព = ពង្រីក, ល = ល្បះ, ឃ = ឃ្លា, ប្រ = ប្រធាន, កន = កន្សោមនាម, កកិ = កន្សោមកិរិយា, កគុ = កន្សោមគុណនាម, កគុណ ឬកគុកិ = កន្សោមគុណកិរិយា, កមធ = កន្សោមមានធ្នាក់, កនប្រ = កន្សោមនាមប្រធាន, កន១ = កន្សោមនាមមួយ, កន២ = កន្សោមនាមពីរ, កទ = កម្មទេសកាល, កកន្លែង = កម្មកន្លែង, កហេតុ = កម្មហេតុ, កបផ = កម្មបទផ្ទាល់, កបម = កម្មបទមិនផ្ទាល់, ឃទេស = ឃ្លាទេសកាល, ឈឃ = ឈ្នាប់ឃ្លា, នសា = នាមសាធារណ៍, នអសា = នាមអសាធារណ៍, កប្រ = កន្សោមប្រធាន, គុប្រ = គុណប្រធាន, គុប = គុណបទ, ឧប = ឧបបទ, កបំពេញ = កម្មបំពេញបទ, ឃរណប = ឃ្លារណប...។

## ៤. ទិដ្ឋភាពនៃសម្ព័ន្ធវិទ្យា

វេយ្យាករណ៍និយាមច្រើនតែចាប់ផ្តើមថា វេយ្យាករណ៍ជាក្បួនឱ្យចេះសរសេរត្រឹមត្រូវនិងនិយាយត្រឹមត្រូវ។ វេយ្យាករណ៍ប្រភេទនេះ លាយឡំឬច្រឡំក្បួនរបស់ភាសាជាមួយនឹងក្បួនរបស់អក្ខរាវិរុទ្ធនៃភាសា លាយឡំប្រព័ន្ធយន្តការ(ឬប្រព័ន្ធមូលដ្ឋានរបស់ភាសា) និងប្រព័ន្ធទម្លាប់វាចា(ឬប្រព័ន្ធនៃផលប្រើប្រាស់ភាសា) ហើយមានចែង

តិចតួចពីសូរវិទ្យានិងសទ្ទតាវិទ្យា។ ម្យ៉ាងទៀត វេយ្យាករណ៍នេះ គ្រាន់តែជាការបង្ហាញរំឭកតាមក្បួននិយាមប៉ុណ្ណោះ ដោយមិនប្រើទម្រង់ ឬសំណង់ល្បះដាក់លាក់ណាមួយដែលជាទម្លាប់វាចានោះទេ។

តាមអ្នកភាសាវិទ្យាសម័យថ្មី យើងគិតថា វេយ្យាករណ៍និយាមគឺជាផ្នែកមួយដែលមិនមានប្រយោជន៍។ យើងយល់ឃើញថា ភាសារបស់មនុស្សប្រៀបដូចជាតឹកតាងនៃបាតុភូតមួយដែលតម្រូវឱ្យមានការសង្កេតឱ្យបានច្បាស់លាស់ ជាជាងការដែលត្រូវបានគេដាក់បទបញ្ញត្តិឱ្យប្រើ។

វេយ្យាករណ៍ពណ៌នា តែងតែប៉ងប្រាថ្នាធ្វើឱ្យភាសាជាក្បួនតែមួយ ដែលមានរបៀបរៀបរយត្រឹមត្រូវក្នុងការនិយាយស្ដី។ ម្យ៉ាងទៀត ការយល់ដឹងអំពីភាសាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងប្រព័ន្ធសាំញ៉ាំដែលពោរពេញទៅដោយក្បួនច្បាប់ និងការប្រកាន់យករបស់ក្រុមនីមួយៗ។ ភាសាគឺជាបាតុភូតនៃការពិចារណាដ៏សាំញ៉ាំដែលវាតម្រូវឱ្យមានការសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រ។ នោះគឺថា យើងអាចសរសេររូបមន្តដែលបានមកពីសម្មតិកម្មទូទៅទាំងឡាយពីរចនាសម្ព័ន្ធនៃភាសាវិទ្យា ហើយធ្វើតេស្តសាកល្បងទៅលើសម្មតិកម្មទាំងនោះ។ វាអាចឱ្យលទ្ធផលផ្ទុយទៅនឹងការពិតនៃភាសាដែលមាន ឬស្របទៅនឹងអ្វីដែលភាសាមាន។

ការសិក្សាវេយ្យាករណ៍លើបញ្ញត្តិនេះ គឺស្ថិតនៅលើផ្នែកសម្មតិកម្មងាយៗច្បាស់លាស់បំផុត។ វាក្យសព្ទ «សម្ព័ន្ធវិទ្យា» ត្រូវបានគេប្រើជាញឹកញាប់ដើម្បីជំនួសវាក្យសព្ទ «វេយ្យាករណ៍» ក្នុងកិច្ចការបច្ចេកទេសភាសាវិទ្យា។ ខណៈពេលដែលបញ្ញត្តិទាំងពីរនេះអាចផ្លាស់ប្ដូរគ្នាបានក៏ដោយ ក៏បញ្ញត្តិ «វេយ្យាករណ៍» ប្រហែលត្រូវបានគេប្រើយ៉ាងទូលាយដើម្បីគ្របដណ្ដប់ទៅដល់ទិដ្ឋភាពនៃរចនាសម្ព័ន្ធនៃភាសា។ ផ្ទុយទៅវិញ «សម្ព័ន្ធវិទ្យា» សំដៅទៅលើវិធីដែលពាក្យផ្សំគ្នាបង្កើតបានទៅជាឃ្លា ហើយឃ្លាផ្សំគ្នាបង្កើតបានជាល្បះ។ ថ្វីត្បិតតែព្រំដែននៃសម្ព័ន្ធវិទ្យាមិនស្រួចស្រាលក៏ដោយ ក៏សម្ព័ន្ធវិទ្យាមានលក្ខណៈផ្ទុយគ្នាទៅនឹងផ្នែកសូរវិទ្យា សទ្ទតាវិទ្យា រូបសព្ទវិទ្យា និងន័យវិទ្យា នៅក្នុងវិធីដែលវេយ្យាករណ៍មិនបានធ្វើវា (ងួន សំអុល, ២០០៩: ១-២)។

សម្ព័ន្ធវិទ្យា គឺផ្ដោតសំខាន់លើរចនាសម្ព័ន្ធល្បះ ហើយវាចែកចេញជាបីទិដ្ឋភាពគឺ ការដាក់ពាក្យជាក្រុម មុខងារពាក្យ និងលំដាប់ពាក្យ។ ទិដ្ឋភាពទាំងបីនៃរចនាសម្ព័ន្ធល្បះនេះ គឺបង្ហាញឱ្យឃើញនៅក្នុងការតោងមែកធាងនៃល្បះ។

ឧទាហរណ៍: សេះមួយក្បាលនេះស៊ីស្មៅតាមជើងភ្នំ។




**ក-ការដាក់ពាក្យជាក្រុម** គឺជាការប្រមូលផ្ដុំពាក្យចូលទៅក្នុងកន្សោមពាក្យដែលមានន័យនិងមុខងារ ហើយសមាសធាតុផ្សំនីមួយៗបង្កើតបានជាកន្សោមពាក្យផ្សេងៗទៀត។ ក្នុងឧទាហរណ៍នៃល្បះខាងលើ យើងអាចដាក់ពាក្យជាកន្សោមដូចជា កន្សោមនាម (noun phrase) កន្សោមកិរិយា (verb phrase) និងកន្សោមមានធ្នាក់ (prepositional phrase)។

**ខ-មុខងារពាក្យ** ផ្ដោតលើភាពទាក់ទងគ្នារវាងកន្សោមនាមនិងកិរិយាសព្ទ ហើយនិងពាក្យផ្សេងៗទៀតនៅក្នុងល្បះ។ វាមានមុខងារបីប្រភេទនៅក្នុងល្បះខាងលើគឺ: ទំនាក់ទំនងវេយ្យាករណ៍ (grammatical relations)

ថ្នាក់ពាក្យ (parts of speech) ទំនាក់ទំនងបង្គោលនិងរណប (relations of head and modifier)។

-ទំនាក់ទំនងវេយ្យាករណ៍នៅក្នុងឃ្លាមានដូចជា៖

(១) ប្រធាន (subject) ជាកន្សោមនាម នៅក្នុងផ្នែកនៃឃ្លា។

(២) បម្រាប់ប្រធាន (predicate) ជាកន្សោមកិរិយា នៅក្នុងផ្នែកនៃឃ្លា។

(៣) កម្មបទផ្ទាល់ (direct object) ជាកន្សោមនាម នៅក្នុងផ្នែកនៃកន្សោមកិរិយា។

(៤) កម្មបទនៃធ្នាក់ (object of preposition) ជាកន្សោមនាមនៅក្នុងផ្នែកនៃកន្សោមមានធ្នាក់។

-ថ្នាក់ពាក្យ មានដូចជា នាម គុណនាម សព្វនាម កិរិយាសព្ទ គុណកិរិយា ធ្នាក់ ឈ្នាប់ ឧទានសព្ទ។

-បង្គោលនិងរណប: នៅក្នុងក្រុមពាក្យនីមួយៗនៃឃ្លាគឺមានធាតុបង្គោលនិងធាតុរណប។ ធាតុបង្គោលនៃកន្សោមពាក្យមួយគឺជាធាតុចាំបាច់សម្រាប់កន្សោមពាក្យនោះដូចជា ក្នុងកន្សោមនាម មាននាមជាបង្គោល កន្សោមកិរិយាមានកិរិយាជាបង្គោល...ក្រៅពីនោះវាជាធាតុរណប។

**គ-លំដាប់ពាក្យ** គឺជាការរៀបពាក្យជាលំដាប់បន្តបន្ទាប់គ្នានៅក្នុងឃ្លា។ ភាសាខ្លះមានលំដាប់ពាក្យក្នុងកន្សោមពាក្យនិងឃ្លាដូចគ្នា ខ្លះទៀតមានលំដាប់ពាក្យខុសគ្នា។

ឧទាហរណ៍ : តុធំមួយ

A big table

សៀវភៅអង់គ្លេសថ្មីមួយក្បាល

A new English book

ប្រភេទពាក្យនិងមុខងាររវាក្នុងឃ្លាខ្មែរ មានលំដាប់ប្រហាក់ប្រហែលនឹងលំដាប់ក្នុងឃ្លានៃភាសាមួយចំនួនមាន បារាំងឬអង់គ្លេស ជាដើម។

ឧទាហរណ៍៖

ឃ្លាខ្មែរ : គាត់ស្រឡាញ់កញ្ញាបុប្ផា។

ឃ្លាបារាំង : Il aime Mademoiselle Bopha.

ឃ្លាអង់គ្លេស: He loves Ms. Bopha.

## ៥. ក្បួនរចនាសម្ព័ន្ធនៃកន្សោមពាក្យ

### ៥.១. ប្រវត្តិនៃក្បួនរចនាសម្ព័ន្ធនៃកន្សោមពាក្យ

នៅឆ្នាំ១៩៥៧ លោក ណម ឆមស្គី បានកំណត់ព្រំដែននៃការសិក្សាត្រឹមសម្ព័ន្ធវិទ្យា។ គាត់ខិតខំបង្កើត «ទ្រឹស្តីរចនាសម្ព័ន្ធនៃភាសា» ដោយមិនយោងទៅរកភាសាណាមួយជាក់លាក់ឡើយ។ ការសិក្សានោះគាត់ហៅថាវេយ្យាករណ៍ (Grammar) ហើយវាផ្តោតសំខាន់នោះគឺវេយ្យាករណ៍។ គាត់យល់ថាបាតុភូតសម្ព័ន្ធវិទ្យាស្ថិតនៅក្នុងកម្រិតពិសេសនិងស្វ័យភាពមួយ ដែលដាច់ចេញពីវចនវិទ្យា និងសទ្ទតាវិទ្យា ហើយក៏ដាច់ចេញពីន័យវិទ្យាដែរ។ ប្រយោគមួយអាចកើតឡើងត្រឹមត្រូវតាមលក្ខណៈសម្ព័ន្ធវិទ្យា អាចពុំមានន័យត្រឹមត្រូវទេ។

ឧទាហរណ៍៖ * គាត់ឱ្យគំនិតពណ៌បៃតង គ្មានពណ៌ដេកទាំងក្តៅចិត្ត។

គោលបំណងនៃទ្រឹស្តីរចនាសម្ព័ន្ធនៃភាសានេះ គាត់ពន្យល់ប្រយោគបែបវេយ្យាករណ៍ ហើយមិនពន្យល់អ្វីផ្សេងទៀតឡើយ។ វេយ្យាករណ៍មានយន្តកម្មបង្កបង្កើត។ លទ្ធកម្មសម្ព័ន្ធវិទ្យា អាចពិពណ៌នាបានដោយឈរលើសម្មតិកម្មដើមនិងប្រព័ន្ធក្បួន។ ភាសាមិនអាចបង្រួមមកនូវត្រឹមកម្រងទិន្នន័យកំណត់មួយទេ។ នៅក្នុងភាសាវាមានយន្តកម្មដែលអាចឱ្យគេបង្កើតប្រយោគរាប់មិនអស់ តាមរយៈក្បួនដែលមានចំនួនកំណត់។ ចរិតលក្ខណៈនៃការបង្កបង្កើតត្រូវបានបង្ហាញតាមបែបរូបវិធី តាមលក្ខណៈបង្កបង្កើតគ្មានទីបញ្ចប់។ ក្បួនមួយអាចឱ្យគេភ្ជាប់ឃ្លាមួយទៅឃ្លាមួយទៀត ដែលគេអាចអនុវត្តក្បួនដោយគ្មានទីបញ្ចប់ (ងួន សំអុល, ២០០៩: ៥)។

នៅពេលយើងប្រើទម្រង់មែកធាងនៃឈ្នាប់ យើងតែងគិតទៅលើភាពខុសគ្នាពីរ។ ទី១ យើងអាចប្រើវាដើម្បីទាក់ទងនឹងឃ្លាដែលមានលក្ខណៈជាមែកធាងហើយមែកធាងប្រភេទនេះ គេអាចគូរវាបាន។ ទី២ វាអាចបណ្តាលឱ្យកើតមានឃ្លាដ៏ធំជាមួយក្បួនវេយ្យាករណ៍ ហើយក្បួនវេយ្យាករណ៍នេះ គេហៅវាថា ក្បួនរចនាសម្ព័ន្ធកន្សោមពាក្យ (Phrase structure rules)។ យោងតាមក្បួនច្បាប់ដែលបានបង្កើតឡើងក្នុងវេយ្យាករណ៍ កន្សោមនាមបញ្ជាក់ន័យឱ្យនាម ហើយនៅក្នុងឃ្លាមួយ ត្រូវចាំបាច់មាន ប្រធាន កិរិយាសព្ទ នាម ជាដើម។ ក្បួនច្បាប់ក្នុងឃ្លានាំឱ្យកើតមាននូវឃ្លាមួយឡើង ហើយដើម្បីធ្វើឱ្យឃ្លាមួយនោះមានលក្ខណៈត្រឹមត្រូវតាមភាសាមួយយើងត្រូវការវាក្យសព្ទដើម្បីប្រើជាធាតុផ្សំក្នុងឃ្លាបន្ថែមផងដែរ។

តាមរយៈស៊េរីនៃដំណាក់កាលនៃការបំបែក អាចឱ្យគេបង្កើតដំណើរការបន្តបន្ទាប់នៃពាក្យ (ដំណើរការបន្តបន្ទាប់នៃពាក្យគឺជាឃ្លា)។ គេភ្ជាប់ការពិពណ៌នាទៅនឹងស៊េរីនៃដំណាក់កាលនៃការបំបែក។ ការពិពណ៌នានេះគឺជាប្រវត្តិនៃការបំបែកឃ្លា។ គេអាចតាងការបំបែកឃ្លាដោយស៊េរីនៃក្បួនដែលបានអនុវត្តឬដោយមែកធាង។

ឃ្លាមួយត្រូវមានប្រធាននិងបម្រាប់ប្រធាន។ ក្នុងកន្សោមនាមអាចមានធាតុបញ្ជាក់ឬធាតុកំណត់ដែលជាគុណនាម។ រីឯក្នុងកន្សោមកិរិយាវិញ មានកិរិយាដែលជាធាតុបង្គោលនិងកន្សោមនាម។

### ៥.២. ប្រភេទកន្សោមពាក្យ

កន្សោមពាក្យ មាន៥ប្រភេទគឺ កន្សោមនាម កន្សោមកិរិយា កន្សោមគុណនាម កន្សោមគុណកិរិយា និងកន្សោមមានធ្នាក់។

កន្សោមនាម គឺមាននាមជាធាតុបង្គោលនិងជាធាតុទីមួយ។ ឯធាតុទីពីរឬធាតុបន្តគឺធាតុរណបដែលស្ថិតនៅខាងស្តាំ។ ឧទាហរណ៍ *តុល្អ* «*តុ*» ជាធាតុបង្គោល ឯ «*ល្អ*» ជាធាតុរណប។ *តុល្អនេះ* «*តុ*» ជាធាតុបង្គោល ឯ «*ល្អ*» និង «*នេះ*» ជាធាតុរណប។




កន្សោមកិរិយា គឺមានកិរិយាជាធាតុបង្គោល។ ឯធាតុរណប គឺជាធាតុទីពីរ(គុណកិរិយា, កម្មបទ)។ ឧទាហរណ៍ *សំដើរលឿន*។ កន្សោមពាក្យ «*ដើរលឿន*» ជាកន្សោមកិរិយា។ កិរិយា «*ដើរ*» ជាធាតុបង្គោលនិងគុណកិរិយា «*លឿន*» ជាធាតុរណប។




កន្សោមគុណនាម គឺមានគុណនាមជាធាតុបង្គោល។ ចំណែកឯគុណកិរិយាជាធាតុរណប។ ឧទាហរណ៍ គាត់មានចម្លាក់*ល្អណាស់*។ កន្សោមពាក្យ «*ល្អណាស់*» ជាកន្សោមគុណនាម។ គុណនាម «*ល្អ*» ជាធាតុបង្គោលនិងគុណកិរិយា «*ណាស់*» ជាធាតុរណប។




កន្សោមគុណកិរិយា គឺមានគុណកិរិយាទីមួយជាធាតុបង្គោល។ ឯគុណកិរិយាទីពីរជាធាតុរណប។ ឧទាហរណ៍ គាត់ឆ្លើយ*រហ័សណាស់*។ កន្សោមពាក្យ «*រហ័សណាស់*» ជាកន្សោមគុណកិរិយា។ គុណកិរិយា «*រហ័ស*» ជាធាតុបង្គោលនិងគុណកិរិយា «*ណាស់*» ជាធាតុរណប។




កន្សោមមានធ្នាក់ គឺមានធ្នាក់ជាធាតុបង្គោល។ ឯធាតុរណប គឺជាធាតុទីពីរ ដែលវាជាកន្សោមនាម។ ឧទាហរណ៍ ចាបយំ*លើមែកឈើ*។ កន្សោមពាក្យ «*លើមែកឈើ*» ជាកន្សោមមានធ្នាក់។ ធ្នាក់ «*លើ*» ជាធាតុបង្គោល និងកន្សោមនាម «*មែកឈើ*» ជាធាតុរណប។




## ៦. ល្បះ

### ៦.១. និយមន័យល្បះ

ល្បះ គឺជាបន្សំរវាងកន្សោមពាក្យនិងកន្សោមពាក្យ។ វាមានន័យគ្រប់គ្រាន់ស្ដាប់បាន។ ល្បះនីមួយៗបញ្ចប់ដោយសញ្ញាខណ្ឌ(។) សញ្ញាសួរ(?) ឬសញ្ញាឧទាន(!) ក្នុងការសរសេរ។

ល្បះនីមួយៗកើតឡើងដោយកន្សោមពាក្យពីរផ្នែក ដែលជាធាតុសំណង់របស់ខ្លួន។ ក្នុងកន្សោមពាក្យទី១ ពាក្យសំខាន់ជានាម ឯក្នុងកន្សោមពាក្យទី២ ពាក្យសំខាន់ជាកិរិយា។ ដូច្នេះ កន្សោមពាក្យទី១ ហៅថា «កន្សោមនាម» ឯកន្សោមពាក្យទី២ ហៅថា «កន្សោមកិរិយា»។ សរុបមក យើងអាចនិយាយថា ល្បះនីមួយៗកើតឡើងជាចាំបាច់ដោយសារកន្សោមនាមនិងកន្សោមកិរិយា។ យើងអាចសរសេរដូចនេះ៖



តាងល្បះជាមែកធាងនិងប្រអប់៖ ឧទាហរណ៍: កុមារយំ។







ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *កុមារ* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កិរិយា *យំ*។ *យំ* ជាកន្សោមកិរិយា ដែលមានមុខងារជាបម្រាប់ប្រធាននិងជាកិរិយាស្នូលនៃល្បះ។ ល្បះនេះមានធាតុសំណង់ពីរគឺ *កុមារ* ជាកន្សោមនាមប្រធាន នៅខាងឆ្វេងនិង *យំ* ជាកិរិយាអកម្ម នៅខាងស្តាំ។

## ៦.២. រចនាសម្ព័ន្ធល្បះ

គេចែករចនាសម្ព័ន្ធល្បះជា៣បែបគឺ ល្បះទោល ល្បះផ្សំ និងល្បះក្រុង។

**ក. ល្បះទោល** គឺជាល្បះដែលក្នុងនោះមានកន្សោមកិរិយាប្រណាប់ប្រធាន(បម្រាប់ប្រធាន) តែមួយ។

ល្បះទោល ជាធម្មតា វាចាំបាច់ត្រូវមានកន្សោមពីរយ៉ាងសំខាន់ គឺកន្សោមប្រធាននិងកន្សោមកិរិយា ឬបម្រាប់ប្រធាន។

ទម្រង់មូលដ្ឋាននៃល្បះទោលមានដូចជា៖

-ទម្រង់ទី១៖ កន + កកិ ( កិ )

ឧ. ក្មេងដើរ។




-ទម្រង់ទី២៖ កន + កកិ ( កិ + កន )

ឧ១. ធីតាជានិស្សិតឧស្សាហ៍។



ឧ២. និស្សិតគ្រប់ៗគ្នាខិតខំស្ដាប់គ្រូ។




-ទម្រង់ទី៣៖ កន + កកិ ( កិ +កមធ )

ឧ. ពូសំនិយាយជាមួយមីងសន។




-ទម្រង់ទី៤៖ កន + កកិ ( កិ + កន + កមធ )

ឧ. បុប្ផាជូនផ្លែឈើដល់ឪពុកម្ដាយ។




**<u>វិភាគល្បះទោល៖</u>**

ឧទាហរណ៍: សុភីឡើងជាប្រធានថ្នាក់។

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ កន្សោមពាក្យ «*សុភី*» ជាកន្សោមនាមប្រធាន ហើយនិងជានាមអសាធារណ៍ នៅខាងឆ្វេងកិរិយា «*ឡើងជា*» ។ កន្សោមពាក្យ «*ឡើងជាប្រធានថ្នាក់*» ជាកន្សោមកិរិយាដែលមានកិរិយាចំណង «*ឡើងជា*» និងកន្សោមពាក្យ «*ប្រធានថ្នាក់*» ជាកន្សោមនាមដែលមានមុខងារជាគុណប្រធានរបស់កន្សោមនាមប្រធាន «*សុភី*»។







ខ. **ល្បះផ្សំ** គឺជាល្បះដែលកើតឡើងដោយបន្សំរវាងឃ្លាច្បង (ឃ្លាគោល/ល្បះគោល) និងឃ្លារណប (ល្បះរណប)។ ឃ្លារណបអាចភ្ជាប់នឹងឃ្លាច្បងដោយឈ្នាប់ឃ្លាឬសព្វនាមឈ្នាប់។ ឃ្លាអាចមានន័យគ្រប់គ្រាន់ឬមិនទាន់គ្រប់គ្រាន់។ ទម្រង់នៃឃ្លារណបមានដូចជា ឃ្លានាម ឃ្លាគុណនាម និងឃ្លាទេសកាល។

ល្បះទោលមាន «កន្សោមប្រធាន កិរិយា កន្សោមនាម និងកន្សោមមានផ្នាក់» ដែលជាធាតុសំណង់របស់ល្បះទោល។ ល្បះផ្សំមានទម្រង់ដូចគ្នានេះដែរ ប៉ុន្តែវាមានធាតុសំណង់ណាមួយ (នៃល្បះ) ជាល្បះ ឬក្នុងធាតុសំណង់ណាមួយមានពង្រីកជាល្បះ។

ឃ្លាច្បងនិងឃ្លារណប សុទ្ធតែមានប្រធាន កិរិយា ឬកម្មបទដូចគ្នា។ ឃ្លារណបអាចនៅបន្ទាប់ពីឃ្លាច្បងឬនៅខាងដើមឃ្លាក៏បាន។ ឃ្លារណបភ្ជាប់នឹងឃ្លាច្បងដោយសារឈ្នាប់ឃ្លាដូចជា ព្រោះ ដើម្បី ដើម្បីនឹង ថា ទោះបី ប្រសិនបើ រហូតដល់ បន្ទាប់ពី ថ្វីត្បិតតែ ដើម្បីឱ្យ លុះ ដែល កាលណា...។

ឧទាហរណ៍: បងខ្ញុំដឹងថាសំមិនចូលចិត្តលេងល្បែង។



នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ «*បងខ្ញុំដឹង*» ជាឃ្លាច្បងដែលកើតឡើងដោយកន្សោមនាម «*បងខ្ញុំ*» ដែលមានមុខងារជាប្រធានរបស់កិរិយា «*ដឹង*» និងកន្សោមកិរិយា «*ដឹង*» ដែលជាកិរិយាសព្ទបង្គោល។ «*ថាសំមិនចូលចិត្តលេងល្បែង*» ជាឃ្លារណបឬឃ្លានាម ដែលមានមុខងារជាកន្សោមនាមកម្មបទរបស់កិរិយាសព្ទ «*ដឹង*» ។ ក្នុងឃ្លារណបនេះកើតឡើងដោយ «*ថា*» ជាឈ្នាប់ឃ្លា និង «*សំ*» ជាកន្សោមនាមប្រធាន រីឯ «*មិនចូលចិត្តលេងល្បែង*» ជាកន្សោមកិរិយា និង «*ល្បែង*» ជាកន្សោមនាម ដែលមានមុខងារជាកម្មបទផ្ទាល់របស់កិរិយាសព្ទ «*ចូលចិត្តលេង*»។ ដូច្នេះឃ្លាទាំងពីរនេះ ចងភ្ជាប់គ្នាដោយសារឈ្នាប់ឃ្លាថា បង្កើតបានជាល្បះផ្សំមួយដែលមានន័យពេញលេញ។

ឧទាហរណ៍: កុមារៗចូលចិត្តអានសៀវភៅដែលមានរូបគំនូរ។




នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ «*កុមារៗចូលចិត្តអានសៀវភៅ*» ជាឃ្លាច្បងនៅក្នុងល្បះដែលកើតឡើងដោយកន្សោមនាម «*កុមារៗ*» ដែលមានមុខងារជាប្រធានរបស់កិរិយា «*ចូលចិត្តអាន*» និង«*ចូលចិត្តអាន*» ជាកិរិយាបង្គោលនិង «*សៀវភៅ*» ជាកម្មបទផ្ទាល់។ «*ដែលមានរូបគំនូរ*» ជាឃ្លារណបឬឃ្លាគុណនាម ដែលមានមុខងារជាពង្រីកឱ្យនាម «*សៀវភៅ*» ។ ជាតុ «*ដែល*» មានមុខងារជាប្រធានរបស់កិរិយា «*មាន*» និងជាសព្វនាមឈ្នាប់ សម្រាប់ជំនួសឱ្យនាម «*សៀវភៅ*»។ ក្នុងឃ្លារណបនេះកើតឡើងដោយ «*ដែល*» ជាឈ្នាប់ឃ្លា និង «*មានរូបគំនូរ*» ជាកន្សោមកិរិយា។

ឧទាហរណ៍: យើងខិតខំរៀនសូត្រដើម្បីប្រទេសជាតិយើងរីកចម្រើន។

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ «*យើងខិតខំរៀនសូត្រ*» ជាឃ្លាច្បងដែលកើតឡើងដោយ «*យើង*» ជាកន្សោមនាមប្រធាន «*ខិតខំរៀនសូត្រ*» ជាកន្សោមកិរិយា។ ចំណែកឃ្លា «*ដើម្បីប្រទេសជាតិយើងរីកចម្រើន*» ជាឃ្លារណបឬឃ្លាទេសកាល ដែលមានមុខងារជាឃ្លាទេសកាលប្រាប់បំណងរបស់កន្សោមកិរិយា «*ខិតខំ*

*រៀនសូត្រ*» ដែលវាកើតឡើងដោយ «*ដើម្បី*» ជាឈ្នាប់ឃ្លានិង «*ប្រទេសជាតិយើង*» ជាកន្សោមនាមប្រធាន ហើយ «*រីកចម្រើន*» ជាកន្សោមកិរិយា។




**គ. ល្បះក្រង** គឺជាល្បះដែលកើតឡើងដោយសារល្បះទោលពីរឬច្រើន ដាក់បន្តបន្ទាប់គ្នាដោយប្រើឈ្នាប់ចងឬមិនប្រើក៏បាន។ បើគេមិនប្រើឈ្នាប់ចងដើម្បីភ្ជាប់ល្បះទោលទាំងនោះ គេត្រូវដកឃ្លានៅចន្លោះល្បះទោលនីមួយៗនោះ។

-ល្បះក្រងកើតពីល្បះទោលពីរដាក់បន្តបន្ទាប់គ្នាដោយប្រើឈ្នាប់ចងដូចជា និង ហើយ តែ ប៉ុន្តែ ឬ រីឯ ។ល។ ឧទាហរណ៍ សៅទៅផ្សារ រីឯប្អូនវានៅផ្ទះ។

-ល្បះក្រងកើតពីល្បះទោលពីរឬច្រើន ហើយគេដាក់បន្តបន្ទាប់គ្នា ដោយដកឃ្លានៅចន្លោះល្បះទោលនីមួយៗ ឧទាហរណ៍ សុកអានសៀវភៅ សៅស្តាប់ចម្រៀង សានមើលទូរទស្សន៍។






## ៦.៣. ប្រភេទឃ្លា

ឃ្លាមាន៤ប្រភេទគឺ ឃ្លាបញ្ជាក់ ឃ្លាបញ្ជា ឃ្លាសំណួរ ឃ្លាឧទាន។

ក. ឃ្លាបញ្ជាក់ទុកដូចជា «ឃ្លាបាត» នៃឃ្លាឯទៀត ព្រោះឃ្លាដទៃទៀតចេញពីឃ្លាពីឃ្លាបញ្ជាក់។ ឃ្លាបញ្ជាក់ងាយមាន៖

-កន្សោមនាមប្រធានចាំបាច់។

-កន្សោមកិរិយាចាំបាច់ដែលមានកិរិយាសព្ទនិងកន្សោមនាមកម្មបទឬកិរិយា «ជា» និងគុណប្រធាន។

-កន្សោមមានធ្នាក់ (កម្មទេសកាល) បន្ទាប់បន្សំ។

ក្នុងឃ្លាបញ្ជាក់ ប្រធាននៅខាងឆ្វេងកិរិយា ឯកម្មបទនៅខាងស្តាំកិរិយា។ ឧ: សុខសំពះឪពុកម្តាយ។

**ខ. ឃ្លាបញ្ជា**ប្រើដើម្បី៖

-បង្គាប់៖ ទៅ! ចូរអ្នកទៅចុះ!

-ឱ្យដំបូន្មាន៖ ចូរអ្នកប្រយ័ត្នគ្រោះថ្នាក់។

-ធ្វើសំណូមពរ៖ សូមឱ្យមិត្តបានសុខ។

-អង្វរ៖ សូមបងអភ័យទោស។

ក្នុងឃ្លាបញ្ជាមានប្រើពាក្យ៖

-ចូរ នៅដើមឃ្លាបញ្ជា (អ្នកធំទៅអ្នកតូច)

-សូម នៅដើមឃ្លាបញ្ជា (អ្នកតូចទៅអ្នកធំ)

-សុំ នៅដើមឃ្លាបញ្ជា (អ្នកធំនិយាយទៅកាន់អ្នកតូច)។

គ. ឃ្លាសំណួរសម្រាប់សួរទៅអ្នករួមប្រាស្រ័យជាមួយ៖

-សុកទៅផ្សារឬទេ?

-តើឯងនៅបម្រើម្តាយឯងឬទេ?

-ការងារយើងបានជោគជ័យនៅថ្ងៃណា?

**ឃ. ល្បះឧទាន** ជាល្បះប្រើសម្រាប់សម្តែងមនោសញ្ចេតនាឬចំណាប់អារម្មណ៍ភ្លាមៗ។ វាមានសំនៀងពិសេសប្លែកពីល្បះសំណួរ។ ល្បះឧទានបញ្ចប់ដោយសញ្ញាឧទាន (!)។

ឧទាហរណ៍៖

-ពូឯងអីក៏ប្រសប់អ្វីម្លេះ!

-ឱ នារីនេះស្អាតណាស់តើ!

## សំណួរ

១. តើសម្ព័ន្ធវិទ្យាជាអ្វី?

២. ចូររៀបរាប់អំពីប្រវត្តិនៃការសិក្សាសម្ព័ន្ធវិទ្យា។

៣. តើ អារីស្តូតបានបែងចែកល្បះជាប៉ុន្មាន?

៤. ចូររៀបរាប់អំពីទិដ្ឋភាពសំខាន់ៗនៃសម្ព័ន្ធវិទ្យា។

៥. តើកន្សោមពាក្យជាអ្វី? មានប៉ុន្មាន? អ្វីខ្លះ?

៦. តើល្បះជាអ្វី?

៧. ចូរឱ្យនិយមន័យនិងឧទាហរណ៍នៃល្បះបញ្ជាក់។

៨. ចូរឱ្យនិយមន័យនិងឧទាហរណ៍នៃល្បះបញ្ជា។

៩. ចូរឱ្យនិយមន័យនិងឧទាហរណ៍នៃល្បះសំណួរ។

១០. ចូរឱ្យនិយមន័យនិងឧទាហរណ៍នៃល្បះឧទាន។

១១. តើល្បះទោលជាអ្វី? ចូររៀបរាប់ពីទម្រង់នីមួយៗនៃល្បះទោលដោយមានឧទាហរណ៍បញ្ជាក់។

១២. តើល្បះផ្សំជាអ្វី? ចូររកល្បះផ្សំក្នុងឯកសារផ្សេងៗឱ្យបាន១០ល្បះ។

១៣. តើល្បះក្រុងជាអ្វី? ចូររកល្បះក្រុងក្នុងឯកសារផ្សេងៗឱ្យបាន១០ល្បះ។

១៤. តើការសិក្សាអំពីល្បះធ្វើឱ្យយើងយល់ដឹងអ្វីខ្លះ?

១៥. ចូរគូសល្បះជាមែងធាងនិងប្រអប់៖

ក. គាត់ទិញផ្លែឈើមួយគីឡូ។

ខ. អ្នកគ្រូយើងសរសើរសិស្សឧស្សាហ៍។

គ. កុមារម្នាក់នេះកំពុងរត់លេងនៅសួនច្បារ។

ឃ. សុភាទិញខោអាវជូនឪពុកម្តាយនាង។

ង. លោកគ្រូទូន្មានថាយើងត្រូវខំរៀនបន្ថែមទៀត។

ច. យើងមិននឹកស្មានថាគាត់មកចូលរួមពិធីនេះទេ។

ឆ. បុរសដែលខ្ញុំឃើញនោះ មិនមែនជាចោរទេ។

ជ. យើងគោរពសិទ្ធិជនបរទេសដែលរស់នៅក្នុងប្រទេសយើង។

ឈ. មនុស្សដែលតែងបារម្ភពីអ្នក មិនមែនចេះតែមានរហូតនោះទេ។

ញ. បើប្អូនប្រឡងជាប់ បងនឹងឱ្យរង្វាន់។

ដ. យើងខិតខំមើលមេរៀន ដើម្បីការប្រឡងបានជោគជ័យ។

ឋ. គាត់គួរហាត់ប្រាណ ព្រោះគាត់ធាត់ខ្លាំងណាស់។

# មេរៀនទី៦
# ន័យវិទ្យានិងការណ៍វិទ្យា

## ១. ន័យវិទ្យា

តួនាទីរបស់ន័យវិទ្យាដែលនៅក្នុងភាសាវិទ្យាបានពឹងផ្អែកលើវេយ្យាករណ៍ ប៉ុន្តែនៅពេលដែលគេបង្កើតមុខវិជ្ជាភាសាវិទ្យា គេចាប់ផ្តើមទុកវេយ្យាករណ៍មួយដោយឡែក ព្រោះគេចាត់ទុកវេយ្យាករណ៍គ្រាន់តែជាការសរសេរឱ្យបានត្រឹមត្រូវប៉ុណ្ណោះ។ គេពិបាកឱ្យនិយមន័យទៅលើន័យវិទ្យាណាស់ ថាតើអ្វីទៅជាន័យវិទ្យា? ហើយគេសិក្សាវារបៀបណា? តើមានទ្រឹស្តីណាខ្លះដើម្បីធ្វើការសិក្សានៅក្នុងផ្នែកន័យវិទ្យានេះ?

គេមានការពិបាកក្នុងការផ្តល់ស្វ័យភាពទៅលើន័យវិទ្យា បានន័យថា ការសិក្សាទៅលើន័យវិទ្យា តែងមានទំនាក់ទំនងជាមួយសម្ព័ន្ធវិទ្យា។ និយមន័យនៃសម្ព័ន្ធវិទ្យាមានយូរណាស់មកហើយ ហើយនៅពេលនោះន័យវិទ្យាពុំទាន់កើតមាននៅឡើយ។ បើគេចង់សិក្សាអំពីន័យវិទ្យា គឺគេមិនប្រើន័យវិទ្យាទេ គេប្រើតក្កវិទ្យានិងទស្សនវិជ្ជាទៅវិញ។ រហូតមកដល់សតវត្សទី២០ ទើបការសិក្សាអំពីទម្រង់នៃសញ្ញាមានល្បឿនកាន់តែរីកចម្រើនឡើង ជាពិសេសនៅមហាវិទ្យាល័យអ៊ុកហ្វត (Oxford) ប្រទេសអង់គ្លេស ដែលបានសិក្សាមុនគេ គឺទៅលើចង្កោមបញ្ញានៃភាសា។ ទោះបីយើងមានទម្រង់ មានសម្ព័ន្ធ មានវេយ្យាករណ៍យ៉ាងណាក៏ដោយ ក៏យើងនៅតែមានន័យ តែន័យនោះស្ថិតនៅក្រោមរូបភាពតក្កវិទ្យា ទស្សនវិជ្ជា ហើយនិងការសិក្សាន័យវិទ្យាបានចាប់ផ្តើមវិភាគតាមបែបសម្ព័ន្ធវិទ្យាបន្តិចម្តងៗ ហើយរហូតមកដល់ឥឡូវនេះ ន័យវិទ្យាមាននៅស្នាមបន្តិចបន្តួចក្នុងសម្ព័ន្ធវិទ្យា។ ពិសេសទៀត គេបានចាប់ផ្តើមសិក្សាន័យដោយឡែក ហើយមិនចង់ឱ្យមានការពាក់ព័ន្ធជាមួយនឹងសម្ព័ន្ធវិទ្យាទេ នៅពេលនោះហើយ គេបានសិក្សាន័យវិទ្យាទៅតាមការពិតជាក់ស្តែង ហើយគេបានបែងចែកសម្ព័ន្ធវិទ្យា និងន័យវិទ្យាដាច់ដោយឡែកពីគ្នា។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលគេសិក្សាអំពីន័យវិទ្យា វាតែងតែមានទំនាក់ទំនងជាមួយសម្ព័ន្ធវិទ្យា តែគេក៏អាចចែកដាច់ទិដ្ឋភាពក្នុងន័យវិទ្យានិងសម្ព័ន្ធវិទ្យាបាន។

ដោយសារការសិក្សាតាមបែបសំឡេង-សូរ សំណេរ-ចំណារ មិនទាន់មានលក្ខណៈបែបផែនណាមួយរៀបចំជាក់លាក់ នៅពេលនោះគេចាត់ទុកទម្រង់ជាសញ្ញានៃប្រព័ន្ធដែលមានទំនាក់ទំនងគ្នា។ តាមការសិក្សាគេថា ឥតមានន័យវិទ្យាទេ មានតែសម្ព័ន្ធវិទ្យា ប៉ុន្តែតាមការវិភាគតាមបែបសម្ព័ន្ធវិទ្យា អ្នកសិក្សាជាច្រើនបានបែងចែកឱ្យដាច់រវាងសារធាតុដែលទាក់ទងនឹងទម្រង់ (Form) និងន័យ (Meaning)។ គេថា ទម្រង់និងន័យ មិនដូចគ្នាទេ គឺជាបញ្ញត្តិពីរផ្សេងគ្នា នៅពេលនោះហើយគេសួរថា ប្រសិនបើវាមានសារធាតុដែលជាទម្រង់ដោយឡែកខុសពីសារធាតុន័យនៃខ្លឹមសារនោះ គឺមានន័យថា សម្ព័ន្ធវិទ្យានិងន័យវិទ្យា ពុំមានទំនាក់ទំនងនឹងគ្នាទេគឺវាចែកដាច់រវាងគ្នានិងគ្នា។ ទោះជាយ៉ាងណាក៏ដោយក៏គេមិនអាចនិយាយ តើការសិក្សាបែបទម្រង់សម្ព័ន្ធវិទ្យា ឬន័យវិទ្យានេះទាក់ទងនឹងទម្រង់បែបណា? តើយើងអាចនិយាយថា ជាធាតុនៃន័យវិទ្យា ឬសម្ព័ន្ធវិទ្យាបាន ឬទេ? តែបើយើងនិយាយពីធាតុហាក់បីដូចជាយើងចង់និយាយថា ន័យវិទ្យាមានទម្រង់ផ្សេង សម្ព័ន្ធវិទ្យាមានទម្រង់មួយដោយឡែក។ ក្នុងការសិក្សាយើងអាចនិយាយថា មានការបែងចែករវាងសម្ព័ន្ធវិទ្យានិងន័យវិទ្យា ហើយកម្រិតណាដែលយើងនិយាយថា មុខវិជ្ជាទាំងពីរមិនអាចបែងចែកចេញពីគ្នាបានទេគឺអាស្រ័យទៅតាមក្របខណ្ឌនៃទ្រឹស្តីដែលយកមកវិភាគ និងកម្រិតនៃការវិភាគ (ដាច់ដោយឡែកពីគ្នា ឬយកទាំងពីរ)។

តាមលោក ចន អ៊ីយ៉ូ (John Iyou) បាននិយាយថា គ្មានទម្រង់ណាមួយលេចធ្លោជាងទម្រង់ណាមួយទេ គឺមិនមែនមានន័យថា ន័យវិទ្យាសំខាន់ជាងសម្ព័ន្ធវិទ្យា។ នៅក្នុងការសិក្សាជួនកាលយើងត្រូវធ្វើការបកស្រាយតាមសម្ព័ន្ធវិទ្យា ជួនកាលតាមន័យវិទ្យា ប៉ុន្តែគ្មានមុខវិជ្ជាណាសំខាន់ជាងមុខវិជ្ជាណាទេ គឺវាមានតួនាទីផ្សេងពីគ្នា។

ដោយសារការសិក្សាន័យវិទ្យាមានលក្ខណៈអរូបី មិនដូចការវិភាគតាមបែបសម្ព័ន្ធវិទ្យាទេ។ សម្ព័ន្ធវិទ្យាមានពាក្យសម្រាប់ហៅ ឬគំរូពិសេសដែលយើងត្រូវសិក្សា ប៉ុន្តែតាមន័យវិទ្យាស្ថិតនៅក្រោមការសិក្សាវិភាគ ហើយការវិភាគនោះមិនមានទម្រង់ណាមួយបញ្ជាក់ច្បាស់លាស់ទេ។

ការសិក្សាអំពីទម្រង់ទៅលើន័យវិទ្យានេះ គឺកើតមាននៅទសវត្សទី៥០ ចុងក្រោយនេះ ដោយចាប់ផ្ដើមធ្វើការរិះគន់លើភាសាសរសេរ ការបង្កើតពាក្យ និងការវិភាគសព្ទបែបយ៉ាង។ នៅក្នុងទិដ្ឋភាពនេះហើយ ដែលការសិក្សាទម្រង់តែងតែគោរពតាមក្បួនខ្នាតវេយ្យាករណ៍ ក្បួននេះវាកើតចេញពីការរិះគន់របស់មនុស្ស តែតាមការវិវត្ត ត្រូវមានការកែប្រែទៅតាមការប្រើប្រាស់ និងតាមពេលវេលា ឥតមានវេយ្យាករណ៍ណាមួយនៅនឹងមួយកន្លែងនោះទេ គឺតែងតែមានការប្រែប្រួលជានិច្ច។

**១.១. និយមន័យ**

ន័យ (ន) (សំ.បា.នយ) មានន័យថា ការណែនាំ ការអធិប្បាយ សេចក្ដីពន្យល់ ហេតុ ទំនង លំនាំ...គួរអ្នកយល់តាមន័យនេះចុះ ព្រោះត្រឹមត្រូវគួរយល់បានហើយ (វចនានុក្រមខ្មែរ, ១៩៦៧-១៩៦៨: ៤៩៦)។

ន័យ មានន័យថា ន័យរបស់ពាក្យណាមួយគឺអ្វី (បញ្ញត្តិ) ដែលពាក្យនោះសម្គាល់។ ន័យប្លែកពីន័យកម្មត្រង់ថាន័យឥតមានអរូបីភាពខ្លាំងដូចន័យកម្មទេ ពីព្រោះឋិតនៅស្រទាប់វាចាឬស្រទាប់នៃទម្លាប់ក្នុងការប្រើប្រាស់ភាសា។ ន័យមិនអាចមានវង្វង់ធំធេងដូចន័យកម្មទេ ពីព្រោះវាលំអោនទៅតាមកាលៈទេសៈ ទៅតាមក្រុម ទៅតាមសហគមន៍។ តាមធម្មតា វចនានុក្រមឱ្យត្រឹមតែន័យស្នូលរបស់ពាក្យ ដែលហៅថា អត្ថានុរូប រីឯន័យប្រយោល ន័យបន្ទាប់បន្សំ គេតែងបន្ថែមតាមសំណៅថា អត្ថបដិរូប។ តាមភាសាវិទូមួយក្រុម ន័យជាវេវចនសព្ទជាមួយនឹងបញ្ញត្តិ (ព្រំ ម៉ល់, ២០០៣: ៥)។

ន័យ គឺជាអ្វីដែលពាក្យស្ដែងឡើងជាសេចក្ដីរបស់ពាក្យនោះ។ ន័យរបស់ពាក្យមួយកើតឡើងពីការផ្សំនៃបម្រើបម្រាស់ន័យ។ ន័យ មិនអាចកើតឡើងដោយឯកឯងទេ មានន័យថា គឺត្រូវតែមានទម្រង់។ ន័យ អាស្រ័យទៅលើពាក្យនិងបរិបទរបស់វា។ ន័យរបស់ឯកតាភាសាមួយកើតឡើងតាមរយៈអន្តរកម្មរវាងឯកតាភាសានោះជាមួយសហបទរបស់វានៅក្នុងបរិបទមួយកំណត់ច្បាស់លាស់ (ច័ន្ទ សំណព្វ, ២០១៦)។

ន័យវិទ្យា (Semantics) គឺជាវិជ្ជាដែលសិក្សាអំពីន័យរបស់ពាក្យនិងប្រវត្តិរបស់ពាក្យផងដែរ។ ន័យវិទ្យាត្រូវនឹងពាក្យភាសាក្រិកថា Semantikos ដែលកម្លាយមកពីពាក្យ Sema (សញ្ញា) មានន័យថា ការឱ្យសញ្ញា ការឱ្យន័យជាក់លាក់ ឱ្យលក្ខណៈសញ្ញា។ ប៉ុន្តែនិយមន័យបែបនេះមិនគ្រប់គ្រាន់ឡើយ ព្រោះក្នុងសម័យបច្ចុប្បន្ន ន័យវិទ្យានេះមានលក្ខណៈទូលំទូលាយនិងអរូបី។

ន័យវិទ្យា គឺជាការសិក្សាអំពីន័យរបស់ពាក្យ ឃ្លា និងល្បះ។ នៅក្នុងការវិភាគន័យ វាតែងតែផ្ដោតសំខាន់ទៅលើការសន្ទតពាក្យជាជាងការនិយាយផ្ទាល់ (ដូច) ដែលចង់ឱ្យដឹងពីន័យរបស់វានៅក្នុងបរិបទជាក់លាក់។ វាអាចទាក់ទងជាមួយនឹងវត្ថុបំណងឬន័យទូទៅដើម្បីជៀសវាងការមើលលើតែប្រធាន ឬន័យតាមតំបន់។ ការធ្វើវិភាគន័យគឺផ្ដោតទៅលើការប្រកបពាក្យដែលយើងដឹងច្បាស់ថាពេលណាយើងត្រូវបកស្រាយន័យថាអ្វី បើសិនជាយើងចែកចំណេះដឹងទៅវិញទៅមករវាងន័យរបស់ពាក្យ ឃ្លា ឬល្បះនៅក្នុងភាសា។

នៅពេលដែលយើងគិតទៅដល់ន័យវិទ្យា គឺជាការសិក្សាពីន័យនៅក្នុងភាសាហើយមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើទិដ្ឋភាពពិតប្រាកដរបស់ន័យ។ យើងមានក្បួនន័យពិសេសដែលអាចទាក់ទាញពាក្យបាន។ យើងអាចទៅឆ្ងាយដើម្បីបង្កើតវិសាលភាពជាក់ច្បាស់រវាងន័យនៃគំនិត និងន័យដែលជាប់ទាក់ទងគ្នា។ ន័យនៃគំនិតផ្ដោតទៅលើគ្រឹះដំបូងទាំងនោះ ដែលសំខាន់គឺសមាសភាគរបស់ន័យដែលដឹកនាំដោយការប្រើសប្រាស់តាមន័យរបស់ពាក្យ។ វាជាប្រភេទនៃន័យដែលវចនានុក្រមបានធ្វើឡើងដើម្បីពិពណ៌នា ដូចពាក្យ *needle* (ម្ជុល) នៅក្នុង

ភាសាអង់គ្លេសវាអាចរួមបញ្ចូលជាមួយពាក្យ « *thin, sharp, steel, instrument* »។ សមាសភាគទាំងនេះអាចជាផ្នែកមួយនៃន័យរបស់គំនិត។

## ១.២. លក្ខណៈវិនិច្ឆ័យន័យវិទ្យា

### ១.២.១. លក្ខណៈន័យនៃល្បះ

នៅលើផ្នែកមួយដែលយើងសិក្សាពីន័យវិទ្យា គឺយើងសិក្សាអំពីគន្លឹះន័យនៃគំនិត ដែលអាចជាជំនួយក្នុងការយល់ន័យដែលមិនត្រឹមត្រូវឬសរសេរដោយបទពិសោធរបស់យើងនៅពេលដែលយើងអានល្បះដូចខាងក្រោម៖

(១) នំអន្សមស៊ីក្មេងប្រុស។

(២) តុស្ដាប់វិទ្យុ។

(៣) សេះកំពុងអានសៀវភៅ។

យើងគួរតែកត់សម្គាល់ដំបូងទៅលើភាពមិនត្រឹមត្រូវនៃល្បះទាំងនេះ ដែលមិនត្រឹមត្រូវទៅតាមទម្រង់ន័យនិងក្បួនរបស់ន័យ។ ក្នុងល្បះ (១) (២) និង(៣) គឺវាត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ដែលមានកន្សោមនាមប្រធាន «នំអន្សម, តុ, សេះ» កិរិយា «ស៊ី, ស្ដាប់, កំពុងអាន» និងកម្មបទផ្ទាល់ «ក្មេងប្រុស, វិទ្យុ, សៀវភៅ»។ ល្បះ (១) (២) និង (៣) នេះគឺជាសម្ព័ន្ធដ៏ល្អ ប៉ុន្តែន័យរបស់វាគឺមិនត្រឹមត្រូវ ព្រោះល្បះដែលត្រឹមត្រូវនោះគឺ (១) «*ក្មេងប្រុសស៊ីនំអន្សម*» ដែលយើងអាចសម្គាល់បានថាវាជាប្រភពនៃបញ្ហា។ យើងអាចធ្វើការសង្កេតនេះជាទូទៅ ហើយនិងអនុវត្តបាន ដោយការព្យាយាមកំណត់ធាតុសំខាន់ឬលក្ខណៈពិសេសនៃន័យដែលនាមណាមួយត្រូវតែមានដើម្បីប្រើជាកម្មវត្ថុនៃកិរិយាសព្ទ។ ធាតុផ្សំបែបនេះអាចមានលក្ខណៈទូទៅដូចជា «ជីវិតភាព» បន្ទាប់មកយើងអាចប្រើគំនិតនេះដើម្បីពិពណ៌នាផ្នែកនៃអត្ថន័យនៃពាក្យដែលមានធាតុន័យ [+] ឬ [-] ដែលមានលក្ខណៈពិសេសនោះ។ ដូច្នេះលក្ខណៈពិសេសដែលក្មេងប្រុសរូបនោះមានគឺ «+ជីវិតភាព» (សំដៅលើមនុស្សឬសត្វដែលមានជីវិត) និងលក្ខណៈពិសេសដែលនាម «នំអន្សម» មាន «– ជីវិតភាព» (សំដៅលើវត្ថុដែលគ្មានជីវិត)។ ឧទាហរណ៍សាមញ្ញនេះជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់វិភាគន័យតានៃពាក្យ។ លក្ខណៈពិសេសដូចជា (+ជីវចល, -មនុស្ស)។

ន័យតា ជាឯកតាអប្បបរមានៅក្នុងន័យបញ្ញត្តិណាមួយ។ សញ្ញាតា «កូនក្មេង» , «មនុស្សជំទង់» , «មនុស្សពេញវ័យ», «មនុស្សប្រុស», «មនុស្សស្រី», «មនុស្សចាស់»...ដែលបូកចូលគ្នាបានវចនសព្ទ «មនុស្ស» គឺជាន័យតា។ ការវិភាគន័យតា គឺជាការស្រាវជ្រាវរកន័យតា។ ឧទាហរណ៍ ពាក្យ «កៅអី កៅអីទ្រេត ជើងតាំង កៅអីវែង កៅអីខ្នើយ» មានន័យតាដូចខាងក្រោមនេះ៖

| ន័យតា / វចនសព្ទ | ន័យតា១: សម្រាប់អង្គុយ | ន័យតា២: មានជើង | ន័យតា៣: សម្រាប់មនុស្សម្នាក់ | ន័យតា៤: មានបង្អែក | ន័យតា៥: មានភ្នាក់ដៃ | ន័យតា៦: ធ្វើពីជាតុរឹង |
|---|---|---|---|---|---|---|
| កៅអី | + | + | + | + | - | + |
| កៅអីទ្រេត | + | + | + | + | + | + |
| ជើងតាំង | + | + | + | - | - | + |
| កៅអីវែង | + | + | - | + | + | + |
| កៅអីខ្នើយ | + | - | + | - | - | - |

### ១.២.២. ផ្នែកសំខាន់ៗនៃការសិក្សាន័យនៅក្នុងភាសា

**ក. ន័យវចនៈ** គឺជាការសិក្សាពីប្រព័ន្ធន័យដែលទាក់ទងនឹងទុនន័យរបស់ពាក្យ (Properties of Words)។ ន័យវចនៈ គឺសិក្សាអំពីន័យរបស់ពាក្យ ដែលផ្ដោតសំខាន់លើខ្លឹមសារទាំងឡាយរបស់ពាក្យជាងការសិក្សាអំពីទម្រង់

ឬវេយ្យាករណ៍។ វចនានុក្រមដើរតួនាទីយ៉ាងសំខាន់ក្នុងការពន្យល់ន័យវចនៈ ទោះបីការពន្យល់ន័យនោះមិនបានគ្រប់ជ្រុងជ្រោយ ឬលម្អិតក៏ដោយ។

**ខ. ន័យវេយ្យាករណ៍** សិក្សាអំពីទិដ្ឋភាពនៃន័យដែលទាក់ទងផ្ទាល់ជាមួយសម្ព័ន្ធ។ ឧទាហរណ៍ ពាក្យ «ភ្លៀង» មានន័យខុសគ្នាដូចតទៅ៖

(៤) ភ្លៀង មិនទាន់រាំងទេ។ (*ភ្លៀង* ជានាម)

(៥) មេឃ ភ្លៀងខ្លាំងណាស់។ (*ភ្លៀង* ជាកិរិយាសព្ទ)

ន័យវេយ្យាករណ៍ផ្សេងទៀតបង្ហាញពីន័យវេយ្យាករណ៍នៃរូបសព្ទ ដូចជា កាន់ > ខ្មាន់, ចាំ > ឆ្មាំ ,ដើរ > ឋ្មើរ ។ល។ ដែលជើង «្ម» សម្គាល់មនុស្ស (ជាន័យវេយ្យាករណ៍)។ នៅក្នុងភាសាអង់គ្លេសមានដូចជា -ed of walk**ed**, -er of long**er**, re- and -al of **retrial** ជាដើម។

**គ. ន័យតក្កៈ** សិក្សាអំពីទំនាក់ទំនងរវាងភាសាធម្មជាតិ (Natural Language) និងប្រព័ន្ធទម្រង់តក្កៈ ដូចជាការបង្ហាញពីឃ្លាសំណើនិងអំណះអំណាង។

ការបង្ហាញពីបម្រាប់ប្រធានបែបតក្កៈ គឺជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធប្រពៃណីសំខាន់ពីរនៃតក្កវិទ្យា ដែលបានប្រើនៅក្នុងទម្រង់ន័យវិទ្យា នោះគឺឃ្លាសំណើ។ ក្នុងប្រព័ន្ធនេះឃ្លាទាំងឡាយត្រូវវិភាគតាមចំណែកពីរគឺ សេចក្តីសំអាងនិងបម្រាប់ប្រធាន។ ទម្រង់ដ៏សាមញ្ញនៃបញ្ញត្តិតក្កៈ គឺមុខងារតក្កៈ ដែលកើតឡើងថេរហើយមុខងារទាំងនោះជាបម្រាប់ប្រធាន។

ឧទាហរណ៍៖ ពាក្យ «**ឆ្កែ (X)**»

X គឺជាអថេរ (ជាតុដែលអាចផ្លាស់ប្តូរបាន) ពីព្រោះវាអាចបង្ហាញពីតម្លៃខុសៗគ្នា។ អញ្ញត្តិ X ត្រូវគ្នានឹងអង្គតា (Entities) ដែលខុសៗគ្នានៃវត្ថុដែលមាននៅក្នុងលោក។ ការកំណត់តម្លៃមួយចំពោះអញ្ញត្តិអថេរនៅក្នុងបញ្ញត្តិនេះស្របតាមឃ្លា។ ឧទាហរណ៍ ឆ្កែ (អាលុក) ដែលនៅក្នុងភាសាខ្មែរមានន័យថា អាលុក គឺជាឆ្កែមួយក្បាល។ ជាតុ (ឆ្កែ) តំណាងឱ្យអញ្ញត្តិថេរចំពោះអត្ថន័យនៃពាក្យឆ្កែ។ បម្រាប់ប្រធានបែបតក្កៈ ប្រើជាចំនួននៃអ្នកប្រតិបត្តិការផងដែរ ដែលបង្ហាញពីអ្នកប្រតិបត្តិជាក់លាក់ (Logical Operations) និងភាពទាក់ទងគ្នា ហើយបង្ហាញពីបញ្ញត្តិសាំញ៉ាំដើម្បីបង្កើតទម្រង់ងាយស្រួលនីមួយៗ។ អ្នកប្រតិបត្តិដែលសំខាន់បំផុតតាងដោយសញ្ញា «∃» (គឺមានន័យថា ខ្លះៗ) ហើយអ្នកប្រតិបត្តិទូទៅ (Universal Operator) តាងដោយសញ្ញា « ∀» (គឺមានន័យថា គ្រប់), ជាមួយ (Together with) តាងដោយសញ្ញា «&» (មានន័យថា និង), => (មានន័យថា ប្រសិនបើ... នោះគឺ if...then) និង « ~ » (មានន័យថា មិន/ទេ) ។ ដូច្នេះ យើងអាចសរសេរនូវរូបមន្តដូចខាងក្រោមនេះ៖

(∀ X) (DOG ឆ្កែ X) ANIMAL សត្វ X)

<u>**បំណកស្រាយ**</u>៖ គ្រប់ X ទាំងអស់, ប្រសិនបើ X គឺជាឆ្កែ នាំឱ្យ X គឺជាសត្វ ហើយនៅក្នុងភាសាដែលមិនប្រែប្រួល គឺឆ្កែទាំងអស់ជាសត្វ។ ក្នុងរូបមន្តនេះ X គឺជាអញ្ញត្តិប្រែប្រួលដែលបញ្ជាក់តម្លៃរបស់វានៃអង្គតាមួយចំនួន។ ឆ្កែនិងសត្វ គឺតំណាងឱ្យន័យថេរនៃពាក្យ *ឆ្កែ* និង *សត្វ* ដែលជាប់ទាក់ទងគ្នា។

គេអាចប្រើរូបមន្តផ្សេងទៀតដែលបញ្ជាក់ពីលក្ខណៈផ្ទុយគ្នា ដូចជា៖

(∀ X) (DOG ឆ្កែ X) FLOWER ផ្កា X)

<u>**បំណកស្រាយ**</u>៖ គ្រប់ X ទាំងអស់, ប្រសិនបើ X គឺជាឆ្កែ នោះនាំឱ្យ X មិនមែនជាផ្កាទេ ឬគ្មានឆ្កែណាគឺជាផ្កាទេ។ រូបមន្តនេះ យើងអាចទាញបានជា៖ (∃X) (MAN X) & (∃Y) (DOG Y) & (SEE X,Y) មានន័យថា វាមានជាតុ X យ៉ាងហោចណាស់មួយដែលថា X គឺជាបុរស (MAN) ហើយវាមានជាតុ Y យ៉ាងហោចណាស់មួយដែលថា Y គឺជាឆ្កែ (DOG) ហើយ *X បានឃើញ Y*។ នៅក្នុងភាសាធម្មតា គឺ *បុរសបានឃើញឆ្កែមួយ* (ALAN CRUSE, 2000: 29)។

## ១.៣. ទិដ្ឋភាពនៃការសិក្សាន័យវិទ្យា

ប្រហែលជាន័យរបស់ល្បះភាគច្រើន គឺជាការផ្សំន័យរបស់ពាក្យផ្សេងៗ។ ការផ្សំន័យកើតឡើងពីការបន្ថែម ឬទំនាក់ទំនងនៃន័យរបស់រូបសព្ទនិងពាក្យជាមួយនឹងកន្សោមពាក្យផ្សេងៗទៀត ឬការបន្ថែមន័យរបស់កន្សោមពាក្យនិងកន្សោមពាក្យ។

ពាក្យនិងរូបសព្ទ គឺជាឯកតាតូចបំផុតនៅក្នុងភាសា។ គោលការណ៍នៃបន្សំន័យ មានន័យថា ន័យរបស់ឃ្លា ឬល្បះ គឺផ្អែកលើន័យរបស់ពាក្យនោះផ្ទាល់និងរបៀបដែលពាក្យទាំងនោះបានតភ្ជាប់គ្នាជារចនាសម្ព័ន្ធ។ ពាក្យជាច្រើនប្រើសម្រាប់ដាក់ឈ្មោះ ចំណែកឯល្បះក៏មិនខុសគ្នាដែរ គឺអាស្រ័យលើសមត្ថភាពទំនាក់ទំនង។ ការសិក្សាអំពីរបៀបដែលន័យរបស់ពាក្យតភ្ជាប់ទៅនឹងឃ្លាឬល្បះ ហើយនិងន័យទំនាក់ទំនងក្នុងចំណោមឯកតាជាច្រើន ត្រូវបានគេហៅថាឃ្លាឬល្បះ។ ន័យនៃល្បះត្រូវស្ថាបនាឡើងពីន័យនៃកន្សោមនាមនិងកន្សោមកិរិយាសព្ទ (តាមគោលការណ៍នៃបន្សំន័យឡើងវិញ)។ ការសិក្សាអំពីន័យនៃភាសាទាក់ទងនឹងទិដ្ឋភាពមួយចំនួនដូចជា ន័យបែបន័យកម្ម ន័យបែបរចនាសម្ព័ន្ធ ន័យបែបការរំជួលចិត្ត ជាដើម។

### ១.៣.១. ន័យបែបន័យកម្ម

ន័យបែបន័យកម្ម គឺជាចម្លុះបញ្ចាំងពិសេសនៃតថភាពនៅក្នុងភាសា ជាខ្លឹមសារភាសាមូលដ្ឋាននៃឯកតា។ ន័យបែបនេះ កំណត់ឡើងតាមរយៈការពិនិត្យនៅក្នុងបញ្ញត្តិ (លក្ខណៈដែលអាចញែកវត្ថុមួយចេញពីវត្ថុមួយផ្សេងទៀត)។ នៅក្នុងវចនានុក្រម គេសង្កេតឃើញការឱ្យខ្លឹមសារនៃពាក្យ តាមរយៈលេខ ១, ២, ៣...។ ជាក់ស្តែងការពន្យល់ន័យរបស់ពាក្យនៅក្នុងវចនានុក្រមគឺមានទិដ្ឋភាពបែបនេះ។

ឧទាហរណ៍ៈ មុខ (១) ប៉ែករូបកាយត្រង់ទីប្រជុំថ្ងាស ចិញ្ចើម ភ្នែក ច្រមុះ មាត់, (២) លំអាន បែបយ៉ាង, (៣) ឡែក ប្រភេទ, (៤) តួនាទី ឋានៈ កិត្តិយស...។

តាមធម្មតា គេតែងសួរថាពាក្យនេះមានន័យដូចម្តេច? សំណួរបែបនេះ គឺចង់សួររកន័យបែបន័យកម្ម។ ន័យវចនៈរបស់ពាក្យ គឺជាចម្លុះបញ្ចាំងនៃវត្ថុ ឬបាតុភូតដែលធ្លាប់ស្គាល់ ធ្លាប់ដឹងរួចមកហើយ ឬចម្លុះបញ្ចាំងនៅក្នុងញាណដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធពាក្យ ក្នុងនាមជាលក្ខណៈខាងក្នុង ចំណែកសំណួរនៃពាក្យជាទំនាក់ទំនងលក្ខណៈខាងក្រៅ។ ពាក្យមួយមានសញ្ញាខាងក្នុងនិងសញ្ញាខាងក្រៅ។

### ១.៣.២. ន័យបែបរចនាសម្ព័ន្ធ

ន័យបែបរចនាសម្ព័ន្ធ គឺជាលក្ខណៈសម្គាល់នៃឯកតាពាក្យសព្ទ ដែលកំណត់ដោយទីកន្លែងរបស់វានៅក្នុងប្រព័ន្ធភាសា ក្នុងទំនាក់ទំនងបន្សំ និងទំនាក់ទំនងបន្លាស់។

ន័យរបស់ពាក្យនៅក្នុងប្រព័ន្ធទំនាក់ទំនងបន្សំ គឺជាន័យដែលមានទំនាក់ទំនងជាបន្ទាត់ផ្តេកជាមួយពាក្យផ្សេង។ គេហៅបានម្យ៉ាងទៀតថា ពិពិធកម្មន័យ ឬការផ្គុំន័យវចនៈរបស់ពាក្យ។ ការផ្គុំពាក្យដើម្បីឱ្យមានន័យ គឺមិនអាចធ្វើបានរវាងពាក្យមួយ និងគ្រប់ពាក្យផ្សេងទៀតទេ គឺថាពាក្យផ្សេងៗអាចផ្គុំចូលគ្នាបានលុះត្រាតែន័យរបស់វាឆ្លើយតបគ្នា ស៊ីចង្វាក់គ្នា ឧទាហរណ៍ «*គាត់ស្តាប់ចម្រៀង ឬគាត់ច្រៀងចម្រៀងពីរោះ* ប៉ុន្តែយើងមិនអាចថា «*គាត់ញ៉ាំពីរោះ ឬគាត់អង្គុយពីរោះ*» បាននោះទេ។ ម្យ៉ាងទៀត ន័យរបស់ពាក្យ មិនអាចឆ្លុះបញ្ចាំងទៅតាមរូបរាងរបស់ពាក្យបានទេ បើសិនជាពាក្យនោះគ្មានទីសេចក្តី (មិននៅក្នុងបរិបទណាមួយ)។ ការផ្សំពាក្យមិនអាចចេះតែប្រើបានតាមសេចក្តីត្រូវការបានឡើយ គឺថាត្រូវតែគោរពទៅតាមការប្រើបាន ស្តាប់បាន អាចយល់ន័យបាន ឧទាហរណ៍ *ត្រីមុខ* និង *មុខត្រី* ឬ *ទឹកមុខ* និង *មុខទឹក* ជាដើម។

ចំណែកឯន័យរបស់ពាក្យនៅក្នុងប្រព័ន្ធទំនាក់ទំនងបន្លាស់វិញ គឺជាន័យដែលមានទំនាក់ទំនងរវាងគ្នានិងគ្នា ប្រឈមន័យគ្នា ហើយស្តែងឡើងនៅក្នុងអត្ថបទដែលអាចមានន័យដូចគ្នា ត្រួតស៊ីគ្នា ប្រហាក់ប្រហែលគ្នា។ យើងអាចបង្កើតឧទាហរណ៍ដូចខាងក្រោមនេះៈ

(៦) ពូសារឿនមិនដែលហ៊ានហូបអាហារឆ្ងាញ់ សម្លៀកបំពាក់ល្អៗទេ មិនដឹងថា គាត់ទុកប្រាក់ធ្វើអ្វីទេ។ សំណាងនិយាយកាត់ « មុខគំរិះ ដូចគាត់ពេលស្លាប់ទៅគ្មាននរណាធ្វើបុណ្យឱ្យទេ »។

(៧) ពូសារឿនមិនដែលហ៊ានហូបអាហារឆ្ងាញ់ សម្លៀកបំពាក់ល្អៗទេ មិនដឹងថា គាត់ទុកប្រាក់ធ្វើអ្វីទេ។ សំណាងនិយាយកាត់ «មុខកំណាញ់ ដូចគាត់ពេលស្លាប់ទៅគ្មាននរណាធ្វើបុណ្យឱ្យទេ»។

(៨) ពូសារឿនមិនដែលហ៊ានហូបអាហារឆ្ងាញ់ សម្លៀកបំពាក់ល្អៗទេ មិនដឹងថា គាត់ទុកប្រាក់ធ្វើអ្វីទេ។ សំណាងនិយាយកាត់ «មុខម៉ៅស្វិត ដូចគាត់ពេលស្លាប់ទៅគ្មាននរណាធ្វើបុណ្យឱ្យទេ»។

ក្នុងល្បះ (៦) (៧) និង(៨) ន័យរបស់ពាក្យ *មុខគំរិះ មុខកំណាញ់* និង*មុខម៉ៅស្វិត* គឺមានន័យដូចគ្នាតាមទំនាក់ទំនងបន្ទាស់។

### ១.៣.៣. ន័យបែបការរំជួលចិត្ត

ន័យបែបការរំជួលចិត្ត ជាន័យពិសេសម្យ៉ាងដែលស្តែងចេញពីការឱ្យតម្លៃរបស់ប្រធានវិស័យទៅលើវត្ថុវិស័យ ដោយប្រើឯកតាភាសាដែលមានន័យបន្ថែមតាមបែបឱ្យតម្លៃសញ្ចេតនា។ នៅក្នុងទិដ្ឋភាពនេះ ការប្រើប្រាស់ពាក្យប្រែប្រួលទៅតាមបរិបទជាពាក្យប្រកបដោយឋានានុក្រម។

ឧទាហរណ៍១:

(៩) បុស្បាអៀនឡើង មុខក្រហម ផៃយ៉ុតញញឹមដាក់នាងរួចបើកឡានចេញទៅ។

(១០) ទ្រង់ខ្វាល់ខ្លាំងណាស់ ឡើងព្រះភ័ក្ត្រក្រហម។

ឧទាហរណ៍២:

(១១) ឯងកុំខំប្រឹងព្រុសខ្លាំងពេក។

(១២) គាត់ពិសាបាយ។

### ១.៣.៤. ន័យបែបន័យកម្មវិស័យនិងន័យអញ្ញថា

ន័យបែបន័យកម្មវិស័យ (Denotation meaning) គឺជាន័យជាក់លាក់ ឬក៏ជាន័យជាក់ស្តែងរបស់ឯកតាភាសាដែលនៅក្នុងស្ថានភាពណាមួយ ព្រោះថានៅក្នុងភាសាពាក្យមួយអាចសម្គាល់វត្ថុឬបាតុភូតផ្សេងៗគ្នានៅក្នុងស្ថានភាពផ្សេងៗគ្នា ខុសៗគ្នា។ ន័យរបស់វា បានភ្ជាប់ទៅនឹងន័យបែបរចនាសម្ព័ន្ធក្នុងការបង្ហាញន័យឱ្យកាន់តែស្តែងច្បាស់ឡើង ប្រាកដឡើង អាចយល់ន័យកាន់តែច្បាស់។

ឧទាហរណ៍១: -មុខក្រាស់ សម្គាល់វត្ថុ

(១៣) កាំបិតនេះមុខក្រាស់ណាស់ ពិបាកសំលៀងមែន។

-មុខក្រាស់ សម្គាល់មនុស្ស

(១៤) មនុស្សអីក៏មុខក្រាស់ម្លេះទេ!

ឧទាហរណ៍២: -សត្វតិរិច្ឆាន ៖ សត្វ-មនុស្ស

-របោយ ៖ បន្លែ-ពាក្យបន្ថែម

-ដើរ ៖ មនុស្សដើរ- ការងារដើរ -នាឡិកាដើរ...។

ន័យកម្មវិស័យមានភាពផ្ទុយគ្នានឹងន័យអញ្ញថា។ ន័យកម្មវិស័យ គឺជាន័យកម្មឋិតថេរនៃសូរសព្ទភាសាណាមួយ ដែលគេចាប់យកក្រៅការប្រើប្រាស់ក្នុងករណីពិសេសណាមួយនៃសូរសព្ទភាសានោះ គឺជាន័យកម្មដែលមិនទាន់មានអញ្ញថាភាពមកឡុកឡំ។ រីឯន័យអញ្ញថា (connotation) ជាន័យពិសេសដែលមានជាប់ពាក់ព័ន្ធជាមួយជីវិត កាលៈទេសៈរបស់បុគ្គលណាម្នាក់ ឬរបស់សហគមន៍នៅដំណាក់កាលណាមួយ។ ឧទាហរណ៍៖ ពាក្យ «យប់» មានន័យកម្មវិស័យថា «ចន្លោះពេលនៅក្រោយថ្ងៃលិចនិងនៅមុនថ្ងៃរះ» ហើយអាចមានន័យអញ្ញថាថា «ទុក្ខសោក ឬអវសានជីវិត» (ព្រំ ម៉ល់, ២០០៣: ៦)។

**១.៤. ទំនាក់ទំនងន័យវចនៈ**

គេមិនត្រឹមតែអាចនិយាយពាក្យថា *container* ដែលវាមានន័យឬជាការបំពេញ «តួនាទី» ក្នុងព្រឹត្តិការណ៍ ពួកវាក៏អាចមាន «ទំនាក់ទំនង» ជាមួយគ្នា។ ក្នុងការនិយាយ ជារៀងរាល់ថ្ងៃ យើងតែងតែពន្យល់ន័យនៃពាក្យនៅក្នុងន័យនៃទំនាក់ទំនងរបស់ពួកវា។ ប្រសិនបើយើងត្រូវបានគេសួរពីន័យនៃពាក្យលាក់កំបាំងឬក៏ផ្ដល់ន័យនៃពាក្យស្លោកអាចនិយាយបានថា «វាដូចគ្នានឹងពួន» ឬន័យនៃពាក្យ *shallow* ដែលមានន័យថា «ផ្ទុយពីជ្រៅ» ឬពាក្យ *daffodil* ដែលមានន័យថា «ផ្កាមួយប្រភេទ»។ ក្នុងការធ្វើដូច្នេះ យើងកំណត់លក្ខណៈនៃពាក្យនីមួយៗ មិនគិតពីលក្ខណៈពិសេសនៃសមាសធាតុរបស់វាទេ ប៉ុន្តែវាអាចពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់វាជាមួយពាក្យផ្សេងទៀត។ វិធីសាស្ត្រនេះត្រូវបានប្រើនៅក្នុងការពិពណ៌នាតាមវាក្យសព្ទភាសា ដែលត្រូវបានគេចាត់ទុកថាជាការវិភាគនៃទំនាក់ទំនងប្រហាក់ប្រហែលគ្នា។ ទំនាក់ទំនងន័យវចនៈ មានដូចជា សទិសន័យ (ឧ. ស៊ី / ហូប) បដិន័យ (ឧ. រាក់ / ជ្រៅ) ពហុន័យ (ឧ. ស៊ីបាយ / ស៊ីសាំង / ស៊ីខ្យល់ / ស៊ីសំណូក...) ជាដើម។

**១.៤.១. សទិសន័យ**

សទិសន័យ (synonymy) គឺជាពាក្យទាំងឡាយដែលស្ថិតនៅក្នុងថ្នាក់ពាក្យតែមួយដែលមានន័យដូចគ្នាទាំងស្រុង ឬប្រហាក់ប្រហែលគ្នា។ គេយកចិត្តទុកដាក់ទៅលើដំណូចនិងន័យរបស់ពាក្យ។ តក្កៈនៃភាសាសមមូលរវាងពាក្យ (គឺថា វាអាចជំនួសគ្នាដោយផ្នែកសមមូលពេញលេញនៅក្នុងអត្ថបទ)។ តួនាទីរចនាបថរវាងពាក្យ ហើយខ្លឹមសារនៃវេវចនសព្ទគឺស្ថិតនៅត្រង់សមមូលនៃខ្លឹមសារនិងពាក្យដូចជា ផ្ទះ គេហដ្ឋាន លំនៅដ្ឋាន ទីជំរ...។

ពាក្យពីរម៉ាត់ ឬវាចាវិលាស(locution) ពីររូបជាវេវចនសព្ទនឹងគ្នា កាលណាពាក្យ ឬវាចាវិលាសនោះមានប្រភេទដូចគ្នា និងអាចជំនួសគ្នាបានក្នុងឃ្លះដោយឥតបណ្ដាលឱ្យឃ្លះមានន័យផ្សេង។ តាមធម្មតា ពាក្យពីរម៉ាត់ដែលជាវេវចនសព្ទនឹងគ្នាមិនមានន័យដូចគ្នាបេះបិទទេ ពោលគឺគេអាចប្រើសម្រាប់ជំនួសគ្នាបានតែក្នុងករណីខ្លះ ឬក៏អាចជំនួសគ្នាបានតែសណ្ឋានភាសាឬបញ្ជិកាភាសា (registers) មានកម្ពស់ខុសគ្នា ឧទាហរណ៍ ពាក្យ *ស្វាមី* (សណ្ឋានខ្ពស់) រីឯពាក្យ *ប្ដី* (សណ្ឋានធម្មតា)។

**១.៤.២. បដិន័យ**

តាមភាសាវិទូមួយចំនួន ន័យរបស់ពាក្យ «*antonym*» ដែលយើងប្រែថា «*បដិន័យ*» មានព្រំដែនមិនជាក់លាក់។ វាសម្គាល់បដិកម្មពិតប្រាកដ(រវាងបដិន័យពិតប្រាកដ)ផង សម្គាល់ប្រតិភាពផង និងភាពដៃគូនឹងគ្នាផង (បង្គ្រប់គ្នា)។

បដិសព្ទពិតប្រាកដ មានជំនឿនលើមាត្រដ្ឋានជាមួយគ្នា ដូច «*តូច* និង *ធំ*» ដែលនៅលើមាត្រដ្ឋាន «*ដងខ្លួន*» អ្វីដែលមិនធំ មិនប្រាកដជាតូចទេ វាអាចជាមធ្យម។ ក្នុងករណីនេះហើយ ដែលគេអាចប្រើវិសេសន៍គុណនាម ឬគុណនាមប្រៀបធៀប និងអតិវិសេសគុណនាម ឬគុណនាមបំផុតភាព ដូចជា ខ្មៅជាង សជាង សណាស់ ខ្មៅយង់ ខ្មៅណាស់...។

ប្រតិភាព គឺភាពដែលសម្គាល់ចលនាពីរទិស មានទៅមានមក ដូចះ «*លក់*» និង «*ទិញ*» ឬ «*ប្ដី*» និង «*ប្រពន្ធ*»។ ឧទាហរណ៍ ពូសុខលក់ឡានឱ្យពូសៅ បានសេចក្ដីថា ពូសៅទិញឡានពីពូសុខ។ ពូសែនជាប្ដីមីងសួន បានសេចក្ដីថា មីងសួនជាប្រពន្ធពូសែន។

ទម្រង់ពីរដែលមានន័យផ្ទុយគ្នាត្រូវបានគេហៅថាបដិន័យ។ ឧទាហរណ៍ទូទៅមួយចំនួនគឺ *រស់ ≠ ស្លាប់, ធំ ≠ តូច, លឿន ≠ យឺត, សប្បាយ ≠ សោកសៅ, ក្ដៅ ≠ត្រជាក់, វែង ≠ ខ្លី, ប្រុស ≠ ស្រី, រៀបការ ≠ នៅលីវ, ចាស់ ≠ ថ្មី, អ្នកមាន ≠ អ្នកក្រីក្រ, ត្រូវ ≠ ខុស...*។ ជាទូទៅ វាត្រូវបានបែងចែកជាពីរប្រភេទចម្បងគឺ «អាចបត់បែនបាន» (ផ្ទុយគ្នាតាមមាត្រដ្ឋាន) និង «មិនអាចបត់បែនបាន» (ផ្ទុយគ្នាដោយផ្ទាល់)។ ចំណុចដែលអាចបត់បែនបានគឺមានដូចជា *ធំ ≠ តូច* អាចត្រូវបានប្រើនៅក្នុងការស្ថាបនាប្រៀបធៀបដូចជា *ខ្ញុំធំជាងអ្នក* ហើយនិង *សេះតូច* មាន

ន័យថា សេះនេះតូចជាងសេះផ្សេងទៀត។ ដូចគ្នានេះផងដែរ អវិជ្ជមាននៃសមាជិកមួយនៃពាក្យដែលមានន័យផ្ទុយគូគ្នា ដែលអាចបត់បែនបាន មិនចាំបាច់សំដៅលើអ្វីផ្សេងទៀតឡើយ។ ឧទាហរណ៍ *ឡានខ្ញុំមិនចាស់ទេ* មានន័យថា *ឡានរបស់ខ្ញុំថ្មី*។

### ១.៤.៣. ឯកន័យ

ពាក្យឯកន័យ (monosemy) គឺជាពាក្យមានន័យវចនៈតែមួយ។ ពាក្យទាំងនេះចែកចេញជាច្រើនប្រភេទដូចជា៖

- ប្រភេទទី១: គឺនាមដែលសម្គាល់ឈ្មោះ (អ្នកណាមួយ) អសាធារណនាម។ នាមឈ្មោះប្រភេទនេះសម្រាប់ហៅឈ្មោះវត្ថុណាមួយ ហើយតែមួយគត់។ ពាក្យនេះក្លាយជាពាក្យពហុន័យបានលុះត្រាតែនាមនេះក្លាយទៅជានាមធម្មតា (សាធារណនាម)។

- ប្រភេទទី២: គឺជំពូកនាមដែលទើបកើតថ្មី ដែលគេមិនទាន់ប្រើប្រាស់ក្នុងលក្ខណៈទូលំទូលាយនៅឡើយ។ ឧទាហរណ៍ ក្រូម៉ូសូម ម៉ូលេគុល កែវយឺត...។

-ប្រភេទទី៣: គឺបច្ចេកសព្ទ។ ឧទាហរណ៍ សទ្ទតា ន័យតា វចនសព្ទ ...។

នៅក្នុងទីសេចក្ដីផ្សេងគ្នាពាក្យឯកន័យសម្គាល់វត្ថុណាមួយពិតប្រាកដ។ ឧទាហរណ៍ ឪពុកម្ដាយខ្ញុំមានកែវយឺតមួយសម្រាប់មើលការប្រណាំងសេះ។ មេបញ្ជាការខ្ញុំ ស្រលាញ់កែយឺតចាស់របស់គាត់ណាស់។

ប្រៀបធៀប
- -មៀននេះ ឆ្ងាញ់ណាស់។ (ផ្លែ)
- -មៀននេះ ដុតឆេះល្អណាស់។ (ដើម)
- -មៀននេះ ដុះល្អណាស់។ (គ្រាប់)

### ១.៤.៤. ពហុន័យ

ពហុន័យ (Polysemy) គឺជាសមត្ថភាពរបស់សញ្ញាមួយ (ពាក្យមួយ ឃ្លាមួយ...) ឬសញ្ញាច្រើនដែលមានន័យច្រើន (បូរណន័យតា មានន័យថា គឺជាដែនន័យដ៏ធំមួយ។ តាមលោក ឌីក ហេបឌីហ្គ (Dick Hebdige) បានឱ្យនិយមន័យនៃពហុន័យថា អត្ថបទនីមួយៗបានបង្កើតឱ្យមានឋានានុក្រមន័យគ្មានព្រំដែន។

ពាក្យពហុន័យ គឺជាពាក្យមានន័យច្រើនយ៉ាង។ ន័យច្រើនយ៉ាងរបស់ពាក្យមានទំនាក់ទំនងរវាងគ្នានិងគ្នាបង្កើតបានជារចនាសម្ព័ន្ធន័យរបស់ពាក្យ។

នៅពេលយើងជួបប្រទះពាក្យពីរឬច្រើនជាមួយដូចគ្នានិងសម្រាប់ការទាក់ទងគ្នា យើងមានអ្វីដែលត្រូវបានគេស្គាល់ថាជាបច្ចេកទេសម្យ៉ាងហៅថាពហុន័យ។ ពហុន័យ អាចត្រូវបានកំណត់ថាជាទម្រង់មួយ (សរសេរ ឬនិយាយ) ដែលមានន័យច្រើនដែលទាំងអស់ត្រូវបានទាក់ទង។

ឧទាហរណ៍ទី១ ពហុន័យនៃពាក្យ «ដាក់» អាចមានន័យផ្សេងៗគ្នា៖

| | |
|---|---|
| (១) បន្ទាបចុះ៖ | គាត់ដាក់អំបែកចុះ។ |
| (២) ប្រគល់៖ | លោកគ្រូដាក់ការហាត់ឱ្យធ្វើ។ |
| (៣) បន្ទន់ខ្លួន៖ | សំចូលចិត្តដាក់ខ្លួនណាស់។ |
| (៤) តម្រង់ចិត្ត៖ | គេដាក់ចិត្តបំពេញភារកិច្ចហើយ។ |
| (៥) ដោះសត្វពីនឹម៖ | កសិករដាក់រទេះតម្រៀបតាមផ្លូវ។ |

ឧទាហរណ៍ទី២ ពហុន័យនៃពាក្យ «**ដើរ**» អាចមានន័យផ្សេងៗគ្នា៖

១. លើកជើងឈានទៅមុខ៖ អ្នកបច្ចេកទេស ដើរចុះ ដើរឡើងក្នុងរោងចក្រ។

២. ប្រព្រឹត្តទៅ៖ កសិកម្មភូមិយើង ដើរបានបង្គួរហើយ។

៣. កម្រើកដោយកម្លាំងអ្វីមួយ៖ នាឡិកានេះ ដើរលឿនណាស់។
៤. កាន់ការដឹកនាំ៖ បងឯងចូលចិត្ត ដើរកប៉ាល់សមុទ្រ។
៥. បើកចុះឡើង៖ មហាវិថីនេះ មានរថយន្ត ដើរតេតអាក់។
៦. ចែកឋានៈ គាត់នឹងដើរ ( ស្លាប់ ) ក្នុងពេលបន្តិចទៀតនេះ។

ប្រសិនបើយើងមិនប្រាកដថា តើការប្រើភាពខុសគ្នានៃពាក្យតែមួយ ជាឧទាហរណ៍នៃសទិសន័យឬពហុន័យ យើងអាចពិនិត្យមើលវចនានុក្រមមួយ ប្រសិនបើពាក្យមានន័យច្រើន (មានន័យថា វាគឺពហុន័យ) បន្ទាប់មកវានឹងមានឋានៈតែមួយដែលមានបញ្ជីមួយ ដែលមានន័យខុសៗគ្នានៃពាក្យនោះ។ ប្រសិនបើពាក្យពីរត្រូវបានបង្កើតជាពាក្យដូចគ្នាពួកវានឹងមានលក្ខណៈពីរដាច់ដោយឡែក។

បើយោលទៅតាមលក្ខណៈទំនាក់ទំនងន័យរបស់ពាក្យ ដែលមាននៅក្នុងភាសាផ្សេងៗ គឺមិនដូចគ្នាទេ វាអាចឱ្យយើងសន្និដ្ឋានបានថា បាតុភូតពហុន័យ គឺជាលក្ខណៈមួយដែលឆ្លុះបញ្ចាំងនូវលក្ខណៈពិសេសរបស់ពាក្យសព្ទជាតិនីមួយៗ។ ដោយហេតុនេះហើយបានជានៅក្នុងការបកប្រែឱ្យបានត្រឹមត្រូវ គឺត្រូវស្គាល់ពីក្រឹត្យក្រមរចនាសម្ព័ន្ធន័យរបស់ភាសានីមួយៗឱ្យបានច្បាស់។

ន័យរបស់ពាក្យពីសម័យកាលមួយទៅសម័យកាលមួយ តែងមានការប្រែប្រួលដោយកត្តាខាងក្រៅភាសា ( សង្គម នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ) និងកត្តាខាងក្នុងភាសាដែលជាហេតុនាំឱ្យពាក្យឯកន័យក្លាយទៅជាពហុន័យ ដូចនេះគេត្រូវបង្កើតពាក្យថ្មី ឬយកពាក្យចាស់ដែលន័យរបស់វាថមថយ គេមិនសូវប្រើប្រាស់ មកដាក់ឈ្មោះឱ្យវត្ថុថ្មី និងបាតុភូតថ្មីទាំងនោះ។

ឧទាហរណ៍: ក្រដាស ក្រដាសផ្តិត ក្រដាសពណ៌ ក្រដាសកាបោន ក្រដាសពុម្ព។
លិខិត លិខិតច្បាប់ លិខិតធ្វើដំណើរ លិខិតអញ្ជើញ។

ការពង្រីកន័យរបស់ពាក្យ ក្នុងរយៈកាលដ៏យូរបាននាំមកនូវពហុន័យរបស់ពាក្យ គឺថា ពាក្យមួយមានន័យច្រើន។

ឧទាហរណ៍: to do ( អង់គ្លេស ) មានន័យ១៦បែប
Savoir ( បារាំង ) មានន័យ ៥បែប។

គ្រួសារ: ១. ក្រុមមនុស្សដែលជាញាតិសន្តាននឹងគ្នា
២. ប្រពន្ធ ឬប្តី

ថ្ងៃ : ១. ព្រះអាទិត្យ
២. រយៈពេល២៤ ម៉ោង
៣. រយៈពេលភ្លឺ ( ផ្ទុយនឹងយប់ )។

ពហុន័យជាបាតុភូតចៀសមិនផុត គឺឱ្យតែគេប្រើពាក្យណាមួយ ពាក្យនោះនឹងមានន័យប្លែកបន្តិចបន្តួចតាមករណីស្ទើរតែរាល់ដង។ ប៉ុន្តែបាតុភូតនេះ មិនរំខានដល់ទំនាក់ទំនងរវាងអ្នកនិយាយគ្នា ( អន្តរជន ) ទេ ពីព្រោះផ្ទុយទៅវិញគឺន័យបរិបទ ឬន័យក្នុងល្បះបែបនេះហើយ ដែលធ្វើឱ្យយើងយល់ច្បាស់ពីស្ថានភាពណាមួយ ន័យទូទៅ ( ន័យកម្ម ) ក្រៅបរិបទទុកយើងឱ្យនៅក្នុងស្ថានភាពមិនច្បាស់លាស់។

### ១.៤.៥. ន័យត្រង់

ន័យត្រង់ (Proper Meaning) គឺជាន័យដែលចង្អុលប្រាប់ត្រង់ៗ ហើយឱ្យយើងស្គាល់វត្ថុ បាតុភូត សកម្មភាព គុណភាព។ល។ ន័យនេះបានឆ្លើយឆ្លងគ្នាដោយចំពោះ ដោយផ្ទាល់ទៅនឹងបញ្ញត្តិ ន័យត្រង់ជាន័យដែលសំដែងនូវការហៅឈ្មោះនៃវត្ថុនៅក្នុងរយៈកាលបច្ចុប្បន្ននៃការវិវត្តរបស់ភាសា។

ឧទាហរណ៍ *មុខមនុស្ស, ផ្ទៃមុខ, ស្បែកមុខ, មុខគោ, មុខក្របី,...*។

តាមឧទាហរណ៍ខាងលើ យើងឃើញថា កន្សោមពាក្យ *មុខមនុស្ស* ពាក្យ *មុខ* ស្ថិតនៅក្នុងដែនន័យត្រង់ ដែលន័យរបស់ពាក្យ *មុខ* នៅតែរក្សាគ្រប់ទម្រង់ជាតុន័យរបស់ខ្លួនមិនមានការបំប្លែងន័យរបស់ខ្លួននៅឡើយទេ។ ន័យរបស់ពាក្យ *មុខ* ក្នុងកន្សោមពាក្យ *មុខមនុស្ស* ពាក្យ *មុខ* នៅតែស្តែងន័យ *មុខ* ដែលសម្គាល់ប្រធាននៃសរីរប្រទេស គឺប៉ែករូបកាយត្រង់ទីប្រជុំនៃថ្ងាស ចិញ្ចើម ភ្នែក ច្រមុះ មាត់ និងចង្កា។

តាមរយៈការពន្យល់ខាងលើយើងឃើញថា ន័យត្រង់ គឺជាន័យឫសរបស់ពាក្យ ដែលរាល់ការប្រើប្រាស់ន័យក្នុងទិដ្ឋភាពផ្សេងៗ ន័យឫសរបស់ពាក្យមិនមានការផ្លាស់ប្តូរទម្រន័យគ្រឹះ ទោះបីវាចូលរួមជាមួយពាក្យដទៃ។ នេះសបញ្ជាក់ថា ន័យត្រង់ គឺជាន័យដើមរបស់ពាក្យដែលពុំទាន់រងឥទ្ធិពលនៃពាក្យដទៃក្នុងការផ្សំន័យ ឬបង្កើតន័យ។ ដូចនេះពាក្យទាំងឡាយណាដែលន័យរបស់វាមិនបានបំប្លែងន័យ មិនទាន់មានការប្រែប្រួលន័យដាច់ស្រលះពីន័យរបស់ពាក្យឫស ហើយដែលជាទូទៅខួរក្បាលរបស់យើងងាយចាប់បាននូវសញ្ញាទាំងនោះ។

### ១.៤.៦. ន័យធៀប

ន័យធៀប (Figurative Meaning) គឺជាន័យប្រយោលចេញផុតពីទម្រន័យគ្រឹះនៃន័យរបស់ពាក្យ។ វាបានបំប្លែងន័យ (ន័យក្លាយ) ពីន័យត្រង់ ហើយមិនមានជាតុន័យណាមួយជាប់ពាក់ព័ន្ធនឹងន័យរបស់ពាក្យឫស ជាពិសេសរូបារម្មណ៍ន័យបានដាច់ស្រលះចេញផុតពីន័យឫសរបស់ពាក្យ (ន័យត្រង់) ហើយធ្វើការបំប្លែងន័យរបស់ខ្លួននៅពេលវាបានចូលរួមជាមួយជាតុដទៃ (ការចូលរួមក្នុងអន្តរកម្ម) បង្កើតបានជាបាតុភូតពហុន័យ។ ដូចនេះន័យធៀបអាចជាពហុន័យ អាចជាបញ្ញត្តិថ្មី ជាពាក្យថ្មីមានអត្តសញ្ញាណន័យផ្ទាល់របស់ខ្លួន។

នៅក្នុងសៀវភៅ បញ្ហាវចនសព្ទវិទ្យាខ្មែរ និពន្ធដោយសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម បោះពុម្ពដោយវិទ្យាស្ថានភាសាជាតិ ឆ្នាំ១៩៩៩ ទំព័រទី៩១ លោកបានប្រើវាក្យសព្ទ រូបារម្មណ៍នីយកម្ម និងរូបារម្មណ៍ដើម្បីបង្ហាញពីការប្រៀបធៀបន័យដែលជាន័យធៀប។ លោកបានសរសេរថា៖ «រូបារម្មណ៍នីយកម្មបានពីការប្រៀបធៀបន័យ គឺជាបែបផែនម្យ៉ាងនៃបំប្លែងន័យ គឺបានសេចក្តីថា ន័យអរូបីកើតឡើងដោយឈរលើមូលដ្ឋានន័យរូបីដោយវិធីប្រដូចបញ្ញត្តិតាមភាពជំណូចឬវិធីជំនួស»។

ការប្រៀបធៀបន័យអាចឈរលើមូលដ្ឋាននៃពាក្យទោល ឬពាក្យផ្សំ ព្រមទាំងកន្សោមពាក្យ ឬសំនួនវោហារសព្ទផងដែរ។ ការប្រៀបធៀបន័យអាចប្រមូលផ្តុំដោយឈរលើបណ្តុំលក្ខណៈនៃវត្ថុពីរ។ ឈ្មោះរបស់វត្ថុមួយក្នុងចំណោមវត្ថុពីរជាញឹកញាប់មានតួនាទីជាអ្នកកំណត់នៃវត្ថុមួយទៀត។

| | | | | | |
|---|---|---|---|---|---|
| ឧទាហរណ៍៖ | ដៃមនុស្ស | - | ដៃទន្លេ | ខោខ្មៅ | - | ចិត្តខ្មៅ |
| | កាំបិតដែក | - | បេះដូងដែក | មាត់មនុស្ស | - | មាត់បឹង |

### ១.៤.៧. បម្រៀបន័យ

បម្រៀបន័យ (Metaphor) គឺជាពាក្យប្រៀបធៀប (Figure of Speech) ដែលពិពណ៌នាពីប្រធានវិស័យមួយដោយការអះអាងថា ការប្រៀបធៀបចំណុចខ្លះដែលមានភាពដូចគ្នាជាមួយវត្ថុផ្សេង ក៏ប៉ុន្តែវត្ថុនោះគ្មានទំនាក់ទំនងគ្នាទេ។ បម្រៀបន័យគឺជាប្រភេទនៃសទិសភាព ហើយវាមានទំនាក់ទំនងយ៉ាងជិតបំផុតជាមួយពាក្យប្រៀបធៀបវោហារសព្ទ ដែលទទួលឥទ្ធិពលតាមរយៈការចូលរួម ការប្រៀបធៀប ឬភាពដូចគ្នា ដូចជារូបាធិដ្ឋាន (allegory) ដែលមានន័យថាសេចក្តីអធិប្បាយដោយការប្រៀបធៀប ពន្លើស (hyperbole) និងឧបមានវិធី (simile)។

បម្រៀបន័យ គឺជាការដាក់ឈ្មោះនៃវត្ថុមួយដោយមួយទៀត ដែលភ្ជាប់ទៅនឹងទីមួយតាមទំនាក់ទំនងជំណូច (ក្រសួងអប់រំ, ១៩៨៦: ១៦៨)។

**ក. បម្រៀបន័យផ្ទួច**

ក្នុងបម្រៀបន័យបែបនេះ គេយកវត្ថុមួយទៅផ្ទួចនឹងវត្ថុមួយទៀត ដោយដាក់ពាក្យសម្គាល់វត្ថុទាំងពីរនោះឱ្យនៅជិតគ្នា។

ឧទាហរណ៍៖

-មេឃស្រកានាគ សមុទ្រមេឃា

(មេឃមានពពកជារូបរាងស្រកាធំៗ ប្រៀបបាននឹងស្រកានាគ )

(សមុទ្រធំធេងគ្មានកោះត្រើយ ប្រៀបដូចនឹងមេឃ)

-ភ្នំផ្លឹង ស្ទឹងទឹកភ្នែក

(ផ្លឹងគរជាគំនរខ្ពស់ដូចភ្នំ។ ផ្លឹងគរដូចភ្នំ > ភ្នំផ្លឹង)

(ទឹកភ្នែកច្រើនណាស់ ដូចទឹកស្ទឹង។ ទឹកភ្នែកហូរដូចស្ទឹង > ស្ទឹងទឹកភ្នែក)

-ជើងភ្នំ ធ្មេញរណា ជើងស្ពាន ក្បាលស្ទឹង ត្រចៀកពាង...។

| | | |
|---|---|---|
| សាគរមេឃា | មិនមែនគង្គា | វាយោដែលខ្វល់ |
| តែក្នុងអាត្មា | តណ្ហារចល់ | ច្រើនហើយជ្រៅសល់ |
| | វិបាកបន្លាយ។ | |

(ចិត្តក្រមុំ ទំព័រ២០)

លក្ខណៈដំណូចមានដូចជា៖

**១. ដំណូចលក្ខណៈខាងក្រៅ**

ឧទាហរណ៍: ជើងមាស (សត្វ) ជើងមាស (គ្រប់), បាតខ្ទះ បាតសង្គម បាតថ្នាក់, កន្ទុយក្រពើ (សត្វ) កន្ទុយក្រពើ (រុក្ខជាតិ), ស្លាប (សត្វ) ស្លាប (យន្តហោះ), ត្រចៀក (មនុស្ស) ត្រចៀក (ប៉ោត)...។

**២. ដំណូចមុខងារ**

ឧទាហរណ៍: ជើងគោ (សត្វ) ជើងគោ(រុក្ខជាតិ), ជើង(មនុស្ស) ជើង(តុ), ដៃ(មនុស្ស) ដៃ(ផ្ទាំង ទ្វារ)។

**៣. ដំណូចទីតាំង**

ឧទាហរណ៍: ជើង (មនុស្ស) ជើង (ភ្នំ), ចង្កេះ (មនុស្ស) ចង្កេះ (ភ្នំ), មុខ (មនុស្ស) មុខ (ផ្ទះ), កន្ទុយ (សត្វ) កន្ទុយ (យន្តហោះ)...។

**៤. ដំណូចសូរសំឡេង**

ឧទាហរណ៍: ថ្ងូរ (មនុស្ស) ថ្ងូរ (ខ្យល់), គ្រហឹម (ឆ្កែ) ក្រហឹម (ផ្គរ)...។

**៥. ដំណូចរស់ជាតិ**

ឧទាហរណ៍: ល្វីង(ថ្នាំ) ល្វីង(សំដី), ជូរ(អម្ពិល) ជូរ(ជីវិត), ផ្អែម(ស្ករ) ផ្អែម(សំដី)...។

**ខ. បម្រៀបន័យផ្តប់**

ក្នុងបម្រៀបន័យបែបនេះ គេយកពាក្យ ឬក្រុមពាក្យមួយមកជំនួសពាក្យ ឬក្រុមពាក្យមួយទៀតទាំងស្រុង។

ឧទាហរណ៍៖

-នៅពេលព្រលឹមឡើង គេឃើញដំណក់ពេជ្រផ្លេកៗ លើចុងស្មៅ។

(ដំណក់ពេជ្រ គឺទឹកសន្សើម)

-ក្រោមស្មើដ៏ស្រទន់ កម្រាលព្រំបៃតងលាតសន្ធឹងខ្លួនដាច់កន្ទុយភ្នែក។

(កម្រាលព្រំបៃតង គឺវាលស្រែពណ៌បៃតង)

**គ. រូបីនីយកម្ម ឬរូបីវិធី**

ក្នុងបម្រៀបន័យបែបនេះ គេយកពាក្យមានលក្ខណ៍អរូបី(ន័យតាអរូបី) [-រូបី ] មកប្រើជាមួយពាក្យមានលក្ខណ៍រូបី (ន័យតារូបី) [+ រូបី ] ដើម្បីធ្វើឱ្យរូបផ្សំនោះមានរូបារម្មណ៍ឡើង។

ឧទាហរណ៍៖

-ភ្លើងតណ្ហា នាវាតណ្ហា រន្ទះស្នេហា...។

តណ្ហា [-រូបី ] ប្រើជាមួយភ្លើង [+ រូបី ] បង្កើតរូបារម្មណ៍រូបី។

| | | |
|---|---|---|
| នាវាតណ្ហា | អណ្តែតទៅណា | ក្នុងកង់លោកិយ |
| គ្មានកោះគ្មានត្រើយ | គ្មានស្បើយបេតី | រកត្រើយសួស្តី |
| | សមុទ្រវេទនា។ | |

(បិត្តក្រមុំ ទំព័រ២១)

ក្នុងកំណាព្យខាងលើ៖

-នាវា ជា នាមរូបី។

-តណ្ហា ជា នាមអរូបី។

-ក្នុងពាក្យ *នាវាតណ្ហា* នាំឱ្យ «*តណ្ហា*» ក្លាយជានាមរូបី មានរូបរាង។ រូបរាងនៃតណ្ហានេះ បង្កើតបានជារូបារម្មណ៍ក្នុងខួរក្បាល។

**ឃ. ជីវចលនីយកម្ម ឬជីវវិធី**

ក្នុងបម្រៀបន័យនេះ គេយកពាក្យមួយមានលក្ខណ៍ន័យ [-ជីវចល] ទៅប្រើជាមួយពាក្យមួយទៀតដែលមានលក្ខណ៍ន័យ [+ ជីវចល] ដើម្បីធ្វើឱ្យពាក្យទីមួយមានជីវិតឡើង៖

ឃ.១. ធ្វើវត្ថុឥតវិញ្ញាណឱ្យមានវិញ្ញាណ (វិញ្ញាណនីយកម្ម)

ឧទាហរណ៍៖

-បុប្ផាញញឹម ខ្យល់ថ្ងូរតម្អូញ រថយន្តស្រែកគ្រហឹម...។

ក្នុងឧទាហរណ៍ខាងលើយើងឃើញ៖

-បុប្ផា ជា នាមអជីវចល។

-ញញឹម ជាកិរិយាប្រើបានតែនឹងប្រធានជីវចល (មនុស្ស)។

-បុប្ផាញញឹម នាំឱ្យ *បុប្ផា* ក្លាយជាមានជីវិត មានវិញ្ញាណ (ក្លាយជាមនុស្ស)។

ឃ.២. ធ្វើវត្ថុឥតចលនា ឱ្យមានចលនា (ចលនានីយកម្ម)

ឧទាហរណ៍៖

-រុក្ខជាតិទាំងឡាយរត់ថយក្រោយយ៉ាងលឿន។

-ទូកលូនសន្សឹមៗលើផ្ទៃទឹក។

-រថយន្តបោលកាត់ព្រៃព្រឹក្សា។

-ពិភពផែនដីចេះតែវិល។

-វិទ្យាសាស្ត្ររំកិលឥតឈប់ឈរ។

ក្នុងឧទាហរណ៍ខាងលើ យើងឃើញ៖

-រុក្ខជាតិ ជា នាមអជីវចល។

-រត់ ជាកិរិយាសព្ទប្រើបានតែជាមួយប្រធានមានជីវចល (សត្វ ឬមនុស្ស)។

-រុក្ខជាតិរត់ នាំឱ្យ *រុក្ខជាតិ* ប្រែជាមានជីវិត មានចលនា (ក្លាយជាសត្វលោក)។

ឃ.៣. ធ្វើវត្ថុឥតចេតនា ឱ្យមានចេតនា (ចេតនានីយកម្ម)

ឧទាហរណ៍៖

-ឈូករត្ន ស្បៃរឿងញញឹម ទទួលរស្មីអរុណ។

-ទឹកជំនាន់ជន់ជោរ យ៉ាងសាហាវ ស្មុះគ្រញ៉េងខ្លួនបំផ្លាញភូមិមាត់ទន្លេយ៉ាងដំណំ។

ក្នុងឧទាហរណ៍ខាងលើ យើងឃើញ៖

-ឈូករត្ន ស្បៃរឿង ជានាមអជីវចល។

-ញញឹម ទទួល ជាកិរិយាប្រើជាមួយប្រធានជីវចលមនុស្ស។

-ឈូករត្នញញឹមទទួលរស្មីអរុណ នាំឱ្យ *ឈូករត្ន* ក្លាយជាប្រធានជីវចលមនុស្សមានចេតនា។

### ១.៤.៨. បន្ទេរន័យ

បន្ទេរន័យ (Metonymy) ជាវិធីមួយដែលគេប្រើសម្រាប់ពន្យល់បញ្ញត្តិមួយដោយប្រើពាក្យមួយសម្រាប់សម្គាល់បញ្ញត្តិមួយទៀតដែលមានលក្ខណៈមួយចាំបាច់ដូចជា ហេតុ ផល នៅក្នុងនិងជំណូច។ល។

បន្ទេរន័យ ជាការដាក់ឈ្មោះនៃវត្ថុមួយដោយវត្ថុមួយទៀត ដែលភ្ជាប់ទៅនឹងទីមួយតាមទំនាក់ទំនងជំនិត។

**ក. ទម្រង់និងខ្លឹមសារ**

ឧទាហរណ៍៖

-បន្ទប់ - បន្ទប់ (បន្ទប់ សម្គាល់មនុស្សក្នុងបន្ទប់)។

-ផ្ទះ -ផ្ទះ (ផ្ទះ សម្គាល់មនុស្សក្នុងផ្ទះ)។

-ទីក្រុង -ទីក្រុង (ទីក្រុង សម្គាល់មនុស្សក្នុងទីក្រុង)។

-គ្រួសារ -គ្រួសារ (គ្រួសារ សម្គាល់មនុស្សក្នុងគ្រួសារ)។

**ខ. វត្ថុទាំងមូលនិងផ្នែកមួយ**

គេយកពាក្យសម្គាល់វត្ថុអ្វីមួយ ទាំងមូលទៅហៅផ្នែកណាមួយនៃវត្ថុទាំងនោះ។

ឧទាហរណ៍៖

-មៀននេះមានទឹកដមឆ្ងាញ់ណាស់ (មៀនសម្គាល់ផ្លែមៀន)។

-មៀននេះដុតធេះល្អណាស់ (មៀនសម្គាល់ដើមមៀន)។

-ស្រុកនេះ គេនិយមដាំមៀន (មៀនសម្គាល់ដើមមៀនទាំងមូល)។

ជួនកាលទៀត គេយកពាក្យសម្គាល់ ផ្នែកមួយនៃវត្ថុទៅហៅ វត្ថុទាំងមូលតែម្តង។

ឧទាហរណ៍៖

-មនុស្សចិត្តថ្ម សម្គាល់មនុស្សដែលមានចិត្តនឹង ប្រៀបដូចថ្ម។

-អន្ទិតសក់ខ្លី សម្គាល់អ្នកម្រៀងអាយៃខ្មែរមួយរូប ដែលកាត់សក់ខ្លី។

-ស្មៀនដៃការេ សម្គាល់អ្នកចម្រៀងចាប៉ី ដែលមានដៃក្ងែង។

-ក្នុងរឿងបុរាណ មានឈ្មោះ អាច្រមុះធំ អាដៃធំ អាខ្នងវែង អាគូថស្វិត...។

**គ. វត្ថុធាតុដើមនិងលទ្ធផល**

ឧទាហរណ៍៖

-មាស (លោហៈ) មាស (អលង្ការ)

-ពេជ្រ (លោហៈ) ពេជ្រ (អលង្ការ)។

**ឃ. អ្នកនិពន្ធ (ផលិតករ) និងស្នាដៃ (ផលិតផល)**

គេយកឈ្មោះផលិតករទៅហៅផលិតផលដែលផលិតករនោះបង្កើតឡើង។

ឧទាហរណ៍ ៖

-សំ មានរឿងទុំទាវពីរក្បាល ៖ មួយតែងដោយ ភិក្ខុសោម មួយទៀត ដោយសន្ធរម៉ុក។ វាចូលចិត្តអាន «ភិក្ខុសោម» ជាងគេ (ភិក្ខុសោម សម្គាល់អ្នកនិពន្ធរឿងទុំទាវផង សម្គាល់សៀវភៅ រឿងទុំទាវផង)។

-គាត់ប្រាប់ខ្ញុំថា ក្នុងចំណោមសៀវភៅវចនានុក្រមរបស់គាត់ គាត់ចូលចិត្តបើក «ជួន ណាត» ជាងគេ (ជួន ណាត ជាឈ្មោះអ្នកនិពន្ធសៀវភៅវចនានុក្រម ហើយអាចសម្គាល់សៀវភៅវចនានុក្រម ជាស្នាដៃរបស់គាត់ថែមទៀត)។

**ង. ចម្រកនិងវត្ថុច្រក**

ចម្រក គឺជាវត្ថុ ឬទីកន្លែងសម្រាប់ដាក់អ្វីផ្សេងៗដែលយកមកច្រកខាងក្នុងវត្ថុនោះ។

ឧទាហរណ៍៖

-ផ្ទះនេះឡូឡាណាស់ ថ្ងៃនេះ (ផ្ទះនេះ ជាចម្រក។ ផ្ទះនេះសម្គាល់មនុស្សនៅក្នុងផ្ទះ។ មនុស្សក្នុងផ្ទះជាវត្ថុច្រក)។

-ភូមិយើងប្រយុទ្ធបង្កបង្កើនផល (ភូមិយើង គឺប្រជាជនក្នុងភូមិទាំងមូល)។

លោហិតកម្ពុជាគ្រប់ស្រទាប់ រស់លើទ្រនាប់ឥតធម៌មេត្តា
តាមតែគេប្រើគ្មានហ៊ានថា សេរីសោតណាគ្មានអ្វីបន្តិច។
(ជួន ម៉េន, មើលដែនដីខ្មែរ)

ក្នុងទីនេះ កម្ពុជា សម្គាល់ប្រជាជនកម្ពុជា។

**ច. ឧបករណ៍និងអ្នកប្រើប្រាស់**

គេយកឈ្មោះឧបករណ៍ទៅហៅអ្នកប្រើប្រាស់ឧបករណ៍នោះ។

ឧទាហរណ៍៖

-មេកន្ត្រៃនេះល្បីល្បាញណាស់ (មេកន្ត្រៃ សម្គាល់មេជាងកាត់ដេរខោអាវ)។

-មេចង្ក្រាននេះ ធ្វើម្ហូបឆ្ងាញ់ណាស់ (មេចង្ក្រាន សម្គាល់អ្នកដាំស្លធ្វើម្ហូប)។

-កូនកាំបិតនេះ ធ្វើការលឿនណាស់ (កូនកាំបិត សម្គាល់ជំនួយការរបស់មេចុងភៅ)។

**ឆ. កន្លែងផលិតនិងវត្ថុផលិត**

គេយកឈ្មោះទីកន្លែងសម្រាប់ផលិតមកដាកឈ្មោះឱ្យវត្ថុដែលគេផលិតបាននៅទីនោះ។

ឧទាហរណ៍៖

-វាចូលចិត្តផឹក «ដំណើបខ្មៅ» ឯបងវាចូលចិត្ត «ម្នាស់» (ដំណើបខ្មៅ ជាឈ្មោះស្រូវ តែក្នុងទីនេះសម្គាល់ស្រា ដែលធ្វើដោយដំណើបខ្មៅនោះ។ ឯ ម្នាស់ក៏សម្គាល់ផ្លែឈើ ហើយទីនេះសម្គាល់ស្រា កើតឡើងដោយម្នាស់ដែរ)។

## ១.៤.៩. ឧបមានឬទំហៀបន័យ

ឧបមានឬទំហៀបន័យ (simile) គឺជាល្បិចរចនាបថមួយបែប ដែលគេប្រៀបធៀបអង្គពីរឱ្យស្របគ្នា ឬមិនស្របគ្នា ដោយប្រើចំណងធៀប «ជាង ដូច ស្មើ គឺ មិនដូច មិនស្មើ» ជាដើម។

ឧទាហរណ៍៖

-សាធុចៅអើយ យាយអរពេកហើយ ហើយយាយស្រលាញ់
សំដីចៅឯង ផ្អែមហើយឈ្ងុយឆ្ងាញ់ សេដាណាមិញ
ផ្អែម*ជាង*ពាក្យចៅ។ (*ម៉ុក សំឱក*)

ក្នុងកំណាព្យខាងលើនេះ កវី យកអង្គពីរមកប្រៀបផ្ទឹមគ្នា៖ អង្គទីមួយជាអង្គបង្គោល ឯអង្គទីពីរ ជាអង្គទំហៀប «*សេដា*» ជាអង្គបង្គោល ឯ «*ពាក្យចៅ*» ជាអង្គទំហៀប។

| | | |
|---|---|---|
| -ម៉ែឪមានគុណ | គុណមានទម្ងន់ | ធ្ងន់*ដូចប្រឹថពី* |
| គ្មានអ្វីនឹងសង | គុណលោកទាំងទ្វី | មាស*ប៉ុនគិរី* |
| | ថ្លៃពុំស្មើហោង។ | (*វិជ្ជាខេមរភាសា ឆ្នាំ១៩២៩*) |

ក្នុងភាសាអង់គ្លេសក៏មានប្រើរចនាបថបែបនេះច្រើនដែរ ដូចជា «*Life is a journey*» នៅក្នុងឈ្មោះនេះមានន័យថា «*ជីវិត គឺជាការធ្វើដំណើរ*»។ យើងអាចពន្យល់បានដូចតទៅ៖

(១) ការដឹកនាំជីវិតមនុស្ស គឺអ្នកធ្វើដំណើរ។

(២) គោលបំណងរបស់ជីវិត គឺគោលដៅ។

(៣) អត្ថន័យសម្រាប់ទទួលគោលបំណង គឺផ្លូវ។

(៤) សេចក្ដីលំបាកក្នុងជីវិត គឺការបង្អាក់ចំពោះដំណើរ។

(៥) អ្នកផ្ដល់ដំបូន្មាន គឺមគ្គុទ្ទេសក៍។

(៦) វឌ្ឍភាពនៃជីវិត គឺចម្ងាយដែលត្រាច់ចរ។

(៧) រឿងរ៉ាវដែលអ្នកថ្លឹងថ្លែងវឌ្ឍនភាពរបស់អ្នកដោយការសម្គាល់ទីកន្លែងផ្សេងៗ។

(៨) ធនធានសម្ភារៈនិងទេពកោសល្យនៃជីវិត គឺវត្ថុបម្រុងទុក។

## ២. ការណ៍វិទ្យា

នៅចុងទសវត្ស ឆ្នាំ១៩៦០ អ្នកទេសចរជនជាតិអាមេរិកចំណាស់ពីរនាក់ ដែលបានធ្វើដំណើរកម្សាន្តនៅប្រទេសស្កុតលែន បានរាយការណ៍ថា នៅក្នុងដំណើរកម្សាន្តរបស់ពួកគេ ហើយពួកគេក៏បានមកដល់ទីក្រុងស្កុតលែនដែលមានព្រះវិហារខ្ទេចខ្ទាំមួយ។ នៅពេលពួកគេឈរនៅក្នុងប្រាសាទ ពួកគេបានឃើញក្មេងប្រុសតូចម្នាក់ហើយពួកគេបានសួរគាត់ថា តើព្រះវិហារនេះត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរដូចម្ដេច? គាត់បានឆ្លើយតបនៅក្នុងសង្គ្រាម។ ការបកស្រាយភ្លាមៗរបស់ពួកគេនៅក្នុងទសវត្សឆ្នាំ១៩៦០ គឺថាគាត់ត្រូវតែសំដៅទៅលើសង្គ្រាមលោកលើកទី២ ដែលបានបញ្ចប់តាំងពី២០ឆ្នាំមុន។ ប៉ុន្តែបន្ទាប់មក ពួកគេបានគិតថា ប្រាសាទនេះមើលទៅហាក់ដូចជាស្ថិតក្នុងសភាពទ្រុឌទ្រោមយូរជាងនេះ ដូច្នេះពួកគេបានសួរក្មេងប្រុសនោះថា តើសង្គ្រាមមួយណាដែលគាត់ចង់និយាយ។ គាត់បានឆ្លើយតបនឹងសង្គ្រាមជាមួយអង់គ្លេស ដែលនៅទីបំផុតពួកគេបានរកឃើញថា បានបញ្ចប់ជាផ្លូវការនៅឆ្នាំ១៧៤៥។

នៅក្នុងមេរៀនមុន យើងបានផ្ដោតលើន័យបញ្ញត្តិនិងទំនាក់ទំនងរវាងពាក្យជាមួយន័យបញ្ញត្តិនេះ។ វាមានទិដ្ឋភាពផ្សេងទៀតនៃន័យដែលពឹងផ្អែកកាន់តែច្រើនលើបរិបទនិងបំណងប្រាស្រ័យទាក់ទងរបស់អ្នកនិយាយ។ នៅក្នុងសាច់រឿងរបស់ ហ្គីល ប្រោន (Gill Brown) អ្នកទេសចរអាមេរិកនិងក្មេងប្រុស ជនជាតិស្កុតលែន ហាក់ដូចជាកំពុងប្រើពាក្យ *war* (សង្គ្រាម) ដែលមានន័យជាមូលដ្ឋានដូចគ្នា។ ទោះយ៉ាងណាក្មេងប្រុសនេះ បានប្រើពាក្យនេះដើម្បីសំដៅទៅលើអ្វីមួយ ដែលភ្ញៀវទេសចរមិននឹកស្មានដល់ ហេតុដូចនេះហើយ ទើបមានការយល់ច្រឡំដំបូង។ ការប្រាស្រ័យទាក់ទងដែលមានភាពច្បាស់លាស់ មិនត្រឹមតែស្គាល់ន័យនៃពាក្យក្នុងសូរសព្ទសម្ដីប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្គាល់ពីអ្វីដែលអ្នកនិយាយចង់មានន័យសំដៅទៅដល់ ដោយសម្ដីរបស់ពួកគេផ្ទាល់។ ការសិក្សាអំពីអ្វីដែលអ្នកនិយាយចង់មានន័យសំដៅទៅដល់អ្វីមួយឬន័យរបស់អ្នកនិយាយ ត្រូវបានគេហៅថា ការណ៍វិទ្យា។

ការបើកបរនៅកន្លែងអគារចតរថយន្ត អ្នកអាចឃើញស្លាកសញ្ញាធំដូចនៅក្នុងរូបភាពដែលបង្ហាញពីស្លាកសញ្ញាចរាចរណ៍ផ្សេងៗ។ អ្នកអានសញ្ញានោះដោយដឹងថាពាក្យនីមួយៗមានន័យយ៉ាងម៉េច ហើយតើសញ្ញាសម្គាល់ទាំងមូលមានន័យយ៉ាងដូចម្ដេច។ ទោះយ៉ាងណាអ្នកមិនគិតថា សញ្ញានោះកំពុងផ្សព្វផ្សាយកន្លែងដែលអ្នកអាចចត

រថយន្តបាន ឧទាហរណ៍ «*your heated attendant*» (ដែលអាចមានន័យថា ចូរយកអ្នកយាមម្នាក់, អ្នកធ្វើឱ្យវាក្តៅឡើង ហើយនេះគឺជាកន្លែងដែលអ្នកអាចចតវាបាន។) តាមជម្រើសផ្សេងៗ សញ្ញានេះអាចបង្ហាញពីកន្លែងដែលចំណតរថយន្តនឹងត្រូវបានអនុវត្តដោយអ្នកយាមដែលមានភាពស្វាហាប់។

ពាក្យនៅក្នុងសញ្ញាខាងលើនេះអាចអនុញ្ញាតឱ្យមានការបកស្រាយបែបនេះ ប៉ុន្តែជាធម្មតាយើងយល់ថាយើងអាចចតរថយន្តនៅកន្លែងនេះបាន ថាជាតំបន់ក្តៅ ហើយថាទីនេះនឹងមានអ្នកមើលថៃឡាន។ ដូច្នេះតើយើងសម្រេចថាសញ្ញានេះមានន័យយ៉ាងម៉េចនៅពេលដែលសញ្ញានោះមិនមានពាក្យ *car* (ឡាន) នៅលើវា នោះ? យើងត្រូវតែប្រើន័យនៃពាក្យតាមបរិបទដែលវាកើតឡើង ហើយនិងចំណេះដឹងខ្លះដែលមានស្រាប់ចំពោះអ្វីដែលអាចទំនងជាសារ នៅពេលយើងធ្វើការឆ្ពោះទៅរកការបកស្រាយសមហេតុផលនៃអ្វីដែលអ្នកបង្កើតសញ្ញានេះ ចង់បង្ហាញប្រាប់យើង។ ការបកស្រាយរបស់យើងអំពី «ន័យ» នៃសញ្ញាសម្គាល់ មិនមែនផ្អែកទៅលើពាក្យទេ តែផ្អែកទៅលើអ្វីដែលយើងគិតថា អ្នកសរសេរចង់បង្ហាញពីអ្វីមួយ។

នៅក្នុងរូបភាពផ្សេងទៀតដែលគេសរសេរជាភាសាអង់គ្លេសថា «*sale baby and toddler*» សន្មតថារឿងធម្មតាហើយហាងនេះមិនបានធ្វើអាជីវកម្មលក់កុមារទេ យើងអាចស្គាល់ការផ្សាយពាណិជ្ជកម្មសម្រាប់លក់សម្លៀកបំពាក់របស់ទារកនិងកុមារតូចៗដែលទើបចេះដើរតេះតះ។ ពាក្យថា *clothes* (សម្លៀកបំពាក់) មិនមាននៅក្នុងសារទេ តែអ្នកផ្សព្វផ្សាយចង់ឱ្យយើងយល់។ យើងចូលរួមយ៉ាងសកម្មក្នុងការបង្កើតការបកស្រាយនូវអ្វីដែលយើងអាននិងស្តាប់។

## ២.១. និយមន័យ

ការណ៍វិទ្យា (pragmatics) គឺជាផ្នែកមួយនៃភាសាវិទ្យា ដែលសិក្សាពីរបៀបដែលបរិបទត្រូវបានគេបញ្ចូលជាជំនួយក្នុងការវិភាគពីន័យ។ ការណ៍វិទ្យា សិក្សាពីកត្តាផ្សេងៗដែលនាំឱ្យយើងជ្រើសរើសជម្រើសណាមួយនៃភាសាក្នុងអន្តរកម្មសង្គមនិងឥទ្ធិពលនៃជម្រើសនោះទៅលើអ្នកដទៃ។

ការសិក្សាពីន័យក្នុងបរិបទមួយ ដែលត្រូវបានបង្កើតដោយអ្នកនិយាយ ឬអ្នកសរសេរ ហើយនឹងបំណកស្រាយន័យដែលត្រូវបានបង្កើតឡើងដោយអ្នកស្តាប់ ឬអ្នកអាន។

ការណ៍វិទ្យា គឺជាការសិក្សាពីទំនាក់ទំនងរវាងទម្រង់ភាសានិងបម្រើបម្រាស់របស់វា ជាពិសេសគឺមានតែការណ៍វិទ្យា ទេ ដែលអាចឱ្យយើង (មនុស្ស) ក្លាយជាការវិភាគបាន ដូចជា ការសន្មត គោលបំណង គោលដៅ និងសកម្មភាព ដែលមនុស្សមាននៅពេលនិយាយភាសា។

តាមវិធីជាច្រើន ការណ៍វិទ្យា គឺជាការសិក្សាអំពីន័យអរូបី ឬរបៀបដែលយើងស្គាល់នូវអ្វីដែលមានន័យទោះបីវាមិនត្រូវបានគេនិយាយឬសរសេរក៏ដោយ។ ដើម្បីឱ្យរឿងនោះកើតឡើង អ្នកនិយាយ (ឬអ្នកនិពន្ធ) ត្រូវតែអាចពឹងផ្អែកលើការសន្មតនិងការរំពឹងទុករួមគ្នាជាច្រើន នៅពេលពួកគេព្យាយាមទំនាក់ទំនងគ្នា។ ការអង្កេតលើការសន្មតនិងការរំពឹងទុកទាំងនោះ ផ្តល់ឱ្យយើងនូវការយល់ដឹងខ្លះៗអំពីវិធី ដែលត្រូវបានប្រាស្រ័យទាក់ទងជាងអ្វីដែលគេនិយាយ។

## ២.២. បរិបទ

នៅក្នុងការពិភាក្សារបស់យើងអំពីឧទាហរណ៍ពីរចុងក្រោយ យើងបានសង្កត់ធ្ងន់លើឥទ្ធិពលបរិបទ។ វាមានបរិបទផ្សេងៗគ្នា។ ប្រភេទមួយត្រូវបានពិពណ៌នាថាបរិបទភាសា ដែលគេស្គាល់ផងដែរថា សហបទ។ សហបទនៃពាក្យមួយ គឺជាសំណុំនៃពាក្យផ្សេងទៀតដែលប្រើក្នុងកន្សោមពាក្យ ឃ្លា ឬល្បះដូចគ្នា។ នៅជុំវិញសហបទមានឥទ្ធិពលខ្លាំងទៅលើអ្វីដែលយើងគិតថា ពាក្យប្រហែលជាមានន័យ។ ក្នុងមេរៀននេះ យើងបានកំណត់ពាក្យ *bank* ជាសទិសសព្ទមួយ ពោលគឺទម្រង់តែមួយដែលមានន័យច្រើន។ ជាទូទៅតើយើងដឹងន័យពាក្យណាមួយដែលមានបំណងនៅក្នុងល្បះជាក់លាក់ណាមួយដូចម្តេច? ជាធម្មតា យើងធ្វើដូច្នេះដោយផ្អែកលើមូលដ្ឋាននៃបរិបទភាសា។

ប្រសិនបើពាក្យ *bank* ត្រូវបានប្រើក្នុងឃ្លាមួយរួមជាមួយពាក្យដូចជា *steep* ឬ *overgrown* (ចោតឬដុះលូតលាស់ឆាប់រហ័ស) យើងមិនមានបញ្ហាក្នុងការសម្រេចថា *bank* ប្រភេទណាមួយមានន័យបែបណានោះទេ។ ប្រសិនបើយើង ស្តាប់ឮនរណាម្នាក់និយាយថានាងត្រូវតែ *get to the bank to withdraw some cash* (ទៅធនាគារដើម្បីដកប្រាក់ខ្លះ) យើងដឹងពីបរិបទភាសានេះថា *bank* ប្រភេទណាមួយមានន័យបែបណា។

ជាទូទៅ យើងដឹងពីរបៀបបកស្រាយពាក្យផ្សេងៗផ្អែកលើមូលដ្ឋាននៃបរិបទជាក់ស្តែង។ ប្រសិនបើយើងឃើញពាក្យ *BANK* នៅលើជញ្ជាំងអគារមួយនៅក្នុងទីក្រុង និងទីតាំងជាក់ស្តែងវានឹងមានឥទ្ធិពលលើការបកស្រាយរបស់យើង។ ខណៈពេលដែលវាមើលទៅដូចជាច្បាស់ជាង យើងគួរតែចងចាំថា វាមិនមែនជាស្ថានភាពជាក់ស្តែងពិតប្រាកដក្រៅទីនោះទេ ដែលបង្កើតជាបរិបទសម្រាប់ការបកស្រាយពាក្យឬឃ្លា។ បរិបទដែលពាក់ព័ន្ធគ្នា គឺជាការបង្ហាញនូវគំនិតរបស់យើង ចំពោះទិដ្ឋភាពទាំងនោះ ដែលមានភាពពិតប្រាកដនៅខាងក្រៅ ដែលយើងប្រើក្នុងការបកស្រាយ។

**ដេកស៊ីស (Deixis)**[3]

វាមានពាក្យធម្មតាមួយចំនួននៅក្នុងភាសារបស់យើង ដែលយើងមិនអាចបកស្រាយបានទាំងអស់នោះទេ ប្រសិនបើយើងមិនដឹងបរិបទ ជាពិសេសបរិបទជាក់ស្តែងរបស់អ្នកនិយាយ។ ទាំងនេះគឺដូចជាពាក្យ *here* (ទីនេះ) និង *there* (ទីនោះ) *, this* (នេះ) និង *that* (នោះ)*, now* (ឥឡូវ) និង *then* (បន្ទាប់មក)*, yesterday* (ម្សិលមិញ)*, today* (ថ្ងៃនេះ) និង *tomorrow* (ថ្ងៃស្អែក) ក៏មានសព្វនាមមួយចំនួនទៀតផងដែរដូចជា *you, me, she, him, it, them* ។ ឃ្លាខ្លះនៃភាសាអង់គ្លេសស្ទើរតែមិនអាចយល់បាន ប្រសិនបើយើងមិនដឹងថា នរណាកំពុងនិយាយអំពីនរណា កន្លែងណា និងពេលណា។ ឧទាហរណ៍ *You'll have to bring it back tomorrow because she isn't here today* (អ្នកត្រូវយកវាមកវិញនៅថ្ងៃស្អែកពីព្រោះនាងមិននៅថ្ងៃនេះទេ)។

ក្រៅបរិបទ ឃ្លានេះពិតជាមិនច្បាស់ទេ។ វាមានសំនួនពាក្យមួយចំនួនធំ (*you* (អ្នក), *it* (វា), *tomorrow* (ថ្ងៃស្អែក), *she* (នាង), *here* (នៅទីនេះ), *today* (ថ្ងៃនេះ)) ដែលពឹងផ្អែកលើចំណេះដឹងអំពីបរិបទជាក់ស្តែងសម្រាប់ការបកស្រាយរបស់ពួកគេភ្លាមៗ (ឃ្លានេះចង់មានន័យថា អ្នកដឹកជញ្ជូន នឹងត្រូវត្រឡប់មកវិញនៅថ្ងៃទី ១៥ ខែកុម្ភៈ ដល់ ៦៦០ College Drive ជាមួយប្រអប់វែងដែលមានស្លាកសម្គាល់ថា «flowers, handle with care ដោះស្រាយដោយយកចិត្តទុកដាក់» ផ្ញើទៅអាសយដ្ឋាន Lisa Landry)។ សំនួនពាក្យដូចជា *tomorrow* (ថ្ងៃស្អែក) និង *here* (នៅទីនេះ) គឺជាឧទាហរណ៍ជាក់ស្តែងនៃចុណ្ណភាគនៃភាសាដែលយើងអាចយល់ន័យបានតែនៅក្នុងវាក្យសព្ទរបស់អ្នកនិយាយ ដែលមានបំណងចង់សំដៅទៅលើន័យអ្វីមួយ។ វាត្រូវបានគេស្គាល់តាមបច្ចេកសព្ទថា សំនួនពាក្យដេកទិក (deictic expressions) ដែលមកពីពាក្យក្រិក ដេកស៊ីស (deixis) ដែលមានន័យថា «ការចង្អុលបង្ហាញ» តាមរយៈភាសា។

យើងប្រើដេកស៊ីស (deixis) ដើម្បីចង្អុលបង្ហាញវត្ថុផ្សេងៗ (*it, this, these boxes*) និងមនុស្ស (*him, them, those idiots*) ជួនកាលគេហៅថាវាទករ (person deixis)។ ពាក្យនិងកន្សោមពាក្យដែលត្រូវបានប្រើដើម្បីចង្អុលបង្ហាញទីតាំងមួយ (*here, there, near that*) គឺជាឧទាហរណ៍នៃវាទឋាន (spatial deixis) ហើយពាក្យដែលប្រើដើម្បីចង្អុលបង្ហាញពេលវេលា (*now, then, last week*) គឺជាឧទាហរណ៍នៃវាទកាល (temporal deixis)។

---

[3] ដេកស៊ីស (Deixis) គឺជាការប្រើពាក្យឬកន្សោមពាក្យទូទៅដើម្បីបញ្ជាក់ពីពេលវេលាជាក់លាក់ ទីកន្លែង ឬមនុស្សនៅក្នុងបរិបទ ឧទាហរណ៍ ពាក្យ *tomorrow (ថ្ងៃស្អែក) there (ទីនោះ) they (ពួកគេ) ...*។

រាល់ការបង្ហាញពីសំនួនពាក្យដែលប្រើសម្រាប់ចង្អុលបង្ហាញទាំងអស់ខាងលើ ត្រូវបកស្រាយក្នុងវាក្យសព្ទដែលពាក់ព័ន្ធនឹងមនុស្ស ទីកន្លែង និងពេលវេលា ដែលអ្នកនិយាយមាននៅក្នុងគំនិត។ យើងធ្វើឱ្យមានភាពខុសគ្នារវាងអ្វីដែលត្រូវបានសម្គាល់ថានៅជិតអ្នកនិយាយ (*this, here, now*) និងអ្វីដែលនៅឆ្ងាយ (*that, there, then*)។ យើងអាចចង្អុលបង្ហាញពីបន្លាស់ប្តូរទីតាំងរបស់អ្នកនិយាយ (វាទករ) (*go*) ឬក៏ទីតាំងរបស់អ្នកនិយាយ (វាទករ) (*come*) ផងដែរ។ ប្រសិនបើអ្នកកំពុងរកអ្នកណាម្នាក់ហើយនាងលេចមុខមករកអ្នក អ្នកអាចនិយាយថា *Here she comes!* (នាងមកទីនេះ!)។ ទោះយ៉ាងណាបើនាងកំពុងឃ្លាតឆ្ងាយពីអ្នកនៅចម្ងាយមួយ អ្នកទំនងជានឹងនិយាយថា *There she goes!* (នាងទៅទីនោះ!)។ ឥទ្ធិពលនៃការចង្អុលបង្ហាញដដែល ពន្យល់ពីស្ថានភាពផ្សេងៗគ្នាដែលអ្នកនឹងប្រាប់នរណាម្នាក់ដើម្បីឱ្យ *Go to bed* (ចូលគេង) ធៀបនឹង *Come to bed* (មកគេង)។

មនុស្សពិតជាអាចប្រើការចង្អុលបង្ហាញ (deixis) ដើម្បីឱ្យមានភាពសប្បាយរីករាយខ្លះ។ ម្ចាស់ហាងដែលដាក់សញ្ញាធំមួយដែលអាន *Free Beer Tomorrow* (ស្រាបៀរឥតគិតថ្លៃនៅថ្ងៃស្អែក) ដើម្បីឱ្យអ្នកត្រលប់ទៅវង្គសាល តែងតែអាចអះអាងថាអ្នកមានពេលតែមួយថ្ងៃគត់ដើម្បីទទួលបានភេសជ្ជៈឥតគិតថ្លៃ។

## ២.៣. យោបោង

នៅក្នុងការពិភាក្សាអំពីដេកស៊ីស (deixis) យើងបានសន្មតថា ការប្រើប្រាស់ពាក្យដើម្បីសំដៅទៅលើមនុស្ស ទីកន្លែង និងពេលវេលា គឺមានបញ្ហាច្រើន។ ទោះយ៉ាងណាក៏ដោយ ពាក្យខ្លួនឯងមិនសំដៅទៅលើអ្វីទាំងអស់។ មនុស្សនិយាយយោងដល់អ្វីមួយ។ យើងត្រូវកំណត់យោបោង (reference) ឱ្យច្បាស់លាស់ ចំពោះសកម្មភាពដែលអ្នកនិយាយ (ឬអ្នកសរសេរ) ប្រើភាសាដើម្បីឱ្យអ្នកស្តាប់ (ឬអ្នកអាន) ស្គាល់អ្វីមួយ។ ដើម្បីអនុវត្តសកម្មភាពនៃយោបោង យើងអាចប្រើនាមអសាធារណ៍ដូចជា *Chomsky (ឆមស្គី), Jennifer (ជេនីហ្វឺ), Whiskas (វីស្កាស)* នាមផ្សេងទៀតនៅក្នុងកន្សោមពាក្យដូចជា *a writer (អ្នកនិពន្ធម្នាក់), my friend (មិត្តខ្ញុំ), the cat (ឆ្មាមួយក្បាល)* ឬសព្វនាម (*he គាត់, she នាង, it វា*)។ ពេលខ្លះយើងសន្មតថាពាក្យទាំងនេះគឺជាពាក្យដែលកំណត់ន័យឱ្យនរណាម្នាក់ឬវត្ថុអ្វីមួយ ប៉ុន្តែវាគឺត្រឹមត្រូវដើម្បីនិយាយថាពាក្យឬកន្សោមពាក្យនីមួយៗ វាមានលំដាប់យោបោងមួយ។ ពាក្យ *Jennifer* (ជេនីហ្វឺ) ឬ *friend* (មិត្តភក្តិ) ឬ *she* (នាង) អាចត្រូវបានប្រើដើម្បីសំដៅទៅលើវត្ថុឬសកម្មភាពផ្សេងៗនៅលើពិភពលោក។ ដូចដែលយើងបានសង្កេតពីមុនរួចមកហើយ សំនួនពាក្យដូចជា *the war* (សង្គ្រាម) មិនកំណត់ន័យអ្វីឱ្យច្បាស់លាស់ដោយខ្លួនវាផ្ទាល់ទេ ពីព្រោះយោបោងរបស់វាអាស្រ័យលើអ្នកណាដែលកំពុងប្រើវា។

### ក. វត្ថុយោង

យើងក៏អាចយោងទៅលើអ្វីៗ នៅពេលដែលយើងមិនប្រាកដថាត្រូវហៅវត្ថុទាំងនោះបែបណា។ យើងអាចប្រើកន្សោមពាក្យដូចជា *the blue thing* (វត្ថុពណ៌ខៀវ) និង*that icky stuff* (វត្ថុដែលមិនស្អាត) ហើយយើងថែមទាំងអាចបង្កើតឈ្មោះរបស់វាផងដែរ។ ឧទាហរណ៍ វាមានបុរសម្នាក់ដែលតែងតែបើកម៉ូតូលឿននិងឮខ្លាំងៗនៅក្បែរសង្កាត់ខ្ញុំ ហើយត្រូវបានគេហៅថា *Mr. Kawasaki* (លោក កាវ៉ាសាគី)។ ក្នុងករណីនេះ ឈ្មោះយីហោម៉ូតូកំពុងត្រូវបានប្រើដើម្បីសំដៅទៅលើមនុស្សម្នាក់។

ដូចនៅក្នុងឧទាហរណ៍ខាងលើដែលលើកឡើងពី *Mr. Kawasaki* (លោក កាវ៉ាសាគី) ជាសកម្មភាពជោគជ័យនៃយោបោងដែលពឹងផ្អែកច្រើនទៅលើសមត្ថភាពរបស់អ្នកស្តាប់ ដើម្បីទទួលស្គាល់នូវអ្វីដែលយើងចង់និយាយជាងចំណេះដឹងនៃវចនានុក្រមរបស់អ្នកស្តាប់អំពីពាក្យដែលយើងប្រើ។ ឧទាហរណ៍នៅក្នុងភោជនីយដ្ឋានមួយ អ្នករត់តុម្នាក់អាចសួរម្នាក់ទៀតថា *Where's the spinach salad sitting?* (តើសាឡាដ spinach អង្គុយនៅឯណា?) ហើយទទួលបានការឆ្លើយតបថា *He's sitting by the door.* (គាត់កំពុងអង្គុយនៅមាត់ទ្វារ)។ ប្រសិនបើអ្នកកំពុងសិក្សាភាសាវិទ្យា អ្នកអាចនឹងសួរនរណាម្នាក់ថា *Can I look at your Chomsky?* (តើខ្ញុំអាច

មើល ឆមស្គីរបស់អ្នកបានទេ?) ហើយទទួលបានការឆ្លើយតបថា *Sure, it's on the shelf over there.* (ប្រាកដណាស់ វាស្ថិតនៅលើធ្នើនៅទីនោះ)។ ឧទាហរណ៍ទាំងនេះបញ្ជាក់ច្បាស់ថាយើងអាចប្រើឈ្មោះដែលទាក់ទងនឹងវត្ថុផ្សេងៗដូចជាសាឡាដ (*salad*) ដើម្បីយោងទៅលើមនុស្សនិងប្រើឈ្មោះមនុស្សដូចជា ឆមស្គី (*Chomsky*) ដើម្បីយោងទៅលើវត្ថុផ្សេងៗ។ ដំណើរការសំខាន់នៅទីនេះ ត្រូវបានគេហៅថាសេចក្តីសន្និដ្ឋាន (inference)។ សេចក្តីសន្និដ្ឋាន គឺជាព័ត៌មានបន្ថែមដែលត្រូវបានប្រើដោយអ្នកស្តាប់ដើម្បីបង្កើតទំនាក់ទំនងរវាងអ្វីដែលត្រូវបានគេនិយាយនិងអ្វីដែលត្រូវតែមានន័យ។ ក្នុងឧទាហរណ៍ចុងក្រោយ អ្នកស្តាប់ត្រូវប្រតិបត្តិដោយប្រើវិចារណញាណ «ប្រសិនបើ X ជាឈ្មោះរបស់អ្នកនិពន្ធសៀវភៅមួយក្បាល នោះ X អាចត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណរបស់សៀវភៅច្បាប់ចម្លងដោយអ្នកនិពន្ធនោះ»។ ប្រភេទនៃការបង្ហាញស្រដៀងគ្នានេះ គឺចាំបាច់ដើម្បីយល់ពីនរណាម្នាក់ដែលនិយាយថា *Picasso is in the museum* (ពីកាស្សូ នៅក្នុងសារមន្ទីរ) ឬ *We saw Shakespeare in London* (យើងបានឃើញ សេកស្ពៀរ៍ ក្នុងទីក្រុងឡុងដ៍) ឬ *Jennifer is wearing Calvin Klein* (ជេននីហ្វឺ កំពុងពាក់ កាល់វីន ក្លេន)។

**ខ. អាណាហ្វ៉ូរ៉ា**

ជាធម្មតាយើងបង្កើតភាពខុសគ្នារវាងការបង្ហាញយោបោងថ្មី ដូចជា *a puppy* (កូនឆ្កែ) ហើយនិងការយោងត្រលប់ទៅពួកវាវិញ ឧទាហរណ៍ដូចជា *the puppy, it* (កូនឆ្កែ ដោយប្រើសព្វនាមបុរិសៈ «វា»)។

*We saw a funny home video about a boy washing **a puppy** in a small bath.*

«យើងបានឃើញវីដេអូផ្ទះកំប្លែងមួយអំពីកុមារម្នាក់ កំពុងលាងកូនឆ្កែក្នុងអាងងូតទឹកតូចមួយ»។

***The puppy** started struggling and shaking and the boy got really wet.*

«កូនឆ្កែបានចាប់ផ្តើមរើបម្រះនិងភ័យញ័រហើយកុមារាបានទទឹកខ្លួនជោគ»។

*When he let go, **it** jumped out of the bath and ran away.*

«នៅពេលដែលគាត់បានលែងវាទៅ វាបានលោតចេញពីបន្ទប់ទឹកហើយបានរត់ទៅឆ្ងាយ»។

នៅក្នុងទំនាក់ទំនងយោងប្រភេទនេះ សំនួនពាក្យយោងទីពីរ (ឬបន្តបន្ទាប់) គឺជាឧទាហរណ៍នៃអាណាហ្វ៉ូរ៉ា (anaphora) ឬការយោងថយក្រោយ។ ការលើកឡើងដំបូង គេហៅថា ពាក្យយោងខាងដើម (antecedent)។ ដូច្នេះនៅក្នុងឧទាហរណ៍របស់យើង *a boy* (កុមារម្នាក់) *a puppy* (កូនឆ្កែ) និង *a small bath* (បន្ទប់ងូតទឹកតូចមួយ) គឺជាពាក្យយោងខាងដើម (antecedent) និង *The puppy* (កូនឆ្កែ) *The boy* (កុមារា) *he* (គាត់) *it* (វា) និង *The bath* (បន្ទប់ងូតទឹក) គឺជាសំនួនពាក្យអាណាហ្វ៉ូរ៉ា (anaphoric expressions)។

អាណាហ្វ៉ូរ៉ា (Anaphora) អាចត្រូវបានចាត់ទុកថាជា យោបោងបន្តបន្ទាប់ទៅអង្គតា (entity)ឬអ្វីៗ ដែលបានបង្ហាញរួចហើយ។ យើងប្រើអាណាហ្វ៉ូរ៉ាភាគច្រើនក្នុងអត្ថបទ ដើម្បីជួយគាំទ្រយោបោង។ ការផ្សារភ្ជាប់គ្នារវាងពាក្យយោងខាងដើមនិងសំនួនពាក្យអាណាហ្វ៉ូរ៉ា ត្រូវបានបង្កើតដោយការប្រើសព្វនាមបុរិសៈ *it* (វា) ឬកន្សោមពាក្យជាមួយ *the* ផ្សំនឹងនាម ដូចជា *the puppy* (កូនឆ្កែ) ឬនាមមួយទៀតដែលទាក់ទងនឹងពាក្យយោងខាងដើម ដូចជា ***The little dog** ran out of the room* (កូនឆ្កែតូចមួយនោះបានរត់ចេញពីបន្ទប់)។ ការផ្សារភ្ជាប់គ្នារវាងពាក្យយោងខាងដើមនិងសំនួនពាក្យអាណាហ្វ៉ូរ៉ាច្រើនតែពឹងផ្អែកលើសេចក្តីសន្និដ្ឋាន ដូចនៅក្នុងឧទាហរណ៍ខាងក្រោមនេះ៖

*We found **a house** to rent, but **the kitchen** was very small.*

«យើងបានរកឃើញផ្ទះជួលហើយ ប៉ុន្តែផ្ទះបាយតូចណាស់»។

*I caught **a bus** and asked **the driver** if it went near the downtown area.*

«ខ្ញុំបានជួបប្រទះឡានក្រុង ហើយបានសួរអ្នកបើកបរថា ប្រសិនបើវាទៅជិតតំបន់ទីប្រជុំជន»។

នៅក្នុងឧទាហរណ៍ទីមួយ យើងត្រូវតែបង្កើតសេចក្តីសន្និដ្ឋានមួយដូចជា ប្រសិនបើ X ជា *a house* (ផ្ទះមួយ) បន្ទាប់មក X មាន *a kitchen* (ផ្ទះបាយមួយ) ដើម្បីបកស្រាយពីការភ្ជាប់ទំនាក់ទំនងរវាងពាក្យយោងខាងដើម *a house* (ផ្ទះមួយ) និងសំនួនពាក្យអាណាហ្វ៉ារ៉ា *the kitchen* (ផ្ទះបាយមួយ)។ ក្នុងឧទាហរណ៍ទីពីរ យើងត្រូវបង្កើតសេចក្តីសន្និដ្ឋានមួយដូចជា ប្រសិនបើ X ជា *a bus* (ឡានក្រុងមួយ) នោះ X មាន *a driver* (អ្នកបើកបរម្នាក់) ដើម្បីភ្ជាប់ទំនាក់ទំនងរវាង *a bus* (ឡានក្រុងមួយ) និង *the driver* (អ្នកបើកបរម្នាក់នោះ)។

យើងបានប្រើពាក្យសេចក្តីសន្និដ្ឋាននៅទីនេះ ដើម្បីពិពណ៌នាអំពីអ្វីដែលអ្នកស្តាប់ (ឬអ្នកអាន) ធ្វើ។ នៅពេលយើងនិយាយអំពីការសន្មតមួយដែលបង្កើតឡើងដោយអ្នកនិយាយ (ឬអ្នកសរសេរ) យើងច្រើនតែនិយាយអំពីបុរេសន្មត (presupposition)។

**គ. បុរេសន្មត**

នៅពេលយើងប្រើសំនួនពាក្យយោងដូចជា *this* (នេះ) *he* (គាត់) ឬ*Shakespeare* (សេកស្ពៀរ៍)ជាធម្មតាយើងសន្មតថា អ្នកស្តាប់របស់យើងអាចស្គាល់យោបោងណាមួយ ដែលត្រូវបានបម្រុងទុក។ នៅក្នុងរបៀបផ្សេងៗទៀត យើងរៀបចំសារជាភាសារបស់យើង ដោយផ្អែកលើមូលដ្ឋាននៃការសន្មតទ្រង់ទ្រាយធំអំពីអ្វីដែលអ្នកស្តាប់របស់យើងបានដឹង។ ពិតណាស់ការសន្មតខ្លះអាចត្រូវបានគេយល់ច្រឡំ ប៉ុន្តែភាគច្រើនវាសមស្រប។ អ្វីដែលអ្នកនិយាយ (ឬអ្នកសរសេរ) សន្មតថាជាការពិតឬត្រូវបានស្គាល់ដោយអ្នកស្តាប់ (ឬអ្នកអាន) អាចត្រូវបានពិពណ៌នាថា បុរេសន្មត (presupposition)។

ប្រសិនបើមាននរណាម្នាក់ប្រាប់អ្នកថា *Your brother is waiting outside* (បងប្រុសរបស់អ្នកកំពុងរង់ចាំនៅខាងក្រៅ) វាមានបុរេសន្មតជាក់ស្តែងដែលអ្នកមានបងប្រុសម្នាក់។ ប្រសិនបើអ្នកត្រូវបានគេសួរថា*Why did you arrive late?* (ហេតុអ្វីបានជាអ្នកមកយឺត?) វាមានបុរេសន្មតដែលអ្នកបានមកដល់យឺត។ ហើយប្រសិនបើអ្នកត្រូវបានគេសួរសំណួរថា *When did you stop smoking?* (តើអ្នកឈប់ជក់បារីនៅពេលណា?) យ៉ាងហោចណាស់ វាមានបុរេសន្មតពីរដែលពាក់ព័ន្ធគ្នា។ ក្នុងការសួរសំណួរនេះ អ្នកនិយាយសន្មតថា អ្នកធ្លាប់ជក់បារី ហើយអ្នកលែងជក់បារីទៀតហើយ។ សំណួរបែបនេះដែលជាសំណួរបង្កើតនូវបុរេសន្មត ហើយវាជាឧបករណ៍ដែលមានអត្ថប្រយោជន៍ណាស់សម្រាប់អ្នកសួរចម្លើយឬមេធាវីជំនុំជម្រះក្តី។ ប្រសិនបើជនជាប់ចោទត្រូវបានសួរដោយព្រះរាជអាជ្ញា *Okay, Mr. Buckingham, how fast were you going when you ran the red light?* (យល់ព្រម លោក បាកឃីងហាំ តើអ្នកបានទៅលឿនប៉ុណ្ណានៅពេលដែលអ្នកបានរត់ទៅបើកភ្លើងក្រហម?) វាមានបុរេសន្មតមួយដែលលោក បាកឃីងហាំ(Mr. Buckingham) ពិតជាបានរត់ទៅបើកភ្លើងក្រហម។ ប្រសិនបើគាត់ឆ្លើយយ៉ាងសាមញ្ញថា *the how fast* (លឿនយ៉ាងម៉េច) ដែលជាផ្នែកមួយនៃសំណួរដោយផ្តល់ល្បឿនមួយ ហើយគាត់កំពុងប្រព្រឹត្តដូច្នេះមែន ប្រហែលជាបុរេសន្មតនោះគឺត្រឹមត្រូវ។

ការពិសោធសាកល្បងមួយ ត្រូវបានគេប្រើដើម្បីពិនិត្យមើលឈ្លេះដែលស្ថិតនៅក្រោមបុរេសន្មត ជាប់ពាក់ព័ន្ធនឹងឈ្លេះបដិសេធមួយដែលមានបុរេសន្មតពិសេសហើយត្រួតពិនិត្យមើល ប្រសិនបើបុរេសន្មតនៅតែពិត។ នៅពេលដែលអ្នកនិយាយថា *My car is a wreck* (ឡានរបស់ខ្ញុំខូចខ្ទេចខ្ទីអស់) ឬក៏កែប្រែជាឈ្លេះបដិសេធបែបនេះវិញ *My car is not a wreck* (ឡានរបស់ខ្ញុំមិនខូចខ្ទេចខ្ទីទេ) បុរេសន្មតមូលដ្ឋាន (*I have a car* (ខ្ញុំមានឡាន)) នៅតែពិត ទោះបីជាឈ្លេះទាំងពីរមានន័យផ្ទុយគ្នាក៏ដោយ។ នេះត្រូវបានគេហៅថា ការពិសោធសាកល្បងដែលមិនប្រែប្រួលដោយប្រើឈ្លេះបដិសេធ សម្រាប់កំណត់អត្តសញ្ញាណបុរេសន្មត ។ ប្រសិនបើមាននរណាម្នាក់និយាយថា *I used to regret marrying him, but I don't regret marrying him now* (ខ្ញុំធ្លាប់សោកស្តាយរៀបការជាមួយគាត់ ប៉ុន្តែខ្ញុំមិនសោកស្តាយរៀបការជាមួយគាត់ទេឥឡូវនេះ) បុរេសន្មត (*I married him* (ខ្ញុំបាន

រៀបការជាមួយគាត់)) នៅតែថេរ ទោះបីជាកិរិយាសព្ទ *regret* (សោកស្ដាយ) មានការផ្លាស់ប្ដូរពីទម្រង់ស្របទៅទម្រង់បដិសេធន៍ក៏ដោយ។

**២.៤. ទង្វើសម្ដី**

យើងបានពិចារណាលើវិធី ដែលយើងបកស្រាយន័យនៃពាក្យសម្ដី ទាក់ទងនឹងអ្វីដែលអ្នកនិយាយចង់និយាយប្រាប់។ យើងមិនទាន់បានពិចារណាអំពីការពិតដែលថា ជាធម្មតាយើងដឹងពីរបៀបដែលអ្នកនិយាយមានបំណងឱ្យយើងចាប់យកឬបកស្រាយមុខងាររបស់អ្វីមួយដែលត្រូវបានគេនិយាយ។ នៅក្នុងវាក្យសព្ទទូទៅ យើងអាចស្គាល់ប្រភេទនៃសកម្មភាព ដែលបានសម្ដែងចេញដោយអ្នកនិយាយតាមពាក្យសម្ដី។ យើងប្រើវាក្យសព្ទនេះថា ទង្វើសម្ដី (speech act) ដើម្បីពិពណ៌នាសកម្មភាពដូចជា ការស្នើសុំ (requesting) ការបញ្ជា (commanding) ការសួរ (questioning) ឬការផ្ដល់ព័ត៌មាន (informing)។ យើងអាចបង្ហាញទង្វើសម្ដីដូចជាការសម្ដែងចេញសកម្មភាពមួយដោយអ្នកនិយាយតាមរយៈពាក្យសម្ដីរបស់ពួកគេផ្ទាល់។ ប្រសិនបើអ្នកនិយាយថា *I'll be there at six* (ខ្ញុំនឹងនៅទីនោះ នៅម៉ោងប្រាំមួយ) អ្នកមិនត្រឹមតែនិយាយទេ អ្នកហាក់ដូចជាកំពុងសម្ដែងទង្វើសម្ដីនៃការសន្យា។

**ទង្វើសម្ដីផ្ទាល់និងមិនផ្ទាល់** (Direct and indirect speech acts)

ជាធម្មតា យើងប្រើរចនាសម្ព័ន្ធនៃវាក្យសម្ព័ន្ធជាក់លាក់ជាមួយមុខងារ ដែលបានធ្វើជាតារាងបញ្ជាក់ពីមុខងាររបស់ពួកវានៅខាងក្រោម។

| | រចនាសម្ព័ន្ធ | មុខងារ |
|---|---|---|
| *Did you eat the pizza?* | Interrogative | Question |
| តើអ្នកបានញ៉ាំភីហ្សាទេ? | ល្បះសំណួរ | សំណួរ |
| *Eat the pizza (please)!* | Imperative | Command (Request) |
| សូមពិសាភីហ្សា! | ល្បះបញ្ជា | បញ្ជា (ស្នើសុំ) |
| *You ate the pizza.* | Declarative | Statement |
| អ្នកបានពិសាភីហ្សា។ | ល្បះបញ្ជាក់ | បញ្ជាក់ |

នៅពេលដែលរចនាសម្ព័ន្ធសំណួរដូចជា *Did you...?* (តើអ្នក...?) *Are they...?* (តើពួកគេ...?) ឬ *Can we...?* (តើយើងអាច ...?) ត្រូវបានប្រើជាមួយមុខងារនៃសំណួរ វាត្រូវបានពិពណ៌នាថាទង្វើសម្ដីផ្ទាល់។ ឧទាហរណ៍នៅពេលដែលយើងមិនដឹងអ្វីមួយហើយយើងស្នើសុំឱ្យនរណាម្នាក់ផ្ដល់ព័ត៌មាន ជាធម្មតា យើងបង្កើតទង្វើសម្ដីផ្ទាល់ដូចជា *Can you ride a bicycle?* (តើអ្នកអាចជិះកង់បានទេ?)។

ចូរប្រៀបធៀបពាក្យសម្ដីនោះជាមួយ *Can you pass the salt?* (តើអ្នកអាចហុចអំបិលបានទេ?)។ ក្នុងឧទាហរណ៍ទី២នេះ យើងមិនសួរសំណួរអំពីសមត្ថភាពរបស់នរណាម្នាក់ទេ។ តាមពិត ជាធម្មតាយើងមិនប្រើរចនាសម្ព័ន្ធនេះជាសំណួរទាំងអស់នោះទេ។ ជាធម្មតាយើងប្រើវាដើម្បីធ្វើការស្នើសុំ។ នោះគឺថាយើងកំពុងប្រើរចនាសម្ពន្ធ័វាក្យសម្ព័ន្ធដែលទាក់ទងនឹងមុខងារនៃសំណួរ ប៉ុន្តែក្នុងករណីនេះ វាគឺជាមុខងារនៃការស្នើសុំ។ នេះគឺជាឧទាហរណ៍នៃទង្វើសម្ដីមិនផ្ទាល់។ នៅពេលណាដែលរចនាសម្ព័ន្ធមួយក្នុងសំណុំល្បះខាងលើ ត្រូវបានប្រើដើម្បីអនុវត្តមុខងារមួយ ក្រៅពីមុខងារដែលបានធ្វើតារាងបញ្ជាក់ពីមុខងាររបស់វានៅលើបន្ទាត់តែមួយ លទ្ធផលគឺជាទង្វើសម្ដីមិនផ្ទាល់។

ពាក្យសម្ដីដូចជា *You left the door open* (អ្នកទុកទ្វារចំហរ) មានរចនាសម្ព័ន្ធបញ្ជាក់ហើយជាទង្វើសម្ដីផ្ទាល់ វាត្រូវបានគេប្រើដើម្បីធ្វើការបញ្ជាក់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើអ្នកនិយាយរឿងនេះទៅកាន់នរណាម្នាក់ដែលទើបតែចូលមក (ហើយវាពិតជាត្រជាក់នៅខាងក្រៅ) អ្នកប្រហែលជាចង់ឱ្យមនុស្សនោះបិទទ្វារ។

អ្នកមិនប្រើរចនាសម្ព័ន្ធបញ្ជាទេ។ អ្នកកំពុងប្រើរចនាសម្ព័ន្ធបញ្ជាក់ដើម្បីធ្វើការស្នើសុំ។ វាជាឧទាហរណ៍មួយទៀតនៃទង្វើសម្តីមិនផ្ទាល់។

វាអាចមានឥទ្ធិពលចម្លែក ប្រសិនបើមនុស្សម្នាក់ខកខានមិនបានស្គាល់ពីទង្វើសម្តីមិនផ្ទាល់របស់មនុស្សម្នាក់ទៀត។ សូមពិចារណាឈុតខាងក្រោម។ ទេសចរម្នាក់ទៅទីក្រុងមួយ គាត់កាន់អីវ៉ាន់របស់គាត់ ហើយគាត់សម្លឹងមើលទៅអ្នកដំណើរម្នាក់ បន្ទាប់មកគាត់សួរអ្នកដំណើរនោះ។

Visitor: *Excuse me. Do you know where the Ambassador Hotel is?*

ទេសចរ: សូមទោស។ តើអ្នកដឹងទេថា សណ្ឋាគារឯកអគ្គរដ្ឋទូតនៅទីណា?

Passer-by: *Oh sure, I know where it is.* (and walks away)

អ្នកដំណើរ: អូ ពិតណាស់ ខ្ញុំដឹងថាវានៅទីណា។ (ហើយដើរចេញ)

នៅក្នុងឈុតនេះ ទេសចរប្រើទម្រង់មួយដែលទាក់ទងនឹងសំណួរ *Do you know...?* (តើអ្នកដឹងទេ?) ហើយអ្នកដំណើរឆ្លើយសំណួរដោយន័យត្រង់ថា *I know...* (ខ្ញុំដឹង...)។ នោះគឺថាអ្នកដំណើរ កំពុងដើរតួដូចជាអ្នកនិយាយដោយប្រើទង្វើសម្តីផ្ទាល់ជំនួសឱ្យទង្វើសម្តីមិនផ្ទាល់ ដែលត្រូវបានប្រើសម្រាប់ការស្នើសុំដើម្បីសួររកទិសដៅ។

មូលហេតុចម្បងដែលយើងប្រើទង្វើសម្តីផ្ទាល់ ហាក់ដូចជាសកម្មភាពផ្សេងៗទាំងនោះ ជាការស្នើសុំ ហើយនិងការបង្ហាញរបៀបប្រយោលដូចជា *Could you open that door for me?* (សូមបើកទ្វារនោះឱ្យខ្ញុំផងបានទេ?) ជាទូទៅ វាត្រូវបានគេចាត់ទុកថា វាមានភាពគួរសមនៅក្នុងសង្គមរបស់យើង ជាងទង្វើសម្តីផ្ទាល់ ដូចជា *Open that door for me!* (បើកទ្វារនោះឱ្យខ្ញុំ!)។ មូលហេតុពិតប្រាកដដែល ពួកគេបានចាត់ទុកថា ភាពគួរសមជាច្រើន ត្រូវផ្អែកលើការសន្មតរួមគ្នារបស់សង្គមមួយ។

## ២.៥. ភាពគួរសម

យើងអាចគិតអំពីភាពគួរសមក្នុងវាក្យសព្ទទូទៅដូចជាការធ្វើអ្វីមួយ ដោយគំនិតផ្សេងៗ ដែលបង្ហាញនូវភាពប៉ិនប្រសប់ ភាពរម្យទម និងសមានចិត្តក្នុងការទាក់ទងជាមួយមនុស្សឯទៀត។ នៅក្នុងការសិក្សាអំពីសម្តីដែលមានលក្ខណៈថ្លៃថ្នូរឬភាពគួរសម ដែលពាក់ព័ន្ធច្រើនបំផុតគឺមុខ (face)។ មុខរបស់អ្នក នៅក្នុងការណ៍វិទ្យា គឺជារូបភាពសាធារណៈរបស់ខ្លួនអ្នក។ នេះគឺជាអារម្មណ៍ផ្លូវចិត្តនិងសង្គមនៃខ្លួនឯងផ្ទាល់ ដែលមនុស្សគ្រប់គ្នាមាន ហើយរំពឹងថាមនុស្សគ្រប់គ្នានឹងស្គាល់អ្នក។ ភាពគួរសមអាចត្រូវបានគេចាត់ទុកថា ជាការបង្ហាញការយល់ដឹងនិងការយកចិត្តទុកដាក់នៃមុខរបស់មនុស្សម្នាក់ទៀត។

ប្រសិនបើអ្នកនិយាយអ្វីមួយ ដែលតំណាងឱ្យការគំរាមកំហែងដល់រូបភាពផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ទៀត ដែលត្រូវបានគេហៅថា ជាទង្វើគំរាមកំហែងដោយប្រើមុខ។ ឧទាហរណ៍ប្រសិនបើអ្នកប្រើទង្វើសម្តីផ្ទាល់ដើម្បីឱ្យនរណាម្នាក់ធ្វើអ្វីមួយ ដូចជា *Give me that paper!* (ឱ្យក្រដាសនោះមកអញ!) អ្នកកំពុងប្រកាន់អាកប្បកិរិយាដូចជាអ្នកមានអំណាចសង្គមច្រើនជាងមនុស្សផ្សេងៗទៀត។ ប្រសិនបើអ្នកពិតជាមិនមានអំណាចខាងសង្គមនោះទេ (ឧទាហរណ៍ អ្នកមិនមែនជាមន្ត្រីយោធាឬ អ្នកយាមគុកនោះទេ) ពេលនោះអ្នកកំពុងអនុវត្តទង្វើគំរាមកំហែងដោយប្រើមុខ។ ទង្វើសម្តីមិនផ្ទាល់មួយ នៅក្នុងទម្រង់ដែលទាក់ទងនឹងសំណួរដូចជា *Could you pass me that paper?* (តើអ្នកអាចប្រគល់ក្រដាសនោះមកខ្ញុំបានទេ?) ដែលបង្ហាញពីការយកចេញចំពោះការសន្មតនៃអំណាចសង្គម។ អ្នកគ្រាន់តែសួរប៉ុណ្ណោះ ប្រសិនបើវាអាចទៅរួច។ នេះធ្វើឱ្យសំណើរបស់អ្នក មិនសូវគំរាមកំហែងដល់មុខរបស់អ្នក ដទៃ។ នៅពេលអ្នកនិយាយអ្វីមួយ ដែលអាចបន្ថយការគំរាមកំហែងចំពោះមុខរបស់អ្នកដទៃ វាអាចត្រូវបានពិពណ៌នាថា ទង្វើទុកមុខ (face-saving act)។

## ៣. ភាពខុសគ្នារវាងន័យវិទ្យានិងការណ៍វិទ្យា

**ក. ន័យវិទ្យា**

-សិក្សាអំពីន័យដែលមិនជាប់ទាក់ទងនឹងបរិបទ គឺន័យផ្ទាល់នៃពាក្យ ឃ្លា និងល្បះ។

-ផ្ដោតជាសំខាន់លើអ្វីដែលព័ត៌មានផ្ដល់ឱ្យ។

-ន័យវិទ្យា គឺទាក់ទងនឹងខ្លឹមសារ។

-ពាក្យនិងទម្រង់ពាក្យ ជាចំណុចស្នូល។

**ខ. ការណ៍វិទ្យា**

-សិក្សាអំពីន័យក្នុងបរិបទនៃការប្រើប្រាស់។

-ផ្ដល់នូវឧបករណ៍សម្រាប់ជួយឱ្យយើងដឹងពីន័យ ដែលត្រូវបានផ្ដល់ដោយបរិបទប្រើក្នុងសង្គមជាក់ស្ដែង រួមបញ្ចូលទាំងឥទ្ធិពលដែលភាសាមានទៅលើស្ថានភាពនៃសម្ដីទាំងនោះផង។

-ផ្ដោតជាសំខាន់លើអ្វីដែលភាសាអាចស្ដែងនូវអំពើណាមួយ។

-ការណ៍វិទ្យា គឺទាក់ទងនឹងទង្វើណាមួយ។

-ព្រឹត្តិការណ៍ឬហេតុការណ៍សំខាន់នានា ជាចំណុចស្នូល។

### សំណួរ

១. តើន័យជាអ្វី?
២. តើន័យវិទ្យាជាអ្វី?
៣. តើន័យតាជាអ្វី?
៤. តើល្បះមួយដែលត្រឹមត្រូវទៅតាមទម្រង់ន័យនិងក្បួនន័យ ត្រូវមានលក្ខណៈដូចម្ដេច?
៥. តើន័យវចនៈជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
៦. តើន័យវេយ្យាករណ៍ជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
៧. តើន័យតក្កៈជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
៨. តើន័យបែបន័យកម្មមានលក្ខណៈដូចម្ដេច?
៩. តើន័យបែបរចនាសម្ព័ន្ធមានលក្ខណៈដូចម្ដេច?
១០. ចូរបង្ហាញពីភាពខុសគ្នារវាងន័យបែបន័យកម្មវិស័យនិងន័យអញ្ញថា។
១១. តើសទិសន័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១២. តើបដិន័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១៣. តើឯកន័យជាអ្វី? ឯកន័យមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
១៤. តើពហុន័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១៥. តើកត្តាអ្វីខ្លះដែលនាំឱ្យមានបាតុភូតពហុន័យ?
១៦. តើន័យត្រង់ជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១៧. តើន័យធៀបជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១៨. ចូរបង្ហាញពីលក្ខណៈនៃបម្រៀបន័យនៅក្នុងភាសាឱ្យបានក្បោះក្បាយ។
១៩. ចូរបង្ហាញពីលក្ខណៈបន្ទន់ន័យនៅក្នុងភាសាឱ្យបានក្បោះក្បាយ។
២០. តើឧបមានន័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
២១. ចូរពន្យល់ល្បះខាងក្រោមនេះ៖

ក. ស្នេហាប្រៀបដូចជាសមរភូមិចម្បាំង។

ខ. ជីវិតគឺជាឆាកល្ខោន។

គ. សម្ដីពីរោះស្រទន់ផ្អែមដូចឱជារសនៃទឹកឃ្មុំ។

២២. តើរូបារម្មណ៍នីយកម្មជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។

២៣. ចូរវិភាគរូបារម្មណ៍សត្វទន្សាយនៅក្នុងរឿងព្រេងខ្មែរមួយចំនួន។

២៤. ចូរវិភាគរូបារម្មណ៍សត្វក្រពើនៅក្នុងរឿងព្រេងខ្មែរមួយចំនួន។

២៥. ចូរវិភាគរូបារម្មណ៍រុក្ខជាតិនៅក្នុងរឿងព្រេងខ្មែរមួយចំនួន។

២៦. តើការណ៍វិទ្យាជាអ្វី?

២៧. តើបរិបទជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍បញ្ជាក់។

២៨. តើដេកស៊ីស (Deixis) ជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។

២៩. តើឃោបោងជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។

៣០. ចូរបង្ហាញពីលក្ខណៈនៃអាណាហ្វ៉ូរ៉ា (anaphora) នៅក្នុងភាសា។

៣១. តើបុរេសន្មតជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។

៣២. ចូរបង្ហាញពីលក្ខណៈនៃទង្វើសម្ដីឱ្យបានក្បោះក្បាយ។

៣៣. ហេតុអ្វីបានជាភាពគួរសមមានលក្ខណៈសំខាន់នៅក្នុងសង្គម?

៣៤. ចូរបង្ហាញពីភាពខុសគ្នារវាងន័យវិទ្យានិងការណ៍វិទ្យា។

# មេរៀនទី៧
# ការប្រែប្រួលនៃភាសា

**១. អម្បូរភាសា**

ដោយសារតែក្នុងពិភពលោកនេះមានភាសាច្រើន រហូតដល់ទៅជាងប្រាំមួយពាន់(៦០០០ ឬក៏ច្រើនជាងនេះទៀត និងដោយភាសាមួយចំនួនមានទិដ្ឋភាព រចនាសម្ព័ន្ធ លក្ខណៈដូចគ្នា ហើយខុសគ្នាពីភាសាមួយទៀត ទើបគេចែកភាសាជាអម្បូរឬអម្បូរភាសា (នៅ ស៊ុន, ២០១០: ៤)។

អម្បូរភាសា គឺជាភាសាមួយក្រុមដែលមានប្រភពចេញពីឫសគល់ភាសាតែមួយ ដែលគេឱ្យឈ្មោះថា បុព្វភាសា ឬភាសាមេ (Proto Language)។ គេអាចមើលឃើញថា លក្ខណៈទំនាក់ទំនងគ្នា រវាងភាសាក្នុងអម្បូរតែមួយ មិនមានលក្ខណៈខុសប្លែកពីទំនាក់ទំនងរវាងពូជធារជីវវិទ្យារបស់មនុស្ស សត្វ រុក្ខជាតិ...ដែរ។ ភាសាជាច្រើនក្នុងសកលលោកត្រូវបានគេទទួលស្គាល់ថា ស្ថិតក្នុងអម្បូរណាមួយជាកំណត់ ប៉ុន្តែមានភាសាមួយចំនួនតូចដែរ ដែលគេពុំទាន់ស្គាល់ថា តើភាសាទាំងនោះមានការទាក់ទងនឹងអម្បូរណាមួយ ឬក៏ត្រូវបានគេកំពុងតែធ្វើសំណើថា តើភាសាទាំងនោះមានការទាក់ទងនឹងអម្បូរណា?

ទស្សនៈអម្បូរភាសា គឺពឹងផ្អែកទៅលើការសន្និដ្ឋានថា ក្នុងពេលណាមួយនោះ ភាសាសាយភាយចេញទៅក្នុងគ្រាមភាសាណាមួយរួចហើយនៅក្នុងភាសាថ្មីមួយទៀត។ ក្នុងករណីខ្លះ ការកំណត់ឱ្យបានពិតប្រាកដអំពីបុព្វភាសាណាមួយ អាចពើបប្រទះនឹងភាពមិនច្បាស់លាស់ ដោយសារតែភាសាទាំងនោះចូលលាយឡំគ្នានឹងភាសាដែលមានបុព្វភាសាផ្សេងតាមរយៈទំនាក់ទំនងពាណិជ្ជកម្ម ឬការរុករានទឹកដី ដែលបង្កើតបានជាភាសានិគមជន និងប្រភេទភាសាចម្រុះ (ល្បាយភាសា) ដូចជាភាសាបារាំងសម្រាប់ប្រជាជនមួយចំនួននៅអាហ្វ្រិក ភាសាអេស្ប៉ាញសម្រាប់ប្រជាជនខ្លះនៅអាមេរិកកណ្ដាល និងអាមេរិកខាងត្បូងជាដើម។

បុព្វភាសារួមនៃអម្បូរភាសាមួយ ត្រូវបានគេស្គាល់ដោយចំពោះ ក្នុងខណៈដែលភាសាភាគច្រើនត្រូវបានគេធ្វើការកត់ត្រាដោយខ្លីៗនូវប្រវត្តិទំនាក់ទំនងនៃភាសាទាំងនោះ ប៉ុន្តែគេអាចមានលទ្ធភាពផងដែរ ក្នុងការរកឃើញលក្ខណៈពិសេសមួយចំនួន តាមរយៈការអនុវត្តវិធីសាស្ត្រប្រៀបធៀប ដែលជាវិធីស្ថាបនាឡើងវិញនូវបុព្វភាសាដែលជាស្នាដៃភាសាវិទូម្នាក់ ឈ្មោះ អូគូស ស្លីឈ័រ (August Schleicher) ក្នុងស.វ.ទី១៩។ នេះបង្ហាញពីភាពយកជាការបាននៃអម្បូរភាសាមួយចំនួន ដែលត្រូវបានគេស្នើឡើងនៅក្នុងបញ្ជីនៃអម្បូរភាសា។ ឧទាហរណ៍ ការស្ថាបនាឡើងវិញនូវបុព្វភាសារួមរបស់អម្បូរភាសាឥណ្ឌូ-អឺរ៉ុប ដែលគេហៅថា បុព្វភាសាឥណ្ឌូ-អឺរ៉ុប។

អម្បូរភាសាអាចចែកជាមែកធាងតូចៗនៃក្រុមភាសាដែលគេហៅថា ក្រុមភាសា។ ឧទាហរណ៍ អម្បូរអូស្ត្រូអាស៊ីចែកចេញជាក្រុមភាសាមួយចំនួនទៀត ដែលក្នុងនោះមាន ក្រុមខ្មែរ-មន ក្រុមនីកូបា ក្រុមមណ្ឌៈ ក្រុមណាហ្គាលី ជាដើម។

រហូតមកដល់បច្ចុប្បន្ននេះ ពាក្យអម្បូរភាសានិងក្រុមភាសានៅប្រើប្រាស់ច្របូកច្របល់គ្នានៅឡើយ (អាចនិយាយបានថា ពាក្យទាំងពីរអាចប្រើជាវេវចនសព្ទនឹងគ្នាបាន) ព្រោះថា ក្រុមភាសាខ្លះ ត្នយ៉ាងក្រុមភាសាស្លាវជាដើម មានមែកធាងច្រើនសឹងតែស្មើ ឬក៏ស្មើនឹងអម្បូរភាសាមួយទៅហើយ។ ភាសាវិទូបានបែងចែកភាសានៅលើលោក ជាអម្បូរធំៗរួមមាន៖

-អម្បូរឥណ្ឌូ-អឺរ៉ុប គឺជាអម្បូរធំមួយដែលគ្របលើទ្វីបអឺរ៉ុបស្ទើរតែទាំងអស់ ហើយនិងមួយភាគធំនៃប្រទេសឥណ្ឌា។

-អម្បូរសាមិតូ-សេមិត ជាអម្បូរធំមួយនៅម្ដុំខាងជើងទ្វីបអាហ្វ្រិក ខាងកើតទ្វីបអឺរ៉ុប និងខាងលិចទ្វីបអាស៊ី។

-អម្បូរនេគ្រូ-អាហ្វ្រិក គឺជាអម្បូរមួយដែលស្ថិតនៅមួយភាគធំនៃទ្វីបអាហ្វ្រិក។

-អម្បូរខ្វាំង គឺជាអម្បូរតូចមួយនៃជនជាតិអាហ្វ្រិករាត់រាយ។

-អម្បូរកូកាស គឺជាអម្បូរតូចល្មមនៃជនជាតិដែលរស់នៅម្តុំដងភ្នំកូកាស (អាស៊ីភាគខាងលិច)។

-អម្បូរម៉ាឡាយូ-ប៉ូលីនេស៊ី គឺជាអម្បូរធំគួរសម ស្ថិតនៅតាមកោះ (ភាគខ្លះនៃមហាសមុទ្រប៉ាស៊ីហ្វិក និងឥណ្ឌា)។

-អម្បូរមេឡានេស៊ី គឺជាអម្បូរតូចដែលស្ថិតនៅប្រជុំកោះមហាសមុទ្រប៉ាស៊ីហ្វិក។

-អម្បូរប៉ាពូ គឺជាអម្បូរតូច (នៅលើកោះនូវែលហ្គីណេ)។

-អម្បូរអូស្រ្តាលី គឺជាអម្បូរធំល្មម (កុលសម្ព័ន្ធដើមនៅអូស្រ្តាលី)។

-អម្បូរកូរ៉េ គឺជាអម្បូរធំមួយរបស់ជនជាតិកូរ៉េទាំងពីរ។

-អម្បូរអៃនូ គឺជាអម្បូរតូចមួយនៅម្តុំខាងជើងប្រទេសជប៉ុន។

-អម្បូរជប៉ុន គឺជាអម្បូរធំមួយប្រើប្រាស់នៅប្រទេសជប៉ុនទាំងមូល។

-អម្បូរចិន គឺជាអម្បូរធំមួយនៅទ្វីបអាស៊ី គ្របដណ្តប់ប្រទេសចិនទាំងមូល។

-អម្បូរអូស្រ្តូអាស៊ី[4] គឺជាអម្បូរសំខាន់មួយនៅទ្វីបអាស៊ី ប៉ែកអាគ្នេយ៍។

-អម្បូរថៃ គឺជាអម្បូរធំមួយដែរនៅទ្វីបអាស៊ី ប៉ែកអាគ្នេយ៍។

-អម្បូរទមិឡ គឺជាអម្បូរធំប្រើប្រាស់នៅឥណ្ឌាភាគខាងត្បូង។

-អម្បូរមេណ្ឌៈ : អម្បូរធំល្មមប្រើប្រាស់នៅភាគខ្លះនៃឥណ្ឌា។

-អម្បូរទីបេ-ភូមា គឺជាអម្បូរធំល្មមប្រើប្រាស់នៅប្រទេសទីបេ ប្រទេសភូមា។

-អម្បូរអេស្គីម៉ូ-កាលេអ៊ីត គឺជាអម្បូរតូចនៅលើសមុទ្រទឹកកក (ប៉ូលខាងជើង)។

-អម្បូរអាមេរិក គឺជាអម្បូរធំមួយប្រើប្រាស់ដោយកុលសម្ព័ន្ធដើមនៅទ្វីបអាមេរិកទាំងមូល (កែប វ៉ាន់ឌី, ១៩៧១)។

## ១.១. អម្បូរភាសាឥណ្ឌូ-អឺរ៉ុប

### ១.១.១. ប្រវត្តិនិងទ្រឹស្តីភាសាឥណ្ឌូ-អឺរ៉ុប

ការលើកឡើងពីភាពស្រដៀងគ្នារវាងភាសាឥណ្ឌានិងភាសាអឺរ៉ុប ត្រូវបានធ្វើឡើងដោយ អ្នកទស្សនាចរជាតិអឺរ៉ុបម្នាក់ឈ្មោះលោក ថូម៉ាស ស្ទេហ្វិន ដែលមកទស្សនាប្រទេសឥណ្ឌានៅ ក្នុងសតវត្សទី១៦។ លោក ស្ទេហ្វិន ជាបេសកជនសាសនាម្នាក់ដែលបានធ្វើការកត់សម្គាល់ពីភាពស្រដៀងគ្នារវាងភាសាឥណ្ឌាបុរាណ ជាពិសេសភាសាខុនកានិ (Konkani) ជាមួយភាសាក្រិកនិងភាសាឡាតាំង។ ការសង្កេតរបស់លោក ស្ទេហ្វិន នេះឃើញមាននៅក្នុងសំបុត្រមួយ ដែលគាត់ផ្ញើទៅបងប្រុសលោក ហើយសំបុត្រនេះ ទើបតែត្រូវបានគេបោះពុម្ពផ្សាយនៅក្នុងសតវត្សទី២០នេះ។

លោក ហ្វីលីប៉ូ សាសេទី ជាតិអ៊ីតាលីជាអ្នកជំនួញម្នាក់ ដែលធ្វើដំណើរទៅកាន់ឧបទ្វីបឥណ្ឌា ហើយលោកជាជនជាតិអឺរ៉ុបទី១ ក្នុងចំណោមអ្នកធ្វើអង្កេតការជាតិអឺរ៉ុបដទៃទៀត បានធ្វើការសិក្សាភាសាឥណ្ឌាបុរាណ គឺភាសាសំស្រ្កឹតនេះឯង។ ក្នុងស្នាដៃរបស់លោកក្នុងឆ្នាំ១៥៨៥ លោក សាសេទី បានធ្វើការកត់សម្គាល់ពីភាពស្រដៀងគ្នារវាងពាក្យមួយចំនួនក្នុងភាសាសំស្រ្កឹត និងភាសាអ៊ីតាលី ដូចជាពាក្យ devah (ទេវៈ) ក្នុងភាសាសំស្រ្កឹត និងពាក្យ dio ក្នុងភាសាអ៊ីតាលី (ប្រែថា អាទិទេព) ពាក្យ sapta ក្នុងភាសាសំស្រ្កឹត និងពាក្យ nove ក្នុងភាសាអ៊ីតាលី (ប្រែថា

[4] ពីមុនគេហៅថា អម្បូរមន-ខ្មែរ។

ប្រាំបួន) ជាដើម។ ទោះជាយ៉ាងណាក៏ដោយទាំងការសង្កេតរបស់លោក ស្ទេស៊ីន និងលោក សាសេទី មិនទាន់នាំទៅរកការជម្រះការងឿងឆ្ងល់នៅឡើយទេ។

ក្នុងឆ្នាំ១៦៤៧ ភាសាវិទូជាតិហូឡង់ម្នាក់ឈ្មោះ ម៉ាគុស ស៊េរ្យុស វ៉ាន បូហ័ន បានធ្វើការកត់សម្គាល់ពីភាពស្រដៀងគ្នាក្នុងចំណោមភាសាឥណ្ឌូ-អឺរ៉ុប ហើយបានធ្វើការសន្និដ្ឋានពីអត្ថិភាពនៃភាសាដើមរួមមួយ ដែលគាត់ដាក់ឈ្មោះឱ្យថា «ស៊ីធៀន (Seythian)»។ លោកបានបញ្ចូលទៅក្នុងសម្មតិកម្មរបស់លោកជាភាសាហូឡង់ ភាសាក្រិក ភាសាឡាតាំង ភាសាពែក្ស និងភាសាអាល្លឺម៉ង់ ហើយក្រោយមកលោកបានបញ្ចូលភាសាស្លាវ ភាសាសេលទិក និងភាសាបាល់ទិក ផងដែរ។ ទោះជា យ៉ាងនេះក្តី ការលើកឡើងរបស់លោក វ៉ាន បូហ័ន មិនទាន់មានគេទទួលស្គាល់ទូលំទូលាយនៅឡើយ ហើយក៏ពុំទាន់ចាត់ទុកជាកម្មវត្ថុសម្រាប់ការសិក្សាស្រាវជ្រាវទៅមុខទៀតដែរ។

វាមានសម្មតិកម្មមួយទៀតដែលបានលេចឡើងជាថ្មីនៅក្នុងឆ្នាំ១៧៨៦ គឺនៅពេលដែលលោក វិលីយាម ចន បានធ្វើបទឧទ្ទេសទី១ ទៅលើភាពស្រដៀងគ្នារវាងភាសាចំណាស់៤គឺ ភាសាឡាតាំង ភាសាក្រិក ភាសាសំស្ក្រឹត និងភាសាពែក្ស។ លោក ថូម៉ាស យ៉ាំង បានប្រើប្រាស់ជាដំបូងគេបង្អស់នូវពាក្យសព្ទ «ឥណ្ឌូ-អឺរ៉ុប» នេះនៅក្នុងឆ្នាំ១៨១៣ ហើយពាក្យសព្ទនេះក៏ក្លាយជាពាក្យស្តង់ដារវិទ្យាសាស្ត្រតាំងពីពេលនោះមក លើកលែងតែក្នុងប្រទេសអាល្លឺម៉ង់ ដែលហៅអម្បូរភាសានេះថា «ឥណ្ឌូ-ស៊េរម៉ាំង»។

### ១.១.២. លក្ខណៈរួមនៃភាសាឥណ្ឌូ-អឺរ៉ុប

សម្រាប់ស្ថានភាពបុរាណនៃភាសាកំណើតរបស់ភាសាឥណ្ឌូ-អឺរ៉ុប គេរកឃើញនូវលក្ខណៈមួយចំនួនដូចតទៅ៖

### ១.១.២.១. ផ្នែកសូរវិទ្យា

គេឃើញថា «o » និង «e» ជាបន្លាស់សូរនៃសទ្ទតាតែមួយ (ក្នុងទីនេះ គួរកត់សម្គាល់ថា ក្នុងសម័យកាលដំបូងស្រៈមិនត្រូវបានគេចាត់ទុកជា សទ្ទតានៅឡើយទេ)។ ក្នុងប្រព័ន្ធភាសាឥណ្ឌូ-អឺរ៉ុប តួនាទីរបស់ស្រៈ «a» គឺមានការលេចឡើងនៃសូរក្នុងបំពង់ក ហើយនៅមានការលេចឡើងនូវការប្រឈមសូរស្រៈវែង-ខ្លី (ឬអាចនឹងមានការលេចឡើងនូវបន្លែកគ្នាទៅតាមការលើកដាក់សំឡេងនិងស្នៀង)។ ក្នុងប្រព័ន្ធភាសាឥណ្ឌូ-អឺរ៉ុបនេះទៀត គេឃើញមានលំដាប់បីនៃលក្ខណៈព្យញ្ជនៈស្ទះ គឺ ឮ (ឃោសៈ) ថ្លង់ (អឃោសៈ) និងសិថិល (ក្នុងការបកស្រាយនៅក្នុងរយៈកាលពីមុនមកប្រហែលជាមានការបកស្រាយខុសពីនេះ) គឺប្រហែលជាគេគ្រាន់តែចាត់ថ្នាក់សូរព្យញ្ជនៈស្ទះត្រឹមតែបម្រឹងខ្លាំងនិងបម្រឹងខ្សោយរបស់ប្រដាប់បន្លឺសូរប៉ុណ្ណោះ)។ ចំពោះសូរព្យញ្ជនៈនេះទៀត គេចែកសូរបំពង់កជាបីលំដាប់សូរនិងមានទំនោរទៅរកការរៀបសូរព្យញ្ជនៈ ជាក្រុមសូរក្រអូមនិងសូរបបូរមាត់។

### ១.១.២.២. ផ្នែករូបសព្ទវិទ្យា

គេឃើញមានការបំបែកពាក្យមានភាពប្លែកៗគ្នា នៅក្នុងទំនាក់ទំនងបន្លាស់តែមួយ។ នាមសព្ទមានទម្រង់វិភត្តិ ហើយគុណនាមបំបែកទៅតាមវចនៈនិងភេទរបស់នាម។ នាមសព្ទត្រូវបានគេចែកជានាមសម្រាប់សម្គាល់ភាវៈមានចលនា (សម្រាប់មនុស្សនិងសត្វ) ភាវៈគ្មានចលនា (សម្រាប់វត្ថុនិងភាវៈផ្សេងៗទៀត)។ ម្ល៉ោះហើយទើបគេចែកនាមជាបីភេទ (លិង្គ)។ ចំពោះទម្រង់កិរិយាសព្ទគេចែកជាពីរស៊េរី ដូចជាស៊េរីកិរិយាសព្ទសកម្មនិងកិរិយាសព្ទអកម្ម ស៊េរីកិរិយាសព្ទកត្តុ និងកិរិយាសព្ទកម្ម។ ចំពោះកាល គេធ្វើឱ្យមានភាពខុសគ្នាពីបច្ចុប្បន្នកាលនិងអតីតកាល ទិដ្ឋភាពសម្រេច និងមិនសម្រេចរបស់ទម្រង់កិរិយាសព្ទ (ទិដ្ឋភាពកិរិយាសព្ទ)។

### ១.១.៣. បំណែងចែកក្រុមភាសាឥណ្ឌូ-អឺរ៉ុប

មូលដ្ឋានសម្រាប់ការបែងចែកភាសាឥណ្ឌូ-អឺរ៉ុប ក្នុងអម្បូរដាច់ដោយឡែកមួយ គឺឈរលើវិស័យភាសាវិទ្យាប្រៀបធៀប ភាសាវិទ្យាប្រវត្តិ ហើយដោយផ្អែកលើគោលការណ៍ទាំងឡាយសម្រាប់ការបែងចែកក្រុមភាសាក្នុងអម្បូរភាសាឥណ្ឌូ-អឺរ៉ុប គេអាចចែកជាក្រុមភាសាឥណ្ឌូ-អឺរ៉ុប ដូចតទៅ៖

**ក. ក្រុមភាសាហេតទី លូប៊ី ឬអាណាតូលី (ក្នុងតំបន់អាស៊ីមីន័រ)**

ជាក្រុមភាសាមួយពួក ដែលគេអាចបែងចែកទៅតាមកាលប្បវត្តិពីរៈ សម័យកាលសតវត្សទី១៨-១៣ មុន គ.ស. គេរកឃើញអក្សរដែកគោល (Cuneiform) របស់ជនជាតិហេតទី ឬនេស៊ីត (អក្សរចារឹករបស់ព្រះចៅអធិរាជហេតទី ព្រះនាមអានីតាសា ក្រោយមកទៀតជាអត្ថបទដែលមានលក្ខណៈជាស្វ័យជីវប្រវត្តិ និងទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ជាដើម)។ គេបានរកឃើញផងដែរនូវអក្សរដែកគោល (Cuneiform) ជាភាសាលូប៊ី និងប៉ាឡៃ (អត្ថបទទាំងពីរភាសានេះត្រូវបានគេសរសេរឡើងក្នុងសតវត្សទី១៤-១៣ មុន គ.ស.)។ ក្នុងចន្លោះពេលក្រោយមកទៀត គេរកឃើញ អត្ថបទជាសំណេរអ៊ីយេរ៉ូគ្លីហ្វ របស់ហេតទីនិងលូប៊ីនៅមុនសតវត្សទី៩-៨ មុនគ.ស. ប៉ុន្តែអត្ថបទនេះមិនទាន់ត្រូវបានគេអានដាច់នៅឡើយ ហើយអត្ថបទទាំងនេះ ក៏គេមិនទាន់ចាត់ចូលទៅក្នុងក្រុមណាមួយក៏ទេដែរ។

**ខ. ក្រុមភាសាអៀរ៉ង់**

ក្នុងរយៈកាលដ៏យូរយារណាស់មកហើយ ភាសានេះមានឈ្មោះថា ភាសាអាបេស្ទី ហើយនៅពេលមុននេះទៅទៀត គេឱ្យឈ្មោះភាសានេះថា ភាសាហ្សេនដឺ ដែលគេយកភាសានេះទៅចងក្រងអត្ថបទពិសិដ្ឋសម្រាប់សាសនា «អាបេស្ទី» ជាសំណេរដែដំបូងបង្អស់នៅក្នុងសតវត្សទី១៣-១៤ នៃគ.ស.។ អត្ថបទទាំងនេះ ជាអត្ថបទសាសនាមានឈ្មោះថា អត្ថបទ «អាបេស្ទីសាសានីត» នៅពាក់កណ្ដាលសហស្សវត្សទី១ ហើយក្រោយមកជាអត្ថបទ «អាវ្រាគីដ» ដែលជាអត្ថបទពិសិដ្ឋ ដូចគម្ពីរវេទដែរ។ ភាសាពៃក្សបុរាណ (ជាភាសាដែលគេសរសេរអត្ថបទ «អាកេមីនីត» ដោយយក សំណេរគុយនេហ្វម (អក្សរដែកគោល) មកប្រើនៅក្នុងសតវត្សទី៦-៤មុនគ.ស.។ ភាសាពៃក្សសម័យកណ្ដាល ឬភាសា ប៉េក្លេយី (សតវត្សទី២-៣នៃគ.ស. ដែលគេរកឃើញសំណេរចារឹកពុម្ពអក្សរនៅលើប្រាក់កាក់ នៅលើ ភាជន៍ នៅលើក្រដាសផ្ដាម នៅក្នុងឯកសារ «ម៉ានីកេ» ក្នុងសតវត្សទី៨-៩នៃគ.ស.។ ភាសាពៃក្សសម័យថ្មីដែលក្នុងសម័យដើមភាសានេះមានឈ្មោះថា ហ្វារស៊ី ប៉ាស៊ី និងដារី ជាភាសាអក្សរសិល្ប៍រាប់សតវត្សមកហើយ។ ជួនកាលគេចែកភាសានេះជាភាសាពៃក្សសម័យទំនើបដែលប្លែកពីភាសាពៃក្សក្លាស៊ីក(បុរាណ) ភាសាតាតហ្សិក ភាសាពូស្ទូ (ពូស្ទូ ភាសាអាហ្វហ្កានីស្ថាន) គ្រាមភាសាឃើត ភាសាលួរ និងបាហ្ទីយ៉ា ជាភាសាដែលមិនទាន់មានអក្សរនៅឡើយ ហើយស្ថិតនៅប៉ែកខាងត្បូងនៃប្រទេសអៀរ៉ង់ គ្រាមភាសាបេ-លូត ឬបេលូតឈីតាតតាលីស្ស គីឡាន និងម៉ាសាន់ដេរ៉ាន់ ទាំងអស់នេះជាគ្រាមភាសាប៉ែកកណ្ដាល និងខាងលិចនៃប្រទេសអៀរ៉ង់ (ភាសាយ៉ាសឌី ឬកាប្រ៊ី ណាអ៊ីនី ណាតាន់ស៊ី គយរីជាដើម។ ភាសាអាសេទី ប៉ាមៀរ ដែលក្នុងនោះមានភាសាស៊ូណាន់ រូសាន់ បារតាន់ អូរ៉ូស្ស៊ រ៍ សារីកូល យ៉ាគូឡាំ អ៊ិស្កាស៊ីម បាហាន់ មូនច្បាន់ យីត្តា ទាំងអស់នេះចាត់ចូលក្នុងក្រុមភាសាអៀរ៉ង់ខាងកើត។

**គ. ក្រុមភាសាតូហារ**

ក្នុងក្រុមភាសានេះ គេបែងចែកជាក្រុមភាសាតូហារប៉ែកខាងកើត ដែលក្នុងនោះមាន ភាសាការ៉ាសា ឬទយហ្វាន់ និងក្រុមភាសាតូហារខាងលិច ក្នុងនោះមានភាសាគូឆាន។

**ឃ. ក្រុមភាសាអាមេនី**

ភាសាអាមេនីបុរាណ-ភាសាក្រាបារ ជាភាសាដែលមានសំណេរចារឹកបុរាណបំផុតមួយ (សតវត្សទី៥-១១ នៃគ.ស.) ដែលក្នុងនោះមានសរសេរពីសាសនា ប្រវត្តិសាស្ត្រ ទស្សនវិជ្ជា និងអត្ថបទដទៃទៀត និងមួយចំនួនធំទៀតជាអត្ថបទបកប្រែ។ ភាសាអាមេនីសម័យកណ្ដាល (សតវត្សទី១២-១៦នៃគ.ស.)។ ភាសាអាមេនីសម័យថ្មីពីសតវត្សទី១៧ នៃគ.ស. នៅពេលដែលមាន ការបង្កើតភាសា «ប្រជាជន» ភាសាអាស្ហារ៉ាបា។ ភាសាអាស្ហារ៉ាបានេះផ្អែកទៅលើគ្រឹះនៃបំណែបផែនភាសាអក្សរសាស្ត្រប៉ែកខាងកើត។ ចំណែកឯ ភាសាអាមេនីប៉ែកខាងលិចផ្អែកលើភាសាអ្នកភ្នំដែលនៅក្នុងភាសានេះ គេរកឃើញមានអត្ថបទអក្សរសិល្ប៍ដ៏សម្បូរបែប។

**ង. ក្រុមភាសាហ្វ្រីងហ្គី (ស្ថិតនៅតំបន់ភាគខាងលិចនៃតំបន់អាស៊ីមីន័រ)**

ភាសាហ្វ្រីងហ្គីបុរាណ គេឃើញមាននៅក្នុងសំណេរចារឹកនានានៅក្នុងសតវត្សទី៨-៣ មុនគ.ស.។ ភាសាហ្វ្រីងហ្គីថ្មី គេរកឃើញនៅក្នុងពាក្យពេចន៍របស់អ្នកនិពន្ធក្រិក និងប៊ីសង់ តាំង ឈ្មោះ ហេសីគ្លី និងអ្នកដទៃទៀត។

**ច. ក្រុមភាសាហ្វ្រាហ្គី**

ក្រុមភាសានេះស្ថិតនៅភាគខាងកើតនៃតំបន់បាល់កង់ និងប៉ែកពាយព្យនៃតំបន់អាស៊ីមីន័រ។

**ឆ. ក្រុមភាសាអ៊ីលីរី**

នៅប៉ែកខាងលិចនៃតំបន់បាល់កង់ និងមួយផ្នែកតូចស្ថិតក្នុងប៉ែកអាគ្នេយ៍នៃប្រទេសអ៊ីតាលី។ ក្រុមភាសានេះ ត្រូវបានគេចែកជាភាសាអ៊ីលីរីផ្ទាល់ និងភាសាម៉េសាបនៅតំបន់ប៉ែកខាងត្បូងនៃប្រទេសអ៊ីតាលី។

**ជ. ក្រុមភាសាអាល់បានី**

គេឃើញសំណេរចារឹកទី១ ជាភាសានេះចាប់ពីសតវត្សទី១៥នៃគ.ស.។ អ្នកប្រាជ្ញមួយចំនួន មើលឃើញថាភាសានេះមានតំណពូជពង្សពីភាសាអ៊ីលីរី។ អ្នកប្រាជ្ញខ្លះទៀតយល់ថា ភាសានេះតវង្សត្រកូលពីភាសាហ្វ្រាហ្គី។

**ឈ. ក្រុមភាសាវេនេត**

ភាសានេះ គេឃើញមាននៅតំបន់ឦសាននៃប្រទេសអ៊ីតាលី ដែលគេរកឃើញនៅក្នុងសំណេរចារឹកចំនួន ២៥០ នៅសតវត្សទី៦-១ មុនគ.ស.។

**៣. ក្រុមភាសាក្រិក**

ភាសានេះ គឺជាភាសាដែលស្ថិតនៅក្នុងក្រុមគ្រាមភាសាក្រិកបុរាណ ក្នុងនោះមានភាសាអ៊ីយ៉ូនអាទិក អារកាដូឈីប ក្រុមភាសាប៉ែកឦសាន និងក្រុមភាសាប៉ែកខាងលិច។ ភាសាទាំងនេះ ត្រូវបានគេរកឃើញនៅក្នុងសំណេរចារឹកនានាក្នុងសតវត្សទី១៥-១១ មុនគ.ស.។ ភាសានេះ ត្រូវបាន លោក ហ្គោមែរ យកទៅប្រើប្រាស់ក្នុងកំណាព្យរបស់លោក ប្រហែលក្នុងសតវត្សទី៩ មុនគ.ស.។ ភាសាក្រិកសម័យកណ្ដាល ឬភាសាប៊ីសង់ តាំង និងតមកទៀត ភាសាក្រិកសម័យថ្មី ដែលគេចែកជាភាសាសម្រាប់សរសេរនិងភាសានិយាយ ។

**ជ. ក្រុមភាសាអ៊ីតាលិក**

ភាសានេះ ជាក្រុមភាសាដែលស្ថិតនៅទៀបកោះអាប៉េណាំង។ ក្នុងសម័យបុរាណ គេឃើញមានភាសាឡាតាំង ដែលក្នុងពេលដំបូងឡើយជាភាសានិយាយរបស់ប្រជាជនទីក្រុងរ៉ូម និងតំបន់ជាយៗទីក្រុងនេះ។ ក្នុងពេលបន្តមកទៀត ភាសានេះបានរីកសាយពេញទូទាំងប្រទេសអ៊ីតាលី ហើយក្រោយមកទៀត ភាសានេះបានរីកសាយពីទៀបកោះពីរ៉ាណេ និងតំបន់ហ្គាល់ រហូតដល់ដាណឺម៉ាក និងទ្វីបអាហ្វ្រិកប៉ែកខាងជើង។ ជាមួយនឹងភាសាឡាតាំងក្នុងសម័យកណ្ដាល ភាសាឡាតាំងជាភាសាប្រជាជនសាមញ្ញ ហើយនៅលើមូលដ្ឋានភាសាឡាតាំងនេះ កើតចេញជាក្រុមភាសាមួយទៀតឈ្មោះថា ក្រុមភាសារ៉ូម៉ាំង។ ក្រុមភាសារ៉ូម៉ាំងនេះចែកចេញជា ភាសាបារាំង ភាសាអុកស៊ីតាន ឬភាសាប្រូវ៉ង់ ភាសាអេស្ប៉ាញ ភាសាកាតាឡាំង ភាសាហ្គាលីស៊ី ភាសាព័រទុយហ្គាល់ ភាសាអ៊ីតាលី ភាសាសារឌីន ភាសារេត្តូរ៉ូម៉ាំង ភាសារ៉ូម៉ានី ភាសាម៉ុលដាវី ភាសាអារ៉ូម៉ាន។ នៅលើមូលដ្ឋានភាសារ៉ូម៉ាំងនេះ គេបង្កើតជាភាសាសិប្បនិម្មិត អេស្ពេរ៉ាន់តូ ផងដែរ។

**ឋ. ក្រុមភាសាកេលត៍**

ភាសានេះស្ថិតនៅខាងចុងទ្វីបអឺរ៉ុបខាងលិច គឺពីអៀរឡង់រហូតដល់ទៀបកោះពីរ៉ាណេ នៅភាគខាងត្បូង។ ក្នុងភាសាក្រុមនេះ តាមទម្លាប់ គេចែកជាពីរក្រុមតូចៗទៀតគឺ ក្រុមទី១មាន ក្រុមភាសាហ្គាល់ ក្នុងនោះមានភាសាហ្គាល់ខ្លួនឯងដែលលាតសន្ធឹងនៅក្នុងទឹកដីបារាំង និងអ៊ីតាលីប៉ែកខាងជើង ហើយក្រោយមកលាតសន្ធឹងមកទិសខាងកើតមកដល់តំបន់បាល់កង់ និងភាសាប្រឺតុង។ ក្រុមទី២ មានភាសាអៀរឡង់ ដែលក្នុងនោះរួមទាំងភាសាអៀរឡង់បុរាណ ភាសាអៀរឡង់សម័យកណ្ដាល និងភាសាអៀរឡង់សម័យថ្មី ភាសាហ្គែល ឬភាសាសូតឡង់ដឺ។

**ឌ. ក្រុមភាសាសែរម៉ាំង**

ភាសានេះចែកជាបីអនុក្រុមភាសាបន្តទៀត។ ទី១ ក្រុមភាសាសែរម៉ាំងខាងកើត ក្នុងនោះ មានភាសាហ្គោត។ ទី២ ក្រុមភាសាសែរម៉ាំងមានដូចជា ភាសាអាល្លឺម៉ង់លើដែលជាទូទៅគេចែកជា ភាសាអាល្លឺម៉ង់លើសម័យបុរាណ (ស.វ.ទី៨-១១) ភាសាអាល្លឺម៉ង់លើសម័យកណ្ដាល (ស.វ.ទី ១២-១៥) និងភាសាអាល្លឺម៉ង់លើសម័យថ្មី ឬភាសាអាល្លឺម៉ង់។ ភាសាអាល្លឺម៉ង់ក្រោមដែលចែកចេញជា ភាសាអាល្លឺម៉ង់ក្រោមសម័យបុរាណ ភាសាអាល្លឺម៉ង់ក្រោមសម័យទំនើប ក្នុងនោះ មានភាសាហូឡង់ ភាសាអាព្រិកាអាន ឬភាសាបួរសំ ភាសាអង់គ្លេសបុរាណ ឬភាសាអង់គ្លោសាក់សុង ភាសាអង់គ្លេសសម័យកណ្ដាល និងភាសាអង់គ្លេសសម័យទំនើប។ ទី៣ ភាសាសែកម៉ាំងប៉ែកខាងជើង ឬភាសាស្កង់ឌីណាវ ក្នុងនោះមានភាសាអីស្លង់ ភាសាដាណឺម៉ាក ភាសាស៊ុយអែត និងភាសាន័រវេស។

**ឍ. ក្រុមភាសាបាល់ទិក**

គេចែកភាសានេះជាពីរអនុក្រុម គឺក្រុមភាសាបាល់ទិកខាងលិចដែលក្នុងនោះមានភាសាព្រូស ភាសាយ៉ាត្វា ឬភាសាស៊ូដាវ ភាសាហ្គាលីន ឬភាសាហ្គោតល្យ៉ាត។ ក្រុមភាសាបាល់ទិក ខាងកើតមានភាសាលីទ្វី ភាសាលីទ្បូអានី។

**ណ. ក្រុមភាសាស្លាវ**

ជាទូទៅគេចែកក្រុមភាសានេះ ជាពីរអនុក្រុមទៀតគឺៈ ទី១ ក្រុមភាសាស្លាវខាងត្បូងមាន ភាសាស្លាវបុរាណ (ស.វ.ទី១០-១១) ភាសាប៊ុលការី ភាសាម៉ាសេដូន ភាសាស៊ែប-ហារវ៉ាត់ ភាសាស្លូវេនី និងភាសាស្លូវែន។ ទី២ ក្រុមភាសាស្លាវខាងលិចក្នុងនោះមានភាសាឆែក ភាសាស្លូវ៉ាក ភាសាប៉ូឡូញជាដើម។ ទី៣ ភាសាស្លាវខាងកើតក្នុងនោះមានភាសារុស្ស៊ី ភាសាអ៊ុយគ្រែន ភាសាបីយេឡូរុស៊ី ជាដើម។

**ត. ក្រុមភាសាឥណ្ឌា ឬឥណ្ឌូ- អារ្យ៉ែន**

នៅវាលទំនាបខាងជើងនៃឧបទ្វីបឥណ្ឌា និងនៅកោះលង្កា។ គេចែកចេញជាភាសាឥណ្ឌាយុគបុរាណ គឺភាសាគម្ពីរវេទ(អត្ថបទចាស់ជាងគេ គឺអត្ថបទគម្ពីរឫគវេទនៅចុងស.វ.ទី២ ដើមស.វ.ទី១មុនគ.ស.) ភាសាសំស្ក្រឹតដែលគេដឹងថា មានចែកចេញជាបំណែកផែនមួយចំនួន ដូចជា ភាសាសំស្ក្រឹតក្លាស៊ិក ភាសាសំស្ក្រឹតអេពិក និងអ្វីដែលគេហៅថា ភាសាពុទ្ធសាសនា។ ភាសាឥណ្ឌាសម័យកណ្ដាល ឬភាសាប្រាក្រឹត ដែលក្នុងនោះមានភាសាមួយដែលគេស្គាល់ច្បាស់ គឺភាសាបាលីដែលគេយកទៅប្រើក្នុងសំណេរចារឹករបស់ស្ដេចអសោករាជផងដែរ។ ភាសាឥណ្ឌាសម័យថ្មីចែកជា ទី១-ក្រុមភាសាកណ្ដាលដែលក្នុងនោះមានភាសាហិណ្ឌី។ ទី២-ក្រុមភាសាខាងកើតដែលក្នុងនោះមានភាសាប៊ីហារី ភាសាបឹងហ្គាលី ភាសាអាស្សាំ ភាសាអូរីយ៉ា។ ទី៣-ក្រុមភាសាខាងត្បូងមានភាសាម៉ារ៉ាធី។ ទី៤-មានក្រុមភាសាសឹងហ្គាល់។ ទី៥-ក្រុមភាសាប៉ែកពាយ័ព្យ ដែលក្នុងនោះមានភាសាស៊ិនធី ភាសាឡិនឌី និងភាសាប៉ិនដ្យាប៊ី។ ទី៦-ក្រុមភាសា ខាងលិចមានភាសាវ៉ាជ្យាស្ថានី ភាសាគុតជ្យារ៉ាទី ភាសាភីលី ភាសាខាន់ដេស្ស៊ី។ ទី៧-ក្រុមភាសាប៉ាហារីដែលក្នុងនោះមានចែកជាក្រុមភាសាប៉ាហារីខាងកើត (នេប៉ាល់) ក្រុមភាសាប៉ាហារីកណ្ដាលមានភាសាគូម៉ាតនី ភាសាកាហ្វាលី និងក្រុមភាសាប៉ាហារីខាងលិច (ប៊ុញ សឿន, ២០១១)។

## ១.២. អម្បូរភាសាអូស្ត្រូអាស៊ី

ជាក្រុមភាសាមួយ ដែលប្រជាជាតិមួយចំនួនយកទៅប្រើប្រាស់សម្រាប់និយាយទាក់ទងគ្នាក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង។ ភាសានេះក៏ត្រូវបានប្រជាជនមួយចំនួននៅតាមកោះនានាក្នុងមហាសមុទ្រឥណ្ឌាប្រើប្រាស់ផងដែរ។

### ១.២.១. លក្ខណៈទូទៅនៃអម្បូរភាសាអូស្ត្រូអាស៊ី

លក្ខណៈប្រព័ន្ធនៃភាសាអម្បូរអូស្ត្រូអាស៊ីមានបញ្ចេកស្រៈបិទ-បើកទៅលើស្រៈ «អេ» [ɛe], «អ៊ី» [i:], «អូ» [ɔo] ហើយនិងមានស្រៈ [ə] ដូចជា [ə] ក្នុងភាសាអង់គ្លេសដែរ។ ស្រៈក្នុងភាសាជាច្រើនមានបញ្ចេកប្រូសូឌី

(prosody) ទៅតាមសូរវែង-ខ្លី។ នៅលើមូលដ្ឋានប្រព័ន្ធព្យញ្ជនៈ គេឃើញមានបញ្ចេកឃោសៈ (ឮ) អឃោសៈ (ថ្លង់) ស្ទះ។ នៅក្នុងភាសាខ្លះមានប្រភេទព្យញ្ជនៈ ដែលមានសំឡេងក្នុងក្បាល និងព្យញ្ជនៈមានខ្យល់។ លក្ខណៈមួយសម្រាប់ភាសាអូស្ត្រូអាស៊ី គឺមានព្យញ្ជនៈគ្មានខ្យល់-ស្ទះនៅខាងចុងរូបសព្ទ។ នៅក្នុងភាសាមន-ខ្មែរដោយសារដំណើរអឃោសៈ ឃោសៈ ស្ទះ នាំឱ្យកើតសណ្ឋានឬបញ្ជិកា ឬស៊េរីក្នុងសូរស្រៈ ដូចជាដំណើរ អឃោសៈ [g] ទៅជា [k] (ក្នុងករណីព្យញ្ជនៈ ក-គ) សូរ [j] ទៅជា [c] (ក្នុងករណីព្យញ្ជនៈ ច-ជ) សូរ [d] ទៅជា [t] (ក្នុងករណីព្យញ្ជនៈ ត-ទ) ជាដើម។ ហេតុការណ៍នេះកើតមានឡើងនៅក្នុងភាសាវៀតមឿង និងផ្នែកខ្លះនៃភាសាប៉ាលុង-វ៉ា ហើយការណ៍នេះក៏ជាជំហានទៅរកការកកើតនៃសៀង (tone) ដែរ។

ចំពោះទម្រង់វេយ្យាករណ៍វិញ ភាសាខ្លះដែលស្ថិតក្នុងអម្បូរអូស្ត្រូអាស៊ី បានរក្សាទុកនូវទម្រង់ផ្នត់ និងភាសាខ្លះទៀតមិនរក្សាទុកនូវទម្រង់ផ្នត់ទេ។ ផ្នត់ទាំងនោះភាគច្រើនជាផ្នត់ដើម និងផ្នត់ដែក វៀរលែងតែភាសាមួយចំនួននៅមានផ្នត់ចុងដូចជា ក្រុមភាសាមុណ្ឌានិងណាហ្គាលី ជាដើម។ ផ្នត់ដើមភាសាអម្បូរនេះច្រើនមានទម្រង់ជា CV, CVC, VC ឬក៏មានតែព្យញ្ជនៈនៅដើមឫសពាក្យតែម្តង។ ឧទាហរណ៍ ក្នុងភាសាខាស៊ី គេឃើញមានពាក្យ k-ti (ដៃ) k-jat (ជើង) (k-ជា ផ្នត់ដើម) kr-pheng (ដោយឡែក) (pheng- ព្រំប្រទល់ ខ្សែបន្ទាត់) ក្នុងភាសានីកូបា mat (ភ្នែក) tei (ដៃ) olmat (គ្រាប់ភ្នែក) oltei (បាតដៃ) okmat (ចិញ្ចើម)។

ឈរលើទម្រង់នៃការបង្កើតពាក្យ ឬការពង្រីកពាក្យមូលដ្ឋាន (ពាក្យឫស) ភាសាមួយ ចំនួនដូចជា ភាសាខាស៊ីជាដើម ត្រូវបានអ្នកស្រាវជ្រាវមួយចំនួនរកឃើញថា វាមានជំហានផ្លាស់ប្តូរពីទម្រង់អ៊ីសូឡង់ទៅរកទម្រង់អាគ្លុយទីណង់។ ចំពោះផ្នត់ដែកវិញ គេឃើញមានផ្នត់ដែក [-ɒn/n-] សម្រាប់បង្កើតនាមសព្ទសម្គាល់ឧបករណ៍និងទីកន្លែង។ ផ្នត់ដែក [-m-] សម្រាប់សម្គាល់អ្នកធ្វើសកម្មភាព ផ្នត់ដែក [-mn-] សម្រាប់សម្គាល់អ្វីដែលជាកន្សោមសំណុំ និងនាមអរូបី។ លើសពីនេះទៅទៀត គេឃើញមានផ្នត់ដែក [-r-], [-l-], [-?-] ផងដែរ។ ដូចជានៅក្នុង ភាសាខាស៊ី គេឃើញមានពាក្យ briw (មនុស្ស) k-aman-uan (មនុស្សជាតិ) ក្នុងភាសានីកូបា dok (ចូល) d-am-uk (ភ្ញៀវ) koan (កូន) k-aman-ean (ជំនាន់) ជាដើម។

ចំពោះភេទ (លិង្គ) របស់នាមសព្ទវិញក្នុងភាសាភាគច្រើន គេកំណត់បានតែទៅលើនាម ដែលសម្គាល់ភាវៈមានជីវិតប៉ុណ្ណោះ។ មានតែភាសាខាស៊ីមួយទេ ដែលមានការសម្គាល់នាមសព្ទ។ ចំពោះវចនៈវិញ ភាសានេះ (ខាស៊ី) មានឯកវចនៈ ទ្វិវចនៈ និងពហុវចនៈ។ ក្នុងផ្នែកសម្ព័ន្ធវិទ្យា ល្បះទោលមានលំដាប់ដូចនេះ ល្បះមានទម្រង់ដូចនេះ ប្រធាន + កិរិយា + កម្មបទ។

## ១.២.២. បំណែងចែកអម្បូរភាសាអូស្ត្រូអាស៊ី

### ក. ក្រុមភាសាសេម៉ាង -សាកៃ

ក្រុមភាសាអាស្លីយ៉ាន គឺជាក្រុមភាសាទាំងឡាយដែលលាតសន្ធឹងនៅទៀបកោះមលក្កា (ប្រទេសម៉ាឡេស៊ី)។ មានគ្រាមភាសាសេម៉ាងមួយត្រូវបានប្រជាជននៅប៉ែកខាងត្បូងប្រទេសថៃ យកមកនិយាយ។ ក្រុមភាសាសេម៉ាង-សាកៃ ឬអាស្លីយ៉ានចែកចេញជាអនុក្រុមមួយចំនួនៈ ទី១ អាស្លីយ៉ានខាងជើង ឬភាសាសេម៉ាង-ប៉ាន់ហ្គាន់។ ទី២ ក្រុមភាសាសេម៉ាងខាងត្បូងជាក្រុមភាសាដែលរលត់ទៅហើយ។ ទី៣ ភាសាតេមីអា ឬឡាណុះ (ភាសាសាកៃខាងជើង)។ ទី៤ ភាសាមេឡៃ (ភាសាសេកៃកណ្តាល។ ទី៥ ភាសាប៉ះមើរ (ភាសាសាកៃខាងកើត)។ ទី៦ ភាសាសេមេលៃ (ភាសាសាកៃប៉ែកអាគ្នេយ៍)។ ទី៧ ភាសាក្នុងអនុក្រុមជ្យាស៊្វ (ភាសាសាកៃខាងកើត)។ ទី៨ ភាសាក្រៅអនុក្រុមសេម៉ះបេរី គឺក្រុមភាសាសាកៃខាងកើត។ ទី៩ ភាសាឈេ-វ៉ុង មានភាព ប្លែកពីភាសាសេម៉ាង និងសាកៃ ត្រង់ថាភាសានេះត្រូវបានកុលសម្ព័ន្ធនេហ្គ្រោអ៊ីដ យកមកនិយាយនៅតំបន់ហ៊ូណុង-បេណុម។

**ខ. ក្រុមភាសាវៀត - មឿង**

ក្រុមភាសាវៀត-មឿង ជាផ្នែកគ្រឹះមួយនៃអម្បូរអូស្ត្រូអាស៊ី។ ជាក្រុមភាសាមួយដែលគ្របដណ្ដប់ភាគច្រើននៅប្រទេសវៀតណាម និងក្នុងប្រទេសខ្លះនៃប្រទេសឡាវ។ ភាសាសំខាន់ៗ ក្នុងក្រុមភាសានេះមានដូចជា ភាសាវៀតណាមបច្ចុប្បន្ននិងគ្រាមភាសានានារបស់ភាសានេះ ភាសាវៀតណាមកណ្ដាល ភាសាមឿងនិងគ្រាមភាសាដ៏ច្រើនសន្ធឹកសន្ធាប់ទៀត ភាសាប៉ាកាតាន ភាសាផាវ៉ុង ភាសាប៉ុង ភាសាស្លាត ឬសេក ជាដើម។

**គ. ក្រុមភាសាប៉ាលុង - វ៉ា**

ក្រុមភាសានេះរួមបញ្ចូលភាសាទាំងឡាយ ដែលលាតសន្ធឹងរហូតដល់ព្រំប្រទល់ ខាងត្បូងនៃប្រទេសចិន ទីបេត៍ ប្រទេសប៊ូតង់ និងនៅប្រទេសវៀតណាម ថៃ ឡាវ និងភូមាផងដែរ។ ក្រុមភាសានេះមានចែកចេញជាអនុក្រុមផ្សេងៗក្នុងនោះមានដូចជា អនុក្រុមប៉ែកខាងលិចដែលមានភាសារាង ឬយ៉ាំងសេក ភាសាប៉ាលុង ឬភាសារូម៉ៃ ក្នុងនោះក៏មានភាសាដាំាំងផងដែរ ភាសាអាំងគូ ឬអាំងគួយ ភាសាវ៉ា ភាសាអេន ភាសាតយឡាយ ភាសាដាណាយ ភាសាឡាវ៉ា ដែលក្នុងនោះមានគ្រាមភាសាមួង មី ប៉ា ប៉ាប៉ាវ។ អនុក្រុមខាងកើតមានភាសា ឃ្មូ ឡា ម៉េត ក្វាក្វាងលីម ខា កន-គី ខាជួយ-លួង ផេង(តេង ឬផុង) តុង-លួង ក្វេន ចុន ហា-ពូ និងគ្រាមភាសាជាច្រើនទៀត។

**ឃ. ក្រុមភាសានីកូបា**

ក្នុងនោះមានភាសាទាំងឡាយ ដែលលាតសន្ធឹងនៅក្នុងប្រជុំកោះនីកូបា។ ភាសាទាំងនោះមាន ភាសាការ (ការនីកូបា) ឬ ពូ ភាសាស្ហូវ្រី តេ-តេត ភាសាតេរ៉េស និងប៉ាប៉ាក (តេ-អ៊ិះ-ឡុង) គ្រាមភាសាកណតាលដែលក្នុងនោះមាន ណាងកាយរី (កោះកូម័រត៍) ឡាហ្វិល (កោះទីរ ស្ទីគូ) តេះញូ (កោះកាឆែល) ឡុង (កោះនីកូបាធំ) អុន (កោះនីកូបាតូច) ឡា-ម៉ុង-ស្វេ (កោះកុន ឌូល) មីឡុះ (គ្រាមភាសាខាងត្បូង) ស្ហមប៉ង។

**ង. ក្រុមភាសាខាស៊ី**

ស្ថិតនៅក្នុងប្រទេសឥណ្ឌានិងបង់ក្លាដេស នៅក្នុងនោះមានបញ្ចូលគ្រាមភាសាមួយចំនួន ដែលអ្នកតំបន់ភ្នំនៅក្នុងរដ្ឋមេឃាឡៃប្រទេសឥណ្ឌាយកមកនិយាយ។ គ្រាមភាសាមួយដែលគេចាត់ទុកថា ជាគ្រាមភាសាស្តង់ដារនោះគឺគ្រាមភាសានៅតំបន់ឆេរ៉ាពូនឌ្យី គ្រាមភាសាឡេង៉ាម (សេនតេង ឬផ្នារ) គ្រាមភាសាបារ (ឡាកាដុង)។

**ច. ក្រុមភាសាមុណ្ឌះ**

ភាសាមួយចំនួនក្នុងក្រុមនេះ ត្រូវបានប្រជាជនមួយចំនួននៃរដ្ឋម៉ាត្យាប្រាដេស រដ្ឋបីហារ អូរិស្សា និងអាន់ដ្រាប្រាដេស (ប្រទេសឥណ្ឌា) យកមកនិយាយ។

**ឆ. ក្រុមភាសាណាហ្គាលី**

ក្រុមភាសាណាហ្គាលី គឺនៅរដ្ឋម៉ាត្យាប្រាដេសប្រទេសឥណ្ឌា។ ក្រុមភាសានេះទទួលឥទ្ធិពលពីភាសានានាគ្រប់ប្រព័ន្ធ ប៉ុន្តែក្រុមភាសានេះនៅរក្សាទុកនូវអ្វីដែលជិតស្និទ្ធនឹងក្រុមភាសាមុណ្ឌះ។

**ជ. ក្រុមភាសាមន - ខ្មែរ**

ជាក្រុមភាសាមួយដែលជាសមាសភាគនៃអម្បូរអូស្ត្រូអាស៊ី។ ពាក្យ «មន-ខ្មែរ» កើតឡើង បញ្ច្រាសពាក្យ «មន-អណ្ណាម» ដែលត្រូវបានគេបង្កើតឡើងនៅពាក់កណ្ដាលសតវត្សទី១៩ ក្នុងន័យចង់ផាត់ចេញភាសាអណ្ណាមចេញពីក្រុមភាសានេះ។ ពាក្យ «មន-ខ្មែរ» មានការរីកសាយយ៉ាងខ្លាំង បន្ទាប់ពីភាសាវិទូអាល្លឺម៉ង់ម្នាក់ឈ្មោះ ស្មីតបាននិពន្ធស្នាដៃមួយឈ្មោះថា «Die Mon-Khmer-VÖlker ein Bindeglied Zwischen VÖlkern Zentralasiens und Austronesiens» ក្នុងឆ្នាំ១៩០៦ និងស្នាដៃផ្សេងៗទៀត។ វានៅមិនទាន់មានឯកភាពគ្នានៅឡើយទេទៅលើការកំណត់ព្រំប្រទល់ក្រុមភាសាមន-ខ្មែរ។

អ្នកសិក្សាស្រាវជ្រាវជាច្រើនបានពង្រីកព្រំដែននៃក្រុមភាសាមន-ខ្មែរ រហូតដល់ក្រសោបយកភាសាមួយចំនួនមកបញ្ចូលក្នុងក្រុមនេះ។ ភាសាទាំងនោះមានដូចជា ភាសាខាស៊ី (លោក ហ្វូនី ញេវ) ភាសាម៉ាឡាកា (លោក

ឪផ្ទួត) និងភាសានីកូបាផងដែរ (លោក គោគោញីយ៉េវ)។ ក្នុងស្នាដៃរបស់លោក ថូម៉ាស និងលោក ហេតលី ដែលទាក់ទងនឹងស្ថិតិវចនសព្ទ បានចាត់បញ្ចូលភាសាវៀតណាមក្នុងក្រុមមន-ខ្មែរនេះដែរ ដោយផាត់ភាសានីកូបា និងភាសាមល្លកាចេញ។ ចំពោះភាសាខាស៊ីវិញនៅក្នុងចំណោមបញ្ហានៅឡើយ។ ដោយឈរលើលក្ខណៈវិនិច្ឆ័យប្រភេទភាសាក្នុងការបែងចែកក្រុមភាសាអូស្ត្រូអាស៊ី លោក ពីណូវ បានស្នើបែងចែកជាសាខាមុណ្ឌៈ និងសាខាខ្មែរ-នីកូបា (ក្នុងសាខាខ្មែរ-នីកូបា លោក ពីណូវ ស្នើចែកក្រុមធំៗពីរ គឺក្រុមមន-ខ្មែរ និងក្រុមនីកូបា ក្នុងករណីនេះ គេមិនបានយកភាសាវៀតណាមមកពិនិត្យទេ)។

អ្នកសិក្សាស្រាវជ្រាវភាគច្រើនបញ្ចូលទៅក្នុងក្រុមមន-ខ្មែរ នូវក្រុមភាសាមួយចំនួនដូចតទៅ ក្រុមភាសាខ្មែរ ក្រុមភាសាមន ក្រុមភាសាព័រ ក្រុមភាសាហ្វាណាខាងជើង ក្រុមភាសាហ្វាណាខាងត្បូង ក្រុមភាសាហ្វាណាខាងលិច ក្រុមភាសាកាទូយ ក្រុមភាសាឃ្មុ ក្រុមភាសាប៉ាលុង។ ភាសាទាំងនេះត្រូវបានគេចាត់ទុកថា ជាក្រុមភាសា «មន-ខ្មែរប្រពៃណី» គឺជាក្រុមភាសាដែលគេធ្លាប់តែថា ជាក្រុមភាសាមន-ខ្មែរតំមាត់ រត់ចិត្តជាយូរមកហើយ។

ក្រុមភាសាមន-ខ្មែរ ប្រពៃណីលាតសន្ធឹងទូទាំងទឹកដីឥណ្ឌូ-ចិន ប្រទេសថៃ ភូមា និងតំបន់វាលទំនាបខាងត្បូងនៃប្រទេសចិន។ ប្រជាជាតិដែលនិយាយភាសាមន-ខ្មែរភាគច្រើនគឺ ជនជាតិខ្មែរ មន និងកួយ និងជនជាតិមួយភាគតូចទៀតដែលមានចំនួនពីចន្លោះពីរបីពាន់ទៅពីរបីម៉ឺនប៉ុណ្ណោះ។

### ១.២.៣. លក្ខណៈក្រុមភាសាមន - ខ្មែរប្រពៃណី

សម្រាប់សទ្ទតាវិទ្យា ស្ទើរតែគ្រប់ភាសាមន-ខ្មែរប្រពៃណីទាំងអស់ គេឃើញមានវត្តមានលំដាប់សូរស្រៈកណ្តាលច្បាស់លាស់ មានវត្តមានព្យញ្ជនៈក្រអូមស្ទះ (ឃោសៈនិងអឃោសៈ)។ ជាក្រឹត្យក្រម ប្រព័ន្ធសូរស្រៈគឺលំដាប់ស្រៈមុខ ស្រៈកណ្តាល និងស្រៈក្រោម (នេះបើគិតតាមចលនាលើ-ក្រោម ឬចលនាបញ្ឈរនៃអណ្តាត)។ ភាសាជាច្រើនមានប្រព័ន្ធសូរស្រៈសម្បូរបែបគឺមានលើសពី៣០ (ភាសាខ្មែរ ភាសាព្រៅ)។ ភាសាភាគច្រើនមានការប្រឈមគ្នារវាងស្រៈវែង-ខ្លី។ ប្រព័ន្ធសូរព្យញ្ជនៈជាធម្មតាមានភាពងាយៗ។ ភាសាជាច្រើនក្នុងចំណោមភាសាមន-ខ្មែរប្រពៃណី ឃើញមានវត្តមានព្យញ្ជនៈដើមក (ភាសាកាទូ ភាសាសួយ ភាសាស្ទៀង) និងព្យញ្ជនៈដើមច្រមុះ (ភាសាកាទូ ភាសាម្នង-ព្នង)។ ជួនកាលព្យញ្ជនៈដើមច្រមុះទាក់ទងយ៉ាងជិតជិតទៅភាពពុទ្ធខ្វរនៃព្យញ្ជនៈ (ភាសាសេដាង)។ ព្យញ្ជនៈមានខ្យល់ត្រូវបានគេជួបប្រទះដោយកម្រក្នុងភាសាសំរែ។

សម្រាប់ពាក្យនៅក្នុងភាសាមន-ខ្មែរប្រពៃណី គេឃើញមានបន្សំធាតុ (ភាគច្រើនជាផ្នត់ដើម) ដែលជាធាតុមិនមានការសង្កត់សូរ (ព្យាង្គខ្សោយ) នៅពីមុខពាក្យមូលដ្ឋាន (ពាក្យឫស) ដែលគេហៅថា «ព្យាង្គខ្លាំង»។ ចំនួនព្យាង្គខ្សោយអាចមានត្រឹមតែ៣ (ភាសាកាទូ) មាន២ (ភាសា ប៉ាលុង) មានតែ១ (ភាសាក្វា បាហ្នា ប៉ាកុះ ឃ្សឹងមូល ព្រៅ)។ ក្នុងនោះ គ្រប់ភាសាមន-ខ្មែរប្រពៃណីទាំងអស់មានពាក្យមួយព្យាង្គដ៏ច្រើន។ ចំណែកឯភាសាមួយចំនួនក្នុងនោះមាន គ្រាមភាសាម្នងមួយចំនួនដូចជា គ្រាមភាសារ៉េឡេមញ៉ាហេង ជាដើម ដែលអនុញ្ញាឱ្យមានតែរចនាសម្ព័ន្ធឯកព្យាង្គប៉ុណ្ណោះ។ ចំពោះចំនួនព្យាង្គនៅក្នុងពាក្យឫសមិនលើសពីពីរព្យាង្គឡើយ។ រចនាសម្ព័ន្ធព្យាង្គខ្លាំង ក៏មានការកម្រិតផងដែរ។ ជាធម្មតាបន្សំព្យញ្ជនៈប្រព្រឹត្តទៅតាមការប្រើប្រាស់ព្យញ្ជនៈលីគីត (liquid) ដូចជា [l], [r] ជាដើម នៅខាងចុងព្យាង្គមានចំនួនតិចតួច (ឬក៏គ្មានសោះ) បើប្រៀបធៀបការប្រើប្រាស់ព្យញ្ជនៈប្រភេទនេះនៅដើមព្យាង្គ។

ចំពោះភាសាមន-ខ្មែរប្រពៃណី គេឃើញមានប្រភេទប្លែកៗនៃសំណូរ (phonation) ស្រៈ មានន័យថាភាពប្លែកគ្នាទៅតាមកម្រិតសំណូរខ្លាំង-ខ្សោយនៃស្រៈ។ ជាទូទៅ គេឃើញមានការប្រឈមរវាងសំណូរស្រៈនិងសំណូរមានខ្យល់(ភាសាសួយ កួយ ហាឡាង ចែស ក្រែ) ឬ ការប្រឈមរវាងសំណូរស្រៈនិងតំណឹងសូរ (ភាសាព្រៅ សេដាង)។ ក្នុងភាសាមួយចំនួនទៀត ប្រភេទសំណូរស្ថិតនៅលើលក្ខណៈស្រៈ (ភាសាខ្មែរ ភាសាមន)។ ជារឿយៗប្រភេទសំណូរជាប់ទាក់ទងនឹងលក្ខណៈសូរវិទ្យា ជាឧទាហរណ៍ ជាប់ទាក់ទងនឹងបញ្ជិកាស្រៈ។ ប៉ុន្តែក្នុងភាសាមួយ

ចំនួន សំណួរនិងបញ្ចិកាស្រៈមានលក្ខណៈដាច់ដោយឡែកពីគ្នា គឺមិនមានឥទ្ធិពលស្មើគ្នាឡើយ (ភាសាម៉ា)។ ក្នុងភាសាភាគច្រើន គេសម្គាល់ឃើញមានទំនាក់ទំនងទៅរកច្រមុះកម្មនូវស្វរស្រៈ ហើយករណីនេះកើតមានឡើងតែក្នុងវង្វង់ស្វរបំពង់កប៉ុណ្ណោះ (ភាសាសេដាង ក្វាហាឡាង)។ ជាក្រឹត្យក្រម ភាសាមន-ខ្មែរបុរាណមិនមានរចនាសម្ព័ន្ធសៀងទេ (មានតែភាសាដាណៃនិងម៉ាង-អ៊ី ប៉ុណ្ណោះ)។

ចំពោះការបង្កើតពាក្យ គេឃើញថា ពាក្យផ្សំនិងកន្សោមពាក្យមានទម្រង់តែមួយ ដែលនាំឱ្យមានការលំបាកក្នុងការចែកប្រភេទពាក្យទាំងពីរនេះឱ្យដាច់ស្រលះពីគ្នា។ ក្នុងភាសាជាច្រើន គេឃើញមានវិធីកម្លាយពាក្យដោយប្រើផ្នត់ (ភាសាកាទូ បាហ្នា ប៉ាកុះ)។ ផ្នត់ដើមភាគច្រើន មានលក្ខណៈជាការញ៉ាំងឱ្យមានអំពើដោយប្រើព្យញ្ជនៈបបូរមាត់(ផ្នត់ដើម [po-] ក្នុងភាសាសេដាង ផ្នត់ដើម [pa-] ក្នុងភាសាប៉ាកុះ និងកាទូ ផ្នត់ដើម [po-] ក្នុងភាសាប៉ាហ្នា ផ្នត់ដើម [b-] [p-] ក្នុងភាសាខ្មែរ ផ្នត់ដើម [pn-] [p-] ក្នុងភាសាឃ្មូ)។ ផ្នត់ដើមដែលមានន័យជាការញ៉ាំងអំពើ ដោយប្រើព្យញ្ជនៈធ្មេញ (ទន្តជៈ) គេឃើញមានផ្នត់ដើម [to-] ក្នុងភាសាបាហ្នា ផ្នត់ដើម [ta-] ក្នុង ភាសាកាទូ និងភាសាប៉ាកុះ។ ផ្នត់ដើមញ៉ាំងអំពើដោយប្រើព្យញ្ជនៈបំពង់ក គេឃើញមានផ្នត់ដើម [ka-] ក្នុងភាសាកាទូ និងភាសាមន។ ផ្នត់ដើមដែលមានន័យបដិការ ឬបង្ហាញពីសកម្មភាពរួម ឬទាក់ទងគ្នាដោយប្រើព្យញ្ជនៈធ្មេញ គេឃើញមានផ្នត់ដើម [to-] ក្នុងភាសាបាហ្នានិងកាទូ ផ្នត់ដើម [ta-] ក្នុងភាសាសេដាង ផ្នត់ដើម [tar-] ក្នុងភាសាបាកុះ។ ផ្នត់ដើមដែលបង្ហាញសកម្មភាពអកម្ម ដោយប្រើព្យញ្ជនៈធ្មេញ គេឃើញមានផ្នត់ដើម [to-] ក្នុងភាសាបាហ្នា និងភាសាកាទូ ផ្នត់ដើម [ti-] ក្នុងភាសាប៉ាកុះ។ ចំពោះផ្នត់ដែក ឃើញមានផ្នត់ដែកសំខាន់ៗមួយចំនួនដូចជា ផ្នត់ដែកសម្គាល់វត្ថុដោយប្រើព្យញ្ជនៈធ្មេញ (ផ្នត់ដែក [-on-] ក្នុងភាសាបាហ្នា ស្ទៀង ផ្នត់ដែក[-m-] ក្នុងភាសាឃ្មូ ផ្នត់ដែក [-an-] ក្នុងភាសាប៉ាកុះ ផ្នត់ដែក [-on-] ក្នុងភាសាសេដាង ផ្នត់ដែក [-ɒm/n-] [-ɒn-] ក្នុងភាសាខ្មែរ)។ ផ្នត់ដែកសម្គាល់អ្នកធ្វើសកម្មភាព ឬអំពើដោយប្រើព្យញ្ជនៈបបូរមាត់ (ផ្នត់ដែក [-ɒm-] ក្នុងភាសាខ្មែរ ផ្នត់ដែក [-m-] ក្នុងភាសាឃ្មូ)។ មានការបាត់បង់ស្ទើរតែទាំងអស់នូវប្រព័ន្ធផ្នត់នៅក្នុងភាសាជាច្រើន ជាពិសេសក្រុមភាសាបាហ្នាខាងត្បូង។ នៅក្នុងភាសាខ្លះ ជាឧទាហរណ៍ ភាសាខ្មែរជាដើម គេឃើញថា ប្រព័ន្ធផ្នត់មិនបានទទួលការលូតលាស់ឡើងទេ គឺរក្សាផ្នត់ពីមុនមកដដែល។ ក្នុងគ្រប់ភាសាទាំងអស់ គេឃើញថា មានការប្រើប្រាស់ប្រព័ន្ធផ្នត់ ក្នុងកម្រិតតិចតួចបំផុត ហើយផ្នត់ទាំងនោះមានន័យមិនច្បាស់លាស់ ឬក៏គ្មានន័យទាំងស្រុងតែម្តង។ ជាទូទៅ គេយល់ថា ប្រព័ន្ធផ្នត់ទាំងនេះជាសំណល់នៅក្នុងភាសាតាំងពីសម័យបុរាណមកម្ល៉េះ ដែលក្នុងសម័យនោះ ភាសាមានការរីកចម្រើនជាងសម័យបច្ចុប្បន្ន ប៉ុន្តែការអះអាងនេះ នៅជាបញ្ហាប្រទាំងប្រទើសនៅឡើយ។ ក្នុងភាសាមួយចំនួនទៀត គេសង្កេតឃើញថានៅមានប្រើប្រាស់ការស្ទួនពាក្យក្នុងកម្រិតច្រើន ឬតិចតួចដែរ។

ក្នុងភាសាមន-ខ្មែរបុរាណគ្មានការផ្លាស់ប្តូរទម្រង់ពាក្យទេ។ ទំនាក់ទំនងពាក្យក្នុងសម្ព័ន្ធ គេឃើញមានការគោរពលំដាប់ពាក្យ និងពាក្យជំនួយ។ ក្នុងភាសាមួយចំនួនអាចនឹងមានការបែងចែកជាថ្នាក់ពាក្យដោយផ្អែកលើការផ្សំកិរិយាជំនួយ និងធាតុជំនួយដទៃទៀត។ ក្នុងភាសាមួយចំនួនមានការខុសគ្នារវាងបម្រាប់ប្រធាន និងនាម ដោយសារតែនាមមិនអាចដើរតួជាបម្រាប់ប្រធានបានទេ ប្រសិនជាគ្មានបន្សំនឹងធាតុជំនួយ។ បម្រាប់ប្រធានចែកចេញជាពីរថ្នាក់ធំៗ គឺកិរិយាសព្ទនិងគុណនាម។ បម្រាប់ប្រធានក្នុងកម្រិតថ្នាក់ទី១ អនុញ្ញាតឱ្យឈ្មោះមានទម្រង់ទ្វេអង្គ។ ចំពោះបម្រាប់ប្រធានលំដាប់ទី២ មិនតម្រូវឱ្យមានទម្រង់ឈ្មោះទ្វេអង្គនេះទេ។ ឧទាហរណ៍ ក្នុងការនិយាយភាសាខ្មែរ គេអាចនិយាយបានថា «*នាងកញ្ញាសរសោរ*» តែមិនអាចនិយាយថា «*នាងកញ្ញាស្អាត*» នោះទេ ក្នុងករណីនេះទាល់តែថែមធាតុជំនួយ «នេះ» ថែមទៀត «*នាងកញ្ញានេះស្អាត*» ឬអាចប្រើធាតុជំនួយដទៃទៀត ដើម្បីពង្រីកទម្រង់ឈ្មោះ។ នៅក្នុងភាសាមួយចំនួន គេមិនប្រើធាតុជំនួយនោះទេ។ ចំពោះសម្ព័ន្ធវិទ្យា ជាទូទៅ ទម្រង់ឈ្មោះទោលមានទម្រង់ជា ប្រធាន + កិរិយាសព្ទ + កម្មបទ (ឡុង សៀម,២០០០)។

## ២. លក្ខណៈនៃបម្រែបម្រួលភាសា

បម្រែបម្រួលភាសា គឺមានទាំងភាពច្បាស់លាស់និងភាពអាថ៌កំបាំង។ ជាក់ស្ដែងភាសាខ្មែរសម័យបុរាណ សម័យកណ្ដាល គឺមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីភាសាខ្មែរទំនើប។ វាពិបាកយល់ ប្រសិនបើគ្មានការបង្ហាញឬការបណ្ដុះបណ្ដាលពិសេសណាមួយ ឧទាហរណ៍ ភាសាខ្មែរសម័យបុរាណក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ ដែលបរិយាយអំពីសម្បថរបស់ «តម្រួច» គ្រប់ជាន់ថ្នាក់ ដែលចារនៅឆ្នាំ១០១១នៃគ.ស. ហើយសិលាចារឹកនេះចុះលេខ K292 មានសេចក្ដីដូចតទៅ៖

៩៣៣ សក នវមី កេត ភទ្របទ អាទិត្យវារ ០ នេះ គិ ពោះ វទ្ធប្រតិជ្ញា ០ យេង ត អំបាល នេះ នា ភាគ តម្រាច ឯក (ទោ ត្រីណិ សត្វារិ) ស្បង ត សបថវេលា កាត តៃ ថ្វាយ អាយុះ នុ ក្រិតជ្ញកក្តិ យេង ត សុទ្ធ ត ធូលិ ជ្រះ បាទ កម្រតេង កំត្វន អញ ស្រីសូរយ្យវម៌្មទេវ ត សកល ស្វេយ ជ្រះ ធម៌្មរាជ្យ នុ ៩២៤ សក ផ្ទេក និ ត ជ្រះ វ្លេង ជ្រះ រត្ន នុ វ្រាម ណាចាយ៌្យ ០

### ប្រែសម្រួលជាភាសាខ្មែរទំនើប៖

មហាសករាជ ៩៣៣ (គ.ស. ១០១១) ប្រាំបួនកើត ខែភទ្របទ ថ្ងៃអាទិត្យ នេះ គឺជាសម្បថរបស់យើងទាំងអស់គ្នា ដែលនៅភាគតម្រួចឯក (ឬ ទោ ត្រី ចត្វា) វេលាសម្បថនេះ យើងសូមកាត់ដៃ ថ្វាយជីវិតដោយភក្ដីដ៏បរិសុទ្ធរបស់យើង ចំពោះព្រះបាទសម្ដេចស្រីសូរ្យវម៌្មទេព ដែលព្រះអង្គបានសោយរាជ្យពេញលក្ខណៈ ពីឆ្នាំ៩២៤ មហាសករាជ (គ.ស. ១០០២)។ យើងសូមធ្វើសម្បថ ចំពោះមុខភ្លើង ព្រះរតនៈ និងព្រាហ្មណាចារ្យទាំងអស់។

ចំណែកឯភាសាខ្មែរសម័យអាណានិគមបារាំងវិញ ក៏មានសំណេរនិងការអានខុសប្លែកពីភាសាខ្មែរបច្ចុប្បន្នដែរ ឧទាហរណ៍ ឯបារាំងសែសដែរលើកទាព់ទៅច្បាំងនិងស្ដេច់យួននោះ បើអ្នកទាំងហ្លាយ្យពុំដឹងជាហេតុដើមទងដូចម្ដេច់នោះ ខ្ញុំនិងអធបា្យព្យដំណេរជូនស្ដាប...។

តាមរយៈឧទាហរណ៍ខាងលើ បញ្ហាដែលបង្កើតឱ្យមានភាពខុសគ្នាទាំងនេះ គឺដោយសារការផ្លាស់ប្ដូរមុននិងក្រោយនៃភាសា ដូច្នេះក៏មានសំណួរដែលថា តើភាសាមានបន្លាស់ប្ដូរយ៉ាងម៉េច? ហេតុអ្វីបានជាភាសាមានបន្លាស់ប្ដូរតាមរយៈកាលដូចនេះ? គ្រប់ភាសាទាំងអស់ទទួលបន្លាស់ប្ដូរពីសម័យកាលមួយទៅសម័យកាលមួយ។ តាមការសិក្សាស្រាវជ្រាវអំពីឯកសារដែលបានកត់ត្រាកន្លងមក យើងឃើញថាភាសាខ្មែរមានការវិវត្តបីលើកធំៗ។ ទី១ ភាសាខ្មែរបុរាណ គឺចាប់តាំងពីកំណើតមកដល់សតវត្សទី១៥។ ទី២ ភាសាខ្មែរកណ្ដាល គឺចាប់តាំងពីសតវត្សទី១៦ដល់សតវត្សទី១៩។ ទី៣ ភាសាខ្មែរទំនើប គឺចាប់តាំងពីសតវត្សទី១៩ដល់បច្ចុប្បន្ន។

## ២.១. ភាពជាប្រព័ន្ធនៃបម្រែបម្រួលភាសា

ជាទូទៅភាពពិតនៃបម្រែបម្រួលភាសា មានលក្ខណៈប្រព័ន្ធនិងភាពទៀងទាត់របស់វា។ បម្រែបម្រួលភាសាខ្លះអាចមានបម្រែបម្រួលប្រធាន កិរិយាសព្ទ និងកម្មបទ។ ឧទាហរណ៍នៅក្នុងភាសាអង់គ្លេស គឺមានកិរិយាសព្ទតិចតួចដែលមិនទទួលឥទ្ធិពលនៃបម្រែបម្រួលលំដាប់ពាក្យ។ នៅគ្រប់កិរិយាសព្ទទាំងអស់ក្នុងភាសាអង់គ្លេសទំនើប គឺឈរនៅមុខកម្មបទផ្ទាល់។ ស្រដៀងគ្នានេះដែរ ឥទ្ធិពលបន្លាស់ប្ដូរស្រៈនៅក្នុងពាក្យ hām គឺមានឥទ្ធិពលមិនត្រឹមត្រូវតែទៅលើពាក្យនោះប៉ុណ្ណោះ វាបង្ហាញនូវកំណើតឡើងយ៉ាងទៀងទាត់នៃស្រៈ ā /a:/ នៃភាសាអង់គ្លេសបុរាណ (Old English) ឧទាហរណ៍ ឥទ្ធិពលនៃបន្លាស់ប្ដូរស្រៈភាសាអង់គ្លេសបុរាណ ā /a:/

| Old (បុរាណ) | Middle (កណ្ដាល) | Modern (ទំនើប) | |
|---|---|---|---|
| /ba:t/ | /bɔ:t/ | /bowt/ | "boat" (ទូក) |
| /a:ϴ / | /ɔ:ϴ / | /owϴ / | "oath" (សម្បថ) |
| /sta:n/ | /stɔ:n/ | /stown/ | "stone" (ថ្ម) |

## ២.២. មូលហេតុនៃបន្លាស់ប្តូរភាសា

បម្រែបម្រួលភាសា គឺមិនអាចគេចផុតបានទេ ដោយសារតែរបៀបដែលភាសាបន្តពីជំនាន់មួយទៅជំនាន់មួយ។ កុមារមិនអាចចាប់ផ្តើមរៀនវេយ្យាករណ៍ទាំងស្រុងនៃភាសាមួយបានទេ ប៉ុន្តែគេត្រូវសិក្សាវេយ្យាករណ៍ផ្អែកលើមូលដ្ឋានគ្រឹះនៃទិន្នន័យដែលពួកគេបានជួបប្រទះ។ នៅក្នុងស្ថានភាពដូចនេះ ភាពខុសគ្នាកម្រកើតមានណាស់ពីជំនាន់មួយទៅជំនាន់មួយ ទោះបីជាមានវេយ្យាករណ៍លម្អិតក៏ដោយ។ លើសពីនេះទៀត ដោយសារតែកុមារប្រើប្រាស់សរីរៈនិងការរីកចម្រើនផ្អែកកម្រិតបញ្ញាដូចគ្នាក្នុងភាសាក៏ដោយ វាត្រូវបានគេរំពឹងថាគំរូដូចគ្នានៃបន្លាស់ប្តូរនឹងកើតមានឡើងនៅគ្រប់ភាសាទាំងអស់។ នេះជាការសង្ខេបនៃមូលហេតុនៃបម្រែបម្រួលភាសាដែលមានដូចជាភាពដូចគ្នានៃការបញ្ចេញសំឡេង ការប្រកបពាក្យ ទំនាក់ទំនងភាសា ដំណួច និងការបង្កើតឡើងវិញ។

## ២.៣. ភាពទៀងទាត់នៃបម្រែបម្រួលសូរសំឡេង

អាមេរិកខាងត្បូងជាទឹកដីដែលមានគ្រាមភាសាជាច្រើននៃភាសាអង់គ្លេសបែបអាមេរិក ជាក់ស្តែងដូចជាការបញ្ចេញសំឡេងពាក្យជាស្រៈផ្សំ /aj/ នៃភាសាអង់គ្លេស ជាធម្មតាបញ្ចេញសំឡេង /a:/ នៅអាមេរិកខាងត្បូង។ បណ្តាញផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ក្នុងកីឡាអូឡាំពិក ឆ្នាំ១៩៩៦ នៅ អាត់ឡង់តា (Attlanta) បានហៅអត្តពលករលោតកម្ពស់ថា «hight jump» ទៅជា «ha: jump» ហើយជនជាតិក្នុងស្រុកនោះបានអញ្ជើញគណៈប្រតិភូទៅសាកគ្រប់ផ្លែឈើដ៏ល្បីល្បាញនៅប្រទេសហ្សកហ្ស៊ី (Georgia) គឺផ្លែ pie /paj/ ហើយគេបានបញ្ចេញសំឡេងថា /pa:/។ ការឆ្លើយតបសូរសំឡេង /aj/ > /a:/ នៃគ្រាមភាសាពីរនេះ គឺជាឧទាហរណ៍នៃការឆ្លើយតបសំឡេងដ៏ទៀងទាត់។ នៅពេលសូរ /aj/ មាននៅក្នុងគ្រាមភាសាដែលមិនមែនជាភាសាអាមេរិកខាងត្បូង នោះសូរ /a:/ មាននៅក្នុងគ្រាមភាសាអាមេរិកខាងត្បូង ហើយវាត្រឹមត្រូវគ្រប់ពាក្យទាំងអស់។

## ២.៤. ការឆ្លើយតបនៃសូរសំឡេង

ភាសាអង់គ្លេសសម័យកណ្តាល ពាក្យ /mouse/ អានថា /mu:s/ ហើយសូរសំឡេង /mu:s/ អាចរស់នៅក្នុងពាក្យ /hu:s/ ក្លាយទៅជា house /haws/ សព្វថ្ងៃ។ ជាទូទៅអ្នកនិយាយភាសាអង់គ្លេសនៅសម័យកណ្តាលបញ្ចេញសំឡេង /u:/ គ្រប់សព្ទទាំងអស់បញ្ចេញសំឡេង /aw/។ នេះជាការឆ្លើយតបដ៏ទៀងទាត់ដូច /aj/ > /a:/។ ដូច្នេះសំឡេង /out/ ត្រូវបានបញ្ចេញសំឡេង /u:t/ ដូចជាពាក្យថា south /sawɵ/ បញ្ចេញសំឡេង /su:ɵ/ ជាដើម។ ការឆ្លើយតបសូរសំឡេងទៀងទាត់យ៉ាងច្រើន បង្ហាញពីការពាក់ព័ន្ធរវាងទម្រង់ចាស់និងទម្រង់ថ្មី។

ការឆ្លើយតបសំឡេងដ៏ទៀងទាត់ គេឃើញកើតមានរវាងទម្រង់ចាស់និងទម្រង់ថ្មីនៃភាសា នៅពេលមានបម្រែបម្រួលសទ្ទតា ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់សូរសំឡេងបុរាណជាងសូរនៃពាក្យរបស់វាផ្ទាល់។ ជាច្រើនសតវត្សមកហើយ ភាសាអង់គ្លេសទទួលការប្រែប្រួលសទ្ទតា ដែលគេហៅថា បម្រែបម្រួលឬបន្លាស់ប្តូរនៃសូរសំឡេង (sound shift) ដូចជា /u:/ ទៅជា /aw/។

បម្រែបម្រួលនៃសទ្ទតា អាចបង្ហាញពីភាពខុសប្លែកគ្នានៃគ្រាមភាសាផងដែរ។ នៅដំណាក់កាលដំបូងនៃបម្រែបម្រួលសូរសំឡេងនៃស្រៈ /aj/ > /a:/ នៃភាសាអង់គ្លេសបែបអាមេរិកបានកើតឡើងតែចំពោះអ្នកនិយាយនៅតំបន់នេះ។ បម្រែបម្រួលមិនបានលាតសន្ធឹងទៅឆ្ងាយទេ ព្រោះតំបន់នេះនៅឆ្ងាយដាច់ពីគេ។

គ្រាមភាសាខុសប្លែកគ្នាតាមតំបន់ អាចកើតឡើងផងដែរនៅពេលបម្រែបម្រួលកើតឡើងគ្រប់ទីកន្លែង ប៉ុន្តែនៅក្នុងតំបន់មួយច្បាស់លាស់។ គ្រាមភាសាតំបន់អាចជាប់ទាក់ទងនឹងភាពដើមនៃគ្រាមភាសាដទៃទៀត។

## ៣. បម្រែបម្រួលខាងសូរសំឡេង

ទោះបីជាគ្រប់ធាតុវេយ្យាករណ៍ងាយប្រែប្រួលតាមរយៈកាល ប៉ុន្តែគំរូខ្លះនៃបម្រែបម្រួលនាំមកនូវលទ្ធផលច្បាស់លាស់។ បម្រែបម្រួលនិងបន្លាស់ប្តូរ គឺអាចកំណត់បានយ៉ាងច្បាស់នៅក្នុងសទ្ទតាវិទ្យានៃភាសា។ គំរូទូទៅនៃបន្លាស់ប្តូរភាសា អាចត្រូវបង្ហាញយ៉ាងច្បាស់លាស់។ បម្រែបម្រួលសំឡេងភាគច្រើន គឺផ្តើមដោយបន្លាស់ប្តូរនៅក្នុង

បរិការណ៍សូរទៀងទាត់។ មូលដ្ឋាននៃដំណើរការភាសាវិទ្យា ដូចជាបម្រែបម្រួលសំឡេងមានលក្ខណៈសូរវិទ្យាដែលជាកម្មវត្ថុនៃអ្នកនិយាយភាសានៅពេលបច្ចុប្បន្ន។ ការឆ្លើយតបជាទូទៅនៃដំណើរការបង្ហាញឱ្យឃើញភាពដូចគ្នានៃការបញ្ចេញសំឡេង និងបម្រែបម្រួលសំឡេងតាមរយៈកាល នៅក្នុងសទ្ទតាវិទ្យា។

ទោះបីជាគ្រប់ទិដ្ឋភាពទាំងអស់ដែលមានដូចជា ការលើកដាក់សំឡេង ការសង្កត់សំឡេង និងរចនាសម្ព័ន្ធព្យាង្គជាដើម សុទ្ធតែជាកម្មវត្ថុនៃបម្រែបម្រួលភាសាពីសម័យមួយទៅសម័យមួយ។ លើសពីនេះទៅទៀត ភាគច្រើននៃបម្រែបម្រួលសូរសំឡេង ជាទូទៅទាក់ទងទៅនឹងកំណាត់ពាក្យ (segment) ដែលផ្តោតជាសំខាន់លើបន្លាស់ប្តូរលំដាប់ (sequential) នៃព្យាង្គនៅក្នុងពាក្យ។ កំណាត់ពាក្យ (segment) និងការបញ្ចេញសំឡេង ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានបម្រែបម្រួលភាសា។ បម្រែបម្រួលអាចមកពីកត្តាអ្នកស្តាប់ផងដែរ។

**៣.១. បម្រែបម្រួលសូរស្រៈ**

លោក អង់ដ្រេ អូដ្រីគួរ (A. Haudricourt) និង អង់ដ្រេ ម៉ារទីណេ (A. Martinet) បានសរសេរថា នៅក្នុងពេលដែលភាសាថៃ ចាប់ផ្តើមកើតមានគុង ឬស្នៀង នៅក្នុងភាសាខ្មែរចំនួនស្រៈ គឺកើនឡើងទ្វេ និងបើគិតអំពីកម្រិតសម្បូរបែបនៃប្រព័ន្ធស្រៈវិញ ភាសាខ្មែរគឺជាភាសាមួយក្នុងចំណោមភាសា ដែលគេចាត់ទុកថា ជាភាសាសម្បូរបែបខាងសំណួរស្រៈក្នុងលោក។ ប្រសិនបើការអះអាងនេះជាការត្រឹមត្រូវនោះ គេអាចធ្វើការសន្និដ្ឋានថា ភាពសម្បូរបែបនៃស្រៈខ្មែរ គឺស្ថិតនៅត្រង់ថា វាមានសេរីពីរ គឺសេរីបិទ និងសេរីបើក។ ជាញឹកញាប់ណាស់ ស្រៈទាំងពីរសេរីនេះ មានទំនាក់ទំនងខាងសំណួរនិងន័យរវាងគ្នានិងគ្នាជាញឹកញាប់នៅក្នុងភាសាខ្មែរ។ វាមានពាក្យមួយចំនួនដែលខុសគ្នាដោយសារគុណភាពស្រៈ និងមានន័យស្រដៀងគ្នា ហើយដែលគេសន្និដ្ឋានថា ចេញពីឫសតែមួយ។

កំណកំណើតពាក្យខ្មែរមួយចំនួនធំបានប្រព្រឹត្តឡើងតាមបន្លាស់ប្តូរសំណួរ ឬក៏តាមវិធីបន្លាស់ប្តូរសំណួរ ឧទាហរណ៍៖ តន់ - ទន់, ចប់ - ឈប់, ប៉ោង - ពងឬចង់, តួង - ទូង, ចាប់ - ជាប់, ចុក - ជុក, តោង - ទោង...។ តាមឧទាហរណ៍នៃពាក្យទាំងពីរបែបនេះ យើងអាចសន្និដ្ឋានអំពីវត្តមាននៃទំនាក់ទំនងន័យដែលបង្កើតឡើងដោយទំនាក់ទំនងរវាងស្រៈទាំងឡាយនេះ គឺ អ-អ៊ អា-អ៊ា អូ-អ៊ូ អុ-អ៊ុ អោ-អ៊ោ។

ក្នុងបច្ចុប្បន្នកាលនេះ ដោយសារវត្តមាននៃសូរវិទ្យាប្រវត្តិសាស្ត្រនៃភាសាខ្មែរ គេមិនអាចអះអាងបានទេអំពីមតិមួយចំនួនដែលថា ស្រៈបើក បង្កើតស្រៈបិទ ព្រោះថា តាមការសិក្សាប្រៀបធៀបពាក្យខ្មែរបុរាណ និងពាក្យខ្មែរសម័យថ្មីអាចឱ្យគេរកឃើញដំណើរវិវត្តន៍ប្រាសមកវិញដែរ ឧទាហរណ៍ បញ - បាញ់, កច - កាច់, វ្រច - ព្រេច, បិង - បឹង, ស្លិក - ស្លឹក, អំវិ - អំពី, គិ - គឺ, កេត - កើត, ជេង - ជើង, តោង - ដូង...។

**៣.២. បម្រែបម្រួលព្យញ្ជនៈ**

យើងបានសង្កេតឃើញរួចមកហើយថា បម្រែបម្រួលគឺមានមិនត្រឹមតែស្រៈប៉ុណ្ណោះទេ តែក៏មានចំពោះព្យញ្ជនៈដែរ។

**ក. ការជំនួសព្យញ្ជនៈក្រអូម «ច» ដោយព្យញ្ជនៈបង្គួរ «ស»**

បម្រែបម្រួលនេះ គេសង្កេតឃើញមាននៅក្នុងពាក្យមួយចំនួនខាងក្រោមនេះ៖

ពាក្យខ្មែរបុរាណ «ធី» ពាក្យខ្មែរសម័យ «ស៊ី»

ពាក្យខ្មែរបុរាណ «ចាយ» ពាក្យខ្មែរសម័យ «សាយ»

ពាក្យខ្មែរបុរាណ «ចឹ្មង» ពាក្យខ្មែរសម័យ «ស្មឹង»

គេអាចសង្កេតឃើញនៅក្នុងពាក្យជាច្រើនក្នុងភាសាខ្មែរទំនើប ដូចជា៖

| | | | | | |
|---|---|---|---|---|---|
| ច្រូង | - | ស្រោង | ជ្រាវ | - | ស្រាវ |
| ច្រូច | - | ស្រោច | ប្រាញ | - | ស្រាញ |

ទំនាក់ទំនងរវាងព្យញ្ជនៈខ្យល់ «ច» និង«ស» ត្រូវបានរក្សាទុកនៅក្នុងភាសាខ្មែរ នៅតំបន់ខ្លះនៃខេត្តតាកែវ ដែលនៅទីនេះ មានរាជធានីចាស់អង្គរបុរី។

**ខ. ការជំនួសព្យញ្ជនៈ «ច» ដោយពាក្យកណ្ដាលស្រះ «យ»**

បម្រែបម្រួលនេះអាចរកឃើញដោយវិធីសិក្សាប្រៀបធៀបពាក្យឫស ដែលផ្ដើមឡើង ដោយព្យញ្ជនៈក្រអូម «ច» នៅក្នុងភាសាបាឌ្នា ក្យូល-ក្យូល ខ្យល់ ភាសាខ្មែរគឺពាក្យខ្ចោលខ្ចោល និងពាក្យខ្យល់។ នៅក្នុងភាសាខ្មែរ «ខ្ចោល» មានកំណើតចេញពីពាក្យ «យោល» ដោយផ្សំជាមួយនឹងផ្នត់ដើម «ក» ដែលផ្ដល់ន័យបន្ថែម «ចលនាសកម្ម»។

**គ. បម្រែបម្រួលព្យញ្ជនៈ «ម» ទៅជា «ង»**

បម្រែបម្រួលបែបនេះ ច្រើនកើតមានឡើងនៅក្នុងវិធីសម្របសម្រួលពាក្យកម្ចីពីសំស្ក្រឹត ឬបាលីមកភាសាខ្មែរ ជាពិសេសគឺមានចំពោះព្យញ្ជនៈចុងព្យាង្គនៃពាក្យទ្វេព្យាង្គ។ ឧទាហរណ៍ ពាក្យសំស្ក្រឹត hamsa នៅក្នុងភាសាខ្មែរក្លាយទៅជា «ហង្ស»។ នៅក្នុងទេវកថា ភាសាសំស្ក្រឹត vamsa នៅក្នុងភាសាខ្មែរ «វង្ស» ហើយពាក្យ «ភ្នំ» ផ្ដល់កំណើតដល់ពាក្យ «ភ្នង» ឬ «ម្នង»។

**ឃ. ការជំនួសគ្នាទៅវិញទៅមករវាងព្យញ្ជនៈ «ញ» និង «ង»**

យើងលើកយកពាក្យ «រឹង» និងពាក្យ «វិញ» មកពិនិត្យ។ ពាក្យ «រឹង» អាចចាត់ទុកជា ពាក្យដំបូង ឬពាក្យដើម ពីព្រោះពាក្យនេះមានតាំងពីយូរយារណាស់មកហើយនៅក្នុងអត្ថបទប្រៀនប្រដៅ (អប់រំ) ខ្មែរក្នុងសម័យបុរាណ។ ឧទាហរណ៍ នៅក្នុងល្បះមួយថា «រក្សាទៅមករឹង» មានន័យថា «ចូរជួយគ្នាទៅវិញទៅមក»។ នៅក្នុងបច្ចុប្បន្នកាលនេះ ពាក្យ «រឹង» មានន័យថា «មួយរំពេច» ឬ «មួយភ្លែត» រីឯពាក្យ «វិញ» មានន័យថា «(សកម្មភាព) ទៅមក» «ផ្ទួន»។

ប៉ុន្តែយើងអាចសន្និដ្ឋានថា ពាក្យ «ខ្លោញ» និងពាក្យ «ក្លោង» មានដំណើរច្រាសមកវិញ គឺព្យញ្ជនៈ «ញ» ក្លាយមកជា «ង» វិញ។ ពាក្យ «ខ្លោញ» មានជាតឹកតាងនៅក្នុងសិលាចារឹក ហើយមានន័យថា «ប្រធាន» «មេ» សម្រាប់ហៅ រាជមន្ត្រី។ ពាក្យកម្លាយចេញពីពាក្យ «ខ្លោញ» នេះគឺជាពាក្យ «ក្លោង» រក្សាន័យបុរាណរបស់ខ្លួននៅក្នុងពាក្យ «មេក្លោង» ប៉ុន្តែម្យ៉ាងវិញទៀត គេប្រើពាក្យ«ក្លោង» នៅក្នុងសមាសភាពនៃពាក្យ «ក្លោងទ្វារ» ដែលមានន័យតែនៅក្នុងការហៅ ផ្នែកខាងលើនៃរោងថែវទទឹងទ្វារប៉ុណ្ណោះ។ ជាទូទៅ គេសង្កេតឃើញថា ខ្យល់ព្យញ្ជនៈ /ង/ រមែង ផ្លាស់ប្ដូរទៅជាខ្យល់ព្យញ្ជនៈ /ញ/ នៅចុងព្យាង្គនៃពាក្យ។

ចំពោះភាសាខ្មែរបច្ចុប្បន្នមានលក្ខណៈពិសេសដូចជា ប្រសិនបើព្យញ្ជនៈប្រកប «ង» នៅខាងក្រោយស្រះ «អ៊ី» ឬ «អេ» វានឹងក្លាយទៅជា «ញ» វិញ។ ឧទាហរណ៍ រីង មីង លីង របេង គេង លេង។ល។

**ង. ការឆ្លងកាត់ព្យញ្ជនៈ «វ» ទៅជា «ព» ឬ «ភ» និង «ផ»**

បម្រែបម្រួលនេះ គេសង្កេតឃើញសឹងតែទូទៅនៅក្នុងពាក្យខ្មែរបុរាណ ដែលក្លាយមកជា ពាក្យខ្មែរសម័យបច្ចុប្បន្ន៖

| ភាសាខ្មែរបុរាណ | ភាសាខ្មែរសម័យបច្ចុប្បន្ន | ភាសាខ្មែរបុរាណ | ភាសាខ្មែរសម័យបច្ចុប្បន្ន |
|---|---|---|---|
| អំវិល | អំពិល | វ្រៃ | ព្រៃ |
| វ្រះ | ព្រះ | វេល | ពេល |
| វុំ | ពុំ | វ្នែក | ភ្នែក |
| វ្លាស | ផ្លាស់ | វ្ទូ | ផ្ទូរ |

រីឯពាក្យកម្ចីពីភាសាសំស្ក្រឹត ក៏មានបម្រែបម្រួលដូចគ្នានេះដែរ៖

| សំស្ក្រឹត | ភាសាខ្មែរសម័យបច្ចុប្បន្ន | សំស្ក្រឹត | ភាសាខ្មែរសម័យបច្ចុប្បន្ន |
|---|---|---|---|
| កម្វជ | កម្ពុជា | វណ៌ | ពណ៌ |
| វុធៈ | ពុធ | វាក្យ | ពាក្យ |
| វិធិ | ពិធី | វេលៈ | ពេល |
| វ្យាករណៈ | ព្យាករណ៍ | វ្យាយាមៈ | ព្យាយាម |

**ច. បម្រែបម្រួលព្យញ្ជនៈឮស្អះ ទៅជាព្យញ្ជនៈថ្លង់**

នៅក្នុងភាសាខ្មែរ គេសង្កេតឃើញមានបម្រែបម្រួលព្យញ្ជនៈឮស្អះ ទៅជាព្យញ្ជនៈថ្លង់។ បម្រែបម្រួលនោះមានឥទ្ធិពលខ្លាំងទៅលើប្រព័ន្ធសទ្ទតាខ្មែរទាំងមូល។ បញ្ហានេះត្រូវ លោក អង់ដ្រេ អូដ្រីគួរ (A. Haudricourt) និង លោក អង់ដ្រេ ម៉ារទីណេ (A. Martinet) បានធ្វើការកត់សម្គាល់ថា នៅក្នុងភាសាខ្មែរនិងភាសាមន បម្រែបម្រួលប្រព័ន្ធព្យញ្ជនៈស្អះ ឃោសៈទៅជា ព្យញ្ជនៈអឃោសៈ គឺជាឥទ្ធិពលសូរវិទ្យាទៅវិញទៅមកនៃបម្រែបម្រួលប្រព័ន្ធព្យញ្ជនៈ ជាទូទៅ។ នៅក្នុងភាសាថៃ ដែលក្នុងនោះ ដំណើរនេះប្រព្រឹត្តទៅដោយឆ្លងកាត់ការបញ្ចេញខ្យល់បំណិត ឧទាហរណ៍ ប > ផ > ព។ នៅក្នុងភាសាបាហ្នារ (ភាសាមន-ខ្មែរ) ដែលនៅដាច់តែឯង នៅលើភ្នំអណ្ណាម ផ្នែកខាងត្បូងបម្រែបម្រួលនេះគ្មានឡើយ។

នៅក្នុងការវិភាគបាតុភូតបែបនេះ នៅក្នុងភាសាខ្មែរ គួរកត់សម្គាល់លក្ខណៈពិសេស សំខាន់ៗមួយចំនួនដូចតទៅ៖

បម្រែបម្រួលព្យញ្ជនៈឃោសៈ (ឮស្អះ) បុរាណ នាំឱ្យកើតមានព្យញ្ជនៈអឃោសៈ មានដូច តទៅ ប៉ុន្តែធ្វើឱ្យបាត់បង់ព្យញ្ជនៈឃោសៈសំខាន់ៗដូចជាព្យញ្ជនៈ គ/g/ និង ជ/c/ ជាដើម។

| ភាសាខ្មែរបុរាណ | ភាសាខ្មែរបច្ចុប្បន្ន | ភាសាខ្មែរបុរាណ | ភាសាខ្មែរបច្ចុប្បន្ន |
|---|---|---|---|
| គ /g/ | ក/k/ | ជ/j/ | ជ/c/ |
| ទ/d/ | ទ/t/ | ព/b/ | ព/p/ |
| វ/v/ | ព/p/ | | |

កំណាកំណើតស្រៈបិទក៏ដូចជាស្រៈបើក។ នៅតាមឯកសារសិលាចារឹកសតវត្សទី១៣ គេមិនទាន់សង្កេតឃើញបាតុភូត នៃបម្រែបម្រួលរបស់ព្យញ្ជនៈឮស្អះណាមួយ ប្រែប្រួលទៅជាព្យញ្ជនៈថ្លង់ទេ។

ឧទាហរណ៍: «ពីរ» មានទម្រង់ដើម (គឺសម័យនគរភ្នំ) ជា «វេរ» «គោ» /go/ ជា «គោ» «នគរ» /nagara/ ជា «អង្គរ»។ បម្រែបម្រួលព្យញ្ជនៈឮស្អះទៅជាថ្លង់ បានប្រព្រឹត្តទៅក្នុងកំឡុងច្រើនសតវត្ស គឺអាចចាប់ផ្ដើមពីសម័យក្រោយអង្គរនាសតវត្សទី១៥មក ហើយទើបតែបញ្ចប់ពេញលេញនៅសតវត្សទី២០។ ប៉ុន្តែខ្យល់ព្យញ្ជនៈ «រ» ដ៏ខ្ទរខ្ទារ ជាសមាសភាពទី២នៃព្យញ្ជនៈ សំយោគ (ក្រ គ្រ ប្រ ជ្រ ត្រ ទ្រ ស្រ) និងជាព្យញ្ជនៈចុងព្យាង្គ ដូចជាក្នុងពាក្យ «ពីរ» «ខ្មែរ» ជាដើម បានត្រូវរក្សាទុកយ៉ាងខ្ជាប់ខ្ជួន ដោយសារភាសាខ្មែរអភិរក្ស មានជាពិសេសភាសាខ្មែរសុរិន្ទ្រនៅប្រទេសថៃ។

ឧទាហរណ៍៖

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| គេ | ge | > | គេ | /eː/ | គី | gi | > | គី | /kiː/ |
| គាប | gap | > | គាប | /kiɜp/ | គរោ | garrop | > | គ្រប | /krɔːp/ |
| គតិ | gati | > | ក្ដី | /kdɜj/ | គណៈ | gana | > | គ្នា | /kʰniɜ/ |
| កថា | kathā | > | ថា | /tʰaː/ | ជា | ja | > | ជា | /ciɜ/ |
| ជាតិ | jati | > | ជាតិ | /ciɜt/ | ជវា | javā | > | ជ្វា | /cwiɜ/ |
| ដារ | dar | > | ទារ | /tiɜ/ | អ្ហា | ada | > | ទា | /tiɜ/ |

វវេ wawe > ពពេ /pɔpɛː/ វល្វេល walwel > ពពិល /pɔpəl/

វេល wela > ពេល /peːl/

បម្រែបម្រួលព្យញ្ជនៈឃោសៈ (ឮស្ទះ) នាំឱ្យមានការបាត់បង់សទ្ទតា (ព្យញ្ជនៈ) មួយចំនួនធំ។ រីឯការបាត់បង់សទ្ទតានេះ ក៏នាំទៅកការបាត់បង់ពាក្យដំបូងៗមួយចំនួន ហើយការស្ដារនិងស្ថាបនាពាក្យទាំងនេះ នឹងអាចធ្វើទៅបានតាមវិធីប្រៀបធៀបទៅនឹងភាសាជិតខាងនានា និងភាសាដែលនៅក្នុងអម្បូរតែមួយ គឺភាសាក្នុងអម្បូរមន-ខ្មែរ។

ការប្រៀបធៀបពាក្យនៅក្នុងភាសាខ្មែរបច្ចុប្បន្ន អាចឱ្យគេរកឃើញនៅក្នុងឧទាហរណ៍ ពាក្យ «ភ្លោះ» ថា បម្រែបម្រួលនេះ ជះឥទ្ធិពលដល់ការបង្កើតពាក្យថ្មី។ ពាក្យផ្ដើមដោយព្យញ្ជនៈ «ដ» និង «ត, ទ» ដូចជា៖

| | | | | | |
|---|---|---|---|---|---|
| ដល់ /dɒl/ | - | ទល់ /tɔl/ | ដង /dɒːŋ/ | - | ទង /tɔːŋ/ |
| ដាក់ /dak/ | - | ទាក់ /tɛak/ | ដាប /daːp/ | - | ទាប /tiəp/ |
| ដ៏ /dɒ/ | - | ត /tɒː/ | ដី /dɜy/ | - | ទី /tiː/ |

ពាក្យផ្ដើមដោយព្យញ្ជនៈ «ប» /b/ និង «ព» «ប៉» /p/

| | | | | | |
|---|---|---|---|---|---|
| បត់ /bɒt/ | - | ពត់ /pɔt/ | បា /baː/ | - | ប៉ា /paː/ |
| បិច /bec/ | - | ប៉ិច /pec/ | បុះ /boh/ | - | ពុះ /puh/ |
| បូក /bɔok/ | - | ពូក /puːk/ | បូត /bɔot/ | - | ពូត /puːt/ |
| បែក /baɛk/ | - | ប៉ែក /paɛk/ | បោរ /baɔ/ | - | ពោរ /poː/ |
| បាំង /baŋ/ | - | ពាំង /pɛaŋ/ | | | |

ការសិក្សាពាក្យតាមវិធីប្រៀបធៀបសូរសព្ទ និងន័យរបស់វា ដើម្បីរកពាក្យភ្លោះនៅក្នុងភាសាខ្មែរបច្ចុប្បន្ន អាចប្រព្រឹត្តទៅបាន ព្រោះថា ព្យញ្ជនៈឮស្ទះនិងថ្លង់ស្ទះនៅតែកើតមានតទៅទៀត។ ឧទាហរណ៍ «ដ» និង «ត, ទ» «ប» និង «ព, ប៉»។ ហេតុដូច្នេះ ការស្រាវជ្រាវពាក្យដែលផ្ដើមដោយព្យញ្ជនៈស្ទះ ព្យញ្ជនៈបំពង់ក «ក» និង «ច» អាចប្រព្រឹត្តទៅបានដោយជោគជ័យ លុះត្រាតែគេធ្វើការប្រៀបធៀបពាក្យខ្មែរជាមួយនឹងពាក្យនៅក្នុងភាសាមន-ខ្មែរដទៃ ព្រោះថានៅក្នុងភាសាខ្មែរបច្ចុប្បន្ន គ្មានគូព្យញ្ជនៈឆ្លើយគ្នាដូចនេះទាំងអស់ទេ (គេអាចប្រៀបធៀបបានតែគូដែលមានស្រៈសេរីផ្សេងៗប៉ុណ្ណោះ។

## ៣.៣. វិធីសង្កត់សំឡេង

វិធីសង្កត់សំឡេង មានតួនាទីកំណត់មួយនៅក្នុងការផ្លាស់ប្ដូរសមាសភាពវចនសព្ទភាសាខ្មែរ ព្រោះថាវិធីសង្កត់សំឡេង មានទំនាក់ទំនងទៅនឹងបន្លាស់ប្ដូររូបភាពខាងក្រៅរបស់ពាក្យ។

អ្នកឯកទេសទាំងអស់បានបញ្ជាក់ថា វិធីសង្កត់សំឡេងនៅក្នុងភាសាខ្មែរ ជាទូទៅស្ថិតនៅលើព្យាង្គទី២នៃពាក្យទ្វេព្យាង្គ។

លោក ហ្សក សឺដែស (G. Coedes) បានហៅវិធីសង្កត់សំឡេងនេះថា ជាវិធីសង្កត់សំឡេងឱណាមិក ហើយយោងទៅតាមទ្រឹស្ដីរបស់ ប្រង់ ស្មែទែរ អំពីភាសាឥណ្ឌូនេស៊ី។ រីឯលោក ម៉ារទីនី (Martini) វិញ ឱ្យឈ្មោះថា «បន្សាយស្រៈព្យាង្គទី១»។

ការសង្កេតអំពីឥទ្ធិពលនៃវិធីសង្កត់សំឡេងទៅលើរចនាសម្ព័ន្ធសូរសព្ទ នៃពាក្យធ្វើទៅបានដោយការវិភាគការដាក់ផ្នត់។ ដូចជាដំណើរនៃការដាក់ផ្នត់ «លើកទី២» គឺស្ថិតនៅលើការឱ្យន័យថ្មី ឬមួយន័យបន្ថែម ដែលសម្ដែងសញ្ញាតនាដល់ពាក្យឯកព្យាង្គ ឬពាក្យចាស់មួយហួសសម័យ ឬពាក្យកម្លាយចាស់មានពីរព្យាង្គ។ ក្នុងនោះ ហេតុការណ៍នេះ ត្រូវបានអះអាងថា វិធីសង្កត់សំឡេង នៅលើព្យាង្គទីពីរនៃពាក្យកម្លាយ បន្សាយព្យាង្គទី១បន្តិចម្ដងៗនៅក្នុងពាក្យទ្វេព្យាង្គ។ ឧទាហរណ៍ កិរិយាស័ព្ទ «វាស់» បង្កើតបានជានាម«រង្វាស់» ដោយប្រើផ្នត់ដើម «អ ង»

ប៉ុន្តែដោយការប្រើប្រាស់ពាក្យជារៀងរាល់ថ្ងៃ ព្យាង្គទី១របស់ពាក្យ មានបម្រែបម្រួលជាពិសេសទៅលើស្រៈ «អ» នៅដើមព្យាង្គ ដោយមានការបញ្ចេញសំឡេង នៅបំពង់ក។ ពាក្យ «អង្វាស់» ដោយមានបម្រែបម្រួលសូរសព្ទក្លាយទៅជា «ង្វាស់» ជាពាក្យឯកព្យាង្គ។ បន្ទាប់មកទៀត គឺមានការដាក់ផ្នត់លើកទី២ គឺបន្ថែមផ្នត់ដើម «រ′ង» ក្លាយជា «រង្វាស់» គឺបន្ថែមកម្លាំងព្យាង្គទី១ ឧទាហរណ៍ វាស់ > អង្វាស់ > រង្វាស់។

នៅក្នុងពាក្យកម្លាយដែលមានពីរព្យាង្គ ក្នុងនោះព្យាង្គទី១ គឺជាផ្នត់ដើម បានសេចក្តីថា ជាធាតុមានន័យមិនពេញលេញរបស់ពាក្យនោះ ពាក្យទី២ជាពាក្យឫស។ នៅក្នុងភាសានិយាយ (សំនួននិយាយ) វិធីសង្កត់សំឡេង ជាទូទៅ បានធ្លាក់ទៅលើព្យាង្គទី២ គឺធ្លាក់ទៅលើធាតុរបស់ពាក្យ ដែលមានន័យពេញលេញ។ ជាលទ្ធផលចុងក្រោយ ពាក្យឫសខុសប្លែកពីផ្នត់ដើមក្នុងករណីភាគច្រើន គឺរក្សារចនាសម្ព័ន្ធសូរសព្ទរបស់ខ្លួន។ របៀបដូចគ្នានេះដែរ គឺប្រព្រឹត្តទៅក្នុងពាក្យសមាសមួយចំនួន ដែលក្នុងនោះ មានធាតុមួយមានសូរខ្សោយជាង។

ពេលនេះយើងនឹងលើកយកករណីមួយចំនួនដែលចាត់ទុកថា ជាផលវិបាកនៃឥទ្ធិពលការសង្កត់សំឡេងទៅលើទម្រង់ខាងក្រៅនៃពាក្យមកពិនិត្យ។ យើងចែកផលវិបាកនៃឥទ្ធិពលនេះជាពីរផ្នែកគឺ ផលវិបាកអវិជ្ជមាននិងផលវិបាកវិជ្ជមាន។

**ក. ផលវិបាកអវិជ្ជមាន**

ការសង្កត់សំឡេងក្នុងរយៈកាលជាច្រើនសតវត្ស បានធ្វើឱ្យមានផលវិបាករចនាសម្ព័ន្ធបុរាណ របស់ពាក្យមានបម្រែបម្រួល។ យើងបានរកឃើញថា ពាក្យខ្មែរបុរាណ អាចជាពាក្យឯកព្យាង្គនិងទ្វេព្យាង្គ។ ពាក្យទ្វេព្យាង្គជាធម្មតាច្រើនតែចាប់ផ្តើមពីព្យញ្ជនៈទោល (គ្មានក្រុម ព្យញ្ជនៈនៅខាងដើម)។ នៅទីតាំងខាងដើម អាចមានសូរស្វៈនៅបំពង់សំឡេង ដែលក្រោមឥទ្ធិពលនៃការសង្កត់សំឡេងក៏បាត់បង់ទៅ ទាំងនេះគឺនាំទៅរកការបាត់បង់ព្យាង្គទាំងមូល។

| ភាសាបាឡា | ភាសាខ្មែរ | | ភាសាបាឡា | ភាសាខ្មែរ | |
|---|---|---|---|---|---|
| ada: | ទា | /tiɜ/ | aka | ក | /kɒ:/ |
| akom | កុំ | /kom/ | apoŋ | ប៉ោង | /paɔŋ/ |
| atap | តប់ | /tɒp/ | acep | ចិប | /cep/ |
| anih | នេះ | /nih/ | | | |

ពាក្យទ្វេព្យាង្គមួយចំនួនក្នុងភាសាខ្មែរបុរាណ ក្រោមឥទ្ធិពលនៃការសង្កត់សំឡេងលើព្យាង្គ បានក្លាយទៅជាពាក្យឯកព្យាង្គ៖

| ពាក្យខ្មែរបុរាណ | | ភាសាខ្មែរបច្ចុប្បន្ន | | ពាក្យខ្មែរបុរាណ | | ភាសាខ្មែរបច្ចុប្បន្ន | |
|---|---|---|---|---|---|---|---|
| អនក | anak | អ្នក | /nɛak/ | អេស្រះ | aseh | សេះ | /sɛh/ |
| អ្មេ | ame | មេ(ម៉ែ) | /me:/ | អ្តា | ata | តា | /ta:/ |
| អំលោ | amlo | ម្លូ | /mlu:/ | បតៅ | patau | ផ្តៅ | /$p^h$daw/ |
| វិនៅ | winɔw | ញ្នៅ | /$p^h$nɔw/ | ករុង | karuŋ | ក្រុង | /kroŋ/ |
| បទះ | padah | ផ្ទះ | /$p^h$tɛah/ | ករោល | karol | ក្រោល | /kraɔl/ |
| គរោប | garop | គ្រប | /krɔ:p/ | ករោម | karom | ក្រោម | /kraɔm/ |
| បរេង | pareŋ | ប្រេង | /prɛeŋ/ | តន្នោត | tannot | ត្នោត | /$t^h$naɔt/ |

គេសង្កេតឃើញមាននិន្នាការមិនបន្លឺព្យញ្ជនៈទី២ក្នុងបន្សំព្យញ្ជនៈ ជាពិសេសព្យញ្ជនៈ «រ» នៅក្នុងក្រុមព្យញ្ជនៈ ក្រ គ្រ ប្រ ជ្រ ត្រ ទ្រ ប្រ ព្រ ស្រ។ ឧទាហរណ៍: ផ្សារ > សារ ជ្រូក > ឈូក ភ្នំពេញ > អំពេញ ជាដើម ក៏ជាផលវិបាកអាក្រក់នៅក្នុងការអភិវឌ្ឍនៃភាសាខ្មែរតទៅអនាគត។

ឥទ្ធិពលនេះនឹងកាន់តែរីកខ្លាំងឡើងៗ ប្រសិនបើនិន្នាការនេះរីកដុះដាលបន្តទៅទៀត បណ្ដាលមកពីអាពាហ៍ពិពាហ៍ល្បាយជាតិសាសន៍ និងសកម្មភាពនៃ «ច្បាប់សន្សំសំចៃនៃការខំប្រឹងប្រែងអាន» និង «ម៉ូដ» នៅក្នុងតំបន់ដែលមានប្រជាជនច្រើន។

**ខ. ផលវិបាកវិជ្ជមាន**

យើងអាចនិយាយបានថា វិធីសង្កត់សំឡេងឌីណាមិក អាចបង្កើតពាក្យថ្មី ព្រមទាំងធ្វើឱ្យមានករណីម្យ៉ាងដែលពាក្យបុរាណនៅតែរស់រានមានជីវិតទន្ទឹមនឹងពាក្យ ដែលកើតថ្មីពីពាក្យបុរាណនេះ ដោយវិធីសង្កត់សំឡេង។ ឧទាហរណ៍ នៅក្នុងភាសាខ្មែរបុរាណពាក្យ «អ្ចះ acah» បង្កើតបានជាពាក្យកម្លាយ «អម្ចាស់» ដោយប្រើផ្នត់ដែក «-ម-» /-m-/។ ប៉ុន្តែ ការសង្កត់សំឡេង បានបន្សាយព្យាង្គទី១។ ទីបំផុតកើតមានពាក្យ «ម្ចាស់» ទន្ទឹមនឹងពាក្យ «អ្ចះ»។ នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន ពាក្យទាំងពីរនេះនៅមានវត្តមានទន្ទឹមគ្នា។ ប៉ុន្តែក្នុងបន្លាស់ប្ដូរន័យពីពាក្យចាស់ទៅពាក្យថ្មី មានបម្រែបម្រួលន័យ ប្រៀបធៀបពាក្យបែបនេះអាចតាងដោយគំនូសបំព្រួញ ដូចតទៅ៖

**ចាស់**

**ពាក្យបុរាណ (អ្ចះ) acah** (តាមវិធីសង្កត់សំឡេង) **ម្ចាស់**

**ម្ចាស់**

នៅក្នុងកន្សោមពាក្យដែលមានទំនាក់ទំនងគុណវិសេសន៍ (ពាក្យមួយកំណត់ ឬបញ្ជាក់ន័យពាក្យមួយទៀត)។ សូមមើលឧទាហរណ៍ខាងក្រោមនេះ:

| | |
|---|---|
| មួយថ្ងៃ > ម្ង៉ៃ (ម្សិលម៉្ងៃ) | មួយដង > ម្ដង (ម្ដងម្កាល) |
| មួយយ៉ាង > ម្យ៉ាង (មួយបែប ម្យ៉ាងវិញទៀត) | មួយកាល > ម្កាល (ម្ដងម្កាល) |
| មួយដុំ > ម្ដុំ (តំបន់) | មួយកែ > ម្កែ |
| មួយនាក់ > ម្នាក់ (ពាក្យនាប់សម្រាប់មនុស្ស)...។ | |

នៅចុងបញ្ចប់នៃផ្នែកនេះ យើងអាចធ្វើកំណត់សម្គាល់ ដូចតទៅ៖

-បម្រែបម្រួលសូរសព្ទ នាំទៅរកបម្រែបម្រួលន័យ។ ក៏ប៉ុន្តែបម្រែបម្រួលនេះ ក៏អាចនាំទៅរកការបាត់បង់ពាក្យមួយចំនួន និងផ្ទុយទៅវិញនាំទៅរកការកកើតពាក្យភ្លោះ។

-ករណីបម្រែបម្រួលសូរសព្ទនីមួយៗ តែងមានទំនាក់ទំនងរវាងគ្នានិងគ្នានិងជាលទ្ធផលកើតបានជាប្រព័ន្ធទំនាក់ទំនងទៅវិញទៅមកនេះ ដែលជាការវិវត្តឬបម្រែបម្រួលនៃភាសា មានលក្ខណៈជារចនាសម្ព័ន្ធក្នុងរយៈកាលប្រវត្តិសាស្ត្រនីមួយៗ។

**៤. បម្រែបម្រួលខាងរូបសព្ទនិងវចនសព្ទ**

នៅក្នុងផ្នែកនេះ យើងពិភាក្សាអំពីបន្លាស់ប្ដូររូបសព្ទនិងវចនសព្ទដែលជាលទ្ធភាពនៃភាពស្រដៀងគ្នា គឺជាដំណូច (analogy) និងការវិភាគឡើងវិញ (reanalysis) ដែលទាក់ទងទៅនឹងការបន្ថែមឬបំបាត់មូលបទ (ជាតុប្រើជាមួយឫសដើម្បីបង្កើតពាក្យថ្មី)។

**៤.១. បម្រែបម្រួលខាងរូបសព្ទ**

បម្រែបម្រួលរូបសព្ទនៃពាក្យ កើតឡើងដោយការបន្ថែមមូលបទជាមួយនឹងឫស។ ការខ្ចីពាក្យមានប្រភពយ៉ាងសំខាន់សម្រាប់មូលបទថ្មីក្នុងភាសាអង់គ្លេស។ ក្នុងភាសាអង់គ្លេសសម័យកណ្ដាល មានពាក្យជាច្រើនផ្ទុកនូវបច្ច័យបទ /ment/ ដូចជាពាក្យ *accomplishment*, *commencement* បង្កើតបានជាវិធីមួយនៅក្នុងភាសា។ ជាយថាហេតុបច្ច័យបទ -ment បានបង្កើតនូវលទ្ធភាពនៃបច្ច័យបទរបស់ខ្លួនក្នុងភាសាអង់គ្លេស ហើយត្រូវបានប្រើជាមូលដ្ឋានដែលមិនដូចលក្ខណៈដើមរបស់ភាសាបារាំង (ដូចពាក្យ *acknowledgement, merriment* ជាដើម)។

នៅក្នុងភាសាខ្មែរក៏មានការខ្ចីពាក្យពីភាសាមួយចំនួន ដើម្បីយកមកប្រើនៅក្នុងវិស័យផ្សេងៗ ដូចជា សាសនា ទស្សនវិជ្ជា រដ្ឋបាល ពាណិជ្ជកម្ម កសិកម្ម ជាដើម។ ភាសាខ្មែរខ្ចីពាក្យខាងសាសនាមកប្រើដូចជា បាប សុខ ទុក្ខ នរក ចិត្ត គោ ចោរ ចក្រវាល មេឃ មុខ ជាដើម មកពីភាសាសំស្ក្រឹតនិងបាលី។ ការខ្ចីពាក្យពីភាសាបារាំង មានដូចជា ដុកទ័រ ក៉ា អុកស៊ីសែន អាលុយមីញ៉ូម ប៉ូលីស កុងត្រូ ស៊ីមី ផ្លាស្ទិក ...។

វាមិនមែនមានន័យថាគ្រប់មូលបទទាំងអស់សុទ្ធតែកើតពីកម្ចីតែម្យ៉ាងនោះទេ ពោលគឺពាក្យផ្ទាល់នៃភាសា អាចអភិវឌ្ឍមូលបទដោយផ្ទាល់នៅក្នុងដំណើរការ ដែលគេហៅថា ការលាយបញ្ចូលគ្នា (fusion) ឧទាហរណ៍ ចាំ + [-ម-] > ឆ្មាំ, ការ + ដើរ > ការដើរ, ត + [-អម់/ណ-] > តំណ, កសិ + ករ > កសិករ...។

### ៤.២. បម្រែបម្រួលខាងវចនសព្ទ

តាមការសិក្សាស្រាវជ្រាវបង្ហាញផងដែរថា បន្លាស់ប្តូរពាក្យកើតឡើងតាមបម្រែបម្រួលខាងវចនសព្ទផងដែរ ហើយក្នុងចំណោមពាក្យទាំងនោះ គឺមានបន្លាស់ប្តូរប្រភេទពាក្យនិងមុខងារពាក្យ។ ដូចជាពាក្យ *menu* ដែលជាធម្មតាប្រើជានាម ប៉ុន្តែគេប្រើវាក្នុងការនិយាយទៅជាកិរិយាសព្ទទៅវិញ។ ប្រសិនបើអ្នកនិយាយទទួលវាយកមកប្រើប្រាស់នោះ *menu* បានបន្ថែមប្រភេទពាក្យជាកិរិយាសព្ទនៅក្នុងវាក្យសព្ទខួរក្បាល (mental lexicon) ឧទាហរណ៍ នៅក្នុងល្បះថា «Have you folks been menued yet?»។ រីឯនៅក្នុងភាសាខ្មែរវិញ ពាក្យ «ឈ្មោះ» ដែលប្រើជានាមសព្ទ ក៏បានប្រើទៅជាកិរិយាសព្ទដែរ ឧទាហរណ៍នៅក្នុងល្បះថា «តើប្អូនឈ្មោះអ្វី?»។

ការបន្ថែមពាក្យថ្មីក៏ជាមូលហេតុដែលធ្វើឱ្យមានបម្រែបម្រួលវចនសព្ទផងដែរ។ នៅក្នុងភាសាអង់គ្លេសមាន ពាក្យជាច្រើនដែលកើតមកពីការបន្ថែមពាក្យថ្មីចូល ហើយសំណុំពាក្យទាំងនោះបង្កើតន័យច្បាស់លាស់តាមវិធីនៃ ការបង្កើតពាក្យ ដូចជា *afternoon, bigmouth, laptop, moreover, zookeeper* ...។ នៅក្នុងភាសាខ្មែរវិញមាន ពាក្យជាច្រើនដែលប្រើតាមវិធីនេះ ដែលគេហៅថាវិធីបន្សំ ដូចជា ដំឡូងឈាមមាន់, ប្រទាលកន្ទុយក្រពើ, កន្ទួតព្រៃ, គោយន្ត, រថភ្លើង, រទេះសេះ, ទឹកដោះគោជូរ, ទឹកកកអនាម័យ...។

### ៥. បម្រែបម្រួលខាងសម្ព័ន្ធ

ដូចជាតុដទៃទៀតដែរ សម្ព័ន្ធ គឺជាកម្មវត្ថុនៃបម្រែបម្រួលតាមរយៈកាលដែរ។ បម្រែបម្រួលខាងសម្ព័ន្ធអាច ទាក់ទងនឹងការកែប្រែមុខងាររចនាសម្ព័ន្ធល្បះឬបម្រែបម្រួលលំដាប់ពាក្យ។ គ្រប់ភាសាទាំងអស់បង្កើតនូវភាពខុស គ្នារវាងប្រធាន កិរិយាសព្ទ និងកម្មបទ។ ភាពខុសគ្នានេះជាធម្មតា ត្រូវបានគេកត់សម្គាល់តាមរយៈលំដាប់ពាក្យ។ វាពុំមានការងឿងឆ្ងល់ថា លំដាប់ពាក្យនោះ មានភាពខុសប្លែកជាងលំដាប់ពាក្យនៃភាសាអង់គ្លេសសម័យកណ្តាល នោះទេ។ លំដាប់ពាក្យដែលប្រើញឹកញាប់បំផុតនៅក្នុងល្បះគឺ ប្រធាន កិរិយា និងកម្មបទ (SVO)។

ឧទាហរណ៍៖

| S | V | O |
|---|---|---|
| *He* | *geseahÞone mann.* | |
| *"He* | *saw* | *the man"* (គាត់បានឃើញបុរសម្នាក់) |

ទោះបីជាយ៉ាងណាក៏ដោយ នៅពេលល្បះមួយចាប់ផ្តើមជាមួយធាតុមួយដូចជាពាក្យ Þa "then" ឬ ne "not" កិរិយាសព្ទបានដាក់នៅទីតាំងទី២ ហើយនាំមុខប្រធាន។

| V | S | O |
|---|---|---|
| *Þa sende* | *sē cyning* | *Þone disc.* |
| *Then sent* | *the king* | *the dish* |

*Then the king sent the dish.*

សរុបមកការធ្វើសញ្ញាសម្គាល់គឺបានបាត់បង់នៅក្នុងភាសាអង់គ្លេសសម័យកណ្តាល តាមរយៈបន្លាស់ប្តូរសូរសំឡេង។ ការរៀបចំលំដាប់ពាក្យ ប្រធាន កិរិយាសព្ទ និងកម្មបទ បានក្លាយទៅជាមធ្យោបាយនៃការសម្គាល់ទំនាក់ទំនងវេយ្យាករណ៍។

## ៦. បម្រែបម្រួលខាងន័យ

ក្នុងចំណោមភាសាមន-ខ្មែរទាំងអស់ ភាសាខ្មែរមានបម្រែបម្រួលសូរសព្ទ រូបសព្ទ និងន័យច្រើនជាងគេ។ អំពីបាតុភូតទាំងពីរនេះ គេអាចពន្យល់បានដោយសារមូលហេតុពីរយ៉ាង៖

-ទីតាំងភូមិសាស្ត្រនៃប្រទេសកម្ពុជា ស្ថិតនៅចំទីប្រជុំផ្លូវកាត់គ្នា ដែលនាំមកនូវអារ្យធម៌បរទេសនានា ដូចជាឥណ្ឌា ចិន លោកខាងលិច...។

-នៅក្នុងប្រវត្តិសាស្ត្រកន្លងមក ភាសាខ្មែរមានទំនាក់ទំនងឥតឈប់ឈរជាមួយនឹងភាសាដទៃទៀត ដូចជាភាសាសំស្ក្រឹត បាលី ចាម ជ្វា ចិន យួន ថៃ បារាំង អង់គ្លេស។ល។

ដូចជាភាសាដទៃទៀតដែរ សមាសភាពវចនសព្ទនៃភាសាខ្មែរ មានការរីកចម្រើនឥតឈប់ឈរ។ ក្នុងសម័យកាលប្រវត្តិសាស្ត្រនីមួយៗ ពាក្យថ្មីៗមួយចំនួនបានកើតឡើងហើយនិងពាក្យមួយចំនួនស្ថិតនៅខាងក្រៅនៃបម្រើបម្រាស់។ កំណកំណើតពាក្យថ្មីមានទំនាក់ទំនងទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច នយោបាយ និងវប្បធម៌របស់ប្រជាជន។ ការបាត់បង់ពាក្យមួយចំនួនចេញពីភាសាជាបឋម គឺជាផលវិបាកនៃការបាត់បង់វត្ថុមួយចំនួន ឬស្ថាប័ននយោបាយមួយចំនួន។

នៅក្នុងភាសាខ្មែរ គេសង្កេតឃើញបម្រែបម្រួលន័យរបស់ពាក្យ មានច្រើនបែបច្រើនយ៉ាងណាស់ ប៉ុន្តែ គេអាចបែងចែកគោលការណ៍ទាំងនេះជាពីរក្រុមសំខាន់ៗគឺ៖ គោលការណ៍នៅក្នុងភាសាវិទ្យា និងគោលការណ៍នៅក្រៅភាសាវិទ្យា។

### ក. គោលការណ៍ក្នុងភាសាវិទ្យា

គោលការណ៍ក្នុងភាសាវិទ្យា គឺត្រូវកំណត់ដោយបម្រែបម្រួលរបៀបរបបនៃរូបសព្ទ សូរសព្ទ និងសម្ព័ន្ធ ឬនិយាយបានម្យ៉ាងទៀតថា ត្រូវកំណត់ដោយកត្តាផ្ទាល់នានាក្នុងភាសា។

### ខ. គោលការណ៍ក្រៅភាសាវិទ្យា

គោលការណ៍ក្រៅភាសាវិទ្យា កើតឡើងដោយបម្រែបម្រួលនៃសង្គម វប្បធម៌ សេដ្ឋកិច្ច និងបច្ចេកទេស ឬមួយលក្ខណៈចម្រុះដែលគេហៅថា «លំហសង្គមនៃពាក្យ» ដែលបង្កើតឡើងដោយសំនួនវោហារភាសាឯកទេសនីយកម្ម ឬការពង្រីកន័យ និងនិន្នាការឆ្ពោះទៅរកភាពពង្រីកបន្ទុកវចីកោសល្យ (ភាពប៉ិនប្រសប់ខាងវាចា ពាក្យសម្តី) និងន័យទាក់ទងនឹងសញ្ចេតនារបស់ពាក្យនីមួយៗ។

ទន្ទឹមនឹងការយកចិត្តទុកដាក់ទៅលើសារៈសំខាន់ នៃការសិក្សាពីបម្រែបម្រួលន័យរបស់ពាក្យ នៅក្នុងការស្រាវជ្រាវអំពីសមាសភាពវចនសព្ទនៃភាសា យើងនឹងធ្វើការវិភាគពីរចំណុច ដែលតាមទស្សនៈយើង គឺវាមានលក្ខណៈសំខាន់ និងជាទិដ្ឋភាពយថាប្រភេទនៃបម្រែបម្រួលន័យរបស់ពាក្យក្នុងភាសាខ្មែរគឺ៖

-បម្រែបម្រួលសូរសព្ទ ដែលនាំទៅរកបម្រែបម្រួលន័យ។

-ការប្រៀបធៀបន័យនិងហេតុបានមកពីការប្រៀបធៀបន័យ ឬរូបារម្មណ៍នីយកម្ម។

បម្រែបម្រួលសូរសព្ទ មិនទាន់អាចនាំទៅរកការបាត់បង់ពាក្យឫសចេញពីភាសាទេ។ បម្រែបម្រួលដែលយើងនិយាយនៅពេលនេះ មានលក្ខណៈអថេរ ហើយប្រព្រឹត្តិទៅក្នុងដំណើរអភិវឌ្ឍន៍ដ៏យូរលង់ និងឥតឈប់ឈរនៃភាសា។

ហេតុនេះហើយ គេសង្កេតឃើញវត្តមានពាក្យនានាដែលរក្សាន័យស្រដៀងនឹងន័យរបស់ពាក្យដើម។ យើងហៅពាក្យទាំងនេះថា ជាពាក្យភ្លោះ។ ដើម្បីជាឧទាហរណ៍ យើងសូមលើកយកពាក្យ «មេ» «មី» និង «ម៉ែ» មកធ្វើការវិភាគ៖

ពាក្យ «មេ» មានន័យថា «ម្ដាយ» «អ្នកដឹកនាំ» «ជាធំ» «ភេទញី»។ ពាក្យ «មី» តាមការពន្យល់របស់លោក ជីវតាក្វាន់ មានន័យថា «លោកស្រី» «មេផ្ទះ» «មីង»។ នៅក្នុងសម័យបច្ចុប្បន្ន ពាក្យ «មី» នេះមានន័យបែបអវិជ្ជមាន និងប្រើសម្រាប់ហៅសត្វភេទញី។ ពាក្យ «ម៉ែ» មានន័យថា «ម្ដាយ» កើតចេញពីពាក្យ «មេ» នៅក្នុងមជ្ឈមសម័យ ដោយសារការក្លាយស្រៈ «អេ» ទៅជាស្រៈផ្សំ «អែ»។

ប្រសិនបើយើងធ្វើគំនូសបំព្រួញការវិវត្តនៃពាក្យ «មី» និង «ម៉ែ» នោះយើងឃើញថា ការវិវត្តិនេះ ប្រព្រឹត្តទៅមិនតាមបន្ទាត់ត្រង់នោះទេ គឺថា ពាក្យទាំងពីរនេះ កើតចេញពីពាក្យ «មេ» តែមួយគត់ ប៉ុន្តែនៅពេលនិយាយ មានការខុសគ្នា។ តាមសិលាចារឹកអង្គរ ពាក្យ «អ្មេ» មានន័យថា ម្ដាយ។

មេ : សម័យបុរាណយូរលង់
→ មី : សម័យបុរាណ
↓ ម៉ែ :មជ្ឈមសម័យ (សម័យកណ្ដាល)

យើងនឹងលើកយកឧទាហរណ៍មួយផ្សេងទៀត ដែលចេញពីភាសាខ្មែរបុរាណ ដើម្បីបង្ហាញអំពីបាតុភូតបម្រែបម្រួលន័យរបស់ពាក្យគឺ មុះ វ្នំ គោល (ប្រមុះ ភ្នំ គោល) ដែលក្នុងសម័យបច្ចុប្បន្ននេះ មានទម្រង់ជា គោល ប្រមុះ ភ្នំ។ ពេលយើងប្រៀបធៀបទម្រង់ទាំងពីរគឺ «ចាស់និងថ្មី» យើងសង្កេតឃើញបម្រែបម្រួលសូរសព្ទនៅក្នុងគ្រប់ពាក្យ មុះ > ប្រមុះ វ្នំ > ភ្នំ គោល > គោល។ ព្យញ្ជនៈ «វ» ប្ដូរទៅជា «ព» រីឯស្រៈ «a» ក្លាយទៅជា «o»។ នៅក្នុងពាក្យទី៣ ស្រៈ «អូ» ប្ដូរជាស្រៈផ្សំ «អោ» រីឯព្យញ្ជនៈបំពង់ក និងព្យញ្ជនៈឮ «sonores» /g/ ក្លាយទៅជាព្យញ្ជនៈថ្លង់ «sourdes» /k/ (ឡុង សៀម, ១៩៩៩)។

## សំណួរ

១. តើភាសាវិទូបែងចែកអម្បូរភាសាជាប៉ុន្មាន? អ្វីខ្លះ?
២. តើគេបែងចែកអម្បូរភាសាទាំងនេះយ៉ាងដូចម្ដេច?
៣. នៅក្នុងភាសាខ្មែរមានពាក្យបាលី-សំស្ក្រឹតជាង៤០%។
តើភាសាខ្មែរជាកូនរបស់ភាសាទាំងពីរនេះឬ? ចូរពន្យល់។
៤. ចូរនិយាយអំពីប្រវត្តិនិងទ្រឹស្ដីភាសាឥណ្ឌូ-អឺរ៉ុបដោយសង្ខេប។
៥. ចូររៀបរាប់អំពីលក្ខណៈរួមនៃភាសាឥណ្ឌូ-អឺរ៉ុប។
៦. តើមានក្រុមភាសាអ្វីខ្លះស្ថិតនៅក្នុងអម្បូរឥណ្ឌូ-អឺរ៉ុប?
៧. ចូរពណ៌នាក្រុមភាសាអៀរ៉ង់។
៨. ចូរពណ៌នាក្រុមភាសាអ៊ីតាលិក។
៩. ចូរពណ៌នាក្រុមភាសាក្រិកនិងក្រុមភាសាអាមេនី។
១០. ចូរពណ៌នាក្រុមភាសាសែរម៉ាំង។
១១. ចូរពណ៌នាក្រុមភាសាស្លាវនិងក្រុមភាសាឥណ្ឌា ឬឥណ្ឌូ-អារ្យ៉ន។
១២. ចូររៀបរាប់អំពីលក្ខណៈទូទៅនៃអម្បូរភាសាអូស្ត្រូអាស៊ី។
១៣. តើមានក្រុមភាសាអ្វីខ្លះស្ថិតនៅក្នុងអម្បូរអូស្ត្រូអាស៊ី?
១៤. ចូរពណ៌នាអំពីក្រុមភាសាសេម៉ាង-សាកៃ និងក្រុមភាសាវៀត-មឿង។
១៥. ចូរពណ៌នាអំពីក្រុមភាសាប៉ាលុង-វ៉ា និងក្រុមភាសានីកូបា។

១៦. ចូរពណ៌នាអំពីក្រុមភាសាខាស៊ី និងក្រុមភាសាមុណ្ឌៈ។
១៧. ចូរពណ៌នាអំពីក្រុមភាសាមន-ខ្មែរ។
១៨. ចូររៀបរាប់អំពីលក្ខណៈក្រុមភាសាមន-ខ្មែរប្រពៃណី។
១៩. តើភាសាណាខ្លះដែលមានការបង្កើតពាក្យដោយប្រើផ្នត់ដែក? ចូរពន្យល់និងលើកឧទាហរណ៍។
២០. តើអ្នកទទួលបានចំណេះដឹងអ្វីខ្លះក្នុងការសិក្សាអំពីអម្បូរភាសានានា?
២១. ចូរបង្ហាញពីមូលហេតុនៃបម្រែបម្រួលភាសា ព្រមទាំងលើកឧទាហរណ៍បញ្ជាក់។
២២. តើបម្រែបម្រួលសូរសំឡេងទាក់ទងនឹងអ្វីខ្លះ?
២៣. ចូររៀបរាប់អំពីបម្រែបម្រួលសូរស្រៈនៃភាសាខ្មែរ។
២៤. ចូរប្រៀបធៀបពីបម្រែបម្រួលសូរស្រៈសម័យបុរាណនិងបច្ចុប្បន្ន។
២៥. ចូររៀបរាប់អំពីបម្រែបម្រួលព្យញ្ជនៈនៃភាសាខ្មែរ។
២៦. ចូរប្រៀបធៀបពីបម្រែបម្រួលព្យញ្ជនៈខ្មែរសម័យបុរាណនិងទំនើប។
២៧. ចូរបង្ហាញពីផលវិបាកវិជ្ជមាននិងផលវិបាកអវិជ្ជមាននៃបម្រែបម្រួលភាសា។
២៨. ហេតុអ្វីបានជាវិធីសង្កត់សំឡេងមានឥទ្ធិពលដល់បម្រែបម្រួលនៃភាសាមួយ? ចូរពន្យល់។
២៩. ចូរបង្ហាញពីបម្រែបម្រួលរូបសព្ទនៅក្នុងភាសាខ្មែរ។
៣០. តើបម្រែបម្រួលភាសាបានផ្តល់ផលវិបាកអ្វីខ្លះ ដល់ភាសានៃជនជាតិមួយ?
៣១. តើមូលហេតុអ្វីបានជាភាសាវិទូពោលថា ភាសាជាចរិតលក្ខណៈរបស់សង្គម? ចូរពន្យល់។
៣២. តើបម្រែបម្រួលន័យរបស់ពាក្យ បណ្តាមកពីមូលហេតុអ្វីខ្លះ? ចូរពន្យល់។
៣៣. តើកត្តាអ្វីខ្លះដែលធ្វើឱ្យមានបម្រែបម្រួលខាងវចនសព្ទនៃភាសា?
៣៤. ចូររៀបរាប់អំពីបម្រែបម្រួលន័យនៃភាសា។
៣៥. តើបម្រែបម្រួលខាងសម្ព័ន្ធអាចធ្វើឱ្យមានបម្រែបម្រួលន័យដែរឬទេ? ចូរពន្យល់។
៣៦. ចូរពន្យល់ពីបម្រែបម្រួលពាក្យទាំងនេះ៖ វ្នំ, ក្ដុំ, ធី, ត្រវង, តៃ, ស្តច, វរេ, ត្នំ, ស្រេ, កេត។

# មេរៀនទី៨
# សង្គមភាសាវិទ្យា

## ១. កំណកំណើតនៃសង្គមភាសាវិទ្យា

ពាក្យសង្គមភាសាវិទ្យា ត្រូវបានប្រើជាទូទៅសម្រាប់ការសិក្សាទំនាក់ទំនងរវាងភាសានិងសង្គម។ នេះគឺជាផ្នែកធំនៃការអង្កេត ដែលបានបង្កើតឡើងតាមរយៈអន្តរកម្មនៃភាសាជាមួយនឹងវិស័យសិក្សាដទៃទៀត។ វាមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនរវិទ្យាតាមរយៈការសិក្សាភាសានិងវប្បធម៌ និងជាមួយសង្គមវិទ្យាតាមរយៈការអង្កេតអំពីតួនាទីនៃភាសានៅក្នុងអង្គការនៃក្រុមសង្គមនិងស្ថាប័ន។ ការសិក្សាអំពីសង្គមភាសាវិទ្យានេះ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងសង្គមចិត្តវិទ្យា ជាពិសេសទាក់ទងនឹងរបៀបដែលឥរិយាបថនិងការយល់ឃើញត្រូវបានបង្ហាញនិងរបៀបដែលអាកប្បកិរិយាក្នុងក្រុមនិងក្រៅក្រុមត្រូវបានកំណត់។ យើងប្រើការតភ្ជាប់ទាំងអស់នេះនៅពេលយើងសាកល្បងវិភាគភាសាពីទស្សនៈនៃសង្គម។

មកដល់សព្វថ្ងៃនេះ បាតុភូតភាសាត្រូវបានគេយកមកពិភាក្សាជាបឋមថា ជាបញ្ញត្តិអរូបីមួយ។ ទោះបីជានៅផ្នែកមេរៀនន័យវិទ្យា បានបរិយាយសង្ខេបៗ ទាក់ទង់នឹងបញ្ហានៃការវិភាគភាសាពិតប្រាកដខ្លះៗក៏ដោយ ក៏ការពិភាក្សាភាគច្រើនរបស់យើង ផ្ដើការផ្ដោតទៅលើតែចង្កោមនៃឧទាហរណ៍ដែលយើងរចនារួចហើយតែប៉ុណ្ណោះ។ យើងមិនសូវបានយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនដូចជា បែបផែននៃការនិយាយរបស់មនុស្ស របៀបដែលភាសាជះឥទ្ធិពលទៅលើជីវភាពរស់នៅ ឬក៏ការជះឥទ្ធិពលពីជីវភាពទៅលើភាសានោះទេ។ ចំណុចនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការដាក់ចេញនូវមូលដ្ឋានគ្រឹះនៃសារព័ន្ធសព្ទ និងបញ្ញត្តិដែលជាវិធីដ៏ចាំបាច់ដូចគ្នា ក្នុងការរក្សានូវព្រំដែនសន្មត រវាងសទ្ទតាវិទ្យា សម្ព័ន្ធវិទ្យា និងន័យវិទ្យា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះបញ្ហាមួយនេះនឹងអាចបង្ហាញឱ្យឃើញកាន់តែច្បាស់ថា អ្នកមិនអាចបំបែកភាសាជាផ្នែកៗ ហើយយកទៅប្រើជាប្រធានបទ ដាច់ៗពីគ្នាទៅវិភាគឱ្យបានល្អិតល្អន់នោះទេ។ ដំណោះស្រាយនេះត្រូវបានគេកំណត់និងដាក់ឱ្យមានលក្ខណៈជាអាដ្ឋាភាព ហើយពេលវេលាវាបានកន្លងហួសទៅហើយ។

បុគ្គលម្នាក់ៗដែលនិយាយ (បញ្ចេញសូរសព្ទ) ភាសា តែងតែធ្វើតាមវិធីមួយដែលខុសប្លែកពីអ្នកនិយាយដទៃទៀត។ សូម្បីតែអ្នកប្រើប្រាស់ភាសាម្នាក់ៗ ក៏ទំនងជាមិនអាចបញ្ចេញសំឡេងតែមួយ ចំនួនពីរដងឱ្យបានដូចគ្នាទាំងស្រុងនោះទេ។ បែបបទដែលមានលក្ខណៈពិសេសនិងជាក់លាក់នៃវាចារបស់បុគ្គលម្នាក់ៗ គេហៅថា បុគ្គលយោបាយ (idiolect) ហើយក៏មិនដែលមានបុគ្គលយោបាយពីរមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ។

ទោះជាយ៉ាងណាក៏ដោយ ក៏ពេលដែលបុគ្គលយោបាយទាំងឡាយក្នុងក្រុមអ្នកនិយាយភាសាមានលក្ខណៈដូចគ្នា ដែលពួកគេអាចមានអារម្មណ៍ថា និយាយដូចគ្នានៅក្នុងភាសាជាក់លាក់ណាមួយ នោះយើងតែងតែចាត់ទុកបែបបទនៃសម្ដីទាំងនោះថាជា ទេសយោបាយ (dialect)។ ទេសយោបាយ និងបុគ្គលយោបាយ មានភាពខុសគ្នា ហើយគេអាចពណ៌នាលក្ខណៈខុសគ្នានេះជាប្រព័ន្ធតាមវត្តមានភាព ឬអវត្តមានភាពនៃក្បួនច្បាប់ជាក់លាក់ណាមួយ ឬក៏ពន្យល់លក្ខណៈខុសគ្នានេះទៅតាមការរៀបចំក្បួន បង្កើតច្បាប់ទាំងនោះផងដែរ។ ហើយបន្ទាប់មកទៀតក្នុងការសិក្សានេះ យើងនឹងពិភាក្សាលើឧទាហរណ៍នៃលក្ខណៈលម្អិតមួយចំនួន ដែលអាចញែកឱ្យឃើញបន្លែកនៃទេសយោបាយ នៅក្នុងការប្រើប្រាស់ភាសានាពេលសព្វថ្ងៃនេះ។ ប៉ុន្តែឥឡូវនេះអ្វីដែលយើងត្រូវចងចាំក្នុងគំនិតនោះគឺថាមនុស្សគ្រប់រូបដោយគ្មានករណីលើកលែង ធ្លាប់និយាយទេសយោបាយមួយចំនួនក្នុងភាសាណាមួយ។ បញ្ញត្តិដ៏មានប្រជាប្រិយនៃបច្ចេកសព្ទ «ទេសយោបាយ» តែងតែពន្យល់ថា «ជាមធ្យោបាយចម្លែក ឬកំប្លែង ឬក៏ជា

មធ្យោបាយទៅតាមតំបន់ ក្នុងការនិយាយ ឬក៏ការសេរសេរ» ហើយដែលពាក្យនេះមិនមែនមានន័យដូច្នោះទេក្នុងភាសាវិទ្យា។

នៅពេលដែលទេសយោបាយជាច្រើនមានសភាពទូទៅដូចគ្នា មានន័យថា អ្នកប្រើប្រាស់ភាសាទាំងអស់គិតថា ខ្លួនគេប្រើប្រាស់សម្តី ដែលមានលក្ខណៈកណ្តាលដូចគ្នា ពេលនោះយើងឱ្យឈ្មោះទេសយោបាយនោះថាជាភាសា។

ជាធម្មតាទេ ការសម្រេចថា តើទេសយោបាយពីរអាចស្ថិតនៅក្នុងភាសាមួយ ឬក៏អត់នោះ គឺជារឿងដ៏ពិបាក បើទោះបីជា ទេសយោបាយទាំងពីរបម្រើឱ្យក្រុមមនុស្សផ្សេងគ្នាក៏ដោយ។ ម្យ៉ាងវិញទៀត យើងក៏ពិបាកក្នុងការកំណត់ព្រំដែនរវាងទេសយោបាយនិងភាសាផងដែរ។ បញ្ហាទាំងអស់នេះបកស្រាយពីគំនិតយោបល់ផ្សេងៗគ្នាអំពីចំនួនជាក់លាក់នៃភាសាដែលមនុស្សប្រើប្រាស់ក្នុងភពផែនដីនាពេលសព្វថ្ងៃនេះ។ យោងទៅតាមការធ្វើបំណែងចែករបស់ភាសាវិទូ ភាសានៅក្នុងលោកអាចមានចំនួនចាប់ពី៣០០០ ទៅ៦០០០ភាសាផ្សេងៗគ្នា។ ជាទូទៅប្រសិនបើអ្នកនិយាយក្នុងក្រុមទេសយោបាយពីរ អាចមានលទ្ធភាពយល់ពីគ្នាទៅវិញទៅមកក្នុងការសន្ទនាធម្មតានោះ យើងអាចនិយាយបានថា ទេសយោបាយរបស់ពួកគេ គឺជាក្រុមរងនៃភាសាមួយ។ ទោះជាយ៉ាងណាក៏ដោយ ក៏គេមិនអាចយកការកំណត់ន័យនេះទៅអនុវត្តឱ្យបានសមស្របនៅក្នុងប្រទេសមួយចំនួនបាននោះទេ។ ជាក់ស្តែងដូចជានៅចិនដីគោកជាកន្លែងដែលទេសយោបាយជាច្រើនមិនអាចនឹងស្តាប់គ្នាយល់បាន ហើយប្រជាជនដែលមកពីជ្រុងម្ខាង និងកន្លែងផ្សេងទៀតនៃប្រទេស មិនអាចស្តាប់សម្តីគ្នាយល់ទាំងស្រុងនោះទេ។ តែទោះជាយ៉ាងណាក៏ដោយតំបន់ណាដែលមានប្រើប្រាស់ភាសាចិន មានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ មានសំណេរភាសាដូចគ្នា ហើយនិងមានប្រពៃណី អក្សរសាស្ត្រដ៏យូរលង់ណាស់មកហើយដូចគ្នា នោះគេអាចនិយាយបានថា ទេសយោបាយទាំងនោះស្ថិតក្នុងក្របខណ្ឌភាសាចិនតែមួយ។

ផ្ទុយទៅវិញ ភាសាណាវ៉ាយ៉ូ (Navajo) និងភាសាអាប៉ាឆេ (Apache) ត្រូវគេចាត់ទុកថាជា ភាសាពីរផ្សេងគ្នា បើទោះជាមានភស្តុតាងប្រវត្តិសាស្ត្រគ្រប់គ្រាន់ក្នុងការបង្ហាញថា ភាសាទាំងពីរនេះមានប្រភពដើមចេញពីអម្បូរភាសាអាថាបាស្កាន (Athabaskan) ហើយអ្នកនិយាយភាសាទាំងពីរនេះ ជួនកាលអាចប្រាស្រ័យទាក់ទងគ្នាបានយ៉ាងងាយក៏ដោយ។

នៅពេលដែលអ្នកនិយាយភាសាម្នាក់ អាចនិយាយភាសាបានលើសពីមួយបានយ៉ាងស្ទាត់ជំនាញ នោះគេចាត់ទុកថាជាអ្នកចេះពីរភាសា (bilingual) ឬ អ្នកនិយាយច្រើនភាសា (multilingual)។ ស្រដៀងគ្នានេះដែរ អ្នកនិយាយម្នាក់ ក៏អាចចេះប្រើទ្វេទេសយោបាយ (bidialectal) ឬក៏ពហុទេសយោបាយ (multidialectal) ផងដែរ។ បច្ចេកសព្ទទាំងនេះ ព្រមទាំងពាក្យទ្វេវប្បធម៌ (bicultural) និង ពហុវប្បធម៌ (multicultural) ត្រូវបានគេប្រើប្រាស់ក្នុងលក្ខខណ្ឌមិនច្បាស់លាស់កាលពីមុន ជាពិសេសក្នុងវិស័យអប់រំ ដែលធ្វើឱ្យភាសាវិទ្យាពិបាកក្នុងការកំណត់ន័យឱ្យច្បាស់លាស់នូវពាក្យទាំងអស់នេះ ដូច្នេះយើងនឹងអាចយល់បានភ្លាម នៅពេលដែលយើងប្រើប្រាស់ពាក្យទាំងនោះ។ បច្ចេកសព្ទ អ្នកចេះពីរភាសា (bilingual) ពិតជាត្រូវការការបកស្រាយពន្យល់បន្ថែមទៀត។

ប្រហែលដោយសារតែ យើងប្រើប្រាស់ភាសាផ្លូវការតែមួយគត់នៅសហរដ្ឋអាមេរិក ទើបការមាននូវជនជាតិអាមេរិកដែលចេះនិយាយពីរភាសាយ៉ាងពិតប្រាកដនោះ គឺហាក់ដូចជារឿងចម្លែកបន្តិច។ ទ្វេភាសានិយមពិតប្រាកដ (true bilingualism) មានន័យថា អ្នកប្រើប្រាស់ភាសាអាចនិយាយភាសាទាំងពីរបានដោយសមត្ថភាពស្មើៗគ្នាដែលម្ចាស់ភាសាដទៃទៀតមិនអាចវិនិច្ឆ័យថា គេជាជនបរទេសបាន ហើយមានសមត្ថភាពអាចប្តូរពីភាសាមួយទៅភាសាមួយទៀតបាន ដោយគ្មានភាពអាក់អួលក្នុងគ្រប់ករណីទាំងអស់។ ជាតួយ៉ាងដើម្បីដឹងពីសមត្ថភាពបែបនេះ គេអាចពិនិត្យឃើញមានតែនៅលើបុគ្គលណា ដែលអាចប្រើភាសាទាំងពីរបានយ៉ាងខ្ជាប់ខ្ជួនតាំងពីកុមារភាពជាមួយសមាជិកក្នុងផ្ទះ និងអ្នកជិតខាងរបស់ខ្លួន។

នៅពេលដែលអ្នកប្រើប្រាស់ភាសាម្នាក់ ចេះនិយាយភាសាកំណើតរបស់ខ្លួនតាំងពីកុមារ ហើយក្រោយមកទៀតក៏បានរៀនភាសាទីពីរ បុគ្គលនោះអាច ឬមិនអាចនិយាយភាសាទីពីរឱ្យបានស្ទាត់ជំនាញនោះទេ គឺអនុលោមទៅតាមកម្រិតនៃភាពស្ទាត់ជំនាញ ហើយអាចប្រែប្រួលទៅតាមកាលៈទេសៈ ព្រមទាំងអាចប្រែប្រួលពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ នៅក្នុងករណីបែបហ្នឹង លើកលែងតែកុមារតូចៗចេញ វាអាចជាការពិតដែលថា ភាសាមួយមានឥទ្ធិពលគ្របដណ្តប់លើភាសាមួយទៀត បើទោះបីជាអ្នកប្រើប្រាស់ភាសានោះអាចនិយាយភាសាទាំងពីរបានយ៉ាងស្ទាត់ជំនាញក៏ដោយ។ ម្យ៉ាងវិញទៀត ឥរិយាបទភាសា(language behavior) មួយចំនួនអាចនឹងបង្កជាភាពលំបាកដល់អ្នកប្រើប្រាស់ភាសាមួយទៀតជាមិនខានឡើយ។

ជាក់ស្តែងប្រជាជននៅសហរដ្ឋអាមេរិក ដែលបានរៀនភាសាអង់គ្លេសតាំងពីតូច ហើយក្រោយមកបានរៀនភាសាទីពីរ អស់រយៈពេលពី ២ ទៅ ៦ ឆ្នាំនៅវិទ្យាល័យ ទំនងជាមិនអាចមាននូវអ្វីដែលគេហៅថា ទ្វេភាសានិយមពិតប្រាកដនោះឡើយ លុះត្រាតែបុគ្គលនោះ មានឱកាសប្រើប្រាស់ភាសាទីពីរបានញឹកញយ ជាមួយម្ចាស់ភាសាកំណើតនោះ។

បុគ្គលយោបាយ ទេសយោបាយ និងភាសា គឺជាបញ្ញត្តិដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធបំផុត ហើយដែលពាក្យទាំងបីនេះទាក់ទិននឹងយោបាយកណ្តាល ដែលមនុស្សម្នាក់ៗបានប្រើប្រាស់ ហើយក៏ថែមទាំងមានសហទំនាក់ទំនងជាមួយជាតិសាសន៍ កេរដំណែលជាតិពន្ធុ និងទីតាំងភូមិសាស្ត្រ នៃអ្នកប្រើប្រាស់ភាសានីមួយៗ ក្នុងពេលចាប់ផ្តើមទទួលចំណេះផ្នែកភាសា។ បច្ចេកសព្ទសណ្ឋានភាសា (register) ក៏ចង់សំដៅដល់បែបផែនភាសាដែលបុគ្គលម្នាក់ៗប្រើប្រាស់ផងដែរ ក៏ប៉ុន្តែពាក្យនេះមានន័យខុសប្លែកបន្តិចពីពាក្យដទៃទៀត។ សណ្ឋានភាសា គឺជារចនាបថនៃទម្លាប់វាចា ឬសំណេរ ដែលមានជាប់ទាក់ទងយ៉ាងជិតស្និទ្ធនឹងតួនាទី ឬស្ថានភាពសង្គមណាមួយ។ ឧទាហរណ៍ចំពោះសិស្សថ្នាក់ទី៧ ដែលរៀននៅទីក្រុង ជាធម្មតាតែងមានរចនាបថសម្តីមួយសម្រាប់ប្រើនៅក្នុងថ្នាក់រៀន បែបបទសម្តីទីពីរប្រើនៅផ្ទះ ហើយនិងបែបបទសម្តីមួយទៀតសម្រាប់ប្រើជាមួយមិត្តភក្តិក្នុងក្រុមនៅតាមដងវិថីទីក្រុង។

## ១.១. ប្រវត្តិនៃសង្គមភាសាវិទ្យា

នៅពេលសព្វថ្ងៃនេះ ភាសាវិទូបានចាប់ផ្តើមខិតខំលះបង់ពេលវេលាជាច្រើនដើម្បីសិក្សាភាសារបស់មនុស្សពិតក្នុងពិភពពិត។ វិស័យឯកទេសន័យកម្មនេះ មានឈ្មោះថា សង្គមភាសាវិទ្យា។

លោក វិលីយាម ឡាបូវ (William Labov) បាននិយាយក្នុងស្នាដៃមួយនៅឆ្នាំ១៩៦៩ថា «ស្ថានភាពសង្គមគឺកត្តាកំណត់ដ៏ចម្បងបំផុតទៅលើឥរិយាបថនិយាយស្តី» ហើយគ្មានហេតុផលណាមួយ ដែលបញ្ជាក់ថា សម្តីគាត់គឺជាការបំផ្លើសនោះទេ។ យើងគ្រាន់តែចង់ពិនិត្យពិចារណាអំពីភាពបរាជ័យនៃប្រព័ន្ធអប់រំអាមេរិកប៉ុណ្ណោះ ពោលគឺនិយាយដល់មុខវិជ្ជា ដែលគេខិតខំបង្កើតអស់រយៈពេល២០០ឆ្នាំមកហើយ ដើម្បីទទួលបាននូវការឯកភាពគ្នានៃភាសានិយាយស្តង់ដាររបស់អាមេរិក។

### ១.១.១. គ្រាមភាសានៃសង្គម

ចំណែកឯការសិក្សាបែបប្រពៃណីនៃគ្រាមភាសាក្នុងតំបន់ មាននិន្នាការផ្តោតលើការនិយាយរបស់ប្រជាជននៅតាមតំបន់ជនបទ។ ការសិក្សាអំពីគ្រាមភាសានៃសង្គមត្រូវបានយកចិត្តទុកដាក់ជាចម្បងជាមួយអ្នកនិយាយនៅតាមទីប្រជុំជននិងទីក្រុង។ នៅក្នុងការសិក្សាសង្គមនៃគ្រាមភាសា វាគឺជាថ្នាក់សង្គមដែលត្រូវបានប្រើជាចម្បងដើម្បីកំណត់ក្រុមអ្នកនិយាយថាមានអ្វីដូចគ្នា។ ក្រុមធំពីរជាទូទៅត្រូវបានគេស្គាល់ថាជា «វណ្ណៈកណ្តាល» អ្នកដែលមានការអប់រំច្រើនឆ្នាំ ហើយបំពេញការងារមិនមែនដោយហត្ថកម្ម និង «វណ្ណៈកម្មករ» អ្នកដែលមានការអប់រំតិចជាង ហើយអនុវត្តការងារដោយហត្ថកម្ម។ ដូច្នេះនៅពេលយើងនិយាយអំពី «ការនិយាយវណ្ណៈកម្មករ» នោះយើងកំពុងនិយាយអំពីគ្រាមភាសាសង្គម។ ពាក្យសព្ទ «ខ្ពស់» និង«ទាប» ត្រូវបានប្រើដើម្បីបែងចែកក្រុមនានាបន្ថែមទៀត

ជាពិសេសលើមូលដ្ឋានសេដ្ឋកិច្ច ការបង្កើតនូវ «ការនិយាយវណ្ណៈខាងលើពាក់កណ្តាល» ជាគ្រាមភាសាសង្គម ឬគ្រាមភាសាសង្គមប្រភេទមួយផ្សេងទៀត។

ដូចជានៅក្នុងការសិក្សាគ្រាមភាសាទាំងអស់ មានតែលក្ខណៈពិសេសមួយចំនួន នៃការប្រើប្រាស់ភាសាប៉ុណ្ណោះ ដែលត្រូវបានគេចាត់ទុកថា ពាក់ព័ន្ធនៅក្នុងការវិភាគនៃគ្រាមភាសាសង្គម។ លក្ខណៈពិសេសទាំងនេះគឺជាការបញ្ចេញសំឡេងពាក្យ ឬរចនាសម្ព័ន្ធ ដែលត្រូវបានប្រើជាប្រចាំក្នុងទម្រង់មួយដោយអ្នកនិយាយនៅក្នុងវណ្ណៈកម្មករ និងទម្រង់មួយទៀតដោយអ្នកនិយាយនៅក្នុងវណ្ណៈកណ្តាល។ ឧទាហរណ៍នៅអេឌីនបឺក(Edinburgh) ប្រទេសស្កុតលែន(Scotland) ជារឿយៗ ពាក្យ *home* ត្រូវបានបញ្ចេញសំឡេងជា [heɪm] ដូចច្បួនគ្នានឹង *name* ក្នុងចំណោមអ្នកនិយាយនៅក្នុងវណ្ណៈកម្មករ ដែលទាប និងត្រូវបានបញ្ចេញសំឡេងជា [hom] ដូចច្បួនគ្នានឹង foam ក្នុងចំណោមអ្នកនិយាយនៅក្នុងវណ្ណៈកណ្តាល។ វាជាភាពខុសគ្នាបន្តិចបន្តួចនៅក្នុងការបញ្ចេញសំឡេង ប៉ុន្តែវាជាសញ្ញាបង្ហាញពីស្ថានភាពសង្គម។ ប្រហែលជាមានឧទាហរណ៍ដែលច្បាស់ជាងនេះមួយគឺ កិរិយាស័ព្ទ *ain't* ដូចក្នុង *I ain't finished yet* ជាទូទៅត្រូវបានប្រើជាញឹកញាប់នៅក្នុងសម្តីវណ្ណៈកម្មករច្រើនជាងសម្តីវណ្ណៈកណ្តាល។

នៅពេលយើងរកមើលឧទាហរណ៍ផ្សេងទៀតនៃការប្រើប្រាស់ភាសា ដែលអាចជាលក្ខណៈនៃគ្រាមភាសាសង្គម យើងចាត់ទុកវណ្ណៈជាអថេរសង្គម (បម្រែបម្រួលនៃសង្គម) និងការបញ្ចេញសំឡេងឬពាក្យជាអថេរភាសា (បម្រែបម្រួលនៃភាសា)។ បន្ទាប់មកយើងអាចសាកល្បងអង្កេតអំពីវិសាលភាពដែលមានបម្រែបម្រួលប្រព័ន្ធដែលពាក់ព័ន្ធនឹងអថេរ (បម្រែបម្រួល)ទាំងពីរដោយរាប់ថា តើអ្នកនិយាយក្នុងថ្នាក់នីមួយៗ ប្រើរបៀបនៃបម្រែបម្រួលភាសានីមួយៗញឹកញាប់ប៉ុណ្ណា។ ជាទូទៅ នេះមិនមែនជាស្ថានភាពទាំងអស់ ឬគ្មានសោះនោះទេ ដូច្នេះជាធម្មតាការសិក្សាគ្រាមភាសាសង្គមបញ្ជាក់ប្រាប់ថា តើអ្នកនិយាយក្នុងក្រុមពិសេសមួយប្រើទម្រង់ណាមួយជាជាងរកឃើញថាមានតែក្រុមមួយឬក្រុមមួយផ្សេងទៀតដែលប្រើទម្រង់នេះ។

ប្រទេសស្វីសដែលជាប្រទេសតូចមួយហើយមានពោរពេញទៅដោយប្រជាជនគ្រប់ជាតិសាសន៍ ព្រមទាំងមានការគ្រប់គ្រងបានយ៉ាងល្អ ក្លាយទៅជាជនរួមជាតិមួយ ដែលមានភាសាសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសជាតិរបស់ខ្លួនដូចជាភាសាបារាំង អាល្លឺម៉ង់ អ៊ីតាលី និងភាសារ៉ូម៉ាំង។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសផ្សេងទៀតដែលមានប្រជាជនប្រើប្រាស់ច្រើនភាសា នៅតែមិនអាចដំណើរការទៅបានដូចប្រទេសស្វីសឡើយ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ យើងបានសង្កេតឃើញថា ភាពចលាចល និងការជជែកតវ៉ាប្រឆាំងគ្នាទៅវិញទៅមក នៅក្នុងពិភពលោកជុំវិញនឹងចម្ងល់នៃចំណោទសួរអំពីភាសាពីរ ឬច្រើនត្រូវបានគេយកទៅប្រើនៅក្នុងលក្ខណៈផ្លូវការទាំងពីរ ព្រមទាំងនៅក្នុងជីវិតប្រចាំថ្ងៃ។ នៅក្នុងប្រទេសកាណាដា នាខេត្តកេប៊ិក ដែលជាខេត្តនិយាយភាសាបារាំងនោះ មានកើតនូវជម្លោះយ៉ាងខ្លាំងចំពោះការជ្រៀតជ្រែកលើប្រព័ន្ធដឹកជញ្ជូនតាមអាកាសរបស់ប្រទេសនេះទៀតផង។

ចំណែកនៅឯប្រទេសអាហ្វ្រិកខាងត្បូង (South Africa) វិញ មានជម្លោះកើតឡើងប្រឆាំងទៅនឹងការប៉ុនប៉ងប្រើពាក្យ អាហ្វ្រិកាន (Afrikaans) នៅក្នុងសាលារៀន។ រីឯនៅប្រទេសប៊ែលហ្ស៊ិក (Belgium) ពួកទាហានហ្វ្លេមីស (Flemish) មានបញ្ហាជម្លោះជាមួយប៉ូលីសចំពោះការប្រើប្រាស់ភាសាដែលមិនមានសិទ្ធិស្មើគ្នារបស់ពួកហ្វ្លេមីសហើយគេបានអះអាងថា ពួកអ្នកនិយាយ នៅតំបន់ហ្វ្លេមីស មានការឈឺចាប់ចំពោះការមើលងាយពីសំណាក់អ្នកនិយាយភាសាបារាំងនៅក្នុងប្រទេស។ បើយើងក្រឡេកមើលមកក្នុងសហរដ្ឋអាមេរិកវិញ ការជ្រើសរើសភាសានិយាយរបស់ប្រជាជនមិនមែនជាបញ្ហាសំខាន់នោះទេ ប៉ុន្តែសំណួរដែលចោទសួរអំពីការអប់រំដោយប្រើភាសាពីរទើបជាប្រធានបទនៃសំណុំរឿងដ៏សំខាន់ដែលត្រូវលើកឡើង នៅឯតុលាការកំពូល ហើយទំនងជាប្រភពមួយដ៏សំខាន់ ចំពោះការមិនចុះសម្រុងគ្នាអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ។ លើសពីនេះទៅទៀត ភាពខុសគ្នានៅក្នុងមូលដ្ឋាននៃភាសា គឺពិតជាមានទំនាក់ទំនងជិតស្និទ្ធណាស់ជាមួយនឹងបញ្ហាសង្គមសេដ្ឋកិច្ចរបស់យើង។ បញ្ហាសង្គមដែលផ្អែកទៅលើកត្តាភាសា ជាធម្មតាកើតមាននៅក្នុងស្ថានភាពដូចខាងក្រោមនេះ៖

១. ទីកន្លែងដែលមានមនុស្សរស់នៅច្រើន (ដូចនៅប្រទេសឥណ្ឌា) ប្រសិនបើទេសយោបាយនោះត្រូវនិយាយភាសាច្រើនខុសៗគ្នា ហើយជួនកាលទីក្រុងជិតគ្នាធ្វើទំនាក់ទំនងគ្នាដោយមិនអាចស្ដាប់គ្នាយល់បាន ឬមានទេសយោបាយផ្ទាល់ខ្លួន។

២. ទីកន្លែងដែលមានឥទ្ធិពលគ្របដណ្ដប់ពីពួកនយោបាយនិងសេដ្ឋកិច្ច ដូចជានៅប្រទេស ដែលស្ថិតនៅក្រោមអាណានិគម ព្យាយាមបញ្ចូលភាសារបស់ខ្លួនទៅលើប្រជាជនជាតិដើម។

៣. ទីកន្លែងដែលមានភាសាជាក់លាក់ហើយនិងក្លាយទៅជានិមិត្តសញ្ញានៃភាសាជាតិខ្លួន ជាមួយនឹងអត្តសញ្ញាណជាតិ ដូចជាភាសាហ្គាលីក (Gaelic Language) ក្នុងប្រទេសអៀរឡង់ (Ireland)។

៤. ទីកន្លែងដែលមានជនជាតិប្រកបដោយឥទ្ធិពលខ្លាំងក្លា ឬក៏ក្រុមជនជាតិដែលមានសេដ្ឋកិច្ចខ្លាំងគ្រប់គ្រងកន្លែងមួយចំនួន ហើយវាបានក្លាយទៅជាកន្លែងដែលមានភាពទាក់ទាញដល់ប្រជាជនដើមដែលរស់នៅតំបន់នោះ អាចនិយាយភាសារបស់ក្រុមដែលមានឥទ្ធិពលទាំងនោះ យ៉ាងហោចណាស់ក៏ដើម្បីជួយសម្រួលដល់ការរកស៊ីរបស់ខ្លួនដែរ។

## ១.១.២. ការអប់រំនិងមុខរបរ

ទោះបីជាស្ថានភាពប្លែកៗនៃជីវិតនីមួយៗបណ្ដាលឱ្យមនុស្សម្នាក់ៗ មានរបៀបនិយាយជាឯកជន ឬគ្រាមភាសាផ្ទាល់ខ្លួន ឬសម្ដីដែលប្រើប្រាស់ដោយជនណាម្នាក់ក៏ដោយ ជាទូទៅ យើងមានទំនោរនិយាយបញ្ចេញសំឡេងដូចជាអ្នកដទៃទៀតដែលយើងមានប្រវត្តិអប់រំនិងឬមុខរបរស្រដៀងគ្នា។

ក្នុងចំណោមអ្នកដែលចាកចេញពីប្រព័ន្ធអប់រំតាំងពីវ័យកុមារ មានគំរូទូទៅនៃការប្រើប្រាស់ទម្រង់ណាមួយដែលមិនមានលក្ខណៈគ្រប់គ្រាន់ ដូចគ្នានឹងការនិយាយរបស់អ្នកដែលបន្តការសិក្សានៅមហាវិទ្យាល័យ។ របៀបនិយាយដូចជា «*Them boys throwed something*» ឬ «*It wasn't us what done it*» ជាទូទៅត្រូវបានទាក់ទងជាមួយនឹងអ្នកនិយាយដែលបានចំណាយពេលតិចក្នុងការអប់រំ។ អ្នកដែលចំណាយពេលច្រើនក្នុងប្រព័ន្ធអប់រំច្រើនតែមានលក្ខណៈពិសេសបន្ថែមទៀតនៅក្នុងភាសានិយាយរបស់ពួកគេផងដែរ ដោយសារការចំណាយពេលច្រើនជាមួយភាសាសរសេរ ដូច្នេះ *threw* មានភាពទំនងជាច្រើនជាង *throwed* និងប្រើ *who* ញឹកញាប់ជាង *what* ដែលសំដៅទៅនឹងមនុស្ស។ ការសង្កេតដែលគ្រូមួយចំនួន «និយាយដូចជាសៀវភៅ» អាចជាការឆ្លុះបញ្ចាំងពីទម្រង់នៃឥទ្ធិពលនេះ ពីភាសាសរសេរអស់ជាច្រើនឆ្នាំនៅក្នុងប្រព័ន្ធអប់រំ។

ក្នុងនាមជាមនុស្សពេញវ័យ លទ្ធផលនៃពេលវេលារបស់យើងនៅក្នុងប្រព័ន្ធអប់រំ ជាធម្មតា ត្រូវបានឆ្លុះបញ្ចាំងពីការកាន់កាប់និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់យើង។ វិធីដែលអ្នកប្រតិបត្តិធនាគារ ផ្ទុយពីអ្នកសម្អាតបង្គួចនៅពេលនិយាយជាមួយគ្នា ជាធម្មតាផ្ដល់នូវភស្តុតាងខាងភាសាសម្រាប់សារៈសំខាន់នៃអថេរសង្គមទាំងនេះ។ នៅទសវត្សឆ្នាំ១៩៦០ សង្គមវិទូ វិលីយ៉ាម ឡាបូវ (William Labov) បានបញ្ចូលសមាសធាតុពីកន្លែងនៃមុខរបរនិងស្ថានភាពសេដ្ឋកិច្ចសង្គមដោយមើលភាពខុសគ្នានៃការបញ្ចេញសំឡេង ក្នុងចំណោមអ្នកលក់នៅក្នុងហាងចំនួន ៣ នៃទីក្រុងញូវយ៉ក (សូមមើល Labov, ២០០៦)។ ពួកគេជា Saks Fifth Avenue (អ្នកទាំងអស់នេះមានរបស់របរប្រើប្រាស់ដែលមានតម្លៃថ្លៃៗ រស់នៅក្នុងស្ថានភាពវណ្ណៈកណ្ដាលកម្រិតខ្ពស់) Macy's (អ្នកទាំងអស់នេះមានរបស់របរប្រើប្រាស់ដែលមានតម្លៃមធ្យម រស់នៅក្នុងស្ថានភាពវណ្ណៈកណ្ដាល) និង Klein (អ្នកទាំងអស់នេះមានរបស់របរប្រើប្រាស់ដែលមានតម្លៃថោកជាង រស់នៅក្នុងស្ថានភាពវណ្ណៈកម្មករ)។ លោក ឡាបូវ (Labov) បានចូលទៅក្នុងហាងនីមួយៗ ហើយនិងបានសួរអ្នកលក់នូវសំណួរជាក់លាក់ ដូចជា *តើស្បែកជើងរបស់ស្ត្រីនៅឯណា?* ដើម្បីទទួលបានចម្លើយជាមួយនឹងពាក្យថាជាន់ទីបួន(*fourth floor*)។ ការបញ្ចេញមតិនេះផ្ទុកនូវឱកាសពីរសម្រាប់ការបញ្ចេញសំឡេង (ឬមិនមាន) នៃការបញ្ចេញសំឡេងក្រោយ /r/ នោះគឺ /r/ សំឡេងបន្ទាប់ពីស្រៈ។ និយាយយ៉ាងម៉ត់ចត់ វាគឺជាសូរសំឡេង /r/ ដែលនៅបន្ទាប់ពីស្រៈនិងមុនព្យញ្ជនៈឬចុងបញ្ចប់នៃពាក្យ។

នៅក្នុងហាងលក់ទំនិញធំៗមានលំនាំធម្មតានៅក្នុងចម្លើយ។ ហាងដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមកាន់តែខ្ពស់ នោះការបញ្ចេញសំឡេង /r/ ក៏កាន់តែច្រើនដែរ ស្ថានភាពកាន់តែទាប នោះការបញ្ចេញសំឡេង /r/ ក៏កាន់តែតិចដែរ។ ដូច្នេះភាពញឹកញាប់នៃការកើតឡើងនៃអថេរភាសានេះ /r/ អាចសម្គាល់គំរូការនិយាយដូចជាថ្នាក់កណ្ដាលធៀបនឹងវណ្ណៈកណ្ដាល ហើយវណ្ណៈកណ្ដាលនេះធៀបនឹងវណ្ណៈការងារ។ ការសិក្សាផ្សេងទៀតបានបញ្ជាក់ពីគំរូធម្មតានេះនៅក្នុងការនិយាយរបស់អ្នកញូវយ៉ក។

នៅក្នុងការសិក្សារបស់អង់គ្លេសដែលបានធ្វើនៅក្នុងការអានប្រហែល៤០ម៉ាយល៍ ខាងលិចនៃទីក្រុងឡុងដ៍ លោក ត្រុដហ្គីល (Trudgill) បានរកឃើញថា តម្លៃសង្គមទាក់ទងនឹងអថេរដូចគ្នា ហើយការបញ្ចេញសូរព្យញ្ជនៈ /r/ នេះ គឺខុសគ្នាខ្លាំង។ អ្នកនិយាយថ្នាក់កណ្ដាលនៅក្នុងការអាន បានបញ្ចេញសំឡេងសូរព្យញ្ជនៈ /r/ តិចជាងសំឡេងអ្នកនិយាយស្ថិតនៅក្នុងវណ្ណៈកម្មករ។ នៅក្នុងទីក្រុងពិសេសនេះ អ្នកនិយាយវណ្ណៈកណ្ដាលជាន់ខ្ពស់ ហាក់ដូចជាមិនបានផ្សព្វផ្សាយសូរសំឡេង /r/ ដែលនៅក្រោយពាក្យនោះទាល់តែសោះ។ ពួកគេបាននិយាយរឿងដូចជា «Oh, *that's mahvellous, dahling!* » ។ លទ្ធផលនៃការសិក្សាទាំងពីរនេះត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងភាគរយនៃក្រុមដែលប្រកាសក្រោយសូរសព្ទ /r/

| **វណ្ណៈសង្គម** | **ទីក្រុងញូវយ៉ក** | **ការអាន** |
|---|---|---|
| វណ្ណៈកណ្ដាលថ្នាក់លើ | ៣២ | ០ |
| វណ្ណៈកណ្ដាលថ្នាក់ទាប | ២០ | ២៨ |
| វណ្ណៈកម្មករថ្នាក់ខ្ពស់ | ១២ | ៤៤ |
| វណ្ណៈកម្មករថ្នាក់ទាប | ០ | ៤៩ |

### ១.១.៣. សញ្ញាសម្គាល់សង្គម

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ សារៈសំខាន់នៃអថេរភាសា /r/ អាចមានលក្ខណៈផ្ទុយគ្នាស្ទើរតែទាក់ទងនឹងស្ថានភាពសង្គមនៅកន្លែងពីរផ្សេងគ្នា ប៉ុន្តែនៅកន្លែងទាំងពីរលំនាំបង្ហាញពីរបៀបដែលការប្រើប្រាស់សំឡេងពិសេសនេះមានមុខងារជាសញ្ញាសម្គាល់សង្គម (social markers)។ នេះគឺមាន (ឬមិនមាន) លក្ខណៈពិសេសដែលបានកើតឡើងជាញឹកញាប់នៅក្នុងសម្ដីរបស់អ្នកសម្គាល់ឬអ្នកដែលជាសមាជិកនៃក្រុមសង្គមណាមួយទោះបីជាអ្នកដឹងឬមិនដឹងក៏ដោយ។

ចំណុចទាំងនេះ មានលក្ខណៈពិសេសនៃការបញ្ចេញសំឡេងផ្សេងទៀតដែលមានមុខងារជាសញ្ញាសម្គាល់សង្គម។ លក្ខណៈពិសេសមួយដែលហាក់ដូចជាការបង្ហាញស្ថិរភាព នៃវណ្ណៈថ្នាក់ទាបនិងការអប់រំកម្រិតទាបនៅពាសពេញពិភពលោកដែលនិយាយភាសាអង់គ្លេស គឺការបញ្ចេញសំឡេងចុងក្រោយនៃ *-ing* ជាមួយ [n] ជាជាង [ŋ] នៅចុងបញ្ចប់នៃពាក្យដូចជា *sitting* និង *drinking*។ ការបញ្ចេញសំឡេងដែលតំណាងដោយ «sittin» និង «drinkin» គឺត្រូវបានផ្សារភ្ជាប់ជាមួយនឹងការនិយាយនៃវណ្ណៈកម្មករ។

សញ្ញាសម្គាល់សង្គមមួយទៀតត្រូវបានគេហៅថា «ការធ្លាក់ចុះនៃសូរ [h] » ដែលធ្វើឱ្យពាក្យ *at* និង *hat* ស្ដាប់ទៅដូចគ្នា។ វាកើតឡើងនៅដើមពាក្យហើយអាចបណ្ដាលឱ្យមានសម្ដីដែលស្ដាប់ទៅដូចជា «*I'm so 'ungry I could eat an 'orse*»។ នៅក្នុងភាសាអង់គ្លេសសម័យទំនើប លក្ខណៈពិសេសនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងវណ្ណៈថ្នាក់ទាបនិងការអប់រំកម្រិតទាប។ វាហាក់ដូចជាមានសមាគមស្រដៀងគ្នានេះដែរ ដែលជាសញ្ញាសម្គាល់សង្គមរបស់ លោក ឆាល ឌិកកេន (Charles Dickens) ដោយលោកបានសរសេរនៅពាក់កណ្ដាលសតវត្សទី១៩។ គាត់បានប្រើវាជាមធ្យោបាយមួយដើម្បីចង្អុលបង្ហាញថាចរិត អ៊ុយរីយ៉ា ហេប (Uriah Heep) នៅក្នុងប្រលោមរបស់លោក ដេវីឌ ខុបស្ពឺហ្វៀហ្វ (David Copperfield) គឺមកពីវណ្ណៈថ្នាក់ទាប ដូចអ្វីដែលបានបញ្ជាក់នៅក្នុងឧទាហរណ៍ទាំងនេះ (George Yule, 2010: 255)។

## ១.២. និយមន័យសង្គមភាសាវិទ្យា

សង្គមភាសាវិទ្យា ជាភាសាវិទ្យាដែលបញ្ចូលទិដ្ឋភាពសង្គមក្នុងការសិក្សាអំពីភាសា។ ភាសាក៏ដូចជាសង្គមដែរមានភាពស្មុគស្មាញ គ្មានឯកសណ្ឋាន ហើយមានការវិវត្តមិនឈប់ឈរ។ អ្វីដែលមានស្ថិរភាពក្នុងរយៈពេលដ៏វែងបង្គួរ គឺគ្រឹះនៃភាសា ហៅថាវេយ្យាករណ៍។

លោក ឡាបូវ បានឱ្យនិយមន័យថា សង្គមភាសាវិទ្យាជាភាសាវិទ្យាទាំងមូល ជាភាសាវិទ្យាពេញលេញគ្រប់ទិដ្ឋភាព។ ទិដ្ឋភាពសង្គមនិងព្រឹត្តិការណ៍សង្គមបានគ្របសង្កត់យ៉ាងខ្លាំងទៅលើទិដ្ឋភាពភាសា។ សង្គមភាសាវិទ្យាបែបនេះជាមែកធាងមួយរបស់សង្គមវិទ្យា។

បើយល់ថាចលនាព្រឹត្តិការណ៍សង្គមគ្រាន់តែជាបុព្វហេតុនាំឱ្យភាសាវិវត្ត និយាយតែពីភាសាដែលវិវត្ត មិននិយាយអ្វីក្រៅពីភាសា នេះជាសង្គមភាសាវិទ្យាពិតប្រាកដ។

ការដែលភាសាវិទ្យាឥតទិដ្ឋភាពសង្គម គេសិក្សាតែពីសទ្ទតាវិទ្យា វចនវិទ្យា និងសម្ព័ន្ធវិទ្យា គេពុំអាចចូលដល់ផ្ទៃសង្គមឡើយ។ ដើម្បីចូលដល់ទិដ្ឋភាពសង្គមដែលមាននៅក្នុងភាសា គេត្រូវទៅឱ្យហួសពីវេយ្យាករណ៍ គឺចូលឱ្យដល់រូបនីយកម្មនៃវេយ្យាករណ៍ គឺទម្លាប់វាចាឬទម្លាប់ក្នុងការប្រើប្រាស់ភាសា (ព្រំ ម៉ល់, ២០១៣: ៨)។

## ២. គ្រឹះទ្រឹស្តីនៃសង្គមភាសាវិទ្យា

## ២.១. និន្នាការនិងកិច្ចការស្រាវជ្រាវនៃសង្គមភាសាវិទ្យា

សង្គមភាសាវិទ្យាមាននិន្នាការពីរគឺ ទី១៖ និន្នាការមួយចាត់ទុកខ្លួនជាមែកធាងមួយនៃសង្គមវិទ្យា។ សង្គមភាសាវិទ្យាបែបនេះសង្កត់ធ្ងន់លើព្រឹត្តិការណ៍សង្គម ហើយទិដ្ឋភាពភាសាត្រូវកប់ក្រោមព្រឹត្តិការណ៍សង្គមរកមើលស្ទើរតែមិនឃើញ។ ទី២៖ និន្នាការមួយបែបទៀតចាត់ទុកខ្លួនជាភាសាវិទ្យាមួយបែប ហើយលោក វិលីយាម ឡាបូវ ថែមទាំងអះអាងថាសង្គមភាសាវិទ្យាជាភាសាវិទ្យាទាំងស្រុងទៀតផង គឺមិនមែនគ្រាន់តែជាមែកធាងនៃភាសាវិទ្យានោះទេ។

## ២.២. ទ្រឹស្តីលោក វិលីយាម ឡាបូវ (William Labov)

លោក ឡាបូវ បានបង្ហាញ (តាមអង្កេតរបស់គាត់) ឱ្យឃើញថា តើជនក្នុងស្រទាប់នីមួយៗក្នុងសង្គមនៅក្រុងញូយ៉កអានកន្សោមពាក្យ «Fourth floor» បែបណាខ្លះ។ អំណានស្តង់ដារគឺ [fɔːθ flɔː] ហើយមានតែជនខ្លះក្នុងស្រទាប់លើនៃសង្គមដែលចាប់អានព្យញ្ជនៈ «r» ដែលមានតែក្នុងអក្ខរាវិរុទ្ធ រួចអ្នកខ្លះទៀតក៏ចាប់ធ្វើតាម ដែលជាហេតុនាំឱ្យរាលដាលដល់ក្រុមឯទៀត។ លោក ឡាបូវ បានធ្វើអង្កេតនៅក្នុងផ្សារទំនើបពាកន្លែងដូចជា ផ្សារ Saks (ផ្សារប្រណិតសម្រាប់អ្នកមាន) ផ្សារ Macy's (ផ្សារថ្នាក់មធ្យម) និងផ្សារ Klein (ផ្សារថ្នាក់ទាបសម្រាប់អ្នកក្រ)។ អ្នកដែលទទួលការអង្កេត គឺបុគ្គលិកដែលមានការអប់រំនិងកម្រិតសង្គមស្របតាមកម្រិតនៃផ្សារនីមួយៗដែរ។ អ្នកដែលអានកន្សោមពាក្យ «Fourth floor» ដោយបញ្ចេញខ្យល់ «r» មានភាគរយដូចតទៅ ៦២% ចំពោះ ផ្សារ Saks, ៥១% ចំពោះផ្សារ Macy's និង២០% ចំពោះផ្សារ Klein។

លទ្ធផលនេះបង្ហាញឱ្យឃើញថា អំណាននេះមានទំនាក់ទំនងនឹងស្រទាប់សង្គម ពោលគឺស្រទាប់នីមួយៗនៃសង្គមមានទំនោរអ្វីមួយប្លែកពីស្រទាប់ដទៃទៀត គឺការវិវត្តនៃភាសាតែងប្រព្រឹត្តទៅតាមជាន់ថ្នាក់តាមស្រទាប់សង្គម។ម្យ៉ាងទៀត អង្កេតរបស់លោក ឡាបូវ បានបង្ហាញផងដែរនូវអំណានព្យញ្ជនៈ «r» តាមជំនាន់អាយុ ដូចជាអាយុ១៥ឆ្នាំដល់៣០ឆ្នាំ គឺ២៥%, អាយុ៣៥ឆ្នាំដល់៥០ឆ្នាំ គឺ២០% និងអាយុ៥៥ឆ្នាំដល់៧០ឆ្នាំ គឺ២០%។ តាមលទ្ធផលនេះ យើងឃើញថា អំណានព្យញ្ជនៈ «r» មានលំនាំតាមជំនាន់ (តាមកំណាត់អាយុ) ពោលគឺការវិវត្តក្នុងភាសាទាក់ទងនឹងរយៈកាល (មានការឆ្លងកាត់ដំណាក់កាល)។

នៅក្នុងការសិក្សាហាងរបស់គាត់ លោក ឡាបូវ (Labov) បានរួមបញ្ចូលធាតុល្បិចមួយផ្សេងទៀតដែលអនុញ្ញាតឱ្យគាត់មិនត្រឹមតែអង្កេតប្រភេទនៃការបែងចែកថ្នាក់សង្គមប៉ុណ្ណោះទេ ប៉ុន្តែក៏មានរបៀបនិយាយផងដែរ

ដែលជាលក្ខណៈសង្គមនៃការប្រើប្រាស់ភាសា។ ភាពខុសគ្នាជាមូលដ្ឋានបំផុតនៅក្នុងរបៀបនិយាយគឺរវាងការប្រើប្រាស់ផ្លូវការនិងការប្រើប្រាស់ក្រៅផ្លូវការ។ របៀបជាផ្លូវការគឺនៅពេលដែលយើងយកចិត្តទុកដាក់កាន់តែខ្លាំងទៅនឹងរបៀបដែលយើងនិយាយ និងរបៀបក្រៅផ្លូវការគឺនៅពេលយើងយកចិត្តទុកដាក់តិច។ ពេលខ្លះពួកគេត្រូវបានពិពណ៌នាថាជា «របៀបប្រុងប្រយ័ត្ន» និង «របៀបធម្មតា»។ ការផ្លាស់ប្តូរពីរបៀបមួយទៅរបៀបមួយទៀតដោយបុគ្គលម្នាក់ ត្រូវបានគេហៅថារបៀបផ្លាស់ប្តូរ។

នៅពេលលោក ឡាបូវ (Labov) សួរអ្នកលក់ថា តើរបស់របរមួយណានៅទីនោះ គាត់ស្មានថាពួកគេឆ្លើយដោយមិនផ្លូវការ។ បន្ទាប់ពីពួកគេបានឆ្លើយសំណួររបស់គាត់រួចហើយ លោក ឡាបូវ (Labov) បានធ្វើពុតជាស្តាប់មិនបាន ហើយនិយាយថា «ថាម៉េច?» ក្នុងគោលបំណងដើម្បីធ្វើឱ្យពាក្យដដែលៗនៃការបញ្ចេញសំឡេងដូចគ្នាដែលត្រូវបានប្រកាសដោយយកចិត្តទុកដាក់បន្ថែមទៀតដើម្បីឱ្យច្បាស់។ នេះត្រូវបានគេយកធ្វើជាគំរូតំណាងនៃរបៀបប្រយ័ត្នជាងរបស់អ្នកនិយាយ។ នៅពេលដែលអ្នកនិយាយនិយាយកន្សោមពាក្យម្តងទៀតថា ជាន់ទីបួន (fourth floor) ប្រេកង់នៃព្យញ្ជនៈក្រោយស្រៈ (postvocalic) របស់សូរព្យញ្ជនៈ /r/ កើនឡើងនៅក្នុងក្រុមទាំងអស់។ ការកើនឡើងប្រេកង់សំខាន់បំផុត គឺស្ថិតក្នុងចំណោមក្រុមរបស់ផ្សារMacy។ នៅក្នុងការរកឃើញមួយដែលត្រូវបានបញ្ជាក់នៅក្នុងការសិក្សាផ្សេងទៀត អ្នកនិយាយថ្នាក់កណ្តាលទំនងជាផ្លាស់ប្តូររបៀបនៃការនិយាយរបស់ពួកគេយ៉ាងសំខាន់នៅក្នុងទិសដៅនៃវណ្ណៈកណ្តាលជាន់ខ្ពស់ នៅពេលពួកគេកំពុងប្រើរបៀបប្រុងប្រយ័ត្ន។

វាអាចប្រើទម្រង់ការកណ្តាលយ៉ាងល្អិតល្អន់បន្ថែមទៀត ដើម្បីបង្កើតលំដាប់បន្ថែមនៅក្នុងប្រភេទផ្សេងៗនៃរចនាបទ។ ការស្នើសុំឱ្យអ្នកណាម្នាក់អានអត្ថបទខ្លីៗឱ្យឮៗ នឹងនាំឱ្យមានការយកចិត្តទុកដាក់ចំពោះការនិយាយជាជាងសួរពួកគេឱ្យឆ្លើយសំណួរមួយចំនួននៅក្នុងបទសម្ភាស។ ការស្នើសុំឱ្យបុគ្គលដដែលនោះអានឱ្យបានច្បាស់នូវបញ្ជីពាក្យនីមួយៗ ដែលដកស្រង់ចេញពីអត្ថបទ នឹងនាំឱ្យមានការបញ្ចេញសំឡេងយ៉ាងប្រុងប្រយ័ត្នជាងមុននៃពាក្យទាំងនោះ ដូច្នេះមានលក្ខណៈជាផ្លូវការនៃរបៀបនិយាយរបស់បុគ្គលម្នាក់ៗ។

នៅពេលដែល លោក ឡាបូវ (Labov) វិភាគវិធីដែលអ្នកញូវយ៉កសម្តែងក្នុងដំណើរការប្រកបដោយភាពវាងវៃនេះ គាត់បានរកឃើញថាមានការកើនឡើងជាទូទៅនៃការថតចម្លងក្រោយ /r/ ក្នុងក្រុមទាំងអស់នៅពេលដែលភារកិច្ចត្រូវការការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការនិយាយ។ ក្នុងចំណោមអ្នកនិយាយវណ្ណៈកណ្តាល ការកើនឡើងគឺអស្ចារ្យខ្លាំងណាស់នៅក្នុងការបញ្ចេញសំឡេងនៃបញ្ជីពាក្យដែលភាពញឹកញាប់នៃការស្តាប់សូរ /r/ គឺពិតជាខ្ពស់ជាងក្នុងចំណោមអ្នកនិយាយថ្នាក់កណ្តាល។ ដូចដែលការសិក្សាផ្សេងទៀតបានបញ្ជាក់នៅពេលដែលអ្នកនិយាយនៅក្នុងក្រុមដែលមានឋានៈកណ្តាលព្យាយាមប្រើទម្រង់មុខមាត់ដែលមានទំនាក់ទំនងជាមួយក្រុមដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងស្ថានភាពផ្លូវការ ពួកគេមានទំនោរក្នុងការប្រើទម្រង់បែបបទហួសកម្រិត។

សរុបមកតាមការស្រាវជ្រាវរបស់លោក វិលីយាម ឡាបូវ បានបញ្ជាក់ឱ្យឃើញថាការវិវត្តនៃភាសាតែងប្រព្រឹត្តទៅតាមជាន់ថ្នាក់ តាមស្រទាប់សង្គម ការវិវត្តក្នុងភាសាទាក់ទងនឹងរយៈកាលនិងការប្រើប្រាស់ភាសាមានការផ្លាស់ប្តូរយ៉ាងជាក់ស្តែងទៅតាមតំបន់។

## ២.៣. ទ្រឹស្តីរយៈត្រីះរបស់លោក ហ្សង់ ហ្គាញើចាំង

ភាសាបានវិវត្តជាប្រព័ន្ធដែលមាន៣ទិស គឺ រយៈកាល រយៈតំបន់ និងរយៈក្រុម។

**(១) រយៈកាល៖** ភាសាវិវត្តជាសម្តីសំដៅប្លែកៗតាមដំណាក់កាលឬជាកាលយោបាយ ដូចជាយោបាយមុនអង្គរ យោបាយក្រោយអង្គរ យោបាយបច្ចុប្បន្ន។

**(២) រយៈតំបន់៖** ភាសាជាសម្តីសំដៅតាមតំបន់ឬវិវត្តជាទេសយោបាយ ដូចជាយោបាយអ្នកក្រុងយោបាយអ្នកជនបទ យោបាយខ្មែរកម្ពុជាក្រោម យោបាយខ្មែរសុរិន្ទ្រ។

(៣) **វយៈក្រុម៖** ភាសាវិវត្តជាសម្ដីសំដៅតាមក្រុមឬវិវត្តជាវណ្ណយោបាយ ដូចជាយោបាយស្ដេច យោបាយមន្ត្រី យោបាយកម្មករ។

## ៣. ការស្វែងយល់ពីបញ្ញត្តិមួយចំនួនតាមរយៈគ្រឹះទ្រឹស្ដី

### ៣.១. សំនួនវត្តមានវិស័យនិងសំនួនអវត្តមានវិស័យ

ហ្សង់ក្លូត ធីវ៉ាលីយេ យល់ថាបន្លែករវាងភាសានិយាយនិងភាសាសរសេរជាគំនិតឥតមានប្រាកដនិយមអ្វីទេ។ ពាក្យ និយាយ ជួនកាលសម្គាល់សំនួនណាដែលចេញជាសំឡេង ជួនកាលសម្គាល់សំនួនចេញពីមាត់ឥតព្រាងទុកជាមុន ហើយដែលមានឃ្លាល្បះខ្ចីខ្ចា។ ពាក្យសរសេរ ជួនកាលសម្គាល់សំនួនណាដែលកត់ត្រាដោយអក្សរដែលគេរៀបចំឃ្លាល្បះសម្អិតសម្អាងក្ដីឬសំនួនគ្រាន់តែជាការចម្លងជាលាយលក្ខណ៍អក្សរនៃសម្ដីនិយាយខ្ចីខ្ចាក្ដី។

លោក ក្លូត អាហ្សែស យល់ថា ភាសាសរសេរមិនមែនជាភាសានិយាយ ដែលគេគ្រាន់តែដាក់ជាលាយលក្ខណ៍អក្សរនោះទេ។ សរសេរដូចគេនិយាយជាការធ្វេសប្រហែស។ និយាយដូចគេសរសេរជាសញ្ញានៃអាកប្បកិរិយាអំណួត។

សំនួនវត្តមានភាពបានប្រើសូរសៀងដែលសំនួនអវត្តមានភាពបានខំសងវិញដោយប្រើសន្មតសញ្ញាផ្សេងៗដូចសញ្ញាក្បៀស សញ្ញាឧទានជាដើម។ ឧ. គាត់ផឹក|តែមួយកែវ| ≠ គាត់ផឹកតែ|មួយកែវ|។

ពាក្យ «និយាយ» និង «សរសេរ» សង្គមភាសាវិទ្យាមិនប្រើ ហើយប្រើសំនួនវត្តមានវិស័យនិងសំនួនអវត្តមានវិស័យវិញ។

**ក. សំនួនវត្តមានវិស័យ**

សំនួនវត្តមានវិស័យមានលក្ខណៈដូចខាងក្រោម៖

-អ្នកនិយាយនិងអ្នកស្ដាប់នៅជិតគ្នា បទអន្តរាគមន៍ភ្លាមៗ។

-សំនួនស្វ័យប្រវត្តិ អាចសាចុះសាឡើង បើមានខុសបន្តិចបន្តួច គេអាចរៀបសេចក្ដីជាថ្មីឡើងវិញភ្លាមៗបាន។

-ល្បះងាយៗអាចច្រំដែល គ្មានឈ្នាប់ សន្ធានសព្ទ។

-វាក្យសព្ទសាមញ្ញ ពាក្យធម្មតា ពាក្យវត្តមានុបករណ៍សម្រាប់ក្សោជំនាប់វាចា។

-មានបរិវត្តនិងស្ថានភាពជាបង្អែក។

-វត្តមាននៃបរិវត្តអនុញ្ញាតឱ្យបង្រួមសេចក្ដី នុះន៎! ល្អអស្ចារ្យ!

-កាយវិការ តម្រាប់ ទឹកមុខ សូរសៀង អនុញ្ញាតឱ្យបន្ថយនិទានកថា។

**ខ. សំនួនអវត្តមានវិស័យ**

សំនួនអវត្តមានវិស័យមានលក្ខណៈសម្គាល់ដូចខាងក្រោម៖

-ម្ចាស់សារនិងអ្នកទទួលនៅឆ្ងាយពីគ្នា បទអន្តរាគមន៍ពន្យារ។

-វាចារៀបរៀង ម្ចាស់សារមានពេលគិតនិងកែជាមុន។

-សម្ព័ន្ធចិត្តផ្ទង់ ល្បះល្បោយ វែង ច្រើនមានឈ្នាប់។

-ពាក្យជម្រើស អាចជាពាក្យវប្បធម៌។

-គ្មានបរិវត្តនិងស្ថានភាពជាបង្អែកទេ។

-និទានកថាវែងអន្លាយ ៖ ម្សិលមិញខ្ញុំបានឃើញនារីម្នាក់ក្នុងសួន ដែលមានរូបឆោមល្អអស្ចារ្យ។

-អ្វីៗទាំងប៉ុន្មានដែលមិនអាចបញ្ជូនតាមសំណេរត្រូវវាយជាសេចក្ដីហូរហែជាសន្មតសញ្ញាជំនួសវិញ ដូចជាសញ្ញាក្បៀស សញ្ញាសួរ សញ្ញាឧទាន។

### ៣.២. សណ្ឋានភាសានិងកម្រិតភាសា

កម្រិតភាសា គឺជាសណ្ឋានភាសាមួយបែបបណ្ដាសណ្ឋានភាសាទាំងឡាយដែលមានក្នុងកាលយោបាយ ទេសយោបាយ និងវណ្ណយោបាយ។

កម្រិតភាសាត្រូវបានលោក ដោនរ៉ូស ចែកជា៥ថ្នាក់ គឺៈ

-កម្រិតសោភ័ណៈ ស្វែងរកសោភ័ណភាព ដូចជាសុន្ទរកថា ទេសនា។

-កម្រិតប្រសើរៈ ស្វែងរកពាក្យចំៗ រកអត្ថសញ្ញាណភាព ដូចជាសន្និសីទ សិក្សាកថា បទអន្តរាគមន៍ វិទ្យាសាស្ត្រ។

-កម្រិតមធ្យមៈ កម្រិតស្តង់ដា វាក្យសព្ទនិងល្បះធម្មតា តែត្រឹមត្រូវតាមវេយ្យាករណ៍ ដូចជាវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ការសន្ទនារវាងមិត្តភក្តិនិងមិត្តភក្តិ។

-កម្រិតសាមញ្ញៈ ភាសាមិនសូវប្រយ័ត្នប្រយែង ច្រើនទាសពីក្បួនវេយ្យាករណ៍ខាងសម្ព័ន្ធ ច្រើនប្រើពាក្យកម្រិតទាប ដូចជាការជជែកគ្នាលែងរវាងគូកន។

-កម្រិតខ្ជីខ្ជាៈ ភាសាឥតប្រយ័ត្នប្រយែង សម្ព័ន្ធច្រើនទាសពីក្បួនវេយ្យាករណ៍ ច្រើនប្រើពាក្យមិនសូវសមគួរ និងពាក្យប្រចាំក្រុមតំបន់ ដូចជាការជជែកគ្នាលេងរវាងដៃគូ រវាងជនស្រទាប់ទាបខ្លាំង។

### ៤. យោបាយល្បាយ

យោបាយល្បាយកើតឡើងពីការជួបប្រទះគ្នារវាងអរិយភាសាឬតន្តិភាសា និងភាសាដែលនៅខ្សត់ខ្សោយ ឬរវាងតន្តិភាសាខ្សត់ខ្សោយជាច្រើនក្នុងស្ថានភាពដែលបណ្ដាលឱ្យកើតភាសាចម្រុះមួយចំនួនហៅ «ពិតឈីន» ដែលមានតន្តិភាសាជាស្នូល ជាពិសេសខាងផ្នែកវាក្យសព្ទ។ ពិតឈីន (pidgin) អាចរលាយទៅវិញ បើអ្នកប្រើប្រាស់ត្រូវបែកខ្ញែកគ្នាឬអាចក្លាយទៅជាភាសាហៅ «ក្រេអូល» បើក្រុមអ្នកប្រើប្រាស់មានភព្វសំណាងក្លាយទៅជាសហគមន៍ ដូចជាសហគមន៍ហៃទី ដែលបានក្លាយរហូតទៅជាជាតិមួយដែលមានប្រទេសផ្ទាល់ខ្លួន (ទទួលបានពីចៅហ្វាយចាស់ដែលជានិគមជនបារាំង)។

### ៤.១. សាបៀរ

សាបៀរ (Sabir) ជាឧបករណ៍សម្រាប់ទាក់ទងគ្នារវាងសហគមន៍ផ្សេងៗ ដែលស្ថានការណ៍បានជំរុញឱ្យនៅជាមួយគ្នា ដូចជានៅក្រុងជំនួញអន្តរជាតិឬសហគមន៍ទាសករខ្មៅ ដែលគេបានចាប់ពីកុលសម្ព័ន្ធផ្សេងៗនៃទ្វីបអាព្រិក ហើយដែលគេបានបង្ខំឱ្យធ្វើការជាមួយគ្នានៅក្នុងចម្ការកប្បាសជាដើម។ សហគមន៍ទាំងនោះមានកម្លាំងស្មើគ្នាហើយគ្មានសហគមន៍ណាអាចបង្ខំសហគមន៍ឯទៀតឱ្យប្រើភាសាខ្លួនឡើយ ដូច្នេះហើយសហគមន៍ទាំងនោះត្រូវប្រើពាក្យខ្ចីពីភាសានេះខ្លះ ពីភាសានោះខ្លះ ព្រមទាំងប្រើកាយវិការថែមទៀត ដើម្បីបង្គ្រប់សេចក្តីត្រូវការ។ ចំពោះសហគមន៍នៃចម្ការកប្បាស ភាសាម្ចាស់ចម្ការបានចូលទៅជាស្នូលនៃសាបៀររបស់ពួកគាត់។ សាបៀរជាឧបករណ៍ខ្សត់ខ្សោយបំផុត នៅឆ្ងាយពីលក្ខណៈនៃភាសាធម្មតា។

### ៤.២. ពិតឈីន

ដើមដំបូង ពិតឈីន (Pidgin) ជាឧបករណ៍ទំនាក់ទំនងប្រើលើកោះនានាក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដែលមានពាក្យភាសាអង់គ្លេសជាស្នូលលាយគ្នានិងពាក្យភាសានានាលើកោះទាំងនោះ។ នៅប្រទេសក្រោមឥទ្ធិពលបារាំង ឧបករណ៍បែបគ្នានេះហៅថា «parler petit nègre» ប៉ុន្តែឥឡូវនេះបារាំងក៏ប្រើពាក្យ «ពិតឈីន» ដែរ ហើយពាក្យនេះថែមទាំងត្រូវគេប្រើជាទូទៅសម្រាប់សម្គាល់ឧបករណ៍ទំនាក់ទំនងខ្សត់ខ្សោយ ដែលបានកើតក្នុងអាណានិគមទោះអាណានិគមអង់គ្លេសក្តី អាណានិគមបារាំងក្តី និងអាណានិគមអេស្ប៉ាញក្តី។ ពិតឈីនមានវាក្យសព្ទច្រើនជាងសាបៀរឆ្ងាយណាស់ តែមិនទាន់បានក្លាយទៅជាភាសានៅឡើយទេ ពីព្រោះវាមិនមានវេយ្យាករណ៍ជាក់លាក់ ទោះក្នុងផ្នែកសទ្ទតាក្តី ក្នុងផ្នែកមូលតាក្តី ក្នុងផ្នែកសម្ព័ន្ធក្តី។ ដោយអ្នកប្រើឧបករណ៍នោះយកសូរពីភាសានេះផង

ពីភាសានោះផង មានសូរខ្លះជាសូររួម សូរខ្លះជាសូរពិសេសរបស់ក្រុមណាមួយ ដែលក្រុមឯទៀតមិនប្រើ។ សូរខ្លះបានក្លាយទៅជាសទ្ទតា ឯសូរខ្លះនៅត្រឹមតែជាសូរ។ ពាក្យកម្ចីពីភាសានានាសឹងសុទ្ធតែនៅត្រឹមជាវាក្យសព្ទប៉ុណ្ណោះ។ វិធីបង្កើតពាក្យថ្មី គ្រាន់តែជាពន្លកតិចតួចស្តួចស្តើង។ សម្ព័ន្ធក៏គ្មានស្ថិរភាពឬឯកភាពដែរ ពោលគឺក្រុមខ្លះប្រើបែបនេះ ក្រុមខ្លះប្រើបែបនោះ ហើយក្រុមដដែលឬមនុស្សដដែលប្រើម្តងយ៉ាងនេះ ម្តងយ៉ាងនោះ ក៏ប៉ុន្តែសមាជិកសហគមន៍ដែលប្រើពិតឈីនអាចស្តាប់គ្នាបាន ពីព្រោះទោះម្នាក់ៗ មិនទាន់ប្រើពាក្យឬឃ្លាប្រយោគទាំងអស់ដូចគ្នាក៏ដោយ ក៏គេធ្លាប់ប្រទះពាក្យឬឃ្លាប្រយោគទាំងនោះរួចមកហើយ (ព្រុំ ម៉ល់, ២០១៣: ២៨)។

នៅពេល គ្រុសាដេស៍ (Crusaders) បានធ្វើដំណើរទៅកាន់ ហូលី លេនដ៍ (Holy Land) ជាទីកន្លែងដែលមានមនុស្សមកពីតំបន់ផ្សេងៗគ្នានៃប្រទេស ហើយពួកគេនិយាយភាសាខុសៗគ្នា។ ដើម្បីដោះស្រាយវិបត្តិដែលកើតមានឡើងក្នុងការទាក់ទងគ្នារបស់ពួកគេ ពួកគេបានប្រើប្រាស់ភាសារួមមួយ គឺភាសាបារាំង ហើយពួកគេបានធ្វើការកំណត់ន័យថា ប្រូវេនកាល (Provencal) គឺជាភាសាដែលប្រើប្រាស់សម្រាប់ប្រជាជននៅតំបន់ភាគខាងត្បូងនៃប្រទេសបារាំង។ ដោយសារតែមូលហេតុនេះ ពាក្យ លីនហ្គា ហ្វ្រង់កា (Lingua Franca) ត្រូវបានគេប្រើសម្រាប់សម្គាល់នូវភាសាផ្សេងទាំងឡាយណា ដែលក្រុមអ្នកភាសាវិទ្យាអាចរកភាសារួម ដើម្បីប្រើក្នុងការទាក់ទងគ្នាក្នុងចំណោមក្រុមដែលនិយាយភាសាច្រើនផ្សេងគ្នា។

លីនហ្គា ហ្វ្រង់កា អាចជាភាសាធម្មជាតិ ដែលមានន័យថាការនិយាយភាសាកំណើត នៅពេលណាមួយតាមរយៈក្រុមមនុស្សមួយចំនួន។ ដូចដែលគេធ្លាប់ឃើញចំពោះភាសាក្រិកនិងឡាតាំង ដែលប្រើរបៀបនេះកាលពីមុន ហើយនិងភាសាស្វាហិលី (Swahili) ដែលទំនងជាត្រូវបានគេប្រើដូចគ្នានេះដែរ នៅក្នុងប្រទេសអាហ្វ្រិកសព្វថ្ងៃ។ តែទោះជាយ៉ាងណាក៏ដោយ វិធីនេះមិនមែនជាដំណោះស្រាយសមស្របនោះទេ ពីព្រោះវាមិនមែនជារឿងងាយស្រួលក្នុងការធ្វើឱ្យភាសាណាមួយមានការឯកភាពដូច្នេះទេ ឬក៏ជំរុញចិត្តអ្នកដែលមានបញ្ហាបែបនេះឱ្យរៀនពីវិធីនេះបានរហ័សឡើយ។

រឿងនេះនឹងរឹតតែមានភាពទូទៅចំពោះ លីនហ្គា ហ្វ្រង់កា បើគេចាត់ទុកទៅក្នុងប្រភេទមួយដែលគេស្គាល់ថា ពិតឈីន។ និយមន័យហើយនិងការប្រើប្រាស់ពាក្យ ពិតឈីន មានច្រើនក្នុងអក្សរសិល្ប៍ ចំណែកនៅក្នុងសៀវភៅនេះវិញ ការផ្តល់និយមន័យនៃពាក្យ ពិតឈីននេះថា ជារបៀបនៃការនិយាយ ដែលមិនមែនជាភាសាកំណើតរបស់អ្នកណាម្នាក់ឡើយ ប៉ុន្តែវាត្រូវបានបង្ហាញតាមរយៈការវិវត្តនៃភាសាពីរយ៉ាងតិច។ តាមធម្មតា ពិតឈីន មាននូវចំណែកដ៏ធំនៃពាក្យសព្ទនិងសូររបស់ភាសា ប៉ុន្តែវាធ្វើឱ្យមានភាពងាយស្រួលទាំងរូបសព្ទនិងសម្ព័ន្ធរបស់ភាសានេះខ្លួនឯង។ ជាតុមួយចំនួនដូចជា វេយ្យាករណ៍ លិង្គ ការវែកញែក ការវិភាគលម្អិតអំពីកាលនៃកិរិយាសព្ទផ្សំ និងប្រព័ន្ធដ៏សាំញ៉ាំនៃសព្វនាម គឺត្រូវបានគេលប់ចេញនៅពេលគេប្រើទៅជាភាសាពិតឈីន។

នៅពេលដែលមនុស្សនិយាយ ភាសាពិតឈីន សម្រាប់មូលហេតុមួយ ឬមូលហេតុផ្សេងទៀត ដោយមានភាពដាច់ចេញពីភាសារបស់សហគមន៍ឯទៀតនោះ វាអាចធ្វើឱ្យអ្នកជំនាន់ថ្មីដែលចាប់កំណើតឡើងមិនអាចទទួលយកនូវភាសាដទៃផ្សេងទៀត ក្រៅតែពីភាសាពិតឈីនទេ។ ភាសាពិតឈីនដែលបានក្លាយទៅជាភាសាកំណើតនោះត្រូវបានគេហៅថា ក្រេអូល ដែលធ្វើឱ្យគេពិបាកក្នុងការកំណត់។

ភាសាមេទីស (Métis) ជាភាសាមួយដែលគេនិយាយនៅក្នុងប្រទេសកាណាដាភាគខាងជើង ដែលកើតចេញពីទំនាក់ទំនងរវាងភាសាបារាំងនិងភាសាគ្រីឥណ្ឌា (Cree Indian)។ វាមានការលំបាកណាស់នៅក្នុងការកំណត់ថាតើ ភាសាមេទីស ជាប្រភេទពិតឈីនឬក៏ជាប្រភេទក្រេអូល ប៉ុន្តែវាបានផ្តល់នូវឧទាហរណ៍ដ៏ល្អមួយចំនួនចំពោះលទ្ធផលនៃភាសាដែលមានលក្ខណៈទំនាក់ទំនងបែបនេះ។

ពិតឈីន នឹងត្រូវលេប់បាត់បង់យ៉ាងឆាប់រហ័ស ប្រសិនជានៅពេលដែលប្រជាជនដែលនិយាយពិតឈីនត្រូវប្រើភាសាផ្សេងដើម្បីសមស្របក្នុងជីវិតរស់នៅ ព្រោះថា ពិតឈីនគ្រាន់តែគេប្រើក្នុងការបំពេញបន្ថែមសម្រាប់

អ្នកនិយាយភាសាកំណើត ហើយមិនសូវមានអ្នកចូលចិត្តប្រើប្រាស់វានោះទេ។ ចំពោះក្រេអូលវិញ ប្រហែលជាមានភាពឋិតថេរយូរអង្វែងជាង ដោយសារតែលីនហ្គា ហ្វ្រង់កា លែងត្រូវគេយកចិត្តទុកដាក់ ហើយប្រសិនបើអ្នកនិយាយភាសាកំណើត នៅដាច់ឆ្ងាយពីប្រជាជនដទៃផ្សេងទៀត។ នេះជាអ្វីដែលកើតមានឡើងជាមួយនឹងលក្ខណៈមូលដ្ឋាននៃក្រេអូល ក្នុងភាសាអង់គ្លេស ដែលគេឱ្យឈ្មោះថាហ្គុលឡាស (Gullah) ហើយត្រូវបាននិយាយដោយប្រជាជនដែលរស់នៅលើកោះ ស៊ី អ៊ីសលេនដ៍ (Sea Island) ដែលនៅដាច់ពីឆ្នេរសមុទ្រកាឡូរីណា (Carolina) ភាគខាងត្បូង។ ការរស់នៅដាច់ពីគេឯងរបស់ប្រជាជនលើកោះនេះ បានធ្វើឱ្យពួកគេនិយាយភាសាហ្គុលឡាស ហើយអាចរក្សាជីវិតនៃភាសានេះមិនឱ្យបាត់បង់។

នៅក្នុងភាសាអង់គ្លេសស្តង់ដារ បានធ្វើការបែងចែកពាក្យទៅតាមភាពខុសប្លែកគ្នាតាមលិង្គចំពោះសព្វនាមបុរិសៈ បុរសទីបីឯកវចនៈ។ ចំណែកនៅក្នុងភាសាហ្គុលឡាស មិនមានការបែងចែកដូចក្នុងភាសាអង់គ្លេសនោះទេ គឺគេប្រើតែទម្រង់នៅខាងក្រោយ *him, im,* និង *e* ចំពោះទម្រង់បុំលិង្គទាំងអស់ដែលក្លាយមកពីភាសាអង់គ្លេស។ បន្ថែមពីលើនេះទៅទៀត បើទោះបីជាសព្វនាមបុរិសៈបុរសទី១ ក្នុងភាសាហ្គុលឡាស ដែលបន្សល់ទុក *I, me, my, we* ប៉ុន្តែក៏មិនបានទុក *us* នោះទេ។ អ្វីដែលលើសពីនេះទៅទៀតនោះគឺ ក្នុងភាសាហ្គុលឡាស មិនមាន *you* ទាំងឯកវចនៈ និងពហុវចនៈ នោះទេ គឺគេប្រើតែ *un* ជំនួស ហើយវាក៏មិនមានដែរនៅក្នុងភាសាអង់គ្លេស។

គេតែងតែយល់ថា វាប្រហែលជាមានប្រយោជន៍ ក្នុងការប្រើប្រាស់តែភាសាមួយសម្រាប់អ្នកទាំងអស់គ្នាក្នុងការទាក់ទងគ្នា ដើម្បីសម្រួលដល់ការលំបាកដែលធ្លាប់មានក្នុងការទាក់ទងទាំងថ្នាក់ជាតិនិងអន្តរជាតិ។ ភាសាដែលគេប្រើនេះនឹងក្លាយទៅជា លីនហ្គា ហ្វ្រង់កា សម្រាប់ពិភពលោក ហើយវានឹងមិនមានបញ្ហាអ្វីទៀតនោះដែរ។

តែទោះជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តនេះមិនអាចទៅមុខបានទេ នៅពេលដែលគេពិភាក្សាដល់ចំណុចរកភាសាណាមួយធ្វើជាភាសាឯកភាពនោះ។ អ្វីដែលជាបញ្ហានោះគឺថា តើគេគួរប្រើភាសាមួយណា? បុគ្គលម្នាក់ៗតែងចង់យកភាសារបស់ខ្លួនមកប្រើជាសកលដោយមិនខ្វល់ពីភាសាផ្សេងៗទៀតទេ។

ជុំវិញបញ្ហានេះមានការលើកឡើងពីមធ្យោបាយមួយ គឺរកនូវភាសាជំនួយ «ភាសាជំនួយអន្តរជាតិ» ដែលមិនមែនជាភាសារបស់ជាតិសាសន៍ណាមួយនោះទេ ប៉ុន្តែគេបង្កើតភាសានេះឡើង ដើម្បីទៅជាភាសាមួយ ដែលដូចជា លីនហ្គា ហ្វ្រង់កា។ ភាសាជំនួយថ្មីនេះត្រូវបានគេឱ្យឈ្មោះថា អេស្ពេរ៉ាន់តូ (Esperanto) ដែលត្រូវបានបំប្លែងចេញពីភាសាអង់គ្លេស ដោយ លោក ឡុតវិក ហ្សាមេនហូហ្វ (Ludwig Zamenhof)។

តាមការប៉ាន់ស្មានពីចំនួនអ្នកនិយាយភាសាអេស្ពេរ៉ាន់តូ សព្វថ្ងៃ គឺមានចំនួនចាប់ពីរាប់រយពាន់នាក់ឡើងទៅ។ ទីស្នាក់ការធំនៃភាសាអេស្ពេរ៉ាន់តូ មានឈ្មោះថាសមាគមន៍អេស្ពេរ៉ាន់តូសកល (The Universal Esperanto Association) មានទីតាំងស្ថិតនៅក្នុងទីក្រុងរ៉ូតធើដាម (Rotterdam) ហើយមានសមាជិកចូលរួមចំនួនជាង១០០ប្រទេស។ គេឃើញមានសៀវភៅជាង ៣០,០០០ក្បាល ដែលសរសេរជាភាសានេះ ហើយក្នុងពេលបច្ចុប្បន្ននេះក៏មានអក្សរសិល្ប៍ច្បាប់ដើមជាភាសាអេស្ពេរ៉ាន់តូ ដែរ ដែលគេបានធ្វើការបកប្រែរួច។ នៅក្នុងប្រទេសមួយចំនួនដូចជា អ៊ីតាលី អូទ្រីស និងហូឡង់ គេឃើញមានការបង្រៀនភាសាអេស្ពេរ៉ាន់តូ នៅក្នុងសាលាដោយចាត់ទុកជាភាសាបរទេសដូចទៅនឹងភាសាបរទេសដទៃទៀត។ នៅពេលបច្ចុប្បន្ននេះភាសាអេស្ពេរ៉ាន់តូត្រូវបានគេយកទៅផ្សព្វផ្សាយក្នុងកម្មវិធីវិទ្យុរបស់បុរីវ៉ាទីកង់ ដោយធ្វើការផ្សាយកម្មវិធីប្រចាំសប្តាហ៍មួយដែលប្រើប្រាស់ភាសាអេស្ពេរ៉ាន់តូ តាមរយៈរលកជាតុអាកាសប្រាំមួយផ្សេងគ្នា គឺរលកជាតុអាកាសបី ផ្សាយទៅកាន់ទ្វីបអឺរ៉ុប និងបីផ្សេងទៀតផ្សាយទៅកាន់ទ្វីបអាព្រិក។ ភាសាអេស្ពេរ៉ាន់តូ មានការពេញនិយមជាខ្លាំងនៅប្រទេសជប៉ុននិងប្រទេសចិន ហើយសូម្បីតែនៅសហរដ្ឋអាមេរិក ក៏មានសមាគមន៍អេស្ពេរ៉ាន់តូ ដ៏ធំមួយដែរ ហើយរហូតមានបើកសន្និបាតរបស់ខ្លួនជាញឹកញាប់ទៀតផង។ យុវជនអាចចាប់ផ្តើមប្រើប្រាស់ភាសានេះបានដោយងាយស្រួលបន្ទាប់ពីការបង្រៀនដែលប្រើរយៈពេលតែពីរម៉ោងប៉ុណ្ណោះ ហើយកុមារម្នាក់ៗវិញ នៅពេលដែលបានរៀនភាសានេះអស់រយៈពេលប្រាំមួយម៉ោង ពួកគេ

អាចធ្វើការទាក់ទងជាមួយកុមារដទៃទៀតនៅជុំវិញពិភពលោកតាមរយៈការផ្លាស់ប្តូរជាអន្តរជាតិ ដែលគេឱ្យឈ្មោះថា ហ្គ្រាណូយ អង់ វេនតូ (Granoj en Vento)។

ការលើកឡើងមកនេះមើលទៅហាក់ដូចជាមានអត្ថប្រយោជន៍ ប៉ុន្តែតើអ្វីទៅដែលអាចធ្វើឱ្យប្រជាជននៅលើពិភពលោកមានការយល់ព្រមគ្នាជាឯកច្ឆន្ទចាត់ទុកភាសាអេស្ពេរ៉ាន់តូ ជាភាសាអន្តរជាតិមួយនោះ។

**៤.៣. ក្រេអូល**

ក្រេអូល (Creole) គឺជាពិតឈីនដែលបានរីកចម្រើន ហើយចាប់មានស្ថិរភាពដោយមានឱកាសល្អ ឧទាហរណ៍ កូនចៅទាសករដែលគេបានចាប់ពីប្រទេសនានានៃទ្វីបអាហ្វ្រិក យកទៅលក់នៅកោះអង់ទីយ (ជិតទ្វីបអាមេរិក) មិនចេះភាសាកំណើតរបស់ឪពុកម្តាយខ្លួនទេ ហើយចេះតែពិតឈីនដែលជាហេតុឱ្យពិតឈីននេះក្លាយទៅជាភាសាកំណើតរបស់អ្នកទាំងនោះ ហើយគេហៅថា «ក្រេអូល» នេះឯង។

ក្រេអូល ជាភាសាគ្រប់លក្ខណៈ ពីព្រោះវាជាភាសាកំណើតរបស់សហគមន៍ណាមួយ មានស្ថិរភាពក្នុងផ្នែកសទ្ទតា បូរណសព្ទ និងសម្ព័ន្ធ។

វត្តមាននៃភាសាក្រេអូល ពេលខ្លះត្រូវបានគេដកស្រង់ជាទ្រឹស្តីជំនួយ ជាពិសេសតាមរយៈទ្រឹស្តីជីវភាសាប្រកបដោយភាពចម្រូងចម្រាស់ដែលចងក្រងឡើងដោយ លោក ប៊ីកកេតុន (Bickerton)។ ក្រេអូល គឺជាភាសាមួយប្រភេទដែលកើតឡើងនិងរីកលូតលាស់ធំធាត់ នៅពេលដែលមានការចងក្រងឡើងនូវសង្គមផ្សេងៗគ្នាឱ្យក្លាយជាសង្គមចម្រុះមួយ ហើយវាទាមទារឱ្យមានការប្រើប្រាស់ភាសាមួយជាគោលសម្រាប់ធ្វើការទាក់ទងគ្នា។ ប្រព័ន្ធភាសាដែលរៀបចំឡើងដោយអ្នកនិយាយភាសាដើម ជាទូទៅមានលក្ខណៈមិនស៊ីគ្នាសម្រាប់ការប្រើប្រាស់បច្ចេកសព្ទចម្រុះនិងប្រឫកប្រុបល់ ដែលគេឱ្យឈ្មោះថាពិតឈីន។ ក្នុងខណៈដែលកូនៗរបស់ពួកគេទាំងនោះ ចាប់ផ្តើមទទួលយកភាសាកំណើត ពួកកុមារទាំងនោះបានទទួលយកនូវទិន្នន័យភាសាដែលមិនត្រឹមត្រូវ ដើម្បីបង្កើតជាភាសាកំណើតរបស់ខ្លួនផ្ទាល់ដ៏មានប្រសិទ្ធភាព ដែលគេឱ្យឈ្មោះថា ក្រេអូល។ ខុសអំពីពិតឈីន ដោយសារភាសាក្រេអូលមានអ្នកនិយាយជាជនជាតិដើម (native speakers) ហើយប្រើប្រាស់នូវវេយ្យាករណ៍យ៉ាងពេញលេញ។

បើយោងទៅតាមលោក ប៊ីកកេតុន ( Bickerton) ទស្សនៈនៃវេយ្យាករណ៍សកល ត្រូវគាំទ្រដោយភាសាក្រេអូល ពីព្រោះសមាសធាតុពិតប្រាកដនានាត្រូវបានចែករំលែកជាមួយនឹងភាសាទាំងអស់នេះ។ ជាឧទាហរណ៍ជាក់ស្តែង ការប្រើប្រាស់នូវកាលៈទេសៈជាសេចក្តីយោងនៅក្នុងភាសានេះ (ត្រូវបង្ហាញឡើងតាមរយៈបណ្តាញកិរិយាសព្ទ) មិនមែនជាខណៈពេលបច្ចុប្បន្នទេ ប៉ុន្តែវាជាអតីតកាល។ តាមរយៈការប្រើប្រាស់កិរិយាជំនួយដើមក្នុងការនិយាយ គេអាចបង្ហាញជាសណ្ឋាននៃកាល ទិដ្ឋភាព និងម៉ូត។ សំឡេងស្របគ្នាបានលេចឡើង ប៉ុន្តែវាជះឥទ្ធិពលលើប្រធាននៃការនិយាយ (ជាការមិនឆ្លើយទៅនឹងកម្មបទ ដូចមាននៅក្នុងភាសាអេស្ប៉ាញជាដើម)។ ភាពស្រដៀងគ្នានានានៃបណ្តាភាសាក្រេអូលគឺថា សំណួរត្រូវបានបង្កើតឡើងជាធម្មតាជាមួយនឹងការផ្លាស់ប្តូរទៅលើការលើកដាក់សំឡេងនៃប្រយោគបែបបញ្ហា មិនមែនជាលំដាប់នៃការរៀបចំពាក្យនោះទេ។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាបន្ថែមនិងស៊ីជម្រៅដោយលោក កាឡា ហាត់សុន កាំ (Carla Hudson-Kam) និង អេលីហ្សា ញូវផត (Elissa Newport) បានលើកឡើងថា ភាសាក្រេអូល អាចមិនគាំទ្រដល់វេយ្យាករណ៍សកលទេ ដោយហេតុថា ពេលខ្លះគេធ្វើការសន្មតវាឡើងប៉ុណ្ណោះ។ នៅក្នុងស៊េរីនៃបទពិសោធ កាឡា ហាត់សុន កាំ (Carla Hudson-Kam) និង អេលីហ្សា ញូវផត (Elissa Newport) បានពិនិត្យមើលថា តើកូនក្មេងនិងមនុស្សចាស់រៀនវេយ្យាករណ៍នៃភាសាកំណើតយ៉ាងដូចម្តេច។ អ្វីដែលគួរឱ្យកត់សម្គាល់ផងដែរនោះគឺថា ពួកគេបានពិនិត្យឃើញថាកុមារម្នាក់ៗមានចេតនាមិនចាប់អារម្មណ៍នូវភាពខុសគ្នាខ្លះៗនៅក្នុងទិន្នន័យភាសារបស់គេ នៅពេលដែលភាពខុសគ្នាទាំងនោះមិនមានភាពជាប់លាប់ ហើយបង្កើតភាសាមួយថ្មីដែលមានទម្រង់ថេរប៉ុណ្ណោះ។ ដោយការធ្វើបែបនោះ គេមានចេតនារៀបចំបទដ្ឋានភាសាដែលពួកគេបានឮនៅជុំវិញខ្លួន។ លោក កាឡា ហាត់សុន

កាំ (Carla Hudson-Kam) និង អេលីហ្សា ញូវផត (Elissa Newport) បានលើកជាសម្មតិកម្មឡើងទៀតថា នៅក្នុងស្ថានភាពភាសាពិតឈីន (និងនៅក្នុងស្ថានភាពជីវិតជាក់ស្ដែងនៃកុមារគថ្លង់ ដែលឪពុកម្ដាយរបស់ពួកគេមិនបានបង្រៀនសញ្ញាច្បាស់លាស់) កុមារទាំងនោះ បានរៀបចំប្រព័ន្ធភាសារបស់ខ្លួនដែលពួកគេដឹងតាមការប៉ាន់ប្រមាណនូវទម្រង់ ពោលគឺមិនដូចទៅនឹងការសន្មតនៃទ្រឹស្ដីក្នុងវេយ្យាករណ៍សកលនោះឡើយ។ លើសពីនេះទៅទៀត វាមិនមែនជាការគួឱ្យភ្ញាក់ផ្អើលទេ ដែលភាសាក្រេអូល អាចចែករំលែកនូវសមាសធាតុជាមួយភាសានានាដែលបានក្លាយមកពីភាពស្រដៀងគ្នាដែលគេហៅថាទុនវេយ្យាករណ៍នោះ។

សរុបមក សង្គមភាសាវិទ្យាជាភាសាវិទ្យាបែបថ្មីដែលទើបមានកំណើតជាង៣០ឆ្នាំប៉ុណ្ណោះ ដូច្នេះហើយវិជ្ជានេះមិនទាន់មានឯកភាពនៅឡើយក្នុងការយកទិដ្ឋភាពសង្គមមកបញ្ចូលក្នុងការសិក្សាពីភាសា។ ចលនាខ្លះទោរទៅរកសង្គមវិទ្យា ហើយទិដ្ឋភាពភាសាត្រូវកប់បាត់ក្រោមព្រឹត្តិការណ៍សង្គមដែលគេពណ៌នានិងយកជាធំ។ ទំនោរនេះចាត់ទុកសង្គមភាសាវិទ្យាជាផ្នែកមួយរបស់សង្គមវិទ្យា។ ចលនាដែលយើងអាចចាត់ទុកថា ជាសង្គមភាសាវិទ្យាពិតប្រាកដ គឺទំនោរដែលយកភាសាជាធំ តែទំនោរនេះក៏មិនទាន់មានឯកភាពក្នុងគ្រឹះមូលដ្ឋានឬគ្រឹះទ្រឹស្ដីនៅឡើយដែរ។

សង្គមភាសាវិទ្យាមានប្រយោជន៍ដល់អក្សរសិល្ប៍ច្រើនជាងភាសាវិទ្យាធម្មតា ពីព្រោះវិជ្ជានេះមិនគ្រាន់តែសិក្សាពីវេយ្យាករណ៍ប៉ុណ្ណោះទេ តែថែមទាំងវិភាគរកលក្ខណៈសង្គមក្នុងទម្លាប់វាចា ដោយសិក្សាអំពីសំនួន អំពីយោបាយ អំពីសណ្ឋាននៃភាសា (មានកម្ពស់វោហារ ប្រភេទទំនាក់ទំនង...) ទៀតផង។

## ៥. ការអនុវត្តទ្រឹស្ដីតាមទិសទាំងបីនៃរយៈគ្រឹះ

### ៥.១. កាលយោបាយ

#### ក. អត្ថបទសិលាចារឹកស្តុកកក់ធំ ពីបន្ទាត់ទី៥៦ ដល់បន្ទាត់ទី៦៦ ផ្ទាំងគ

(៥៦) មនវ្រះបាទបរមេស្វរ ប្រតិស្នាកម្រតេងជគត្តាជម្នោនគរស្រីមាហេន្ទ្របវ្វិត០ វ្រះបាទ (៥៧) បរមេស្វរ កល្បនាសន្តានអ្នកស្តុករន្សិ០ ភទ្របត្តនគិតជាស្ទិងនាកម្រតេងជគត្តាជប្រ (៥៨) ទ្វទ្ធទៅ០ វ្រះវរសាបរំអាច្ចិមានអ្នកតទៃ គិតសិងនាកម្រតេងជគត្តាជ០ លេងសន្តានអ្នកនោះ (៥៩) គុស្យ០ នេះគិរោះ ហសាខសន្តាននោះ ០ សន្តានអនិន្ទិតបុរតេំស្រុកសតគ្រាម០ កុរុងកវបុរឱ្យ (៦០) ប្រសាទភូមិអ្យវិសយ ឥន្ទ្របុរ០ សន្តានចតស្រុកជ្នះភទ្រយោគិ០ អង្វយ្កគិស្ថាបនាវ្រះសិវលិ (៦១) ង្គតគិ០ មនវ្រះបាទបរមេស្វរ មោកអំវិជវាបិកុរុង្វិម្នោនគរឥន្ទ្របុរ០ ស្តែងអញសិវកៃវល្យ (៦២) តម្និប្រាជ្ញ ជាគុរុ ជារាជបុរោហិតវ្រះបាទ បរមេស្វរ០ មនវ្រះបាទបរមេស្វរថ្លេងមោកអំវិឥន្ទ្រ (៦៣) បុរ០ ស្តែងអញសិវ កៃវល្យមោក នុវ្រះកន្ទារ ហោមនាវ្រះរាជការយ្យ០ វ្រះប្រេនាំកុលេតស្រ្តីបុរុសមោ (៦៤) កឱក្ក០ លុះហអ្យវិសយប្វូទិសវ្រះប្រេឱ្យប្រសាទភូមិ ចតស្រុកជ្នះកុតិទុកកុលេនោះអង្វយ្កគិ (៦៥) មនវ្រះបាទ បរមេស្វរកុរុង្វិអាយនគរ ហរិហរាល័យ០ ស្តែងអញសិវកៃវល្យអង្វ្យម្នោនគរ (៦៦) នោះឱក្ក០

#### សេចក្ដីប្រែសម្រួល

បន្ទាត់ទី៥៦-៦១: ព្រះបាទបរមេស្វរប្រតិស្ឋកម្រតេងជគត្តាជនៅនគរស្រីមាហេន្ទ្របវ្វិត។ ព្រះបាទបរមេស្វរ ចាត់សន្តានអ្នកស្តុករន្សី និងភទ្របត្តនឱ្យជាស្មឹង នាកម្រតេងជគត្តាជ តាំងពីពេលនេះទៅ។ ព្រះករុណាវរសាប មិនអាចឱ្យអ្នកដទៃទៅជាអ្នកបូជាកម្រតេងជគត្តាជទេ គឺឱ្យតែសន្តានអ្នកនោះមួយគត់។ នេះគឺសាខាសន្តាននោះ។ សន្តានអនិន្ទិតបូរមានកំណើតនៅស្រុកសតគ្រាម។ ស្ដេចកវបុរប្រទានភូមិនៅវិស័យឥន្ទ្របុរ។ សន្តាន (នោះ) តាំងស្រុកឈ្មោះភទ្រយោគិ រស់នៅក្នុងស្រុកនោះ ស្ថាបនាព្រះសិវលិង្គនៅស្រុកនោះ។

បន្ទាត់ទី៦១-៦៦: ព្រះបាទបរមេស្វរមកអំពីជវា ជាស្ដេចនៅនគរឥន្ទ្របុរ។ ស្ដេងអញ សិវកៃវល្យជាអ្និប្រាជ្ញជាគុរុ ជារាជបុរោហិតរបស់ព្រះបាទបរមេស្វរ។ ព្រះបាទបរមេស្វរ ឡើងមកអំពីនគរឥន្ទ្របូរ។ ស្ដេងអញសិវកៃវល្យមកជាព្រះកន្ទារ ហោម ក្នុងព្រះរាជការ។ ព្រះ (មរមេស្វរ) ប្រើឱ្យគ្រួសារគាត់ទាំងប្រុសទាំងស្រីមកដែរ។ លុះមក

ដល់វិស័យបូរិទិស ព្រះអង្គឱ្យជី តាំងស្រុកឈ្មោះកុតិ ទុកគ្រួសារនៅទីនោះ។ ព្រះបរមេស្វរជាស្តេចនៅនគរហរិហរាល័យ។ ស្តេងអញសិរិកេរ៍ល្បៃនៅនគរនោះដែរ (ឃិន សុខ, ២០០៧: ៧-៨)។

**ខ. អត្ថបទសិលាចារឹកនគរវត្តលេខ២ ពីបន្ទាត់ទី១ ដល់បន្ទាត់ទី២៤ សរសេរតាមតួអក្សរខ្មែរសម័យបច្ចុប្បន្ន**

(១) នេះតគិត្រិពិតសុចិរិតសទ្ធានៃខ្ញុំអំចស្សសំតេ (២) ចព្រះរាជមាតាមហាកល្យាណវត្តីគ្រីសុជាតា (៣) ឱត្តមជាតិក្សត្រិព្រះមហាឱបាសិការត្នបពិ (៤) ត្រថ្វាយបង្គមប្រនំម្រទូលតព្រះវរបាទារុន្ទ (៥) នៃសំតេច ព្រះមហាគ្រីរត្នត្រៃកម្រតែងយេង (៦) តជាពុំនកត្រេយត្រាណ ប្រធាណរុសំពៅជា (៧) រតរួងឱតុង្គជានុនាំឆ្លោងលេងស្រមទ្វពោល (៨) មនគិកព្ពជាតកន្តារសារនោ ខ្ញុំអំចស្សមានសទ្ធា (៩) តំលាចិត្តប្រព្រទ្ធិសាងសព៌្វកុសលរៀងមោក លុះ (១០) ជាតឥលូនេះ មន្តិលុះត១៤៩៩សក ឆ្លូនក្សត្រ (១១) ចតុទ្ទិគិកេតអាសាឍ្យ សោរ៍ពារ ខ្ញុំអំចស្សយល (១២) ស្តចព្រះរាជបុត្រមានសទ្ធាសាងព្រះពិស្ណុលោក (១៣) កម្ពុជបុរាននេះឱយបរិប្វរុបុរានវិង ខ្ញុំម (១៤) អំចស្សត្រេកអរអេនុមោទនានុស្តចព្រះរាជបុត្រ (១៥) ពេគហោង ខ្ញុំអំចស្សមានសុចរិសទ្ធាព្វត (១៦) ព្រះសាស្នាព្រះតឋាគតស្រគតតាលអនិច្ចារំពឹង (១៧) យលនាមរុបធម្មនេះពុំទ្យេង ស្បង្គពុំជូអាត្មា (១៨) គុះ គិបិខ្ញុំអំចស្សតាកព្រះកេសមោលីនាមានចេ (១៩) ស្តាធិការអំពលនុមុទ្ធាភិសេកនោះបងព្វតស្នា (២០) នព្រះពិស្ណុលោកនេះ សុរេចតុតជាក្នុកសាងព្រះ (២១) ពុទ្ធរុបព្វតស្ថានបាកាណនេះសោត មានសច្ចាទី (២២) ថ្វាននុជាឱបាសករត្នចាំបញ្ចសិលរ៉ៃយ្យក្សាយាម (២៣) ចាំអស្តាង្គសិលព្វតថ្ងៃអថ្ទមីបុនិមីអំមាពិស្យិជា (២៤) ប្រក្វតិលុះអាយុក្ខយ្យតជាបន្ទ័ស្សហោង...

**សេចក្ដីប្រែនៃអត្ថបទសិលាចារឹកនគរវត្តលេខ២ ពីបន្ទាត់ទី១ដល់ទី២៤**

បន្ទាត់ទី១ដល់ទី៤: នេះគឺសទ្ធាសុចរិតរបស់ខ្ញុំអម្ចាស់ ជាសម្ដេចព្រះរាជមាតាមហាកល្យាណវត្តីស្រីសុជាតាឧត្តមជាតិក្សត្រី ព្រះមហាឧបាសិការត្នបពិត្រ។

បន្ទាត់ទី៤ដល់ទី៨: សូមថ្វាយបង្គំប្រណមទូលព្រះវរបាទារុពិន្ទ នៃសម្ដេចព្រះមហាស្រីរតនត្រៃកម្រតែងយើងដែលជាពំនាក់ត្រើយត្រាណ ប្រធានដូចសំពៅជារថរុងឧត្តម នឹងនាំឆ្លងលែងសមុទ្រគឺវដ្តសង្សារ។

បន្ទាត់ទី៨ដល់ទី១០: ខ្ញុំអម្ចាស់មានសទ្ធាចិត្តជ្រះថ្លាសាងកុសលគ្រប់សព្វរៀងមកដល់ជាតិឥឡូវនេះ។

បន្ទាត់ទី១០ដល់ទី១៥: នៅឆ្នាំឆ្លូវ សករាជ១៤៩៩ ថ្ងៃសៅរ៍ ១៤កើត ខែអាសាឍ ខ្ញុំអម្ចាស់ឃើញស្ដេចព្រះរាជបុត្រមានសទ្ធាសាងព្រះវិស្ណុលោក (អង្គរវត្ត) នៃកម្ពុជបុរាណនេះឱ្យបានល្អដូចកាលសម័យបុរាណឡើងវិញ ខ្ញុំអម្ចាស់ត្រេកអរ ហើយទទួលអនុមោទនានឹងស្ដេចព្រះរាជបុត្រខ្លាំងណាស់។

បន្ទាត់ទី១៥ដល់ទី១៧: ខ្ញុំអម្ចាស់មានចិត្តសទ្ធាចំពោះព្រះសាសនានៃព្រះតថាគតយល់អំពីអនិច្ចធម៌នាមរូបនេះពុំទៀងឡើយ ពុំមែនជារបស់ខ្លួនឡើយ។

បន្ទាត់ទី១៨ដល់ទី២១: ហេតុនេះខ្ញុំអម្ចាស់សូមកោរសក់ប្រកបដោយរិទ្ធិចេស្ដា លាងព្រះកេសនៅស្ថានព្រះវិស្ណុលោកនេះ។ រួចហើយដុតសក់នេះធ្វើជាក្នុក ដើម្បីសាងព្រះពុទ្ធរូបដាក់នៅទីបាកាណនេះ។

បន្ទាត់ទី២១ដល់ទី២៤: ខ្ញុំសូមអធិដ្ឋានឱ្យបានជាឧបាសករតន៍ ព្យាយាមរក្សាសីលប្រាំ រក្សាសីលប្រាំបីនៅថ្ងៃ៨កើតនិង៨រោច នៅថ្ងៃពេញបូរមី និងថ្ងៃខែដាច់ ជានិច្ចរហូតដល់ព្រះជន្មាយុហោង (ឃិន សុខ, ២០០៧: ១៤-១៥)។

## ៥.២. វណ្ណាយោបាយ

### ៥.២.១. រាជសព្ទ

ពាក្យរាជសព្ទមានគេចងក្រងនិងពិនិត្យឡើងវិញ តាមព្រះរាជតម្រាស់របស់ព្រះបាទសម្ដេចព្រះអង្គដួង។ ក្នុងគ.ស. ១៨៥៧ ដោយមានក្ដីកង្វល់ពីការបាត់បង់ស្នាដៃអក្សរសាស្ត្រ ទ្រង់ត្រាស់បង្គាប់ទៅគណៈកម្មការមួយដែលមានមន្ត្រីសង្ឃជាន់ខ្ពស់បីអង្គ និងមន្ត្រីថ្នាក់ខ្ពស់ចំនួនបួនរូប ឱ្យពិនិត្យផ្ទៀងផ្ទាត់ពាក្យនិងអក្ខរាវិរុទ្ធ ព្រមទាំង

បង្កើតពាក្យថ្មីៗបន្ថែមទៀតសម្រាប់ឆ្លើយតបសេចក្តីត្រូវការប្រចាំថ្ងៃ។ រួចហើយគេចងក្រងជាគោលប្រធានបទ ព្រមទាំងមានអមដោយព្រះរាជក្រឹត្យស្តីពីឋានន្តរៈនៃព្រះក្សត្រា ព្រះក្សត្រីផង។ ចិតសិបប្រាំឆ្នាំក្រោយមក នៅគ.ស. ១៩៣១ គេយកស្នាដៃនេះទៅបោះពុម្ពនៅពុទ្ធសាសនបណ្ឌិត្យ តាមព្រះរាជតម្រិះរបស់ព្រះអង្គម្ចាស់នពន្តមសុផ្កាវង្ស ព្រោះទ្រង់មានព្រះរាជបំណងមិនចង់ឱ្យរាជសព្ទនេះ ចេះនៅតែក្នុងចំណោមមន្ត្រីធំៗដែលមានអភ័យឯកសិទ្ធិប៉ុណ្ណោះ។ ទ្រង់ចង់ឱ្យប្រជារាស្ត្រសាមញ្ញទូទៅបានចេះដឹងផង។ ពាក្យរាជសព្ទនេះ មាននៅក្នុងព្រះរាជពង្សាវតារដែរ។ ក្នុងនោះ គេឃើញមានរចនាសម្ព័ន្ធប្រយោគប្លែកៗតាមរូបភាពដោយឡែកៗ។ ម្យ៉ាងទៀត គេឃើញមានពាក្យរាជសព្ទនៅក្នុងអត្ថបទអក្សរសិល្ប៍ ជាពិសេសរឿងនិទានប្រភេទកឹងកន្ត្រៃ។

ឧទាហរណ៍៖

| | | | |
|---|---|---|---|
| ព្រះឱសថ : ថ្នាំកែរោគ | ព្រះបាទ : ជើង | ព្រះឆាយ : កញ្ចក់ | សិរ : ក្បាល |
| ផ្ទំ : ដេក សម្រាន្ត | សោយ : ស៊ី ផឹក ជក់ | ប្រឈូន : ឈើ | ទត : អាន មើល |
| ទ្រង់ប្រសូត្រ : កើត ឆ្លងទន្លេ | ទ្រង់ព្រះតម្រិះ : គិត | ទ្រង់ព្រះកន្សែង : យំ | ទ្រង់ជ្រាប : ដឹង |
| ទ្រង់ព្រះរាជទាន : ឱ្យ | នាសា : ច្រមុះ | កេសា : សក់ | ភក្ត្រ : មុខ |
| ស្វាមី : ប្តី | មហេសី : ប្រពន្ធ | បិតា : ឪពុក | មាតា : ម្តាយ...។ |

## ៥.២.២. សង្ឃសព្ទ

ចំពោះសង្ឃសព្ទខ្មែរ កុមារៗមានឱកាសរៀនបច្ចេកសព្ទទាំងនេះតាមរយៈឪពុកម្តាយខ្លួន។ ពាក្យសង្ឃសព្ទមានចំនួនតិចជាងពាក្យរាជសព្ទ ហើយពាក្យនៃរាជសព្ទនេះទៀតក៏នៅមិនគ្រប់ដែរ ដូច្នេះហើយ គេគ្រាន់តែដាក់ពាក្យ «ព្រះ» នៅខាងឆ្វេងនៃពាក្យធម្មតា គេអាចដោះស្រាយបញ្ហាបាន ដូចជាពាក្យ «ព្រះប្រធាន» ជាដើម។

ឧទាហរណ៍៖

| | | | |
|---|---|---|---|
| គង់ : អង្គុយ | ឆាន់ : បរិភោគ ផឹក | ស្រង់ទឹក : ងូតទឹក | ជាវ : ទិញ |
| ចង្ហាន់ : ចំណីអាហារ | ញោម : ឪពុកម្តាយ ពុទ្ធបរិស័ទ | និមន្ត : ដើរ | ប្រសូត្រ : កើត |
| ព្រះជន្ម : អាយុ | សិង : ដេក គេង | ចម្រើនពរ : លាឬបាទ | អាពាធ : ឈឺ...។ |

## ៥.២.៣. ពលរដ្ឋសព្ទ

ពលរដ្ឋសព្ទត្រូវចែកជាពីរក្រុម ទី១ ក្រុមសម្រាប់មន្ត្រី និងទី២ ក្រុមសម្រាប់ប្រជារាស្ត្រ។ នៅក្នុងក្រុមនីមួយៗមានថ្នាក់តទៅទៀត ជាពិសេសក្រុមពាក្យសម្រាប់មន្ត្រី។

ឧទាហរណ៍ទូទៅ ឆ្លងពីប្រជារាស្ត្រទៅប្រជារាស្ត្រឬទៅមន្ត្រីតូចតាច គេប្រើពាក្យដូចជា ខ្ញុំប្រាប់ឯងថា ខ្ញុំប្រាប់ពូថា ខ្ញុំសូមជម្រាបពូថា ខ្ញុំសូមជម្រាបលោកថា លោកពូបាននិយាយថា លោកមានប្រសាសន៍ថា...។

ឧទាហរណ៍ដែលបង្ហាញការគោរពខ្លាំងឡើងៗ ពីទាបទៅខ្ពស់ គេប្រើពាក្យដូចជា សូមគោរព សូមមេត្តាជ្រាប គោរពជូន សូមគោរពជូន ខ្ញុំមានកិត្តិយសជូនលោក សូមជម្រាបជូនឯកឧត្តម ...។

## ៥.៣. ទេសយោបាយ

យើងបានដឹងថា ប្រព័ន្ធទម្លាប់វាចា ពាក់ព័ន្ធនឹងផ្នែកបីគឺ សូរ វាក្យសព្ទ និងសម្ព័ន្ធ ប៉ុន្តែចំពោះភាសាដែលប្រើក្នុងប្រទេសតូចមួយ ល្បះឥតមានការប្រែប្រួលទៅតាមតំបន់ទេ។ យើងសិក្សាតែអំពីសូរនិងអំពីវាក្យសព្ទប៉ុណ្ណោះ។ ការសិក្សាស៊ីជម្រៅល្អិតល្អន់អំពីការប្រែប្រួលសូរនិងវាក្យសព្ទត្រូវការកំណត់ទីតាំងឱ្យតូច ពីព្រោះក្នុងខេត្តនីមួយៗ ការប្រែប្រួលអាចមានពីស្រុកមួយទៅស្រុកមួយ។

ឧទាហរណ៍៖ មក : ម៉ោ, ថ្ងៃ : ង៉ៃ, តូច : ទូច, ធ្វើ : ធើ, រក : រ, យក : យ...។

## សំណួរ

១. តើសង្គមភាសាវិទ្យាជាអ្វី?
២. ចូររៀបរាប់អំពីកំណកំណើតនៃសង្គមភាសាវិទ្យាដោយសង្ខេប។
៣. តើសង្គមភាសាវិទ្យាមានប្រវត្តិមកពីណា?
៤. តើគ្រាមភាសាសង្គមជាអ្វី?
៥. តើបញ្ហាសង្គមដែលផ្អែកលើកត្តាភាសាកើតមាននៅក្នុងស្ថានភាពដូចម្ដេចខ្លះ?
៦. តើការសិក្សាសង្គមភាសាវិទ្យាមានជាប់ទាក់ទងនឹងការអប់រំនិងមុខរបរដូចម្ដេចខ្លះ?
៧. តើសញ្ញាសម្គាល់សង្គម (social markers) ជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
៨. តើសង្គមភាសាវិទ្យាមាននិន្នាការប៉ុន្មានយ៉ាង? អ្វីខ្លះ?
៩. ចូរបង្ហាញពីទ្រឹស្ដីរបស់លោក វិលីយាម ឡាបូវ ក្នុងការសិក្សាភាសាភ្ជាប់ទៅនឹងទិដ្ឋភាពសង្គម។
១០. ចូរបង្ហាញពីទ្រឹស្ដីរបស់លោក ហ្សង់ ហ្គាញើប៉ាំង ក្នុងការសិក្សាអំពីសង្គមភាសាវិទ្យា។
១១. តើសំនួនវត្តមានវិស័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១២. តើសំនួនអវត្តមានវិស័យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១៣. តើលោក ហ្សង់ក្លូត ឆីវ៉ាលីយេ យល់បែបណាចំពោះភាសានិយាយនិងភាសាសរសេរ?
១៤. តើលោក ដោនរ៉ូស ចែកកម្រិតភាសាជាប៉ុន្មានថ្នាក់? អ្វីខ្លះ?
១៥. តើយោបាយល្បាយជាអ្វី?
១៦. ចូរបង្ហាញពីសាបៀរ (sabir) តាមរយៈសង្គមភាសាវិទ្យា។
១៧. តើពិតឈីន (pidgin) ជាអ្វី?
១៨. ចូរបង្ហាញពីលក្ខណៈពិតឈីនតាមរយៈសង្គមភាសាវិទ្យា។
១៩. តើក្រេអូល (creole) ជាអ្វី?
២០. ចូរបង្ហាញពីលក្ខណៈរបស់ក្រេអូលតាមរយៈទ្រឹស្ដីសង្គមភាសាវិទ្យា។
២១. ចូរប្រៀបធៀបលក្ខណៈខុសគ្នារវាងសង្គមវិទ្យានិងសង្គមភាសាវិទ្យា។
២២. តើការសិក្សាភាសាដោយបញ្ចូលទិដ្ឋភាពសង្គមផ្ដល់ប្រយោជន៍អ្វីខ្លះដល់វិស័យភាសាវិទ្យា?
២៣. តើកាលយោបាយជាអ្វី?
២៤. ចូរបង្ហាញពីកាលយោបាយនៃភាសាខ្មែរតាមរយៈសិលាចារឹកណាមួយនៅសម័យមុនអង្គរនិងអង្គរ។
២៥. ចូរបង្ហាញពីកាលយោបាយនៃភាសាខ្មែរសម័យកណ្ដាល។
២៦. តើវណ្ណយោបាយជាអ្វី? ចែកចេញជាប៉ុន្មាន? អ្វីខ្លះ?
២៧. ចូរបង្ហាញពីវណ្ណយោបាយនៃភាសាខ្មែរសម័យទំនើប។
២៨. តើទេសយោបាយជាអ្វី?
២៩. ចូរបង្ហាញពីទេសយោបាយនៃភាសាខ្មែរនៅខេត្តមួយចំនួន។
៣០. តើការបែងចែកភាសាតាមថ្នាក់ក្រុមមានឥទ្ធិពលអ្វីខ្លះដល់សង្គមជាតិមួយ?
៣១. តើការសិក្សាសង្គមភាសាវិទ្យាឆ្លុះបញ្ចាំងឱ្យឃើញអ្វីខ្លះអំពីទំនាក់ទំនងរវាងភាសានិងសង្គម?

# មេរៀនទី៩
# ការចាប់យកភាសា

## ១. ការចាប់យកភាសាទី១

ការចាប់យកភាសាទី១ គឺគួរឱ្យកត់សម្គាល់ចំពោះល្បឿនដែលភាសាកើតឡើង។ មុនពេលកុមារចាប់ផ្ដើមចូលរៀន ភាសារបស់ពួកគេបានក្លាយជាភាសាដ៏ជឿនលឿនមួយដើម្បីដំណើរការប្រព័ន្ធនៃការបញ្ចេញមតិខ្លួនឯង និងការប្រាស្រ័យទាក់ទងដែលគ្មានសត្វដទៃទៀតឬកុំព្យូទ័រមកប្រកួតប្រជែងបាន។ បន្ថែមលើល្បឿននៃការចាប់យកភាសា ការពិតនោះ គឺកើតឡើងសម្រាប់កុមារទូទៅដោយគ្មានការណែនាំសម្រាប់កុមារទាំងអស់ ហើយនិងមិនគិតពីភាពខុសគ្នាខ្លាំងចំពោះកាលៈទេសៈរបស់កុមារទាំងនោះទេ ដើម្បីផ្ដល់ការគាំទ្រដល់គំនិតដែលថា កុមារចាប់យកភាសាតាំងពីកំណើតមកម្ល៉េះ។ យើងអាចគិតថា នេះជាសមត្ថភាពពិសេសសម្រាប់ភាសាដែលទារកទទួលបានតាំងពីកំណើតមក។ ទោះទទួលបានដោយខ្លួនវាក្ដី ក៏សមត្ថភាពភាសានៅតែមិនទាន់គ្រប់គ្រាន់នៅឡើយដែរ។

នៅមេរៀននេះ យើងចាប់ផ្ដើមលើកយកមូលដ្ឋានគ្រឹះនៃការពិតមួយចំនួនអំពីការចាប់យកភាសាដែលទ្រឹស្ដីមួយចំនួននៃចំណេះដឹងភាសាត្រូវតែអាចពន្យល់បាន។ បន្ទាប់មកយើងនឹងធ្វើការពិចារណារកចម្លើយទូទៅដើម្បីឆ្លើយទៅនឹងសំណួរថា តើកុមារៗចាប់យកភាសាយ៉ាងដូចម្ដេច ហើយដើម្បីចង្អុលបង្ហាញឱ្យកាន់តែច្បាស់បញ្ហាទាំងនេះមិនមែនចាប់ផ្ដើមឡើងដោយការពន្យល់នូវការពិតដែលបានកំណត់នោះទេ។ ឧទាហរណ៍ ដូចជាការបង្ហាញនូវវេយ្យាករណ៍ ជាទូទៅដែលស្របទៅនឹងចំណេះដឹងដែលបានទទួលពីកំណើតនៃក្បួនច្បាប់ភាសាដែលណែនាំទៅអ្នករៀនភាសា។ យើងនឹងបង្ហាញថា ទ្រឹស្ដីនេះ គឺជាទ្រឹស្ដីល្អប្រសើរជាមួយនឹងការពន្យល់ការពិតដ៏គួរឱ្យគត់សម្គាល់នៃការចាប់យកភាសាដែលយើងចាប់ផ្ដើម។ ក្នុងការសិក្សានេះមានវាក្យសព្ទបច្ចេកទេសសំខាន់ៗមួយចំនួនចាំបាច់ត្រូវបែងចែកនៅដើមដំបូង។ នៅក្នុងភាសាជាសាកលជាក់ស្ដែង ដូចជានៅក្នុងអត្ថបទនេះ យើងធ្វើការបែងចែកនូវភាពខុសគ្នារវាងសមត្ថភាពយល់ដឹងអំពីភាសានិងការប្រើប្រាស់ភាសា។ ការប្រើប្រាស់ភាសារួមមានការបញ្ចេញសូរសំឡេង យើងធ្វើឬប្រហែលនឹងធ្វើរឿងនេះ ការប្រើប្រាស់នេះពោរពេញទៅដោយដែនកំណត់នៃការយកចិត្តទុកដាក់ទៅលើពេលវេលានៃធនធានទាំងនេះដែរ ជាទូទៅយើងបង្កើតកំហុសនៅពេលយើងនិយាយដូចជាការភ្លេចនៅការផ្ដើមប្រយោគរបស់ខ្លួនយើងផ្ទាល់ ឬការធ្វើឱ្យគំនិតថ្មីបង្អាក់ ឬក៏បរាជ័យក្នុងការនិយាយប្រយោគចប់ចុងចប់ដើមដោយសារតែការក្អក កណ្ដាស់ ឬឈឺក្បាល ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់នេះ គឺជាការពិត ហើយការលើកឡើងបែបនេះមិនមែនជាទ្រឹស្ដីមូលដ្ឋានគ្រឹះនៃចំណេះដឹងភាសាទេ។ ជំនួសពីនេះ យើងព្យាយាមស្វែងយល់ចំណេះដឹងភាសារបស់យើងផ្ទាល់ និងក្រឹត្យក្រមភាសានៅក្នុងខួរក្បាលរបស់ពួកយើង។

### ១.១. ការចាប់យកនិងធាតុចូល

ចំណុចមួយក្នុងចំណោមអត្តចរិតដ៏ពិសេសរបស់ជីវិតមនុស្ស គឺថាអ្នកដែលនៅលីវស្ទើរតែទាំងអស់ អាចទទួលបានចំណេះដឹងពីភាសានៅវ័យកុមារបំផុត។ ហេតុផលទាំងនេះ បន្ថែមឱ្យមានការគិតដ៏ពិសេស ដែលពោរពេញទៅដោយភាពស្មុគស្មាញរបស់ប្រព័ន្ធទទួលចំណេះដឹង។ ប្រសិនបើអ្នកសង្ស័យផ្នែកខ្លះនៃការអះអាងទាំងនេះថា មនុស្សគ្រប់រូបទទួលចំណេះដឹងតាមរយៈភាសា ដែលពួកយើងទទួលបានភាសានៅវ័យកុមារ ដែលប្រព័ន្ធគឺស្មុគស្មាញ ដើម្បីជានាថា ពួកយើងជួយពួកគេធាប់ៗជាមួយនឹងភស្តុតាង។ សម្រាប់ឥឡូវនេះសន្មតថា ពួកគេត្រូវហើយសួរខ្លួនអ្នក «យ៉ាងដូចម្ដេច?» តើកុមារមានអាយុប៉ុន្មាន ដែលអាចទទួលចំណេះដឹងពីភាសា ដែលប្រៀបដូចជាប្រព័ន្ធយ៉ាងស្មុគស្មាញនេះ បានតាមរបៀបណាខ្លះ? អ្នកប្រហែលជាគិតថា ឪពុកម្ដាយជាអ្នកបង្រៀនភាសាដល់កូនៗរបស់គេ ប៉ុន្តែនេះគឺមិនត្រឹមត្រូវឡើយ លើកលែងតែនៅពេលដែលឪពុកម្ដាយជាអ្នកផ្ដល់ឱ្យបែបបទនៃភាសា

មួយដោយការនិយាយទៅកាន់កូនៗរបស់ពួកគេ។ អ្វីដែលពួកយើងនឹងជជែកពិភាក្សានៅក្នុងមេរៀននេះ គឺថា កុមារៗទទួលចំណេះដឹងភាសាយ៉ាងលឿន ពីព្រោះវាមិនមែនជាហ្វៃនរបស់ពួកគេតែមួយមុខនោះទេ។ នោះជាអ្វីដែលពួកយើងនឹងជជែកពិភាក្សាថា កុមារៗកើតមកជាមួយចំណេះដឹងតាំងពីកំណើតមកម្ល៉េះ ដែលជាអ្នកនាំផ្លូវទៅកាន់ចំណេះដឹងភាសា។ ចំណេះដឹងដែលមានមកពីកំណើតនេះ គឺស្គាល់ថា ជាវិធីនៃការទទួលចំណេះដឹងភាសារួមបញ្ចូលគោលការណ៍រួមទៅកាន់គ្រប់ភាសាមនុស្សហៅថា វេយ្យាករណ៍សកល។ ចំណេះដឹងភាសាជាអ្វីដែលមានតាំងពីកំណើត ហើយករណីនេះមិនធ្លាប់បានសិក្សាពីមុនមកទេ។ បើគេនិយាយអំពីចំណេះដឹងភាសា នោះហាក់ដូចជាអ្វីដែលចំឡែកនៅក្នុងបរិស្ថាននៃភាសា (ឧទាហរណ៍ ពាក្យដោយឡែកនៃភាសាណាមួយឬភាសាដទៃទៀត នឹងអនុវត្តក្នុងគោលការណ៍សកល)។

**១.១.១. ការចាប់យកភាសា**

ក្នុងរបាយការណ៍មួយ ដែលក្រុមស្រាវជ្រាវរបស់ពួកយើង ដែលនិយាយអំពីការផ្លាស់ប្តូរភាសារបស់កុមារៗនឹងឈានទៅកាន់ភាពផ្តាច់ព្រ័ត្រហើយ។ អង្គហេតុពិសេសភាគច្រើន គឺប្រហែលជាមិនមានការហ្វឹកហាត់ពិសេសឬក៏ប្រុងប្រយ័ត្នក្នុងដំណើរតាមលំដាប់លំដោយនៃការដាក់បញ្ចូលភាសា។ កុមារធម្មតាទាំងអស់ គឺទទួលបានភាសាធម្មជាតិ។ ភាសាធម្មជាតិនេះ សំដៅទៅលើលក្ខណៈជាសកលនៃការចាប់យកភាសា។ លក្ខណៈសកលនៃភាសាឈរលើការប្រៀបធៀបយ៉ាងច្បាស់អំពីដែនកំណត់នៃការសម្រេចសមត្ថភាពនៃការយល់ដឹងយ៉ាងច្បាស់និងសាមញ្ញមួយ ដូចជាសមត្ថភាពក្នុងការគណនា ឬក៏ចំណងប្រទាក់គ្នា។ ទាក់ទងនឹងការសង្កេតមួយគឺថា កុមារទាំងអស់នៅក្នុងសហគមន៍ភាសាមួយ គឺសម្រេចបានប្រព័ន្ធវេយ្យាករណ៍ប្រហាក់ប្រហែលគ្នា នោះគឺជាភាពស្មើគ្នារបស់មនុស្សគ្រប់គ្នា បើទោះបីជាមានសេរីភាពដ៏ធំទូលាយនៅក្នុងបទពិសោធភាសាក៏ដោយ។ ចុងក្រោយពួកយើងនឹងមើលថាភាពរហ័សរបស់កុមារៗក្នុងការចាប់យកភាសា ហើយនិងកំហុសបន្តិចបន្តួចដើម្បីពិចារណាអំពីចំនួនលំបាកខ្លាំងដែលកើតមាន។

ទោះបីជាភាពចម្រុះនៃភាសាធម្មជាតិ រូបភាពទាំងនេះគឺជាមុខវិជ្ជានៃការទទួលចំណេះដឹងដែលធ្លាប់បានធ្វើការសង្កេត ដូច្នេះជាញឹកញាប់ភាសាឆ្លងកាត់ការយល់ដឹងរបស់ពួកយើងអំពីភាសាពិតរបស់ភាសាធម្មជាតិ។ ប៉ុន្តែនេះមិនមែនជាវិធីបណ្តាលឱ្យមានការភ្ញាក់ផ្អើលដល់ឪពុកម្តាយក្នុងការមើលដំណើរលោតត្រដាងនេះទេ ឬក៏មានភាពលំបាកដល់អ្នកវិទ្យាសាស្ត្រក្នុងការពន្យល់ទ្រឹស្តីនេះឡើយ។ តើអ្វីជាលក្ខណៈពិសេសនៃភាសាធម្មជាតិ ហើយកុមារៗអាចធានាថាគ្មានបរាជ័យ ហើយពួកគេនឹងទទួលបានប្រព័ន្ធសាំញ៉ាំនៃច្បាប់ទទួលបានភាសា និងការយល់ដឹងនៅពេលពួកគេរៀននៅសាលា នៅពេលគេទទួលចំណេះដឹងដំបូងនៅឯសាលា តើវាជាការចាប់យកជំនាញដ៏ពិបាកនិងស្មុគស្មាញមួយឬ? នេះគឺជាល្បងប្រាជ្ញាមួយដែលអ្នកទ្រឹស្តីភាសាវិទ្យា ត្រូវតែធ្វើការដោះស្រាយ។

ការសង្កេតបន្ទាប់ គឺទាក់ទងទៅនឹងទិន្នន័យភាសាវិទ្យាដំបូង ស្ថានភាពបទពិសោធជាមួយនឹងការរៀនភាសារបស់កុមារៗ។ កុមារខ្លះចំណាយពេលច្រើនចាប់ពីពីរទៅបីឆ្នាំដំបូងជាមួយនឹងមនុស្សពេញវ័យដែលផ្តល់ឱ្យពួកគេនូវអាកប្បកិរិយាផ្ទាល់ខ្លួនពិសេសមួយ។ ប្រសិនបើនេះជាបញ្ហាតែមួយដែលយើងជួបប្រទះ ប្រហែលជាពួកយើងនឹងសរុបថា កុមារៗគឺបង្រៀនភាសាដោយឪពុកម្តាយនិងអ្នកថែទាំរបស់គេ។ ប៉ុន្តែកុមារខ្លះទៀតទទួលបាននូវអាកប្បកិរិយាផ្ទាល់ខ្លួន ថ្វីបើមានមនុស្សពេញវ័យនៅថែទាំពួកគេក៏ដោយ។ ហើយពួកគេទទួលបានការវិវត្តភាសាស្មើៗគ្នា នៅពេលដែលកុមារៗទទួលអាកប្បកិរិយាពិសេសផ្ទាល់ខ្លួនច្រើនបន្ថែមទៀត។ នៅស្ថានភាពផ្សេងទៀត កុមារទាំងនេះចំណាយពេលវេលាជាមួយកុមារដទៃទៀត ហើយក៏មិនស្ថិតនៅក្នុងស្ថានភាពណាមួយដែរ។ នៅគ្រប់កាលៈទេសៈទាំងនេះ កុមារអាចគ្រប់គ្រងការទទួលបាននូវភាសាកំណើតមួយ។ ភាពខុសគ្នាមួយចំនួនរវាងបទពិសោធរបស់កុមារម្នាក់ៗ គឺវប្បធម៌ សង្គម និងគ្រោះថ្នាក់។ ក្រោយពីការសិក្សាទៅលើកុមារៗជាច្រើន របាយការណ៍របស់ពួកយើងនឹងសរុបថា បើទោះបីជាកុមារធំលូតលាស់នៅសហគមន៍ភាសាដូចគ្នាក៏ដោយ ហើយរៀនភាសាតែ

មួយក៏ដោយ ក៏ប្រហែលជាមានភាពចម្រុះគ្នាដ៏ទូលំទូលាយនៃបទពិសោធភាសា អំឡុងពេលដែលពួកគេនៅវ័យកុមារ។ បើទោះបីជាមានភាពចម្រុះគ្នានៃបទពិសោធក៏ដោយ របាយការណ៍នេះផងដែរកត់សម្គាល់ថា កុមារគ្រប់រូប នៅគ្រប់សហគមន៍ភាសាទាំងអស់ ទទួលបានចំណេះដឹងភាសារបស់សហគមន៍នោះ។

ចំណុចទាក់ទងមួយទៀតគឺថា កុមារទាំងអស់នៅក្នុងសហគមន៍ភាសាតែមួយ គឺរៀនភាសាដូចគ្នា។ ក្នុងន័យនេះគឺថា វេយ្យាករណ៍ដែលគេទទួលបាន គឺមានលក្ខណៈដូចគ្នា។ ក្រៅពីនេះការយល់ទៅវិញទៅមកនឹងមិនអាចកើតឡើងឡើយ។ ភាពដូចគ្នារបស់កុមារៗ គឺការជួបគ្នានៅលើកម្រិតវេយ្យាករណ៍ស្មើគ្នា និងការរកឃើញបន្ថែមនៅក្នុងអង្គហេតុដែលកុមារៗទាំងអស់ទទួលបានការដាក់បញ្ចូលខុសៗគ្នា (ទិន្នន័យភាសាវិទ្យាដំបូង)។ តើកុមារៗអាចគ្រប់គ្រងការរៀនដើម្បីនិយាយ និងយល់ភាសាមួយបានយ៉ាងដូចម្តេច បើទោះបីជាការលូតលាស់របស់កុមារទាំងនោះនៅក្នុងមជ្ឈដ្ឋានខុសប្លែកគ្នាច្រើន?

ការសង្កេតនេះ គឺនាំឱ្យយើងសួរថា តើការរៀនជាក់ស្តែង គឺទាមទារគ្រប់ចំណេះដឹងដែលទទួលបានភាសាទាំងអស់។ នៅក្នុងបរិបទនេះ វាគឺជាការកត់សម្គាល់យ៉ាងសំខាន់នៅលើសមិទ្ធផលរបស់កុមារៗដែលមានឪពុកម្តាយជាអណិកជន។ ថ្វីបើនៅក្នុងករណីមនុស្សពេញវ័យដែលជាអណិកជន ហើយមានភាពលំបាកយ៉ាងខ្លាំងទៅលើជំនាញជាមូលដ្ឋាននៃភាសានៅក្នុងសហគមន៍ថ្មី។ នេះគឺជារឿងធម្មតាសម្រាប់កូនៗរបស់ពួកគេ ដើម្បីទទួលបានភាសាថ្មីដោយគ្មានភាពលំបាក។ ពិតណាស់កុមារទាំងអស់នេះ មិនប្រើនូវទម្លាប់របស់ឪពុកម្តាយរបស់ពួកគេនោះទេ ប៉ុន្តែពួកគេស្វែងយល់នូវភាពស្មុគស្មាញទាំងអស់នៅក្នុងការនិយាយភាសាជុំវិញពួកគេ ដូចដែលកុមារៗដទៃទៀតដែលមានឪពុកម្តាយ ជាជនជាតិដើម។

នេះគឺជាអង្គហេតុពីដំបូងអំពីចំណេះដឹងដែលទទួលបានភាសា។ ជាដំបូង ចំណេះដឹងភាសា គឺជាលក្ខណៈសកល (ជាមួយនឹងអម្បូរមនុស្ស) ហើយនិងបន្ទាប់មក គឺជាសេរីភាពដ៏ទូលំទូលាយនៅក្នុងប្រភេទដែលដាក់បញ្ចូលមជ្ឈដ្ឋានដែលអនុញ្ញាតឱ្យកុមារៗ អភិវឌ្ឍភាសារបស់ពួកគេ។ យើងត្រូវតែឆ្លើយតបយ៉ាងហ័សនិងត្រឹមត្រូវទៅតាមការសង្កេត។ ការសង្កេតដទៃទៀតដែលមាននៅក្នុងរបាយការណ៍គឺថាកុមារៗមួយចំនួនរៀនភាសាជាច្រើន ទោះបីជាកុមារៗភាគច្រើនរៀនត្រឹមតែមួយភាសាក៏ដោយ។ នៅក្នុងសហគមន៍ដែលមានអ្នកនិយាយលើសពីមួយភាសា កុមារៗគឺទទួលបានគ្រប់ភាសាទាំងអស់នៅក្នុងសហគមន៍នោះ។ ដូច្នេះនៅក្នុងវិធីនេះ យ៉ាងហោចណាស់ភាសាច្បាស់ជាមានមុខងារនៃការដាក់បញ្ចូល ប្រសិនបើទិន្នន័យភាសាដំបូងរបស់កុមារៗ គឺមានកំណត់ត្រឹមតែមួយភាសា និងរៀនត្រឹមតែមួយភាសា ប៉ុន្តែបើកុមារៗនិយាយពីរភាសា ពួកគេនឹងរៀនទាំងពីរភាសា។ ហើយបើនិយាយបីភាសា កុមាររៀនបីភាសា ដូចនេះជាបន្តបន្ទាប់។ បើសិនភាសារួមច្រើន កុមារគឺផ្លាស់ទៅកាន់សហគមន៍ភាសាផ្សេងទៀត និងប្រហែលជាបាត់បង់នូវការប្រើប្រាស់តួនាទីដែលពួកគេធ្លាប់និយាយ ហើយពួកគេប្រហែលជាភ្លេចលឿនមួយឬលើសពីមួយភាសា ប៉ុន្តែប្រសិនបើកុមារដែលនិយាយឬប្រើលើសពីមួយភាសានឹងទទួលបានចំណេះហើយនិងការប្រើប្រាស់គ្រប់ភាសាទាំងអស់។ ការសិក្សានេះ បង្ហាញឱ្យពួកយើងដឹងថា កុមារខ្លះអាចក្លាយទៅជាអ្នកនិយាយច្រើនភាសា (ពហុភាសា)។

ការសង្កេតដទៃទៀតគឺថាគ្រប់ភាសាទាំងអស់ដែលរៀន គឺមានភាពងាយស្រួលស្មើគ្នា។ គ្មានភាសាដោយឡែកណាមួយដែលពិបាកខ្លាំងនោះទេ ការសង្កេតនេះគឺទទួលបានចំណេះដោយក្រុមកុមារៗដែលបានបំបែកពីរក្រុមធំ ហើយការសង្កេតនេះបានបង្ហាញទៅកាន់ក្រុមទាំងពីរនេះ។ ពេលខ្លះមានការលើកឡើងថា ភាសារុស្ស៊ី ភាសាជប៉ុន ឬក៏ភាសាអង់គ្លេស គឺពិបាករៀន។ ការលើកឡើងនេះប្រហែលជាត្រឹមត្រូវ ដែលអ្នកនិយាយភាសាអង់គ្លេសរកឃើញនូវភាពលំបាកក្នុងការរៀនភាសាជាងការរៀនភាសាផ្សេងទៀត។ របកគំហើញនេះ គឺសំខាន់ក្នុងការកត់ត្រាថាកុមារៗជនជាតិរុស្ស៊ីគឺទទួលបានចំណេះដឹងភាសារុស្ស៊ី បានលឿនជាមួយនឹងការខិតខំបន្តិចបន្តួចដូចគ្នាទៅនឹងជនជាតិអង់គ្លេស ឬក៏កុមារៗជនជាតិអាមេរិក ភាពត្រឹមត្រូវ គឺដូចគ្នានូវគ្រប់ភាសាទាំងអស់។

ពួកយើងគួរតែកត់សម្គាល់ផងដែរថា កុមារដែលរៀនលើសពីមួយភាសា គឺរៀនជាមួយនឹងភាពងាយស្រួលស្មើគ្នាលើគ្រប់ភាសាដែលពួកគេបានរៀន។ ដូច្នេះភាសារបស់ឪពុកម្តាយ គឺមិនកំណត់ភាសារបស់កូនៗឡើយ លើកលែងតែនៅក្នុងវិញ្ញាណដែលច្បាស់លាស់បំផុត ដែលកុមារនិយាយភាសាអ្វីក៏ដោយ គឺនិយាយទៅកាន់ពួកគេ។ នោះគឺនិយាយថាគ្រប់កុមារជនជាតិអង់គ្លេស គឺរៀនភាសាអង់គ្លេស។ គ្រប់កុមារជនជាតិចិន គឺរៀនភាសាចិន។ នេះគឺជាចំណុចមួយដ៏សំខាន់សម្រាប់ពង្រឹងការសរុបនេះ។ តាមការសង្កេតនេះ បង្ហាញឱ្យយើងដឹងថា ប្រសិនបើកុមារបានកើតជាមួយឪពុកម្តាយដែលនិយាយភាសាអង់គ្លេស ហើយបានយកពួកគេទៅកាន់ប្រទេសចិន ហើយបានធំធាត់នៅទីនោះ កុមារទាំងនោះ គឺនិយាយភាសាចិន មិនមែនភាសាអង់គ្លេសទេ។ ការសង្កេតដែលបង្ហាញថា ភាសាសហគមន៍ គឺគ្រប់គ្រាន់ក្នុងការអភិវឌ្ឍភាសា ដែលហៅនៅក្នុងសំណួរមួយនៃការមិនឯកភាពគ្នាអំពីភាសា ដែលជាតម្រូវការរបស់កុមារដើម្បីទទួលបានការបង្ហាត់ជាក់ស្តែងក្នុងការរៀនភាសា។ សរុបមក អង្គហេតុអំពីដំណើរការចំណេះដឹងដែលទទួលបានមកពីភាសា (ជាមួយការគោរពតាមភាពខុសគ្នានៅក្នុងភាសា) បង្ហាញទាំងអស់ថាចំណេះដឹងដែលទទួលបានភាសា គឺដូចគ្នាទាំងអស់។ យើងហៅការកំណត់នេះថា ទុកភាសាផ្ទាល់ខ្លួន បន្ទាប់មកគឺជាឯកលក្ខណភាពនៃការចាប់យកភាសា។

អង្គហេតុសកលភាពនិងឯកលក្ខណភាពនៃការចាប់យកភាសា គឺទទួលបានការចាប់អារម្មណ៍ក្រៃលែង។ នៅពេលមានសម្មតិកម្មនៃការសង្កេតបែបវិទ្យាសាស្ត្រ ពួកយើងនឹងបើកបង្ហាញអង្គហេតុមួយចំនួនដែលបង្កើតឱ្យមានអង្គហេតុស្រពិចស្រពិលទាំងនេះ ដោយការប្រៀបធៀប។ ជាដំបូង ការចាប់យកភាសាគឺមានភាពរហ័ស។ ស្ទើរតែគ្រប់ភាពស្មុគស្មាញទាំងអស់នៃភាសា គឺជំនាញស្រាប់ដោយកុមារៗមុនពេលដែលពួកគេចូលរៀន។ នៅអាយុ៣ទៅ៤ឆ្នាំ គឺមានពាក្យជាច្រើនដែលកុមារៗមិនស្គាល់ ប៉ុន្តែទោះបីជានិស្សិត ឬក៏សាស្ត្រាចារ្យក៏ដោយ ក៏ពួកគេនៅតែអភិវឌ្ឍពាក្យរបស់ពួកគេដែរ។ ជាធម្មតាកុមារៗបានត្រឹមតែរៀនអាននិងសរសេរ នៅពេលកុមារទាំងនេះមានអាយុ៥ឬ៦ឆ្នាំ។ ពួកគេប្រហែលមិនអាចរៀបរាប់ពីអារម្មណ៍របស់ពួកគេនៅក្នុងការនិយាយឡើយ។ ករណីនេះមិនគួរជាការបាត់បង់ទិសដៅអង្គហេតុដែលកុមារអាយុ៥ឆ្នាំ អាចបង្កើតហើយយល់ឃ្លា ល្បះដ៏ច្រើននិងស្មុគស្មាញ។ នៅអាយុ៥ឆ្នាំ កុមារគឺមានជំនាញគ្រប់ប្រភេទនៃសំណង់ប្រយោគដែលបានប្រើនៅក្នុងភាសារបស់ពួកគេ។ ជាមួយគ្នានេះដែរ កុមារនៅអាយុនេះ គឺមិនត្រឹមតែចាប់យកលេខនោះទេ ប៉ុន្តែកុមារភាគច្រើន គឺអាចចងខ្សែស្បែកជើងខ្លួនឯង ឬក៏គូរម្រាមដៃមនុស្សថែមទៀតផង។ ចំណេះដឹងរហ័សដោយកុមារវ័យក្មេង គឺជាអង្គហេតុសំខាន់ផ្សេងទៀតដែលប្រឈមមុខនឹងទ្រឹស្តីចិត្តភាសាវិទ្យា ដើម្បីបកស្រាយបញ្ហាទាំងនេះ។

សារៈសំខាន់ទី៤របស់អង្គហេតុអំពីការអភិវឌ្ឍភាសា គឺជាជំហានបន្តបន្ទាប់របស់កុមារម្នាក់ៗ ទៅតាមរយៈជំនាញភាសានៃសហគមន៍របស់ពួកគេ។ ពួកគេរីកចម្រើនដោយដំណាក់កាលដូចៗគ្នា នៃចំណេះដឹងដែលទទួលបាន ហើយនៅក្នុងលំដាប់តែមួយ។ វាគឺត្រឹមត្រូវដែលតម្លៃដោយឡែករបស់កុមារៗឆ្លងកាត់នូវដំណាក់កាលទាំងនេះប្រហែលខុសប្លែក ទោះយ៉ាងណានៅក្នុងពាក្យដទៃទៀត ដំណាក់កាលគឺមិនមែនជាអាយុ គឺជាសន្ទស្សន៍ដ៏ប្រសើរមួយនៃកម្រិតអភិវឌ្ឍភាសារបស់កុមារៗ។ អង្គហេតុនេះផងដែរត្រូវតែពិចារណា ដោយបែបបទខ្លះៗនៃការចាប់យកភាសា។

ដំណើរការនៃការចាប់យកភាសាមានតម្រូវការមូលដ្ឋានមួយចំនួន។ អំឡុងពេលនៃការអភិវឌ្ឍរយៈពេល ២ ឬ ៣ ឆ្នាំដំបូង កុមារតម្រូវឱ្យមានការនិយាយលួងលោមជាមួយអ្នកប្រើភាសាដទៃទៀត ដើម្បីនាំយកសមត្ថភាពភាសាទូទៅ ទៅទំនាក់ទំនងជាមួយភាសាជាក់លាក់មួយ ដូចជាភាសាអង់គ្លេស។ យើងក៏បានកំណត់សារៈសំខាន់នៃការបញ្ជូនវប្បធម៌ផងដែរ។ នេះមានន័យថា ភាសាពិសេសដែលកុមាររៀនមិនត្រូវបានទទួលមរតកពីហ្សែនទេ ប៉ុន្តែត្រូវបានទទួលនៅក្នុងមជ្ឈដ្ឋានប្រើប្រាស់ភាសាជាក់លាក់មួយ។

កុមារត្រូវការសមត្ថភាពពីធម្មជាតិដើម្បីបញ្ចូននិងទទួលសញ្ញាសូរពីភាសាណាមួយ។ ទារកទាំងអស់បង្កើតសំឡេងថ្ងូរ (cooing) និងសំឡេងកកែកករ ក្នុងរយៈពេល១ឆ្នាំ ប៉ុន្តែទារកគថ្លង់ពីកំណើតបានបាត់សំឡេងនេះបន្ទាប់ពីរយៈពេលប្រហែលជា៦ខែ។ ដូច្នេះកុមារត្រូវតែអាចស្តាប់ភាសានោះបាន ដើម្បីនិយាយភាសាមួយ។ ទោះជាយ៉ាងណាក៏ដោយ ក៏កុមារស្តាប់សំឡេងភាសានោះមិនគ្រប់គ្រាន់ទេ។ ករណីមួយត្រូវបានរាយការណ៍ដោយ លោកម៉ូស្កូវីត (Moskowitz) នៅឆ្នាំ១៩៩១ បានបង្ហាញថា កុមារដែលរស់នៅជាមួយនឹងឪពុកម្តាយដែលគថ្លង់ ហើយពួកគេមានកូនប្រុសម្នាក់ ប៉ុន្តែកូនប្រុសនេះគឺស្តាប់ឮដូចក្មេងធម្មតាដែរ។ គេក៏បានដាក់កម្មវិធីទូរទស្សន៍និងវិទ្យុសម្រាប់កុមារៗ ឱ្យក្មេងប្រុសនេះមើលផងដែរ ប៉ុន្តែក្មេងប្រុសនេះ មិនមានលទ្ធភាពនិយាយឬយល់ភាសាអង់គ្លេសបានទេ។ អ្វីដែលគាត់បានរៀនយ៉ាងមានប្រសិទ្ធភាពតាំងពីអាយុ៣ឆ្នាំ គឺការប្រើប្រាស់ភាសាសញ្ញាអាមេរិក នោះគឺជាភាសាដែលគាត់ធ្លាប់មានទំនាក់ទំនងជាមួយឪពុកម្តាយរបស់គាត់។ តម្រូវការចាំបាច់មួយទំនងជាឱកាសដើម្បីធ្វើអន្តរកម្មជាមួយអ្នកដទៃតាមរយៈភាសា។

**១.១.២. ធាតុចូល**

តាមកាលៈទេសៈធម្មតា ទារកដែលកើតមក ពិតជាត្រូវបានជួយក្នុងការចាប់យកភាសារបស់ពួកគេដោយអាកប្បកិរិយាធម្មតារបស់កុមារធំនិងមនុស្សពេញវ័យនៅក្នុងមជ្ឈដ្ឋានជុំវិញផ្ទះដែលផ្តល់នូវគំរូភាសា ឬជាធាតុចូលសម្រាប់កុមារ។ មនុស្សពេញវ័យ ដូចជាឪពុកម្តាយនិងជីដូនជីតាមិនចង់និយាយទៅកាន់មនុស្សតូច មុនពួកគេចូលរួមក្នុងការសន្ទនារវាងមនុស្សពេញវ័យនិងមនុស្សពេញវ័យ។ វាមិនមានច្រើនទេ «ឧទាហរណ៍ *Well, John Junior,* តើយើងនឹងវិនិយោគលើឧស្សាហកម្មឈើបខៀវ ឬតើគ្រាប់ធញ្ញជាតិនាពេលអនាគតផ្តល់នូវអនាគតល្អជាងនេះ?» ទោះយ៉ាងណាក៏ដោយ វាហាក់ដូចជាមានច្រើនណាស់ (ឧទាហរណ៍ *Oh! Goody, now Daddy push choo-choo?*) ចរិតសម្តីដែលមានលក្ខណៈសាមញ្ញ ត្រូវបានទទួលយកដោយមនុស្សម្នាក់ដែលចំណាយពេលច្រើនក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារ ហើយត្រូវបានគេហៅថា សម្តីអ្នកថែទាំ។

លក្ខណៈពិសេសនៃសម្តីប្រភេទនេះ ហៅថា «*motherese*» ឬ «សម្តីដែលដឹកនាំកុមារ» គឺជាការប្រើសំណួរជាញឹកញាប់ ដែលជារឿយៗ ប្រើការនិយាយបំផ្លើស ការនិយាយបន្ថែមសំឡេង។ ទាំងនេះ គឺជាពាក្យសាមញ្ញៗ ដូចជា *tummy, nana* ទម្រង់បែបបទនៃការនិយាយដោយផ្ទាល់មាត់ ការពិពណ៌នានិងការពិពណ៌នាសម្រាប់អ្វីដែលនៅក្នុងមជ្ឈដ្ឋានរបស់កុមារ *choo-choo, poo-poo, pee-pee, wa-wa*។ សម្តីអ្នកថែទាំក៏ត្រូវបានកំណត់ដោយរចនាសម្ព័ន្ធប្រយោគសាមញ្ញនិងពាក្យដដែលៗជាច្រើន។ ប្រសិនបើកុមារពិតជានៅក្នុងដំណើរការនៃការបង្កើតប្រព័ន្ធនៃការដាក់សំឡេងនិងពាក្យជាមួយគ្នានោះ គំរូសាមញ្ញទាំងនេះដែលបង្កើតឡើង ដោយមនុស្សពេញវ័យដែលមានអន្តរកម្ម អាចដើរតួជាតម្រុយដ៏ល្អសម្រាប់ការរៀបចំរចនាសម្ព័ន្ធមូលដ្ឋានដែលពាក់ព័ន្ធ។ លើសពីនេះទៅទៀត វាត្រូវបានគេសង្កេតឃើញជាទូទៅថា សម្តីរបស់អ្នកដែលប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយកុមារតូចៗ មានការផ្លាស់ប្តូរហើយកាន់តែមានលក្ខណៈល្អិតល្អន់ នៅពេលកុមារចាប់ផ្តើមប្រើភាសាកាន់តែច្រើនឡើងៗ។ ដំណាក់កាលជាច្រើននៅក្នុងដំណើរការចាប់យកភាសាដំបូងត្រូវបានគេរកឃើញ។

មនុស្សជាច្រើនជឿថា កុមារៗរៀននិយាយបានយ៉ាងត្រឹមត្រូវដោយសារឪពុកម្តាយរបស់ពួកគេ ដែលជាអ្នកកែតម្រូវ នៅពេលពួកគេនិយាយអ្វីខុស។ នេះមិនអាចក្លាយជាមូលដ្ឋាននៃការចាប់យកភាសានោះទេ។ ជាដំបូងពួកយើងសង្កេតឃើញថា ការចាប់យកភាសា គឺមានកំហុសច្រើន។ ប្រសិនបើកុមារៗមិនបានបង្កើនូវកំហុសណាមួយនោះទេ ពួកយើងសង្ឃឹមយ៉ាងមុតមាំថា ឪពុកម្តាយរបស់ពួកគេជាអ្នកកែតម្រូវ។

តើអ្វីទៅជាកំហុសដែលកុមារៗ បានបង្កើតឡើង? អ្នកស្រាវជ្រាវបានរកឃើញថា ឪពុកម្តាយមិនបានជួយកែតម្រូវនូវកំហុសប្រព័ន្ធវេយ្យាករណ៍ដល់កូនៗរបស់ពួកគេនោះទេ ទោះបីជាការកែតម្រូវឡើងវិញរបស់អ្នកផ្សេងៗទៀតក៏ដោយ។ នៅដើមទសវត្សឆ្នាំ១៩៧០ កុមារចំនួន១២នាក់ត្រូវបានគេសង្កេតដោយការថតសំឡេងនិងការថត

វីដេអូ អស់រយៈពេលជាច្រើនរយម៉ោងដោយអ្នកស្រាវជ្រាវច្រើននាក់ ដែលធ្វើការក្នុងវិស័យចិត្តភាសាវិទ្យា។ គ្រប់ទិន្នន័យទាំងអស់ គឺបានឆ្លងកាត់ការត្រួតពិនិត្យយ៉ាងល្អិតល្អន់ ការព្យាយាមខ្លាំងដើម្បីស្វែងរកអង្គហេតុក្នុងការគាំទ្រ និងប្រឆាំងនូវសម្មតិកម្មដោយឡែក ដូចជាសម្មតិកម្មដែលថា ឪពុកម្តាយជួយដល់កូនដើម្បីអភិវឌ្ឍជំនាញភាសារបស់កូនខ្លួន។

ការសិក្សាមួយអំពីវត្តមាននៃការរិះគន់ស្ថាបនា (ឬក៏ភស្តុតាងអវិជ្ជមាន) ទៅកាន់កុមារៗ ដោយចិត្តវិទូ រ៉ូជ័រ ប្រោន (Roger Brown) និង កាម៉េ ហានឡុន (Camille Hanlon) បានយល់ឃើញថា ឪពុកម្តាយទទួលខុសត្រូវលើពាក្យសម្ដីរបស់កូនខ្លួន។ ដំបូងអ្នកវិទ្យាសាស្ត្រទាំងនេះ បានកត់ត្រាគ្រប់ករណីទាំងអស់ដែលឪពុកម្តាយឆ្លើយដោយការបង្ហាញនូវអ្វីដែលកូនខ្លួនបាននិយាយហើយពួកគាត់មិនយល់អ្វីនោះទេ។ ពួកគេបានរកឃើញថា វាមិនមានភាពពាក់ព័ន្ធគ្នារវាងការយល់ឃើញរបស់ឪពុកម្តាយ ជាមួយនិងទម្រង់វេយ្យាករណ៍ ដែលកុមារបាននិយាយនោះឡើយ។ ឪពុកម្តាយប្រហែលអាចយល់ភាសារបស់កូនតាមរយៈការនិយាយច្បាស់ៗ។

ប្រោន (Brown) និង ហានឡុន (Hanlon) បានកត់ត្រាផងដែរនូវករណីយល់ស្របនិងមិនយល់ស្របនៅក្នុងចម្លើយរបស់ឪពុកម្តាយ។ អ្វីដែលពួកគេបានរកឃើញ គឺចម្លើយយល់ស្របដែលមិនមានភាពខុសគ្នារវាងប្រយោគដែរត្រូវតាមក្បួននិងការនិយាយខុសរបស់កុមារៗនោះឡើយ។ ឪពុកម្តាយ គឺផ្តល់មតិស្ថាបនានូវភាពខុសគ្នារវាងប្រយោគខុសនិងប្រយោគត្រូវ ដោយមិនបានយល់ឃើញថា តើប្រយោគទាំងនេះ គឺត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ឬក៏អត់។ ជាឧទាហរណ៍ កុមារម្នាក់ដែលក្រុមលោក ប្រោន (Brown) សិក្សានោះ បាននិយាយថា «*Mama isn't boy, he a girl*» ទោះបីជាការនិយាយខុសវេយ្យាករណ៍ក្តី ក៏ម្តាយនាងតបថា ត្រឹមត្រូវហើយ។ ម្យ៉ាងទៀតនៅពេលកុមារនិយាយថា «*Walt Disney come on Tuesday*» ម្តាយនាងតបថា «*No, he does not*» (ពីព្រោះដូចដែលយើងដឹង *Walt Disney* គឺមកនៅថ្ងៃអាទិត្យ)។ សរុបមកឪពុកម្តាយ គឺផ្តល់ភាពអវិជ្ជមានត្រឡប់ទៅឱ្យកូនៗវិញ នៅពេលកូនៗនិយាយមិនពិត ប៉ុន្តែពួកគេគឺមិនចែកចាយការពង្រឹងភាពវិជ្ជមាននិងភាពអវិជ្ជមានដែលជាវិធីមួយទាក់ទងទៅនឹងការរៀនភាសារបស់កូនៗខ្លួន។

ក្រុមអ្នកស្រាវជ្រាវរកឃើញភស្តុតាងដើម្បីឆ្លើយតបនឹងមតិរិះគន់ផ្សេងៗ ដែលជាការផ្តល់នូវកត្តាសំខាន់ក្នុងការអភិវឌ្ឍភាសា។ ភស្តុតាងនៃប្រភេទនេះ គឺធ្វើឱ្យជឿជាក់ ថ្វីបើវាជាបទពិសោធផ្ទាល់ខ្លួនក៏ដោយ។ ជាញឹកញាប់យើងបានកត់សម្គាល់ថា កុមារៗខកខានទទួលឱកាសដែលឪពុកម្តាយព្យាយាមជួយកែតម្រូវភាសាពួកគេ។ ជាឧទាហរណ៍កុមារម្នាក់ដែលគេបានឮសម្ដីរបស់នាង ដោយនាងបាននិយាយថា «*Nobody don't like me*» ព្រោះឪពុកនាងជាភាសាវិទូ។ ឪពុកកុមារនេះ ព្យាយាមកែតម្រូវវេយ្យាករណ៍នៅក្នុងប្រយោគរបស់កូន។ ឪពុកព្យាយាមនិយាយថា «*No, say , Nobody likes me*» កុមារនៅតែនិយាយថា «*Nobody don't like me*»។ នាងនិយាយឡើងប្រាំបីដង រហូតដល់ចុងក្រោយកុមារគិតថា នាងយល់នូវការកែតម្រូវ។ នាងបាននិយាយបន្តទៀតថា «*Oh! Nobody don't likes me*»។

រឿងនេះផ្តល់នូវការយល់ដឹងដ៏ច្រើនទៅក្នុងបញ្ហាដែលកុមារនឹងប្រឈមមុខ ប្រសិនបើពួកគេបានប្រើនូវការដាក់បញ្ចូលរបស់ឪពុកម្តាយ ដើម្បីជាមូលដ្ឋានកែតម្រូវកំហុសវេយ្យាករណ៍របស់ពួកគេ គឺជាបញ្ហាដទៃទៀត។

មតិខ្លះតែងតែណែនាំថា ក្មេងអភិវឌ្ឍចំណេះដឹងវេយ្យាករណ៍នៃភាសាតាមរយៈការត្រាប់តាម។ នោះគឺក្មេងរៀនភាសាតាមការត្រាប់តាមសម្ដីរបស់ឪពុកម្តាយ។ ចំណុចនេះប្រហែលជាមានការពិតតិចតួចអំពីសំណើនេះ វាមិនអាចក្លាយជារឿងទាំងមូលនោះទេ។ ប្រភពភស្តុតាងមួយដែលឆ្លើយតបទៅនឹងការអះអាងថា ក្មេងៗរៀនដោយការត្រាប់តាម មកពីភាពទៀងទាត់របស់ក្មេង។ ឧទាហរណ៍មួយគឺ ក្មេងបង្កើតកំហុសកាលអតីតកាល និងទម្រង់ពហុវចនៈដូចជាពាក្យ «*goed*» និង «*foots*»។ ទម្រង់ទាំងនេះ គឺច្បាស់លាស់ មិនមែនបង្កើតតាមការត្រាប់តាមទេ ពីព្រោះពួកគេមិនបង្ហាញនូវការទទួលជាតុចូលពីមនុស្សពេញវ័យទេ។ ទម្រង់មនុស្សមិនទាន់ពេញវ័យទាំងនេះ គឺជា

ភស្តុតាង ដែលកុមារបង្កើតទម្រង់ទូទៅនីយកម្ម (មានន័យថាជាក្បួន) ដែលអាចផ្តល់លទ្ធភាពដល់កុមារដើម្បីបង្កើតភាសាដែលពួកគេមិនធ្លាប់ជួបប្រទះពីមុនមក។ នៅក្នុងករណីនេះ កុមារអាចសម្រេចបានច្បាស់លាស់នូវទម្រង់មនុស្សពេញវ័យអំពីអតីតកាលនិងពហុវចនៈ ប៉ុន្តែមានការអោក់អួលនូវការអនុវត្ត ដើម្បីទប់ស្កាត់ការប្រែប្រួលដែលធ្វើឱ្យពួកគេមិនអាចចាប់យកវេយ្យាករណ៍មនុស្សពេញវ័យបាន។

នេះជាការកត់សម្គាល់ដ៏គួរឱ្យចាប់អារម្មណ៍ផងដែរថា ពាក្យសម្តីរបស់មនុស្សដែលមិនទាន់ពេញវ័យ ដូចជា «*goed*» និង «*foots*» បន្តលេចឡើងនៅក្នុងពាក្យសម្តីរបស់កុមារអស់រយៈពេល៣ទៅ៤ខែ ពេលខ្លះច្រើនឆ្នាំ។ ការប្រមើលមើលនេះ ត្រូវបានគេយកចេញពីទម្រង់វេយ្យាករណ៍របស់កុមារៗ ក្រោយពីកុមារជួបប្រទះនូវការកើតឡើងនូវការប្រែប្រួលរបស់មនុស្សពេញវ័យដទៃទៀត។ ទម្រង់ផ្សេងៗទាំងនេះនៅក្នុងការប្រណាំងប្រជែងជាមួយទម្រង់ខុសដែលកើតចេញមកពីវេយ្យាករណ៍របស់កុមារ។ ករណីនេះធ្លាប់បានណែនាំថា ទម្រង់ខុសរបស់កុមារត្រូវបានគេប្រានចោល ពីព្រោះវេយ្យាករណ៍របស់ពួកគេ មានផ្ទុកនូវគោលការណ៍រាំងស្ទះមួយឬគោលការណ៍ពិសេសមួយ។ យោងទៅតាមប្រភេទគោលការណ៍នេះ វត្តមាននៃទម្រង់ប្រែប្រួលទប់ស្កាត់នូវច្បាប់បង្កើតឡើងទូទៅមួយ។ ទម្រង់ទាំងពីរនៃការបង្ហាញនេះ គឺអនុញ្ញាតឱ្យមានក្នុងពេលដំណាលគ្នា ប្រសិនបើមានភស្តុតាងច្រើន (នៅក្នុងការដាក់បញ្ចូល) សម្រាប់ទម្រង់ផ្សេងៗនៃការបង្ហាញ។ គោលការណ៍អនុវត្តច្បាស់លាស់ទាំងនេះ គឺនៅក្នុងវេយ្យាករណ៍របស់មនុស្សពេញវ័យ ព្រមទាំងវេយ្យាករណ៍របស់កុមារ។ យោងទៅតាមការទទួលយកទាំងពីររបស់មនុស្សពេញវ័យ គឺ «*dived*» និង «*dove*» ប៉ុន្តែមិនមែន «*singed*» នោះទេ។

ឧទាហរណ៍ផ្សេងទៀតដែលបង្កើតឡើងដោយកុមារ ហើយនិងមិនមែនបង្កើតឡើង ដោយមនុស្សពេញវ័យចំណុចនេះផ្តោតលើសំណួររបស់ពួកគេ។ ពេលខ្លះ កុមារសួរទម្រង់សំណួរដែលមិនត្រឹមត្រូវ ដូចជា «*Where he is going*» ? អ្វីដែលបង្កើតការចាប់អារម្មណ៍ គឺថាកុមារដែរសួរសំណួរដូចនេះ ហើយក៏បានសួរផងដែរនូវសំណួរខុសនៅក្នុងប្រភេទផ្សេងទៀត ដូចជា «*Is he going?*» នេះមានន័យថា ពួកគេមានការដាក់បញ្ចូលអារម្មណ៍ទៅក្បួនដែលជាតម្រូវការទម្រង់សំណួរទាំងនេះ។ ប៉ុន្តែជាញឹកញាប់ពួកគេបរាជ័យក្នុងការអនុវត្តក្បួនត្រឹមត្រូវនៅក្នុងទម្រង់សំណួរ។ ទម្រង់ទាំងនេះ គឺបង្កើតវេយ្យាករណ៍នៅក្នុងចិត្តរបស់កុមារ (សមហេតុផលនូវដែនកំណត់នូវការសម្តែងរបស់ពួកគេ) ហើយនិងមិនត្រលប់មកវិញនូវការប៉ុនប៉ងរបស់ពួកគេ ដើម្បីគ្រាប់តាមអ្វីដែលពួកគេជួបប្រទះនៅក្នុងការដាក់បញ្ចូល។

គេធ្លាប់បានរកឃើញថា កុមារដែលនិយាយភាសាអង់គ្លេសមួយចំនួនចន្លោះអាយុ៣ទៅ៤ឆ្នាំ មិនបានផ្លាស់ប្តូរការដាក់បញ្ចូលបន្ថែមពាក្យនៅក្នុងសំណួរមួយចំនួនរបស់ពួកគេ ដូចជា «*What do you think what pigs eat?*» ការលេចធ្លោឡើងនៃពាក្យបន្ថែមនៅក្នុងភាសារបស់កុមារដែលរៀនភាសាអង់គ្លេស មិនអាចពន្យល់ពីការឆ្លើយតបរបស់កុមារក្នុងធាតុចូលទេ។ ទោះបីជា ការបង្កើតទម្រង់ទាំងនេះមិនត្រឹមត្រូវល្អ តាមទម្រង់វេយ្យាករណ៍អង់គ្លេសក៏ដោយ ក៏សំណង់ប្រយោគទាំងនេះ គឺបានរកឃើញនៅក្នុងគ្រាមភាសាអាល្លឺម៉ង់ និងភាសាដទៃទៀត។ ភស្តុតាងទាំងនេះ មានតម្លៃក្នុងការកត់ត្រាថា ប្រសិនសម្មតិកម្មពីកំណើត គឺត្រឹមត្រូវ បន្ទាប់មកទៀត គឺមិនមានហេតុផលជាអាទិភាពក្នុងការសង្ឃឹមសម្មតិកម្មវេយ្យាករណ៍កុមារ ដែលជាជំនួយទៅកាន់បទពិសោធភាសាវិទ្យា។ ទោះជាយ៉ាងណា ប្រសិនបើក្មេងៗបង្កើតនូវសម្មតិកម្មទាំងនេះ តាំងពីពួកគេជាមនុស្សមិនទាន់ពេញវ័យផងនោះ សម្មតិកម្មនេះគួរតែស្របទៅតាមលទ្ធភាពនៃវេយ្យាករណ៍សកល។

សេចក្តីពន្យល់ដែលសមហេតុផលដទៃទៀតអំពីកុមារអភិវឌ្ឍភាសាតាមរបៀបណាគឺថា ឪពុកម្តាយធ្វើឱ្យកូនពួកគេនិយាយ និងធ្វើឱ្យទម្រង់ធម្មតារបស់កុមារទៅក្នុងប្រយោគដែលសមរម្យ។ ឧទាហរណ៍ ប្រសិនបើកុមារនិយាយថា «*Daddy chair*» ឪពុកម្តាយប្រហែលឆ្លើយតបវិញថា «*Yes, That's right dear, you're sitting on Daddy's chair*»។ បើទោះបីជាពេលខ្លះ ឪពុកម្តាយធ្វើដូចនេះក៏ដោយ វាមិនអាចក្លាយជាប្រព័ន្ធដ៏មឹុងម៉ាត់ ដើម្បី

អភិវឌ្ឍភាសានោះទេ។ នេះគឺបានបង្ហាញនៅក្នុងការសិក្សាជាមួយកុមារសាលាមត្តេយ្យ។ ក្រុមមនុស្សពេញវ័យមួយក្រុមបានសួរទៅកាន់កុមារផ្សេងៗដោយទៀងទាត់ អ្វីដែលកុមារនិយាយ។ ពួកគេធ្វើដូចនេះរយៈពេលប្រាំថ្ងៃក្នុងមួយសប្តាហ៍ អស់រយៈពេលបីខែ។ ក្រុមដទៃទៀត គឺឪពុកម្តាយដែលជាអ្នកដឹកនាំក្រុម។ ការពង្រីកគឺមិនទៀងទាត់ឡើយសម្រាប់ក្រុមនេះ។ ការរកឃើញដ៏សំខាន់នេះ គឺផ្អែកលើបទពិសោធក្រុម កុមារដែលបានបង្ហាញនូវភាពគ្មានប្រសើរឡើងនៅក្នុងភាសារបស់ពួកគេ ហើយទាក់ទងនឹងក្រុមត្រួតពិនិត្យនោះ គឺមិនទទួលបានការពង្រីកពាក្យសម្តីរបស់ពួកគេឡើយ។ ទោះបីជាពេលខ្លះ ឪពុកម្តាយធ្វើឱ្យកូនៗនិយាយក៏ដោយ ក៏នេះប្រហែលជាមិនមែនអង្គហេតុដំបូងនៅក្នុងការអភិវឌ្ឍភាសាឡើយ។

## ១.២. ដំណាក់កាលនៃការចាប់យកភាសា

កុមារធម្មតាទាំងអស់អភិវឌ្ឍភាសាក្នុងពេលដំណាលគ្នានឹងកាលវិភាគដូចគ្នា។ យើងអាចនិយាយថាកុមារចាប់ផ្តើមអភិវឌ្ឍដូចគ្នា ដូចជាការអង្គុយ ការវារ ការឈរ ការដើរ ការប្រើដៃ និងសកម្មភាពរាងកាយផ្សេងៗទៀត។ ដំណើរការទាំងនេះហាក់ដូចជាថា ដំណាក់កាលនៃការចាប់យកភាសា មានមូលដ្ឋានដូចគ្នានឹងការអភិវឌ្ឍនៃការកំណត់ផ្នែកជីវសាស្រ្តជំនាញចលនា។ ដំណាក់កាលផ្នែកជីវសាស្រ្តនេះ ត្រូវបានចងភ្ជាប់ទៅនឹងការបំពេញលក្ខណៈនៃខួរក្បាលរបស់កុមារ។

យើងអាចគិតថា កុមារមានសមត្ថភាពជីវសាស្រ្តដើម្បីដោះស្រាយនូវភាពប្លែកៗពីគ្នានៃការបញ្ចូលទិដ្ឋភាពភាសាច្បាស់លាស់នៅដំណាក់កាលខុសគ្នាៗ ក្នុងរយៈពេលដើមឆ្នាំនៃជីវិតរបស់ពួកគេ។ មុនពេលដែលកុមារចាប់ផ្តើមនិយាយ ពួកគេបានដំណើរការយ៉ាងសកម្មនូវអ្វីដែលពួកគេបានឮ។ យើងអាចកំណត់បាននូវអ្វីដែលកុមារតូចៗកំពុងយកចិត្តទុកដាក់ដោយវិធីដែលពួកគេកើនឡើងឬថយចុះ «ឥរិយាបថនៃការជញ្ជក់» ក្នុងការឆ្លើយតបទៅនឹងសំឡេងនិយាយឬបង្វែរទិសដៅទៅរកសំឡេងទាំងនោះ។ នៅអាយុមួយខែ ទារកមួយដែលមានសមត្ថភាពក្នុងការសម្គាល់រវាងសំឡេងដូចជា បា [ba] និង ប៉ា [pa] ។ ក្នុងកំឡុងពេលបីខែដំបូង កុមារមានទម្រង់យំដែលមានលំនាំខុសៗគ្នាសម្រាប់តម្រូវការខុសៗគ្នាបង្កើតស្នាមញញឹមធំៗ ដើម្បីឆ្លើយតបនឹងការធ្វើទឹកមុខហើយចាប់ផ្តើមបង្កើតសំឡេងប្លែកៗ។

### ១.២.១. ការថ្ងូរនិងកកែកករ

ការប្រើសំឡេងដូចការនិយាយដំបូងបំផុតត្រូវបានពិពណ៌នាថាជាការសហការ។ ក្នុងរយៈពេលពីរបីខែដំបូងនៃជីវិតកុមារមានសមត្ថភាព ដោយចាប់ផ្តើមបង្កើតសំឡេងស្រដៀងនឹងស្រៈ ជាពិសេសស្រៈដែលជាស្រៈខ្ពស់ស្រដៀងនឹង [i] និង [u] ។ នៅពេលកុមារមានអាយុបួនខែ កុមារមានសមត្ថភាពក្នុងការនាំផ្នែកខាងក្រោយនៃអណ្តាតទៅទំនាក់ទំនងទៀងទាត់ជាមួយផ្នែកខាងក្រោយនៃក្រអូមមាត់ អាចឱ្យទារកបង្កើតសំឡេងស្រដៀងនឹងព្យញ្ជនៈ [k] និង [g] ហេតុដូច្នេះការពិពណ៌នារួមថាការថ្ងូរ (cooing) ឬ សំឡេងឆែតៗ (gooing) សម្រាប់ការបង្កើតសំឡេងប្រភេទនេះ។ ការសិក្សាអំពីការយល់ដឹងសម្តី បានបង្ហាញថា នៅពេលពួកគេមានអាយុច្រើនខែទារកអាចឮពីភាពខុសគ្នារវាងស្រៈ [i] និង [a] ហើយនិងបែងចែកពីភាពខុសគ្នារវាងសូរព្យាង្គផ្សេងៗដូចជា [ba] និង [ga]។

នៅចន្លោះអាយុពីប្រាំមួយ ទៅប្រាំបីខែ កុមារអាចអង្គុយបាន ហើយបង្កើតសូរស្រៈនិងព្យញ្ជនៈផ្សេងៗគ្នានិងអាចបន្សំសូរទាំងពីរជាមួយគ្នាដូចជា ba-ba-ba និង ga-ga-ga។ ការបង្កើតសំឡេងប្រភេទនេះត្រូវបានពិពណ៌នាថា ជាសម្តីកកែកករ (babbling) នៅដំណាក់កាលកកែកករបន្តបន្ទាប់ទៀត នៅអាយុប្រហែលប្រាំបួនទៅដប់ខែ។ វាមានគំរូលើកដាក់សំឡេងដែលគួរឱ្យកត់សម្គាល់ដើម្បីបង្កើតការផ្សំគ្នារវាងព្យញ្ជនៈនិងស្រៈ ដូចជា ba-ba-da-da។ សូរសំឡេងខ្យល់ច្រមុះក៏កាន់តែមានលក្ខណៈទូទៅនិងការរៀបលំដាប់នៃព្យាង្គច្បាស់លាស់ ដូចជា ma-ma និង da-da ហើយវាកើតឡើងម្តងហើយម្តងទៀតចំពោះកុមារ។

នៅពេលកុមារចាប់ផ្ដើមតោងឈរនៅខែទីដប់និងទីដប់មួយ ពួកគេមានសមត្ថភាពប្រើសំឡេងរបស់ពួកគេដើម្បីបង្ហាញពីអារម្មណ៍ផ្សេងៗនិងរបៀបលើកដាក់សំឡេង។ ដំណាក់កាលកកែកករចុងក្រោយនេះ ត្រូវបានសម្គាល់ដោយបន្សំព្យាង្គដែលស្មុគស្មាញជាងនេះ ឧទាហរណ៍ ma-da-ga-ba ពោលគឺមានការបង្កើតសំឡេងច្រើនហើយព្យាយាមធ្វើត្រាប់តាម។ ការប្រើប្រាស់សំឡេងបុរេភាសា (pre-language) នេះ ផ្ដល់ឱ្យកុមារនូវបទពិសោធខ្លះនៃតួនាទីសង្គមចំពោះការនិយាយស្ដី ពីព្រោះមនុស្សធំមានទំនោរប្រតិកម្មទៅនឹងសំឡេងកកែកករបស់កុមារទោះយ៉ាងណាវាហាក់ដូចជាការចូលរួមចំណែករបស់កុមារក្នុងការប្រាស្រ័យទាក់ទងក្នុងសង្គម។

ចំណុចមួយនៃការប្រុងប្រយ័ត្នគួរតែត្រូវបានបន្លឺឡើងនៅចំណុចនេះ។ អ្នកស្រាវជ្រាវភាសាកុមារពិតជាផ្ដល់របាយការណ៍ដោយយកចិត្តទុកដាក់បំផុតទៅលើអាយុរបស់កុមារដែលពួកគេសិក្សា។ ទោះយ៉ាងណាក៏ដោយពួកគេក៏មានការប្រុងប្រយ័ត្នខ្ពស់ផងដែរ ក្នុងការចង្អុលបង្ហាញថា មានការប្រែប្រួលយ៉ាងខ្លាំងក្នុងចំណោមកុមារទាក់ទងនឹងអាយុដែលលក្ខណៈពិសេសនៃការអភិវឌ្ឍភាសាកើតឡើង។ ដូច្នេះយើងគួរតែចាត់ទុកសេចក្ដីថ្លែងទាក់ទងនឹងដំណាក់កាលអភិវឌ្ឍន៍ដូចជា ត្រឹមប្រាំមួយខែ ឬដល់អាយុពីរឆ្នាំ ដែលប្រហាក់ប្រហែលនឹងអាចមានការប្រែប្រួលចំពោះកុមារម្នាក់ៗ។

### **១.២.២. ដំណាក់កាលមួយពាក្យ**

នៅចន្លោះពីដប់ពីរទៅដប់ប្រាំបីខែ កុមារចាប់ផ្ដើមផលិតពាក្យដែលមានសម្ដីតែមួយឯកតាដែលអាចស្គាល់បាន។ ដំណាក់កាលនេះហៅថា ដំណាក់កាលតែមួយពាក្យ ហើយត្រូវបានកំណត់ដោយការនិយាយតែមួយពាក្យៗដែលត្រូវបានប្រើសម្រាប់វត្ថុប្រចាំថ្ងៃដូចជា ទឹកដោះគោ (milk) នំឃុកឃី (cookie) ឆ្មា (cat) ពែង (cup) និងស្លាបព្រា (spoon ជាទូទៅ បញ្ចេញសំឡេង [pun])។ ទម្រង់ផ្សេងៗទៀតដូចជា [ʌsæ] អាចកើតឡើងក្នុងកាលៈទេសៈដែលបង្ហាញថា កុមារកំពុងផលិតកំណែថ្មី ដែលជាស្លាកសម្គាល់ថា «មួយពាក្យ» សម្រាប់ដំណាក់កាលនេះអាចយល់ច្រឡំហើយពាក្យមួយដូចជា ឯកតាតែមួយ អាចនឹងត្រឹមត្រូវច្រើនជាងនេះ។ ពេលខ្លះយើងប្រើពាក្យថាឃ្លាដែលមានតែមួយពាក្យ (holophrastic) ដែលមានន័យថាទម្រង់តែមួយមានមុខងារជាឃ្លាឬល្បះ) ដើម្បីពិពណ៌នាសម្ដី ដែលអាចត្រូវបានវិភាគថា ជាពាក្យមួយ ឃ្លាមួយ ឬល្បះមួយ។

នៅពេលកុមារផលិតសម្ដីបែបឃ្លាមានតែមួយពាក្យ ភាគច្រើនហាក់ដូចជាត្រូវបានប្រើដើម្បីដាក់ឈ្មោះវត្ថុពួកគេអាចនឹងត្រូវបានបង្កើតឡើងសម្រាប់កុមារដែលកំពុងពង្រីកការប្រើប្រាស់ពាក្យរបស់ពួកគេ។ នៅពេលកុមារឃើញគ្រែទទេ ហើយកុមារអាចបង្កើតឈ្មោះរបស់បងស្រីម្នាក់ដែលតែងតែដេកនៅលើគ្រែនោះ សូម្បីតែមិនមានឈ្មោះរបស់មនុស្សនោះក៏ដោយ។ ដំណាក់កាលនេះ កុមារអាចមានសមត្ថភាពសំដៅចំពោះឈ្មោះ Karen និងគ្រែ ប៉ុន្តែមិនអាចបញ្ចូលទម្រង់ពាក្យទាំងពីរឱ្យចូលគ្នាបាននៅឡើយទេ ដើម្បីបង្កើតកន្សោមពាក្យដ៏ស្មុគស្មាញមួយ។

### **១.២.៣. ដំណាក់កាលពីរពាក្យ**

ដំណាក់កាលពីរពាក្យអាស្រ័យលើអ្វីដែលយើងរាប់ថា វាជាការកើតឡើងនៃពាក្យពីរផ្សេងគ្នាដែលត្រូវបានប្រើជាមួយគ្នា។ ដំណាក់កាលពីរពាក្យអាចចាប់ផ្ដើមនៅប្រហែលដប់ប្រាំបីទៅម្ភៃខែ ដូចវាក្យសព្ទរបស់កុមារ ផ្លាស់ទីលើសពីហាសិបពាក្យ។ នៅពេលដែលកុមារមានអាយុពីរឆ្នាំ កុមារអាចបន្សំពាក្យផ្សេងៗគ្នាបានដូចជា កៅអីទារក (baby chair) ម៉ែញ៉ាំ (mommy eat) ឆ្មាអាក្រក់ (cat bad) ។ល។ វាមានកន្សោមពាក្យច្រើនដែលជាប់ទាក់ទងនឹងបរិបទរស់នៅនិងការនិយាយស្ដីរបស់ពួកគេ។ កន្សោមពាក្យ កៅអីទារក (baby chair) អាចជំនួសឱ្យការបង្ហាញពីកម្មសិទ្ធិ (នេះជាកៅអីទារក) ឬតាមការស្នើសុំ (ដាក់ទារកចូលកៅអី) ឬជាសេចក្ដីថ្លែងការណ៍មួយ (ទារកស្ថិតនៅលើកៅអី) អាស្រ័យលើស្ថានភាពខុសៗគ្នា។

អ្វីដែលបានរៀបរាប់ខាងលើនេះ វាបង្ហាញឱ្យឃើញថា កុមារពិតជាមានបំណងប្រាស្រ័យទាក់ទងតាមរយៈការបង្ហាញបែបនេះ។ មុខងារន័យសំខាន់ទាំងនេះ គឺថាមនុស្សពេញវ័យមានអាកប្បកិរិយា ដូចជាការទំនាក់ទំនង

កំពុងកើតឡើង។ នោះគឺកុមារមិនត្រឹមតែបង្កើតការនិយាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានការគាំទ្រត្រឡប់មកវិញផងដែរ ដែលពាក្យសម្ដីនេះបានចូលរួមចំណែកក្នុងអន្តរកម្មក្នុងសង្គម។ លើសពីនេះទៅទៀតនៅពេលកុមារមានអាយុពីរឆ្នាំ កុមារអាចផលិតពាក្យចាប់ពី២០០ ឬ ៣០០ពាក្យខុសៗគ្នា។ ពួកគេនឹងអាចមានសមត្ថភាពយល់ដឹងលើសពីប្រាំដង ហើយនិងលេងកម្សាន្តជាមួយដៃគូសន្ទនាតាមការមើលថែរបស់អ្នកថែទាំកុមារ។

### ១.២.៤. ដំណាក់កាលនៃសម្ដីសារទូរលេខ

នៅចន្លោះអាយុពី ពីរ ទៅ ពីរឆ្នាំកន្លះ កុមារចាប់ផ្ដើមផលិតពាក្យសម្ដីបានចំនួនច្រើន ដែលអាចត្រូវបានចាត់ថ្នាក់ថាជាសម្ដី «ពហុពាក្យ»។ លក្ខណៈសំខាន់នៃការកាត់ខ្សែសម្ដីទាំងនេះ មានចំនួនពាក្យច្រើន ប៉ុន្តែភាពខុសគ្នានៃទម្រង់ពាក្យចាប់ផ្ដើមលេចឡើង។ មុនពេលយើងអង្កេតការអភិវឌ្ឍនេះ យើងគួរកត់សម្គាល់ក្នុងដំណាក់កាលដែលត្រូវបានពិពណ៌នាថា ជាសម្ដីសារទូរលេខ (telegraphic speech) ។ នេះត្រូវបានកំណត់ដោយខ្សែនៃពាក្យ (រូបសព្ទវចនៈ) ក្នុងឃ្លាឬល្បះដូចជា *this shoe all wet* (ស្បែកជើងនេះទាំងអស់សើម) *cat drink milk and daddy go bye-bye* (ឆ្មាផឹកទឹកដោះគោនិងឪពុកទៅលាសិនហើយ)។ កុមារបានអភិវឌ្ឍសមត្ថភាពបង្កើតល្បះមួយចំនួនយ៉ាងច្បាស់លាស់ នៅដំណាក់កាលនេះហើយ ដែលកុមារអាចទទួលបាននូវលំដាប់ពាក្យត្រឹមត្រូវ។ នៅពេលដែលទម្រង់សម្ដីសារទូរលេខប្រភេទនេះ កំពុងតែផលិតឡើង ចំនួននៃការផ្លាស់ប្ដូរទម្រង់វេយ្យាករណ៍ ចាប់ផ្ដើមលេចចេញជាទម្រង់ពាក្យខ្លះនិងធ្នាក់ធម្មតា ដូចជា *in, on* ក៏មានប្រើផងដែរ។

នៅអាយុ ពីរឆ្នាំកន្លះ វាក្យសព្ទរបស់កុមារកំពុងតែរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយនិងកុមារកំពុងចាប់ផ្ដើមនិយាយច្រើន ព្រមគ្នាជាមួយនឹងការរីកលូតលាស់សកម្មភាពរាងកាយ រួមមានការរត់និងការលោត។ នៅអាយុបីឆ្នាំ វាក្យសព្ទរបស់កុមារបានកើនឡើងដល់រាប់រយពាក្យហើយការបញ្ចេញសំឡេងកាន់តែដូចទៅនឹងទម្រង់ភាសាមនុស្សពេញវ័យ។ នៅចំណុចនេះ វាពិតជាមានតម្លៃណាស់ចំពោះការពិចារណាលើប្រភេទឥទ្ធិពលអ្វីដែលមនុស្សពេញវ័យមាននៅក្នុងការអភិវឌ្ឍពាក្យសម្ដីរបស់កុមារ។

## ១.៣. ដំណើរការនៃការចាប់យកភាសា

នៅពេលដែលភាសាកុមារកើនឡើង ជាញឹកញាប់វាត្រូវបានគេសន្មតថា នៅក្នុងន័យខ្លះកុមារត្រូវបាន «បង្រៀន» ឱ្យចេះនិយាយភាសា។ គំនិតនេះពិតជាមិនគាំទ្រទៅលើអ្វីដែលកុមារធ្វើនោះទេ។ សម្រាប់កុមារភាគច្រើន គ្មាននរណាម្នាក់ផ្ដល់ការបង្ហាត់បង្រៀនពីរបៀបនិយាយភាសាទេ។ យើងមិនគួរស្រមៃគិតថា ខួរក្បាលរបស់កុមារគឺទទេ ហើយត្រូវបានបញ្ចូលបន្ថែមជាមួយពាក្យនិងឃ្លាផ្សេងៗដែរ។ ទស្សនៈត្រឹមត្រូវជាងនេះនឹងធ្វើឱ្យកុមារមានការស្ដាប់នាយ៉ាងសកម្មពីអ្វីដែលយើងនិយាយជាមួយពួកគេព្រមទាំងវិធីប្រើប្រាស់ភាសាបាន។ ផលិតកម្មភាសារបស់កុមារលេចឡើងជាបញ្ហាច្រើននៃការបង្កើតឡើងនិងការសាកល្បងថា តើវាដំណើរការឬអត់។

ជាធម្មតាវាមិនអាចទៅរួចទេដែលថាកុមារកំពុងតែចាប់យកភាសាមូលដ្ឋានរបស់ពួកគេតាមរយៈដំណើរការនៃការត្រាប់តាមភាសារបស់មនុស្សពេញវ័យ។ ជាការពិតណាស់ កុមារតូចៗ អាចស្ដាប់ឮពាក្យថ្មីៗ ដែលមនុស្សពេញវ័យនិយាយក្នុងពេលណាមួយ ហើយពួកគេប្រាកដជាទទួលយកវាក្យសព្ទច្រើននូវសម្ដីដែលពួកគេស្ដាប់ឮ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សពេញវ័យជាធម្មតាមិនបង្កើតនូវការបញ្ចេញមតិជាច្រើនដែលនាំឱ្យមានការចាប់អារម្មណ៍ចំពោះកុមារទេ។ ចូរកត់ចំណាំនូវរបៀបដែលកុមារបង្កើតកិរិយាសព្ទថ្មីមួយទាំងស្រុង ឧទាហរណ៍ *to Woodstock* ក្នុងបរិបទមួយ។

NOAH៖ (កំពុងរើសតុក្កតាឆ្កែ) នេះគឺជា Woodstock។ (គាត់បង្ហាញប្រដាប់កុមារលេងនៅចំពោះមុខ ADAM)

ADAM៖ ហេ Woodstock, កុំធ្វើរឿងនោះ (Noah បន្ត)

ADAM៖ ខ្ញុំនឹងទៅផ្ទះ ដូច្នេះអ្នកនឹងមិន Woodstock ខ្ញុំទេ។

វាមិនទំនងជាថាមនុស្សពេញវ័យ «ការកែតម្រូវ» មានឥទ្ធិពលទៅលើរបៀបនិយាយរបស់កុមារ។ សេចក្តីបំព្រួញបទសន្ទនាលេងសើចជាច្រើន ដែលទាក់ទងនឹងមនុស្សពេញវ័យ ព្យាយាមកែតម្រូវពាក្យសម្តីរបស់កុមារ ហើយវាហាក់ដូចជាបង្ហាញពីភាពអស់សង្ឃឹមនៃកិច្ចការនេះ។ សូម្បីតែនៅពេលដែលការកែតម្រូវត្រូវបានព្យាយាមតាមរបៀបដែលមិនសមហេតុផលក៏ដោយ ក៏កុមារនឹងបន្តប្រើទម្រង់ដែលបានបង្កើតឡើងដោយខ្លួនឯង ទោះបីជាការធ្វើដដែលៗរបស់មនុស្សពេញវ័យចំពោះអ្វីដែលទម្រង់ត្រឹមត្រូវគួរតែមាន។ សូមកត់សម្គាល់ថា នៅក្នុងសន្ទនាខាងក្រោមនេះ កុមារដែលមានអាយុបួនឆ្នាំ មិនធ្វើត្រាប់តាមការនិយាយរបស់មនុស្សពេញវ័យហើយក៏មិនទទួលយកការកែតម្រូវរបស់មនុស្សពេញវ័យដែរ។

Child: My teacher **holded** the baby rabbits and we patted them.

កុមារៈ គ្រូរបស់ខ្ញុំបានកាន់កូនទន្សាយហើយយើងបានរៀបចំវា។

Mother: Did you say your teacher **held** the baby rabbits?

ម្តាយ: តើអ្នកនិយាយថាគ្រូរបស់អ្នកកាន់កូនទន្សាយទេ?

Child: Yes.

កុមារ: បាទ។

Mother: What did you say she did?

ម្តាយ: តើអ្នកនិយាយថានាងបានធ្វើអ្វី?

Child: She **holded** the baby rabbits and we patted them.

កុមារៈ នាងបានកាន់កូនទន្សាយហើយយើងរៀបចំវា។

Mother: Did you say she **held** hem tightly?

ម្តាយ: តើអ្នកបាននិយាយថានាងបានកាន់ពួកវារឹតខ្លាំងទេ?

Child: No, she **holded** them loosely.

កុមារៈ អត់ទេ នាងកាន់ពួកវាថ្នមៗទេ។

កត្តាមួយដែលហាក់ដូចជាសំខាន់ ក្នុងដំណើរការចាប់យកភាសារបស់កុមារ គឺជាការប្រើប្រាស់ជាក់ស្តែងនៃការរួមបញ្ចូលគ្នានៃសំឡេងនិងពាក្យ ទាំងនៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ ឬនៅក្នុងការលេងល្បែងពាក្យតែម្នាក់ឯង។ កុមារអាយុពីរឆ្នាំម្នាក់ដែលត្រូវបានពិពណ៌នានៅ Weir (ឆ្នាំ១៩៦៦) ត្រូវបានគេថតសំឡេងនៅពេលគាត់ដេកលើគ្រែតែម្នាក់ឯងហើយគេបានស្តាប់ឮកុមារនោះលេងសំឡេងជាពាក្យនិងឃ្លាជាច្រើន ដូចជា *I go dis way...way bay...baby do dis bib...all bib...bib...dere*។ ការលេងពាក្យប្រភេទនេះហាក់ដូចជាមូលដ្ឋានដ៏សំខាន់ក្នុងការអភិវឌ្ឍភាសារបស់កុមារ។ ព័ត៌មានលម្អិតនៃការអភិវឌ្ឍនេះហួសឆ្ងាយពីដំណាក់កាលសារទូរលេខ ដែលត្រូវបានគេតាមដានតាមរយៈលក្ខណៈភាសា ដែលចាប់ផ្តើមប្រែជាមូលដ្ឋានទៀងទាត់ ក្នុងលំហូរជាប់គ្នានៃការបញ្ចូលពាក្យសម្តីពីមណ្ឌលដដែកតូចមួយនៃខួរក្បាលរបស់កុមារ។

## ១.៤. ការអភិវឌ្ឍផ្នែករូបសព្ទវិទ្យា

នៅពេលដែលកុមារមានអាយុពីរឆ្នាំកន្លះ គាត់នឹងឆ្លងហួសពីទម្រង់សម្តីសារទូរលេខ ហើយនិងបញ្ចូលនូវការផ្លាស់ប្តូរទម្រង់រូបសព្ទ ដែលបង្ហាញពីមុខងារវេយ្យាករណ៍នៃបម្រើបម្រាស់នាមនិងកិរិយាសព្ទ។ ដំបូង វាតែងតែកើតឡើងចំពោះទម្រង់ -ing នៅក្នុងកន្សោមពាក្យ ដូចជា *cat sitting* និង *mommy reading book*។

ការអភិវឌ្ឍផ្នែករូបសព្ទបន្តបន្ទាប់ គឺជាលក្ខណៈសម្គាល់នៃពហុវចនៈទៀងទាត់ជាមួយនឹងទម្រង់ -s ដូចជានៅក្នុងពាក្យ boys និង cats។ ការចាប់យកសញ្ញាសម្គាល់ពហុវចនៈជារឿយៗត្រូវបានបន្ថែមដោយដំណើរការនៃការពង្រីកក្បួនបន្ថែម (overgeneralization)។ កុមារពង្រីកក្បួនបន្ថែមដោយការបន្ថែម -s ដើម្បីបង្កើតទម្រង់

ពហុវចនៈហើយនិងនិយាយអំពី *foots* និង *mans*។ នៅពេលដែលការបញ្ចេញសំឡេងជំនួសនៃរូបសព្ទពហុវចនៈដែលប្រើជាមួយពាក្យ *houses* (ឧទាហរណ៍ ការបញ្ចប់នៅសំឡេង [-əz]) យកមកប្រើ។ វាក៏ត្រូវបានគេផ្តល់ឱ្យនូវការអនុវត្តពង្រីកក្បួនបន្ថែមរបស់ពាក្យនិងទម្រង់ផ្សេងៗ ដូចជា *boyes* ឬ *footes* អាចត្រូវបានគេស្តាប់ឮ។ ទន្ទឹមនឹងពេលជាមួយគ្នានោះដែរ ការពង្រីកក្បួនបន្ថែមនេះកំពុងកើតឡើង ហើយកុមារខ្លះក៏ចាប់ផ្តើមប្រើពហុវចនៈប្រែប្រួល (irregular plurals) ដូចជា *men* ត្រឹមត្រូវមួយរយៈ ប៉ុន្តែបន្ទាប់មកពួកគេព្យាយាមប្រើក្បួនទូទៅលើទម្រង់ផ្សេងៗ ដើម្បីបង្កើតកន្សោមពាក្យដូចជា *some mens* និង *two feets* ឬក៏ *two feetses* ។ មិនយូរប៉ុន្មានការប្រើប្រាស់ទម្រង់កម្មសិទ្ធិ (-'s) ចាប់ផ្តើមកើតឡើងក្នុងកន្សោមពាក្យដូចជា *girl's dog* និង *Mummy's book*។

នៅពេលប្រហែលគ្នានោះដែរ ទម្រង់កិរិយាសព្ទផ្សេងគ្នា «to be» ដូចជា *are* និង *was* ចាប់ផ្តើមប្រើបាន។ ការលេចចេញនូវទម្រង់ដូចជា *was* និងនៅគ្រាដដែលនោះ *went* និង *came* អាចកត់សម្គាល់បាន។ ទាំងនេះគឺជាទម្រង់អតីតកាលប្រែប្រួលនៃកិរិយាសព្ទក្នុងភាសាអង់គ្លេស ដែលយើងមិនរំពឹងថា កុមារស្តាប់ឮមុនទម្រង់ទៀងទាត់ផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ ពួកគេធ្វើមុនការលេចចេញនៃការផ្លាស់ប្តូរទម្រង់ -ed។ នៅពេលដែលទម្រង់អតីតកាលកិរិយាសព្ទទៀងទាត់ «*walked, played*» ចាប់ផ្តើមលេចឡើងនៅក្នុងពាក្យសម្តីរបស់កុមារ នោះទម្រង់កិរិយាសព្ទប្រែប្រួលមិនអាចលេចចេញនៅពេលនេះបានទេ ជំនួសដោយការពង្រីកក្បួនបន្ថែមកំណែថ្មី ដូចជា *goed* និង *comed* ។ ក្នុងរយៈពេលមួយ ទម្រង់ផ្លាស់ប្តូរ -ed អាចបន្ថែមទៅលើទម្រង់ទាំងអស់ ដែលបង្កើតនូវភាពចម្លែកដូចជា *walkeded* និង *wented*។ ដូចគ្នានឹងទម្រង់ពហុវចនៈផ្សេងទៀត កុមារឈប់ប្រើ (ជាទូទៅ បន្ទាប់ពីអាយុបួនឆ្នាំ) ដែលទម្រង់ទាំងនេះជាទម្រង់ទៀងទាត់និងទម្រង់ប្រែប្រួល។

នៅទីបំផុតកិរិយាសព្ទទៀងទាត់ -s លេចឡើងក្នុងទម្រង់កិរិយាសព្ទបច្ចុប្បន្នកាលដែលប្រើជាមួយសព្វនាមបុរិសៈទីបីឯកវចនៈ។ វាកើតឡើងជាលើកដំបូងជាមួយនឹងកិរិយាសព្ទបង្គោល «*comes, looks*» ហើយបន្ទាប់មកជាមួយនឹងកិរិយាសព្ទជំនួយ «*does, has*» ។

តាមរយៈលំដាប់នេះមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង។ ការផ្លាស់ប្តូររបស់កុមារម្នាក់ៗបង្កើតបានជាទម្រង់ពេញលេញនៅថ្ងៃមួយនិងបង្កើតជាទម្រង់ប្លែកៗនៅថ្ងៃបន្ទាប់។ ភស្តុតាងនេះបង្ហាញថា កុមារកំពុងស្វែងរកវិធីប្រើប្រព័ន្ធភាសាដោយផ្តោតលើការប្រាស្រ័យទាក់ទងនិងអន្តរកម្មជាមួយមនុស្សផ្សេងៗជាជាងការកែតម្រូវ។ សម្រាប់កុមារ ការប្រើទម្រង់ដូចជា *goed* និង *foots* គឺជាមធ្យោបាយនៃការព្យាយាមនិយាយនូវអ្វីដែលគាត់ចង់មានន័យថា នេះជាដំណាក់កាលពិសេសនៃការអភិវឌ្ឍ។ ការបង្កើតឧបសគ្គរបស់ឪពុកម្តាយទាំងនោះដែលទទូចថាកូនមិនបានស្តាប់ឮនូវរឿងរ៉ាវផ្សេងៗនៅផ្ទះ ដោយពួកគេទទួលស្គាល់យ៉ាងច្បាស់ក្រឡែតថា «កូនខ្លួនកំពុងធ្វើត្រាប់តាមឪពុកម្តាយ តាយាយ ពូមីង ឬមនុស្សពេញវ័យដទៃទៀត»។ ពួកគេមិនមែនព្រមទទួលស្គាល់ថា វាមានកម្លាំងជំរុញបឋមក្នុងការចាប់យកភាសាទី១ឡើយ។

## ១.៥. ការអភិវឌ្ឍផ្នែកសម្ព័ន្ធវិទ្យា

ភស្តុតាងស្រដៀងគ្នានេះប្រឆាំងនឹង «ការធ្វើត្រាប់តាម» ដែលជាមូលដ្ឋាននៃការផលិតពាក្យសម្តីរបស់កុមារ ត្រូវបានរកឃើញនៅក្នុងការសិក្សាអំពីរចនាសម្ព័ន្ធឈ្លះដែលត្រូវបានប្រើដោយកុមារតូចៗ។ កុមារម្នាក់ត្រូវបានគេស្នើសុំឱ្យនិយាយម្តងទៀតនូវអ្វីដែលនាងបានឮ ហើយនិងនាងនឹងស្តាប់ពាក្យនិយាយរបស់មនុស្សពេញវ័យដូចជា *the owl who eats candy runs fast* (សត្វទីទុយដែលស៊ីស្ករគ្រាប់ រត់លឿន) ហើយបន្ទាប់មកនាងនិយាយម្តងទៀតក្នុងទម្រង់ជា *the owl who eats candy and he runs fast* (សត្វទីទុយស៊ីស្ករគ្រាប់ហើយវារត់យ៉ាងលឿន)។ វាគឺច្បាស់ណាស់ថា កុមារយល់ពីអ្វីដែលមនុស្សពេញវ័យកំពុងតែនិយាយ។ នាងគ្រាន់តែមានវិធីផ្ទាល់ខ្លួនក្នុងការបង្ហាញវា។

ចំពោះករណីនេះ មានការសិក្សាជាច្រើនអំពីការអភិវឌ្ឍផ្នែកសម្ព័ន្ធនៅក្នុងពាក្យសម្តីរបស់កុមារ។ យើងនឹងពិនិត្យមើលការអភិវឌ្ឍនៃរចនាសម្ព័ន្ធពីរដែលហាក់ដូចជាទទួលបានតាមរបៀបទៀងទាត់ ដោយកុមារដែលនិយាយភាសាអង់គ្លេសភាគច្រើន។ នៅក្នុងការបង្កើតទម្រង់សំណួរនិងការប្រើទម្រង់អវិជ្ជមាន មានដំណាក់កាលកំណត់អត្តសញ្ញាណចំនួនបី។ អាយុដែលកុមារឆ្លងកាត់ដំណាក់កាលទាំងនេះ អាចខុសគ្នាបន្តិចបន្តួច ប៉ុន្តែគំរូទូទៅមួយហាក់ដូចជាដំណាក់កាលទី១ កើតឡើងចន្លោះពីអាយុ ១៨ ទៅ ២៦ខែ ដំណាក់កាលទី២ ចន្លោះអាយុពី ២២ ទៅ ៣០ខែ និងដំណាក់កាលទី៣ ចន្លោះអាយុពី ២៤ ទៅ ៤០ខែ។ ការត្រួតស៊ីគ្នាក្នុងអំឡុងពេលដែលកុមារឆ្លងកាត់ដំណាក់កាលទាំងនេះ គឺជាឥទ្ធិពលពីធម្មជាតិនៃអត្រាខុសគ្នា ដែលកុមារផ្សេងគ្នាអភិវឌ្ឍរចនាសម្ព័ន្ធទាំងនេះនិងរចនាសម្ព័ន្ធផ្សេងទៀត។

### ១.៥.១. ការបង្កើតទម្រង់ល្បះសំណួរ

ការបង្កើតទម្រង់ល្បះសំណួរ ដំណាក់កាលដំបូងរបស់កុមារមានរបៀបពីរបែប។ ជាធម្មតា កុមារគ្រាន់តែបន្ថែមទម្រង់បែប Wh ( *Where, Who*) ទៅខាងដើមនៃកន្សោមពាក្យ ឬបញ្ចេញសំឡេងកន្សោមពាក្យនោះជាមួយនឹងការលើកដាក់សំឡេងឡើងនៅចុងល្បះ សូមមើលឧទាហរណ៍ខាងក្រោមនេះ៖

*Where kitty ? Doggie ?*

( តើកូនឆ្មានៅឯណា ? កូនឆ្កែ ? )

*Where horse go ? Sit chair ?*

( តើសេះទៅណា ? អង្គុយកៅអី ? )

នៅដំណាក់កាលទីពីរ កន្សោមពាក្យស្មុគស្មាញជាច្រើនអាចត្រូវបានបង្កើតឡើង ប៉ុន្តែរបៀបលើកដាក់សំឡេងឡើងនៅតែបន្តប្រើប្រាស់។ វាអាចកត់សម្គាល់បានថាទម្រង់ Wh ជាច្រើនត្រូវបានប្រើដូចជាក្នុងឧទាហរណ៍ខាងក្រោមនេះ៖

*What book name ?* *You want eat ?*

( តើសៀវភៅឈ្មោះអ្វី ? អ្នកចង់ញ៉ាំទេ ? )

*Why you smiling ?* *See my doggie ?*

( ហេតុអ្វីបានជាអ្នកញញឹម ? សូមមើលកូនឆ្កែរបស់ខ្ញុំ ? )

នៅដំណាក់កាលទី៣ ការផ្លាស់ប្តូរទីតាំងនៃកិរិយាសព្ទជំនួយក្នុងទម្រង់ល្បះសំណួររបស់ភាសាអង់គ្លេស «*I can have...> Can I have...?*» អាចឃើញច្បាស់នៅក្នុងពាក្យសម្តីរបស់កុមារ ប៉ុន្តែមិនរីករាលដាលដោយស្វ័យប្រវត្តិចំពោះគ្រប់ប្រភេទទម្រង់ល្បះសំណួរនោះទេ។ តាមពិតកុមារខ្លះចាប់ផ្តើមចូលរៀននៅថ្នាក់ទីប្រាំ ឬទីប្រាំមួយ ក៏ពួកគេនៅតែអាចចូលចិត្តទម្រង់ល្បះសំណួរបែប *Wh* ( ជាពិសេសជាមួយទម្រង់ល្បះសំណួរបដិសេធន៍ ) វាមិនមានប្រភេទនៃកំណែថ្មីដែលត្រូវបានរកឃើញនៅក្នុងពាក្យសម្តីរបស់មនុស្សពេញវ័យ ( ឧទាហរណ៍ *Why kitty can't ... ?* ជំនួសឱ្យទម្រង់ល្បះសំណួរជា *Why can't kitty... ? )*។ ក្រៅពីបញ្ហាទាំងនេះជាមួយទម្រង់ល្បះសំណួរបែប Wh- និងបញ្ហាដែលកំពុងបន្តជាមួយនឹងរូបសព្ទនៃកិរិយាសព្ទ ( ឧទាហរណ៍ *Did I caught ... ?* ជំនួសឱ្យ *Did I catch ... ?*) ដំណាក់កាលទី៣ ទម្រង់ល្បះសំណួរកាន់តែដូចនឹងទម្រង់ល្បះសំណួររបស់មនុស្សពេញវ័យ សូមពិនិត្យមើលឧទាហរណ៍ខាងក្រោមនេះ៖

| | |
|---|---|
| *Can I have a piece ?* | *Did I caught it ?* |
| ( តើខ្ញុំអាចមានមួយដុំបានទេ ? ) | ( តើខ្ញុំបានចាប់វាទេ ? ) |
| *Will you help me ?* | *How that opened ?* |
| ( តើអ្នកនឹងជួយខ្ញុំទេ ? ) | ( តើវាបានបើកដោយរបៀបណា ? ) |

*What did you do ?* *Why kitty can't stand up ?*

(តើអ្នកបានធ្វើអ្វី ?) (ហេតុអ្វីបានជាកូនឆ្មាមិនអាចក្រោកឈរបាន ?)

**១.៥.២. ការបង្កើតទម្រង់បដិសេធន៍**

ក្នុងករណីទម្រង់ឈ្លះបដិសេធន៍ ដំណាក់កាលទី១ ហាក់ដូចជាទាក់ទងនឹងការដាក់បញ្ចូលរបៀបធម្មតា *No* ឬ *Not* នៅខាងដើមឈ្លះ សូមមើលនៅក្នុងឧទាហរណ៍ខាងក្រោមនេះ៖

*No mitten* *not a teddy bear*

(មិនមានស្រោមដៃអត់ម្រាមទេ) (មិនមែនតុក្កតាខ្លាឃ្មុំទេ)

*no fall* *no sit there*

(មិនធ្លាក់ទេ) (មិនអង្គុយនៅទីនោះទេ)

នៅដំណាក់កាលទី២ ការបន្ថែមទម្រង់ឈ្លះបដិសេធន៍ផ្សេងៗទៀត *don't* និង can't លេចចេញឡើង ហើយនិង*no* និង *not* ត្រូវបានប្រើកាន់តែច្រើននៅពីមុខកិរិយាសព្ទជាជាងនៅខាងដើមនៃឈ្លះដូចក្នុងឧទាហរណ៍ទាំងនេះ៖

*He no bite you* *I don't want it*

(វាមិនខាំអ្នកទេ) (ខ្ញុំមិនចង់បានវាទេ)

*That not touch* *You can't dance*

(នោះមិនប៉ះទេ) (អ្នកមិនអាចរាំបានទេ)

ដំណាក់កាលទីបី យើងមើលឃើញការដាក់បញ្ចូលគ្នានៃទម្រង់កិរិយាសព្ទជំនួយផ្សេងៗទៀត ដូចជា *didn't* និង *won't* នៅពេលដែលទម្រង់ឈ្លះក្នុងដំណាក់កាលទី១បាត់បង់ទៅវិញ។ ការចាប់យកដ៏យឺតបំផុតគឺទម្រង់ឈ្លះបដិសេធន៍ *isn't* ហើយនិងលទ្ធផលដែលទម្រង់នៃដំណាក់កាលទី២ខ្លះ (ជាមួយ *not* ជំនួសដោយ *isn't*) នៅតែបន្តប្រើអស់រយៈពេលយូរទៀត ជាក់ស្តែងដូចជាក្នុងឧទាហរណ៍ខាងក្រោមនេះ៖

*I didn't caught it* *He not taking it*

(ខ្ញុំមិនបានចាប់វាទេ) (គាត់មិនបានយកវាទេ)

*She won't let go* *This not ice cream*

(នាងនឹងមិនអនុញ្ញាតឱ្យទៅទេ) (នេះមិនមែនការ៉េមទេ)

ការសិក្សាអំពីការប្រើប្រាស់ការអភិវឌ្ឍនៃទម្រង់ឈ្លះបដិសេធន៍របស់កុមារ បានបង្កើតនូវគំរូឧទាហរណ៍ខ្លះដែលគួរជាទីពេញចិត្តសម្រាប់ប្រតិបត្តិការនូវក្បួនផ្ទាល់ខ្លួនរបស់កុមារ នៅក្នុងការបង្កើតទម្រង់ឈ្លះបដិសេធន៍នេះឡើង។ ឧទាហរណ៍ដ៏អស្ចារ្យមួយ (ពី McNeill ឆ្នាំ១៩៦៦) ក៏បង្ហាញពីភាពឥតប្រយោជន៍នៃការកែតម្រូវរបស់មនុស្សពេញវ័យទៅលើពាក្យសម្ដីរបស់កុមារផងដែរ។

Child: *Nobody don't like me.*

កុមារ៖ គ្មានអ្នកណាមិនចូលចិត្តខ្ញុំទេ។

Mother: *No, say «nobody likes me.»*

ម្តាយ: ទេនិយាយថា «គ្មានអ្នកណាចូលចិត្តខ្ញុំទេ»

Child: *Nobody don't like me.*

កុមារ៖ គ្មានអ្នកណាមិនចូលចិត្តខ្ញុំទេ។ (ពាក្យដដែលៗចំនួនប្រាំបីដងនៃការសន្ទនានេះ)

Mother: *No, now listen carefully; say «nobody likes me.»*

ម្តាយ៖ ទេ! ឥឡូវនេះ ស្តាប់ដោយយកចិត្តទុកដាក់ និយាយថា «គ្មានអ្នកណាចូលចិត្តខ្ញុំទេ»។

Child: *Oh! Nobody don't likes me.*

កុមារ៖ អូ! គ្មានអ្នកណាមិនចូលចិត្តខ្ញុំទេ។

## ១.៦. ការអភិវឌ្ឍផ្នែកន័យវិទ្យា

ការនិទានរឿងពិតខ្លីៗដែលឪពុកម្ដាយរំឭកពីការនិយាយដំបូងរបស់កូនពួកគេ (ចំពោះការបង្កើតឧបសគ្គយ៉ាងខ្លាំងនៃកុមារធំពេញវ័យ) ជាធម្មតាទាក់ទងនឹងឧទាហរណ៍នៃការប្រើប្រាស់ពាក្យចម្លែក។ វាត្រូវបានគេទូន្មានថាសត្វរុយជាប្រភពនៃការនាំមេរោគចូលក្នុងផ្ទះ កុមារម្នាក់បានសួរថា តើអ្វីទៅជា «មេរោគ» ហើយចម្លើយគឺ «អ្វីមួយដែលសត្វរុយលេងជាមួយ»។ ករណីនេះមិនបានកំណត់ន័យឱ្យច្បាស់លាស់ ដែលកុមារភ្ជាប់នឹងពាក្យដែលពួកគេប្រើនោះទេ។

ការលើកឡើងនេះហាក់ដូចជានៅក្នុងដំណាក់កាលនៃសម្ដីបែបឃ្លាមានតែមួយពាក្យ ដែលកុមារជាច្រើនប្រើវាក្យសព្ទមានកំណត់របស់ពួកគេដើម្បីយោងទៅលើវត្ថុមួយចំនួនដែលមិនទាក់ទងគ្នា។ ជាដំបូងកុមារម្នាក់បានប្រើពាក្យ *bow-wow* ដើម្បីសំដៅទៅលើឆ្កែ ហើយបន្ទាប់មក ក៏សំដៅទៅលើផ្នែករោមសត្វជាមួយនឹងកែវភ្នែកសិប្បនិម្មិតដែលធ្វើពីកែវរបស់តុក្កតាឆ្កែនោះ ឡេវអាវ និងសូម្បីតែទែម៉ូម៉ែត្រងូតទឹក។ ពាក្យ *bow-wow* ហាក់ដូចជាមានន័យថាជាវត្ថុដែលមានរាងភ្លឺចាំង។ កុមារផ្សេងទៀត ជារឿយៗពង្រីកន័យនៃពាក្យ *bow-wow* ដើម្បីសំដៅទៅលើសត្វឆ្មា គោ និងសេះ។

ដំណើរការនេះត្រូវបានគេហៅថា ការពង្រីកបន្ថែមន័យ (overextension) ហើយនិងគំរូទូទៅបំផុតសម្រាប់កុមារដើម្បីពង្រីកន័យនៃពាក្យដោយផ្អែកលើមូលដ្ឋានស្រដៀងគ្នានៃរូបរាង សំឡេង និងទំហំ ហើយនិងការពង្រីកបន្ថែមន័យនេះស្ថិតក្នុងកម្រិតតិចតួច (lesser extent) បន្លាស់ប្ដូរ (movement) និងទម្រង់ផ្ទៃលើ (surface structure or texture)។ ដូច្នេះ ពាក្យ *ball* (បាល់) ត្រូវបានពង្រីកន័យដល់វត្ថុមូលគ្រប់ប្រភេទរួមទាំងអំពូលភ្លើងចង្កៀង ដៃទ្វារ (ប្រដាប់កាន់បើកបិទទ្វារ) និងព្រះចន្ទ្រ។ ពាក្យ *tick-tock* ត្រូវបានគេប្រើសម្រាប់សម្គាល់នាឡិកាមួយ ប៉ុន្តែក៏អាចប្រើសម្រាប់សម្គាល់ទំហំបន្ទប់ទឹកមួយដែលមានប្រដាប់វាស់រាងមូល។ ផ្អែកលើមូលដ្ឋានទំហំពាក្យ *fly* ត្រូវបានកុមារប្រើសម្រាប់សម្គាល់សត្វល្អិត ហើយបន្ទាប់មក ត្រូវបានពួកគេយកមកប្រើសម្រាប់សម្គាល់កម្ទេចធូលីនិងសូម្បីតែកម្ទេចនំប៉័ង។ ដាក់ស្ដែងដោយសារតែភាពស្រដៀងគ្នានៃទម្រង់ផ្ទៃលើ កុមារបានប្រើពាក្យ *sizo* ជាលើកដំបូងសម្រាប់សម្គាល់ ថា *scissors* (កន្ត្រៃ) ហើយបន្ទាប់មក បានពង្រីកន័យរបស់ពាក្យនេះទៅវត្ថុលោហៈទាំងអស់។ ការអភិវឌ្ឍផ្នែកន័យវិទ្យានៃការប្រើពាក្យរបស់កុមារ គឺជាដំណើរការនៃការពង្រីកបន្ថែមន័យពាក្យលើកដំបូង បន្ទាប់មកវាមានដំណើរការអភិវឌ្ឍបន្តិចម្ដងៗនៃពាក្យនីមួយៗនៅពេលកុមារចាប់ផ្ដើមរៀនពាក្យជាច្រើនបន្ថែមទៀត។

ទោះបីការពង្រីកបន្ថែមន័យពាក្យ ត្រូវបានគេចងក្រងជាឯកសារយ៉ាងល្អនៅក្នុងការបង្កើតពាក្យសម្ដី របស់កុមារ វាមិនមានការចាំបាច់ប្រើក្នុងការយល់ពាក្យសម្ដី (speech comprehension)នោះទេ។ កុមារអាយុពីរឆ្នាំម្នាក់ប្រើពាក្យ *apple* (ផ្លែប៉ោម) ដើម្បីសម្គាល់ទៅលើវត្ថុដែលមានរាងមូលផ្សេងៗទៀត ដូចជា a *tomato* (ប៉េងប៉ោះ) និង a *ball* (បាល់) ប៉ុន្តែវាមិនមានភាពខុសគ្នាទេក្នុងការជ្រើសរើសយក *the apple* (ផ្លែប៉ោម) នៅពេលសួរពីវត្ថុមូលមួយចំនួនរួមទាំងបាល់និងប៉េងប៉ោះនោះផងដែរ។

លក្ខណៈពិសេសគួរឱ្យចាប់អារម្មណ៍មួយនៃការអភិវឌ្ឍន័យពាក្យសព្ទរបស់កុមារ គឺវិធីជាក់លាក់មួយនៃទំនាក់ទំនងវចនសព្ទ ដែលត្រូវបានគេពិភាក្សាដោះស្រាយបញ្ហានេះ។ នៅក្នុងអនុសព្ទ (hyponymy) កុមារ តែងតែប្រើពាក្យ «កម្រិតពាក់កណ្ដាល» នៅក្នុងសំណុំអនុសព្ទ (hyponymous set) ដូចជាសត្វ -ឆ្កែ-មេឆ្កែ-ឆ្មា-ជ្រូក។ វាហាក់ដូចជាតក្កភាពជាងមុនដើម្បីរៀនពាក្យទូទៅបំផុត (សត្វ) ប៉ុន្តែភស្តុតាងទាំងអស់បង្ហាញថា កុមារប្រើពាក្យ *dog* (ឆ្កែ)លើកដំបូង ដោយការពង្រីកបន្ថែមន័យពាក្យសព្ទខិតជិតនឹងន័យនៃពាក្យ *animal* (សត្វ)។ នេះអាចត្រូវ

បានផ្សារភ្ជាប់ទៅនឹងទំនោរស្រដៀងគ្នានៃមនុស្សពេញវ័យ នៅពេលគេនិយាយជាមួយនឹងកុមារ ដើម្បីបង្ហាញពីពាក្យថា *flowers* (មិនមានន័យសំដៅលើរុក្ខជាតិទូទៅទេ ឬ វាអាចជាផ្កាឈូក ឬផ្កាកុលាបជាដើម)។

វាក៏ហាក់ដូចជាថាទំនាក់ទំនងន័យផ្ទុយ ត្រូវបានគេរកឃើញថា កុមារចាប់យកយឺតពេលបន្តិច (បន្ទាប់ពីអាយុប្រាំឆ្នាំ)។ នៅក្នុងករណីសិក្សាមួយ កុមារមត្តេយ្យខ្លះបានចង្អុលបង្ហាញដើមប៉ោមដែលមានច្រើន នៅពេលសួរថា *where tree has more apples?* (តើដើមប៉ោមកន្លែងណាដែលមានផ្លែច្រើន?) ហើយនៅពេលសួរផងថា *Which tree has less apples?* (តើដើមប៉ោមមួយណាដែលមានផ្លែតិច?)។ ពួកគេហាក់ដូចជាគិតថា ការឆ្លើយតបត្រឹមត្រូវនឹងមានទំហំធំជាងមុនដោយមិនយកចិត្តទុកដាក់លើភាពខុសគ្នារវាង *more* (ច្រើន) និង *less* (តិច)។ ភាពខុសគ្នារវាងពាក្យន័យផ្ទុយមួយចំនួនផ្សេងទៀតដូចជា *before* (មុន) */ after* (ក្រោយ) និង *buy* (ទិញ) / *sell* (លក់) ក៏ហាក់ដូចជាការចាប់យកយឺតបន្តិចដែរ។

ថ្វីបើការពិតបង្ហាញថា កុមារនៅតែចាប់យកនូវទិដ្ឋភាពជាច្រើនទៀតក្នុងការចាប់យកភាសាដំបូងរបស់ខ្លួននៅរយៈពេលប៉ុន្មានឆ្នាំក្រោយនៃកុមារភាព វាត្រូវបានគេសន្និដ្ឋានជាធម្មតាថា នៅពេលកុមារមានអាយុប្រាំឆ្នាំ កុមារបានបំពេញដំណើរការមូលដ្ឋាននៃការចាប់យកភាសាបានមួយផ្នែកធំហើយ។ បើយោងតាមអ្នកខ្លះយល់ឃើញថា កុមារគឺនៅក្នុងទីតាំងល្អដើម្បីចាប់ផ្តើមរៀនភាសាទីពីរ (ឬភាសាបរទេស)។ ទោះជាយ៉ាងនេះក្តី ក៏មនុស្សភាគច្រើនមិនចាប់ផ្តើមរៀនភាសាផ្សេងទេរហូតដល់ពេលក្រោយ។ សំណួរដែលតែងតែកើតឡើងថា ការចាប់យកភាសាទី១ គឺពិតជាមិនពិបាកស្មុគស្មាញនិងស្វ័យប្រវត្តិច្រើនបំផុត ហេតុអ្វីក៏ការរៀនភាសាទី២ ពិបាកខ្លាំងម្ល៉េះ? យើងនឹងព្យាយាមឆ្លើយសំណួរនោះនៅក្នុងផ្នែកទី២បន្តទៀត។

## ២. ការចាប់យកភាសាទី២

### ២.១. ការចាប់យកភាសាទី២តាមធម្មជាតិ

កុមារមួយចំនួនលូតលាស់ធំធាត់ឡើងនៅក្នុងមជ្ឈដ្ឋានសង្គមមួយ ដែលមានការប្រើប្រាស់ភាសាលើសពីមួយភាសា ហើយពួកគេអាចចាប់យកភាសាទី២នេះ នៅក្នុងស្ថានភាពប្រហែលគ្នាទៅនឹងភាសាទី១ដែរ។ កុមារដែលមានសំណាងទាំងនោះ គឺចាប់យកភាសាទី២ តាមភាសាធម្មជាតិរបស់ពួកគេ ដែលបង្កើតបានជាការប្រើប្រាស់ពីរភាសា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមយើងទាំងអស់ ក៏មិនបញ្ចេញឱ្យឃើញនូវភាសាទី២រហូតដល់ច្រើនដែរ ករណីដូចជា ដាវីត សេដារីស (David Sedaris) ជាដើម។ សមត្ថភាពរបស់យើងម្នាក់ៗអាចប្រើភាសាទី២ បន្ទាប់ពីយើងចូលរៀននៅសាលា ហើយភ្ជាប់ទៅនឹងសមត្ថភាពនៃភាសាទី១របស់យើង។ វាមានអ្វីដែលជាអាថ៌កំបាំងនៅក្នុងរឿងនេះ បើតាមការប្រមើលមើលទៅ វាមិនមានប្រព័ន្ធចំណេះដឹងដទៃទៀត ដែលយើងអាចរៀននៅអាយុពីរឬបីឆ្នាំ ឱ្យបានល្អប្រសើរជាងអាយុដប់បីឬសាមសិបឆ្នាំនោះដែរ។ ហេតុផលមួយចំនួន បានផ្តល់នូវយោបល់ដើម្បីបកស្រាយពីអាថ៌កំបាំងនេះ ហើយវាមានគោលការណ៍ផ្សេងៗគ្នា ដើម្បីចូលរួមដោះស្រាយចំពោះអ្នករៀនឱ្យទទួលបានប្រសិទ្ធភាពក្នុងការប្រាស្រ័យទាក់ទងក្នុងភាសាទី២ ដូចភាសាទី១របស់ពួកគេដែរ។

ការចាប់យកភាសាទី២តាមបែបធម្មជាតិ គឺផ្តោតសំខាន់ទៅលើមជ្ឈដ្ឋានដែលមនុស្សនោះរស់នៅផងដែរ ដោយសារតែពួកគេបានស្តាប់ឮនិងធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងជនជាតិដទៃ ដែលនិយាយភាសាទី២នោះក្នុងជីវភាពរស់នៅរបស់ពួកគេ។ ករណីក្មេងប្រុសអ្នកលក់វត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរណ៍នៅតំបន់អង្គរដែលមានអាយុប្រហែល១២ឬ១៣ឆ្នាំ អាចនិយាយបានច្រើនភាសា។

### ២.២. ការចាប់យកភាសាទី២តាមការរៀន

ភាពខុសប្លែកគ្នាមួយ ត្រូវបានធ្វើឡើងរវាងការរៀនក្នុងការរៀបចំភាសាបរទេសមួយ នេះមានន័យថាការរៀនភាសាមួយ ដែលមិនមានការនិយាយភាសានេះនៅក្នុងសហគមន៍នោះទេ) ហើយនិងការរៀបចំភាសាទី២នេះមានន័យថាការរៀនភាសាមួយដែលនិយាយភាសានេះនៅក្នុងសហគមន៍។ កូនសិស្សជនជាតិជប៉ុនដែលរៀន

នៅក្នុងថ្នាក់ភាសាអង់គ្លេសមួយ ដែលនៅក្នុងប្រទេសជប៉ុនរៀនភាសាអង់គ្លេសជាភាសាបរទេស ហើយសិស្សខ្លះទៀតបានរៀនថ្នាក់ភាសាអង់គ្លេសនៅសហរដ្ឋអាមេរិក ពួកគេគួរបានរៀនភាសាអង់គ្លេសជាភាសាទី២។ នៅក្នុងករណីផ្សេងទៀត ពួកគេកំពុងព្យាយាមរៀនភាសាផ្សេងៗ ដូច្នេះកន្សោមពាក្យ «ការរៀនភាសាទី២» ត្រូវបានប្រើជាទូទៅដើម្បីពិពណ៌នាអំពីស្ថានភាពទាំងពីរ។

**២.២.១. ការចាប់យកនិងការរៀន**

ភាពខុសគ្នាដែលមានន័យជាក់លាក់មួយផ្សេងទៀត ត្រូវបានធ្វើឡើងរវាងការចាប់យកភាសានិងការរៀនភាសា។ ពាក្យ «ការចាប់យក» ត្រូវបានប្រើដើម្បីសំដៅទៅលើការអភិវឌ្ឍសមត្ថភាពជាបណ្តើរ ៗ នៅក្នុងភាសាមួយដោយការប្រើវាដោយធម្មជាតិនៅក្នុងស្ថានភាពទំនាក់ទំនងជាមួយអ្នកដទៃដែលយល់ដឹងពីភាសា។ ទោះយ៉ាងណាពាក្យ «ការរៀន» អនុវត្តចំពោះដំណើរការយល់ដឹងកាន់តែច្បាស់នៃការប្រមូលចំណេះដឹងអំពីលក្ខណៈពិសេសដូចជាវាក្យសព្ទនិងវេយ្យាករណ៍នៃភាសាមួយ ជាពិសេសនៅក្នុងការរៀបចំវិទ្យាស្ថានភាសា។ ឧទាហរណ៍ ចំពោះគណិតវិទ្យា យើងត្រូវរៀន ទើបយើងចេះ ពោលគឺមិនមែនចាប់យកដូចភាសាទេ។

សកម្មភាពដែលទាក់ទងនឹងការរៀនសូត្រ ត្រូវបានគេប្រើប្រាស់ជាប្រពៃណីក្នុងការបង្រៀនភាសា នៅតាមសាលារៀន ហើយនិងមានទំនោរនៅពេលដែលទទួលបានជោគជ័យ ដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីភាសា (ដូចដែលបានបង្ហាញនៅក្នុងការសាកល្បង) ជាងភាពជាក់ស្តែងក្នុងការប្រើប្រាស់ភាសា (ដូចដែលបានបង្ហាញនៅក្នុងអន្តរកម្មសង្គម)។ សកម្មភាពដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងការចាប់យកភាសា គឺជាបទពិសោធរបស់កុមារតូចៗនិងដោយភាពស្រដៀងគ្នា អ្នកដែលចាប់យកភាសាទី២ ពីរយៈពេលដ៏យូរបានចំណាយក្នុងការធ្វើអន្តរកម្ម ការប្រើប្រាស់ភាសាជាមួយអ្នកនិយាយភាសាដើមកំណើត (native speakers of language)។ បុគ្គលទាំងឡាយណាដែលមានការប៉ះពាល់នឹងភាសាទី២ ភាគច្រើនជាប្រភេទបទពិសោធនៃការរៀនដែលមានទំនោរមិនអភិវឌ្ឍប្រភេទដូចគ្នានៃការគាំទ្រ ជាទូទៅដូចអ្នកដែលមានបទពិសោធនៃការទទួលបានប្រភេទនៃបទពិសោធច្រើនជាងនេះទេ។

**២.២.២. ឧបសគ្គនៃការចាប់យកភាសា**

សម្រាប់មនុស្សភាគច្រើន បទពិសោធជាមួយភាសាទី២ គឺខុសគ្នាជាមូលដ្ឋានពីបទពិសោធនៃភាសាទី១របស់ពួកគេហើយវាមិនអំណោយផលសម្រាប់ការចាប់យកភាសាទេ។ ជាធម្មតាពួកគេជួបប្រទះភាសាទី២ ក្នុងអំឡុងពេលវ័យជំទង់ឬយុវវ័យរបស់ពួកគេ ក្នុងរយៈពេលពីរបីម៉ោងរាល់សប្តាហ៍នៃពេលវេលាសិក្សា (ជាជាងតាមរយៈអន្តរកម្មថេរដែលមានបទពិសោធដូចជាកុមារ) ជាមួយនឹងរបស់ផ្សេងទៀតជាច្រើនកំពុងបន្ត (កុមារតូចៗមានអ្វីផ្សេងទៀតដែលត្រូវធ្វើ) និងជាមួយភាសាដែលគេស្គាល់រួចហើយ ដែលអាចរកបានសម្រាប់តម្រូវការប្រាស្រ័យទាក់ទងប្រចាំថ្ងៃរបស់ពួកគេ។ ទោះបីជាការពិតដែលថា ពេលវេលាមិនគ្រប់គ្រាន់ ការផ្តោតអារម្មណ៍និងការលើកទឹកចិត្តធ្វើឱ្យអន្តរាយដល់ការរៀនភាសាទី២ជាច្រើនក៏ដោយ ក៏មានបុគ្គលមួយចំនួនដែលហាក់ដូចជាអាចយកឈ្នះលើវប្បធម៌ផ្សេងៗគ្នានិងអភិវឌ្ឍសមត្ថភាពក្នុងការប្រើប្រាស់ភាសាទី២ ប្រកបដោយប្រសិទ្ធភាព ទោះបីជាមិនមានសំឡេងដូចអ្នកនិយាយភាសាដើមកំណើតក៏ដោយ (ឧទាហរណ៍ *someone for whom* វាជាភាសាទី១)។

ទោះជាយ៉ាងណា ស្ថានភាពគំនិតនៃការចាប់យកភាសា យុវវ័យមួយចំនួនហាក់ដូចជាតម្រង់ឆ្ពោះទៅដូចភាសាកំណើតយ៉ាងស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាទី២នេះ។ វាមានបុគ្គលមួយចំនួន ដែលអាចទទួលបាននូវជំនាញអាជីពក្នុងការសរសេរភាសា ប៉ុន្តែមិនអាចនិយាយភាសាបាន។ ឧទាហរណ៍មួយ គឺករណីលោក យ៉ូសែប ខន់រ៉ាត (Joseph Conrad) ដែលបានសរសេរប្រលោមលោកជាភាសាអង់គ្លេស ដែលបានក្លាយជាអក្សរសិល្ប៍តន្តីអង់គ្លេស ប៉ុន្តែការនិយាយភាសាអង់គ្លេសរបស់គាត់បានរក្សានូវការសង្កត់សំឡេងភាសាប៉ូឡូញខ្លាំងដែលជាភាសាទី១របស់គាត់។ នេះអាចបង្ហាញថា លក្ខណៈពិសេសខ្លះរបស់ភាសាទី២ដូចជាវាក្យសព្ទនិងវេយ្យាករណ៍ងាយស្រួល

រៀនជាងភាសាដទៃទៀត ដូចជាការបញ្ចេញសំឡេងជាដើម។ ជាការពិតណាស់ បើយើងគ្មានបទពិសោធដំបូងនៃការប្រើប្រាស់សំឡេងនិងការលើកដាក់សំឡេងនៃភាសាទី២ទេ សូម្បីតែអ្នកសិក្សាពេញវ័យដែលមានសមត្ថភាពខ្ពស់ក៏ទំនងជាត្រូវបានគេយល់ថា មានការសង្កត់សំឡេងលើប្រភេទពាក្យខ្លះផងដែរ។

ការសង្កេតប្រភេទនេះ ជួនកាលបានបង្ហាញនូវភស្តុតាងថា បន្ទាប់ពីរយៈពេលវិភាគទៅលើការចាប់យកភាសាបានកន្លងផុតទៅ វាក្លាយជាការលំបាកខ្លាំងណាស់ក្នុងការចាប់យកភាសាមួយទៀតយ៉ាងពេញលេញ ក្នុងអំឡុងពេលពេញវ័យ។ យើងប្រហែលជាគិតអំពីដំណើរការនេះទាក់ទងនឹងសមត្ថភាពផ្នែកភាសារបស់យើងដែលត្រូវបានគ្រប់គ្រងដោយលក្ខណៈពិសេសនៃភាសាទី១ ជាមួយនឹងការបាត់បង់លទ្ធផលនៃភាពបត់បែនបាន ឬក៏ភាពបើកចំហដើម្បីទទួលបានលក្ខណៈពិសេសនៃភាសាមួយផ្សេងទៀត។

ការប្រឆាំងតបនឹងទស្សនៈនេះ វាត្រូវបានបង្ហាញថាសិស្សនៅវ័យជំទង់ ពួកគេរៀនបានលឿននិងមានប្រសិទ្ធភាពច្រើនចំពោះភាសាទី២ នៅក្នុងថ្នាក់រៀនជាងកុមារអាយុប្រាំពីរឆ្នាំ។ ជាការពិត វាអាចនិយាយបានថាការរៀនសូត្រដែលមានប្រសិទ្ធិភាពនៃភាសាទី២ មួយ (ទោះបីជាមានដាននៃការសង្កត់សំឡេងក៏ដោយ) តម្រូវឱ្យមានការរួមបញ្ចូលគ្នានៃកត្តាផ្សេងៗ។ ប្រសិទ្ធិភាពខ្ពស់បំផុតសម្រាប់ការរៀនសូត្រ ប្រហែលជាអាយុចាប់ពីដប់ទៅដប់ប្រាំមួយឆ្នាំ នៅពេលដែលអាចបត់បែនបានចំពោះសមត្ថភាពផ្ទាល់ខ្លួនរបស់យើង ហើយភាសាមិនបានបាត់បង់ទាំងស្រុងនោះទេ ជាពិសេសភាពចាស់ទុំនៃជំនាញពុទ្ធិ អាចជួយឱ្យមានការវិភាគកាន់តែមានប្រសិទ្ធភាពលើលក្ខណៈទៀងទាត់នៃភាសាទី២ ដែលបានរៀន។

## ២.២.៣. កត្តាដែលមានប្រសិទ្ធភាព

ទោះបីជាក្នុងអំឡុងពេលអាយុល្អបំផុតដែលស្នើសម្រាប់ការសិក្សាភាសាទី២ អាចមានឧបសគ្គក្នុងការចាប់យកភាសាប្រភេទផ្សេងគ្នា។ មនុស្សវ័យជំទង់ច្រើនតែមានការដឹងខ្លួនច្រើនជាងកុមារ។ ប្រសិនបើ ការសិក្សាភាសាទី២ មិនមានមូលដ្ឋានធន្ទះរឹងមាំទេនោះឬសេចក្ដីខ្មាសអៀននៃការព្យាយាម បង្កើតសំឡេងខុសគ្នានៃភាសាផ្សេងទៀត វាអាចបដិសេធនូវសមត្ថភាពរាងកាយនិងការយល់ដឹងដែលមានស្រាប់។ ប្រសិនបើភាពចង្អៀតចង្អល់នេះត្រូវបានលើកតម្លៃចំពោះកង្វះខាតនៃការយល់អារម្មណ៍របស់មនុស្សជាមួយវប្បធម៌ដទៃទៀត (ឧទាហរណ៍ ការមិនមានអារម្មណ៍រកឃើញនូវភាពដូចគ្នា ជាមួយនឹងអ្នកនិយាយឬទំនៀមទម្លាប់របស់ពួកគេ) នោះលទ្ធភាពវៃឆ្លាតដែលមិនគ្រប់គ្រាន់ពិតប្រាកដ ដើម្បីបញ្ចេញសូរសំឡេងឱ្យដូច ជនជាតិរុស្ស៊ី ឬអាល្លឺម៉ង់ ឬអាមេរិក អាចរារាំងដំណើរការនៃការរៀនសូត្រ។

ប្រតិកម្មអារម្មណ៍ប្រភេទនេះឬផលប៉ះពាល់ ក៏អាចបណ្ដាលមកពីសៀវភៅសិក្សា បរិយាកាសថ្នាក់រៀនមិនល្អ ឬកាលវិភាគនៃការសិក្សានិង/ឬការងារហត់នឿយជាដើម។ អារម្មណ៍ឬបទពិសោធអវិជ្ជមានទាំងនេះ គឺជាកត្តាដែលអាចបង្កឧបសគ្គដល់ការចាប់យកភាសា។ ជាទូទៅប្រសិនបើយើងមានអារម្មណ៍តប់ប្រមល់ មានអារម្មណ៍មិនស្រួលខ្លួន ចិត្តចង្អៀតចង្អល់ ឬមិនយកចិត្តទុកដាក់ យើងទំនងជារៀនមិនបានច្រើន ឬការរៀនភាសាទី២របស់យើងគ្មានប្រសិទ្ធភាពទេ។

កុមារហាក់ដូចជាមិនសូវមានការដាក់កំហិតដោយកត្តាប៉ះពាល់ផ្សេងៗនោះទេ។ ការពិពណ៌នាអំពីការចាប់យកភាសាទី២ ក្នុងវ័យកុមារភាព គឺមានករណីជាច្រើនដែលកុមារតូចៗជម្នះការហាមឃាត់របស់ពួកគេយ៉ាងឆាប់រហ័សនៅពេលពួកគេព្យាយាមប្រើពាក្យនិងឃ្លាថ្មីៗ។ ពេលខ្លះមនុស្សពេញវ័យ ក៏អាចយកឈ្នះលើការហាមឃាត់ចិត្តរបស់ពួកគេផងដែរ។ នៅក្នុងការសិក្សាគួរឱ្យចាប់អារម្មណ៍មួយ ក្រុមអ្នកសិក្សាភាសាទី២ នៃមនុស្សពេញវ័យមួយក្រុម បានស្ម័គ្រចិត្តដើម្បីធ្វើឱ្យកម្រិតពុញទ្រាន់របស់ពួកគេបានថយចុះដោយកម្រិតជាតិអាល់កុលរបស់ពួកគេកើនឡើងបន្តិចម្ដងៗ (ការសាកល្បងនេះគឺឱ្យក្រុមអ្នកសិក្សាផឹកស្រាដើម្បីបំបាត់ភាពភ័យខ្លាច)។ មកដល់ចំណុចជាក់លាក់មួយ ការបញ្ចេញសំឡេងភាសាទី២ មានការប្រសើរឡើង ប៉ុន្តែបន្ទាប់ពីចំនួននៃអ្នកផឹកស្រាខ្លះ ដូចដែល

យើងរំពឹងទុកការបញ្ចេញសំឡេងកាន់តែយ៉ាប់យ៉ឺនជាងមុនទៅទៀត។ វគ្គសិក្សាភាសាបារាំងត្រូវបានគេណែនាំឱ្យផឹកស្រាកូញាក់ (cognac) រីឯភាសារុស្ស៊ីវិញ គឺផឹកស្រាវ៉ូដកា (vodka) អាចផ្តល់នូវដំណោះស្រាយមួយផ្នែក ប៉ុន្តែការហាមឃាត់ទំនងជាវិលត្រឡប់មកវិញដោយភាពឥតស្រើង។

## ២.៣. ការផ្តោតលើវិធីសាស្ត្រ

ទោះបីជាវាមានឧបសគ្គទាំងអស់នេះក៏ដោយ ក៏តម្រូវការសម្រាប់ការបង្ហាត់បង្រៀននៃភាសាដទៃទៀតបាននាំទៅរកគោលវិធីនិងវិធីសាស្ត្រនៃការអប់រំផ្សេងៗគ្នាក្នុងគោលបំណងជំរុញការរៀនសូត្រភាសាទី២ ឱ្យកាន់តែរីកចម្រើនឡើង។ នៅអំឡុងឆ្នាំ១៤៨៣ លោក វិលីយាម ខាសថុន (William Caxton) បានប្រើម៉ាស៊ីនបោះពុម្ពដែលបានបង្កើតថ្មីមួយរបស់គាត់ដើម្បីផលិតសៀវភៅមួយក្បាល «*Right good lernyng for to lerne shortly frenssh and englyssh*»។ គាត់មិនមែនជាអ្នកទី១ ដើម្បីចងក្រងសៀវភៅលំហាត់សម្រាប់អ្នកសិក្សាភាសាទី២ នោះទេ ហើយនិងទម្រង់ឃ្លាល្បះនៃសៀវភៅរបស់គាត់មានពាក្យស្វាគមន៍បែបប្រពៃណីបុរាណ (*Syre, god you kepe. I haue not seen you in longe tyme*) មានភាពខុសគ្នាពីភាសាអង់គ្លេសទំនើបជាច្រើន។ គោលវិធីសាស្ត្រថ្មីៗរៀបចំឡើងដើម្បីលើកកម្ពស់ការរៀនសូត្រភាសាទី២ ដែលមានទំនោរទៅលើទស្សនៈទ្រឹស្តីផ្សេងៗគ្នាអំពីរបៀបរៀនភាសាទី២ ឱ្យបានល្អបំផុត។

### ២.៣.១. វិធីសាស្ត្របកប្រែវេយ្យាករណ៍

វិធីសាស្ត្របែបប្រពៃណីបំផុត គឺត្រូវធ្វើឱ្យមានការពេញចិត្តចំពោះការរៀនភាសាទី២ តាមរបៀបដូចគ្នានឹងមុខវិជ្ជាសិក្សាផ្សេងទៀតដែរ។ បញ្ជីវាក្យសព្ទនិងការបង្កើតក្បួនវេយ្យាករណ៍ត្រូវបានប្រើដើម្បីកំណត់គោលដៅនៃការរៀនសូត្រ ការទន្ទេញចាំមាត់ត្រូវលើកទឹកចិត្ត ហើយភាសាសរសេរវិញត្រូវសង្កត់ធ្ងន់ជាងភាសានិយាយ។ វិធីសាស្ត្រនេះមានឫសគល់ក្នុងការបង្រៀនបែបប្រពៃណីសម្រាប់ភាសាឡាតាំង ហើយនិងត្រូវបានគេពិពណ៌នាជាវិធីសាស្ត្របកប្រែវេយ្យាករណ៍។ ស្លាកនេះពិតជាត្រូវបានអនុវត្តចំពោះគោលវិធីសាស្ត្រដោយអ្នករិះគន់មិនត្រឹមត្រូវដើម្បីឱ្យវិធីសាស្ត្រនេះអន់ថយ ដែលបានចង្អុលបង្ហាញថា ការសង្កត់ធ្ងន់លើការរៀនភាសាទី២ ជារឿយៗធ្វើឱ្យសិស្សមិនចេះពីរបៀបដែលភាសានេះអាចត្រូវបានប្រើក្នុងការសន្ទនាប្រចាំថ្ងៃ។ ទោះបីជាវិធីសាស្ត្រនេះបង្កើតឡើងយ៉ាងច្បាស់លាស់សម្រាប់អ្នកប្រើប្រាស់ភាសាទី២ ដែលទទួលបានជោគជ័យអស់ជាច្រើនសតវត្សក៏ដោយ ក៏ពេលខ្លះវាត្រូវបានគេអះអាងថា សិស្សអាចចាកចេញពីសាលា ដោយទទួលបានចំណាត់ថ្នាក់ខ្ពស់នៅក្នុងថ្នាក់ភាសាបារាំងតាមរយៈវិធីសាស្ត្រនេះដដែល ប៉ុន្តែវាមិនទាន់រកឃើញការបាត់បង់វិធីសាស្ត្រនេះនៅឡើយទេ នៅពេលដែលវាត្រូវបានគេធ្វើសម្មតិកម្មដោយការប្រើវិធីសាស្ត្រនេះដាក់ស្តែងនៅប្រទេសបារាំងសម្រាប់បង្រៀនភាសាបារាំង។

### ២.៣.២. វិធីសាស្ត្រស្តាប់និយាយ (សោតជីវ្ហា)

គោលវិធីសាស្ត្រមួយដែលមានលក្ខណៈខុសគ្នាខ្លាំងដោយសង្កត់ធ្ងន់លើភាសានិយាយ ហើយវាបានក្លាយជាការពេញនិយមនៅពាក់កណ្តាលសតវត្សរ៍ទី២០។ វាពាក់ព័ន្ធនឹងការធ្វើបទបង្ហាញជាប្រព័ន្ធនៃរចនាសម្ព័ន្ធភាសាទី២ ដោយផ្លាស់ប្តូរពីភាពសាមញ្ញទៅភាពស្មុគស្មាញជាងនេះក្នុងទម្រង់ជាការហ្វឹកហាត់ច្រើន ដែលសិស្សត្រូវធ្វើម្តងហើយម្តងទៀត។ គោលវិធីសាស្ត្រនេះដែលគេហៅថា វិធីសាស្ត្រស្តាប់និយាយភាសា គឺត្រូវបានបង្កើតឡើងដោយជំនឿថា ការប្រើប្រាស់ភាសា គឺជាការបង្កើតទម្លាប់មួយដែលអាចត្រូវបានអភិវឌ្ឍផ្នែកភាសានេះដោយអនុវត្តន៍ច្រើន។ ការអនុវត្តនេះ ភាគច្រើនពាក់ព័ន្ធនឹងការចំណាយច្រើនម៉ោង នៅក្នុងបន្ទប់ពិសោធន៍ភាសាម្តងហើយម្តងទៀតដើម្បីហ្វឹកហាត់និយាយភាសា។ កំណែថ្មីនៃវិធីសាស្ត្រនេះ នៅតែបន្តប្រើនៅក្នុងការបង្រៀនភាសានៅឡើយ ប៉ុន្តែការរិះគន់លើវិធីសាស្ត្រនេះ ត្រូវបានគេចង្អុលបង្ហាញថា ការអនុវត្តដាច់ដោយឡែកក្នុងការគាំទ្រគំរូហ្វឹកហាត់ភាសា ដែលមិនមានចំណុចដូចគ្នាទៅនឹងអន្តរកម្មនៃការប្រើប្រាស់ភាសានិយាយទៅតាមធម្មជាតិពិតនៃភាសានោះទេ។ លើសពីនេះទៅទៀតវាអាចគួរឱ្យធុញទ្រាន់យ៉ាងខ្លាំងទៅវិញ។

### ២.៣.៣. វិធីសាស្ត្រទំនាក់ទំនង

ការពិនិត្យឡើងវិញថ្មីៗនៃបទពិសោធដែលទាក់ទងនឹងការរៀនភាសាទី២ អាចត្រូវបានពិពណ៌នាថា ជាវិធីសាស្ត្រទំនាក់ទំនង។ ពួកគេមានប្រតិកម្មមួយផ្នែកប្រឆាំងនឹងសិល្បៈនៃការអនុវត្តគំរូនេះហើយក៏ប្រឆាំងនឹងជំនឿថាការរៀនក្បួនវេយ្យាករណ៍នៃភាសាមួយដែលចាំបាច់ នឹងបណ្តាលឱ្យមានសមត្ថភាពប្រើប្រាស់ភាសា។ ទោះបីជាវាមានកំណែថ្មីខុសគ្នាជាច្រើននៃវិធីបង្កើតបទពិសោធទំនាក់ទំនង សម្រាប់អ្នកសិក្សាភាសាទី២ក៏ដោយ ក៏ពួកគេពឹងផ្អែកលើជំនឿថា មុខងារភាសា (អ្វីដែលវាត្រូវបានប្រើប្រាស់សម្រាប់អ្វីមួយនោះ) គួរតែត្រូវបានសង្កត់ធ្ងន់ជាងទម្រង់នៃភាសា (រចនាសម្ព័ន្ធវេយ្យាករណ៍ត្រឹមត្រូវឬប្រព័ន្ធសូរត្រឹមត្រូវ)។ មេរៀនដែលបង្រៀនក្នុងថ្នាក់ ទំនងជាត្រូវបានរៀបចំឡើងជុំវិញបញ្ញត្តិដូចជា «ការសួររកអ្វីៗ» នៅក្នុងស្ថានភាពសង្គមខុសៗគ្នា ជាជាង «ទម្រង់នៃអតីតកាលរបស់កិរិយាសព្ទ» នៅក្នុងល្បះផ្សេងៗគ្នា។ ការផ្លាស់ប្តូរទាំងនេះស្របពេលជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីផ្តល់សម្ភារៈសមស្របបន្ថែមទៀតសម្រាប់ការសិក្សាភាសាទី២ ដែលមានគោលបំណងជាក់លាក់ដូចជា «ភាសាអង់គ្លេសសម្រាប់បុគ្គលិកពេទ្យ» ឬ «ភាសាជប៉ុនសម្រាប់អ្នកជំនួញ»។

## ២.៤. ការផ្តោតលើអ្នករៀន

ការផ្លាស់ប្តូរជាមូលដ្ឋានបំផុត ក្នុងវិស័យនៃការរៀនសូត្រភាសាទី២ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានផ្លាស់ប្តូរពីការព្រួយបារម្ភជាមួយគ្រូ សៀវភៅសិក្សា និងវិធីសាស្ត្រដើម្បីផ្តល់ចំណាប់អារម្មណ៍ទៅលើអ្នកសិក្សា និងដំណើរការចាប់យកភាសា។ ឧទាហរណ៍ លក្ខណៈដែលគាំទ្រលើកំណែទម្រង់មួយនៃវិធីសាស្ត្រទំនាក់ទំនងភាគច្រើន គឺការអត់ឱនចំពោះកំហុស ដែលបង្កើតឡើងដោយនិស្សិតម្នាក់ៗ។ ជាប្រពៃណី «កំហុស» ត្រូវបានគេចាត់ទុកថា វាជាអវិជ្ជមានហើយត្រូវជៀសវាងឬលុបបំបាត់ចោល។ ការទទួលយកកំហុសថ្មីៗបន្ថែមទៀតក្នុងបម្រើបម្រាស់ភាសាទី២ របស់អ្នកសិក្សា គឺផ្អែកលើការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងទស្សនៈបែបប្រពៃណីពីរបៀបនៃការរៀនភាសាទី២ ដែលកើតមានឡើង។

ការពិចារណាទៅលើអ្នកនិយាយភាសាអេស្ប៉ាញ (ភាសាទី១) ដូចជា *in the room there are three womens* (នៅក្នុងបន្ទប់មានស្ត្រីបីនាក់) ជាការបរាជ័យក្នុងការរៀនភាសាអង់គ្លេសត្រឹមត្រូវ (ដែលអាចត្រូវបានកែតាមរយៈការអនុវត្តបន្ថែមនៃទម្រង់ត្រឹមត្រូវ) យើងអាចមើលសម្តីនេះ ដែលជាការបង្ហាញពីដំណើរការនៃការចាប់យកភាសាទី២ តាមធម្មជាតិនៃសកម្មភាពប្រើប្រាស់ភាសា។ កំហុសមិនមែនជាអ្វីដែលរារាំងដល់ការរីកចម្រើនរបស់សិស្សនោះទេ ប៉ុន្តែប្រហែលវាជាតម្រុយមួយដល់វឌ្ឍនភាពនៃសកម្មភាពរៀនសូត្រ ដែលត្រូវបានធ្វើឡើងដោយសិស្សនៅពេលគាត់ព្យាយាមរកមធ្យោបាយទំនាក់ទំនងក្នុងភាសាថ្មី។ ដូចគ្នានឹងកុមារដែលចាប់យកភាសាទី១ បង្កើតប្រភេទទម្រង់ខុសពីធម្មតានៅពេលខ្លះ ដូច្នេះយើងរំពឹងថាអ្នកសិក្សាភាសាទី២ អាចបង្កើតទម្រង់ស្រដៀងគ្នានៅដំណាក់កាលជាក់លាក់ណាមួយ។ ឧទាហរណ៍ ដូចជាពាក្យ «*womens*» អាចត្រូវបានគេមើលឃើញថា វាជាប្រភេទនៃទូទៅនីយកម្មបន្ថែម (នៃ -s ជាសញ្ញាសម្គាល់ពហុវចនៈ) ដែលត្រូវបានប្រើដោយអ្នកសិក្សាស្របតាមវិធីទូទៅបំផុតក្នុងការបង្កើតទម្រង់ពហុវចនៈនៃភាសាអង់គ្លេស។

### ២.៤.១. ការផ្ទេរ

ជាការពិតកំហុសមួយចំនួនអាចបណ្តាលមកពីការផ្ទេរ ដែលត្រូវបានគេហៅផងដែរថា ឥទ្ធិពលឆ្លងភាសា។ ការផ្ទេរមានន័យថា ការប្រើសំឡេង សំនួនពាក្យ ឬរចនាសម្ព័ន្ធពីភាសាទី១ នៅពេលដែលអនុវត្តនៅក្នុងភាសាទី២។ ឧទាហរណ៍ អ្នកនិយាយភាសាអេស្ប៉ាញ (ភាសាទី១) ដែលនិយាយថា «*take it from the side inferior*» ប្រហែលជាព្យាយាមប្រើគុណនាមអេស្ប៉ាញ «*inferior*» (ដែលមានន័យនៅភាសាអង់គ្លេសថា *lower*) ហើយដាក់វានៅក្រោយនាម ដូចជាប្រភេទនៃសំណង់ល្បះរបស់ភាសាអេស្ប៉ាញ។ ប្រសិនបើភាសាទី១ និងភាសាទី២ មានលក្ខណៈស្រដៀងគ្នា (ឧទាហរណ៍ ការបង្កើតពហុវចនៈនៅខាងចុងនៃនាម) នោះអ្នកសិក្សាអាចទទួលបាន

អត្ថប្រយោជន៍ពីការផ្ទេរវិជ្ជមាននៃចំណេះដឹងភាសាទី១ ទៅភាសាទី២។ ម្យ៉ាងទៀតលក្ខណៈនៃការផ្ទេរភាសាទី១ ដែលពិតជាខុសគ្នាពីភាសាទី២ (ឧទាហរណ៍ ការដាក់គុណនាមបន្ទាប់ពីនាម) នាំឱ្យមានការផ្ទេរអវិជ្ជមាន ហើយវាអាចធ្វើឱ្យការបញ្ចេញមតិ ភាសាទី២ មានភាពលំបាកក្នុងការយល់។ យើងគួរចងចាំថា ការផ្ទេរអវិជ្ជមាន (ពេលខ្លះហៅថា អន្តរាគមន៍) គឺជារឿងធម្មតានៅក្នុងដំណាក់កាលដំបូងនៃការរៀនសូត្រភាសាទី២ ហើយជារឿយៗមានការថយចុះនៅពេលដែលអ្នកសិក្សាមានការយល់ដឹងពីភាសាទី២។

### ២.៤.២. អន្តរភាសា

តាមការត្រួតពិនិត្យជាក់លាក់មួយ ការបង្កើតភាសាដោយអ្នកសិក្សាភាសាទី២ មានកំហុសធំមួយចំនួនដែលហាក់ដូចជាមិនមានទំនាក់ទំនងជាមួយទម្រង់ផ្សេងៗនៃភាសាទី១ឬភាសាទី២។ ឧទាហរណ៍ អ្នកនិយាយភាសាអេស្ប៉ាញជាភាសាទី១ ដែលនិយាយភាសាអង់គ្លេសថា «*She name is Maria*» គឺកំពុងបង្កើតទម្រង់មួយដែលមិនមានប្រើដោយអ្នកនិយាយភាសាអង់គ្លេសដែលជាមនុស្សពេញវ័យ ហើយនិងមិនមានកើតឡើងចំពោះកុមារដែលចាប់យកភាសាអង់គ្លេសដែលជាភាសាទី១ និងមិនមែនជាមូលដ្ឋានរចនាសម្ព័ន្ធនៃភាសាអេស្ប៉ាញទេ។ កស្តុតាងប្រភេទនេះបង្ហាញឱ្យឃើញថា វាមានប្រព័ន្ធនៅចន្លោះគ្នាដែលប្រើនៅក្នុងដំណើរការនៃការចាប់យកភាសាទី២ ហើយមានទិដ្ឋភាពច្បាស់លាស់នៃភាសាទី១ និងភាសាទី២ ប៉ុន្តែវាមានប្រព័ន្ធខាងក្នុងផ្សេងៗគ្នាទៅតាមក្បួនរបស់វាផ្ទាល់។ ប្រព័ន្ធនេះត្រូវបានគេហៅថា អន្តរភាសា ហើយវាត្រូវបានគេពិចារណាថា ជាមូលដ្ឋាននៃការបង្កើតភាសាទី២ទាំងអស់។

ប្រសិនបើអ្នកសិក្សាខ្លះអភិវឌ្ឍការកំណត់លំដាប់នៃកន្សោមពាក្យរបស់ភាសាទី២ត្រឹមត្រូវ និងមានទម្រង់ជាច្រើនដែលមិនភ្ជាប់ទៅនឹងភាសាគោលដៅ ហើយវាហាក់ដូចជាមិនមានដំណើរទៅមុខទៀត។ អន្តរភាសារបស់ពួកគេត្រូវបានគេនិយាយថា វាក្លាយជាហួសសម័យទៅហើយ។ ដំណើរការហួសសម័យកម្ម (fossilization) នៅក្នុងការបញ្ចេញសំឡេងភាសាទី២ ហាក់ដូចជាមូលដ្ឋានទំនងបំផុតនៃអ្វីដែលត្រូវបានគេយល់ឃើញថា ជាការសង្កត់សំឡេងភាសាបរទេស។ ទោះយ៉ាងណាអន្តរភាសាមិនត្រូវបានរៀបចំឡើងដោយហួសសម័យនោះទេ។ អន្តរភាសានេះ នឹងអភិវឌ្ឍតាមបែបធម្មជាតិនៃភាសា ហើយក្លាយជាអត្ថន័យដ៏មានប្រសិទ្ធភាពនៃការទំនាក់ទំនងភាសាទី២ ដែលផ្តល់ឱ្យនូវលក្ខខណ្ឌសមស្របផ្សេងៗ។ ការរកឃើញនូវអ្វីដែលរាប់ថា ជាលក្ខខណ្ឌសមស្របសម្រាប់ការរៀនភាសាទី២ ឱ្យទទួលបានជោគជ័យគឺជាការបន្តស្រាវជ្រាវតំបន់ណាមួយ។

### ២.៤.៣. ការលើកទឹកចិត្ត

វាមានកត្តាជាច្រើនដែលផ្សំគ្នានៅក្នុងលទ្ធផលជោគជ័យនៃអ្នកសិក្សាភាសាទី២។ ជាក់ស្តែងការលើកទឹកចិត្តក្នុងការរៀនសូត្រមានសារៈសំខាន់ណាស់។ អ្នកសិក្សាជាច្រើនត្រូវមានឧបករណ៍សម្រាប់ជំរុញការលើកទឹកចិត្ត។ ពួកគេចង់រៀនភាសាទី២ ដើម្បីទទួលបានគោលដៅផ្សេងទៀត ដូចជាការបំពេញសេចក្តីត្រូវការបញ្ចប់ការសិក្សានៅសាលារៀន ឬអាចអានសៀវភៅវិទ្យាសាស្ត្រផ្សេងៗ ប៉ុន្តែមិនមែនសម្រាប់គោលបំណងសង្គមណាមួយឡើយ។ ផ្ទុយទៅវិញអ្នកសិក្សាទាំងនោះដែលមានកម្លាំងចិត្តចង់រៀនភាសាទី២ សម្រាប់គោលបំណងសង្គម ដើម្បីចូលរួមក្នុងជីវិតសង្គមរបស់សហគមន៍ដែលប្រើប្រាស់ភាសានោះ ហើយក្លាយជាសមាជិកដែលទទួលយកបាននៃសហគមន៍នោះ។

ចំណុចទាំងនេះ ក៏គួរឱ្យកត់សម្គាល់ផងដែរថា អ្នកដែលមានបទពិសោធជោគជ័យខ្លះ ក្នុងការទាក់ទងនឹងភាសាទី២ គឺជាចំណោមមនុស្សដែលមានកម្លាំងចិត្តរៀនសូត្រច្រើនបំផុត។ ដូច្នេះការលើកទឹកចិត្តអាចជាលទ្ធផលនៃភាពជោគជ័យដែលជាមូលហេតុមួយផងដែរ។ ស្ថានភាពរៀនភាសាមួយដែលផ្តល់ការគាំទ្រនិងលើកទឹកចិត្តដល់សិស្សឱ្យព្យាយាមប្រើជំនាញភាសាទី២ ទោះបីពួកគេចេះបន្តិចបន្តួចក៏ដោយ ក៏ពួកគេអាចប្រើវាដោយជោគជ័យដើម្បីប្រាស្រ័យទាក់ទងគ្នា ហើយនិងត្រូវតែមានជំនួយច្រើនជាងមួយដែលពឹងផ្អែកលើកំហុសផ្សេងៗ ការកែតម្រូវ

និងកង្វះខាតមានភាពត្រឹមត្រូវឥតខ្ចោះ។ ជាការពិតអ្នកសិក្សាដែលមានឆន្ទៈដើម្បីព្យាករណ៍ពីការបង្កើតកំហុស ដោយយថាហេតុនិងការព្យាយាមប្រាស្រ័យទាក់ទងក្នុងភាសាទី២ នឹងមានទំនោរទៅរកឱកាស ដើម្បីទទួលបានជោគជ័យច្រើន។ ផ្នែកសំខាន់មួយនៃឱកាសនោះ គឺសមត្ថភាពនៃធាតុចូល។

## ២.៤.៤. ធាតុចូលនិងធាតុចេញ

ពាក្យ «ធាតុចូល» ត្រូវបានប្រើប្រាស់នៅក្នុងការចាប់យកភាសាទី១ ដើម្បីពិពណ៌នាភាសាដែលអ្នកសិក្សាត្រូវបានលាតត្រដាងបង្ហាញឱ្យឃើញឡើង។ ដើម្បីជាប្រយោជន៍ដល់ការរៀនសូត្រភាសាទី២ ដែលធាតុចូលនោះត្រូវតែអាចយល់បាន ពីព្រោះយើងមិនអាចដំណើរការអ្វីដែលយើងមិនយល់ទេ។ ធាតុចូលអាចត្រូវធ្វើឱ្យយល់បានដោយសារភាពសាមញ្ញនៅក្នុងរចនាសម្ព័ន្ធនិងវាក្យសព្ទ ដូចជានៅក្នុងភាពខុសគ្នានៃការនិយាយ ដែលគេហៅថាសម្ដីជនបរទេស (foreigner talk)។ អ្នកនិយាយភាសាអង់គ្លេសដើមកំណើតអាចព្យាយាមសួរនិស្សិតបរទេសថា *how are you getting on in your studies?* ប៉ុន្តែបើមិនយល់ទេ អាចប្ដូរទៅជា *English class, you like it?* សម្ដីជនបរទេសប្រភេទនេះ អាចមានអត្ថប្រយោជន៍ មិនត្រឹមតែសម្រាប់ភាពជោគជ័យក្នុងការទាក់ទងភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់ជូនអ្នកសិក្សាដំបូងនូវឧទាហរណ៍ច្បាស់លាស់ ហើយនិងអាចយល់បាននូវទម្រង់មូលដ្ឋាននៃភាសាទី២ ដែលជាធាតុចូល។

ទោះយ៉ាងណាការអភិវឌ្ឍអន្តរភាសារបស់អ្នកសិក្សា មានភាពត្រឹមត្រូវសម្រាប់អន្តរកម្មបន្ថែម ហើយនិងប្រភេទនៃធាតុចូលចរចា (negotiated input) ដែលកើតឡើងនៅក្នុងការសន្ទនា។ ធាតុចូលចរចា គឺជាធាតុចាំបាច់នៃភាសាទី២ ដែលអ្នកសិក្សាអាចទទួលបានអន្តរកម្ម តាមរយៈការស្វែងរកសម្រាប់ការបញ្ជាក់ឱ្យ ច្បាស់លាស់នៅពេលដែលការយកចិត្តទុកដាក់សកម្មកំពុងផ្តោតលើអ្វីដែលបាននិយាយនោះ។ នៅក្នុងអន្តរកម្មខាងក្រោម ពីកា (Pica) ឆ្នាំ១៩៩១ សូមកត់សម្គាល់ពីរបៀបដែលអ្នកសិក្សាម្នាក់ មិនមែនជាអ្នកនិយាយភាសាអង់គ្លេសដើមកំណើតនិងអ្នកនិយាយភាសាអង់គ្លេសដើមកំណើតចរចាជាមួយគ្នា។ ធាតុចូលដែលអាចយល់បាន ឧទាហរណ៍ការប្រើប្រាស់ពាក្យ *triangle* (ត្រីកោណ) ដើម្បីពិពណ៌នាអំពីរូបរាងមួយ ត្រូវបានផ្ដល់ជូននៅចំណុចមួយដែលអ្នកសិក្សាត្រូវការវា ហើយនិងយកចិត្តទុកដាក់លើអត្ថន័យនៅក្នុងបរិបទ។

NS[5]: *like part of a triangle?* (ដូចជាផ្នែកនៃត្រីកោណទេ?)

NNS[6]: *what is triangle?* (តើត្រីកោណគឺជាអ្វី?)

NS: *a triangle is a shape um it has three sides* (ត្រីកោណគឺជារាង អ៊ុម វាមានបីជ្រុង)

NNS: *a peak?* (ចំណុចកំពូល?)

NS: *three straight sides* (បីជ្រុងជាប់គ្នា)

NNS: *a peak?* (ចំណុចកំពូល?)

NS: *yes it does look like a mountain peak, yes* (មែន វាមើលទៅដូចជាកំពូលភ្នំមែន បាទ)

NNS: *only line only line?* (ខ្សែតែមួយប៉ុណ្ណោះ?)

NS: *okay two of them, right? one on each side? a line on each side?*
(មិនអីទេ ចំនួនពីរខ្សែក្នុងចំណោមពួកវា មែនទេ? មួយចំហៀង? ខ្សែនៅសងខាង?

NNS: *yes* (បាទ)

NS: *little lines on each side?* (បន្ទាត់តូចនៅសងខាង?)

---

5 NS (native speaker) មានន័យថាអ្នកនិយាយភាសាដើមកំណើត។

6 NNS (non-native speaker) មានន័យថាមិនមែនជាអ្នកនិយាយភាសាដើមកំណើត។

NNS: *yes* (បាទ)

NS: *like a mountain?* (ដូចជាភ្នំមែនទេ?)

NNS: *yes* (បាទ)

នៅក្នុងប្រភេទនៃអន្តរកម្មនេះ អ្នកសិក្សាមានបទពិសោធដោយទទួលបានអត្ថប្រយោជន៍ទាំងធាតុចូល (ការស្តាប់សំឡេងភាសាទី២) និងការបង្កើតធាតុចេញ (ការនិយាយភាសាទី២)។ អ្នកសិក្សាមានឱកាសដើម្បីបង្កើតធាតុចេញ ដែលអាចយល់បាននៅក្នុងអន្តរកម្មប្រកបដោយអត្ថន័យ ហើយវាហាក់ដូចជាធាតុសំខាន់មួយទៀតក្នុងការអភិវឌ្ឍសមត្ថភាពរបស់អ្នកប្រើប្រាស់ភាសាទី២ ប៉ុន្តែវាគឺជាផ្នែកមួយនៃភាពលំបាកបំផុតក្នុងការផ្តល់នូវថ្នាក់ភាសាទី២ ដែលមានអ្នកសិក្សាច្រើននាក់ឬថ្នាក់ធំ។ ដំណោះស្រាយមួយគឺបង្កើតភារកិច្ចនិងសកម្មភាពផ្សេងៗគ្នាដែលអ្នកសិក្សាត្រូវប្រាស្រ័យទាក់ទងគ្នា ជាធម្មតាក្នុងក្រុមតូចៗឬដៃគូសន្ទនាឬពិភាក្សា ដើម្បីផ្លាស់ប្តូរព័ត៌មានឬដោះស្រាយបញ្ហា។ ទោះបីជាមានភាពភ័យខ្លាចថា អ្នកសិក្សានឹងរៀនពីកំហុសរបស់គ្នាទៅវិញទៅមកក៏ដោយ ក៏លទ្ធផលនៃការរៀនសូត្រផ្អែកលើកមូលដ្ឋានកិច្ចការ ដែលផ្តល់នូវភស្តុតាងយ៉ាងច្រើន ហើយនិងការប្រើប្រាស់ភាសាទី២ ឱ្យកាន់តែប្រសើរជាងមុនតាមរយៈអ្នកសិក្សាម្នាក់ៗ។ គោលដៅសកម្មភាពបែបនេះមិនមែនថាអ្នកសិក្សានឹងស្គាល់កាន់តែច្បាស់អំពីភាសាទី២នោះទេ ប៉ុន្តែពួកគេនឹងអភិវឌ្ឍសមត្ថភាពទំនាក់ទំនងនៅក្នុងភាសាទី២។

## ២.៥. សមត្ថភាពបណ្តូរទំនាក់ទំនងនៃភាសា

សមត្ថភាពបណ្តូរទំនាក់ទំនង អាចត្រូវបានគេចាត់ទុកថា ជាសមត្ថភាពទូទៅក្នុងការប្រើប្រាស់ភាសាឱ្យបានត្រឹមត្រូវសមរម្យនិងទន់ភ្លន់។ សមាសភាគទីមួយគឺសមត្ថភាពវេយ្យាករណ៍ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យនិងរចនាសម្ព័ន្ធត្រឹមត្រូវ។ ការផ្តោតអារម្មណ៍ទៅលើសមត្ថភាពវេយ្យាករណ៍តែមួយផ្នែកនោះ វានឹងមិនផ្តល់ឱ្យអ្នកសិក្សានូវសមត្ថភាពបកប្រែឬបង្កើតកន្សោមពាក្យភាសាទី២ បានត្រឹមត្រូវនោះទេ។

សមត្ថភាពប្រើប្រាស់ភាសាសមស្រប គឺជាសមាសភាគទី២ ដែលគេហៅថាសមត្ថភាពសង្គមភាសាវិទ្យា។ វាអាចឱ្យអ្នកសិក្សាដឹងថា ពេលណាត្រូវនិយាយថា *Can I have some water?* ធៀបនឹង *Give me some water!* នេះបើយោងតាមបរិបទសង្គម។ អ្វីដែលត្រូវបានបកស្រាយជាច្រើនក្នុងវាក្យសព្ទការណ៍វិទ្យា ត្រូវតែស្គាល់ច្បាស់នៅក្នុងបរិបទវប្បធម៌នៃភាសាទី២ ប្រសិនបើអ្នកសិក្សាចង់អភិវឌ្ឍសមត្ថភាពសង្គមភាសាវិទ្យា។

សមាសភាគទីបី គឺសមត្ថភាពយុទ្ធសាស្ត្រ។ នេះគឺជាសមត្ថភាពក្នុងការរៀបចំសារមួយដែលប្រកបដោយប្រសិទ្ធភាពនិងសងតាមរយៈយុទ្ធសាស្ត្រផ្សេងៗ សម្រាប់ភាពលំបាកណាមួយ។ ក្នុងការប្រើប្រាស់ភាសាទី២ អ្នកសិក្សាជួបប្រទះដោយចៀសមិនផុត នៅពេលមានគម្លាតគ្នារវាងបំណងប្រាស្រ័យទាក់ទងនិងសមត្ថភាពក្នុងការបង្ហាញបំណងនោះ។ អ្នកសិក្សាខ្លះអាចឈប់និយាយ (គំនិតអាក្រក់) រីឯអ្នកផ្សេងទៀតនឹងព្យាយាមបញ្ចេញមតិដោយប្រើយុទ្ធសាស្ត្រទំនាក់ទំនង (គំនិតល្អ)។ ឧទាហរណ៍ អ្នកនិយាយភាសាហូឡង់ជាភាសាទី១ ចង់សំដៅទៅលើ *een hoefijzer* ជាភាសាអង់គ្លេស ប៉ុន្តែមិនស្គាល់ពាក្យអង់គ្លេសទេ។ ដូច្នេះហើយ នាងបានប្រើយុទ្ធសាស្ត្រទំនាក់ទំនង។ នាងបានបង្កើតវិធីដើម្បីយោងទៅវត្ថុមួយដោយប្រើវាក្យសព្ទដែលនាងដឹងរួចទៅហើយ ដោយនិយាយថា *the things that horses wear under their feet, the iron things* (អ្វីដែលសេះពាក់នៅក្រោមជើងរបស់ពួកគេវត្ថុដែក) ហើយនិងអ្នកស្តាប់បានយល់ភ្លាមៗអំពីអ្វីដែលនាងចង់និយាយ *horseshoes* (ដែកក្រចកជើងសេះ)។ ភាពបទបែននៃការប្រើប្រាស់ភាសាទី២នេះ គឺជាគន្លឹះមូលដ្ឋានមួយដែលទទួលបានភាពជោគជ័យក្នុងការប្រាស្រ័យទាក់ទង។ ជារួម សមត្ថភាពយុទ្ធសាស្ត្រគឺជាសមត្ថភាពមួយដើម្បីយកឈ្នះបញ្ហាទំនាក់ទំនងដែលមានសក្តានុពលក្នុងអន្តរកម្ម។

## ៣. ភាពផ្សេងគ្នារវាងការអានរបស់អ្នកសិក្សាភាសាទី១និងភាសាទី២

នៅក្នុងករណីជាច្រើន ដែលបង្ហាញថា ភាពខុសគ្នារវាងបរិបទនៃការអានរបស់ភាសាទី១និងភាសាទី២គឺជាបញ្ហាទាក់ទងនឹងកម្រិតសមត្ថភាពរបស់អ្នកសិក្សាទាំងអស់ ក៏ប៉ុន្តែនៅក្នុងករណីខ្លះ គឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាងការអានរបស់អ្នកសិក្សាភាសាទី១និងភាសាទី២ដែលប្រការនេះបានធ្វើឱ្យលេចឡើងជាសំណួរជាច្រើនសម្រាប់អ្នកសិក្សាស្រាវជ្រាវ។ ភាពផ្សេងគ្នាធំរវាងការអានរបស់អ្នកសិក្សាភាសាទី១និងភាសាទី២ គឺត្រូវបានគេចែកជាបីក្រុម ដាច់ដោយឡែកពីគ្នាគឺៈ

ទី១ ភាសានិងដំណើរការផ្សេងៗគ្នា

ទី២ ភាពផ្សេងគ្នានូវបទពិសោធនិងភាពឯកជន

ទី៣ ភាពខុសគ្នាដោយផ្អែកលើវប្បធម៌សង្គមឬស្ថាប័ន។

ភាពខុសគ្នាទាំងបីចំណុចខាងលើនេះ គឺអាស្រ័យលើសារៈសំខាន់ក្នុងការយល់ដឹងនៃធម្មជាតិ និងការវិវត្តក្នុងការអានរបស់ភាសាទី២។ ខាងក្រោមនេះ ជាការបង្ហាញពីភាពខុសគ្នារវាងចំណុចទាំងបីខាងលើរវាងភាសាទី១និងភាសាទី២។

### ៣.១. ភាសានិងដំណើរការផ្សេងៗគ្នា

ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានបង្ហាញពីភាពខុសគ្នាសំខាន់ៗ រវាងអ្នកអានភាសាទី១និងអ្នកអានភាសាទី២ លើចំណុចចំនួនប្រាំពីរ គឺវាក្យសព្ទ វេយ្យាករណ៍ ការនិយាយស្ដី អក្ខរាវិរុទ្ធ មេតាភាសា (meta-linguistic[7]) និងមេតាពុទ្ធិ(meta-cognitive[8]) ព្រមទាំងបញ្ហាភាសា និងដំណើរការជាប់គ្នា។ នៅក្នុងភាពខុសគ្នាទាំងនេះ ពិតជាបានបង្ហាញពីទិដ្ឋភាពភាគច្រើន ដល់អ្នកសិក្សាយ៉ាងទូលំទូលាយ ទាំងការអាននិងការអភិវឌ្ឍ សម្រាប់ការស្រាវជ្រាវមួយដែលអាចជួយយើងឱ្យយល់ពីភាពខុសគ្នាផ្សេងៗ ព្រមទាំងផលប៉ះពាល់ដែលអាចធ្វើបាននៅក្នុងសមត្ថភាពនៃការអានដ៏ទូលំទូលាយ។ ខាងក្រោមនេះគឺជាចំណុចទាំងប្រាំពីរៈ

#### ក. ចំណេះដឹងខុសគ្នានៃការស្គាល់ពាក្យ វេយ្យាករណ៍ និងការប្រើពាក្យសម្ដី

ភាពខុសគ្នាទីមួយ គឺសិស្សភាសាទី១ ភាគច្រើន បានរៀនអានភាសាដើមរបស់ពួកគេនៅពេលដែលគេមានអាយុពីបួនទៅប្រាំមួយឆ្នាំ។ ក្រុមប្រភេទនេះ បានរៀនភាគច្រើនបំផុតនូវរចនាសម្ព័ន្ធវេយ្យាករណ៍មូលដ្ឋាន នៃភាសាដើមរបស់ពួកគេ ដូចជា ចំណេះដឹងដែលមាននៅក្នុងប្រព័ន្ធខួរក្បាល នៃការប្រើប្រាស់ពាក្យពេចន៍ជាដើម។ លើសពីនេះទៅទៀត ក្រៅពីការសិក្សារចនាសម្ព័ន្ធនៃភាសា ដែលប្រើជាទូទៅសម្រាប់សរសេរនៅក្នុងអត្ថបទទាំងអស់នេះ ត្រូវបានអ្នកសិក្សាភាសាទី១ បន្តអនុវត្តជាទៀងទាត់រហូតដល់គេមានអាយុដប់ពីរឆ្នាំ ប៉ុន្តែភាគច្រើននៃរចនាសម្ព័ន្ធជាមូលដ្ឋាន គឺត្រូវបានរៀនតាំងពីដើមមក (តាំងពីមុនអាយុបួនឆ្នាំ) រួចទៅហើយ ផងដែរ។ ការប៉ាន់ស្មាននៃចំណេះដឹងវាក្យសព្ទរបស់កុមារដែលមានអាយុប្រាំមួយឆ្នាំ គឺមានចំនួនខុសគ្នាមិនថា តែភាសាទី១ឬភាសាទី២នោះទេ ប៉ុន្តែជាទូទៅអ្នកស្រាវជ្រាវបានឯកភាពគ្នាថា ចំណេះដឹងនៃពាក្យដែលកុមារមានអាយុកម្រិតនេះ គឺអាចមានចាប់ពី ៥000 ទៅ ៧000 ពាក្យ។

ប្រការនេះ គឺជាចំណុចពិសេសរបស់អ្នកសិក្សាភាសាទី១ ដែលប្រសើរជាងអ្នកសិក្សាភាសាទី២ជាច្រើនទៀត ដែលពួកគេត្រូវចាប់ផ្ដើមអានប្រយោគសាមញ្ញៗ តាំងពីចាប់ផ្ដើមរៀនទៅ។ សិស្សភាសាទី២ដទៃទៀត

[7] Metalinguistic គឺជាមែកធាងមួយនៃភាសាវិទ្យាដែលសិក្សាអំពីភាសាហើយនិងទំនាក់ទំនងភាសាទៅនឹងឥរិយាបថវប្បធម៌។ វាក៏មានន័យថាការយកភាសាទៅពន្យល់ភាសាខ្លួនវា ឬភាសាដទៃ។

[8] Metacognitive គឺដំណើរការយល់ដឹងគំនិតផ្ទាល់ខ្លួនរបស់នរណាម្នាក់ហើយនិងការយល់ដឹងពីគំរូដែលនៅពីក្រោយពុទ្ធិនេះ។

ជាពិសេស នៅក្នុងវគ្គបណ្តុះបណ្តាលការអាន មិនត្រូវបានរំពឹងថា នឹងកើនឡើងនូវសមត្ថភាពយល់ដឹងនូវចំណេះផ្សេងៗចំពោះពួកគេទេ ព្រោះថារាល់ព័ត៌មានដែលផ្ទុកនៅក្នុងអត្ថបទដែលគេអានភាគច្រើន គេបានដឹងរួចទៅហើយ តាមរយៈការរស់នៅក្នុងសង្គមដែលប្រើប្រាស់ភាសាកំណើតរបស់គេមកម្ល៉េះ។ ការខ្វះចំណេះដឹងគន្លឹះវេយ្យាករណ៍ និងចំណេះដឹងនៃការនិយាយស្តីរបស់ភាសាទី២នេះ ក៏បានបង្ហាញថាសិស្សប្រភេទភាសាទី២ ត្រូវការមូលដ្ឋានគ្រឹះមួយចំនួននៃចំណេះដឹងក្នុងការបង្កើតរចនាសម្ព័ន្ធឃ្លា និងអត្ថបទក្នុងភាសាទី២ សម្រាប់ពង្រឹងការអានឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពទូលំទូលាយបន្ថែមទៀត។

**ខ. ការលើកកម្ពស់អំពីការយល់ដឹងមេតាពុទ្ធិ និងមេតាភាសា**

ក្នុងករណីដែលសិស្ស អាចលើកកម្ពស់ការយល់ដឹងអំពីមេតាភាសា (Metalinguistic awareness) គឺសំដៅទៅលើការយល់ថា ភាសាគឺជាប្រព័ន្ធមួយនៃទំនាក់ទំនងក្បួនភាសា និងជាទម្រង់មូលដ្ឋានសម្រាប់សមត្ថភាពក្នុងការវិភាគពីផ្សេងគ្នានៃការប្រើប្រាស់ភាសា គឺអាចជួយឱ្យពួកគេមានភាពងាយស្រួលច្រើនក្នុងការអានអត្ថបទ។ ការចូលរួមកាន់តែច្រើនក្នុងការវិភាគមេតាភាសានិងត្រួតពិនិត្យពីដំណើរការ ដែលអាចធ្វើឱ្យយើងមានភារកិច្ច និងភាពលំបាកកាន់តែច្រើន ប៉ុន្តែលទ្ធផលនៃការយល់ដឹងអំពីមេតាភាសាគឺអាចជួយឱ្យអ្នកសិក្សាភាសាទី២ យល់ដឹងពីប្រព័ន្ធមួយនៃទំនាក់ទំនងក្បួនភាសានិងទម្រង់មូលដ្ឋាន សម្រាប់សមត្ថភាពក្នុងការវិភាគពីផ្សេងគ្នានៃការប្រើប្រាស់ភាសា បានកាន់តែច្រើនឡើងថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ មិនមានការកំណត់ជាក់លាក់ណាមួយ ក្នុងការអភិវឌ្ឍនៃដំណើរការទាំងនេះ ដើម្បីជាសញ្ញាអាចឱ្យអ្នកសិក្សាអាចអនុវត្តវិធីមេតាភាសា បាននោះឡើយ ហើយវានឹងនាំការផ្លាស់ប្តូរបន្តិចម្តងៗដល់អ្នកសិក្សាអាចចូលទៅក្នុងដែននៃការយល់ដឹងភាសាមួយបានជាក់ជាមិនខាន។ ចំណេះដឹងអំពីមេតាពុទ្ធិ គឺចំណេះដឹងអ្វីមួយដែលយើងបានដឹង។ ការមានចំណេះដឹងផ្នែកនេះ គឺអាចឱ្យអ្នកសិក្សាភាសាទី២ អាចឆ្លុះបញ្ចាំងលើការធ្វើផែនការ ការកំណត់គោលដៅ ដំណើរការភារកិច្ច និងអាចវិភាគនិងដោះស្រាយបញ្ហាបាន។ នេះ គឺជាការបង្ហាញជាលក្ខណៈមូលដ្ឋានពីលក្ខណៈនៃវិធីសាស្ត្រនៃការសិក្សា ហើយជាពិសេសគឺការរំពឹងក្នុងការប្រើប្រាស់សមត្ថភាពនៃការអានរបស់ភាសាទី២តែប៉ុណ្ណោះ។

**គ. ភាពខុសគ្នាក្នុងចំណោមការដាក់ឱ្យត្រូវ**

ភាពខុសគ្នារវាងស្ថានភាពនៃការអានរបស់ភាសាទី១និងភាសាទី២ គឺមានសារៈសំខាន់ណាស់សម្រាប់យើង ដែលស្ថិតក្នុងមជ្ឈដ្ឋានសិក្សាអប់រំ ព្រោះយើងត្រូវដឹងថា អ្នកសិក្សាភាសាទី១ បានចំណាយពេលជាច្រើនឆ្នាំ ដើម្បីកសាងនូវបទពិសោធនិងភាពស្ទាត់ជំនាញលើការប្រើប្រាស់នូវភាសាឱ្យមានភាពស្វ័យប្រវត្តិរបស់ខ្លួន ឯភាសាទី២វិញ គឺត្រូវទាមទារឱ្យមានការព្យាយាមខ្ពស់ ដើម្បីឈានទៅចាប់យកកម្រិតឱ្យបានស្មើនឹងភាសាទី១។ សរុបមកវិញ គឺភាសាទី១ បានចំណាយពេលតិចជាងភាសាទី២ ក្នុងការសិក្សាភាសា។

**ឃ. ភាពខុសគ្នាក្នុងចំណោមភាសាពីរ**

ភាពខុសគ្នារវាងភាសាណាមួយជាពីរភាសា គឺទំនងជាមានភាពប្រែប្រួលមួយគួរឱ្យកត់សម្គាល់ ហើយថែមទាំងមានភាពខុសគ្នាទៀតផង ដែលប្រការទាំងនេះ អាចមានឥទ្ធិពលដ៏ទូលំទូលាយ ដល់សិស្សដែលជាអ្នកសិក្សាភាសាទី២ នៅពេលដែលក្នុងថ្នាក់សិក្សាភាសាទី២ មានអ្នកសិក្សាភាសាទី១ច្រើន។

**ង. ខុសប្លែកគ្នារវាងសមត្ថភាពផ្នែកភាសាទី១ ជាមូលដ្ឋានសម្រាប់ភាសាទី២**

ការវាស់ស្ទង់សមត្ថភាពរបស់ភាសាទី២ គឺជាផ្នែកមួយដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ជាមូលដ្ឋានគ្រឹះសម្រាប់ការអានរបស់ភាសាទី២។ សម្មតិកម្មនៃកម្រិតភាសា គឺបានអះអាងថា សិស្សត្រូវតែមានចំណេះដឹងផ្នែកភាសាទី២ ឱ្យបានគ្រប់គ្រាន់ ដើម្បីធ្វើឱ្យប្រសិទ្ធភាពក្នុងការប្រើប្រាស់នូវជំនាញ ដែលជាផ្នែកមួយនៃសមត្ថភាពក្នុងការយល់ដឹងរបស់ភាសាទី១។

**ច. ភាពខុសប្លែកគ្នារវាងឥទ្ធិពលនៃការចែករំលែកចំណេះដឹងផ្នែកភាសា**

បញ្ហាដំបូង នៅក្នុងការពិភាក្សាអំពីការផ្លាស់ប្តូរនូវចំណេះដឹងភាសា ជួនកាលអាចជួយផ្ទេរចំណេះដឹងពីភាសាទី១ ទៅភាសាទី២ ដើម្បីឱ្យភាសាទី២ អាចមានការយល់ដឹងកាន់តែច្រើន ប៉ុន្តែចំណេះដឹងទាំងនោះក៏អាចបង្កផលរំខានផងដែរ សម្រាប់អ្នកសិក្សាភាសាទី២។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ចំណេះដឹងពីភាសាទី១ទៅភាសាទី២ អាចដំណើរការបានល្អប្រសើរតែក្នុងកម្រិតសិក្សាដំបូងនិងកម្រិតសិក្សាមធ្យមតែប៉ុណ្ណោះ។

**ឆ. ឥទ្ធិពលអន្តរកម្ម លើការសិក្សាភាសាពីរ**

បញ្ហានៃការសិក្សាភាសាពីរនៅក្នុងពេលតែមួយ ក៏បង្ហាញផងដែរនូវកត្តាដែលមិនមែនជាការសិក្សាភាសាដែលអាចបែងចែកភាសាទី១និងភាសាទី២ថាយ៉ាងណានោះទេ។ ដូច្នេះ មិនមានភាពងាយស្រួលទេ ក្នុងការដែលរៀនភាសាពីរក្នុងពេលតែមួយសម្រាប់ភាសាទី២ បើប្រៀបធៀបជាមួយភាសាទី១។

**៣.២. ភាពខុសគ្នារវាងកត្តាបុគ្គលនិងបទពិសោធនៃអ្នកអាន L1 និងអ្នកអាន L2**

**ក. កម្រិតខុសគ្នានៃសមត្ថភាពនៃការអានរបស់ភាសាទី១និងភាសាទី២**

អ្វីដែលជាភាពសំខាន់រវាងការអានរបស់ភាសាទី២ គឺអាស្រ័យទៅលើឥទ្ធិពលកម្រិតនៃការអានរបស់ភាសាទី១។ បើកាលណាអ្នកសិក្សាភាសាទី១ មិនមានសមត្ថភាពយល់ដឹងច្រើនពីភាសារបស់គេ គឺគេមិនអាចចែករំលែកចំណេះដឹងរបស់ខ្លួនទៅដល់អ្នកសិក្សាភាសាទី២ទេ ព្រោះគេមិនមានមូលដ្ឋានចំណេះដឹងទាក់ទងនឹងសង្គមដែលគេរស់នៅសម្រាប់ចែករំលែកដល់អ្នកសិក្សានៅក្នុងថ្នាក់ជាមួយគ្នាឡើយ។

**ខ. ភាពខុសគ្នាក្នុងការជំរុញទឹកចិត្ត ក្នុងការអានរបស់ភាសាទី២**

នៅពេលយើងធ្វើការប្រៀបធៀបបរិបទនៃការអានរបស់ភាសាទី១និងភាសាទី២ គឺយើងតែងតែមើលឃើញភាពខុសគ្នាក្នុងការជំរុញទឹកចិត្តក្នុងការអាន គឺភាគច្រើនអាស្រ័យទៅលើសមត្ថភាពនិងការព្យាយាមអានរបស់សិស្ស។ ប៉ុន្តែ អ្នកសិក្សាភាសាទី១ តែងតែអាចអានអត្ថបទបានប្រសើរជាងភាសាទី២ មិនខាន។

**គ. ប្រភេទផ្សេងៗនៃអត្ថបទសម្រាប់អ្នកអានភាសាទី២**

ជាបទពិសោធ អ្នកសិក្សាម្នាក់ៗមានកម្រិតនៃការអានអត្ថបទផ្សេងគ្នា បើនិយាយពីការអានរបស់ភាសាទី១និងភាសាទី២ ដែលអត្ថបទទាំងនោះ គឺជាធនធានបន្ថែមសម្រាប់ការអានឱ្យមានភាពទូលំទូលាយបន្ថែមទៀត។ ការអាននេះគឺជួយឱ្យអ្នកសិក្សាទាំងភាសាទី១និងភាសាទី២ អាចបង្កើននូវសមត្ថភាពនៃការយល់ដឹងនូវចំណេះដឹងថ្មីៗ តាមរយៈអត្ថបទនៃភាសាដែលគេបានអាន។

**ឃ. ប្រភពធនធានភាសាផ្សេងៗ សម្រាប់អ្នកអានភាសាទី២**

ចំណុចសំខាន់រួមនៃភាពខុសគ្នា គឺឋិតនៅលើការប្រើប្រាស់វចនានុក្រមដែលមានពីរភាសា ដែលរួមមានការពន្យល់ ការបកប្រែ និងការពន្យល់ពីប្រភពនៃពាក្យ ក្នុងបរិបទប្រើប្រាស់ពាក្យនៅក្នុងអត្ថន័យរបស់អ្នកអានភាសាទី២ ដែលវាមិនមាននៅក្នុងបរិបទរបស់អ្នកអានភាសាទី១។ អ្នកសិក្សាភាសាទី២ អាចយកបរិបទវប្បធម៌របស់អ្នកអានភាសាទី១ មកគ្រាន់តែជាប្រភពអត្ថបទសម្រាប់ការអានរបស់គេតែប៉ុណ្ណោះ ផ្ទុយពីអ្នកអានភាសាទី១ ដែលពួកគេមានអ្វីៗទាំងនេះ តាំងពីកំណើតរបស់ពួកគេមកម្ល៉េះ។

**៣.៣. ភាពខុសគ្នារវាងកត្តាសង្គមវប្បធម៌និងស្ថាប័នផ្សេងៗ ដែលជះឥទ្ធិពលលើការអភិវឌ្ឍការអានរបស់ភាសាទី១និងភាសាទី២**

ការអភិវឌ្ឍនៃការអានរបស់អ្នកសិក្សាទាំងភាសាទី១និងទាំងភាសាទី២ គឺអាចមានឥទ្ធិពលយ៉ាងខ្លាំងពីសំណាក់ឪពុកម្តាយ។ ឪពុកម្តាយ គឺជាអ្នកបង្ហាញនូវវិធីសាស្ត្រ/វិធីសាបទនៃការអាននិងការសរសេររបស់ពួកគាត់ទៅដល់កូនៗ ដែលឋិតនៅក្នុងបន្ទុកជាមួយគ្នា។ ទាំងនេះមានចំណុចបីដែលសំខាន់នៅក្នុងចំណុចនេះ៖

**ក. ទី១ ភាពខុសគ្នារវាងប្រភេទសង្គមវប្បធម៌របស់អ្នកអានភាសាទី២**

ភាពខុសគ្នាសំខាន់រវាងភាសាទី១និងភាសាទី២ គឺត្រូវបានបែងចែក ប៉ុន្តែភាគច្រើនអ្នកសិក្សាភាសាទី២ តែងនាំទៅជាមួយនូវវប្បធម៌នៃសង្គមរបស់គេ ទៅចែកចាយឬប្រើប្រាស់នៅក្នុងថ្នាក់រៀនដែលមានអ្នកសិក្សាភាសាទី១ នៅលាយឡំជាមួយគ្នាដែរ។

**ខ. ទី២ ភាពខុសគ្នារវាងការរៀបចំអត្ថបទនិងដំណើរការនៃការនិយាយ**

ចំណុចដែលទាក់ទងទៅនឹងការរៀបចំ គឺថាអាចមានឥទ្ធិពលដ៏ទូលំទូលាយ ក្នុងការអានរបស់ភាសាទី២ រួមបញ្ចូលទាំងភាពខុសគ្នានៅក្នុងវិធី ដែលអត្ថបទនោះបង្ហាញពីទំនាក់ទំនង និងភាពជិតជិតនៃវប្បធម៌របស់គេ ជាមួយនឹងភាសាដែលគេប្រើប្រាស់ចំពោះអ្នកអាន។ ការរំពឹងទុកអំពីបរិមាណនៃព័ត៌មានថ្មីៗដែលត្រូវបានបង្កប់នៅក្នុងអត្ថបទណាមួយ។

ការសន្មតអំពីភាពប្រាកដប្រជារបស់អ្នកបកប្រែសម្រាប់កម្មវិធីអំណានភាសា គួរតែត្រូវបានដឹកនាំឱ្យបានច្បាស់លាស់ ព្រោះថាការបកប្រែភាសាពីអត្ថបទភាសាមួយទៅអត្ថបទភាសាមួយទៀត គឺទាមទារឱ្យមានការពិនិត្យពិច័យឱ្យបានច្បាស់លាស់ មុននឹងដាក់ឱ្យអ្នកសិក្សារៀន បើមិនដូច្នោះទេ អត្ថបទសិក្សាដែលមិនបានគ្រប់គ្រងត្រឹមត្រូវតាមកម្រិតអ្នកអានឬអ្នកសិក្សា នឹងបង្កជាបញ្ហាមិនខាន។

**គ. ទី៣ ភាពខុសគ្នាពីការរំពឹងទុក នៃស្ថាប័នអប់រំរបស់អ្នកអានភាសាទី២**

ភាពខុសគ្នារវាងការអានរបស់ភាសាទី១និងភាសាទី២ គឺត្រូវបានតម្រែតម្រង់ដោយអាកប្បកិរិយាផ្សេងៗគ្នា ប្រភេទផ្សេងគ្នា និងការរំពឹងទុកការរចនាសម្ព័ន្ធអប់រំរបស់អ្នកអានភាសាទី១និងភាសាទី២។ អ្នកអានភាសាទី២ បានតម្រែតម្រង់ពីចំណេះដឹងនិងទង្វើផ្សេងៗ ពីបទពិសោធស្ថាប័នសិក្សារបស់អ្នកអានភាសាទី១ដែលអានតម្រង់ទិសផ្ទុយពីស្ថាប័នរបស់ភាសាទី២ ដែលបានកំណត់ទៅតាមផ្នត់គំនិតរបស់គេ។

តាមរយៈការសិក្សានិងរៀបរាប់ពីភាពខុសគ្នារវាងអ្នកអានភាសាទី១និងភាសាទី២ កន្លងមកនេះ ឃើញថា ភាពខុសគ្នាសំខាន់ៗ រវាងអ្នកអានភាសាទី១និងអ្នកអានភាសាទី២ គឺឋិតនៅលើចំណុចចំនួនប្រាំពីរ គឺវាក្យសព្ទ វេយ្យាករណ៍ ការនិយាយស្ដី អក្ខរាវិរុទ្ធ មេតាភាសា និងមេតាពុទ្ធិ ព្រមទាំងបញ្ហាភាសានិងដំណើរការជាប់គ្នា។ ក្រៅពីនេះ គឺនៅមានការពាក់ព័ន្ធទៅនឹងសមត្ថភាពចំណេះដឹងដែលអ្នកសិក្សាបានទទួលពីមជ្ឈដ្ឋានដែលគេរស់នៅ។ ក្នុងនោះឪពុកម្ដាយ សង្គមបរិយាកាសនៃថ្នាក់សិក្សារបស់ពួកគេក៏ជាកត្តាជំរុញឱ្យការសិក្សានិងការអានរបស់អ្នកអានភាសាទី១និងអ្នកអានភាសាទី២ មានភាពមិនដូចគ្នាដែរ។ បន្ថែមលើសពីនេះទៅទៀត គឺការជំរុញលើកទឹកចិត្តដល់អ្នកអានឱ្យមានចិត្តក្នុងការអានរបស់ខ្លួន ហើយអ្នកដែលអាចជួយបានរួមមានគ្រួសារ មិត្តភក្ដិ ឬថ្នាក់គ្រប់គ្រងសាលាជាដើម។ ទោះបីជាអ្នកអានឬអ្នកសិក្សាទាំងឡាយបានទទួលនូវការលើកទឹកចិត្តនិងការឧបត្ថម្ភពីសំណាក់អ្នកខាងក្រៅខ្លួនយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចទទួលបានផលដដែល ប្រសិនណាបុគ្គលដែលជាអ្នកសិក្សាខ្លួនឯងមិនបានខិតខំព្យាយាមសិក្សា ដោយខ្លួនឯងនោះ។

ដូច្នេះ ដើម្បីជំរុញឱ្យការអានរបស់អ្នកសិក្សាទាំងភាសាទី១និងភាសាទី២ មានការរីកចម្រើន គឺទាមទារឱ្យមានការជួយជំរុញនិងបង្ហាត់បង្ហាញពីសំណាក់អ្នកជុំវិញខ្លួន ប៉ុន្តែបើសិនចង់បានលទ្ធផលកាន់តែប្រសើរ គឺបុគ្គលសិក្សាផ្ទាល់ត្រូវតែខិតខំសិក្សាព្យាយាមដោយខ្លួនឯង ទើបជាប្រការប្រសើរ។

## សំណួរ

១. តើការចាប់យកភាសាទី១ជាអ្វី?

២. ចូរបង្ហាញពីទិដ្ឋភាពទូទៅនៃការចាប់យកភាសាទី១?

៣. តាមរយៈវេយ្យាករណ៍សកល តើគេយល់ឃើញបែបណាចំពោះការចាប់យកភាសាទី១?

៤. ចូរបង្ហាញពីលក្ខណៈធម្មជាតិរបស់កុមារនិងការចាប់យកភាសា។
៥. តើធាតុចូលនៃការចាប់យកភាសារបស់កុមារមានអ្វីខ្លះ?
៦. ទស្សនៈមួយចំនួនលើកឡើងថា ក្មេងអភិវឌ្ឍចំណេះដឹងមួយចំនួនតាមការត្រាប់តាម។ តើទស្សនៈនេះមានលក្ខណៈសមហេតុផលដែរឬទេ? ចូរពន្យល់។
៧. តើដំណាក់កាលនៃការចាប់យកភាសារបស់កុមារមានលក្ខណៈដូចម្ដេចដែរ?
៨. ចូរពណ៌នាអំពីការថ្ងូរនិងកកែកកររបស់កុមារក្នុងការចាប់យកភាសា។
៩. តើដំណាក់កាលមួយពាក្យជាអ្វី? ចូរពន្យល់និងលើកឧទាហរណ៍។
១០. តើដំណាក់កាលពីរពាក្យ កុមារចេះនិយាយអ្វីខ្លះ?
១១. តើកុមារអាចផលិតពាក្យបានប្រហែលប៉ុន្មាននៅដំណាក់កាលពីរពាក្យ?
១២. ចូររៀបរាប់អំពីការចាប់យកភាសារបស់កុមារនៅដំណាក់កាលនៃសម្ដីសារទូរលេខ?
១៣. ចូរបង្ហាញពីដំណើរការនៃការចាប់យកភាសារបស់កុមារ។
១៤. ចូរបង្ហាញពីការអភិវឌ្ឍផ្នែករូបសព្ទវិទ្យារបស់កុមារឱ្យបានក្បោះក្បាយ។
១៥. តើកុមារអភិវឌ្ឍផ្នែកសម្ព័ន្ធវិទ្យានៅអាយុប៉ុន្មាន?
១៦. ចូរបង្ហាញពីការបង្កើតទម្រង់ល្បះសំណួររបស់កុមារ។
១៧. ចូរបង្ហាញពីការបង្កើតទម្រង់ល្បះបដិសេធរបស់កុមារ។
១៨. ចូរពណ៌នាអំពីការអភិវឌ្ឍផ្នែកន័យវិទ្យារបស់កុមារ។
១៩. តើការពង្រីកបន្ថែមន័យ (overextension) ជាអ្វី?
២០. តើការចាប់យកភាសាទី២ជាអ្វី?
២១. តើការចាប់យកភាសាទី២តាមធម្មជាតិនិងការរៀនមានលក្ខណៈខុសគ្នាដូចម្ដេច?
២២. តើការចាប់យកភាសាទី២មានឧបសគ្គអ្វីខ្លះ?
២៣. តើកត្តាអ្វីខ្លះដែលមានប្រសិទ្ធភាពដល់ការចាប់យកភាសាទី២?
២៤. តើគេមានវិធីសាស្ត្រអ្វីខ្លះដែលទាក់ទងនឹងការចាប់យកភាសាទី២ឱ្យមានប្រសិទ្ធភាព?
២៥. ក្នុងចំណោមវិធីសាស្ត្រទាំងនោះ តើវិធីសាស្ត្រមួយណាល្អជាងគេ? ព្រោះអ្វី?
២៦. ចូរពណ៌នាអំពីការផ្ដោតលើអ្នករៀនឱ្យបានក្បោះក្បាយ។
២៧. តើសមត្ថភាពបណ្ដូរទំនាក់ទំនងនៃភាសាផ្ដល់ផលអ្វីខ្លះដល់ការចាប់យកភាសាទី២?
២៨. ចូរបង្ហាញពីភាពខុសគ្នារវាងការអានរបស់អ្នកសិក្សាភាសាទី១និងភាសាទី២។
២៩. តើកត្តាសង្គមវប្បធម៌និងស្ថាប័នផ្សេងៗបានជះឥទ្ធិពលអ្វីខ្លះ ទៅលើការអភិវឌ្ឍការអានរបស់ភាសាទី១ និងភាសាទី២?

# សេចក្តីសង្ខេបសៀវភៅ

សៀវភៅ «**មូលដ្ឋានគ្រឹះភាសាវិទ្យា**» នេះ តាក់តែងឡើងសម្រាប់ជាឯកសារគោលនិងជាជំនួយសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រភាសាវិទ្យានៃដេប៉ាតឺម៉ង់ភាសាវិទ្យា។ នៅក្នុងសៀវភៅសិក្សាគោលនេះមានចំនួន៩ មេរៀន។ ក្នុងមេរៀនទី១ និយាយទាក់ទងនឹងសញ្ញាណទូទៅនៃភាសានិងភាសាវិទ្យា ដែលត្រូវបានចែកជាពីចំណុចធំៗទៀត គឺភាសានិងភាសាវិទ្យា។ ក្នុងមេរៀនទី២ និយាយអំពីប្រព័ន្ធសំណេរ ដែលរៀបរាប់ពីការកកើតឡើងនៃសំណេរដំបូងរបស់មនុស្សជាតិនិងការវិវត្តនៃប្រព័ន្ធសំណេរនេះ។ ក្នុងមេរៀនទី៣ និយាយអំពីសូរនិងប្រព័ន្ធសូរនៃភាសា (សូរវិទ្យានិងសទ្ទតាវិទ្យា) ដែលរៀបរាប់ពីការបញ្ចេញសំឡេងនៃភាសា ការចាត់ថ្នាក់អំពីប្រព័ន្ធស្រៈនិងព្យញ្ជនៈជាដើម។ ក្នុងមេរៀនទី៤ និយាយអំពីការបង្កើតពាក្យនិងរូបសព្ទវិទ្យា ដែលបរិយាយអំពីវិធីបង្កើតពាក្យនិងរចនាសម្ព័ន្ធរបស់ពាក្យនៅក្នុងភាសា។ ក្នុងមេរៀនទី៥ និយាយអំពីសម្ព័ន្ធវិទ្យា ដែលបរិយាយលម្អិតអំពីរចនាសម្ព័ន្ធនៃកន្សោមពាក្យនិងឃ្លា។ ក្នុងមេរៀនទី៦ និយាយអំពីន័យវិទ្យានិងការណ៍វិទ្យា ដែលរៀបរាប់ពីន័យរបស់ពាក្យ ឃ្លា និងល្បះ ព្រមទាំងន័យនៅក្នុងបរិបទនៃបម្រើបម្រាស់ភាសា។ ក្នុងមេរៀនទី៧ ការប្រែប្រួលនៃភាសា ដែលបរិយាយអំពីអម្បូរភាសា មូលហេតុនៃការផ្លាស់ប្តូរភាសាពីសម័យមួយទៅសម័យមួយទៀត។ ក្នុងមេរៀនទី៨ និយាយអំពីសង្គមភាសាវិទ្យា ដែលរៀបរាប់ពីការប្រើប្រាស់ភាសានៅក្នុងសង្គមទៅតាមវណ្ណៈ ក្រុម ពេលវេលា ទីកន្លែង និងតំបន់ផ្សេងៗ។ ចំណែកឯមេរៀនទី៩ និយាយអំពីការចាប់យកភាសា ដែលបរិយាយលម្អិតអំពីដំណើរការនៃការចាប់យកភាសាទី១ ការអភិវឌ្ឍភាសាទី១ ទៅតាមដំណាក់កាលរីកចម្រើនរបស់មនុស្ស និងការចាប់យកភាសាទី២។

# ឯកសារពិគ្រោះ

## I. ឯកសារភាសាខ្មែរ


កេង វ៉ាន់សាក់ (១៩៦៣) *កំណាព្យចិត្តក្រមុំ* ភ្នំពេញ។

កេង វ៉ាន់សាក់ (១៩៦៤) *មូលដ្ឋានគ្រឹះក្នុងការបង្កើតពាក្យថ្មី* ភ្នំពេញ។

កេង វ៉ាន់សាក់ (១៩៦៦) *វេយ្យាករណ៍ខ្មែរសង្ខេប ភាគទី១សូរសព្ទខ្មែរ* ភ្នំពេញ។

កែប វ៉ាន់ឌី (១៩៧១) *អរិយធម៌ខ្មែរ-មន* ភ្នំពេញ។

ក្រសួងអប់រំ (១៩៨២) *វេយ្យាករណ៍ថ្នាក់ទី៦* មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

ក្រសួងអប់រំ (១៩៨៦) *វេយ្យាករណ៍ថ្នាក់ទី៨* មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

ក្រសួងអប់រំ (១៩៨៣) *វេយ្យាករណ៍ថ្នាក់ទី៥* មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (២០១៣) *សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍ ខ្មែរ-បារាំង-អង់គ្លេស* រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ គណៈកម្មការភាសាវិទ្យា (២០១៨) *សៀវភៅវេយ្យាករណ៍ភាសាខ្មែរ* ភ្នំពេញ។

ខៀវ ជុំ (១៩៦២) *កម្ពុជវេយ្យាករណ៍* បណ្ណាគារត្រៃរតន៍ ភ្នំពេញ។

គេន រង្សី (២០១៥) *វចនសព្ទវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

គេន រង្សី (២០១៨) *វចនវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

គេន រង្សី (២០២០) *វចនវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឃឹន សុខ (២០០៧) *វេយ្យាករណ៍ភាសាខ្មែរ* ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា។

ឃួន សុខម្ភូ (១៩៧០) *ទំរង់សូរវិទ្យាខ្មែរ* ភ្នំពេញ។

ងួន សំអុល (២០០៩) *សម្ព័ន្ធវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យអង្គរខេមរា។

ចាន់ វឌ្ឍនា (២០១១) *សម្ព័ន្ធវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ចាន់ វឌ្ឍនា (២០១២) *វេយ្យាករណ៍ខ្មែរ* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ច័ន្ទ សំណព្វ (២០១០) *បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ* រាជបណ្ឌិត្យសភាកម្ពុជា។

ច័ន្ទ សំណព្វ (២០០៧) *ឯកសារបង្រៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឆាន់ គឹមសឿន (២០១៣) *សញ្ញាណទូទៅនិងទ្រឹស្តីនៃភាសាវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឆាន់ គឹមសឿន (២០១៦) *ភាសាវិទ្យាប្រៀបធៀប* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ។

ជួរ គារី (២០០៧) *វចនានុក្រមអត្ថាធិប្បាយ សទិសសព្ទ ពហុន័យសព្ទ* ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពដោយបណ្ណាគារអង្គរ។

ឌ. គាម (២០០០) *ការសិក្សាអំពីវិវត្តន៍នៃអក្សរខ្មែរ* ការផ្សាយរបស់បណ្ណាល័យអប្សរា។

នៅ ស៊ុន (២០១០) *លក្ខណៈភាសាខ្មែរ* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

នៅ ស៊ុន (?) *សញ្ញាណទូទៅនៃសូរវិទ្យានិងសទ្ទតាវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុងសេចក្តីព្រាង។

ប៉ិញ សឿន (២០១១) *ទ្រឹស្តីមូលដ្ឋាននៃភាសាវិទ្យាប្រៀបធៀប* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ប៊ុញ សឿន (២០១៤) *ឯកសារណែនាំអំពីភាសាវិទ្យាទូទៅ* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
ប៊ី សុខគង់ (២០០២) *ប្រភេទពាក្យក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ រាជបណ្ឌិត្យសភាកម្ពុជា។
ព្រុំ ម៉ល់ (២០០៣) *មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ* ភ្នំពេញ។
ព្រុំ ម៉ល់ (២០០៣) *មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា និងវិជ្ជាសន្ទាន* ភ្នំពេញ។
ព្រុំ ម៉ល់ (២០០៦) *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប* ភ្នំពេញ។
ព្រុំ ម៉ល់ (២០១២) *អំពីអក្សរខ្មែរ អក្ខរាវិរុទ្ធនៃភាសាខ្មែរ និង វចនានុក្រមខ្មែរ*។
ព្រុំ ម៉ល់ (២០១៣) *មូលដ្ឋាននៃសង្គមភាសាវិទ្យា* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ។
ភាសាសញ្ញាកម្ពុជា (២០០៨) *ភាសាសញ្ញាកម្ពុជា សៀវភៅសិស្សភាគ១* ភ្នំពេញ។
យៀង វីបុត្រ (២០០៦) *ការបង្កើតពាក្យក្នុងភាសាខ្មែរទំនើបតាមវិធីកំលាយ* សារណាបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា។
លី ធាមតេង (១៩៦០) *អក្សរសាស្ត្រខ្មែរ* ភ្នំពេញ។
វង្ស មេង (២០២០) *កម្រងសិក្សាភាសា វប្បធម៌ និងសង្គមខ្មែរ* ការផ្សាយរបស់អ្នកនិពន្ធ។
វចនានុក្រមខ្មែរ ភាគ១និងភាគ២ (១៩៦៧-១៩៦៨) ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ។
សុខ ឈន និងឆាន់ គឹមសឿន (២០១៣) *ន័យវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ។
សូ មុយឃៀង (២០០៤) *វេយ្យាករណ៍ ទំរង់ផ្នត់ដើមខ្មែរ ភាគ១និង២* ភ្នំពេញ។
សូ មុយឃៀង (២០០៤) *វេយ្យាករណ៍ ទំរង់ផ្នត់ដែកខ្មែរ ភាគ៣និង៤* ភ្នំពេញ។
សូ មុយឃៀង (២០១៦) *សម្ព័ន្ធវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
សួន ឱសថ (២០១៣) *និវេសន៍នៃវេយ្យាករណ៍ខ្មែរ* សាកលវិទ្យាល័យ អាស៊ីអឺរ៉ុប។
សំ អេងលាង (២០១០) *សង្គមភាសាវិទ្យា* ឯកសារបកប្រែ ប្រើប្រាស់ផ្ទៃក្នុង។
សំរិត សុទ្ធា, សុខ ឈន និងឆាន់ គឹមសឿន (២០២០) *សូរវិទ្យានិងសទ្ទតាវិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
ហ៊ាន សុខុម (១៩៩៨) *សទ្ទានុក្រមបច្ចេកសព្ទទំនើប* ខ្មែរលើដេ។
ហ៊ុន គឹមសៀ (១៩៦៣) *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* បណ្ណាគារភ្នំពេញ។
ហ្សង់ មីសែល ហ្វីលីពី (២០០៩) *ឯកសារណែនាំអំពីសូរវិទ្យា* បោះពុម្ពដោយហ្វូណាន ភ្នំពេញ។
ឡុង សៀម (២០០០) *ទំនាក់ទំនងភាសាមន-ខ្មែរជាមួយភាសាផ្សេងៗ* បកប្រែដោយ ប៊ី សុខគង់ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា។
ឡុង សៀម (១៩៩៩) *បញ្ហាវចនសព្ទវិទ្យាខ្មែរ* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
អ៊ុក ចួន (១៩៨៧) *វចនវិទ្យានិងវេយ្យាករណ៍វិទ្យា* ឯកសារប្រើប្រាស់ផ្ទៃក្នុង សាលាគរុវិជ្ជាជាន់ខ្ពស់។
អៀវ កើស (១៩៦៧) *ភាសាខ្មែរ សាកល្បងពិនិត្យរកហេតុផល* ភ្នំពេញ។
អ្នកស្រី ត្រឹងា (១៩៧៤) *អរិយធម៌ខ្មែរ* ភ្នំពេញ។

## II. ឯកសារភាសាបរទេស


Adrian Akmajian, Richard A. Demers, Ann K. Farmer & Robert M. Harnish. (2001). *Linguistics "An Introduction to Language and Communication".* Fifth edition, The MIT Press.

Alan Cruse. (2000). *Meaning in Language "An Introduction to Semantics and Pragmatics"*. Oxford University Press.

Brian D. Jeseph & Rechard D. Jenda (editor). (2003). *Handbook of Historical Linguistics*. Blackwell Publishing.

David Crystal. (2008). *A Dictionary of Linguistics and Phonetics*. Blackwell Publishing.

David Odden. (2005) *Introducing Phonology*. Cambridge University Press.

Ferdinand de Sausure. (1915). *Course in General Linguistics*. translated by Wade Baskin.

George Yule. (2010). *The Study of Language*. Third and fourth editions, Cambridge University Press.

Grover Hudson. (2000). *Essential Introductory Linguistics*. Blackwell Publishing.

John I. Saeed. (2009). *Semantics*. Wiley-Blackwell.

Michael Kenstowicz. (1994). *Phonology in Generative Grammar*. Blackwell.

Ralph Fasold & Jeff Connor-Linton. (2006). *An Introduction to Language and Linguistics*. Cambridge University Press.

Rochelle Lieber. (2009). *Introducing Morphology*. Cambridge University Press.

Simon & Schuster. (1992). *What Is Linguistics ?*. Singapore.

Suzette Haden Elgin. (1992). *What is Linguistics ?.* Second edition, Pearson College Div.

Victoria Fromkin, Robert Rodman & Nina Hyams. (2014). *An Introduction to Language*. Tenth edition, Wadsworth.

William O'Grady, Michael Dobrovolsky & Mark Aronoff. (1993). *Contemporary Linguistics (An Introduction).* University of New Yok.